

HUMAN
RIGHTS
WATCH

# ឧត្តមសេនីយ៍បាតដៃកខ្វក់ទាំង១២នាក់នៅកម្ពុជា

## ប្រវត្តិសាស្ត្រដ៏យូរអង្វែងនៃការរំលោភសិទ្ធិមនុស្សដោយឧត្តមសេនីយ៍របស់លោក ហ៊ុន សែន



# ឧត្តមសេនីយ៍បាតដៃកខ្វក់ទាំង១២នាក់នៅកម្ពុជា

ប្រវត្តិសាស្ត្រដ៏យូរអង្វែងនៃការរំលោភសិទ្ធិមនុស្ស
ដោយឧត្តមសេនីយ៍របស់លោក ហ៊ុន សែន

រក្សាសិទ្ធិ© ២០១៨
អង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែនរ៉ៃត៍វច្ឆ (Human Rights Watch)

បោះពុម្ពនៅសហរដ្ឋអាមេរិកលេខ
NSBN: 978-1-6231-36222
រចនាបទក្របសៀវភៅដោយរ៉ាហ្វែល ហ្ជីមិណេ (Rafael Jimenez)

អង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែនរ៉ៃត៍វច្ឆ (Human Rights Watch) ការពារសិទ្ធិមនុស្សជុំវិញពិភពលោក។ យើងស៊ើបអង្កេតយ៉ាងហ្មត់ចត់នូវការរំលោភសិទ្ធិមនុស្ស ហើយលាតត្រដាងកស្តុតាងរំលោភទាំងនោះយ៉ាងទូលំទូលាយ បន្ទាប់មកដាក់សម្ពាធលើអ្នកមានអំណាច ដើម្បីឲ្យគោរពសិទ្ធិមនុស្ស និងធានានូវយុត្តិធម៌។ អង្គការសិទ្ធិមនុស្ស យូមែនរ៉ៃត៍វច្ឆ ជាអង្គការអន្តរជាតិឯករាជមួយ បំពេញការងារជាចលនារស់រវើក ដើម្បីលើកស្ទួយភាពថ្លៃថ្នូររបស់មនុស្ស និងជ្រោមជ្រែងការពារបុព្វហេតុសិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់រូប។

អង្គការឃ្លាំមើលសិទ្ធិមនុស្សយូមែនរ៉ៃត៍វច្ឆ (Human Rights Watch) គឺជាអង្គការអន្តរជាតិ ដែលមានបុគ្គលិកនៅក្នុងប្រទេសចំនួនជាង ៤០ និងមានការិយាល័យនៅក្នុងទីក្រុងអាំស្ទែដាំ (Amsterdam) ទីក្រុងបេរូត (Beirute) ទីក្រុងប៊ែកឡាំង (Berlin) ទីក្រុងប្រ៊ុចសែល (Brussels) ទីក្រុងឈីកាហ្គោ (Chicago) ទីក្រុងហ្សឺណែវ (Geneva) ទីក្រុងហ្គោម៉ា (Goma) ទីក្រុងចូហានណេសប៊ឺក (Johannesburge) ទីក្រុងឡុងដ៍ (London) ទីក្រុងឡូសអាន់ចេឡេស (Los Angeles) ទីក្រុងម៉ូស្គូ (Moscow) ទីក្រុងណៃរ៉ូប៊ី (Nairobi) ទីក្រុងញូវយ៉ក (New York) ទីក្រុងប៉ារីស (Paris) ទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ (San Francisco) ទីក្រុងស៊ីដនី (Sydney) ទីក្រុងតូក្យូ (Tokyo) ទីក្រុងតូរ៉ូនតូ (Toronto) ទីក្រុងទូនីស (Tunis) ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី (Washington, DC) និងទីក្រុងហ្សូរីច (Zurich) ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅក្នុងគេហទំព័ររបស់យើង៖ http://www.hrw.org

ខែមិថុនា ឆ្នាំ២០១៨

ISBN:978-1-6231-36222

# ឧត្តមសេនីយ៍បាតដៃកខ្វក់ទាំង១២នាក់នៅកម្ពុជា

*ប្រវត្តិសាស្ត្រដ៏យូរអង្វែងនៃការរំលោភសិទ្ធិមនុស្សដោយឧត្តមសេនីយ៍របស់លោក ហ៊ុន សែន*

**ផែនទីប្រទេសកម្ពុជា** ........................................ x

**«របាយការណ៍សង្ខេប»** ........................................ 1

*បទរំលោភបំពាននានា នៅក្នុងសម័យខ្មែរក្រហម* ........................................ 7

*អំពើរំលោភបំពាន នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម័យរដ្ឋកម្ពុជា* ...... 7

*អំពើរំលោភបំពាននៅក្នុងអំឡុងសម័យ អ៊ុនតាក់ (UNTAC)* ........................................ 9

*ការរំលោភបំពានចាប់តាំងពីសម័យអ៊ុនតាក់ (ឆ្នាំ ១៩៩៣ រហូតមកដល់បច្ចុប្បន្ន)* ............ 10

*កំណែទម្រង់កងកម្លាំងសន្តិសុខ ដែលមាននិន្នាការនយោបាយ ពិតជាទៅមិនរួច* ............ 12

**វិធីសាស្ត្រ** ........................................ 15

**សាវតា** ........................................ 17

*កងកម្លាំងប្រដាប់អាវុធកម្ពុជាឆ្នាំ ១៩៧៨ ដល់បច្ចុប្បន្ន* ........................................ 17

*ការបះបោរប្រឆាំងប៉ុល ពត មុនខែមករា ឆ្នាំ ១៩៧៩* ........................................ 17

*ការបង្កើតកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា (RPAFK)* ........................................ 21

*កងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា បន្ទាប់ពីលោក ប៉ែន សុវណ្ណ* ........................................ 24

*កងទ័ពបដិវត្តន៍ប្រជាជនកម្ពុជាក្រោមលោក ហ៊ុន សែន*.....25
*កងកម្លាំងប្រដាប់អាវុធប្រជាជនកម្ពុជា រដ្ឋកម្ពុជា និងអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា* (អ៊ុនតាក់).....27
*កងកម្លាំងប្រដាប់អាវុធប្រជាជនកម្ពុជា ក្រោមសហនាយករដ្ឋមន្ត្រី*.....30
*កងយោធពលខេមរភូមិន្ទកម្ពុជា* (១៩៩៣-មកបច្ចុប្បន្ន).....31
*កងយោធពលខេមរភូមិន្ទ* (RCAF) *បច្ចុប្បន្ន*.....37
*ការត្រួតត្រាបន្ថែមរបស់គណបក្សប្រជាជនកម្ពុជាលើកងកម្លាំងប្រដាប់អាវុធ*.....39
*កងរាជអាវុធហត្ថខ្មែរ ទសវត្សរ៍ ១៩៨០ ដល់បច្ចុប្បន្ន*.....51
**នគរបាលកម្ពុជាឆ្នាំ ពី១៩៧៩ ដល់បច្ចុប្បន្ន**.....57
*ក្រសួងមហាផ្ទៃ និងនគរបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា* (PRK).....57
*អ៊ុនតាក់ ក្រសួងមហាផ្ទៃ និងប៉ូលីស*.....61
*១៩៩៣ ៖ ក្រសួងមហាផ្ទៃ និងនគរបាលនៃរាជរដ្ឋាភិបាលកម្ពុជា*.....64
*ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា និងនគរបាលបច្ចុប្បន្ន*.....69
I. **ឧត្តមសេនីយ៍ប៉ុល សារឿន មេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ**.....72
*ជាមួយខ្មែរក្រហម ឆ្នាំ១៩៦៨-១៩៧៨*.....72
*ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ១៩៧៩-១៩៩១*.....73
*ប៉ុល សារឿន និងអ៊ុនតាក់ឆ្នាំ១៩៩១-១៩៩៣*.....76
*ប៉ុល សារឿន និងភ្លាមៗក្រោយពេលអ៊ុនតាក់ ឆ្នាំ១៩៩៣-១៩៩៦*.....77
*នៅសម័យរដ្ឋប្រហារខែកក្កដា ឆ្នាំ១៩៩៧ របស់លោក ហ៊ុន សែន*.....81
*ប៉ុល សារឿន ជានាយសេនាធិការបន្ទាប់ពីរដ្ឋប្រហារ ឆ្នាំ១៩៩៧-២០០៩*.....83
*លោក ប៉ុល សារឿន ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ចាប់តាំងពីឆ្នាំ ២០០៩*.....84
II. **ឧត្តមសេនីយ៍គន់ គីម មេបញ្ជាការរងជាន់ខ្ពស់នៃកងយោធពល**.....90
**ខេមរភូមិន្ទ អគ្គបញ្ជាការចម្រុះនៃកងយោធពលខេមរភូមិន្ទ**.....90
*លោក គន់ គីម ជាមួយខ្មែរក្រហម ១៩៧០-១៩៧៨*.....90

*លោក គន់ គីម ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា* (PRK) *និងរដ្ឋកម្ពុជា* (SOC) *១៩៧៩-១៩៩១* ........ 91
*លោក គន់ គីម និងរដ្ឋាភិបាលចម្រុះក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣* ........ 93
*លោក គន់ គីម រដ្ឋប្រហារឆ្នាំ ១៩៩៧ និង ការបោះឆ្នោតឆ្នាំ ១៩៩៨* ........ 96
*លោក គន់ គីម ឆ្នាំ១៩៩៩-២០១២* ........ 102
*នៅក្នុងការបោះឆ្នោតឆ្នាំ ២០១៣ និងចាប់តាំងពីនោះមក* ........ 104
III. **ឧត្តមសេនីយ៍សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថជាតិ និងអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ** ........ 113
*លោក សៅ សុខា ក្នុងឆ្នាំ ១៩៧៧-១៩៧៨* ........ 113
*លោក សៅ សុខា និងសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា ១៩៧៩-១៩៩១* ........ 114
*លោក សៅ សុខា ក្នុងសម័យអ៊ុនតាក់ និងក្រោយអ៊ុនតាក់ ឆ្នាំ១៩៩១-១៩៩៦* ........ 117
*លោក សៅ សុខា និងរដ្ឋប្រហាររបស់លោក ហ៊ុន សែន ឆ្នាំ ១៩៩៧* ........ 118
*លោក សៅ សុខា និងការបោះឆ្នោតឆ្នាំ១៩៩៨* ........ 121
*លោក សៅ សុខា ១៩៩៩-២០០៨* ........ 122
*លោក សៅ សុខា ត្រូវបានឡើងសក្តិបន្ថែមទៀត ឆ្នាំ២០០៩-២០១២* ........ 127
*លោក សៅ សុខា ការបោះឆ្នោត ឆ្នាំ២០១៣ ព្រឹត្តិការណ៍ក្រោយការបោះឆ្នោត* ........ 131
*និងចាប់តាំងពីពេលនោះមក* ........ 131
IV. **នាយឧត្តមសេនីយ៍ផ្កាយមាស ៤ នេត សាវឿន អគ្គស្នងការនគរបាលជាតិ** ........ 142
*លោក នេត សាវឿន នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា ឆ្នាំ ១៩៧៩-១៩៩១* ........ 142
*លោក នេត សាវឿន និង អ៊ុនតាក់ ឆ្នាំ ១៩៩១ ដល់ឆ្នាំ ១៩៩៣* ........ 144
*លោក នេត សាវឿន ចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៧* ........ 145
*នេត សាវឿន ក្នុងពេលរដ្ឋប្រហាររបស់លោក ហ៊ុន សែន ឆ្នាំ១៩៩៧ និងការបោះឆ្នោតឆ្នាំ ១៩៩៨* ........ 146
*លោក នេត សាវឿន ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៨* ........ 148

*លោក នេត សាវឿន ក្នុងតួនាទីជាអគ្គស្នងការនគរបាលជាតិ ចាប់ពីឆ្នាំ២០០៨ មកទល់បច្ចុប្បន្ន* .......... 148
*លោក នេត សាវឿន ក្នុងពេលបោះឆ្នោតឆ្នាំ ២០១៣ និងចាប់ពីពេលនោះមក* .......... 151
V. **ឧត្តមសេនីយ៍ឯកផ្កាយមាស ៣ ជា ម៉ន មេបញ្ជាការរង កងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី ៤** .......... 158
*លោក ជា ម៉ន នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ពីឆ្នាំ ១៩៧៩ ដល់ ១៩៩១* .......... 158
*លោក ជា ម៉ន និង អ៊ុនតាក់ ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៣* .......... 159
*លោក ជា ម៉ន ចាប់ពីរដ្ឋាភិបាលចម្រុះ រហូតដល់ពេលរដ្ឋប្រហារ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ ១៩៩៧* .......... 161
*លោក ជា ម៉ន បន្ទាប់ពីរដ្ឋប្រហារ ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០១៣* .......... 163
*លោក ជា ម៉ន ក្នុងពេល និងក្រោយពេលបោះឆ្នោតឆ្នាំ ២០១៣* .......... 164
VI. **ឧត្តមសេនីយ៍ឯកផ្កាយមាស ៣ ប៊ុន សេង មេបញ្ជាការរងកងទ័ពជើង** .......... 167
**គោក និង ជាមេបញ្ជាការយោធភូមិភាគទី ៥** .......... 167
*លោក ប៊ុន សេង នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៩១* .......... 167
*លោក ប៊ុន សេង និង អ៊ុនតាក់ ចាប់ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ១៩៩៣* .......... 167
*លោក ប៊ុន សេង ក្នុងអំឡុងពេល និងក្រោយពេលបោះឆ្នោត ឆ្នាំ២០១៣* .......... 172
VII. **ឧត្តមសេនីយ៍ឯកផ្កាយមាស ៣ ជឿន សុវណ្ណថា មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី ២** .......... 174
VIII. **នាយឧត្តមសេនីយ៍ឯកផ្កាយមាស ៣ ចាប ភក្តី នាយរងសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ និង ជាមេបញ្ជាការកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១** .......... 181
*លោក ចាប ភក្តី ក្រោយសម័យអ៊ុនតាក់ ឆ្នាំ ១៩៩៣-១៩៩៧* .......... 181
*លោក ចាប ភក្តី និងរដ្ឋប្រហាររបស់លោក ហ៊ុន សែន នៅឆ្នាំ ១៩៩៧* .......... 182
*លោក ចាប ភក្តី ចាប់ពីឆ្នាំ១៩៩៧* .......... 185

*លោក ចាប ភក្តី ក្រោយពេលបោះឆ្នោតឆ្នាំ ២០១៣* ........ 186

IX. **ឧត្តមសេនីយ៍ឯកផ្កាយមាស ៣ រ័ត្ន ស្រ៊ាង មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និង ជាមេបញ្ជាការកងរាជអាវុធហត្ថ រាជធានីភ្នំពេញ** ........ 193

*លោក រ័ត្ន ស្រ៊ាង នៅខេត្តកណ្តាល និង ខេត្តបន្ទាយមានជ័យ ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ២០០៣* ........ 193

*លោក រ័ត្ន ស្រ៊ាង និងការបោះឆ្នោតឆ្នាំ២០១៣* ........ 195

*លោក រ័ត្ន ស្រ៊ាង ជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានី ពីខែកញ្ញា ឆ្នាំ២០១៣ -មករា ២០១៤* ........ 196

*លោក រ័ត្ន ស្រ៊ាង ជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ បន្ទាប់ពីខែមករា ឆ្នាំ ២០១៤* ........ 201

X. **នាយឧត្តមសេនីយ៍ផ្កាយមាស ៤ សុខ ផល អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍** ........ 205

*លោក សុខ ផល នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៩១* ........ 205

*លោក សុខ ផល និង អ៊ុនតាក់ ចាប់ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៣* ........ 207

*លោក សុខ ផល នៅក្រោមនាយកដ្ឋានកណ្តាលសន្តិសុខនៃរាជរដ្ឋាភិបាល ពីឆ្នាំ១៩៩៣-២០០៣* ........ 212

*លោក សុខ ផល ក្នុងតួនាទីជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០១៤* ........ 214

*សុខ ផល និងការបង្ក្រាបអ្នកសកម្មនិយមខ្មែរក្រោម និងអ្នកចែកខិតប័ណ្ណប្រឆាំងលោក ហ៊ុន សែន* ........ 215

*លោក សុខ ផល និងការបញ្ជូនជនជាតិអ៊ុយហ្គ័រ (Uighur)ដែលស្វែងរកសិទ្ធិជ្រកកោន ត្រលប់ទៅប្រទេសចិនវិញដោយបង្ខំ* ........ 217

*លោក សុខ ផល  ពេលបោះឆ្នោតជាតិឆ្នាំ ២០១៣ និង ចាប់តាំងពីធ្វើជាអគ្គនាយកអន្តោប្រវេសន៍* ........ 218

XI. **នាយឧត្តមសេនីយ៍ផ្កាយមាស៤ ម៉ក់ ជីតូ អគ្គស្នងការរងនគរបាលជាតិ** ........ 225

*លោក ម៉ក់ ជីតូ ក្រោយសម័យអ៊ុនតាក់ ចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០១២* ..................... 226
*ម៉ក់ ជីតូ ការបោះឆ្នោត ការបង្ក្រាបក្រោយការបោះឆ្នោត ខែកក្កដា ឆ្នាំ ២០១៣ និងពីពេលនោះមក* ..................... 230
XII. **នាយឧត្តមសេនីយ៍ផ្កាយមាស ៤ ជួន សុវណ្ណ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ** ..................... 235
*លោក ជួន សុវណ្ណ នៅខេត្តកណ្តាល ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ២០១០* ..................... 235
*លោក ជួន សុវណ្ណ ជាអគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ* ..................... 236
*លោក ជួន សុវណ្ណ និង ការបោះឆ្នោតឆ្នាំ ២០១៣* ..................... 241
*ជួន សុវណ្ណ ការបង្ក្រាបចលាចលក្រោយការបោះឆ្នោតពីឆ្នាំ ២០១៣-២០១៤ និងពីពេលនោះមក* ..................... 242
XIII. **ការទទួលស្គាល់របស់អង្គការសហប្រជាជាតិ ចំពោះសារសំខាន់នៃ** ..................... 254
**កំណែទម្រង់វិស័យសន្តិសុខ** ..................... 254
*មិនធ្វើតាមការសន្យា* ..................... 254
*បទដ្ឋានកំណែទម្រង់វិស័យសន្តិសុខរបស់អង្គការសហប្រជាជាតិ* ..................... 256
XIV. **អនុសាសន៍** ..................... 263
*រដ្ឋាភិបាលពាក់ព័ន្ធ ម្ចាស់ជំនួយកម្ពុជា អង្គការសហប្រជាជាតិ និងតួអង្គមានឥទ្ធិពលផ្សេងទៀត គួរតែ ៖* ..................... 265
*ចំពោះការចូលរួមប្រឡូកប៉ូកប៉ាក់ក្នុងឆាកនយោបាយរបស់កងកម្លាំងសន្តិសុខកម្ពុជាវិញ រដ្ឋាភិបាលពាក់ព័ន្ធនានា ម្ចាស់ជំនួយរបស់កម្ពុជា អង្គការសហប្រជាជាតិ និងតួអង្គ ដែលមានឥទ្ធិពលដទៃទៀត គួរតែ៖* ..................... 266
**សេចក្តីថ្លែងអំណរគុណ** ..................... 269

# ផែនទីប្រទេសកម្ពុជា




© Human Rights Watch

# «របាយការណ៍សង្ខេប»

*ក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រីហ៊ុនសែន សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាធ្លាក់ដាំក្បាលចុះ។ បើទោះកិច្ចព្រមសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ មានចែងយ៉ាងជាក់ច្បាស់នូវបទបញ្ញត្តិស្តីពីសិទ្ធិមនុស្ស និងជំនួយអភិវឌ្ឍន៍រាប់ពាន់លានដុល្លា ដែលក្នុងនោះបានចំណាយយ៉ាងសន្ធឹកសន្ធាប់ទៅលើផ្នែកបច្ចេកទេសលើកស្ទួយនីតិរដ្ឋ សិទ្ធិមនុស្ស និងកំណែទម្រង់ប្រព័ន្ធតុលាការក្តី កម្ពុជាកំពុងបោះពួយត្រឡប់ថយក្រោយយ៉ាងលឿនឆ្ពោះទៅរករបបឯកបក្ស។*

*ល្បឿននៃការធ្លាក់ដាំក្បាលចុះនេះ ក៏បានធ្វើឱ្យកក្រើករំពើកដល់ប្រជាធិបតេយ្យ និងសិទ្ធិជាមូលដ្ឋាន ដែលមានតែសំបកក្រៅនោះទៀតផង។*

*ក្នុងឆ្នាំកន្លងទៅ គណបក្សសង្គ្រោះជាតិត្រូវបានរំលាយ ហើយប្រធានគណបក្សនេះ គឺលោក កឹម សុខា ត្រូវបានចាប់ដាក់គុកថា ក្បត់ជាតិ ដែលជាបទចោទមិនត្រឹមត្រូវ។ ចំណែកលោក សម រង្ស៊ី មេដឹកនាំស្ថាបនិកនៃគណបក្សសង្គ្រោះជាតិម្នាក់ទៀត ត្រូវបានចោទប្រកាន់ និងកាត់ទោសផ្ទួនៗ រាប់មិនអស់ពីបទព្រហ្មទណ្ឌ ហើយដើម្បីគេចពីការជាប់ពន្ធនាគារ លោកបាននិរទេសខ្លួនទៅនៅក្រៅប្រទេសចាប់តាំងពីឆ្នាំ២០១៦។*

*ក្នុងខែកញ្ញា ឆ្នាំ២០១៧ ព្រឹត្តប័ត្រ ឌឹ ខេមបូឌា ដេលី* (The Cambodia Daily) *ត្រូវបង្ខំចិត្តបិទការផ្សាយ។ បន្ទាប់មកក្នុងឧសភា ឆ្នាំ ២០១៨ ម្ចាស់កាសែត ភ្នំពេញប៉ុស្តិ៍ ត្រូវបានគាបសង្កត់ដោយរដ្ឋាភិ-បាលកម្ពុជាឲ្យលក់កាសែតនេះ ទៅឲ្យក្រុមហ៊ុនម៉ាឡេស៊ី ដែលមានចំណងមេត្រីភាពជាមួយលោក ហ៊ុន សែន។ រដ្ឋាភិបាលបានចេញបញ្ជាបិទវិទ្យុអេហ្វអឹម* (FM) *ក្នុងស្រុក ដែលផ្សាយបន្តកម្មវិធីរបស់វិទ្យុអាស៊ីសេរី* (RFA) *និងសំឡេងសហរដ្ឋអាមេរិក* (VOA)*។ អតីតអ្នកយកព័ត៌មានអាស៊ីសេរីពីរនាក់ ត្រូវបានចាប់ឃុំខ្លួន និងចោទប្រកាន់តាមទំនើងចិត្តពីបទលួចផ្តល់ព័ត៌មានទៅឲ្យរដ្ឋបរទេស។*

*សំឡេងរិះគន់ទាំងអស់ ត្រូវបានខ្ទាតចេញពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងប្រទេស។ បុគ្គលិក ៥នាក់ នៃសមាគមការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍នៅកម្ពុជា ហៅកាត់ថា អាដហុក* (ADHOC) *ដែលជាអង្គការមួយទទួល*

បានការគោរពខ្ពស់ ត្រូវបានចាប់ដាក់គុក ដែលអ្នកទាំង ៥ បច្ចុប្បន្ន ត្រូវបានអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន រង់ចាំការជម្រះក្ដីនោះ គឺជាសំណុំរឿងចោទប្រកាន់បង្កប់ទៅដោយមូលហេតុនយោបាយ។ ជាការឆ្លើយតប អង្គការសិទ្ធិមនុស្សនានា និងបណ្ដាអ្នករិះគន់រដ្ឋាភិបាលកម្ពុជា បានធ្វើការត្រួតពិនិត្យបំបិទសិទ្ធិខ្លួនឯងក្នុងការបញ្ចេញមតិ ដើម្បីគេចចេញពីគោលដៅស៊ីបរបស់រដ្ឋាភិបាល។

## បញ្ជីនៃករណីវាយប្រហារលើសិទ្ធិ និងសេរីភាពជាមូលដ្ឋាន នៅតែបន្តមានជាប់ជានិច្ច។

លោក ហ៊ុន សែន បានក្លាយជានាយករដ្ឋមន្ត្រីតាំងពីឆ្នាំ ១៩៨៥ ហើយចាប់តាំងពីឆ្នាំ ២០១៥ បានក្លាយជាប្រធានគណបក្សប្រជាជនកម្ពុជា (CPP) ដែលគ្រប់គ្រងអំណាចតាំងពីឆ្នាំ ១៩៧៩។[1] ដោយលោក រ៉ូប៊ើត មូហ្កាបេ (Robert Mugabe) មេដឹកនាំប្រទេសហ្ស៊ីមបាបវេ (Zimbabwe) ធ្លាក់ពីអំណាចបាត់ទៅ ឥឡូវនេះ គឺលោក ហ៊ុន សែន ជាមេដឹកនាំម្នាក់នៅក្នុងចំណោមប្រាំនាក់ ដែលដឹកនាំផ្ដាច់ការយូរជាងគេក្នុងពិភពលោក។ ដូចគ្នានឹងជនផ្ដាច់ការដទៃទៀតដែរ លោក ហ៊ុន សែន បាននិយាយអំពីខ្លួនឯងថា លោកជាមនុស្សទីបី ហើយបានព្យាយាមលើកដំកើងខ្លួនឯងថា ជាបុគ្គលអស្ចារ្យមានបុណ្យលើគេ ដោយបានដាក់ឈ្មោះខ្លួនឯងនៅតាមសាលារៀនរាប់រយខ្នង (ដែលសាលារៀនទាំងនោះត្រូវបានកសាងឡើងដោយលុយជំនួយពីប្រភពនានា)។ គោរមងាររបស់លោកជាភាសាខ្មែរ គឺ "សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន" ដែលបកស្រាយមកភាសាធម្មតាថា សម្ដេច មេទ័ពកំពូល ដ៏មហាខ្លាំងក្លាអស្ចារ្យប្រកបដោយគតិគុណ និងជ័យជម្នះ។ លោក ហ៊ុន សែន បច្ចុប្បន្នពាក់ស័ក្តិឲ្យខ្លួនឯងជាឧត្តមសេនីយ៍ផ្កាយមាសប្រាំផុតលេខជាអមតៈ។

កត្តាដែលជំរុញលោក ហ៊ុន សែន ចាត់វិធានការបង្ក្រាប បង្ហាញថា គាត់ និងគណបក្សប្រជាជនកម្ពុជាភ័យខ្លាចថា បើមិនប្រើធម៌ក្ដៅបែបនេះទេ ពួកគេប្រាកដជាមិនឈ្នះការបោះឆ្នោត ដែលត្រូវបានកំណត់ធ្វើនៅខែកក្កដា ឆ្នាំ ២០១៨ នោះឡើយ។ គណបក្សសង្គ្រោះជាតិបានឈ្នះឆ្នោតដោយមិនបានគ្រោងទុក កាលពីក្នុងពេលបោះឆ្នោតជាតិ ឆ្នាំ ២០១៣ បើទោះជាមានភាពលំអៀងជាប្រព័ន្ធ ជារចនាសម្ព័ន្ធ និងការបន្លំយ៉ាងសម្បើមក្ដី។ ជ័យជម្នះគណបក្សនេះបានកើតឡើងម្ដងទៀត នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ឆ្នាំ ២០១៧។ អ្នកបោះឆ្នោតជាពលរដ្ឋកម្ពុជានៅតាមជនបទ និងយុវជន ដែលមានអត្រាភាគរយ

[1] លោកហ៊ុនសែនបានក្លាយជានាយករដ្ឋមន្ត្រីនៅថ្ងៃទី 14 ខែមករាឆ្នាំ1985 បន្ទាប់ពីរយៈពេលខ្លីនៃការកាន់តំណែងជានាយករដ្ឋមន្ត្រីស្ដីទី ក្រោយមរណភាពរបស់លោកនាយករដ្ឋមន្ត្រីចាន់ ស៊ី ក្នុងខែធ្នូឆ្នាំ 1984។

កើនឡើងក្នុងចំណោមពលរដ្ឋសរុប បានគាំទ្រគណបក្សប្រឆាំងយ៉ាងខ្លាំងក្លា។ ប្រជាពលរដ្ឋកម្ពុជាភាគច្រើន មិនខុសពីប្រជាពលរដ្ឋនៅប្រទេសដទៃទៀតទេ កាលបើបានរស់នៅក្រោមរបបផ្តាច់ការជ្រក់ជ្រេញយូរហើយនោះ គឺពួកគេស្រេកឃ្លានចង់ផ្លាស់ប្តូរខ្លាំងណាស់។

លោក ហ៊ុន សែន ឆ្លើយតបថា ការចូលរួមក្នុងនយោបាយប្រឆាំង និងរិះគន់លោក រិះគន់គណបក្សប្រជាជនកម្ពុជា ឬរិះគន់រដ្ឋាភិបាល គឺជាទម្រង់ក្បត់ជាតិហើយ។ ពេលដែលគ្មានភស្តុតាងសម្រាប់ការចោទប្រកាន់នេះ លោក ហ៊ុន សែន បានខំបង្កើតឈុតឆាកជាបដិវត្តពណ៌មួយឡើង ដើម្បីចោទសហរដ្ឋអាមេរិក មហាអំណាចបរទេស និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតថា មានគម្រោងផ្តួលរំលំរាជរដ្ឋាភិបាល។ ការវាយប្រហារអ្នករិះគន់ធ្ងន់ធ្ងរបែបនេះ ដែលកើតឡើងចាប់តាំងពីការធ្វើរដ្ឋប្រហារកម្ចាត់ដៃគូរដ្ឋាភិបាលចម្រុះនៅឆ្នាំ ១៩៩៧ (គឺគណបក្សរាជានិយម ហ្វ៊ុនស៊ិនប៉ិច ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ) នោះ គឺជាសញ្ញាបង្ហាញឲ្យឃើញពីការដឹកនាំរបស់លោក ហ៊ុន សែន ដែលមិនចូលចិត្តលទ្ធិប្រជាធិបតេយ្យពហុបក្ស ជាយូរមកហើយ។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានចងក្រងទុកជាឯកសារនូវកំណត់ត្រារំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងររបស់លោក ហ៊ុន សែន តាំងពីមុនៗ មក។ ចាប់តាំងពីពេលលោក ហ៊ុន សែន ឡើងកាន់អំណាចមក មានអ្នកប្រឆាំង អ្នកកាសែត មេដឹកនាំសហជីព មនុស្សផ្សេងទៀតរាប់រយនាក់ ត្រូវបានគេសម្លាប់ក្រោមហេតុផលនយោបាយ។ ទោះជាក្នុងករណីជាច្រើន គេបានស្គាល់អ្នកដែលទទួលខុសត្រូវក្នុងការសម្លាប់នោះក្តី ក៏គ្មានករណីណាមួយ ត្រូវបានស៊ើបអង្កេត និងកាត់ទោសឲ្យបានម៉ត់ចត់ទេ គឺគេទុកឱ្យអ្នកនោះនៅរួចខ្លួនដោយសេរីតែម្តង។ ករណីខ្លះ អ្នកកេះកៃកាំភ្លើង ឬអ្នកដែលគេទម្លាក់កំហុសដាក់ ត្រូវបានគេកាត់ឱ្យជាប់ទោស ឯថ្នាក់លើគេទុកឲ្យនៅដោយមិនអាចប៉ះពាល់បាន។ អ្នករិះគន់ជាច្រើននាក់ ត្រូវបានចាប់ខ្លួន វាយដំ យាយីរំខាន និងបំភិតបំភ័យ ដូចជាបុគ្គលិកសិទ្ធិមនុស្ស មេដឹកនាំកម្មករ សកម្មជន និងសមាជិកសហជីព សកម្មជនខាងដីធ្លី សមាជិកអ្នកសរសេរប្លុក (blogger) ជំនាន់ថ្មី និងមនុស្សមួយចំនួនទៀត ដែលបញ្ចេញមតិតាមអនឡាញ (Online) ជាដើម។ តុលាការដែលនៅក្រោមការត្រួតត្រារបស់គណបក្សប្រជាជនកម្ពុជា បានចោទប្រកាន់មនុស្សដែលមិនបានប្រព្រឹត្តខុស ឬចោទប្រកាន់តាមហេតុផលនយោបាយរាប់រយនាក់។

ពេលដែលលោក ហ៊ុន សែន ដឹកនាំការបង្ក្រាបទាំងនេះ ហើយនៅបន្តកាន់អំណាចបាន គឺតាមរយៈការ

បង្កើតក្រុមសមមិត្តឃោរឃៅនៅក្នុងជួរកងកម្លាំងសន្តិសុខ ដើម្បីអនុវត្តទស្សនៈ និងបញ្ជារបស់ គាត់។ លោក ហ៊ុន សែន ធ្វើបែបនេះតាមរយៈការដំឡើងបុណ្យស័ក្តិដល់មនុស្សដែលស្មោះស្ម័គ្រនឹងគាត់ ជាជាងការដំឡើងតាមក្រសួងស្ថាប័នដែលគេបានបម្រើការឲ្យតាមផ្លូវការ ដូចជាទាហាន កងរាជអាវុធហត្ថ និងនគរបាលជាដើម។

របាយការណ៍នេះ រៀបរាប់លម្អិតអំពីមន្ត្រីជាន់ខ្ពស់ក្នុងកម្លាំងសន្តិសុខចំនួន ១២ នាក់ ដែលរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៧០ រហូតមកដល់បច្ចុប្បន្ននេះ

- នាយឧត្តមសេនីយ៍ផ្កាយមាស៤ ប៉ុល សារឿន អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ
- នាយឧត្តមសេនីយ៍ផ្កាយមាស៤ គន់ គីម អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជានាយសេនាធិការចម្រុះ
- នាយឧត្តមសេនីយ៍ផ្កាយមាស ៤ សៅ សុខា អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- នាយឧត្តមសេនីយ៍ផ្កាយមាស៤ នេត សាវឿន អគ្គស្នងការនគរបាលជាតិ
- ឧត្តមសេនីយ៍ឯកផ្កាយមាស៣ ជា ម៉ន មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី៤
- ឧត្តមសេនីយ៍ឯកផ្កាយមាស៣ ប៊ុន សេង មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការកងយោធភូមិភាគទី៥
- ឧត្តមសេនីយ៍ឯកផ្កាយមាស៣ ជឿន សុវណ្ណថា មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី២
- ឧត្តមសេនីយ៍ឯកផ្កាយមាស៣ ចាប ភក្តី នាយរងសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងពលតូចទ័ពពិសេសឆត្រយោង៩១១
- ឧត្តមសេនីយ៍ឯកផ្កាយមាស៣ រ័ត្ន ស្រ៊ាង មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- នាយឧត្តមសេនីយ៍ផ្កាយមាស៤ សុខ ផល អគ្គស្នងការរងនគរបាលជាតិ និងជាអគ្គនាយកអន្តោប្រវេសន៍

- នាយឧត្តមសេនីយ៍ផ្កាយមាស ៤ ម៉ក់ ជីតូ អគ្គស្នងការរងនគរបាលជាតិ និងជាអគ្គលេខាធិការរងនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន និង
- នាយឧត្តមសេនីយ៍ផ្កាយមាស៤ ជួន សុវណ្ណ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ។

បុគ្គលទាំង ១២ រូបនេះ គឺជាឆ្អឹងខ្នងបង្អែកនៃរបបនយោបាយផ្តាច់ការ រំលោភសិទ្ធិមនុស្ស ដែលធ្វើឱ្យការគ្រប់គ្រងអំណាចរបស់លោក ហ៊ុន សែន រឹតតែផ្តាច់ការ។ ម្នាក់ៗនៃបុគ្គលទាំងនេះ សុទ្ធតែមានទំនាក់ទំនងនយោបាយ និងទំនាក់ទំនងផ្ទាល់ខ្លួនជិតស្និទ្ធនឹងលោក ហ៊ុន សែន ដែលជួយធ្វើឱ្យប្រាកដថា កងទ័ព កងអាវុធហត្ថ និងនគរបាល បំពេញតួនាទីនយោបាយមួយធានាដល់ការគ្រប់គ្រងអំណាចរបស់គណបក្សប្រជាជនកម្ពុជាបន្តទៅមុខៗ ពួកគេម្នាក់ៗ សុទ្ធតែបម្រើអាជីពការងារនៅក្នុងរដ្ឋាភិបាល ដែលទទួលបានប្រាក់ខែសមគួរ ហើយនៅមានទ្រព្យសម្បត្តិអាថិកំបាំងដែលមិនអាចពន្យល់បានយ៉ាងច្រើនសម្បើមទៀត។

បើទោះជាម្នាក់ៗនៃបុគ្គលទាំង ១២ រូបនេះ មានការទទួលខុសត្រូវខាងផ្លូវច្បាប់តំណាងឱ្យរដ្ឋ ជាជាងតំណាងឲ្យគណបក្ស ហើយត្រូវបំពេញតួនាទីរបស់ខ្លួនដោយមិនលំអៀង និងដោយអព្យាក្រឹតក្តី ក៏រាល់សកម្មភាពជាចំហ គឺពួកគេធ្វើក្នុងលក្ខណៈនិយមគណបក្សខ្លាំងតែម្តង។ បុគ្គលទាំង ១២ រូបនេះ ជាសមាជិកគណៈកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា ដែលជាគណៈកម្មាធិការជាន់ខ្ពស់បំផុតសម្រាប់ធ្វើគោលនយោបាយគណបក្ស។ សមាជិកគណៈកម្មាធិការកណ្តាលគណបក្ស ត្រូវតែអនុវត្តរាល់គោលនយោបាយរបស់គណបក្ស។ ការតម្រូវរបៀបនេះ គឺជាបញ្ហាទំនាស់ទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ តាមគោលការណ៍ កងកម្លាំងប្រដាប់អាវុធមានសិទ្ធិបោះឆ្នោត និងមានសិទ្ធិបញ្ចេញមតិឯកជនរបស់ខ្លួន ប៉ុន្តែក្នុងពេលបំពេញការងារវិជ្ជាជីវរបស់ខ្លួន ពួកគេមិនអាចលម្អៀងនយោបាយទេ បើមិនដូច្នោះសាធារណជននឹងមើលឃើញថា កងកម្លាំងប្រដាប់អាវុធទាំងនោះកាន់ជើងគណបក្សមួយនេះ ឬមួយនោះហើយ។ ការធ្វើបែបនេះ ក៏ជាការរំលោភមាត្រា ៩ នៃច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ (ឆ្នាំ ១៩៩៧) ដែរ ដែលចែងថា "យោធិនត្រូវមានអព្យាក្រឹតភាពក្នុងមុខនាទី ក្នុងសកម្មភាពការងារ និងហាមឃាត់ការប្រើមុខងារ និងសម្ភាររបស់រដ្ឋ ដើម្បីសកម្មភាពនយោបាយណាមួយ"។ ការរំលោភបំពាន ដែលអ្នកទាំង ១២ រូប ជាប់ពាក់ព័ន្ធ រួមមានអំពើរំលោភសិទ្ធិមនុស្ស ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តតាំងពីទសវត្សរ៍ឆ្នាំ ១៩៧០ រហូតមកដល់បច្ចុប្បន្ន។ ភាគ

ច្រើននៃអ្នកទាំង ១២នាក់នេះ បានជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងមិនចាំបាច់ ជ្រុលហួសប្រមាណ ដែលរហូតពេលខ្លះធ្វើឱ្យស្លាប់អ្នក ដែលតវ៉ាប្រឆាំងភាពមិនប្រក្រតីនៃការបោះឆ្នោត ដែលមិនសេរី និងមិនត្រឹមត្រូវ ប្រឆាំងការរឹបអូសដីធ្លី ការរំលោភសិទ្ធិការងារ និងបញ្ហាប្រាក់ឈ្នួលតិច។ បុគ្គលទាំងនេះ ភាគច្រើនក៏ពាក់ព័ន្ធនឹងការរំលោភបំពាន ដែលមិនមែនជានយោបាយផងដែរ ប្រឆាំងនឹងពលរដ្ឋធម្មតា ដូចជាការរឹបអូសដីធ្លីដោយរំលោភបំពាន ការសម្លាប់ ការធ្វើទារុណកម្ម និងការឃុំឃាំងតាមអំពើចិត្ត។ អ្នកទាំងនេះខ្លះបានចូលរួមនៅក្នុងរបបខ្មែរក្រហម ប៉ុល ពត ចន្លោះពីខែមេសា ឆ្នាំ ១៩៧៥ ដល់ខែមករា ឆ្នាំ ១៩៧៩។ បុគ្គលទាំងអស់នេះ សុទ្ធតែមានតួនាទីរៀងៗខ្លួន ក្នុងរយៈពេលបន្តបន្ទាប់៖ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ពីខែមករា ឆ្នាំ ១៩៧៩ ដល់ខែមេសា ឆ្នាំ ១៩៨៩ សម័យរដ្ឋកម្ពុជាពីខែមេសា ឆ្នាំ ១៩៨៩ ដល់ខែមិថុនា ឆ្នាំ ១៩៩៣ រាប់ទាំងសម័យ អ៊ុនតាក់ (UNTAC) គ្រប់គ្រងប្រទេសពីខែមីនា ឆ្នាំ ១៩៩២ ដល់ខែមិថុនា ឆ្នាំ ១៩៩៣ សម័យរដ្ឋាភិបាលអន្តរកាល និងបន្តមករាជរដ្ឋាភិបាលកម្ពុជា ពីខែកក្កដា ឆ្នាំ ១៩៩៣ រហូតមកដល់សម័យបច្ចុប្បន្ន។

ម្នាក់ៗនៃបុគ្គលទាំង ១២ រូបនេះ ហាក់ដូចជាអង្គរក្សផ្ទាល់របស់លោក ហ៊ុន សែន។ អ្នកទាំង១២ រូបសុទ្ធតែជំពាក់គុណបុណ្យលោក ហ៊ុន សែន ចំពោះតួនាទីមុខតំណែងជាន់ខ្ពស់ ដែលគេមានក្នុងកងកម្លាំងសន្តិសុខ។ ពួកគេមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយលោក ហ៊ុន សែន រាប់ទសវត្សរ៍មកហើយ ហើយពួកគេមានឆន្ទៈរំលោភបំពានសិទ្ធិមនុស្សដើម្បីលោក ហ៊ុន សែន។ លោក ប៉ុល សារឿន និងលោកគន់ គីម គឺជាសមាជិកនៃឧបករណ៍សន្តិសុខយោធាខ្មែរក្រហម ដូចលោក ហ៊ុន សែន ដែរ។ អ្នកទាំងបី សុទ្ធតែជាកម្មាភិបាលខ្មែរក្រហមនៅភូមិភាគបូព៌ា។ លោក ហ៊ុន សែន បានឆ្លងទៅប្រទេសវៀតណាម នៅឆ្នាំ ១៩៧៧ ហើយបានក្លាយជាបុគ្គលគន្លឹះសំខាន់មួយរូបនៅក្នុងអង្គការចាត់តាំងយោធា និងក្រុមផ្សេងទៀត ដែលទំនុកបម្រុងដោយវៀតណាមក្នុងឆ្នាំ ១៩៧៨ ដើម្បីប្រឆាំងរបបប៉ុល ពត។ លោក ហ៊ុន សែន បានធ្វើជារដ្ឋមន្ត្រីការបរទេសនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា វ័យក្មេងជាងគេលើពិភពលោក។ លោក ប៉ុល សារឿន ដែលទៅដល់ប្រទេសវៀតណាម នៅក្នុងឆ្នាំ ១៩៧៨ ក៏ជាតួអង្គសំខាន់មួយដែរក្នុងមុខតំណែង ដែលគាំទ្រដោយវៀតណាម នៅសម័យនោះ។ លោក សៅ សុខា លោក ជា ម៉ន និង លោក ជឿន សុវណ្ណ ជាជំនួយការលោក ហ៊ុន សែន និងក្រោយមកក្លាយជាសមាជិកកងកម្លាំងប្រដាប់អាវុធក្នុងអង្គភាពតូចមួយ ដែលលោក ហ៊ុន សែនបង្កើតឡើងនៅពេលនោះដែរ។ ចំណែកលោក គន់ គីម លោក នេត សាវឿន និង លោកសុខផល បានក្លាយជាមនុស្សជំនិតលោក ហ៊ុន សែន យ៉ាងហោចណាស់នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ហើយ

លោក ចាប ភក្តី វិញយ៉ាងហោចណាស់បានក្លាយជាជំនិតលោក ហ៊ុន សែ នៅពាក់កណ្តាលទសវត្សរ៍នោះ គឺនៅពេលគាត់ដើរតួនាទីសំខាន់នៅក្នុងការធ្វើរដ្ឋប្រហាររបស់លោក ហ៊ុន សែន នៅឆ្នាំ ១៩៩៧។ រីឯលោក ជួន សុវណ្ណ និង រ័ត្ន ស្រ៊ាង គឺជាកូនចៅរបស់លោក គន់ គីម ដែលតាមរយៈលោកគន់ គីម នេះហើយទើបពួកគេមានទំនាក់ទំនងជាមួយលោក ហ៊ុន សែន។

## បទរំលោភបំពាននានា នៅក្នុងសម័យខ្មែរក្រហម

ឧត្តមសេនីយ៍ពីររូប ដែលមានកំណត់ត្រាពីការរំលោភសិទ្ធិមនុស្សយូរជាងគេ គឺលោក ប៉ុល សារឿន និង គន់ គីម។ អ្នកទាំងពីរជាសមាជិកឧបករណ៍នៃកងសន្តិសុខយោធាបក្សកុម្មុយនិស្តកម្ពុជារបស់ ប៉ុល ពត (ដែលគេស្គាល់ថា ខ្មែរក្រហម)។ ក្នុងពេលកំពុងកាន់អំណាច ខ្មែរក្រហមជាអ្នកទទួលខុសត្រូវចំពោះការស្លាប់របស់ពលរដ្ឋចំនួនប្រមាណពី ១លាន ២សែននាក់ ទៅ ២លាន ៨សែននាក់ ដោយសារការសម្លាប់ អត់បាយ និងជំងឺ។ ចំនួននេះ គឺចន្លោះពី ១៣ និង ៣០ភាគរយនៃពលរដ្ឋសរុប។ ក្នុងនោះ ក៏រាប់ចូលទាំងការស្លាប់ពាក់ព័ន្ធនឹងកាទទួលខុសត្រូវរបស់លោក ប៉ុល សារឿន និងលោក គន់ គីម នៅកន្លែងសន្តិសុខរបស់ខ្មែរក្រហម ដែលជាមណ្ឌលសួរចម្លើយ ធ្វើការធ្វន់ និងសម្លាប់ចោល។ លោក ប៉ុល សារឿន ជាអនុលេខានៃសេនាធិការយោធាភូមិភាគបូព៌ា ដែលគ្រប់គ្រងលើមន្ទីរសន្តិសុខតំបន់ ឈ្មោះ ស-៧៩។ លោក គន់ គីម ជាប្រធានមន្ទីរសន្តិសុខស្រុកត្បូងឃ្មុំ នៃតំបន់ ២១។

## អំពើរំលោភបំពាន នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម័យរដ្ឋកម្ពុជា

គោលនយោបាយ និងការអនុវត្តរបស់ខ្មែរក្រហម បានធ្វើឱ្យខ្ទេចខ្ទាំសង្គមកម្ពុជា ហើយបង្កលក្ខណៈងាយស្រួលសម្រាប់ជ័យជម្នះនៃការឈ្លានពានរបស់វៀតណាម នៅក្នុងខែធ្នូ ឆ្នាំ ១៩៧៨ និងឈានទៅបង្កើតបានរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅក្នុងខែមករា ឆ្នាំ ១៩៧៩។ រដ្ឋាភិបាលថ្មីមិនមែនដាក់បញ្ចូលតែលោក ប៉ុល សារឿន និង គន់ គីម ប៉ុណ្ណោះទេ គឺមានអតីតខ្មែរក្រហមនៅគ្រប់ជាន់ថ្នាក់ផ្សេងៗទៀត។ ក្នុងនោះ ក៏មានលោក ហ៊ុន សែន ដែលជាសមាជិកឧបករណ៍សន្តិសុខយោធាខ្មែរក្រហមម្នាក់ដែរ។ លោក ហ៊ុន សែន ធ្លាប់ជាមេបញ្ជាការយោធាខ្មែរក្រហមនៅពេលនោះ ដែលដើរតួនាទីមិនច្បាស់លាស់នៅក្នុងតំបន់

ដែលមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានកើតឡើង។

សាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានប្រយុទ្ធប្រឆាំងដោយក្រុមខ្មែរក្រហម ដែលបានកែទម្រង់ ហើយបន្តប្រយុទ្ធតាមរបៀបទ័ពព្រៃប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាជាប់រហូត ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៨ ជាពេលដែលប៉ុលពត ស្លាប់ និងក្នុងពេលដែលចលនាខ្មែរក្រហមបែកបាក់ និងដួលរលំ។ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ត្រូវបានប្រយុទ្ធប្រឆាំងដោយចលនាអ្នកតស៊ូមិនមែនកុម្មុយនិស្តផ្សេងទៀត ដែលគេស្គាល់ឈ្មោះថា រណសិរ្សរួបរួមជាតិកម្ពុជា ដើម្បីឯករាជ្យ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការ ហៅកាត់ថា ហ៊្វុនស៊ិនប៉ិច (FUNCINPEC) ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨១ ដោយអតីតព្រះមហាក្សត្រ សម្តេចព្រះនរោត្តមសីហនុ ហើយបន្ទាប់មករណសិរ្សនេះត្រូវបានដឹកនាំដោយបុត្រារបស់ព្រះអង្គគឺព្រះអង្គម្ចាស់នរោត្តមរណឫទ្ធិ។

របបឯកបក្ស នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានបង្កើតឡើង និងពង្រឹងការគ្រប់គ្រងអំណាចរបស់ខ្លួនតាមរយៈនយោបាយដាក់គុកទូទាំងប្រទេសដោយគ្មានការចោទប្រកាន់ ឬជំនុំជម្រះ និងតាមប្រព័ន្ធធ្វើទារុណកម្មអ្នកជាប់ឃុំផ្នែកនយោបាយរាប់ពាន់នាក់។ ជនជាប់ឃុំទាំងនោះជាច្រើននាក់បានស្លាប់ដោយសារការធ្វើបាប និងស្ថានភាពឃុំឃាំងដ៏អាក្រក់ហួសប្រមាណទាំងនោះ។

ប្រវត្តិបុគ្គល ១០រូប ក្នុងចំណោម ១២រូប នៅក្នុងរបាយការណ៍នេះ គឺជាប់ពាក់ព័ន្ធអំពើរំលោភទាំងនេះ តាមរយៈតួនាទីរបស់ខ្លួន នៅក្នុងសេវាផ្សេងៗ ទាំងនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងបន្តមករបបរដ្ឋកម្ពុជា ដូចជាក្នុងផ្នែកនយោបាយ យោធា ផ្នែកស្រាវជ្រាវចារកិច្ច និងអង្គភាពនគរបាល ហើយផ្នែកទាំងនេះ ជាស្ថាប័នមូលដ្ឋានដែលបាននាំអ្នកទាំងនោះមកកាន់តួនាទីកងកម្លាំងសន្តិសុខលេចធ្លោ នៅក្នុងពេលបច្ចុប្បន្ននេះ។ អំពើរំលោភបំពាននានា ត្រូវបានប្រព្រឹត្តឡើងនៅក្នុងការបង្ក្រាបអ្នកងើបតវ៉ាមិនពេញចិត្តនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយមានវៀតណាមជាខ្នងបង្អែកផង គឺមានការឃុំឃាំងផ្នែកនយោបាយតាមអំពើចិត្ត និងការធ្វើទារុណកម្មជាប្រចាំនៅពន្ធនាគារខេត្ត ដែលឋិតនៅក្រោមអំណាចលោក ប៉ុល សារឿន នៅជាអភិបាលខេត្តនោះ។ ពន្ធនាគារក្រុងភ្នំពេញនៅពេលនោះ មានលោក នេត សាវឿន ជាមន្ត្រីនគរបាលជាន់ខ្ពស់។ ហើយឧបករណ៍សន្តិសុខនយោបាយរបស់ក្រសួងមហាផ្ទៃពេលនោះ មានលោក សុខ ផល ជាកម្មាភិបាលសំខាន់មួយរូបនៅទីនោះដែរ។

## អំពើរំលោភបំពាននៅក្នុងអំឡុងសម័យ អ៊ុនតាក់ (UNTAC)

នៅឆ្នាំ ១៩៩១ រដ្ឋកម្ពុជា និង ហ៊្វុនស៊ិនប៉ិច (FUNCINPEC) ដែលជាក្រុមអ្នកតស៊ូមិនមែនកុម្មុយនិស្តទីពីរ (មួយទៀត គឺរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (KPNLF) និងក្រុមខ្មែរក្រហម ប៉ុល ពត បានរួមគ្នាចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលជាកិច្ចព្រមព្រៀងមួយស្តីពីដំណោះស្រាយនយោបាយរួមនៃជម្លោះកម្ពុជា។ ក្នុងនោះ មានរដ្ឋាភិបាលអន្តរជាតិចំនួន ១៨ ប្រទេសផ្សេងទៀត ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះដែរ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីស មានចែងអំពីអាណត្តិការងាររបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា (ហៅកាត់ថា អ៊ុនតាក់) ដើម្បីរំសាយកម្លាំងប្រដាប់អាវុធនៅតាមតំបន់ភាគច្រើនរបស់កម្ពុជា និងគ្រប់គ្រងផ្ទាល់នូវផ្នែកសំខាន់ៗ ផ្នែករដ្ឋបាលដែលមានពេលនោះ ដើម្បីបង្កើតបរិយកាសនយោបាយអព្យាក្រឹតមួយសម្រាប់ឱ្យអង្គការសហប្រជាជាតិរៀបចំការបោះឆ្នោត ដែលធ្វើឡើងនៅខែឧសភា ឆ្នាំ១៩៩៣ នោះ។

នៅក្នុងសម័យ អ៊ុនតាក់ ប្រវត្តិអ្នកទាំង ១២ រូប បានពាក់ព័ន្ធច្រើនក្នុងអំពើហិង្សានយោបាយរបស់របបរដ្ឋកម្ពុជា ដែលរាប់ទាំងឃាតកម្មនយោបាយ។ គោលដៅនៃអំពើហិង្សា និងឃាតកម្ម គឺគណបក្សហ៊្វុនស៊ិនប៉ិច និងអ្នកនយោបាយប្រឆាំងអហិង្សាផ្សេងទៀត ដើម្បីកំណត់ទិសដៅធានាឱ្យគណបក្សប្រជាជនកម្ពុជាឈ្នះក្នុងការបោះឆ្នោត ដែលរៀបចំដោយអង្គការសហប្រជាជាតិ នៅខែឧសភា ឆ្នាំ ១៩៩៣ នោះ។ តាមរបាយការណ៍មួយរបស់អ៊ុនតាក់ បង្ហាញថា របបរដ្ឋកម្ពុជា ជាអ្នកទទួលខុសត្រូវចំពោះព្រឹត្តិការណ៍សម្លាប់អ្នកនយោបាយប្រឆាំងចំនួន ៣៩ ករណី ដែលបានធ្វើឱ្យមានគ្រោះថ្នាក់មនុស្សចំនួន ៤៦ នាក់ និងការសម្លាប់ ២៥ នាក់ផ្សេងទៀត។ គោលបំណងសំខាន់នៃការសម្លាប់នេះ គឺដើម្បីបំភិតបំភ័យពលរដ្ឋ។ ហើយក៏មានករណីសម្លាប់មនុស្សភ្លាមៗបន្ទាប់ពីចាប់ឃាត់ខ្លួនពួកគេដែរ ដែលក្នុងនោះមានជនរងគ្រោះសរុប៤០នាក់។ របាយការណ៍នោះក៏បានរាយបញ្ជីករណីរំលោភបំពានរបស់រដ្ឋកម្ពុជារាប់រយករណីទៀត រួមមានការបាត់ខ្លួនដោយបង្ខំ និងការធ្វើទារុណកម្មផង។ តួលេខនៅក្នុងរបាយការណ៍នេះ មិនបានរាយចំនួនករណីរំលោភបំពានឱ្យអស់ទេ ពីព្រោះអ៊ុនតាក់ មិនអាចស៊ើបអង្កេតបានគ្រប់ករណីឡើយ ឬក៏អាចបញ្ជាក់បានថា នរណា

ជាអ្នកទទួលខុសត្រូវចំពោះករណីទាំងអស់ ដែលមិនបានស៊ើបអង្កេតនេះដែរ។[2]

ទោះជាយ៉ាងនេះក្តី នៅក្នុងការបោះឆ្នោត គណបក្ស ហ៊្វុនស៊ិនប៉ិច បានឈ្នះលើគណបក្សប្រជាជនកម្ពុជា។ ប៉ុន្តែក្រុមគណបក្សប្រជាជនកម្ពុជា ដែលដឹកនាំដោយលោក ហ៊ុន សែន គំរាមប្រើហិង្សាជំទាស់លទ្ធផលបោះឆ្នោត។ ដោយឈរលើមូលដ្ឋាននេះ គណបក្សប្រជាជនកម្ពុជា ក៏បានទាមទារដោយជោគជ័យឱ្យអង្គការសហប្រជាជាតិបង្កើតសម្ព័ន្ធភាពសហនាយករដ្ឋមន្ត្រី រវាងហ៊្វុនស៊ិនប៉ិច-ស៊ីភីភី (FUNCINPEC-CPP) ដោយឱ្យសម្តេចក្រុមព្រះជានាយករដ្ឋមន្ត្រីទី១ ហើយលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី២។ បើទោះជាការនេះមានន័យខុសគ្នាបន្តិចបន្តួចក្តី ក៏ម្នាក់ៗ មានអំណាចខាងផ្លូវច្បាប់ដូចគ្នា។

## ការរំលោភបំពានចាប់តាំងពីសម័យអ៊ុនតាក់ (ឆ្នាំ ១៩៩៣ រហូតមកដល់បច្ចុប្បន្ន)

បន្ទាប់ពីអាជ្ញាធរអ៊ុនតាក់ ចាកចេញនៅឆ្នាំ ១៩៩៣ អំពើហិង្សានយោបាយរបស់គណបក្សប្រជាជនកម្ពុជាបានបញ្ចេញផ្កាភ្លើងម្តងទៀត។ នោះគឺការប្រឆាំងនឹងអ្នកសារព័ត៌មានរិះគន់ និងគណបក្សជាតិខ្មែរ ដែលទើបបង្កើតថ្មី និងដឹកនាំដោយលោក សម រង្ស៊ី ជាអតីតរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុរបស់គណបក្ស ហ៊្វុនស៊ិនប៉ិច ត្រូវបានគេកំណត់គោលដៅតាមធ្វើឃាតជាបន្តបន្ទាប់។ សម្ព័នភាពសហនាយករដ្ឋមន្ត្រីដែលត្រូវបានរៀបចំឡើង នៅឆ្នាំ ១៩៩៣ នោះ បានបញ្ចប់នៅឆ្នាំ ១៩៩៧ គឺនៅពេលដែលលោក ហ៊ុន សែន បណ្តេញព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ចេញពីអំណាចតាមរយៈរដ្ឋប្រហារ។

ភាគច្រើននៃបុគ្គលទាំង ១២ រូប បានជាប់ពាកព័ន្ធនឹងអំពើហិង្សានយោបាយពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៨ ជាពិសេស លោក គន់ គីម លោក ចាប ភក្តី លោក ជា ម៉ន លោក ប៊ុន សេង លោក ជឿន សុវន្តា លោក នេត សាវឿន និង លោក សៅ សុខា។ ភាគច្រើននៃបុគ្គលទាំងនេះ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងរដ្ឋប្រហាររបស់លោក ហ៊ុន សែន នៅថ្ងៃទី៥ និងទី៦ ខែកក្កដា ឆ្នាំ ១៩៩៧ ប្រឆាំងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលជានាយករដ្ឋមន្ត្រីទី១ និងគណបក្សហ៊្វុនស៊ិនប៉ិចរបស់ព្រះអង្គ។ រដ្ឋប្រហារនេះ បានសម្លាប់សមាជិកដែលមានភក្តីភាពបំផុតចំពោះគណបក្សរាជានិយមចំនួនជាង១០០នាក់។ ក្នុងរបាយការណ៍របស់

---

[2] អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា របាយការណ៍ចុងក្រោយ (អ៊ុនតាក់) របស់អង្គភាពផ្នែកសិទ្ធិមនុស្ស ខែកញ្ញា ឆ្នាំ១៩៩៣។

ការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ខែសីហា ឆ្នាំ ១៩៩៧ បានចងក្រងឯកសារអ្នកស្លាប់ថា មានចំនួន ៤១ នាក់ ហើយថា ចំនួននេះ អាចមានដល់ ៦០ នាក់ ដែលត្រូវបានគេសម្លាប់ដោយហេតុផលនយោបាយក្រៅប្រព័ន្ធតុលាការ បន្ទាប់ពីរដ្ឋប្រហារហើយ។[3] តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ សម្រាប់សិទ្ធិមនុស្សប្រចាំនៅកម្ពុជា លោក ថូម៉ាស ហ៊ែមម៉ាប៊ើគ (Thomas Hammarberg) ថ្លែងក្រោយមកទៀតថា ក្នុងហេតុការណ៍នោះ មានមនុស្សរាប់សិបនាក់ ត្រូវបានគេប្រហារជីវិតភ្លាមៗក្រោយការចាប់ឃាត់ខ្លួន ករណីឃាតកម្ម និងករណីបាត់ខ្លួនក្រោយរដ្ឋប្រហារ។

ការសម្លាប់នោះ បានបណ្តាលឱ្យអ្នកនយោបាយប្រឆាំង និងសកម្មជននិរទេសខ្លួនទៅក្រៅប្រទេសដោយសារបារម្ភអំពីអាយុជីវិតរបស់ខ្លួន។ ទោះដូច្នេះក្តី អ្នកនយោបាយបានត្រឡប់មកប្រទេសវិញ ក្រោមការសម្របសម្រួលចរចាដោយប្រទេសជប៉ុន សហរដ្ឋអាមេរិក និងអង្គការសហប្រជាជាតិ ដើម្បីចូលរួមការបោះឆ្នោត នៅខែកក្កដា ឆ្នាំ ១៩៩៨ ដែលជាដំណើរការបោះឆ្នោតមួយប្រកបដោយហិង្សា និងមានគុណវិបត្តិ។

រដ្ឋប្រហារឆ្នាំ ១៩៩៧ និងសន្ទឹកឆ្នោតនៅឆ្នាំ ១៩៩៨ នោះ បានបន្តឱ្យមានការបោះឆ្នោតរដ្ឋសភាក្រោមការកេងបន្លំរបស់គណបក្សប្រជាជនកម្ពុជានៅឆ្នាំ ២០០៣, ២០០៨ និងឆ្នាំ ២០១៣។ គណបក្សប្រជាជនកម្ពុជាអះអាងថា ខ្លួនបានឈ្នះដោយពិតប្រាកដ ស្របពេលដែលគណបក្សកាន់អំណាចមួយនេះ បានបន្សាបឥទ្ធិពលគណបក្សហ៊្វុនស៊ិនប៉ិច ហើយផ្តល់សម្បទាននយោបាយឱ្យវិញខ្លះ ក្នុងពេលដែលជីវិតនយោបាយរបស់គណបក្សរាជានិយមមួយនេះបម្រុងនឹងស្លាប់ទៅហើយនោះ។

ទោះជាយ៉ាងណា ការក្តោបក្តាប់អំណាចបាននេះ មិនបានធ្វើឱ្យលោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជាអស់មានឧបសគ្គប្រឆាំងនឹងខ្លួនឡើយ។ ហើយនេះក៏មិនបានបញ្ឈប់ពួកគេពីការពឹងផ្អែកលើការលូតលាស់អំណាចសេដ្ឋកិច្ចរបស់ខ្លួន តាមរយៈក្រុមអ្នកមានអំណាចរឹបអូសដីធ្លី និងការកេងប្រវ័ញ្ចលើកម្មកររោងចក្រ ដែលមានប្រាក់ខែតិចនោះដែរ។ ពីឆ្នាំ ១៩៩៨ ទៅដល់ឆ្នាំ ២០០៨ ឧបសគ្គផ្នែកនយោបាយចំពោះលោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា គឺការលេចចេញវត្តមានគណបក្ស សម រង្ស៊ី (SRP) ដែល

[3] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (COHCHR) "អនុស្សរណៈជូនរាជរដ្ឋាភិបាលកម្ពុជា ៖ ភស្តុតាងនៃការប្រហារជីវិតក្រៅច្បាប់ ការធ្វើទារុណកម្ម និងការបាត់ខ្លួន ចាប់តាំងពីថ្ងៃទី 2-7 ខែកក្កដាឆ្នាំ 1997" ថ្ងៃទី 21 ខែកក្កដាឆ្នាំ 1997 ទំព័រទី 2 ។ http://cambodia.ohchr.org/WebDOCs/DocStatements/1997/Statement_21081997E.pdf (ចូលមើលនៅថ្ងៃទី 31 ខែតុលាឆ្នាំ 2012 ។)

មានប្រជាប្រិយភាព និងចេះតែរីកធំធាត់ឡើងៗ ឧបសគ្គផ្នែកសង្គមចំពោះលោក ហ៊ុន សែនវិញ គឺគណបក្ស សម រង្ស៊ី បង្ហាញខ្លួនកាន់តែខ្លាំងឡើងចូលរួមក្នុងបាតុកម្មតវ៉ាជាមួយមហាជនប្រឆាំងនឹងការបាត់បង់ដីធ្លី និងផ្ទះសម្បែង ហើយជាញឹកញាប់នោះ គឺគណបក្សប្រឆាំងមួយនេះ ចូលរួមជាមួយកម្មកររោងចក្រដែលដឹកនាំដោយសហជីពធ្វើកូដកម្មទាមទារប្រាក់ឈ្នួល និងលក្ខខណ្ឌការងារឲ្យបានល្អប្រសើរ។

ក្នុងឆ្នាំ ២០១២ លោក សម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី និងលោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស បានច្របាច់គណបក្សទាំងពីរបញ្ចូលគ្នាទៅជាគណបក្សតែមួយ ដោយដាក់ឈ្មោះថា គណបក្សសង្គ្រោះជាតិ (Cambodian National Rescue Party or CNRP) ដើម្បីប្រកួតជាមួយគណបក្សប្រជាជនកម្ពុជា ក្នុងការបោះឆ្នោត នៅឆ្នាំ ២០១៣។ ការបោះឆ្នោតនេះមានលក្ខណៈមិនប្រក្រតីជាប្រព័ន្ធ ហើយក៏មិនសេរី និងយុត្តិធម៌ដែរ។ គណបក្សប្រជាជនកម្ពុជាអះអាងពីជ័យជម្នះបន្តិចបន្តួច (ប្រកៀកប្រកិតគ្នា) ដែលធ្វើឱ្យលោក ហ៊ុន សែន នៅកាន់អំណាចដដែល។

## កំណែទម្រង់កងកម្លាំងសន្តិសុខ ដែលមាននិន្នាការនយោបាយ ពិតជាទៅមិនរួច

លោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា រឹតតែពឹងផ្អែកលើមេបញ្ជាការទាំង ១២ រូប និងមេបញ្ជាការជាន់ខ្ពស់ផ្សេងទៀត នៅក្នុងកងកម្លាំងយោធា រាជអាវុធហត្ថ និងនគរបាល ដែលជាប្រធានបទនៃរបាយការណ៍នេះ។ និន្នាការនេះ ត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់ ក្នុងមហាសន្និបាតរបស់គណបក្សប្រជាជនកម្ពុជា នៅឆ្នាំ ២០១៥ ជាពិសេស ការកើនឡើងចំនួនមេបញ្ជាការកងកម្លាំងសន្តិសុខ ឬកងប្រដាប់អាវុធ និងមន្ត្រីរដ្ឋាភិបាលផ្សេងទៀត ដែលទទួលបន្ទុកផ្នែកសន្តិសុខនៅក្នុងគណៈកម្មាធិការកណ្ដាលរបស់គណបក្សប្រជាជនកម្ពុជា (សូមមើលឧបសម្ព័ន្ធទី ១)។ តាមការគណនារបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សយូមែនរ៉ៃត៍វ៉ច្ឆ (Human Rights Watch) យ៉ាងហោចណាស់មានមន្ត្រី ៨០ រូប ត្រូវបានគេបញ្ចូលបន្ថែម។ នៅមហាសន្និបាតបក្ស ក្នុងខែមករា ឆ្នាំ ២០១៨ ដែលត្រូវអនុម័តផែនការបក្សសម្រាប់ការបោះឆ្នោតជាតិឆ្នាំ ២០១៨ ក៏មានបញ្ចូលបុគ្គលិកនៃកងកម្លាំងសន្តិសុខសន្ទឹកសន្ទាប់ដែរ។ ក្នុងនោះ គឺមានមន្ត្រីយោធា ៦៤ នាក់ ភាគច្រើនជាថ្នាក់ឧត្តមសេនីយ៍ទោ នេះបើតាមឯកសារដែលអង្គការឃ្លាំមើលសិទ្ធិមនុស្សយូមែនរ៉ៃត៍វ៉ច្ឆបានឃើញ។[4]

[4] មិចដារ៉ានិងអាណាថេបបាលី "រង្វង់ខាងក្នុងរបស់គណបក្សប្រជាជនកម្ពុជាបានរីកចម្រើនទៅមុខ ខ្សោយជាងប្រទេសចិននិងវៀតណាម" កាសែត

*លោក ហ៊ុន សែន បានប្រកាស "ការប្តេជ្ញាចិត្តដាច់ខាត" រក្សាស្ថិរភាពសណ្តាប់ធ្នាប់នយោបាយនៅកម្ពុជា ដើម្បីឱ្យគាត់អាចក្លាយជានាយករដ្ឋមន្ត្រីបន្តទៀត ក្រោយការបោះឆ្នោត ដែលកំណត់ធ្វើនៅឆ្នាំ២០១៨។[5] យោងតាមប្រវត្តិពីអតីតកាល និងតួនាទីបច្ចុប្បន្នកាលរបស់ពួកគេ គឺថា លោក ហ៊ុន សែន ពឹងផ្អែកលើមេបញ្ជាការទាំង ១២រូបនេះ និងកូនចៅរបស់ពួកគេ ដើម្បីប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្ស នៅពេលណាចាំបាច់សម្រាប់តែអំណាច និងផលប្រយោជន៍សេដ្ឋកិច្ចរបស់ពួកគេ។ ភាពគ្រោះថ្នាក់នេះ គឺបានឆ្លុះបញ្ចាំងទាំងតាមរយៈកំណត់ត្រាសកម្មភាពរំលោភបំពានសិទ្ធិមនុស្សរបស់ពួកគេយូរមកហើយ ក៏ដូចជាក្នុងបរិបទនៃការបោះឆ្នោតឆ្នាំ ២០១៣ និងការបោះឆ្នោត ដែលកំណត់ធ្វើនៅឆ្នាំ ២០១៨ ដែរ។ មហាបាតុកម្មដោយសន្តិវិធីបានកើតមានក្រោយការបោះឆ្នោតឆ្នាំ ២០១៣ ប្រឆាំងការបន្លំសន្លឹកឆ្នោតដោយគណបក្សប្រជាជនកម្ពុជា ហើយការធ្វើកូដកម្មទ្រង់ទ្រាយធំថ្មី ទាមទារឱ្យដំឡើងប្រាក់ឈ្នួល ក៏បានកើតឡើងដែរ។ ការប៉ុនប៉ងទាំងកំពោលរបស់កងកម្លាំងសន្តិសុខ ដើម្បីទប់ស្កាត់ និងបង្ក្រាបការប្រមូលផ្តុំទាំងនេះ ជួនកាលបង្កឱ្យសង្គមវឹកវរ ដែលធ្វើឱ្យកងសន្តិសុខលើកយកជាមូលហេតុ ដើម្បីឆ្លើយតបភាពវឹកវរនោះដោយអំពើហិង្សាហួសហេតុ រួមមានទាំងការប្រើកម្លាំងមិនចាំបាច់ ដែលបណ្តាលបាត់បង់ជីវិតមនុស្ស។ ជាលទ្ធផល មានមនុស្សស្លាប់ចំនួន ៧នាក់ នៅដើមឆ្នាំ ២០១៤។ គណបក្សប្រជាជនកម្ពុជា ថ្កោលទោសការតវ៉ា និងកូដកម្មទាំងនោះថា ជាផែនការរបស់គណបក្សសង្គ្រោះជាតិ (CNRP) ញុះញង់ឱ្យមាន "បដិវត្តពណ៌"។ តាំងពីពេលនោះមកលោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា ចាប់ផ្តើមយុទ្ធនាការរំលោភសិទ្ធិមនុស្សដោយដៅមុខសញ្ញាទៅរកគណបក្សសង្គ្រោះជាតិ និងប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងសង្គមស៊ីវិល ដោយអះអាងថា នេះជាវិធានការចាំបាច់ក្នុងការបង្ការកុំឱ្យមាន បដិវត្តន៍ពណ៌ ដែលថាបើមិនតប់ស្កាត់ទេ បដិវត្តន៍ពណ៌នឹងអាចកើតឡើងពាក់ព័ន្ធនឹងការបោះឆ្នោតនៅឆ្នាំ ២០១៨ រាប់ទាំងការតវ៉ាប្រឆាំងនឹងការលួចបន្លំសន្លឹកឆ្នោតផង។*

*របាយការណ៍នេះ ចាប់ផ្តើមឡើងដោយមានប្រវត្តិលម្អិតអំពីកម្លាំងសន្តិសុខបីផ្នែកសំខាន់ ដែលមាននៅរហូតមកដល់សព្វថ្ងៃនេះ គឺកងទ័ព កងរាជអាវុធហត្ថ និងនគរបាល។ ការវិវឌ្ឍនៃខ្សែបញ្ជារបស់ពួកគេ សូម*

---

ភ្នំពេញប៉ុស្តិ៍ខែមករាថ្ងៃទី 22 ឆ្នាំ 2018 https://www.phnompenhpost.com/national-politics/cpp-inner-circle-expands-dwarfing-chinas-and-vietnams (ចូលមើលថ្ងៃទី 24 ខែមករាឆ្នាំ 2018) ។ ផ្តល់ឲ្យក្នុងលក្ខខណ្ឌនៃការរក្សាការសម្ងាត់ ច្បាប់ថតចម្លងលើឯកសារមាននៅជាមួយអង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែនរ៉ាយវ៍ច្ឆ។

[5] សម្តេចតេជោហ៊ុនសែន ប្រកាសថាបឹងប្តូរផ្តាច់ដាច់ខាត ដើម្បីការពារសន្តិភាព ស្ថិតភាពនយោបាយ និងការអភិវឌ្ឍន៍។ សម្តេចតេជោថា មានការអភិវឌ្ឍន៍ប្រសើរជាងមានចលាចលកើតឡើង, ថ្ងៃទី៧ ខែមិថុនាឆ្នាំ 2016, http://www.freshnewsasia.com/index.php/en/25913-2016-06-07-02-13-56.html (ចូលមើលថ្ងៃទី ៧ ខែមិថុនាឆ្នាំ 2016) ។

មើលក្នុងឧបសម្ព័ន្ធទី ២, ៣, និងទី ៤។ ឧបសម្ព័ន្ធនេះ បន្តដោយប្រវត្តិបុគ្គលទាំង១២ រូប។ របាយការណ៍នេះ គឺបញ្ចប់ដោយការផ្តល់អនុសាសន៍ ជូនដល់រាជរដ្ឋាភិបាលកម្ពុជា អង្គការសប្រជាជាតិ ម្ចាស់ជំនួយ និងរដ្ឋាភិបាលផ្សេងៗទៀត សម្រាប់ធ្វើកំណែទម្រង់ផ្នែកកងកម្លាំងសន្តិសុខ។ អនុសាសន៍ទាំងនេះ ត្រូវបានធ្វើឡើង តាមការបង្ហាញពីភាពបរាជ័យនៃកិច្ចប្រឹងប្រែងរបស់សហគមន៍អន្តរជាតិនៅក្នុងវិស័យនេះ ដែលទទួលស្គាល់ថា ការកែទម្រង់ផ្នែកសន្តិសុខ គឺមានសារសំខាន់បំផុត សម្រាប់ការលើកស្ទួយ និងការពារសិទ្ធិមនុស្ស នៅប្រទេសកម្ពុជា។ ប្រសិនបើមិនធ្វើឱ្យកងកម្លាំងសន្តិសុខមានវិជ្ជាជីវៈ ហើយជនរំលោភបំពានសំខាន់ៗមិនបានទទួលខុសត្រូវសមស្របទេនោះ លទ្ធភាពកែទម្រង់លទ្ធិប្រជាធិបតេយ្យមានតិចតួច ឬការកែទម្រង់រចនាសម្ព័ន្ធណាមួយនៅប្រទេសកម្ពុជា ពិតជាមិនអាចទៅរួចទេ។

សូមមើលជំពូក ១៤ សម្រាប់អនុសាសន៍ពេញលេញទាំងស្រុង។

# វិធីសាស្ត្រ

*របាយការណ៍នេះ យោងទៅតាមការសម្ភាសន៍ផ្ទាល់ រួមមានមន្ត្រីស៊ីវិល និងយោធាជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជា សមាជិកយោធា និងនគរបាល មន្ត្រីរាជការ ចៅក្រម ព្រះរាជអាជ្ញា អ្នកការទូតបរទេសនិងកម្ពុជា អ្នកកាសែតបរទេស និងកម្ពុជា និងអ្នកធ្វើការផ្នែកសិទ្ធិមនុស្ស អ្នកសិក្សា ព្រមទាំងអ្នកដទៃទៀតដែលក្នុងចំណោមអ្នកទាំងនោះ ក៏បានផ្ដល់ប្រភពព័ត៌មានដោយបើកចំហ និងឯកសារផ្សេងៗទៀតរបស់ពួកគេ។ លើសពីនេះទៀត របាយការណ៍នេះ ពឹងផ្អែកខ្លាំងទៅលើឯកសារបោះពុម្ពផ្សាយ ហើយក្នុងករណីខ្លះក៏ពឹងផ្អែកឯកសារ ដែលមិនបានបោះពុម្ពផ្សាយ ជាភាសាអង់គ្លេស ភាសាខ្មែរ វៀតណាម ចិន និងបារាំង រួមទាំងរបាយការណ៍សារព័ត៌មានតាមអ៊ីនធឺណេត និងបោះពុម្ពផ្សាយ តាមសៀវភៅនិងទស្សនាវដ្ដី និងឯកសារដែលបានផ្សព្វផ្សាយ ឬដាក់នៅក្នុងបណ្ណសារនៃរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលដទៃទៀត ដោយអង្គការសហប្រជាជាតិ និងអង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិ។ ឯកសារទាំងនេះរួមមានទិន្នន័យមូលដ្ឋាន ដែលបានបង្កើតជាមូលដ្ឋានសម្រាប់របាយការណ៍ស្ដីពីសិទ្ធិមនុស្ស និងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធនានានៅកម្ពុជា ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០ រហូតមកដល់ពេលបច្ចុប្បន្ន និងស្ថិតនៅក្នុងការចងក្រងជាឯកសារ ជាមួយអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិយូមែនរ៉ៃត៍វ៉ច្ឆ* (Human Rights Watch)។ *អត្ថបទនៃបទសម្ភាសន៍ជាច្រើនមាននៅក្នុងបញ្ជីឯកសាររបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ។*

*ដោយសារតែកំណើនគាបសង្កត់របស់រដ្ឋាភិបាលទៅលើអង្គការសិទ្ធិមនុស្សក្នុងស្រុក រួមទាំងការចាប់ខ្លួនតាមតែអំពើចិត្ត និងការរំលោភបំពានលើរូបរាងកាយទៅលើបុគ្គលិករបស់ពួកគេ ព័ត៌មានជាក់លាក់ពីប្រភពអង្គការទាំងនេះ ត្រូវបានលុបចេញពីរបាយការណ៍នេះ។ ហេតុដូចនេះ ជំនួសឱ្យឈ្មោះចំៗនៃអង្គការទាំងនោះ យើងប្រើឃ្លាថា «អង្គការសិទ្ធិមនុស្សក្នុងស្រុក» ដើម្បីយោងឬបញ្ជាក់ពីប្រភពឯកសាររបស់ពួកគេ។*

*ដោយសារតែការរំលោភបំពានទៅលើសកម្មភាពនិយមសិទ្ធិមនុស្ស សារព័ត៌មាន និងការស្រាវជ្រាវមិនប្រកាន់បក្សនយោបាយដទៃទៀតនៅក្នុងប្រទេសកម្ពុជា ឈ្មោះអ្នកសំភាសន៍ អ្នកផ្ដល់បទសំភាសន៍ និងអត្តសញ្ញាណព័ត៌មានអំពីពួកគេ អ្នកនិពន្ធមិនបង្ហាញជូនទេ គឺដើម្បីការពារពួកគេពីការសងសឹក ដែលអាចកើតមានពីអាជ្ញាធរ ដោយរួមទាំងលោក ហ៊ុន សែន និងមេបញ្ជាការកងកម្លាំងសន្តិសុខជាន់ខ្ពស់ ដែលជា*

ប្រធានបទនៃរបាយការណ៍នេះ។ ការមានប្រភពព័ត៌មានមិនពេញលេញណាមួយ នៅក្នុងលេខយោង គឺដើម្បីការពារប្រភពទាំងនេះ។

ដូចគ្នានេះផងដែរ ព័ត៌មានមួយចំនួនរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ក៏បានទាញយកពីប្រព័ន្ធផ្សព្វផ្សាយតាមអ៊ិនធឺរណែតជាភាសាវៀតណាម និងភាសាខ្មែរ ដែលបានបោះពុម្ពផ្សាយថ្មីៗនេះ និងប្រភពព័ត៌មានតាមអ៊ីនធឺណិតផ្សេងទៀត ត្រូវបានដកស្រង់យកមកដាក់ក្នុងរបាយការណ៍ ដែលក្នុងករណីខ្លះប្រហែលជាលែងមាននៅលើអ៊ីនធឺណិតតទៅទៀតហើយ។

# សាវតា

## *កងកម្លាំងប្រដាប់អាវុធកម្ពុជាឆ្នាំ ១៩៧៨ ដល់បច្ចុប្បន្ន*

### *ការបះបោរប្រឆាំងប៉ុល ពត មុនខែមករា ឆ្នាំ ១៩៧៩*

*កងយោធពលខេមរភូមិន្ទបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជា គឺជាអ្នកស្នងបន្តពីកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានបង្កើតឡើងនៅឆ្នាំ១៩៧៩ ក្រោយពីការឈ្លានពាននៃកងទ័ពវៀតណាមមកលើប្រទេសកម្ពុជា ដែលនាំឱ្យមានការដួលរលំនៃគណបក្សកុម្មុយនីស្តកម្ពុជា (CPK) ដែលគេនិយមហៅថា របបខ្មែរក្រហម។*

*កងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា បានកើតចេញពីកងកម្លាំងទ័ពព្រៃប្រឆាំងនឹងការគ្រប់គ្រងរបស់ខ្មែរក្រហម។ ក្រុមបះបោរទាំងនេះ បានធ្វើប្រតិបត្តិការនៅព្រំប្រទល់កម្ពុជាជាមួយវៀតណាម ឡាវ និងថៃ តាំងពីមុនគណបក្សកុម្មុយនីស្តកម្ពុជា(CPK) ខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ទៅទៀត។ ក្រោមការជួយឧបត្ថម្ភរបស់វៀតណាម អង្គភាពផ្លូវការជាលើកដំបូងត្រូវបានបង្កើតឡើងនៅថ្ងៃទី ២២ ខែមេសាឆ្នាំ ១៩៧៨។*

*ក្នុងចំណោមប្រជាជនកម្ពុជាដំបូងគេ ដែលបានរៀបចំ និងដឹកនាំកងកម្លាំង និងអង្គភាពទាំងនេះ គឺជាពួកកុម្មុយនិស្តដែលបានចំណាយពេលជាច្រើនឆ្នាំនៅប្រទេសវៀតណាម ដែលអ្នកខ្លះបានទៅរស់នៅទីនោះតាំងពីឆ្នាំ១៩៥៤ ចំណែកអ្នកខ្លះទៀតបានរត់គេចខ្លួន ឬបំបែកខ្លួនចេញពីខ្មែរក្រហមប៉ុល ពត មុនខែមេសាឆ្នាំ ១៩៧៥។ នេះរាប់បញ្ចូលទាំងមន្ត្រីរដ្ឋាភិបាលកម្ពុជានាពេលអនាគត ដូចជាលោក ប៉ែន សុវណ្ណ លោក ចាន់ ស៊ី លោក ខាង សារិន  លោកសយ កែវ និងប៊ូ ថង។ ក្រោយមក ក៏មានការចូលរួមពីអ្នកដែលបានរត់ចោលបក្សកុម្មុយនិស្តកម្ពុជាបន្ថែមទៀត ដែលភាគច្រើនគឺអ្នករត់គេចពីការបោសសំអាតរបស់ខ្មែរក្រហម ។ ឧទាហរណ៍ ក្នុងខែឧសភា ឆ្នាំ១៩៧៨ អតីតអនុប្រធានវរៈសេនាធិការកណ្តាលខ្មែរក្រហមតំបន់បូព៌ាទី២១ គឺលោក ហ៊ុន សែន ដែលបាននៅវៀតណាមតាំងពីខែមិថុនាឆ្នាំ១៩៧៧ ក៏បានចូលរួមផងដែរ។ ចាប់តាំងពីខែ*

*កញ្ញា ឆ្នាំ១៩៧៨ អង្គការចាត់តាំងប្រឆាំងនឹងខ្មែរក្រហមប៉ុល ពតនៅក្នុងប្រទេសវៀតណាម ត្រូវបានចូលរួមដោយអតីតសមមិត្តទាហានដទៃទៀតនៃកងទ័ពខ្មែរក្រហមនៅភាគខាងកើត ដែលក្នុងនោះមានសមមិត្តអតីតអនុប្រធានអគ្គសេនាធិការនៃភូមិភាគបូព៌ាលោក ហេង សំរិន និង លោក ប៉ុល សារឿន។*

*ខណៈការរៀបចំបង្កើតនូវទីបញ្ជាការដ្ឋានមួយសម្រាប់បញ្ជាអង្គភាពនានានៃកងទ័ពកម្ពុជា មិនទាន់បានសម្រេចពេញលេញនៅឡើយ កងទ័ពវៀតណាមបានបើកការវាយឈ្លានពានទ្រង់ទ្រាយធំ ដើម្បីផ្តួលរលំរបបខ្មែរក្រហមប៉ុលពត នៅថ្ងៃទី ២៥ ខែធ្នូឆ្នាំ១៩៧៨ ហើយបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ៧ ខែមករាឆ្នាំ ១៩៧៩។*[6]

*ដោយមិនអើពើនឹងការចូលរួមប្រឹងប្រែងរបស់អ្នកដទៃ លោក ហ៊ុន សែន បានអះអាងថា កងយោធពលខេមរភូមិន្ទបច្ចុប្បន្ន មានដើមកំណើតនៅក្នុងកងកម្លាំងប្រដាប់អាវុធកម្ពុជា ដោយគាត់ និងជំនួយការមួយចំនួនបានជួយបង្កើតចំណុះឱ្យគណៈបញ្ជាការ "៥៧៨" ដែលបានបង្កើតឡើងនៅខែឧសភា ឆ្នាំ១៩៧៨ ដែលមានលោក ហ៊ុន សែន ជាមេបញ្ជាការយោធានៃគណៈបញ្ជាការ។*[7] *នេះគ្រាន់តែជាផ្នែកមួយនៃរចនាសម្ព័ន្ធបញ្ជាការធំជាងគេមួយ ដែលដឹកនាំដោយមន្ត្រីកងទ័ពវៀតណាម។ កងទ័ពរបស់គណៈបញ្ជាការ រួមមានកងឯកភាពតូចៗមួយចំនួននៃកងវរសេនាតូច ដូចជាកងវរសេនាតូចលេខ១២៥ កងវរសេនាតូចលេខ២២៦ និងកងវរសេនាតូចលេខ២០៧ ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៨។ ទោះជាយ៉ាងក៏*

---

[6] លោក បិន ឃីណាន របបប៉ុលពត ៖ ការប្រណាំងប្រជែងអំណាចនិងការប្រល័យពូជសាសន៍នៅកម្ពុជា ក្រោមរបបខ្មែរក្រហម 1975-78 (បោះពុម្ពលើកទី 3) (New Haven: សារព័ត៌មានសាកលវិទ្យាល័យយេលឆ្នាំ 2008), ទំព័រ 392-411, 440-442; លោក Timothy Carney, "កងកម្លាំងប្រដាប់អាវុធរបស់ហេងសំរិននិងតុល្យភាពយោធានៅក្នុងប្រទេសកម្ពុជា  លេខ) ទិនានុប្បវត្តិនយោបាយអន្តរជាតិ"16 លេខ 3: ឆ្នាំ 1986) ទំព័រទី 153-160 ។ ប៉ែនសុវណ្ណ និងនាងសារុន, ប៉ែនសុវណ្ណ ៖ ជីវប្រវត្តិសង្ខេបនិងបុព្វហេតុនៃជាតិនិងមាតុភាពកម្ពុជា (*pensvoanchivapravoat neungbophahetcheat meatophoumKampuchea*( (ស៊ីថល ៖ ភាសាខ្មែរ ឆ្នាំ 2002) ទំព័រ 129-154; កាសែតភ្នំពេញប៉ុស្តិ៍ពីថ្ងៃទី 16 ដល់ថ្ងៃទី 29 ខែឧសភាឆ្នាំ 1997 " http://www.phnompenhpost.com/national/pen-sovann-out-settle-old-scores, បានចូលដំណើរការនៅថ្ងៃទី 12 ខែតុលាឆ្នាំ 2012; ហេងសំរិន, សម្តេចមហាពញ្ញាចក្រី ហេង សំរិន (s*amdech akkeakmohaponheachakreihengsamrin* អារ្យធម៌ ឆ្នាំ :ភ្នំពេញ) (2013) ទំព័រទី 99-152; Merle L. Pribbenow II "រឿងនិទានឧត្តមសេនីយ៍ប្រាំរូប ៖ ការឈ្លានពានរបស់វៀតណាមនៅកម្ពុជា" ទិនានុប្បវត្តិប្រវត្តិសាស្ត្រយោធា  លេខ)70 ៖ ខែមករាឆ្នាំ 2006) ទំព័រ 459-484 ។

[7] ហ៊ុនសែន ថ្លែងសុន្ទរកថានៅខួបលើកទី 4 នៃទិវាអតីតយុទ្ធជនកម្ពុជាថ្ងៃទី 21 ខែមិថុនាឆ្នាំ 2011  http://cnv.org.kh/address-at-the- 4th-anniversary-of-cambodian-veterans-day/(ចូលមើលថ្ងៃទី 28 ខែសីហាឆ្នាំ 2012) ។ ហ៊ុនសែន  មតិយោបល់ដែលបានជ្រើសរើស នៅឯការប្រារព្ធខួបឆ្នាំទី"4 នៃអតីតយុទ្ធជនកម្ពុជា ថ្ងៃទី "21 ខែមិថុនាឆ្នាំ 2011 ។ http://cnv.org.kh/selected-comments-at-the- celebration-of-the-4th-anniversary-of-the-cambodian-war-veterans/ (ចូលមើលថ្ងៃទី 28 ខែសីហាឆ្នាំ 2012)។

*ដោយ ពួកគេមិនមានកម្លាំងពេញលេញទេ ហើយចំនួនកម្លាំងទាហ៊ានក្រោមបញ្ជារបស់លោក ហ៊ុន សែន ដែលត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវក្នុងការប្រយុទ្ធនៅក្នុងផ្នែកខាងកើតនៃទន្លេមេគង្គ គឺមានត្រឹមតែ ១០០ នាក់ប៉ុណ្ណោះ។*[8]

*ពលទាហានទាំងនេះ និងអង្គភាពដទៃទៀត ដែលបានបង្កើតឡើងក្រោមការជួយឧបត្ថម្ភរបស់វៀតណាម ក្នុងអំឡុងពេលសេសសល់នៃឆ្នាំ១៩៧៨ និងមុនថ្ងៃទី៧ ខែមករាឆ្នាំ១៩៧៩ បានចូលរួមជាផ្នែកតូចមួយនៅក្នុងការឈ្លានពានរបស់វៀតណាម។ ហើយសម្រាប់គោលបំណងឃោសនា កងទ័ពវៀតណាមខ្លះបានក្លែងខ្លួនជាកងទ័ពកម្ពុជា ធ្វើសកម្មភាពត្រួសត្រាយផ្លូវសម្រាប់កំណើតនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា* (PRK) *។*[9] *កងកម្លាំងទាំងនេះក្រោយមកបានបង្កើតជាផ្នែកស្នូលនៃកងយោធាក្រោយថ្ងៃ៧មករា របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា* (PRK) *។ ទោះជាយ៉ាងណា គណៈបញ្ជាការ ៥៧៨ ត្រូវបានរំលាយ។*[10] *នៅថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៨ លោក ហ៊ុន សែន ត្រូវបានចាត់តាំងជាថ្មីឲ្យទទួលបន្ទុកកិច្ចការយុវជននៅក្នុងអង្គការចាត់តាំងនយោបាយប្រឆាំងនឹងប៉ុលពត ដែលគេនៅតែដាក់បញ្ចូលគ្នានៅវៀតណាម ក្នុងគ្រានោះ។*[11] *បើទោះជាកងទ័ពវៀតណាមដណ្តើមបានទីក្រុងភ្នំពេញពីខ្មែរក្រហមប៉ុល ពត នៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ក៏ដោយ ក៏អនាគតមេដឹកនាំរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមានលោក ហ៊ុន សែន និងកម្មាភិបាលផ្សេង*

---

[8] សុន្ទរកថាសាធារណៈដោយហ៊ុនសែនថ្ងៃទី 22 ខែសីហាឆ្នាំ 2016https://www.facebook.com/hunsencambodia/videos/1078918852156611/ (ចូលមើលថ្ងៃទី 24 ខែសីហាឆ្នាំ 2016).

[9] អនាមិក, ផ្សាយតាម Facebook ("BTC I. ការរំដោះ ជំពូកទី "11: កម្ពុជា  លេខ)29) "(BTC I. " Giai Phóng "Chuong Xi: Campuchia [#29])16 ខែសីហាឆ្នាំ 2015, https://www.facebook.com/notes/vi%E1%BB%87t-nam/btc-i-gi%E1%BA%A3i-ph%C3%B3ng-ch%C6%B0%C6%A1ng-xi-campuchia-29/501606653255069/ (ចូលមើលថ្ងៃទី 20 ខែធ្នូឆ្នាំ 2015) ។

[10] "ជាផ្នែកមួយនៃប្រវត្តិសាស្ត្រដែលមិនអាចបំភ្លេចបាន"(M9t phan lich sU' không the lãng quên, Quân đ9i nhân dân [QDND]), January 2, 2012, http://www.qdnd.vn/qdndsite/vi-vn/61/43/khoa-hoc-nghe-thuat-quan-su/mot-phan-lich-su-khong-the-lang-quen-/171869.html (ចូលមើលថ្ងៃទី 21 ខែមករាឆ្នាំ 2016) ។ "Re: កងទ័ពស្ម័គ្រចិត្តវៀតណាមនិងអ្នកជំនាញយោធានៅក្នុង K ៖ ចម្លើយ # 16, បង្ហោះនៅថ្ងៃ 4 ខែមិថុនា 2010," http://www.vnmilitaryhistory.net/index.php?PHPSESSID=2snlb039tfo3tjtvbc6hhtb212&topic=16326.msg229387#msg2293 87 (ចូលមើលថ្ងៃទី 4 ខែមករាឆ្នាំ 2015) ។ "ឯកសារស្តង់ដារ កងទ័ពស្ម័គ្រចិត្តវៀតណាមនិងអ្នកជំនាញខាងយោធានៅតំបន់ :K (II)" (Tài li�u chuein: Quân tình nguy�n và Chuyên gia quân s11 Vi�t Nam tqi K [II]), ថ្ងៃទី 7 ខែវិច្ឆិកាឆ្នាំ 2014 http://nguoidongbang.blogspot.com/2014/11/tai-lieu-chuan-quan-tinh-nguyen-va_7.html (ចូលមើលថ្ងៃទី 4 ខែមករាឆ្នាំ 2015) 3: វេទិកាស្មា " ស្មា - គាក -(Kỳ 3: Ke vai sát cánh trong hoqn nqn), Quân đ9i nhân dân, ថ្ងៃទី 27 ខែធ្នូឆ្នាំ 2013, http://www.qdnd.vn/qdndsite/vi-vn/61/43/35-nam-ngay-quan-tinh-nguyen-viet-nam-giup-nhan-dan-campuchia-thoat-khoi- hoa-diet-chung/ky-3-ke-vai-sat-canh-trong-hoan-nan/280706.html (ចូលមើលថ្ងៃទី 5 ខែមករាឆ្នាំ 2015); Carney, ទំព័រ "កងទ័ពប្រដាប់អាវុធរបស់ហោងសំរិន" ទី166 ។

[11] ប៉ែនសុវណ្ណ, ជីវប្រវត្តិសង្ខេប ទំព័រ.148 ។

ទៀតស្ថិតនៅក្នុងប្រទេសវៀតណាមនៅឡើយ រហូតដល់ចុងខែមករា ឬដើមខែកុម្ភៈ ឆ្នាំ១៩៧៩ នៅពេលដែលវៀតណាម បានដឹកពួកគេតាមយន្តហោះមកកម្ពុជា ដើម្បីចាប់ផ្តើមចូលរួមនៅក្នុងការគ្រប់គ្រងប្រទេស។ លោក ហ៊ុន សែន ត្រូវបានតែងតាំងជារដ្ឋមន្ត្រីការបរទេស។

អំឡុងពេលមួយទសវត្សរ៍ក្រោយមក យោងតាមកំណត់ត្រាផ្លូវការរបស់វៀតណាម និងកម្ពុជា កងទ័ពវៀតណាមមានវត្តមាននៅលើទឹកដីកម្ពុជាមានចំនួន ២០០,០០០នាក់ (ពីរសែននាក់) និងមន្ត្រីវៀតណាម ១០,០៩៥ នាក់ (មួយម៉ឺនកៅសិបប្រាំនាក់) ដាក់ពង្រាយនៅទូទាំងប្រទេស ដើម្បីការពារ និងជួយស្ថាបនារចនាសម្ព័ន្ធរបស់របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា រួមទាំងគណកម្មាធិការមជ្ឈឹមបក្ស ក្រសួងរដ្ឋថ្នាក់ជាតិ ខេត្តក្រុង និងជាពិសេស នៅក្នុងផ្នែកយោធា សន្តិសុខ និងផ្នែកកិច្ចការបរទេស។[12] ការពិគ្រោះយោបល់កិច្ចការសំខាន់ៗកម្រិតខ្ពស់រវាងសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងមេដឹកនាំវៀតណាមបានធ្វើឡើងញឹកញាប់។ យ៉ាងហោចណាស់ក្នុងគ្រាដំបូងៗ មន្ត្រីខ្មែរនៃរបបថ្មីនេះ គឺពឹងផ្អែកស្ទើរតែទាំងស្រុងលើវៀតណាម។ ដូចកំណត់ត្រារបស់វៀតណាមបង្ហាញថា "កម្មាភិបាល និងជំនាញការរបស់យើងធ្វើអ្វីៗគ្រប់បែបយ៉ាងទាំងអស់ដោយធ្វើជាមេផង និងអ្នកបម្រើផង ក្នុងដំណើរការកសាងរបបថ្មីមួយ គឺជួយរៀបចំរចនាសម្ព័ន្ធពីថ្នាក់កំពូលរហូតដល់ថ្នាក់ក្រោម"។[13] ប្រវត្តិកំណត់ត្រារបស់មន្ត្រីវៀតណាមផ្សេងទៀតក៏រំលឹកដែរថា វៀតណាមបានជួយបង្កើតកងកម្លាំងសន្តិសុខ ដែលចំណុចនេះត្រូវបានបញ្ជាក់ក្នុងប្រវត្តិផ្ទៃក្នុងរបស់គណបក្សកម្ពុជាទាក់ទងនឹងកងទ័ពនិងនគរបាល។[14]

និយាយពីមន្ត្រីវៀតណាម ដែលបំពេញភារកិច្ចនៅកម្ពុជា ឯកសារផ្ទៃក្នុងមួយរបស់ក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី

---

[12] Huỳnh Anh Dũng, "កំណត់សម្គាល់អំពីកម្ពុជា )1975-1991)" (Ghi chép ve Campuchia [1975-1991]), http://vietsuky.wordpress.com/2012/12/01/220-ghi-chep-ve-campuchia-1975-1991-1/ (បានចូលដំណើរការនៅថ្ងៃទី 20 ខែមិថុនាឆ្នាំ 2015) ។ គណបក្សប្រជាជនកម្ពុជា, ប្រវត្តិនៃការតស៊ូនិងការអភិវឌ្ឍន៍នៃមាតុភូមិកម្ពុជា និងទំនាក់ទំនងកម្ពុជា  វៀតណាមពីឆ្នាំ -1989 ដល់ឆ្នាំ 2013 (pravoat ney kar ta-sou neung aphivoat meatophoum kampuchea neung tumneak-tumnorng kampuchea- vietnam pi chhnam 1989 dal chhnam 2013) (រាជធានីភ្នំពេញឆ្នាំ 2015) ទំព័រទី 8-9, 221-230

[13] Huỳnh Anh Dũng, កំណត់សម្គាល់អំពីកម្ពុជា (1975-1991).

[14] Nguyen Văn Hong, សង្គ្រាមដែលមិនត្រូវការ :Memoir មួយ (Cu9c Chie'n Tranh Bat Bu9c: Hoi Uc) (Ho Chi Minh City: Nhà Xuat Ban Tre, *2004*), p.99; Tran Xuân Ban, et al., ប្រវត្តិនៃកងពលថ្មើរជើងទី 7 (1966-2006) (Lich sU' SU đoàn b9 binh 7 [1966-2006]), http://www.quansuvn.net/index.php?topic=4304.120 ប្រវត្តិនៃកងពលតូចទី 7 (1966-2006); Tran Bá Điem, et al., ប្រវត្តិនៃកងពលថ្មើរជើងទី 330 / តំបន់យោធា 9 (1976-2001) (ការចែកចាយផ្ទៃក្នុង( (Lich SU' SU Đoàn B9 Binh 330 Quân Khu 9 [1976-2001] [LUu ành N9i B9]) (Ha Noi: Nhà xuat ban quân đôi nhân dân, 2004), pp.84-116; CPP, ប្រវត្តិនៃការតស៊ូ, pp.39-52

*នៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និយាយថា "យើងគួរតែពិភាក្សាកិច្ចការទាំងអស់ជាមួយសមមិត្តទីប្រឹក្សា។ ថ្វីដ្បិតថ្ងៃងមតិយោបល់របស់ទីប្រឹក្សា(ជំនាញការ)បរទេសឱ្យបានម៉ត់ចត់។ រាល់ការងារនៅគ្រប់ជាន់ថ្នាក់ និងគ្រប់ផ្នែកទាំងអស់ យើងគួរតែពិភាក្សាជាមួយទីប្រឹក្សាបរទេស ដើម្បីឱ្យមានការឯកភាពគ្នាក្នុងកម្មវិធី និងផែនការសកម្មភាពប្រចាំសប្តាហ៍ និងប្រចាំខែ[15]" ។ មន្ត្រីសន្តិសុខជាន់ខ្ពស់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជាមួយរូប បានរំឭកថា "ការសន្ទនាគ្នារវាងមន្ត្រីវៀតណាម និងមន្ត្រីកម្ពុជា ពិតជាមាន ក៏ប៉ុន្តែអ្វីដែលទីប្រឹក្សា (វៀតណាម) និយាយចេញមក យើងត្រូវតែធ្វើតាម"។[16]*

## *ការបង្កើតកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា* (RPAFK)

*ការចូលមកដល់កម្ពុជាពីប្រទេសវៀតណាមមុនមន្ត្រីកម្ពុជាដទៃទៀត គឺលោក ប៉ែន សុវណ្ណ លេខាទីមួយនៃបក្សកុម្មុយនីស្តកម្ពុជា ដែលកាលនោះ នៅតែជាអង្គការសម្ងាត់នៃបក្សកុម្មុយនិស្តរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានលេចមុខក្នុងឆ្នាំ១៩៨១ ជាបក្សប្រជាជនបដិវត្តន៍កម្ពុជា* (RPPK) *ដែលមានសមាជិកតែ ៨៣៩ នាក់ប៉ុណ្ណោះនៅពេលនោះ។ រហូតមកដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ ទើបសមាជិករបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា អាចប្រជំប្រសងជាមួយចំនួនមន្ត្រីវៀតណាមនៅក្នុងប្រទេស។[17]*

*នៅឆ្នាំ១៩៧៩ មុនពេលដែលបក្សប្រជាជនបដិវត្តន៍កម្ពុជាបង្ហាញខ្លួន លោក ប៉ែន សុវណ្ណ គឺជារដ្ឋមន្ត្រីក្រសួងការពារជាតិនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដំបូងគេ និងជាអគ្គមេបញ្ជាការកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា។[18] បន្ទាប់មកលោកបានក្លាយជាប្រធានក្រុមប្រឹក្សានៃក្រុមប្រឹក្សារដ្ឋមន្ត្រី(រដ្ឋមន្ត្រី) រហូតដល់ថ្ងៃ*

---

[15] Evan Gottesman, ប្រទេសកម្ពុជាបន្ទាប់ពីខ្មែរក្រហម ៖ នៅខាងក្នុងនយោបាយកសាងជាតិ (New Haven: សារព័ត៌មានសាកលវិទ្យាល័យយ៉េល 2002) ទំព័រ 143-144 ។

[16] លោកបប្រែដ អាដាំស៍ សម្ភាសជាមួយស៊ិន សែនថ្ងៃទី 20 ខែឧសភាឆ្នាំ 2002 ។

[17] ប៉ែនសុវណ្ណ ប៉ែនសុវណ្ណ ៖ សង្ខេបជីវប្រវត្តិ, ទំព័រ 155-157; សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK)"ការសម្រេចចិត្តលើបញ្ហារបស់កម្មាភិបាល" (sechkdey samrech ampi panhaha kammaphibal) ចុះហត្ថលេខា លេខាទី"1" ចុះកាលបរិច្ឆេទតាមបរិបទដល់ដើមឆ្នាំ 1979 ។ SPK [ទីភ្នាក់ងារសារព័ត៌មានផ្លូវការរបស់រដ្ឋាភិបាលដូចដែលបានតាមដាននៅក្នុងការដកស្រង់ខាងក្រោមនេះនិងក្រោមការផ្សាយរបស់ក្រសួងផ្សាយព័ត៌មានសហរដ្ឋអាមេរិក ថ្ងៃទី 3 ខែកក្កដាឆ្នាំ 1979) ។ គណបក្សប្រជាជនកម្ពុជា, ប្រវត្តិនៃការតស៊ូ, ទំព័រ 188, 20-21

[18] SPK, 19 មករា 1979; ប៉ែនសុវណ្ណ, ជីវប្រវត្តិសង្ខេប, ទំព័រ 16 ។ វិទ្យុទីក្រុងភ្នំពេញថ្ងៃទី 6 ខែមករាឆ្នាំ 1979 (ដែលត្រូវបានតាមដាននិងដកស្រង់ពីការផ្តល់ជូនដោយសេវាកម្មព័ត៌មានបរទេសរបស់អាមេរិក។

ដែលគេកំចាត់គាត់ចេញនៅថ្ងៃទី ២ ធ្នូ ឆ្នាំ១៩៨១ ជាពេលដែលលោកត្រូវបានចាប់ខ្លួន។ លោក ប៉ែន សុវណ្ណ ចោទថា លោក ហ៊ុន សែន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចាប់ខ្លួនលោកនៅក្នុងទីក្រុងភ្នំពេញ ហើយបញ្ជូនទៅដាក់ពន្ធនាគារអស់ជាច្រើនឆ្នាំនៅក្នុងប្រទេសវៀតណាម។[19]

ក្នុងអំឡុងពេលកាន់អំណាចដ៏ខ្លីរបស់គាត់ លោក ប៉ែន សុវណ្ណ បានធ្វើការជាមួយវៀតណាម ដើម្បីកសាងកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា(RPAFK) ចាប់ពីក្រសួងការពារជាតិ ចុះរហូតដល់កងពលធំ និងអង្គភាពតូចៗនៅគ្រប់កម្រិត។[20] នៅខាងភាគីកម្ពុជា ការងារនេះត្រូវបានអនុវត្តដោយអគ្គសេនាធិការកំពូលរបស់កងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា ដែលស្ថិតនៅក្រោមក្រសួងការពារជាតិ។ ក្រសួងការពារជាតិ ត្រូវបានបែងចែកទៅជាបីអង្គភាពសំខាន់ៗក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា៖ អគ្គសេនាធិការ អគ្គស្នងការដ្ឋាននយោបាយ និងអគ្គស្នងការភស្តុភា។[21] អគ្គស្នងការដ្ឋាននយោបាយ ទទួលខុសត្រូវក្នុងការធានាភាពស្មោះត្រង់របស់កងកម្លាំងប្រដាប់អាវុធចំពោះបក្សកាន់អំណាច ក្នុងគោលដៅសម្រេចឲ្យបានការត្រួតត្រាផ្នែកនយោបាយ ១០០ ភាគរយលើកងទ័ព ចាប់ពីថ្នាក់កំពូលរហូតទៅដល់ថ្នាក់ក្រោម។[22]

អ្នកដែលត្រូវបានគេតែងតាំងដំបូងគេ ជាមេអគ្គសេនាធិការ គឺលោក សយ កែវ ដែលត្រូវបានជំនួសភ្លាមនៅពាក់កណ្តាលឆ្នាំ១៩៨១ ដោយលោក ខាង សារិន ប៉ុន្តែក្រោយមក បានបន្តតំណែងនេះវិញ។[23] ខ្សែសង្វាក់បញ្ជាការត្រូវបានបង្កើតឡើង ដែលមានកងពលធំនៃកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា ថ្នាក់ជាតិ និងអង្គភាពឯកទេសតូចៗ ហើយកងកម្លាំងបដិវត្តន៍ប្រជាជនកម្ពុជាថ្នាក់ក្រុងនិងខេត្ត ត្រូវបានដាក់អមនិងឲ្យស្ថិតក្រោមក្រសួងការពារជាតិ និងអគ្គសេនាធិការ។[24] អគ្គសេនាធិការបំពេញមុខងារជាទីបញ្ជាការដ្ឋានកណ្តាលរបស់

---

[19] "ប៉ែនសុវណ្ណ ចេញដើម្បីដោះស្រាយពិន្ទុចាស់ វិទ្យុភ្នំពេញថ្ងៃទី "21 ខែកក្កដាឆ្នាំ 1981 ។ ប៉ែនសុវណ្ណ, ជីវប្រវត្តិសង្ខេប, ទំព័រ.215-217; ភ្នំពេញប៉ុស្ត៍ចាប់ពីថ្ងៃទី 16 ដល់ថ្ងៃទី 29 ខែឧសភា ឆ្នាំ 1997 ។

[20] វិទ្យុភ្នំពេញថ្ងៃទី 18 ខែមិថុនាឆ្នាំ 1980 ខានី  ទំព័រទី "កងទ័ពប្រដាប់អាវុធរបស់ហេងសំរិន"157-167

[21] ប៉ែនសុវណ្ណ, ជីវប្រវត្តិសង្ខេប ទំព័រ.215; SPK, ថ្ងៃទី៣ ខែមេសា 1979; SPK ថ្ងៃទី 26 ខែកក្កដាឆ្នាំ1979; វិទ្យុភ្នំពេញថ្ងៃទី30 ខែមករាឆ្នាំ1989 ។

[22] វិទ្យុភ្នំពេញ 22, ថ្ងៃទី 8 ខែធ្នូឆ្នាំ 1979; SPK, ថ្ងៃទី 1 ខែមីនាឆ្នាំ 1980; វិទ្យុភ្នំពេញថ្ងៃទី 5 ខែមិនាឆ្នាំ 1980 ។ វិទ្យុភ្នំពេញថ្ងៃទី 23 ខែមេសាឆ្នាំ 1980 វិទ្យុភ្នំពេញថ្ងៃទី 26 ខែមេសាឆ្នាំ 1980 គណបក្សប្រជាជនកម្ពុជា, ប្រវត្តិសាស្ត្រនៃការតស៊ូ, p.22 ។

[23] វិទ្យុភ្នំពេញថ្ងៃទី 8 ខែមេសាឆ្នាំ 1979, ប៉ែនសុវណ្ណ, ជីវប្រវត្តិសង្ខេប, ទំព័រ 155-157; សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) សេចក្តីសម្រេចចិត្តលើ ["បញ្ហានៃសមមតិត្ n.d.] ; SPK ថ្ងៃទី 3 ខែកក្កដាឆ្នាំ 1979; វិទ្យុភ្នំពេញថ្ងៃទី 9 ខែតុលាឆ្នាំ 1981

[24] វិទ្យុភ្នំពេញថ្ងៃទី 4 ខែមិថុនាឆ្នាំ 1982 ។ វិទ្យុភ្នំពេញថ្ងៃទី 16 ខែកក្កដាឆ្នាំ 1982 ។ វិទ្យុភ្នំពេញថ្ងៃទី 19 ខែមីនាឆ្នាំ 1981 ។

ក្រសួងសម្រាប់សម្របសម្រួលរាល់កិច្ចការប្រចាំថ្ងៃទាំងអស់ រាប់បញ្ចូលទាំងការចេញបញ្ជាទៅកងកម្លាំងប្រដាប់អាវុធ។[25]

ប៉ុន្តែ កងកម្លាំងប្រដាប់អាវុធថ្នាក់ក្រោមជាតិ ស្របពេលគ្នានេះដែរ ក៏ស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងរបស់ "គណៈបញ្ជាការឯកភាព" ដឹកនាំដោយគណបក្សប្រចាំមូលដ្ឋាន និងប្រធានរដ្ឋបាលមូលដ្ឋានដែលទទួលខុសត្រូវធ្វើសកម្មភាពជាមួយនគរបាល និងកងជីវពលនៅសមរភូមិក្រោយ។[26] នេះឆ្លុះបញ្ចាំងពីការពិតដែលថា បន្ថែមលើតួនាទីប្រយុទ្ធនៅសមរភូមិរបស់ខ្លួន ក្នុងការវាយប្រហារសំណល់ខ្មែរក្រហមប៉ុលពត កងទ័ពបដិវត្តន៍ប្រជាជនកម្ពុជាក៏ទទួលខុសត្រូវផងដែរលើ "សណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈ។"[27]

រចនាសម្ព័ន្ធនយោបាយ និងយោធាភាគច្រើនរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានគេរៀបចំឱ្យស្របតាមពេលវេលាដែលរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានអនុម័តក្នុងខែមិថុនាឆ្នាំ១៩៨១។ នៅពេលដែលខ្មែរក្រហមធ្វើសង្គ្រាមទ័ពព្រៃនៅតាមបណ្តោយព្រំដែនថៃ ដោយមានការគាំទ្រផ្ទាល់ពីប្រទេសថៃ និងចិន ហើយយ៉ាងហោចណាស់ មានការគាំទ្រដោយប្រយោលពីសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងប្រទេសដទៃទៀត រដ្ឋធម្មនុញ្ញបានកំណត់បក្សប្រជាជនបដិវត្តន៍កម្ពុជា (RPPK) ថាជា "កម្លាំងផ្ទាល់ដែលដឹកនាំទាំងស្រុងនូវរាល់ការកិច្ចបដិវត្តន៍នៅក្នុងប្រទេស"។ រដ្ឋធម្មនុញ្ញកំណត់ថា ប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺជាអគ្គមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធ ប៉ុន្តែពុំមានចែងអំពីអំណាចបញ្ជាឡើយ។
រដ្ឋធម្មនុញ្ញកំណត់អាណត្តិនៃក្រុមប្រឹក្សារដ្ឋមន្ត្រីរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ថាជារដ្ឋាភិបាល-"ជាអង្គការគ្រប់គ្រងដោយផ្ទាល់លើវិស័យសង្គម និងដឹកនាំពង្រឹងសេដ្ឋកិច្ចជាតិដោយផ្ទាល់" ។ ក្រុមប្រឹក្សា

---

[25] វិទ្យុភ្នំពេញថ្ងៃទី 5 ខែមីនាឆ្នាំ 1984

[26] សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) គណៈគ្រប់គ្រងកិច្ចការបក្សរាជធានីភ្នំពេញ អនុស្សរណៈយោគយល់គ្នា ៖" កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចប្រជុំគណៈបញ្ជាការឯកភាពក្រុង" 333 KoABPh-DA, ថ្ងៃទី 18 ខែវិច្ឆិកាឆ្នាំ 1982 ។ វិទ្យុភ្នំពេញថ្ងៃទី 6 ខែឧសភាឆ្នាំ 1988; រដ្ឋកម្ពុជា )SOC), អនុក្រឹត្យលេខ 73 អនក្រ ចុះថ្ងៃទី 11 ខែកក្កដាឆ្នាំ1989។ អង្គការសហប្រជាជាតិ (អ.ស.ប) របាយការណ៍ស្តីពីបេសកកម្មស្វែងយល់របស់អង្គការសហ" ប្រជាជាតិស្តីពីរចនាសម្ព័ន្ធបច្ចុប្បន្ន និងការអនុវត្តរដ្ឋបាលនៅកម្ពុជាចាប់ពីថ្ងៃទី24 ខែមេសាដល់ថ្ងៃទី9 ខែឧសភាឆ្នាំ1990" ខែមិថុនាឆ្នាំ1990 ទំព័រ47 ។ អង្គការសហប្រជាជាតិ "បេសកកម្មស្វង់មតិសហប្រជាជាតិប្រចាំនៅកម្ពុជា ៖ សន្តិសុខសាធារណៈនិងនគរបាលស៊ីវិលនៅក្នុងរដ្ឋកម្ពុជា ទំព័រទី "29 ទំព័រ 31 ។ សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK)។

[27] SPK ថ្ងៃទី 3 ខែមេសាឆ្នាំ 1979

រដ្ឋមន្ត្រី ក៏ទទួលខុសត្រូវ "ពង្រឹង និងបង្កើនចំនួនកងកម្លាំងការពារជាតិ" និង "ប្រមូលផ្តុំកម្លាំងទ័ព" ព្រមទាំង "ចាត់វិធានការចាំបាច់នានាដើម្បីការពារជាតិ" ក៏ប៉ុន្តែរដ្ឋធម្មនុញ្ញមិនបានចែងច្បាស់លាស់អំពីអំណាចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីក្នុងការបញ្ជា និងត្រួតត្រាលើកងទ័ពឡើយ។[28]

## កងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា បន្ទាប់ពីលោក ប៉ែន សុវណ្ណ

ដោយសារតែការប៉ះទង្គិចគ្នាជាមួយអាជ្ញាធរវៀតណាមលើគោលនយោបាយ ដែលត្រូវបន្តធ្វើរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា លោក ប៉ែន សុវណ្ណ ត្រូវបានដាក់ជំនួសដោយលោក ចាន់ ស៊ី ជានាយករដ្ឋមន្ត្រី។ លោក ចាន់ ស៊ី ជាអតីតទាហានជើងចាស់ ដែលស្នាក់នៅយូរអង្វែងក្នុងប្រទេសវៀតណាមម្នាក់ទៀត និងដែលបានកាន់កាប់តំណែង របស់លោក ប៉ែន សុវណ្ណ ជារដ្ឋមន្ត្រីការពារជាតិ មុនពេលគេដកលោកប៉ែន សុវណ្ណចេញ។[29] បន្ទាប់មក គាត់បានប្រគល់តំណែងនេះទៅលោក ប៊ូ ថង ខណៈដែលលោក សយ កែវ នៅជាប្រធានអគ្គសេនាធិការ ដែលដើរតួនាទីលេចធ្លោជាងមុន បន្ទាប់ពីការកំចាត់លោក ប៉ែន សុវណ្ណ ចេញ។[30] តំណែងអគ្គមេបញ្ជាការ ដែលកាន់កាប់ដោយអតីតអនុប្រធានសេនាធិការតំបន់បូព៌ារបស់គណបក្សកុម្មុយនីស្តកម្ពុជាគឺលោក ហេងសំរិន ដែលជាប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺជាក់ស្តែងគ្រាន់តែជាតំណែងពិធីការតែប៉ុណ្ណោះ។[31] តួនាទីនៃការចេញ "បញ្ជាពីថ្នាក់កំពូល" គឺក្រសួងការពារជាតិ និងអគ្គសេនាធិការ ជាអ្នកបន្តដើរតួរដែល ក្នុងនោះរួមទាំងការត្រួតត្រាលើមេបញ្ជាការយោធាតំបន់នានា ដែលត្រូវបានរៀបចំសម្រួលនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ ដើម្បីគ្រប់គ្រងកងកម្លាំងខេត្ត ឱ្យស្របគ្នានឹងគណៈបញ្ជាការឯកភាពមូលដ្ឋានដែលបានរៀបចំមុនហើយនោះ។[32] ខ្សែសង្វាក់គ្រប់គ្រងនេះ បានផាត់អតីតកម្មាភិបាលកងទ័ពបក្សកុម្មុយនីស្តកម្ពុជាតំបន់បូព៌ា ដូចជាលោក ហេង សំរិន និងលោក ប៉ុលសារឿន ចេញផុតពីការត្រួតត្រាកងទ័ព។

---

[28] សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) "រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មាត្រា "4, 59, 64, 66 ថ្ងៃទី 27 ខែមិថុនាឆ្នាំ 1981

[29] វិទ្យុភ្នំពេញថ្ងៃទី 22 ខែកក្កដាឆ្នាំ 1981 SPK ថ្ងៃទី 2 ខែមករាឆ្នាំ 1985

[30] វិទ្យុភ្នំពេញថ្ងៃទី 13 ខែធ្នូឆ្នាំ 1983 វិទ្យុភ្នំពេញថ្ងៃទី 2 ខែមករាឆ្នាំ 1982

[31] សូមមើល ឧទាហរណ៍ វិទ្យុភ្នំពេញថ្ងៃទី 31 ខែកក្កដាឆ្នាំ 1984

[32] វិទ្យុភ្នំពេញ, នៅថ្ងៃទី 16 ខែតុលាឆ្នាំ 1984, វិទ្យុភ្នំពេញថ្ងៃទី 9 ខែមេសាឆ្នាំ 1982, ខានី  ទំព័រ "កងកម្លាំងប្រដាប់អាវុធរបស់ហេងសំរិន"166 ។

*នៅថ្ងៃទី ១០ ខែកុម្ភៈឆ្នាំ ១៩៨២ សាធារណរដ្ឋប្រជាមានិតកម្ពុជា បានប្រកាសច្បាប់ស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារដ្ឋមន្ត្រី" ដែលមានរៀបរាប់លំអិតនៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨១។ ច្បាប់នេះបញ្ជាក់ថា ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា គ្រប់គ្រងត្រឹមតែវិស័យសេដ្ឋកិច្ច និងសង្គម ដោយមិនបានចែងពីអំណាចបញ្ជាណាមួយលើកងទ័ព និងកងកម្លាំងដទៃទៀតទេ។*[33] *បញ្ជាក់បន្តពីច្បាប់នេះ ក៏មាន "សេចក្តីប្រកាសស្តីពីប្រព័ន្ធការងារក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សារដ្ឋមន្ត្រី" ចុះកាលបរិច្ឆេទថ្ងៃទី ៣១ ខែមិនា ឆ្នាំ ១៩៨២ រៀបរាប់ថា ក្រុមប្រឹក្សារដ្ឋមន្ត្រី ជារដ្ឋាភិបាលផ្នែកសេដ្ឋកិច្ច និងសង្គមជាចម្បង។ ទោះជាយ៉ាងណា សេចក្តីប្រកាសនោះ បានដាក់ក្រសួងមហាផ្ទៃឲ្យស្ថិតនៅក្រោមការដឹកនាំរបស់ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី (នាយករដ្ឋមន្ត្រី) គឺលោក ចាន់ ស៊ី ប៉ុន្តែមិនបានដាក់ក្រសួងការពារជាតិឱ្យស្ថិតក្រោម ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីទេ។ ហេតុដូច្នេះ រដ្ឋមន្ត្រីក្រសួងការពារជាតិ (កាលណោះគឺ លោក ប៊ូ ថង) មានអំណាចស្វ័យភាពស្មើមុខស្មើមាត់នឹងនាយរដ្ឋមន្ត្រី។*[34]

## *កងទ័ពបដិវត្តន៍ប្រជាជនកម្ពុជាក្រោមលោក ហ៊ុន សែន*

*លោក ចាន់ ស៊ី បានទទួលមរណៈភាពនៅថ្ងៃទី ៣១ ខែធ្នូឆ្នាំ១៩៨៤។*[35] *សមមិត្ត ហ៊ុន សែន ដែលមានប្រទេសវៀតណាមនៅពីក្រោយ បានទទួលតំណែងជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីនៅថ្ងៃទី១៤ ខែមករា ឆ្នាំ ១៩៨៥ និងជានាយករដ្ឋមន្ត្រីកម្ពុជាតាំងពីពេលនោះមក ។*[36] *បន្ទាប់ពីចូលកាន់មុខតំណែងមក លោក ហ៊ុន សែនបានពង្រឹងបន្ថែមនូវសិទ្ធិអំណាចរបស់អគ្គសេនាធិកា តាមរយៈអនុក្រឹត្យមួយ ដែលបញ្ជាក់បន្ថែមនូវអំណាចបញ្ជារបស់អគ្គសេនាធិការលើកងកម្លាំងប្រដាប់អាវុធរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា* (PRK) *ទាំងអស់។*[37] *លោក សយ កែវ ត្រូវបានដកចេញពីតំណែងជាប្រធានអគ្គសេនាធិការ ហើយជំនួស*

---

[33] សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) ថ្ងៃទី "ច្បាប់ស្តីពីអង្គការនិងសកម្មភាពរបស់ទីស្តីការគណៈរដ្ឋមន្ត្រី" (10 ខែកុម្ភៈឆ្នាំ 1982)

[34] សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) "សេចក្តីប្រកាសស្តីពីប្រព័ន្ធការងារនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី" ថ្ងៃទី 01 ខែមីនាឆ្នាំ 1982

[35] SPK ថ្ងៃទី 2 ខែមករាឆ្នាំ 1985 ។

[36] បទសម្ភាស Brad Adams ជាមួយលោកគង់គាំ ថ្ងៃទី 23 ខែវិច្ឆិកាឆ្នាំ1999 វិទ្យុទីក្រុងភ្នំពេញ, ថ្ងៃទី 14 ខែមករាឆ្នាំ 1985; ចាប់ពីខែកញ្ញាឆ្នាំ 1993 - [98] លោកហ៊ុនសែនគឺជានាយករដ្ឋមន្ត្រីជាលើកដំបូងជាមួយសម្តេចនរោត្តមរណឫទ្ធិរហូតដល់ការបះបោររបស់លោកហ៊ុនសែនក្នុងខែកក្កដាឆ្នាំ 1997 ហើយបន្ទាប់មកជាមួយអ៊ឹងហួត។

[37] សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) អនុក្រឹត្យលេខ 25 អនក្រចុះថ្ងៃទី 20 ខែវិច្ឆិកាឆ្នាំ 1985

ដោយ លោក កុយ ប៊ុនថា ដែលត្រូវបានតំឡើងឋានៈជារដ្ឋមន្ត្រីក្រសួងការពារជាតិ នៅខែធ្នូ ឆ្នាំ១៩៨៦។ លោក កែ គឹមយ៉ាន បានក្លាយជាប្រធានអគ្គសេនាធិការ។[38]

នៅខែសីហាឆ្នាំ ១៩៨៨ វៀតណាម បានដកកងទ័ពពាក់កណ្តាល និងមន្ត្រីភាគច្រើនរបស់ខ្លួនចេញពីកម្ពុជា ហើយវៀតណាមបានស្នើដល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) ឲ្យធ្វើកិច្ចព្រមព្រៀងសន្តិភាពជាមួយពួកខ្មែរក្រហម និងជាមួយភាគីសត្រូវផ្សេងទៀត ប៉ុន្តែរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា មិនយល់ព្រម ហើយពេលនោះលោក ហ៊ុន សែន បានចេញសេចក្តីប្រកាសតាំងខ្លួនឯងជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី "ទទួលខុសត្រូវដឹកនាំផ្ទាល់កងកម្លាំងយោធា និងការងារសន្តិសុខ" ដោយកាត់បន្ថយអំណាចរដ្ឋមន្ត្រីក្រសួងការពារជាតិ មកត្រឹមតែជាមនុស្សទទួលខុសត្រូវខាងសាងសង់សំណង់យោធា។ នៅខែធ្នូ ឆ្នាំ១៩៨៨ សមមិត្តហ៊ុន សែនបានដឹកនាំការសើរើរៀបចំរចនាសម្ព័ន្ធយោធាឡើងវិញ ដោយឱ្យលោក ទៀ បាញ់ ឡើងកាន់កាប់តំណែងជួសលោក កុយ ប៊ុនថា ជារដ្ឋមន្ត្រីក្រសួងការពារជាតិ តាំងពីពេលនោះរហូតមក។ លោក ប៉ុល សារឿន ឡើងកាន់កាប់តំណែងជួសលោក កែ គឹមយ៉ាន ដែលជាប្រធានអគ្គសេនាធិការ។[39]

ក្នុងចំណោមតួអង្គនានា ដែលបានលេចធ្លោនៅក្នុងវិស័យយោធា និងការពារជាតិក្នុងឆ្នាំ ១៩៨៦-១៩៨៨ មានតែលោក ប៉ុល សារឿន ជាអតីតអ្នករត់ចោលជួរភូមិភាគបូព៌ានៃបក្សកុម្មុយនីស្តកម្ពុជា ដែលមានទំនាក់ទំនងជាមួយលោក ហ៊ុន សែន។[40] លោក កុយ ប៊ុនថា បានដើរចេញពីខ្មែរក្រហមហើយបានចាកចេញទៅវៀតណាមមុនឆ្នាំ១៩៧៥។ លោកទៀ បាញ់ ជាជនជាតិភាគតិចថៃបានចាកចេញពីជួរខ្មែរក្រហមនៅឆ្នាំ ១៩៧៤ ហើយបានភៀសខ្លួនទៅប្រទេសថៃនៅឆ្នាំ១៩៧៥។ លោក ទៀ បាញ់ បានចូលរួមជាមួយក្រសួងការពារជាតិរបស់សាធារណរដ្ឋប្រជាមានិតនៅឆ្នាំ១៩៧៩ ហើយក្រោយមកក្លាយជារដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ ទូរគមនាគមន៍ និងដឹកជញ្ជូន មុនពេលវិលត្រឡប់មកក្រសួងការពារជាតិវិញ។[41] លោក កែ

---

38 វិទ្យុភ្នំពេញថ្ងៃទី 22 ខែធ្នូឆ្នាំ 1985; SPK ថ្ងៃទី 11 ខែធ្នូឆ្នាំ 1986 ។

39 លោកហ្វង អាញ់ដុង, កំណត់សម្គាល់អំពីកម្ពុជា (1975-1991) ។ គណបក្សប្រជាជនកម្ពុជា, ប្រវត្តិនៃការតស៊ូ, ទំព័រ 14-15 ។ ភ្នំពេញវិទ្យុ, ថ្ងៃទី 20 ខែសីហា ឆ្នាំ 1988 ។

40 អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) "របាយការណ៍ស្តីពីការសម្ភាសន៍របស់ប៉ាន់ថៃ, ខឹមសោភ័ន, ភួងស៊ីផេន កែគឹមយ៉ាន និងញឹកហួន "ថ្ងៃទី 3 ខែសីហាឆ្នាំ 1993 ។

41 ណឹមសុវ៉ាត បដិវត្តន៍នៅភូមិដាច់ស្រយាលៈ រឿងទាបាញ់ (ភ្នំពេញ ៖ រាហ៊ូ ឆ្នាំ 2009) ទំព័រ 157-158

គឺមយ៉ាន មិនមានជីវប្រវត្តិចេញពីខ្មែរក្រហមទេ។[42] គាត់ប្ដូកពីគេនៅក្នុងជួរយោធានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ គាត់ធ្លាប់ជាមេបញ្ជាការវាយប្រយុទ្ធប្រឆាំងនឹងទ័ពព្រៃខ្មែរក្រហម ប៉ុល ពត នៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ហើយបន្ទាប់មកក្លាយជាលេខាធិការគណៈកម្មាធិការរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា និងជាប្រធានរដ្ឋបាលខេត្តបាត់ដំបង។[43]

លោក ប៉ុល សារឿន ដែលជានាយសេនាធិការ មានអំណាចបញ្ជាលើកងកម្លាំងប្រដាប់អាវុធទាំងស្រុងរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា និងជាតួឯកយោធាដ៏មានអំណាចបំផុតនៅក្បែរលោក ហ៊ុន សែនផ្ទាល់។[44] ការពិតនេះ ត្រូវបានបញ្ជាក់បង្ហាញជាសាធារណៈនៅពេលគាត់ធ្វើជាអធិបតីនៃការប្រមូលផ្តុំអង្គភាពយោធាថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានដែលនៅពេលជួបជុំម្តងៗ គាត់បានចេញបទបញ្ជាយោធានិងសារណែនាំនយោបាយដល់យោធាទាំងអស់នោះ។[45]

## កងកម្លាំងប្រដាប់អាវុធប្រជាជនកម្ពុជា រដ្ឋកម្ពុជា និងអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់)

ក្នុងការរៀបចំដកកងទ័ពវៀតណាមបន្ថែមទៀត និងការប្រុងប្រៀបសំរាប់កិច្ចព្រមព្រៀងសន្តិភាពដែលអាចកើតមាន រួមទាំងខ្មែរក្រហម និងកងកម្លាំងតស៊ូប្រដាប់អាវុធដទៃទៀត នៅក្នុងខែមេសាឆ្នាំ១៩៨៩ សមមិត្តប្រមុខរដ្ឋ ហេង សំរិន បានប្រកាសរដ្ឋធម្មនុញ្ញថ្មីមួយ ដែលប្រែក្លាយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាទៅជារដ្ឋកម្ពុជា (SOC)។[46] យោងតាមរដ្ឋធម្មនុញ្ញថ្មីនោះ បក្សប្រជាជនបដិវត្តន៍កម្ពុជា នៅតែជា "កម្លាំងដឹកនាំសង្គម និងរដ្ឋកម្ពុជា" ។[47] ក្នុងនាមជាប្រធានក្រុមប្រឹក្សារដ្ឋ (លោក ហេង សំរិន) នៅតែជា "អគ្គមេ

---

[42] Michael Vickery, កម្ពុជា ៖ នយោបាយសេដ្ឋកិច្ចនិងសង្គម (ទីក្រុងឡុងដ៍: ហ្វ្រេនភីនផេជ័រឆ្នាំ 1986) ទំព័រ 80-82; អ៊ុនតាក់ " សម្ភាស "សូវ៉ាត បដិវត្តន៍ pp.127-139 ។

[43] Nguyen Van Hng, សង្គ្រាមដែលមិនត្រូវការ, ទំព័រ 99; វិទ្យុភ្នំពេញថ្ងៃទី 13 ខែតុលាឆ្នាំ 1985 SPK ថ្ងៃទី 25 ខែតុលាឆ្នាំ 1985

[44] PRK អនុក្រឹត្យលេខ 25 អនក្រ ចុះថ្ងៃទី 20 ខែវិច្ឆិកាឆ្នាំ 1985 ។ អ៊ុនតាក់ "របាយការណ៍ស្តីពីការសម្ភាសន៍។ "

[45] វិទ្យុភ្នំពេញថ្ងៃទី 29 ខែមករាឆ្នាំ 1990 វិទ្យុភ្នំពេញថ្ងៃទី 31 ខែសីហាឆ្នាំ 1990 វិទ្យុភ្នំពេញថ្ងៃទី 30 ខែមករាឆ្នាំ 1990 ភ្នំពេញ វិទ្យុរាជធានីភ្នំពេញ, ថ្ងៃទី 11 ខែមករាឆ្នាំ 1992; វិទ្យុភ្នំពេញថ្ងៃទី 6 ខែសីហាឆ្នាំ 1990 វិទ្យុភ្នំពេញថ្ងៃទី 28 ខែវិច្ឆិកាឆ្នាំ 1990 ។

[46] លោកហ្វង អាញ់ដុង កំណត់សម្គាល់អំពីកម្ពុជា (1975-1991) ។

[47] រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា) មាត្រា 4 ថ្ងៃទី 30 ខែមេសាឆ្នាំ 1989 ។ ភ្នំពេញវិទ្យុថ្ងៃទី 5 ខែឧសភាឆ្នាំ 1989 ។

បញ្ជាការ” នោះ គឺជាអ្វីដែលរដ្ឋធម្មនុញ្ញ បានកំណត់ឡើងវិញនូវកងទ័ពប្រជាជនកម្ពុជា (CPAF) ប៉ុន្តែមុខងារផ្នែកសន្តិសុខយោធារបស់ក្រុមប្រឹក្សារដ្ឋ ត្រូវបានកំណត់មកដើរតួនាទីជាអ្នក ”សំរេច” តម្លើងឋានន្តរស័ក្តិ និងប្រគល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីយោធាតាម "អនុសាសន៍របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។”[48] ក្រុមប្រឹក្សារដ្ឋមន្ត្រីបន្តគ្រប់គ្រងដោយផ្ទាល់លើសង្គម និងថ្នាក់ដឹកនាំនៃកិច្ចការងារអភិវឌ្ឍន៍ជាតិ។[49] នៅក្នុងវិស័យយោធា ក្រុមប្រឹក្សារដ្ឋមន្ត្រីនៅតែទទួលខុសត្រូវចំពោះ "ការពង្រឹង និងការបង្កើនកងកម្លាំងការពារជាតិ” "អនុវត្តការប្រមូលផ្តុំកងកម្លាំងទ័ព" និង "ចាត់វិធានការចាំបាច់ផ្សេងទៀត ដើម្បីការពារប្រទេសជាតិ" ប៉ុន្តែ រដ្ឋធម្មនុញ្ញថ្មីដូចរដ្ឋធម្មនុញ្ញចាស់ដែរ នៅតែមិនបានចែងដាក់លាក់នូវអំណាចបញ្ជា និងអំណាចគ្រប់គ្រងរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីទៅលើកងទ័ពឡើយ។[50]

នៅខែកក្កដាឆ្នាំ ១៩៨៩ រដ្ឋកម្ពុជា (SOC) បានអនុម័តច្បាប់មួយស្តីពី “ ការកែសម្រួលអង្គការចាត់តាំង តួនាទី និងភារកិច្ចរបស់ក្រសួងការពារជាតិ” ។[51] ច្បាប់នេះបានចែងថា ក្រសួង "ដឹកនាំ និងគ្រប់គ្រងកងទ័ពគ្រប់ប្រភេទ” ហើយត្រូវ “សហការជាមួយកម្លាំងនគរបាល ដើម្បីការពារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម” ប៉ុន្តែអំណាចទាំងនេះនៅតែអនុវត្តតាមរយៈអគ្គបញ្ជាការដដែល។[52]

នៅខែកុម្ភៈ ឆ្នាំ១៩៩២ រដ្ឋកម្ពុជា (SOC) បានចេញសេចក្តីសម្រេចមួយឱ្យឈ្មោះថា “សេចក្តីសម្រេចស្តីពីប្រព័ន្ធការងារនៃក្រុមប្រឹក្សារដ្ឋមន្ត្រី" ជំនួសច្បាប់ឆ្នាំ១៩៨២ របស់សាធារណរដ្ឋប្រជាមានិតកម្ពុជាស្តីពីការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី។ ជាថ្មីម្តងទៀត សេចក្តីសម្រេចនេះបានពណ៌នារដ្ឋាភិបាល ជាលើកដំបូង និងសំខាន់បំផុតថាជា "អង្គការគ្រប់គ្រងសង្គម និងសេដ្ឋកិច្ច " ក៏ប៉ុន្តែ វាបានផ្តល់សិទ្ធិអំណាចដល់នាយករដ្ឋមន្ត្រី ឱ្យដឹកនាំការងារយោធា និងសន្តិសុខកម្ពុជា ដោយចែករំលែកការទទួលខុសត្រូវជាមួយរដ្ឋមន្ត្រីការពារជាតិ លោក ទៀ បាញ់ ប៉ុន្តែពុំបានផ្តល់ការទទួលខុសត្រូវផ្នែកសន្តិសុខឱ្យលោក ស ខេង ដែលជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃថ្មី (ជាប្អូនថ្លៃរបស់លោក ជា ស៊ីម) ដែលជាអតីតខ្មែរក្រហមភូមិភាគបូព៌ា និងជាអ្នកគ្រប់គ្រង

---

48 SOC "រដ្ឋធម្មនុញ្ញ" មាត្រា 62 ។ វិទ្យុភ្នំពេញថ្ងៃទី 5 ខែឧសភាឆ្នាំ 1989; SOC "រដ្ឋធម្មនុញ្ញ" មាត្រា 60 ។ វិទ្យុភ្នំពេញ ថ្ងៃទី៥ ខែឧសភា ឆ្នាំ 1989

49 SOC "រដ្ឋធម្មនុញ្ញ" មាត្រា 64 ។ វិទ្យុភ្នំពេញថ្ងៃទី 5 ខែឧសភាឆ្នាំ 1989។

50 SOC "រដ្ឋធម្មនុញ្ញ" មាត្រា 66 ។ វិទ្យុភ្នំពេញថ្ងៃទី 5 ខែឧសភាឆ្នាំ 1989។

51 SPK ថ្ងៃទី 15 ខែកក្កដាឆ្នាំ 1989។

52 SOC "ច្បាប់ស្តីពីការកែតម្រូវរបស់អង្គការតួនាទីនិងភារកិច្ចនៃក្រសួងការពារជាតិ" ថ្ងៃទី 20 ខែកក្កដាឆ្នាំ 1989។ អ៊ុនតាក់ "របាយការណ៍ស្តីពីការសម្ភាសន៍។ "

ជនស៊ីវិលដើងចាស់របស់បក្សប្រជាជនកម្ពុជា ដែលមិនមានបទពិសោធខាងកម្លាំងសន្តិសុខ។[53] ច្បាប់មួយទៀតអនុម័តនៅខែមេសាឆ្នាំ១៩៩២ ដែលមានប្រសិទ្ធិភាពស្រដៀងគ្នានេះ បានបញ្ជាក់ពីបញ្ហានេះ។[54]

ស្ថានភាពនេះកើតឡើងស្របពេលដែលអាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) បានចាប់ផ្តើមដាក់ពង្រាយនៅខែមីនាដល់មេសាឆ្នាំ ១៩៩២ ដោយមានអាណត្តិពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសនាខែតុលាឆ្នាំ ១៩៩១ ដើម្បីរំសាយកងកម្លាំងប្រដាប់អាវុធនានារបស់កម្ពុជា និងបង្កើតការគ្រប់គ្រងដោយផ្ទាល់លើវិស័យសំខាន់ៗរបស់អង្គការចាត់តាំងរដ្ឋបាលដែលមានស្រាប់ រួមទាំង "ក្រសួងការពារជាតិ" ផង។ គ្រប់យ៉ាងទាំងអស់ត្រូវបានកំណត់ ដើម្បីបង្កើតបរិយាកាសនយោបាយអព្យាក្រឹត្យ សម្រាប់ការបោះឆ្នោត ដែលរៀបចំដោយអង្គការសហប្រជាជាតិ ដែលបានប្រារព្ធធ្វើនៅខែឧសភាឆ្នាំ១៩៩៣។[55] ដំណើរការនេះ ត្រូវបានគេសន្មត់ថា ត្រូវគ្រប់គ្រងដោយក្រុមការងារយោធាចម្រុះដែលបង្កើតឡើងដោយអ៊ុនតាក់ (MMWG) ដោយមានការចូលរួមពី កងទ័ពប្រជាជនកម្ពុជា (CPAF) និងកងកម្លាំងប្រដាប់អាវុធរបស់ខ្មែរក្រហមប៉ុលពត និងក្រុមមិនមែនកុម្មុយនិស្តប្រឆាំងគណបក្សប្រជាជនកម្ពុជា និងអ្នករាជានិយមហ៊្វុនស៊ិនប៉ិច។ ប៉ុន្តែ ពួកខ្មែរក្រហមមិនបានគោរពតាមកិច្ចសន្យារបស់ខ្លួនដែលមានចែងក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសនោះទេ។ បន្ទាប់មកទៀត រដ្ឋកម្ពុជា (SOC) ក៏មិនរក្សាការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការរំសាយកងទ័ពដែរ។ ពួកខ្មែរក្រហមបានបន្តសង្រ្គាមទ័ពព្រៃប្រឆាំងនឹងរដ្ឋកម្ពុជា និងដែលក្រោយមក ដោយមានការយល់ព្រមពីអ៊ុនតាក់ រដ្ឋកម្ពុជាបានចាប់ផ្តើមប្រតិបត្តិការយោធាប្រឆាំងនឹងខ្មែរក្រហម។ ការបោះឆ្នោតបានកើតឡើងចំពេលមានជម្លោះប្រដាប់អាវុធ។[56]

ចំពោះការប៉ុនប៉ងរបស់អ៊ុនតាក់ ដើម្បីត្រួតពិនិត្យកងទ័ពប្រជាជនកម្ពុជា(CPAF) គណបក្សប្រជាជនកម្ពុជាបានវាយតម្លៃត្រូវថា ការប៉ុនប៉ងនេះនាំឱ្យបរាជ័យចំពោះ "ប្រព័ន្ធបក្សតែមួយ" របស់ខ្លួន ដែលមានការិយាធិបតេយ្យ "គ្រប់គ្រងរចនាសម្ពន្ធសង្គមពីលើដល់បាតក្រោម" ដែល "បញ្ចូលគ្នាជាដុំមួយ នាំឱ្យអ៊ុនតាក់មិន

---

[53] អ៊ុនតាក់ "អ្នកដែលនៅក្នុងរដ្ឋកម្ពុជា: គណបក្សប្រជាជនកម្ពុជា" ថ្ងៃទី 14 ខែវិច្ឆិកាឆ្នាំ 1992; SOC, សេចក្តីសម្រេចលើប្រព័ន្ធការងារនៃទីស្តីការគណៈរដ្ឋមន្ត្រី, 97 / SSR, ថ្ងៃទី 2 ខែកុម្ភៈឆ្នាំ 1992, ចំណុច 1, 11 ។

[54] SOC "ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី" ថ្ងៃទី 6 ខែមេសាឆ្នាំ 1992។

[55] អសប UN, "ប្រទេសកម្ពុជា: អ៊ុនតាក់", http://www.un.org/en/peacekeeping/missions/past/untacbackgr2.html (ចូលមើលថ្ងៃទី 3 ខែមករា, 2009) ។

[56] លោក Peter Bartu "" បក្សពួកទី 5 ": អង្គការសហប្រជាជាតិនៅកម្ពុជាឆ្នាំ 1991-1993" (សាត្រាស្លឹករឹតដែលមិនបានផ្សព្វផ្សាយ), ទំព័រ 129-183

អាចជ្រៀតចូលត្រួតត្រាបាន” ហើយរចនាសម្ព័ន្ធបែបនេះក៏ “អាចទប់ទល់អ្វីៗក៏បានយ៉ាងងាយស្រួលដែរ។”[57] ជាក់ស្តែង លោក ហ៊ុន សែន និងលោក ប៉ុល សារឿន បានបន្តគ្រប់គ្រងពេញទីលើកងទ័ពប្រជាជនកម្ពុជា (CPAF) រីឯលោក កែ គឹមយាន ដែលលោក ប៉ុល សារឿន មានតំណែងធំជាងនៅក្នុងឋានានុក្រមគណបក្សប្រជាជនកម្ពុជានោះ ត្រូវបានចាត់តាំងឱ្យធ្វើជាមន្ត្រីទំនាក់ទំនងជាមួយអ៊ុនតាក់ តាមរយៈក្រុមការងារយោធាចម្រុះ (MMWG) របស់ខ្លួន ។ សេចក្តីសម្រេចចម្បងនៅក្រុមការងារយោធាចម្រុះ (MMWG) ជាពិសេសសេចក្តីសំរេចទាក់ទងនឹងរឿងនយោបាយសំខាន់ៗ ដែលត្រូវធ្វើឡើង ត្រូវតែមានការយល់ព្រមពីលោក ប៉ុល សារឿន។ ការធ្វើរបៀបនេះ ក៏ដោយសារតែលោក ហ៊ុន សែន បានចាត់ទុក លោក កែ គឹមយ៉ាន ថានៅពេលខ្លះ “ទន់ជ្រាយ” នៅចំពោះមុខអ៊ុនតាក់ និងគណបក្សហ៊្វុនស៊ិនប៉ិច ដែលប្រការនេះអាចបង្ករជាគ្រោះថ្នាក់ដល់គបក្សបក្សប្រជាជនកម្ពុជា។[58]

## កងកម្លាំងប្រដាប់អាវុធប្រជាជនកម្ពុជា ក្រោមសហនាយករដ្ឋមន្ត្រី

គណបក្សហ្វុនស៊ិនប៉ិច (FUNCINPEC) និងដៃគូចំរុះរបស់ខ្លួន ដែលមានគណបក្សប្រជាធិបតេយ្យសេរីនិយមពុទ្ធសាសនា (BLDP) បានឈ្នះ ៦៨ អាសនៈក្នុងចំណោម ១២០ កៅអីនៅក្នុងការបោះឆ្នោតអ៊ុនតាក់។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា បានគំរាមកំហែងបំបែកយកខេត្តភាគខាងកើតចំនួន ៧ និងបំផុះសង្គ្រាមស៊ីវិលឡើងវិញ ប្រសិនបើពួកគេមិនត្រូវបានធ្វើជាដៃគូស្មើគ្នានៅក្នុងរដ្ឋាភិបាលថ្មី រួមទាំងការរក្សាទុកដដែលនូវការគ្រប់គ្រងត្រួតត្រាលើកងយោធា និងកងប៉ូលីស។ យោងតាមលោកឧត្តមសេនីយ៍ ចន សាន់ឌឺសុន (John Sanderson) មេដឹកនាំនៃសមាសភាពយោធាអ៊ុនតាក់ “ ប្រសិនបើមានគេបង្ហើបឱ្យដឹងថា លោក ហ៊ុន សែន ជាមេក្លោងនៃការគំរាមបំបែកខ្លួននោះ គាត់ប្រហែលជាមិនអាចក្លាយជាសហនាយករដ្ឋមន្ត្រីទេ”។[59]

តទៅនេះគឺជាអ្វីដែលបែកធ្លាយក្រោយមក។ នៅថ្ងៃទី ៣ ខែមិថុនាឆ្នាំ ១៩៩៣ ព្រះបាទសម្តេច ព្រះនរោត្តម

---

[57] នឹមសូវ៉ាត គោលនយោបាយឈ្នះឈ្នះរបស់សម្តេចតេជោហ៊ុនសែនក្នុងបរិបទអន្តរជាតិ (ភ្នំពេញរាជ្យឆ្នាំ 2012) ទំព័រទី 22 ។)

[58] អ៊ុនតាក់ "នរណាជាអ្នកណា" អ៊ុនតាក់ "របាយការណ៍ស្តីពីការសម្ភាសន៍" សម្រាប់ឧទាហរណ៍ជាក់លាក់សូមមើលវិទ្យុរាជធានីភ្នំពេញថ្ងៃទី 11 ខែមិថុនាឆ្នាំ 1993 ។

[59] Brad Adams សម្ភាសតាមទូរស័ព្ទជាមួយលោកឧត្តមសេនីយ៍លោក John Sanderson, ថ្ងៃទី 18 ខែធ្នូឆ្នាំ 2001 ។

*សីហនុ (មិនទាន់ឡើងសោយរាជលើកទី២ទេរហូតដល់ខែកញ្ញា១៩៩៣) បានប្រកាសរដ្ឋាភិបាលចម្រុះបណ្តោះអាសន្នមួយរបស់គណបក្សហ្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា។ ដោយគ្មានអំណាចផ្លូវច្បាប់ ហើយដាក់ស្តែង ដោយគ្មានការពិគ្រោះយោបល់ជាមួយបុត្រារបស់ព្រះអង្គ គឺមេដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិចព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ព្រះបាទសីហនុបានធ្វើការជាមួយគណបក្សប្រជាជនកម្ពុជា តែងតាំងព្រះអង្គឯងជាប្រមុខរដ្ឋ ជានាយករដ្ឋមន្ត្រី និងឧត្តមមេបញ្ជាការជាន់ខ្ពស់នៃកងកម្លាំងប្រដាប់អាវុធកម្ពុជា។[60] រដ្ឋាភិបាលនេះ ត្រូវបានរំសាយវិញភ្លាមៗក្រោមការជំទាស់របស់មជ្ឈដ្ឋានជាតិ និងអន្តរជាតិជាបន្តបន្ទាប់ ប៉ុន្តែសម្តេចសីហនុ នៅតែជាមេបញ្ជាការជាន់ខ្ពស់នៃកងទ័ពកម្ពុជាចម្រុះភាគី ដែលត្រូវបានប្រកាសនៅពីថ្ងៃទី ១០ ខែមិថុនា។[61] ប៉ុន្តែព្រះសីហនុបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះអង្គនឹងមិនបញ្ជាលើកងកម្លាំងណាមួយឡើយ។[62]*

*បន្តិចក្រោយមក រដ្ឋាភិបាលបណ្តោះអាសន្នមួយ ត្រូវបានបង្កើតឡើងដោយមានព្រះអង្គម្ចាស់នរោត្តមរណឫទ្ធិនិងលោកហ៊ុន សែន ជាសហប្រធាន។ សម្តេចសីហនុ បានដាក់ពួកគេជាសហបញ្ជាលើ "កងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា កងកម្លាំងជំនួយ កងកម្លាំងប៉ូលីស និងកងកម្លាំងសន្តិសុខកម្ពុជា" ដែលក្នុងពេលជាមួយគ្នានេះ ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ក៏មានជាសហរដ្ឋមន្ត្រីដែរ។[63] ពួកគេភ្លាមៗបានចាប់ផ្តើមចេញបទបញ្ជារួមគ្នា។[64] លោក កែ គឹមយ៉ាន ត្រូវបានតែងតាំងជាមេបញ្ជាការនៃអគ្គសេនាធិការ អមដោយអគ្គបញ្ជាការរងគឺឧត្តមសេនីយ៍មកពីគណបក្សហ្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា។[65]*

## *កងយោធពលខេមរភូមិន្ទកម្ពុជា (១៩៩៣-មកបច្ចុប្បន្ន)*

*នៅថ្ងៃទី ២១ ខែកញ្ញាឆ្នាំ ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីមួយក្រោយសម័យអ៊ុនតាក់ ត្រូវបានអនុម័តបង្កើតព្រះរាជា*

60 វិទ្យុភ្នំពេញថ្ងៃទី 3 ខែមិថុនាឆ្នាំ 1993

61 វិទ្យុភ្នំពេញថ្ងៃទី 4 ខែមិថុនាឆ្នាំ 1993; វិទ្យុភ្នំពេញថ្ងៃទី 13 ខែមិថុនាឆ្នាំ 1993; វិទ្យុទីក្រុងភ្នំពេញថ្ងៃទី 11 ខែមិថុនាឆ្នាំ 1993

62 វិទ្យុភ្នំពេញថ្ងៃទី 22 ខែមិថុនាឆ្នាំ 1993

63 វិទ្យុទីក្រុងភ្នំពេញថ្ងៃទី 2 ខែកក្កដាឆ្នាំ 1993

64 វិទ្យុទីក្រុងភ្នំពេញថ្ងៃទី 6 ខែកក្កដាឆ្នាំ 1993; វិទ្យុទីក្រុងភ្នំពេញថ្ងៃទី 16 ខែកក្កដាឆ្នាំ 1993

65 វិទ្យុទីក្រុងភ្នំពេញ, ថ្ងៃទី 4 ខែកក្កដាឆ្នាំ 1993; រដ្ឋាភិបាលបណ្តោះអាសន្នកម្ពុជា (PGC) ក្រេត ថ្ងៃទី 5 ខែកក្កដាឆ្នាំ 1993

*ណាចក្រកម្ពុជាលើកទី២។ រដ្ឋធម្មនុញ្ញចែងថា ព្រះមហាក្សត្រ គឺជាអគ្គមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ។ យ៉ាងណាក៏ដោយ ស្របតាមគោលការណ៍ទូទៅដែលថា "ព្រះមហាក្សត្រ ទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាច" និងរដ្ឋធម្មនុញ្ញក៏ចែងផងដែរថា កងកម្លាំងប្រដាប់អាវុធទាំងនេះ ត្រូវស្ថិតនៅក្រោមបញ្ជារបស់មេបញ្ជាការកំពូលមួយរូប ដែលត្រូវបានតែងតាំងដាច់ដោយឡែក។[66] រដ្ឋធម្មនុញ្ញ ក៏បានដាក់រដ្ឋាភិបាល ឲ្យទទួលបន្ទុកការពារជាតិ និងធានា "សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ" ផងដែរ។[67]*

*មាត្រា ២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី អនុម័តថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៤ ចែងថា រដ្ឋាភិបាល "គ្រប់គ្រង បញ្ជា និងប្រើប្រាស់ទាហាន ប៉ូលីស និងកងកម្លាំងប្រដាប់អាវុធដទៃទៀត ព្រមទាំងគ្រប់គ្រងការដឹកនាំសកម្មភាពរបស់ពួកគេ" ។ ដោយគ្មានចែងបញ្ជាក់ពីឯកឬពហុ នាយករដ្ឋមន្ត្រីទីមួយ គឺសម្តេចក្រុម ព្រះនរោត្តម រណឫទ្ធិ និង នាយករដ្ឋមន្ត្រីទីពីរ គឺលោក ហ៊ុន សែន មានអំណាចស្មើគ្នានៅក្នុងរដ្ឋាភិបាលចម្រុះ។ មាត្រា៩ នៃច្បាប់នេះ ផ្តល់អំណាចដល់នាយករដ្ឋមន្ត្រី (ឯកឬសហ) អាច "បញ្ជាសកម្មភាពទាំងអស់របស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ" ។ មាត្រា ១៩ ចែងថា ឧបនាយករដ្ឋមន្ត្រី ធ្វើសកម្មភាពស្របតាមប្រតិភូកម្មមិនអចិន្ត្រៃយ៍របស់នាយករដ្ឋមន្ត្រី និងអាចសម្រេចចិត្តទាក់ទងនឹងការដឹកនាំជាទូទៅលើរដ្ឋាភិបាលបាន ទាល់តែមានការយល់ព្រមពីនាយករដ្ឋមន្ត្រីប៉ុណ្ណោះ។ មាត្រា១៥ បានផ្តល់ឱ្យនាយករដ្ឋមន្ត្រីនូវអំណាចតែងតាំង ផ្ទេរ និងដកចេញ "មន្ត្រីយោធាជាន់ខ្ពស់" និងមន្ត្រីដទៃទៀតដោយមិនចាំបាច់យោងលើអំណាចដទៃទៀតឡើយ។[68] ការបកស្រាយទិដ្ឋភាពច្បាប់នៃមាត្រានេះរបស់គណបក្សប្រជាជនកម្ពុជាតាំងពីពេលនោះមក បានដាក់ឱ្យលោក ហ៊ុន សែន " បញ្ជាផ្ទាល់" លើកងកម្លាំងប្រដាប់អាវុធ និងនគរបាល។[69] កងកម្លាំងប្រដាប់អាវុធ មាន "កងទ័ពជើងគោក កងទ័ពអាកាស និងកងទ័ពជើងទឹក" ។[70]*

---

[66] រាជរដ្ឋាភិបាលកម្ពុជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា" ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ 1993 (មាត្រា 23)។ វិទ្យុភ្នំពេញថ្ងៃទី 30 ខែកញ្ញា ដល់ ថ្ងៃទី 5 ខែតុលា ឆ្នាំ 1993

[67] រាជរដ្ឋាភិបាលកម្ពុជា "រដ្ឋធម្មនុញ្ញ" (មាត្រា 52) ។ វិទ្យុភ្នំពេញ ថ្ងៃទី 30 ខែកញ្ញា ដល់ ថ្ងៃទី 5 ខែតុលា ឆ្នាំ 1993។

[68] រាជរដ្ឋាភិបាលកម្ពុជា )RGC( ព្រះរាជក្រមលេខ 02 / នស /94 ថ្ងៃទី 20 ខែកក្កដាឆ្នាំ 1994 រាជរដ្ឋាភិបាលកម្ពុជា ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្ត" ថ្ងៃទី "ទៅនៃគណៈរដ្ឋមន្ត្រី20 ខែកក្កដាឆ្នាំ 1994 ។

[69] អ៊ិន យឿន, Droite de la Fonction Publique (ភ្នំពេញ ឆ្នាំ2013) ទំព័រទី 314-315 ។

[70] រាជរដ្ឋាភិបាលកម្ពុជា (RGC) ព្រះរាជក្រមលេខ ចស/រកម 1197/05 ថ្ងៃទី 6 ខែវិច្ឆិកាឆ្នាំ 1997 ។

នៅខែមករា ឆ្នាំ១៩៩៦ អំណាចខាងផ្លូវច្បាប់របស់ក្រសួងការពារជាតិ ត្រូវបានកំណត់នៅក្នុងច្បាប់សង្ខេបមួយ ដែលនៅក្នុងច្បាប់នោះចែងថា ក្រសួងនេះមាន "សមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងក្នុងវិស័យការពារជាតិ" ប៉ុន្តែមិនបានចែងជាក់លាក់អំពីអំណាចគ្រប់គ្រងទៅលើកងកម្លាំងប្រដាប់អាវុធសោះឡើយ ដែលជាក់ស្តែងណាស់គឺទុកចន្លោះប្រហោង ទៅចែងលំអិតនៅក្នុងច្បាប់រដ្ឋបាលផ្សេងទៀត និងទុកឱ្យការអនុវត្តន៍ជាទម្លាប់នៅមានដដែល។[71]

ការបង្កើតនេះ ធ្វើឡើងតាមច្បាប់រដ្ឋបាលជាបន្តបន្ទាប់ ដែលបញ្ជាក់ថា អគ្គសេនាធិការ ជាអង្គភាពកំពូល" ដឹកនាំបញ្ជាផ្ទាល់" នៃកងពលធំ និងកងពលតូចអន្តរាគមន៍នានា រួមទាំងអង្គភាពសម្រាំងដែលមានមូលដ្ឋាននៅជុំវិញរាជធានីភ្នំពេញ ដូចជាកងពលតូចលេខ ៧០ និងកងពលតូចលេខ៩១១។[72]ក្រៅពីមានសេវាសេនាធិការជាច្រើន ដូចជាការិយាល័យចារកម្មទី២ និងក្រុមស្រាវជ្រាវស៊ើបការណ៍សម្ងាត់ អគ្គសេនាធិការទទួលបន្ទុកគ្រប់គ្រងទីបញ្ជាការកងកម្លាំងប្រយុទ្ធជំនាញពិសេសមួយចំនួន ដូចជាបញ្ជាការកងកម្លាំងពិសេស។[73] អគ្គសេនាធិការក៏មានតួនាទី "ដឹកនាំបញ្ជាការផ្ទាល់" លើយោធាភូមិភាគចំនួន៦នៅកម្ពុជាផងដែរ។[74]

អនុក្រឹត្យរបស់នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៤ ខែវិច្ឆិកាឆ្នាំ ១៩៩៣ បានបញ្ជាក់ពីការមានតំបន់យោធាចំនួន ៦ ដែល "ដាក់ក្រោមការដឹកនាំបញ្ជាផ្ទាល់ពីអគ្គសេនាធិការ" និងផ្នែកប្រតិបត្តិការសឹក "ស្ថិតក្រោម" យោធភូមិភាគទាំងនោះ។[75] ពួកគេបញ្ជាកងពលធំ ឬ កងពលតូចរបស់ភូមិភាគ[76] និងមានអំណាចលើ "ផ្នែកប្រតិបត្តិការសឹករង" ដែលភាគច្រើនត្រូវបានរៀបចំជាផ្នែកសឹករងខេត្ត និងជួនកាលជាផ្នែកសឹករងស្រុក។[77] ពួកគេបានចែករំលែកកិច្ចការបញ្ជា ជាមួយអភិបាលមូលដ្ឋាន តាមរយៈគណៈប្រធាននៃគណៈបញ្ជាការឯកភាព

---

[71] រាជរដ្ឋាភិបាលកម្ពុជា (RGC), ច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ ថ្ងៃទី"24 ខែមករាឆ្នាំ 1996 ។ យឿន, Droite, ទំព័រ 321-312 ។

[72] រាជរដ្ឋាភិបាលកម្ពុជា (RGC), អនុក្រឹត្យលេខ 35 អនក្រ។ , កក្កដា 14, 1994; រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យលេខ 64 អនក្រ។ , ថ្ងៃទី 20 ខែតុលាឆ្នាំ 1994; រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យលេខ 51 អនក្រ។ សីហា 25 1994; រាជរដ្ឋាភិបាលកម្ពុជា (RGC) ព្រះរាជក្រឹត្យលេខនស / រកត /1097/211, ថ្ងៃទី 28 ខែតុលាឆ្នាំ 1997។

[73] រាជរដ្ឋាភិបាលកម្ពុជា (RGC), អនុក្រឹត្យលេខ 17 អនក្រចុះថ្ងៃទី 18 ខែវិច្ឆិកាឆ្នាំ 1993 ។ ប្រភពដដែល Ibid.

[74] រាជរដ្ឋាភិបាលកម្ពុជា (RGC), អនុក្រឹត្យលេខ 12 អណក្រ ចុះថ្ងៃទី 24 ខែវិច្ឆិកាឆ្នាំ 1993 PGC, ក្រឹត្យ, 5 កក្កដា 1993; (KOC) "បញ្ជី មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកការិយាល័យនិងអង្គភាពក្រោមបុគ្គលិកទូទៅ ខែវិច្ឆិកាឆ្នាំ "1995។

[75] ប្រភពដដែល Ibid.

[76] ប្រភពដដែល Ibid.

[77] ប្រភពដដែល Ibid.

នូវអំណាចគ្រប់គ្រងលើកងកម្លាំងសន្តិសុខទាំងអស់នៅក្នុងតំបន់ត្រួតត្រារបស់ពួកគេ។[78] ការចូលរួមរបស់កងយោធពលខេមរភូមិន្ទនៅក្នុងកិច្ចការសន្តិសុខនៅគ្រប់កម្រិតទាំងអស់ ត្រូវបានចែងនៅក្នុងលក្ខន្តិកៈមួយដោយប្រកាសថា "ក្នុងកាលៈទេសៈចាំបាច់ កងយោធពលខេមរភូមិន្ទអាចចូលរួមក្នុងកិច្ចការពារសន្តិសុខសាធារណៈ" ។[79]

ក្នុងរដ្ឋាភិបាលបណ្តោះអាសន្ន និងរដ្ឋាភិបាលដែលបង្កើតដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ សម្តេចក្រុមព្រះ នរោត្តមរណឫទ្ធិ និងលោក ហ៊ុន សែន ត្រូវបានតែងតាំងជំណាលគ្នាជាសហមេបញ្ជាការជាន់ខ្ពស់នៃកងកម្លាំងប្រដាប់អាវុធ និងនគរបាល។[80] នៅក្នុងបរិបទនៃការចែករំលែកអំណាចគ្នារបស់គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជានេះ លោក ប៉ុល សារឿន ត្រូវលាឈប់ពីតំណែងអគ្គមេបញ្ជាការកងទ័ព ដែលតំណែងនេះត្រូវបានប្រគល់ឱ្យទៅលោក កែ គឹមយ៉ាន វិញ។ អនុប្រធានទី១ របស់គាត់ពីគណបក្សហ៊្វុនស៊ិនប៉ិច គឺឧត្តមសេនីយ៍ ញឹក ប៊ុនឆៃ និងអនុប្រធានទី ២ មកពីគណបក្សប្រជាជនកម្ពុជា លោក ប៉ុល សារឿន ។[81]

ដូចដែលរៀបរាប់លម្អិតខាងក្រោមនេះ នៅដើមខែកក្កដា ឆ្នាំ១៩៩៧ លោក ប៉ុល សារឿន និងមន្ត្រីជាន់ខ្ពស់របស់កងទ័ពប្រជាជនកម្ពុជា (CPAF) ដទៃទៀត ដែលស្មោះត្រង់នឹងលោក ហ៊ុន សែន បានធ្វើរដ្ឋប្រហារក្រោមការដឹកនាំរបស់លោក ហ៊ុន សែនប្រឆាំងនឹងគណបក្សហ៊្វុនស៊ិនប៉ិច។ ដោយជឿជាក់ថា វាមិនចាំបាច់សោះនោះ លោក ទៀ បាញ់ និងលោក មាស សុភា បានជ្រើសរើសមិនចូលរួម។ រដ្ឋប្រហារដែលបានដកអំណាចសម្តេចក្រុមព្រះ នរោត្តមរណឫទ្ធិ ជានាយករដ្ឋមន្ត្រីទីមួយ បានសម្លាប់មន្ត្រីជាន់ខ្ពស់របស់ហ៊្វុនស៊ិនប៉ិចជាច្រើននាក់ និងបានបណ្តេញលោក ញឹក ប៊ុនឆៃ និងមេដឹកនាំយោធាហ៊្វុនស៊ិនប៉ិច ដែលនៅមានជីវិតជាច្រើននាក់ទៀតឱ្យរត់គៀសខ្លួនទៅព្រំដែនថៃ ធ្វើជាទ័ពព្រៃតស៊ូប្រឆាំង (លោកហ៊ុន សែន) អស់រយៈពេលជាងមួយឆ្នាំ។ រដ្ឋប្រហារថ្ងៃ៥-៦ កក្កដា ក៏បានបណ្តេញមន្ត្រីហ្វុនស៊ិនប៉ិច និងគូប្រជែងនយោបាយជាច្រើន

[78] រាជរដ្ឋាភិបាលកម្ពុជា (RGC) អនុក្រឹត្យលេខ 22 អាណរៈថ្ងៃទី 9 ខែឧសភាឆ្នាំ 1994 រាជរដ្ឋាភិបាលកម្ពុជា )RGC) អនុក្រឹត្យលេខ 156 អនក្រ។ បកថ្ងៃទី 31 ខែមីនាឆ្នាំ 2014។

[79] រាជរដ្ឋាភិបាលកម្ពុជា (RGC) ព្រះរាជក្រម chs/រកម 1197/05 ថ្ងៃទី 6 ខែវិច្ឆិកាឆ្នាំ 1997។

[80] PGC, ក្រឹត្យ, 2 កក្កដា 1993។

[81] PGC, ក្រឹត្យ, 5 កក្កដា 1993; KOC "បញ្ជីមន្ត្រីជាន់ខ្ពស់។ "

ទៀតដែលប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជាឲ្យនិរទេសខ្លួនចេញក្រៅប្រទេស។ ទាំងអស់នេះ បានធ្វើឲ្យមានការផ្លាស់ប្តូរទូវតុល្យភាពអំណាចនៅក្នុងជួររដ្ឋបាលស៊ីវិល និងកងកម្លាំងសន្តិសុខ ដើម្បីបំពេញចិត្តលោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា ដោយដាក់ពួកគេឱ្យរៀបចំការបោះឆ្នោតជាតិ ដែលគ្មានសេរី និងគ្មានយុត្តិធម៌ នៅក្នុងខែកក្កដា ឆ្នាំ១៩៩៨ ដែលពួកគេបានអះអាងថា ដើម្បីផ្តួលគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ីដែលកំពុងលេចធ្លោ។

នៅថ្ងៃទី ៣០ ខែវិច្ឆិកាឆ្នាំ ១៩៩៨ លោក ហ៊ុន សែន បានក្លាយជានាយករដ្ឋមន្ត្រីតែម្នាក់ឯង។ នៅពេលនោះលោក ហ៊ុន សែន បានកំចាត់ចោលមន្ត្រីហ៊្វុនស៊ិនប៉ិចចេញអស់ទាំងស្រុងពីអំណាចគណៈបញ្ជាការទោះបីជា មន្ត្រីហ៊្វុនស៊ិនប៉ិចមួយចំនួនតូចកាន់តំណែងពិធីការនៅមាននៅឡើយក្តី។ ចំណុចនេះ ត្រូវបានគេមើលឃើញក្នុងវង្វង់យោធារបស់គណបក្សប្រជាជនកម្ពុជាថា ជាការបញ្ចប់នូវសម័យកាលនៃ "ការចេញបទបញ្ជាមិនច្បាស់លាស់" និងក៏ជាការចាប់ផ្តើមសម័យកាលនៃការជានាឱ្យមាន "សមត្ថកិច្ចដឹកនាំតែម្នាក់នៅទូទាំងប្រទេស" ។[82] នៅខែកុម្ភៈ ឆ្នាំ១៩៩៩ លោក ហ៊ុន សែន បានចាប់ផ្តើមរៀបចំរចនាសម្ព័ន្ធឡើងវិញ ហើយបានផ្លាស់ប្តូរបញ្ជាការយោធាបន្ថែមទៀត។ ក្រសួងការពារជាតិ នៅតែចាត់តាំងឲ្យ "ដឹកនាំ និងគ្រប់គ្រងលើវិស័យការពារជាតិ" ប៉ុន្តែនៅតែគ្មានអំណាច "ដឹកនាំបញ្ជាការដោយផ្ទាល់" លើអង្គភាពយោធា ឬស្ថាប័នដែលបញ្ជាអង្គភាពទាំងនេះ។ ក្រសួងការពារជាតិ ក៏មិនត្រូវបានផ្តល់អំណាច ឱ្យបំពេញការងារប្រើបុគ្គលិកសំខាន់ៗឡើយ ដូចជាការប្រមូល និងវិភាគព័ត៌មានជាដើម។[83]

ផ្ទុយទៅវិញ ការដឹកនាំបញ្ជាផ្ទាល់លើកងយោធពលខេមរភូមិន្ទ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមបញ្ជាការកំពូលតែមួយ ដែលបានបង្កើតឡើងថ្មី ដោយច្របាច់បញ្ចូលអគ្គសេនាធិការកំពូលពីមុន ចូលទៅក្នុងបញ្ជាការកំពូលដែលមានពីមុន ដើម្បីបង្កើតជាអង្គការចាត់តាំងតែមួយ ដឹកនាំដោយមេបញ្ជាការកំពូលរបស់កងយោធពលខេមរភូមិន្ទ។ ជារួម ទាំងមេបញ្ជាការកំពូល មេបញ្ជាការរងកំពូល មេបញ្ជាការ និងមេបញ្ជាការរងមួយចំនួននៃអគ្គមេបញ្ជាការចម្រុះ ដែលត្រូវបានដាក់ឈ្មោះថ្មី ត្រូវបានគេតែងតាំងជាក្បាលដឹកនាំបញ្ជាលើបញ្ជាការកងទ័ព បញ្ជាកងជើងទឹក កងទ័ពអាកាស កងពលធំ និងកងពលតូចអន្តរាគមន៍នៃ

---

[82] សុវត្តិ, គោលនយោបាយឈ្នះឈ្នះ-, ទំព័រ 267-268

[83] រាជរដ្ឋាភិបាលកម្ពុជា )RGC), អនុក្រឹត្យលេខ 37 អនក្រ, 16 ខែកុម្ភៈ 1999។

កងយោធពលខេមរភូមិន្ទ និងការិយាល័យអគ្គសេនាធិការជាន់ខ្ពស់ជាច្រើន រួមទាំងនាយកដ្ឋានស្រាវជ្រាវ និងស៊ើបការណ៍។[84] អង្គភាពកងយោធពលខេមរភូមិន្ទមួយចំនួន ត្រូវបានប្រមូលផ្តុំទៅជាក្រុមថ្មី ហើយកងឯកាពផ្សេងទៀត ត្រូវបានរៀបចំ និងចាត់តាំងឡើងវិញ។[85] នៅក្នុងការរៀបចំនេះ បញ្ជាការកងទ័ពត្រូវបានផ្តល់អំណាចកម្រិតមធ្យមខ្លះ លើយោធភូមិភាគ និងកងពលតូចអន្តរាគមន៍ ដែលមានមូលដ្ឋាននៅតាមខេត្តជាច្រើន ដោយមិនបានភ្ជាប់ជាមួយកងពលណាមួយរបស់កងយោធពលខេមរភូមិន្ទទេ។[86] ទោះជាយ៉ាងណាក៏ដោយ អគ្គសេនាធិការចម្រុះ ត្រូវបានគេបង្កើតឡើងដោយមានអំណាចច្រើនជាងអគ្គសេនាធិការកំពូលពីមុនទៅទៀត និងច្រើនជាងអង្គភាពបញ្ជាការដទៃទៀតទាំងអស់។ លោក ហ៊ុន សែនបានសង្កត់ធ្ងន់ថា សេនាធិការចម្រុះនេះត្រូវបានបង្កើតឡើង ដើម្បីជានាទូវ "ភក្តីភាពទាំងស្រុង" របស់កងកម្លាំងប្រដាប់អាវុធចំពោះ "បុព្វហេតុជាតិ" ក្នុងការ "រក្សានិងពង្រឹង..ស្ថិរភាព សន្តិសុខនិងសណ្តាប់ធ្នាប់សង្គម"។[87]

ចំពោះមូលហេតុនយោបាយផ្ទៃក្នុងគណបក្សប្រជាជនកម្ពុជាវិញ លោក កែ គឹមយ៉ាន ត្រូវបានតែងតាំងជាមេបញ្ជាការកំពូលថ្មី ខណៈលោកប៉ុល សារឿន ត្រូវបានតែងតាំងជាមេបញ្ជាការអគ្គសេនាធិការចំរុះថ្មី និងជាមេបញ្ជាការរងកំពូល។[88] ចំណុចនេះបញ្ជាក់បានថា នៅពេលអវត្តមានលោក កែ គឹមយ៉ាន នោះលោក ប៉ុល សារឿននឹងទទួលតួនាទីនៃអគ្គមេបញ្ជាការកំពូល ព្រមជាមួយនឹងតំណែងជាមេបញ្ជាការនាយសេនាធិការចម្រុះ។[89] លោកកែ គឹមយ៉ាន ដែលបានជំទាស់ និងមិនបានចូលរួមក្នុងការធ្វើរដ្ឋប្រហារឆ្នាំ១៩៩៧ នោះ ត្រូវបានគេនិយាយថា ខ្វះអំណាចបញ្ជាលោក ប៉ុល សារឿន ដែលជាអ្នកបញ្ជាកងកម្លាំងយោធាសំខាន់ៗ ចូលរួមក្នុងរដ្ឋប្រហារ។ នៅក្នុងការអនុវត្តជាក់ស្តែង អំណាចបញ្ជាកងយោធពលខេមរភូមិន្ទ ស្ថិតនៅជាមួយលោក ប៉ុល សារឿន លោកគន់ គឹម ដែលជាមនុស្សដែលលោក ហ៊ុន សែន ជឿទុកចិត្តយូរអង្វែងមក ហើយ និងជាអ្នកបានចូលរួមដ៏សំខាន់នៅក្នុងរដ្ឋប្រហារ ១៩៩៧ ព្រមទាំងមេបញ្ជាការយោធភូមិភាគមួយចំនួនទៀត។ ពួកគេទាំងអស់នេះ បានធានាដល់ការបន្តតំណែងរបស់លោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រី។

---

84 រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រឹត្យលេខ នស/រល /0199/21 ថ្ងៃទី 24 ខែកុម្ភៈឆ្នាំ 1999។

85 សុវត្ថិ Sowath, គោលនយោបាយឈ្មុះ ឈ្មុះ - ទំព័រ 269-270។

86 រាជរដ្ឋាភិបាលកម្ពុជា (RGC), ក្រសួងការពារជាតិ "ថតផ្ទាល់ខ្លួនរបស់មន្ត្រីជាន់ខ្ពស់កងយោធពលខេមរភូមិន្ទ ឆ្នាំ2002" ។ ស្ថានទូតអាមេរិកប្រចាំកម្ពុជាឆ្នាំ "កងយោធពលខេមរភូមិន្ទ ឆ្នាំ2003"។

87 គណបក្សប្រជាជនកម្ពុជា, ប្រវត្តិសាស្ត្រនៃការតស៊ូនេះ, ទំព័រ 182-185 ។

88 រាជរដ្ឋាភិបាលកម្ពុជា (RGC) ព្រះរាជក្រឹត្យលេខនស / រតូវ /0199/22 ថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ1999។

89 KOC, ការពាររាជាណាចក្រកម្ពុជា 2000 ៖ សន្តិសុខនិងការអភិវឌ្ឍន៍ភ្នំពេញ៖ ឆ្នាំ 2000) ទំព័រ 462 ។

*នៅថ្ងៃទី៩ ខែវិច្ឆិកាឆ្នាំ ១៩៩៩ លោក ហ៊ុន សែន បានតែងតាំងលោក គន់ គីម ជាមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ។[90] នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ លោក កែ គឹមយ៉ាន ត្រូវបានដកចេញពីមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ហើយត្រូវបានជំនួសដោយប៉ុល សារឿន។ លោក គន់ គីមត្រូវបានតែងតាំងជានាយអគ្គសេនាធិការចម្រុះ។ មេបញ្ជាការរងជាន់ខ្ពស់បន្ថែម និងថ្មីមួយចំនួនត្រូវបានតែងតាំង រួមទាំងលោក ហ៊ីង ប៊ុន ហៀង និងលោក សៅ សុខា ដែលទាំងពីរនាក់នេះគឺជាអ្នកដើរតួសំខាន់នៅក្នុងការធ្វើរដ្ឋប្រហារ។[91]*

## *កងយោធពលខេមរភូមិន្ទ (RCAF) បច្ចុប្បន្ន*

*កងយោធពលខេមរភូមិន្ទសព្វថ្ងៃនេះ មានសមាសភាពកងទ័ពជើងគោក ជើងទឹក និងជើងអាកាស។ ការសិក្សាមួយពិនិត្យមើលយុទ្ធសាស្ត្រការពារជាតិឆ្នាំ ២០១៣ របស់រដ្ឋាភិបាល បានកត់សម្គាល់ឃើញថា ការកែសម្រួលរចនាសម្ព័ន្ធនៃរចនាសម្ព័ន្ធបញ្ជាការកំពូលរបស់ខ្លួននៅឆ្នាំ ១៩៩៩ បានបន្សល់ទុកនូវ "ការត្រួតស៊ីគ្នាលើតួនាទី ការទទួលខុសត្រូវ និងការចាត់តាំងការងារ" និងកង្វះនិយមន័យទាក់ទងនឹងបទបញ្ជាចេញសមរភូមិ។[92] ទោះជាយ៉ាងណា ចាប់តាំងពីឆ្នាំ ២០១២មក ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលគ្រប់គ្រង និងស្និទ្ធជាមួយគណបក្សប្រជាជនកម្ពុជា បានចេញផ្សាយអត្ថបទសិក្សាពិនិត្យមើលឡើងវិញមួយស្តីពីរចនាសម្ព័ន្ធយោធា ដែលបានបង្ហាញថា នៅក្នុងអគ្គសេនាធិការកំពូល/អគ្គសេនាធិការចម្រុះ នាយសេនាធិការលោក គន់ គីម ជាអ្នកមានអំណាចបញ្ជាលើកងយោធពលខេមរភូមិន្ទលើសលុបលើគេឯង។ ប្រព័ន្ធផ្សព្វផ្សាយទាំងអស់នោះ បញ្ជាក់ថា មេបញ្ជាការកំពូលលោក ប៉ុល សារឿន និងមេបញ្ជាការកងទ័ពជើងគោកលោក មាស សុភា មានអំណាចតិចតួច ហើយថា រដ្ឋមន្ត្រីការពារជាតិលោក ទៀ បាញ់ វិញមានអំណាចបន្តិចបន្តួច ឬគ្មានអំណាចបញ្ជាផ្ទាល់តែម្តង។[93]*

---

90 រាជរដ្ឋាភិបាលកម្ពុជា (RGC) ព្រះរាជក្រឹត្យលេខនស / រតក /1199/192 ថ្ងៃទី 9 ខែវិច្ឆិកាឆ្នាំ 1999។

91 រាជរដ្ឋាភិបាលកម្ពុជា (RGC), រាជក្រឹត្យលេខ នសរ/កត /010/061 ថ្ងៃទី 22 ខែមករាឆ្នាំ 2009។

92 រាជរដ្ឋាភិបាលកម្ពុជា (RGC), ការពិនិត្យយុទ្ធសាស្ត្រការពារជាតិឆ្នាំ 2013 (ភ្នំពេញ ថ្ងៃទី 4 ខែធ្នូ ឆ្នាំ 2012) ទំព័រទី 12 ។

93 ប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានត្រួតពិនិត្យ រួមបញ្ចូលប្រព័ន្ធអនឡាញដូចជា ទូរទស្សន៍បាយ័ន, នគរវត្ត, រស្មីកម្ពុជា (CEN), ដើមអំពិល (DAP), កោះសន្តិភាព និងប្រេសញូអេស៊ា (ភាសាខ្មែរ)

ការវិភាគលើមុខតំណែងនានារបស់សមាជិកភាពនៃគណៈកម្មាធិការមជ្ឈិមបក្សរបស់គណបក្សប្រជាជនកម្ពុជា ដែលបានពង្រីកដោយសមាជវិសាមញ្ញគណបក្ស ក្នុងខែមករា-កុម្ភៈឆ្នាំ ២០១៥ បានបង្ហាញថា បន្ថែមពីលើការមានកងរាជអាវុធហត្ថ កងទ័ពជើងគោក និងកងទ័ពអាកាស ក៏មានកងយោធពលខេមរភូមិន្ទ ដែលមានអង្គភាពកងទ័ពជើងគោក មានជាអាទិ៍ កងពលធំអន្តរាគមន៍លេខ ២ កងពលធំអន្តរាគមន៍លេខ ៣ ក្រុមអង្គរក្សរបស់នាយករដ្ឋមន្ត្រី (ដែលគេស្គាល់ជាផ្លូវការថាជាទីបញ្ជាការអង្គរក្ស) កងពលតូចអន្តរាគមន៍លេខ៧០ កងពលតូចអន្តរាគមន៍លេខ៩១១ កងពលតូចអន្តរាគមន៍ទី១ កងពលតូចអន្តរាគមន៍លេខ១១ កងពលតូចអន្តរាគមន៍ទី ១៤ កងវរសេនាតូចយោធាភូមិភាគពិសេសលេខ៣ និង ៤ កងវរសេនាធំយោធាភូមិភាគលេខ ៤២ និងកងកម្លាំងប្រតិបត្តិការសឹករង កងពលធំយោធាភូមិភាគ ២ លេខ ២១ និងកងកម្លាំងប្រតិបត្តិការសឹករង និងកងកម្លាំងភូមិភាគប្រតិបត្តិការសឹករងទី៣ កងពលតូចលេខ៤១ និង៤២ នៃយុទ្ធភូមិភាគទី៤ និងកងកម្លាំងប្រតិបត្តិការសឹករង និងកងពលតូចលេខ៥១ ៥២ និង៥៣នៃយុទ្ធភូមិភាគទី៥ និងកងកម្លាំងប្រតិបត្តិការសឹករង។ ហើយនៅខែសីហាឆ្នាំ ២០១៧ កងពលតូចអន្តរាគមន៍លេខ១២៨ ជំនួយឲ្យយោធភូមិភាគ១ ក៏ត្រូវបានគេបង្កើតឡើង ដាក់បញ្ចូលក្នុងកងវរសេនាធំលេខ៤២។[94]

ការរៀបចំនៅក្នុងវិស័យការពារយោធា ដូចដែលលោក ប៉ុល សារឿន បានពណ៌នាថា បញ្ជាការកំពូល ជាផ្លូវការគឺជា "ស្ថាប័នកំពូលនៅក្នុងឋានានុក្រមនៃកងយោធពលខេមរភូមិន្ទ" និង "ជាមូលដ្ឋានសម្រាប់សម្របសម្រួលរវាងអគ្គសេនាធិការ និងក្រសួងការពារជាតិ" ក៏ប៉ុន្តែ "បញ្ជាការនៃកងទ័ពទាំងមូល" នៅតែជា "ការទទួលខុសត្រូវរបស់អគ្គសេនាធិការ។"[95] នាយទាហ៊ានជំនួយការឲ្យលោក ទៀ បាញ់ ក៏បានពន្យល់ផងដែរថា ខណៈ ដែលអគ្គសេនាធិការស្ថិតក្រោមបង្គាប់របស់ក្រសួងការពារជាតិ ប៉ុន្តែអគ្គសេនាធិការឯករាជពីក្រសួង។ ដូចគ្នានេះដែរ ទោះបីជាអគ្គសេនាធិការស្ថិតនៅ "ក្រោមបង្គាប់" បញ្ជាការកំពូលក៏ដោយ ក៏វានៅតែក្តាប់អំណាច "បញ្ជា និងគ្រប់គ្រងកងកម្លាំងទ័ពទាំងអស់" រួមទាំងកងទ័ពក្នុងយោធភូមិភាគ និងជា

---

94 សម្តេចតេជោហ៊ុនសែនកំពុងធ្វើដំណើរទៅសួរសុខកងទ័ពនៅយោធភូមិភាគទី១ ខេត្តស្ទឹងត្រែង ដើម្បីដោះស្រាយការលំបាករបស់កងកម្លាំងប្រដាប់អាវុធ ថ្ងៃទី16 ខែសីហាឆ្នាំ 2017 http://www.freshnewsasia.com/index.php/en/localnews/62887-2017-08-16-01-38-39.html (ចូលមើលនៅថ្ងៃទី 16 ខែសីហាឆ្នាំ 2017 )។

95 "ប្រទេសកម្ពុជា ៖ គណបក្សពង្រីកការត្រួតត្រាលើកងកម្លាំងសន្តិសុខ ចេញផ្សាយនៅថ្ងៃទី "4 ខែកុម្ភៈឆ្នាំ 2015 "https://www.hrw.org/news/2015/02/04/cambodia-party-extends-control-security - កម្លាំង ប៉ុលសារឿនយុទ្ធសាស្ត្រ DFID របស់សម្តេចតេជោ ហ៊ុន សែន ភ្នំពេញ) ៖ បោះពុម្ព 4 ឆ្នាំ 2014) ទំព័រ 32 ។

*របនាសម្ព័ន្ធ ដែលទទួលខុសត្រូវដោយផ្ទាល់សម្រាប់ "កិច្ចសហការជាមួយកងកម្លាំងសន្តិសុខ [ដទៃទៀត] ដើម្បីការពារនិងរក្សាសណ្តាប់ធ្នាប់សង្គម" ។*[96]

## *ការត្រួតត្រាបន្ថែមរបស់គណបក្សប្រជាជនកម្ពុជាលើកងកម្លាំងប្រដាប់អាវុធ*

*ទោះបីជាលោក ហ៊ុន សែន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពប៉ារីសក្នុងនាមគណបក្សប្រជាជនកម្ពុជា ហើយទោះជាបានប្តេជ្ញាបញ្ចប់ការគ្រប់គ្រងរបស់បក្សលើកងកម្លាំងប្រដាប់អាវុធ និងស្ថាប័នរដ្ឋដទៃក៏ដោយ ក៏គណបក្សប្រជាជនកម្ពុជាមិនដែលបោះបង់ចោលការត្រួតត្រាលើយោធាឡើយ (ឬនគរបាល តុលាការ ឬមន្ត្រីរដ្ឋដទៃទៀតឡើយ)។ មន្ត្រីយោធាជាន់ខ្ពស់ក្លាយជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាគណៈកម្មាធិការមជ្ឈិមបក្សនៃគណបក្សប្រជាជនកម្ពុជា និងចូលរួមក្នុងកិច្ចប្រជុំរបស់គណបក្ស។ ការអនុវត្តបែបនេះ បានក្លាយទៅជាការបើកចំហ និងផ្លូវការនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។*

*នៅផ្ទៃក្នុងគណបក្សប្រជាជនកម្ពុជា នៅតែបន្តដាក់អាទិភាពខ្ពស់លើការពង្រីកចំនួនមន្ត្រី និងទាហាននៅក្នុងកងកម្លាំងប្រដាប់អាវុធ ដោយមិនបញ្ចូលទាហាន ឬមន្ត្រីណាមកពីគណបក្សដទៃទៀតទេ ប៉ុន្តែបើសមាជិកមកពីបក្សផ្សេងៗ ដែលបានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ទើបអនុញ្ញាត។*[97] *មន្ត្រីជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ ដូចជាមេអគ្គសេនាធិការចម្រុះគន់ គឹម បានចូលរួមជាសាធារណៈជាអ្នកដឹកនាំក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជា ដើម្បីកសាងមូលដ្ឋានបក្ស ចាប់តាំងពីគណបក្សប្រជាជនកម្ពុជា បានបរាជ័យនៅក្នុងការបោះឆ្នោតឆ្នាំ ២០១៣។*[98] *ការងារនេះត្រូវបានពង្រីក បន្ទាប់ពីសមាជគណបក្សប្រជាជនកម្ពុជា ពីខែមករាដល់ខែកុម្ភៈ ឆ្នាំ២០១៥ ដើម្បីអនុវត្តន៍ការផ្លាស់ប្តូរនយោបាយយ៉ាងចំហ រួមមានការលើកកម្ពស់ការដឹកនាំគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន និងចំណោមទាហានក្នុងការប្រមូលផ្តុំរៀបចំកងទ័ព។*[99]

---

[96] សុវត្ថិ, គោលនយោបាយឈ្នះឈ្នះ, ទំព័រ 55-56។

[97] គណបក្សប្រជាជនកម្ពុជា, ប្រវត្តិសាស្ត្រនៃការតស៊ូ, ទំព័រ 289។

[98] "នាយឧត្តមសេនីយ៍គន់គីម អញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយសារាចរលើកទី ៣៨ នៃគណៈកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា។" ថ្ងៃទី 6 ខែកក្កដាឆ្នាំ 2015, http://beta.nokorwatnews.com/?p=31306#sthash.ePX98Ga3.dpuf (ចូលមើលនៅថ្ងៃទី 26 ខែកក្កដាឆ្នាំ 2015) ។

[99] "លោក អ៊ុងសំខាន់ ចុះទៅស្តាប់សកម្មភាពនិងរបាយការណ៍លទ្ធផលរបស់មន្ត្រីបក្សនៅក្នុងស្រុកដងទង់ (ថ្ងៃទី20 ខែកក្កដាឆ្នាំ 2015)" http: //

ការបង្ហាញអំណាចបញ្ជាខ្ពស់ផុតលេខរបស់លោក ហ៊ុន សែន លើកងយោធពលខេមរភូមិន្ទ បានធ្វើឡើង នៅក្នុងពេលប្រមូលផ្តុំថ្នាក់ដឹកនាំកងទ័ព ដែលលោកបានកោះប្រជុំនៅថ្ងៃទី ២៣ ខែកក្កដាឆ្នាំ ២០១៥ នៅទីស្នាក់ការផ្ទាល់ខ្លួនរបស់លោក នៅទួលក្រសាំងក្នុងខេត្តកណ្តាល ដែលមានមន្ត្រីកងទ័ពជាន់ខ្ពស់ កងរាជអាវុធហត្ថ កងទ័ពជើងទឹក កងទ័ពអាកាស និងមន្ត្រីប៉ូលិស ពីគ្រប់ទិសទីក្នុងប្រទេសកម្ពុជាមកចូលរួម។ យោងតាមប្រព័ន្ធផ្សព្វផ្សាយដែលជិតស្និទ្ធនឹងគណបក្សប្រជាជនកម្ពុជា ពួកគេទាំងអស់ជាថ្នាក់ដឹកនាំតំណាងឱ្យកងកម្លាំងសន្តិសុខចំនួន ១៨០,០០០ នាក់ (មួយសែនប្រាំបីម៉ឺន)។[100] ក្នុងឱកាសនេះ លោក ហ៊ុន សែន បានកំណត់និយមន័យ៦ចំណុចនៃ"ភារកិច្ចរបស់កងកម្លាំងប្រដាប់អាវុធ" ក្នុងនោះរួមទាំងផ្នែកការពារជាតិ និងផ្នែកសន្តិសុខនយោបាយក្នុងផ្ទៃប្រទេស។ ទាក់ទិននឹងផ្នែកសន្តិសុខនយោបាយក្នុងផ្ទៃប្រទេស លោក ហ៊ុន សែន បានចេញ "បទបញ្ជាដាច់ខាត" ថា កងកម្លាំងប្រដាប់អាវុធត្រូវតែ "ធានាថានឹងគ្មានបដិវត្តពណ៌" នៅក្នុងប្រទេសកម្ពុជាទេ ដែលលោកសំដៅចលនានានាប្រឆាំងរដ្ឋាភិបាលនៅអឺរ៉ុបខាងកើត។ លោកបញ្ជាក់ថា កងទ័ពត្រូវតែ "កំចាត់ចោលសកម្មភាពទាំងឡាយណាបង្កឡើងដោយក្រុមណាមួយ ឬបក្សណាមួយ "ដែលត្រូវបានចាត់ថា "ខុសច្បាប់"។[101] សារព័ត៌មានស្និទ្ធនឹងគណបក្សប្រជាជនកម្ពុជា បានរាយការណ៍ថា អ្វីដែលលោក ហ៊ុន សែន និយាយអំពី "បដិវត្តពណ៌" នោះ គឺជាការអះអាងថា គណបក្សសង្គ្រោះជាតិ (CNRP) មានគំរោងញុះញង់ឲ្យមានការតវ៉ាដ៏ធំមួយ ដើម្បីផ្តួលរំលំគាត់។[102]

រដ្ឋមន្ត្រីការពារជាតិលោក ទៀ បាញ់ បាននិយាយបន្ទរតាមបញ្ជារបស់លោក ហ៊ុន សែន ទៅកាន់មេបញ្ជាការកងកម្លាំងសន្តិសុខនៅក្នុងសុន្ទរកថាក្រោយមកនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ដោយបន្ថែមថាផែនការធ្វើបដិវត្តពណ៌របស់គណបក្សប្រឆាំងកន្លងមក បានធ្វើឱ្យគាត់ "ខឹងយ៉ាងខ្លាំង" ហើយថាឥឡូវនេះវាចាំបាច់ដើម្បី "គ្រប់គ្រងលទ្ធិប្រជាធិបតេយ្យ "នៅក្នុងប្រទេសកម្ពុជា ដើម្បីបង្ការភាពអនាធិបតេយ្យ។[103]

---

www.dap-news.com/2011-06-14-02-39-55/95545-2015-07-20-07-17-29.html (ចូលមើលថ្ងៃទី 20 ខែកក្កដា ឆ្នាំ 2015)។

[100] វិភាគ ៖" បុរសខ្លាំងតេជោហ៊ុនសែន លើកយកយុទ្ធសាស្ត្រប្រឆាំងបដិវត្តពណ៌និងរក្សាភាពស្ងប់ស្ងាត់ (ថ្ងៃទី 23 កក្កដា 2015,)" http: //www.dap-news.org) ។ .com / 2011-06-14-02-39-55 / 95757-2015-07-23-07-58-54.html (ចូលមើលថ្ងៃទី 23 ខែកក្កដាឆ្នាំ 2015)

[101] សម្តេចហ៊ុនសែន ថ្ងៃសៅរ៍ទី) "ភារកិច្ចកងកម្លាំងប្រដាប់អាវុធ"23 កក្កដាឆ្នាំ 2015)

[102] វិភាគ" :បុរសខ្លាំងតេជោហ៊ុនសែន លើកយកយុទ្ធសាស្ត្រប្រឆាំងបដិវត្តពណ៌និងរក្សាភាពស្ងប់ស្ងាត់ ថ្ងៃទី) "23 កក្កដា 2015, http: //www.dap-news.org) ។ .com / 2011-06-14-02-39-55 / 95757-2015-07-23-07-58-54.html (ចូលមើលថ្ងៃទី 23 ខែកក្កដាឆ្នាំ 2015)

[103] "ទៀបាញ់រំព្ញកពេលវេលាមុនការព្រមព្រៀងនយោបាយ។ " កម្ពុជាឌេលី ថ្ងៃទី 29 ខែកក្កដាឆ្នាំ២០១៥ ) https://www.cambodiadaily.com/news/tea-

នៅថ្ងៃទី២៩ ខែកក្កដា លោក ជា ដារ៉ា មេបញ្ជាការរងជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ បានថ្លែងទៅកាន់កិច្ចប្រជុំមន្ត្រីយោធា និងនគរបាលថា ពួកគេត្រូវតែការពារគណបក្សប្រជាជនកម្ពុជា ប្រឆាំងនឹងគណបក្សសង្គ្រោះជាតិ និងរក្សាទុកលោក ហ៊ុន សែនឱ្យនៅកាន់អំណាច ពីព្រោះ "កងទ័ពជារបស់គណបក្សប្រជាជនកម្ពុជា" ហើយលោក ហ៊ុន សែន គឺជាអ្នក "ចិញ្ចឹមបីបាច់ បណ្តុះបណ្តាល ដឹកនាំ និងបញ្ជា" គណបក្សប្រជាជនកម្ពុជា។[104] មេបញ្ជាការកងរាជអាវុធហត្ថ លោកសៅ សុខា គឺស្ថិតក្នុងចំណោមមេបញ្ជាការរងមួយរូបនៃកងយោធពលខេមរភូមិន្ទ ដែលបានចូលរួមក្នុងបទបង្ហាញរបស់លោក ជា ដារ៉ា។[105]

បន្ទាប់ពីសុន្ទរកថាថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៥ របស់លោក ហ៊ុន សែនមក ពួកមេបញ្ជាការកំពូលៗនៃកងយោធពលខេមរភូមិន្ទ និងមេបញ្ជាការកងរាអាវុធហត្ថកម្ពុជា បានបង្ហាញភាពលំអៀងនយោបាយរបស់ពួកគេយ៉ាងសម្ញែងខ្ពស់ដល់កម្រិតមួយដែលមិនធ្លាប់មាន ដោយបានចុះផ្សព្វផ្សាយជាសាធារណៈយ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់គណបក្សប្រជាជនកម្ពុជាទៀតផង។ ចំណោមអ្នកលេចធ្លោបំផុតក្នុងការបង្ហាញឥទ្ធិពលត្រួតត្រារបស់គណបក្សប្រជាជនកម្ពុជាទៅលើផ្នែកយោធានោះ គឺមានលោក ប៉ុល សារឿន ដែលជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ លោក គុន គីម មេបញ្ជាការអគ្គសេនាចម្រុះ និងលោក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ពួកគេបានបង្ហាញខ្លួននៅក្នុងពិធីជប់លៀងនានាដោយឈរផ្អែកស្លាកសញ្ញារបស់គណបក្សប្រជាជនកម្ពុជា ដើម្បីផ្សព្វផ្សាយគោលនយោបាយគណបក្ស និងត្រួតពិនិត្យ និងជំរុញការអនុវត្តន៍គោលនយោបាយបក្ស។ ពួកគេ និងមេបញ្ជាការជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទដទៃទៀត ក៏មានតួនាទីជាម្ចាស់កម្មវិធីរបស់គណបក្សប្រជាជនកម្ពុជា ក្នុងព្រឹត្តិការណ៍ស្វាគមន៍សមាជិកគណបក្សដែលបានជ្រើសរើសថ្មីៗ រួមទាំងការទទួលពួកអ្នកចុះចូលគណបក្សប្រជាជនកម្ពុជា ពីគណបក្សសង្គ្រោះជាតិផង។[106]

---

banh-recalls-time-before-political-detente-89845/ (ចូលមើលថ្ងៃទី29 ខែកក្កដាឆ្នាំ 2015)។ "ប្រមុខការពារជាតិប្តេជ្ញាគ្រប់គ្រងលទ្ធិប្រជាធិបតេយ្យ" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 29 ខែកក្កដាឆ្នាំ 2015 http://www.phnompenhpost.com/national-defence-chief-vows-control-democracy (ចូលមើលថ្ងៃទី 29 ខែកក្កដាឆ្នាំ 2015)

[104] លោកផ្កាយមាសបួនជាតារ៉ា ថាកងទ័ពជាទ័ពរបស់បក្សប្រជាជនកម្ពុជា" ថ្ងៃទី 29 ខែកក្កដាឆ្នាំ 2015, http://www.rfa.org/khmer/news/politics/Dara-said- RCAF-belong-to-CPP-07282015235842.html (ចូលមើលថ្ងៃទី 29 ខែកក្កដាឆ្នាំ 2015)

[105] "មេកងយោធពលខេមរភូមិន្ទម្នាក់ ប្រកាសថាកងទ័ពជាកម្មសិទ្ធិរបស់គណបក្សប្រជាជនកម្ពុជា" (ថ្ងៃទី 29 កក្កដា 2015, http://vodhotnews.com/31138) (ចូលមើលថ្ងៃទី 29 ខែកក្កដាឆ្នាំ 2015។)

[106] "ប៉ុល សារឿន ថ្លែងសុន្ទរកថាសំខាន់ៗស្តីពីតម្លៃនៃសន្តិភាពដល់សកម្មជនយុវជននៃសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ  ថ្ងៃទី)"24 ខែសីហាឆ្នាំ 2012) 2015, http: //www.dap-news.com/2011-06-14-02-39-55/97747-2015-08-24-05-26-18.html (ចូលមើលថ្ងៃទី 24 ខែសីហាឆ្នាំ 2015); "ឧត្តម

*ក្នុងអំឡុងពេលប៉ុន្មានខែបន្តបន្ទាប់ក្នុងឆ្នាំ២០១៥ បទបញ្ជារបស់ហ៊ុនសែន ដើម្បីទប់ស្កាត់ការគំរាមកំហែង ដែលគេសន្មត់ថា ជាបដិវត្តពណ៌នោះ ត្រូវបានផ្សព្វផ្សាយតាមរយៈខ្សែសង្វាក់បញ្ជា ទៅកាន់យោធភូមិភាគ និងអង្គភាពកងទ័ពក្នុងតំបន់ផ្សេងៗ និងអង្គភាពកងរាជអាវុធហត្ថ រហូតដល់ទាហ៊ានកម្រិតខេត្ត និងស្រុក។[107] លោក ប៉ុល សារឿន និងមេបញ្ជាការកងរាជអាវុធហត្ថដទៃទៀត ក៏បានប្រាប់ពួកគេដែរថា ក្រុមនយោបាយប្រឆាំងលោក ហ៊ុន សែន គឺជា "មនុស្សមិនស្មោះត្រង់ និងគ្មានសីលធម៌" ជាជនដែល "តែងតែបង្កើតរឿងរ៉ាវ បំភ្លៃរឿងរ៉ាវ និងប្រើប្រជាពិថុតិក្នុងចេនាអាក្រក់អំពាវនាវឲ្យផ្តួលរំលំរាជរដ្ឋាភិបាល" ។[108]*

---

សេនីយ៍គន់គីមអញ្ជើញជាអធិបតីស្តាប់បុព្វកថាលើការវិវឌ្ឍន៍និងការរីកចម្រើនរបស់គណបក្សប្រជាជន "http[://beta.nokorwatnews.com/??p=35802#sthash.HjoUNsQH.dpuf (ចូលមើលថ្ងៃទី 25 ខែកក្កដាឆ្នាំ 2015); គណៈកម្មាធិការមជ្ឈឹមបក្ស ចុះជួយខេត្តស្វាយរៀង ធ្វើការជួបប្រជុំដើម្បីប្រមូលលទ្ធផលនៃការអនុវត្តន៍កាតព្វកិច្ច, http://beta.nokorwatnews.com/?p=36006#sthash.Xo3PHURJ.dpuf (ចូលមើលថ្ងៃទី 26 ខែកក្កដាឆ្នាំ 2015) ។ "សៅសុខាផ្តល់សុន្ទរកថាសំខាន់ៗស្តីពីតួនាទីរបស់កងរាជអាវុធហត្ថក្នុងការថែរក្សាសន្តិភាពនិងស្ថេរភាព  ថ្ងៃទី)"25 ខែសីហាឆ្នាំ 2015) http: //www.cambodiadaily.com/news/lao-sakha-two-bapakatha- //www.dap-news.com/2011-06-14-02-39-55/97629-2015-08-22-04-15-28 (ចូលមើលថ្ងៃទី 25 ខែសីហាឆ្នាំ 2015)" សៅសុខា សមាជិកគណៈកម្មាធិការកណ្តាល ចូលរួមធ្វើជាអធិបតីក្នុងការប្រជុំពិនិត្យលទ្ធផលនៃសកម្មភាពការងារ "ថ្ងៃទី 29 ខែសីហាឆ្នាំ 2015, http://www.dap-news.com/2011-06-14-02-39 ។ -55 / 98065-2015-08-29-03-02-08.html (ចូលមើលថ្ងៃទី 29 ខែសីហាឆ្នាំ 2015); សមាជិកគណបក្សសង្គ្រោះជាតិជាង 500 នាក់បានចូលរួមជីវភាពនយោបាយជាមួយគណបក្សប្រជាជននៅខេត្តឧត្តរមានជ័យ " ថ្ងៃទី 5 ខែសីហាឆ្នាំ 2012) 2015, http://www.dap-news.com/2011-06-14-02-39-55 / 96302-2015-08-01-04-58-09.html (ចូលមើលថ្ងៃទី 1 ខែសីហាឆ្នាំ 2015) ។ "មាសសុភា អញ្ជើញប្រកាសទទួលស្គាល់សមាជិកថ្មីចំនួន 800 នាក់នៅក្នុងខណ្ឌសែនសុខ" (ថ្ងៃទី 22 ខែសីហាឆ្នាំ 2015) http://www.dap-news.com/2011-06-14-02-39-55 / 97618-2015-08-22-03-12-27.html (ចូលមើលថ្ងៃទី 22 ខែសីហាឆ្នាំ 2015)។

[107] "ពិធីផ្សព្វផ្សាយអនុសាសន៍សម្តេចតេជោដល់តំបន់សឹករងខេត្តកំពង់ធំ ថ្ងៃទី) "4 ខែសីហាឆ្នាំ 2015) http://kampucheathmey.com/kpt/?p = 49999 (ចូលមើលថ្ងៃទី 4 ខែសីហាឆ្នាំ 2015)។ "អភិបាលខេត្តតាកែវប្រាប់កងទ័ពឱ្យត្រៀមខ្លួនដើម្បីបង្ក្រាបអ្នកដែលប្រើបដិវត្តពណ៌ដើម្បីផ្តួលរំលំរាជរដ្ឋាភិបាល" (ថ្ងៃទី 11 ខែសីហាឆ្នាំ 2014), http: // www ។ khmerhn.com / /www.dap-news.com/2011- 06-14-02-39-55 / 96898-2015-08-11-08-37-12.html (ចូលមើលថ្ងៃទី11 ខែសីហាឆ្នាំ 2014)។ កងកម្លាំងប្រដាប់អាវុធ ត្រូវតែគោរពតួនាទីនិងភារកិច្ច 6 ចំណុចរបស់ខ្លួន ក្នុងការការពារសន្តិសុខនិងសណ្តាប់ធ្នាប់។ ថ្ងៃទី 18 ខែសីហាឆ្នាំ 2015 http: // kampucheathmey.com/kpt/?p = 58048 (ចូលមើលនៅថ្ងៃទី 18 ខែសីហាឆ្នាំ 2015); "ការផ្សព្វផ្សាយកាតព្វកិច្ចចំនួន 6 ចំណុចដល់ទាហានរបស់សម្តេចតេជោហ៊ុនសែន នាយករដ្ឋមន្ត្រី ថ្ងៃទី) "6 ខែសីហាឆ្នាំ 2015) http://kampucheathmey.com/kpt/?p=58142 (ចូលមើលនៅថ្ងៃទី 18 ខែសីហាឆ្នាំ 2015); "មេបញ្ជាការកងទ័ព ៖ កងយោធពលខេមរភូមិន្ទត្រូវតែការពាររដ្ឋាភិបាលស្របច្បាប់ ថ្ងៃទី) "25 ខែសីហាឆ្នាំ 2015) http://www.dap-news.com/2011-06-14 -02-39-55 / 97856-2015-08-25-10-31-59.html (ចូលមើលថ្ងៃទី 25 ខែសីហាឆ្នាំ 2015)។ "ទៀវិញជួបពិភាក្សាជាមួយសមាជិកសភាមណ្ឌល ក្នុងស្រុកមណ្ឌលសីមា "ថ្ងៃទី 29 ខែតុលា ឆ្នាំ 2015, http://dap-news.com/2011-06-14-02-39-55/98079-2015-08)។ - 29-05-27-09.html (ចូលមើលថ្ងៃទី 29 ខែសីហាឆ្នាំ 2015)។

[108] "ឧត្តមសេនីយ៍ជាតារ៉ា និងកងទ័ពនៅលើប្រាសាទព្រះវិហារ បង្ហាញពីការគាំទ្រដល់យន្តការសម្តេចតេជោហ៊ុនសែន ដើម្បីដោះស្រាយបញ្ហាព្រំដែន" ថ្ងៃទី 21 ខែសីហាឆ្នាំ 2015, http://www.dap-news.com/2011-06-14-02-39-55/97546-2015-08-21-02-58-54.html (ចូលមើលនៅថ្ងៃទី 21 ខែសីហាឆ្នាំ 2015 ); "ឧត្តមសេនីយ៍ជាតារ៉ា ៖ ក្នុងកងទ័ពសមរភូមិមុខ ប្រកាសគាំទ្រយ៉ាងពេញទំហឹង ដល់យន្តការដោះស្រាយបញ្ហាព្រំដែនជាមួយបណ្តាប្រទេសជិតខាងរបស់សម្តេចតេជោហ៊ុនសែន" ថ្ងៃទី 22 ខែសីហាឆ្នាំ 2015។ http: //www.dap-news.com/2011-06-14-02-39-55/97631-2015-08-22-04-30-01.html (ចូលមើលថ្ងៃទី 22 ខែសីហាឆ្នាំ 2015); "នគរបាល កងរាជអាវុធហត្ថ បង្ហាញការគាំទ្រដល់ហ៊ុនសែនលើបញ្ហាផែនទី" កម្ពុជាឌេលីថ្ងៃទី 24 ខែសីហាឆ្នាំ 2015 https://www.cambodiadaily.com/news/police- military-show-support-for-hun-sen-on-maps-issue-92354 / (ចូលមើលថ្ងៃទី 24 ខែ

*នៅថ្ងៃទី៩ ខែកញ្ញាឆ្នាំ ២០១៥ លោក សាយ ឈុំ អនុប្រធានគណបក្សប្រជាជនកម្ពុជា បានណែនាំយ៉ាងសម្ងាត់ថា កងកម្លាំងប្រដាប់អាវុធតាមមូលដ្ឋាន ដែលមិនទាន់បានធ្វើដូច្នេះ ត្រូវតែចេញសេចក្ដីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រជំហររបស់លោក ហ៊ុន សែនស្ដីពីបញ្ហាព្រំដែន។[109] មេបញ្ជាការកំពូលលោក ប៉ុល សារឿន បានបន្ទរតាមសេចក្ដីថ្លែងការណ៍នេះនៅថ្ងៃតែមួយ ដោយវាយប្រហារមនុស្សរបស់គណបក្សសង្គ្រោះជាតិដែលរិះគន់លោក ហ៊ុន សែន ថាជា "ក្រុមមនុស្សអសីលធម៌ ដែលនិយាយកុហក និងមួលបង្កាច់ការពិត"។[110] បន្ទាប់មក លោក សៅ សុខា ក៏បានធ្វើតាម។[111] ការស្នើសុំគាំទ្រពីអង្គភាពមូលដ្ឋានបានចេញជាលទ្ធផល។[112] ការណែនាំកងកម្លាំងប្រដាប់អាវុធឲ្យធ្វើសកម្មភាពប្រឆាំងនឹងក្រុមប្រឆាំងត្រូវបានគេធ្វើម្ដងហើយម្ដងទៀត បញ្ចេញសំឡេងគំរាមកំហែងកាន់តែច្រើននៅឆ្នាំ ២០១៦ ជាពិសេសបន្ទាប់ពីមានការតវ៉ាដោយសន្តិវិធីតូចមួយដឹកនាំដោយសង្គមស៊ីវិល ក្នុងខែឧសភាប្រឆាំងនឹងការចាប់ខ្លួន និងការចោទប្រកាន់ដែលមានចរិតនយោបាយលើអ្នកការពារសិទ្ធិមនុស្សចំនួនប្រាំនាក់ ពាក់ព័ន្ធនឹងសកម្មភាពរបស់ពួកគេប្រឆាំងការរំលោភសិទ្ធិមនុស្ស។ [113]*

---

សីហាឆ្នាំ 2015); "ការពារដាច់ខាត មិនឱ្យមានបដិវត្តពណ៌ក្នុងព្រះរាជាណាចក្រកម្ពុជា" ថ្ងៃទី 28 ខែសីហាឆ្នាំ 2015 http://beta.nokorwatnews.com/?p= 43321 # sthash.Qsg1l4Lf.dpuf (ចូលមើលថ្ងៃទី 28 ខែសីហាឆ្នាំ 2015)។

[109] គណបក្សប្រជាជនកម្ពុជា "ជម្រាបជូនប្រធានគណៈកម្មការរាជធានីខេត្ត "46/15 លចកខ (បោះត្រា  នៅថ្ងៃទី ("សម្ងាត់"9 ខែកញ្ញាឆ្នាំ 2015 ឯកសាររបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ាយវ៉ច្ឆ។

[110] "កងទ័ពថ្កោលទោសដាច់អហង្កា អ្នកបង្កាច់បង្ខូចរាជរដ្ឋាភិបាលក្នុងសំណុំរឿងផែនទីនិងព្រំដែន" (ថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 2015) (ចូលមើលថ្ងៃទី 10 ខែកញ្ញាឆ្នាំ 2015) "ប្រមុខកងទ័ព ជំរុញឲ្យយោធាទាំងអស់ ទប់ស្កាត់ឲ្យបានដាច់ខាតនូវបុគ្គលណា ដែលមាននិន្នាការ បង្ករអរិភាពចំពោះជាតិ សាសនា និងសង្គម" ថ្ងៃទី 15 ខែកញ្ញាឆ្នាំ 2015, http: //www.dap-news.com/2011-06-14-02-39-55/99154-2015 -09-15-07-43-36.html (ចូលមើលថ្ងៃទី 15 ខែកញ្ញាឆ្នាំ 2015) ។

[111] "នាទីរបស់នាយឧត្តមសេនីយ៍ សៅសុខា គាំទ្រចំពោះសម្ដេចអគ្គមហាសេនាធិបតីតេជោហ៊ុនសែន "http://beta.nokorwatnews.com/?p =46981 #sthash.PB9s8aXb.dpuf (ចូលមើលថ្ងៃទី 13 ខែកញ្ញាឆ្នាំ 2015)។

[112] ឧត្តមសេនីយ៍ត្រីវ៉ាសារិទ្ធ មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តត្បូងឃ្មុំ ប្រកាសគាំទ្រសេចក្ដីថ្លែងការរបស់សម្ដេចតេជោហ៊ុនសែនស្ដីអំពីបញ្ហាព្រំដែន" ។ hun sen sdei ampi banhaha prum-den), [nd], http://beta.nokorwatnews.com/?p=47619#sthash.Wi4lvNCp.dpuf (ចូលមើលថ្ងៃទី 16 ខែកញ្ញាឆ្នាំ 2015)។

[113] "ប្រទេសកម្ពុជា ៖ ត្រូវបញ្ឈប់យុទ្ធនាត្រួតពិនិត្យនិងដាក់កំហិតសិទ្ធិ និងការចោទប្រកាន់ដែលមានការជំរុញខាងនយោបាយ ដែលគំរាមកំហែងដល់ការងារសិទ្ធិមនុស្ស" ចេញផ្សាយនៅរាត្រីថ្ងៃទី 3 ខែឧសភាឆ្នាំ 2016 អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ាយវ៉ច្ឆ https://www.hrw.org/news/2016/05/03/cambodia-cease- campaign-curtail-rights-monitoring.

នៅពេលរដ្ឋាភិបាលប្រើប្រាស់ការឃុំឃាំងបណ្តោះអាសន្ន ការគំរាមកំហែង និងការបំភិតបំភ័យដទៃទៀត ដើម្បីបង្ក្រាបការតវ៉ាទាំងនេះ កូនប្រុសពៅរបស់លោក ហ៊ុន សែន គឺលោក ហ៊ុន ម៉ានិត ដែលជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ចក្រសួងការពារជាតិ នៅទីបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ បានបង្ហាញទិដ្ឋភាពជាផ្លូវការអំពីហេតុអ្វីទើបចាំបាច់ដែលត្រូវធ្វើដូច្នោះ។ នៅក្នុងបទសម្ភាសន៍មួយ ដែលចេញផ្សាយនៅដើមខែមិថុនា ឆ្នាំ២០១៦ លោក ហ៊ុន ម៉ានិត បានបញ្ជាក់ថា នៅពេលការបោះឆ្នោតថ្មីនៅកម្ពុជាមកដល់ អាជ្ញាធរមិនត្រូវអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាល "ប្រមូលផ្តុំប្រជាជនធ្វើចលនាបំពានលើរដ្ឋាភិបាលទេ" ដោយពន្យល់ថា "ការប្រមូលផ្តុំតូចៗ គឺជាការចាប់ផ្តើមមួយ ហើយប្រសិនបើមិនអាចគ្រប់គ្រងវាទេ វានឹងឈានទៅដល់បាតុកម្មកាន់តែធំឡើងៗ"។ លោក ហ៊ុន ម៉ានិត បានបន្ថែមថា "ពួកអ្នកតវ៉ាដើងចាស់ ត្រូវបានគេស្គាល់ច្បាស់ទាំងនៅក្នុងប្រទេសកម្ពុជា ទាំងនៅក្រៅប្រទេស ចំពោះការតវ៉ាញឹកញាប់របស់ពួកគេ លើបញ្ហាដីធ្លី សិទ្ធិមនុស្ស ឬបញ្ហាប្រជាធិបតេយ្យ"។[114]

នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៦ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ឧត្តមសេនីយ៍ទៀ បាញ់ បានរំលឹកឡើងវិញថា គោលនយោបាយការពារជាតិរបស់រាជរដ្ឋាភិបាល តម្រូវឱ្យកងយោធពលខេមរភូមិន្ទរាំងខ្ទប់ "បដិវត្តពណ៌" ដែលជាការបន្តលាបពណ៌ខ្លាំងឡើងៗរបស់គណបក្សប្រជាជនកម្ពុជាទៅលើរាល់បាតុកម្មអហិង្សាទាំងអស់។[115]

នៅថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០១៦ យោងទៅតាមរបាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ ដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា លោក ប៉ុល សារឿន មេបញ្ជាការកំពូល បានអំពាវនាវនៅក្នុងកិច្ចប្រជុំរៀបចំផែនការមួយនៅក្នុងបញ្ជាការកំពូល "ដោយស្នើឱ្យយោធាទាំងមូលត្រូវតែកំចាត់ និងបំបាត់ចោលជាបន្ទាន់នូវជនណាម្នាក់ និងបុគ្គលទាំងអស់ដែលមានគំនិតចង់បំផ្លាញសន្តិភាព ធ្វើឱ្យមានចលាចលក្នុងសង្គមកម្ពុជា"។ លោក ប៉ុល សារឿន បានបន្តទៀតថា គ្រប់អង្គភាពយោធា ត្រូវចូលរួមក្នុងការបង្ការរាល់បទល្មើសប្រឆាំងនឹងគោលនយោបាយ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។ លើសពីនេះទៀត លោកឧត្តម

---

114 "ប្រធានស៊ើបអង្កេតនិយាយអំពីការតវ៉ានិងការផ្លាស់ប្តូររបប", ថ្ងៃទី 1 ខែមិថុនាឆ្នាំ 2016, http://www.khmertimeskh.com/news/25624/intelligence-chief-talks-about-protests-and-regime-change/ (ចូលមើលថ្ងៃទី 2 ខែមិថុនាឆ្នាំ 2016)។

115 "មន្ត្រីកងយោធពលខេមរភូមិន្ទ ត្រូវបានប្រាប់ឲ្យការពាររដ្ឋាភិបាល "ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 5 ខែកក្កដាឆ្នាំ 2016, http://www.phnompenhpost.com/national/rcaf-officials-told-protect-govt) ចូលមើលថ្ងៃទី 6 ខែកក្កដាឆ្នាំ 2016)។

*សេនីយរូបនេះបាននិយាយសង្កត់ធ្ងន់ថា "កងទ័ពត្រូវចូលរួមជាមួយប្រជាពលរដ្ឋតាមមូលដ្ឋាននីមួយៗ ដើម្បីពង្រឹងសាមគ្គីភាពជាតិ ដើម្បីទប់ស្កាត់ទាន់ពេលវេលានូវកងកម្លាំងជ្រុលនិយម ដែលជំរុញឱ្យមានអស្ថិរភាពនៅក្នុងសង្គមជាតិ ហើយជាពិសេស ទប់ស្កាត់ឱ្យបានដាច់ខាតនូវការបង្កភាពចលាចល ឬសកម្មភាពណាដែលមានគំនិតចង់បំផ្លាញសន្តិភាព គឺត្រូវតែបំបាត់ចោលភ្លាមៗ។"[116] ក្នុងចំណោមមេបញ្ជាការរងកំពូលៗដែលមានវត្តមាននៅក្នុងអង្គប្រជុំនោះដែរ គឺលោក គន់ គីម និងលោក ហ៊ីង ប៊ុនហៀង ដែលអ្នកទាំងពីរបានគាំទ្រភ្លាមៗចំពោះសុន្ទរកថារបស់លោក ទៀ បាញ់ និងលោក ប៉ុល សារឿន។[117] របាយការណ៍មួយ ដែលត្រូវបានបង្ហាញដល់សន្និបាតគណៈមជ្ឈិមបក្សប្រជាជនកម្ពុជា នៅថ្ងៃទី១៩ ខែកក្កដាឆ្នាំ ២០១៦ បានអំពាវនាវឱ្យគណបក្ស ចាប់យកគ្រប់ឱកាស ដើម្បីវាយលុកដ៏ខ្លាំងក្លាប្រឆាំងនឹងគណបក្សប្រឆាំងតាមរយៈ "ការបន្តពង្រឹងឧបករណ៍រដ្ឋអំណាច ជាពិសេស គឺប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ"។[118]*

*សក្តានុពលនៃកងកម្លាំងប្រដាប់អាវុធ ក្នុងការដឹកនាំបង្ក្រាបខាងនយោបាយនៅទូទាំងប្រទេស ត្រូវបានលើកកម្ពស់ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៥ តាមរយៈការចាប់ផ្តើមឡើងវិញ និងការឲ្យធ្វើសកម្មភាព និងពង្រីកសមាគមអតីតយុទ្ធជនកម្ពុជា ដែលក្នុងនោះ លោក ហ៊ុន សែន ជាប្រធាន ហើយលោក គន់ គីមជាអគ្គលេខា។ សមាគមដែលមានសមាសភាពយោធាតែគ្មានអាវុធនេះ មានប្រសិទ្ធិភាពជាអង្គការមហាជន។ នៅខែមិថុនា ឆ្នាំ២០១៦ សមាគមនេះបានអះអាងថា មានសមាជិកចំនួន ៧២,២៥០នាក់ (ប្រាំពីរម៉ឺនពីរពាន់ពីររយហាសិប) ដោយមានរចនាសម្ព័ន្ធ ឋានានុក្រមនៃគណៈកម្មាធិការ និងសាខានៅកម្រិតជាតិ ខេត្ត ក្រុង*

---

116 "ប្រមុខកងទ័ព ៖ វាចាំបាច់ដើម្បីបំបំបាត់និងលះបង់បុគ្គលម្នាក់ណាដែលមានចិត្តគំនិតចង់បំផ្លាញសន្តិភាព" (http://bayontv.com.kh/archives/71756, 5 កក្កដា 2016) (ចូលមើលខែកក្កដា 6 ឆ្នាំ 2016) "ទប់ស្កាត់សកម្មភាព ដែលមានគំនិតធ្វើឱ្យខូចសន្តិភាពនៅកម្ពុជា" http://beta.nokorwatnews.com/?p=108665, ថ្ងៃទី 10 ខែកក្កដាឆ្នាំ 2016 (ចូលមើលថ្ងៃទី 10 ខែកក្កដាឆ្នាំ 2016)។

117 "ប្រមុខកងទ័ព ៖ វាចាំបាច់ដើម្បីលុបបំបាត់និងលះបង់បុគ្គលម្នាក់ណា ដែលមានគំនិតគឺចង់បំផ្លាញសន្តិភាព" (http://bayontv.com.kh/archives/71756, 5 កក្កដា 2016 (ចូលមើលខែកក្កដា 6 ឆ្នាំ 2016)។ "ទប់ស្កាត់សកម្មភាព ដែលមានគំនិតធ្វើឱ្យខូចដល់សន្តិភាពនៅកម្ពុជា។ " http://beta.nokorwatnews.com/?p=108665, July 10, 2016 (ចូលមើលថ្ងៃទី 10 ខែកក្កដាឆ្នាំ 2016) "ឧត្តមសេនីយ៍ហ៊ីងប៊ុនហៀង ៖ ទាហានគឺជាអ្នក បម្រើប្រជាជន។ គ្រប់ទីកន្លែងដែលមានកងទ័ព ពួកគេត្រូវតែធ្វើតែល្អ ដើម្បីជួយដល់ប្រជាជន " ថ្ងៃទី 6 ខែកក្កដាឆ្នាំ 2016 http: //www.freshnewsasia.com/index.php/en/28287-2016-07-06-09-00 -11.html (ចូលមើលថ្ងៃទី 6 ខែកក្កដាឆ្នាំ 2016)។ "ឧត្តមសេនីយ៍គន់គីម បានចុះលើកទឹកចិត្តដល់មន្ត្រីនៅតាមព្រំដែនកម្ពុជាថៃ ថ្ងៃទី "9 ខែកក្កដាឆ្នាំ 2016 http://dap- news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93%E1%9E%80%E 1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A% E1%9E%91%E1%9F%81%E1%9E%9F/10154.html (ចូលមើលថ្ងៃទី 9 ខែកក្កដា 2016) ។

118 គណៈកម្មាធិការមជ្ឈិម គណបក្សប្រជាជន "របាយការណ៍ស្តីពីសភាពការណ៍ទូទៅក្នុងឆមាសទី១ និងទិសដៅភារកិច្ចរបស់គណបក្សឆមាសទី២ ឆ្នាំ២០១៦" ថ្ងៃទី 19 ខែកក្កដាឆ្នាំ 2016។

ស្រុកនិងឃុំ។[119] ដូចគ្នានឹងនៅថ្នាក់កំពូលដែរ សមាគមនេះត្រូវបានដឹកនាំនៅឯកម្រិតមូលដ្ឋាន តាមរយៈមន្រ្តីកងកម្លាំងសន្តិសុខ ដែលភាគច្រើនជាទាហាន ក៏ប៉ុន្តែក៏មាននគរបាល និងកងរាជអាវុធហត្ថផងដែរ ដែលជួយដោយអាជ្ញាធររដ្ឋមានអំណាចជានគរបាលយុត្តិធម៌។[120] ចំណែកនៅរាជធានីភ្នំពេញ ប្រធានសមាគម គឺលោក ជួន សុវណ្ណ ដែលជាមេនគរបាលរាជធានី និងអនុប្រធានសមាគម គឺលោក រ័ត្ន ស្រាង ដែលជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានី ។ អ្នកទាំងពីរគឺជាអ្នកការពារលោក គន់ គីម ជាយូរអង្វែងមកហើយ។ គេទាំងពីរត្រូវបានលើកបន្តុបក្នុងតំណែងនេះ នៅក្នុងពិធីមួយដែលលោក គន់ គីមធ្វើជាអធិបតី។[121] ការដាក់បញ្ចូលអតីតយោធា និងអតីតនគរបាល ទៅក្នុងសមាគមដើម្បីធ្វើសកម្មភាពរបស់សមាគមបានរៀបចំធ្វើឡើងនៅទូទាំងកំរិតថ្នាក់ជាតិតែម្តងក្រោមអំណាចបញ្ជាការកងកម្លាំងសន្តិសុខ តែម្តង។[122]

ការលំអៀងឥតលាក់លៀមរបស់មេបញ្ជាការកងកម្លាំងសន្តិសុខនេះ បានបន្តធ្វើនៅឡុងពេលគណបក្សប្រជាជនកម្ពុជា បង្កើនសន្ទុះយុទ្ធនាការបោះឆ្នោតឃុំក្នុងឆ្នាំ២០១៧ និងការបោះឆ្នោតជាតិនៅឆ្នាំ២០១៨។ នៅថ្ងៃទី ៤ ខែវិច្ឆិកាឆ្នាំ ២០១៦ នាយឧត្តមសេនីយ៍ ឥត សារ៉ាត់ អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ដែលទទួលខុសត្រូវផ្នែកហ្វឹកហ្វឺនយោធា បានបញ្ជាឲ្យមន្រ្តីកងយោធពលខេមរភូមិន្ទ ធ្វើអ្វីៗគ្រប់យ៉ាងដើម្បីធានាថា កងកម្លាំងប្រដាប់អាវុធ "ត្រូវតែប្រឆាំងដាច់ខាត" ចំពោះរាល់សកម្មភាពដែលចាត់ទុកថា "មានបំណងបំផ្លាញសន្តិសុខ សណ្តាប់ធ្នាប់ល្អ និងស្ថិរភាពសង្គម"។[123] បួនថ្ងៃក្រោយមក ឧបនាយករដ្ឋមន្រ្តី

---

[119] សមាគមអតីតយុទ្ធជនកម្ពុជា  លេខ)1 ៖ ឆមាសទី 1 ឆ្នាំ 2016) ។

[120] "ពិធីទទួលស្គាល់សមាសភាពគណៈកម្មាធិការអតីតយុទ្ធជនកម្ពុជា" ថ្ងៃទី15 ខែធ្នូឆ្នាំ2015, http://beta.nokorwatnews.com/?p=66243#sthash.eG1vtvi2.dpuf (ចូលមើលថ្ងៃទី16 ខែធ្នូ ឆ្នាំ2015)។ "ឯកឧត្តម ឧត្តមសេនីយ៍គន់គីម អញ្ជើញជាអធិបតីក្នុងពិធីទទួលស្គាល់គណៈកម្មាធិការខណ្ឌដង្កោ " ឆ្នាំ 2015 "កិច្ចប្រជុំសមាគមអតីតយុទ្ធជនខេត្តកំពង់ចាម ដើម្បីពង្រឹងគុណភាពការងាររបស់ខ្លួន ថ្ងៃទី6 ខែមករា ឆ្នាំ 2016 http://kampucheathmey.com/kpt/?p=138593 (ចូលមើលថ្ងៃទី 8 ខែមករាឆ្នាំ 2016)។ ប្រធានសមាគមអតីតយុទ្ធជនកម្ពុជានៅខេត្តកំពង់ឆ្នាំងបានលើកឡើងពីអត្ថប្រយោជន៍នៃការស្លាប់ ដល់សមាជិកគ្រួសារអតីតយុទ្ធជនពីរនាក់នៅក្នុងខណ្ឌចំនួនពីរថ្ងៃទី 8 ខែមករាឆ្នាំ 2016 http://kampucheathmey.com/kpt/?p=142917 (ចូលមើលថ្ងៃទី 9 ខែមករាឆ្នាំ 2014) )។ គណៈកម្មាធិការស្រុកអន្លង់វែងនៃសមាគមអតីតយុទ្ធជនកម្ពុជាត្រូវបានរៀបចំឱ្យមានពិធីផ្តល់អត្ថប្រយោជន៍សម្រាប់ការស្លាប់ដល់ក្រុមគ្រួសាររបស់មនុស្សបីនាក់ដែលបានស្លាប់នៅថ្ងៃទី 29 ខែមករាឆ្នាំ 2016 http://kampucheathmey.com/kpt/?p=163897 (ចូលមើលថ្ងៃទី 29 ខែមករាឆ្នាំ 2016)។ ជួនសារុន ត្រូវបានតែងតាំងជាប្រធានថ្មីនៃសមាគមអតីតយុទ្ធជននៅកម្ពុជា ខណៈអភិបាលខេត្តជាប្រធានកិត្តិយស។ ថ្ងៃទី 8 ខែមិថុនាឆ្នាំ 2016, http://www.freshnewsasia.com/index.php/en/26051-2016-06-08-14-17-16.html (ចូលមើលថ្ងៃទី 8 ខែមិថុនាឆ្នាំ 2016)។

[121] "លោកឧត្តមសេនីយ៍ជួនសុវណ្ណ ត្រូវបានតែងតាំងជាប្រធានសមាគមអតីតយុទ្ធជនរាជធានីភ្នំពេញ ខណៈពេលដែលលោកឧត្តមសេនីយរ័ត្នស្រ៊ាងជាអនុប្រធាន ថ្ងៃទី15 ខែកញ្ញា ឆ្នាំ2015 http://dap-news.com/2011 -06-14-02-39-55 / 99183-2015-09-15-11-03-38.html (ចូលមើលថ្ងៃទី15 ខែកញ្ញាឆ្នាំ 2015)

[122] "លោក គន់គីមជួបសមាជិកអតីតយុទ្ធជននិងចូលនិវត្តន៍ជាង 200 នាក់នៅស្រុកស្រីសន្ធរ  ថ្ងៃទី"2 ខែមិថុនា ឆ្នាំ 2016 http: //www.dap-news.com/kh/%E1%9E%96%E1%9F%90% E1% 9E% 8F% E1% 9F% 8C% E1% 9E% 98% E1% 9E% B6% E1% 9E% 93% E1% 9E% 80% E 1% 9% 92% E1% 9E% 93% E1 E1% 9A% E1% 9E% 91% E1% 9F% 81% E1% 9E% 9E% 96% E1% 9F% 81% E1% 9E% 9F / 6956.html (ចូលមើលថ្ងៃទី 3 ខែមិថុនាឆ្នាំ 2016)

[123] "ឧត្តមសេនីយ៍ឥតសារ៉ាត់ ៖ កងយោធពលខេមរភូមិន្ទគាំទ្រនិងការពារសកម្មភាពទាំងអស់ ដែលស្របតាមច្បាប់" ថ្ងៃទី4 ខែវិច្ឆិកា ឆ្នាំ2016

និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ឧត្តមសេនីយ៍ទៀបាញ់ បានពន្យល់ប្រាប់ទៅកាន់ពិធីប្រមូលផ្តុំទ័ពក្នុងទិវាកងយោធពលខេមរភូមិន្ទ ដែលមានការចូលរួមដោយឧត្តមសេនីយ៍មេបញ្ជាការកំពូលប៉ុល សារឿន ក្នុងចំណោមមន្ត្រីជាន់ខ្ពស់ដទៃទៀតថា "គណបក្សប្រឆាំង" ត្រូវទទួលខុសត្រូវចំពោះកិច្ចប្រឹងប្រែងក្នុងការបង្កើតអស្ថេរភាព។ លោក ទៀបាញ់ បានសរសើរកងកម្លាំងសន្តិសុខដែលបានរារាំងសកម្មភាពទាំងនេះតាមរយៈការបង្ក្រាបទាន់ពេលវេលាលើបាតុកម្ម និងការតវ៉ា។[124]

នៅក្នុងពិធីមួយនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៧ រដ្ឋមន្ត្រីការពារជាតិបានបន្តធ្វើការអំពាវនាវដល់បុគ្គលិកកងកម្លាំងប្រដាប់អាវុធទាំងអស់ "កុំឱ្យជឿលើការញុះញង់របស់គណបក្សប្រឆាំង"។[125] លោក ទៀ បាញ់ បានរិះគន់ជនទាំងឡាយដែលលោកថា បានប្រើ "ល្បិច " និង " ញុះញង់" និងថា មិនបាននិយាយពីស្នាដៃនៃការអភិវឌ្ឍន៍ប្រទេស ហើយលោកប្រាប់ទៅកាន់កម្លាំងយោធាថា ត្រូវត្រៀមខ្លួនបញ្ឈប់ "ព្យុះសង្ឃរា" គឺកម្លាំងប្រមូលផ្តុំដែលចង់ផ្លាស់ប្តូរ ក្នុងបរិបទបោះឆ្នោតនាពេលខាងមុខ ដោយពន្យល់ថា "នយោបាយតែងតែមកលងយើង និងបង្កបញ្ហាដល់យើង"។ និយាយនៅក្នុងបរិបទមួយទៀត លោក ទៀ បាញ់ និយាយចំៗលើគណបក្សសង្គ្រោះជាតិតែម្តង ដោយថ្លែងថា "យើងពិចារណាកម្លាំង [របស់យើង] គឺជាកម្លាំងដែលអាចបញ្ឈប់ ឬរារាំងកុំឲ្យគណបក្សប្រឆាំងមួយនេះ អនុវត្តបំណងប្រាថ្នារបស់វាបានងាយស្រួល" ។[126]

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧ កងយោធពលខេមរភូមិន្ទ និងប៉ូលីស ត្រូវបានប្រគល់ភារកិច្ចដោយរដ្ឋាភិបាល ឱ្យទប់ស្កាត់ "បដិវត្តពណ៌" នៅក្នុង "ផែនការសកម្មភាព" របស់ "គណៈកម្មាធិការអន្តរក្រសួងមួយដើម្បីដោះស្រាយកូដកម្ម និងបាតុកម្មតាមគោលដៅទាំងអស់"។[127] បេសកកម្មនេះ ត្រូវបានរៀបចំជាផ្លូវការក្នុង

---

http://www.freshnewsasia.com/index.php/en/internationalnews/38618-2016-11- 04-08-13-35.html (ចូលមើលនៅថ្ងៃទី4 ខែវិច្ឆិកាឆ្នាំ 2016)។

[124] ឧបនាយករដ្ឋមន្ត្រីទៀបាញ់ ៖ ទោះបីមានអស្ថិរភាពនយោបាយ បង្ករដោយពួកប្រឆាំងយ៉ាងណាក៏ដោយ ក៏សេដ្ឋកិច្ចនៅតែរក្សាបានល្អឥតខ្ចោះ" ថ្ងៃទី 8 ខែវិច្ឆិកា ឆ្នាំ2016 http://www.freshnewsasia.com/index.php/en/localnews/ 38883-2016-11-08-05-31-48.html (ចូលមើលថ្ងៃទី 8 ខែវិច្ឆិកាឆ្នាំ 2016)

[125] ទៀបាញ់ ៖ សព្វថ្ងៃនេះ បើបញ្ហានយោបាយកើតឡើងនៅប្រទេសកម្ពុជា កងទ័ពមិនអាចឈរស្ងៀមបានទេ") ថ្ងៃទី 2 ខែកុម្ភៈឆ្នាំ 2017 http://dap-news.com/kh/%E1%9E%96%E1%9F%90 E1% 9E% 9F% E1% 9E% 80% E% 1% 9F% 92% E1% 9E% 93%% E1% 9E% 8F% E1% 9F% 8C% E1% 9E% 98% E1% 9E% B6% E1% 9E% E1% 9E% 96% E1% 9E% 91% E1% 9F / 28116 ។ html (ចូលមើលនៅថ្ងៃទី 2 ខែកុម្ភៈឆ្នាំ 2017)

[126] "លោកបាញ់ព្រមានអំពី" ខ្យល់ព្យុះសង្ឃរានៃការផ្លាស់ប្តូរ "ភ្នំពេញប៉ុស្ត៍ថ្ងៃទី6 ខែកុម្ភៈឆ្នាំ 2017 http://www.phnompenhpost.com/national/banh-warns-hurricane-change (ចូលមើលថ្ងៃទី 7 ខែកុម្ភៈឆ្នាំ 2017)

[127] "រដ្ឋប្រហារពណ៌ស្ថិតនៅលើរបៀបវារៈរបស់ក្រុម៖ កាសែត "ភ្នំពេញប៉ុស្ត៍ថ្ងៃទី 7 ខែកុម្ភៈឆ្នាំ 2017 ។
http://www.phnompenhpost.com/national/colour-coup-groups-agenda (ចូលមើលថ្ងៃទី 8 ខែកុម្ភៈឆ្នាំ 2017)

បទបញ្ជាដាច់ដោយឡែកមួយចំពោះកងយោធពលខេមរភូមិន្ទ។[128]

នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០១៧ លោក ហ៊ុន សែនបានផ្តើមប្រើភាសាព្រមានធ្ងន់ៗឡើងវិញចំពោះអ្នកទាំងឡាយ ដែលគាត់ចោទប្រកាន់ថា បានបញ្ឆេះផែនការបដិវត្តន៍ ដោយឲ្យដំបូន្មានដល់ពួកគេ "ឲ្យរៀបចំមឈូសឲ្យហើយទៅ" និងបាននិយាយបន្ថែមថា គាត់មិន "និយាយលេងទេ"។[129] នៅចុងខែនោះ នាយករដ្ឋមន្ត្រីបានដាស់តឿនដល់អ្នកដែលគិតថា ខ្លួនអាចយកឈ្នះការបោះឆ្នោតប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជា។ លោកហ៊ុន សែន ថាពួកទាំងនោះកំពុងតែ "យល់សប្តិ" ពីព្រោះក្នុងដៃរបស់គាត់មានកងទ័ព ដែលស្ថិតក្រោមការបញ្ជាឱ្យ "ការពារសន្តិភាព ... មិនថាត្រូវបង់ថ្លៃប៉ុន្មានក៏ដោយ"។[130] លោក ទៀ បាញ់ បានចេញការគំរាមថា កងយោធពលខេមរភូមិន្ទ មិនអនុញ្ញាតឱ្យមានការអំពាវនាវជាសាធារណៈឱ្យមានពាក្យស្លោក "ការផ្លាស់ប្តូរ" ដែលបានប្រើប្រាស់ដោយអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ ដែលបានអំពាវនាវក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជាតិឆ្នាំ២០១៣ ដើម្បីជំនួសលោក ហ៊ុន សែន ដោយសម រង្ស៊ីនោះទេ។[131]

នៅក្នុងបរិបទនេះ ថវិកាជាតិសម្រាប់ឆ្នាំ២០១៧ ត្រូវបានរដ្ឋាភិបាលបង្កើនសម្រាប់កងកម្លាំងប្រដាប់អាវុធជិត២០ភាគរយលើសឆ្នាំ២០១៦ ដោយបង្កើនដល់៤៦៤ លានដុល្លារអាមេរិក។[132] នេះគឺជាផ្នែកមួយនៃនិន្នាការជាក់ស្តែងក្នុងការបង្កើនថវិកាលើវិស័យយោធាតាំងពីឆ្នាំ២០០៦មកម្ល៉េះ នៅពេលដែលថវិកាយោធា

---

128 "ក្រសួងការពារជាតិប្រកាសថាកងទ័ពគឺដើម្បីការពារសន្តិភាពរបស់ប្រទេសកម្ពុជា និងប្រឆាំងនឹងបដិវត្តពណ៌" 2 មីនា 2017, http://www.freshnewsasia.com/index.php/en/localnews/48535-2017-03-02-06-00-53.html (ចូលមើលថ្ងៃទី 2 ខែមីនាឆ្នាំ 2017)

129 អង្គការឃ្លាំមើលសិទ្ធិមនុស្ស៖ ប្រាប់ពួកគេថា ខ្ញុំចង់សម្លាប់ពួកគេ ៖ ពីរទសវត្សរ៍នៃនិទណ្ឌភាព ក្រោមការដឹករបស់លោក ហ៊ុន សែន នៅកម្ពុជា (2012) https://www.hrw.org/report/2012/11/13/tell-them-i-want- ទំព័រ 40; "សម្តេចតេជោនឹងអត់ឱនជនណាម្នាក់ដែលបំផ្លាញសន្តិភាព "ថ្ងៃទី 13 ខែកុម្ភៈឆ្នាំ 2017 http://dap-news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93%E1%9E%80%E1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%91%E1%9F%81%E1%9E%9F/29136.html (ចូលមើលថ្ងៃទី 13 ខែកុម្ភៈឆ្នាំ 2017)

130 "សម្តេចតេជោ៖ អ្នកខ្លះនិយាយថានៅពេលមានជ័យជំនះនៅឆ្នាំ 2018 ពួកគេនឹងបង្ក្រាបអ្នកដែលមិនបានទទួលលទ្ធផល" ថ្ងៃទី 22 ខែកុម្ភៈឆ្នាំ 2017 http://dap-news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93%E1%9E%80%E 1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%91%E1%9F%81%E1%9E%9F/30015.html (ចូលមើលថ្ងៃទី 22 ខែកុម្ភៈឆ្នាំ 2017) ។ "សម្តេចតេជោ ហ៊ុន សែនបានប្រកាសម្តងទៀតអំពីការការពារសន្តិភាពរបស់ប្រទេសកម្ពុជា ទោះក្នុងតម្លៃណាក៏ដោយ។

131 "ឯកឧត្តមទៀបាញ់នឹងមិនអនុញ្ញាតឱ្យស្រែកនៃការផ្លាស់ប្តូរ! ផ្លាស់ប្តូរ! ជាដាច់ខាត ដែលនឹងនាំឲ្យខូះសន្តិភាពនៅក្នុងប្រទេសកម្ពុជា ថ្ងៃទី 25 ខែកុម្ភៈឆ្នាំ 2017 http: // dap-news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F E1% 9E% 80% E% 1% 9F% 92% E1% 9E% 93% E1% 9E% BB% E1% 9E%% E1% 9E% 9E% 84% E1% 9E% 94% E1% 9F% 92% E1% 9E% 9A% E1% 9E% 91% E1% 9F% 81% E1% 9E% 9F / 30423.html (មើលថ្ងៃ 25 ខែកុម្ភៈឆ្នាំ 2017)

132 "ម៉ាណែតជម្រុញការចំណាយសម្រាប់កងកម្លាំងប្រដាប់អាវុធ។ ភ្នំពេញប៉ុស្តិ៍ថ្ងៃទី14 ខែវិច្ឆិកាឆ្នាំ 2016 http://www.phnompenhpost.com/national/manet-touts-spending-boost-armed-forces (ចូលមើលថ្ងៃទី14 ខែវិច្ឆិកាឆ្នាំ 2016)។

ពេលនោះមានត្រឹមតម្លៃ៧៩.៧ លានដុល្លារអាមេរិក។ ខណៈការបង្កើនខ្ទង់នៃថវិកាទៅក្នុងវិស័យនេះ គេអាចពន្យល់ដោយសារមានការប៉ះទង្គិចអាវុធនៅតាមព្រំដែនជាមួយប្រទេសថៃ ប៉ុន្តែគោលបំណងចម្បងក្នុងការបង្កើនថវិកាជាបន្តបន្ទាប់សម្រាប់វិស័យយោធាហាក់ ដើម្បីធានាថា កងយោធពលខេមរភូមិន្ទនឹងឈរនៅខាង "គណបក្សប្រជាជនកម្ពុជា" ប្រឆាំងនឹងគណបក្សសង្គ្រោះជាតិ ជាពិសេសនៅក្នុងបរិបទនៃការបោះឆ្នោត។[133]

ដូចមុនការបោះឆ្នោតជាតិឆ្នាំ២០១៣ដែរ នៅចុងឆ្នាំ២០១៦ មន្ត្រីសន្តិសុខជាន់ខ្ពស់បានចាប់ផ្តើមអនុវត្តសកម្មភាពពង្រឹងមូលដ្ឋានរបស់គណបក្សប្រជាជនកម្ពុជានៅតាមខេត្ត។ មេបញ្ជាការរងកំពូល ឧត្តមសេនីយ៍ជា ដារ៉ា ក្នុងអំឡុងពេលធ្វើដំណើរទៅចែកអំណោយដល់អ្នកបោះឆ្នោតនៅខេត្តបាត់ដំបង បានឃោសនាថា លោក ហ៊ុន សែន មិនត្រឹមតែជានាយករដ្ឋមន្ត្រីប៉ុណ្ណោះទេ ប៉ុន្តែក៏ជាប្រធានគណបក្សប្រជាជនកម្ពុជាផងដែរ។[134]

សកម្មភាពបែបនេះ បានកើនឡើងបន្ទាប់ពីសន្និសីទគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនកម្ពុជា នៅខែធ្នូ ឆ្នាំ២០១៦ ដែលត្រូវបានគេចាត់ទុកថា ជាសមាជវិសាមញ្ញគណបក្ស ដែលយុទ្ធសាស្ត្ររបស់គណបក្សនេះ បានបង្កើតឡើងសម្រាប់ឈ្នះការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ និងការបោះឆ្នោតជាតិឆ្នាំ២០១៨ ត្រូវបានប្រកាស។ យុទ្ធសាស្ត្រនេះ បានសង្កត់ធ្ងន់ទៅលើសារសំខាន់របស់មេដឹកនាំគណបក្សប្រជាជនកម្ពុជា ដែលត្រូវចុះទៅមូលដ្ឋាន ដើម្បីពង្រឹង និងលើកកម្ពស់ការគាំទ្រសម្រាប់គណបក្ស។[135]

---

[133] "ក្នុងពេលមានសន្តិភាព ការចំណាយយោធារបស់កម្ពុជា កើនឡើង "ថ្ងៃទី24 ខែវិច្ឆិកាឆ្នាំ 2016 ។ https://www.cambodiadaily.com/news/peacetime-cambodia-military-spending-soars-120934/ (ចូលមើលថ្ងៃទី 24 ខែវិច្ឆិកាឆ្នាំ 2016)

[134] "លោកបណ្ឌិតជា ដារ៉ា ទទួលបានទឹកប្រាក់ច្រើនជាង១០ លានរៀលពីមូលនិធិសម្តេចក្រឡាហោម ដើម្បីប្រគល់ជូនស្ត្រីដែលបានផ្តល់កំណើត និងគ្រួសារចំនួន ៥៦ គ្រួសារ ដែលបានស្លាប់នៅឃុំកក់ឃ្មុំ )"ថ្ងៃទី 28 ខែវិច្ឆិកាឆ្នាំ 2016) http://www.freshnewsasia.com/index.php/en/localnews/40387-2016-11-28-09-22-18.html, (ចូលមើលថ្ងៃទី 28 ខែវិច្ឆិកាឆ្នាំ 2016)។ សម្រាប់សកម្មភាពរបស់ឧត្តមសេនីយ៍ អ៊ុក គឹមលក រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សូមមើល "ក្រុមការងារស្រុកថ្មគោលរបស់គណបក្សប្រជាជនកម្ពុជា ជួបជុំបូកសារុបលទ្ធផលការងារ ចុះបញ្ជីអ្នកបោះឆ្នោត និងផ្សព្វផ្សាយណែនាំមួយចំនួន" ខែធ្នូ ថ្ងៃទី12 ឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/localnews/41492-2016-12-12-02-58-57.html (មើលថ្ងៃទី12 ខែធ្នូឆ្នាំ 2016)។

[135] គណបក្សប្រជាជនកម្ពុជានឹងធ្វើសន្និសីទគណៈកម្មាធិការកណ្តាលលើកទី 40 របស់ខ្លួនក្នុងសប្តាហ៍ទី 3 នៃខែធ្នូនេះ ថ្ងៃទី 7 ខែធ្នូឆ្នាំ 2016 http://www.freshnewsasia.com/index.php/en/localnews/41072-2016- 12-07-00-18-52.html (ចូលមើលថ្ងៃទី 7 ខែធ្នូឆ្នាំ 2016)។ គណបក្សប្រជាជនកម្ពុជាត្រូវធ្វើមហាសន្និបាតវិសាមញ្ញនៅពាក់កណ្តាលខែធ្នូឆ្នាំ 2013 (ថ្ងៃទី 6 ខែធ្នូឆ្នាំ 2016) http: // dap-news.com/kh/%E1%9E%96%E1%9F%90%E1%9E% 9E% 93% E1% 9E% 80% E% 1% 9% 92% E1% 9E% 93% E1% 9E 9E% 9E% 9E% 9E% 9E% E1% 9F% 92% E1% 9E% 9A% E1% 9E% 91% E1% 9F% 81% E1% 9E% B% e% q%% 9F/23285.html (ចូលមើលនៅថ្ងៃទី 6 ខែធ្នូឆ្នាំ 2016)។ គណបក្សប្រជាជនកម្ពុជាធ្វើសមាជវិសាមញ្ញនៅពាក់កណ្តាលខែធ្នូ ថ្ងៃទី 6 ខែធ្នូឆ្នាំ 2016 http: // dap-news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98% E1% 9E% B6% E1% 9E% 93% E1% 9E% 80%E1% 9F% 92%E1%9E%93%E1%9%%E1% 9E% 94 % E1% 9F% 92% E1% 9E% 9A% E1% 9E% 91% E1% 9F% 81% E1% 9E% 9F / 23285.html (បានចូលដំណើរការនៅថ្ងៃទី 6 ខែធ្នូឆ្នាំ 2016); ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 8 ខែធ្នូឆ្នាំ 2016 http://www.phnompenhpost.com/national/cpp-congress-map-out-election-plan (ចូលមើលថ្ងៃទី 8 ខែធ្នូឆ្នាំ 2016)។

ដោយមានលោក ហ៊ុន សែនជាអធិបតី ប្រតិភូបក្សចំនួន១,៨៦០ នាក់ (មួយពាន់ប្រាំបីរយហុកសិប) បានចូលរួមក្នុងសន្និបាត រួមទាំងសមាជិកគណៈកម្មាធិការមជ្ឈិម៤៩៥នាក់ផង។[136] លោក ហេង សំរិន ប្រធានកិត្តិយសបានស្បថក្នុងសុន្ទរកថារបស់លោកថានឹង "គ្មានអំណាចបីសាច" ត្រូវបានអនុញ្ញាតឱ្យមក "រារាំង" ការអភិវឌ្ឍន៍របស់គណបក្សប្រជាជនកម្ពុជាទេ។[137] នៅក្នុងកិច្ចពិភាក្សាអំពី "ការពង្រឹងបន្ថែមនៃកំពែងការពារប្រទេស" របស់គណបក្សប្រជាជនកម្ពុជា សេចក្តីថ្លែងការណ៍ បានគូសបញ្ជាក់អំពី "ការថែរក្សាដ៏រឹងមាំនៃស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ" ដែលសន្និបាតនេះនិយាយថា កិច្ចប្រជុំបានផ្តល់នូវកម្លាំងជំរុញបន្ថែមទៀត។ ក្នុងនាមជាប្រធានគណបក្ស លោក ហ៊ុន សែន បានបញ្ជាឱ្យសមាជិកបក្សទាំងអស់ "ចាប់ផ្តើមធ្វើសកម្មភាពឲ្យកាន់តែខ្លាំងក្លាបន្ថែមទៀត ឆ្ពោះទៅកាន់មូលដ្ឋាន" ទាក់ទងនឹងការបោះឆ្នោតឆ្នាំ២០១៧ និង២០១៨។[138] បទបញ្ជានេះ ក៏សំដៅរួមបញ្ចូលទាំងមេបញ្ជាការជាន់ខ្ពស់ (បាតដៃកខ្វក់ទាំង១២រូប) ដែលជាប្រធានបទនៃរបាយការណ៍នេះ ក៏ដូចជាកងកម្លាំងសន្តិសុខ និងកងប្រដាប់អាវុធដទៃជាច្រើនទៀត។[139]

---

[136] "ព្រឹកនេះគណបក្សប្រជាជនកម្ពុជា ធ្វើសន្និសីទគណៈកម្មាធិការកណ្តាលនៅកោះពេជ្រ" (ថ្ងៃទី 17 ខែធ្នូឆ្នាំ 2016) http://www.freshnewsasia.com/index.php/en/localnews/41992-2016-12-17-05 -46-17.html (ចូលមើលថ្ងៃទី 17 ខែធ្នូឆ្នាំ 2016); លទ្ធផលនៃសន្និសីទគណៈកម្មាធិការមជ្ឈិមបក្សលើកទី 40 នៃអាណត្តិទី 5 ថ្ងៃទី18 ខែធ្នូ ឆ្នាំ 2016 http: // dap-news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F E1% 9E% 80% E% 1% 9% 92% E1% 9E% 93% E1% 9E% ប៊ីប៊ី %E1% 9F% 8C% E1% 9E% 98% E1% 9E% B6% E1% 9E% 93% E1% 9E% 9E% 9E% 9F% 81% E1% 9E% 9F / 24371.html (ចូលមើលថ្ងៃទី18 ខែធ្នូឆ្នាំ 2011) 2016)។

[137] "សម្តេចហេងសំរិនសង្ឃឹមថា ប្រជាជនកម្ពុជានឹងបន្តប្រគល់អំណាចឱ្យគណបក្សប្រជាជនកម្ពុជាដឹកនាំប្រទេស" ថ្ងៃទី 17 ខែធ្នូឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/localnews/41998-2016-12-17-04-52-16.html (ចូលមើលថ្ងៃទី 17 ខែធ្នូឆ្នាំ 2016)

[138] សម្តេចតេជោហ៊ុនសែនបញ្ជាឱ្យសមាជិកគណបក្សប្រជាជនកម្ពុជាបង្កើនចុះមូលដ្ឋាន "ថ្ងៃទី 18 ខែធ្នូឆ្នាំ 2016 http://www.freshnewsasia.com/index.php/en/localnews/42083-2016-12-18-11-45-29.html (ចូលមើលថ្ងៃទី 18 ខែធ្នូឆ្នាំ 2016)

[139] សូមមើលផ្នែកនីមួយៗខាងក្រោម "ខៀវសុភ័ក្រ្តចែកអំណោយដល់ប្រជាពលរដ្ឋជាង 100 គ្រួសារដែលរងការឈឺចាប់ដោយការខ្វះខាតនៅឃុំថ្កូវ ស្រុកកំពង់ត្របែក ថ្ងៃទី 24 ខែធ្នូឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/localnews/42523-2016-12-24-10-57-35.html (ចូលមើលនៅថ្ងៃទី 24 ខែធ្នូឆ្នាំ 2016)។ ឧត្តមសេនីយ៍ឯកម៉ាឈឿននិងលោកស្រីអ៊ុកម៉ាលីជីកា អញ្ជើញជាអធិបតីសន្និសីទគណៈកម្មាធិការបក្សឃុំសូទិព្វ ស្រុកព្រៃឈរ។ ថ្ងៃទី 24 ខែធ្នូឆ្នាំ 2016, http://www.freshnewsasia.com/index.php/en/localnews/42526-2016-12-24-14-43-31.html (បានមើលនៅថ្ងៃទី 24 ខែធ្នូឆ្នាំ 2016) ។ យុវជនគណបក្សប្រជាជននៅខេត្តប៉ៃលិន ជួបជុំសិក្ខាសាលាដើម្បីប្រមូលការងារឆ្នាំ2016 និងទិសដៅអនុវត្តការងារឆ្នាំ2017។ ថ្ងៃទី 27 ខែធ្នូ ឆ្នាំ 2016 http: //www.freshnewsasia.com/index.php/en/localnews/42718-2016-12-27-09-41-55.html (ចូលមើលថ្ងៃទី 27 ខែធ្នូឆ្នាំ 2016) ។ "លោក។ លោកម៉េងសំផនរៀបចំសន្និបាតបូកសរុបលទ្ធផលការងារនិងកម្មវិធីនយោបាយរបស់គណបក្សប្រជាជនក្នុងសង្កាត់ក្រុងបារិត។ ថ្ងៃទី 31 ខែធ្នូឆ្នាំ 2016 http: // dapnews.E1% 9E% 9E% 9E% 98% E1% 9E% B6% E1% 9E% 93% E1% 9E% E1% 9E% 96% E1% 9F% 90% E1% 9E% 8F% E1% 9F% 8C% % 80%E1% 9F% 92% E1% 9E% 93% E1% 9E% B% E1% 9E% 84% E1% 9E% 94% E1% 9F% 92% EE% 9E% 9A% E1% 9E% 91% E1% 9%% 81% E1% 9E% 9F / 25448.html (បានមើលនៅថ្ងៃទី 31 ខែធ្នូឆ្នាំ 2016)។ (ចូលមើលថ្ងៃទី 24 ខែធ្នូឆ្នាំ 2016) ។ ឧត្តមសេនីយ៍ឯកម៉ាឈឿននិងលោកស្រីអ៊ុកម៉ាលី អញ្ជើញជាអធិបតីក្នុងពិធីសន្និបាតនៃគណៈកម្មាធិការបក្សឃុំសូទិប ស្រុកព្រៃឈរ ថ្ងៃទី 24 ខែធ្នូឆ្នាំ 2016

## កងរាជអាវុធហត្ថខ្មែរ ទសវត្សរ៍ ១៩៨០ ដល់បច្ចុប្បន្ន

កងរាជអាវុធហត្ថ (GRK) មានដើមកំណើតជាស្ថាប័ននៅក្នុងកងវរសេនាធំលេខ៧០ ដែលមានមូលដ្ឋាននៅភ្នំពេញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលវាជាកងវរសេនាតូចនគរបាលយោធា។ យ៉ាងណាក៏ដោយ កងវរសេនាតូចនគរបាលយោធានេះ ដែលមានយុត្តាធិការតែទៅលើកម្លាំងយោធាត្រូវបានរំលាយនៅខែតុលា ឆ្នាំ១៩៩១ នៅពេលមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសស្តីពីកម្ពុជា។[140] កងរាជអាវុធហត្ថដែលជាកងកម្លាំងនគរបាលយោធា មានយុត្តាធិការលើជនស៊ីវិល និងបុគ្គលិកយោធា ត្រូវបានបង្កើតឡើងដោយក្រឹត្យចុះកាលបរិច្ឆេទក្នុងខែកក្កដា ឆ្នាំ១៩៩៣ ដែលចាប់ផ្តើមដោយមានការបើកវគ្គបណ្តុះបណ្តាលពិសេសដល់កងកម្លាំងនេះ។[141] ការបង្កើតកងរាជអាវុធហត្ថ ត្រូវបានលើកទឹកចិត្តដោយអ៊ុនតាក់ ដែលគាំទ្រដោយសម្តេចព្រះសីហនុ ហើយត្រូវបានផ្តល់ថវិកាដោយបារាំង ដែលដំបូងបារាំងក៏បានផ្តល់ការបណ្តុះបណ្តាលផងដែរ។ គោលបំណងរបស់បារាំង គឺការបង្កើតកងកម្លាំងសន្តិសុខអព្យាក្រឹត្យពីនយោបាយ និងមានវិជ្ជាជីវៈខ្ពស់ សម្រាប់ឆ្លើយតបទៅសម្តេចព្រះ នរោត្តម សីហនុ។ ក៏ប៉ុន្តែ មុនពេលកងកម្លាំងថ្មីនេះអាចបើកប្រតិបត្តិការបាន សម្តេចព្រះនរោត្តម សីហនុ ត្រូវបានផាត់ចេញពីឆាកនយោបាយ។ លោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា បានបន្ទុចបង្អាក់ និងឆ្លៀតឱកាសអូសទាញស្ថាប័នកងរាជអាវុធហត្ថលើផ្ទៃប្រទេស មកបម្រើគោលដៅនយោបាយផ្ទាល់ខ្លួនរបស់ពួកគេ ហើយមិនយូរប៉ុន្មាន ក៏បានជោគជ័យក្នុងការធ្វើឱ្យកងរាជអាវុធហត្ថ ក្លាយជាកម្លាំងហ្វឹកហ្វឺនដ៏ល្អបំផុតរបស់ពួកគេ សម្រាប់ប្រើប្រាស់ប្រឆាំងនឹងសត្រូវនយោបាយរបស់ខ្លួនទៅវិញ។[142]

---

។ http://www.freshnewsasia.com/index.php/en/localnews/42526-2016-12-24-14-43-31.html (ចូលមើលថ្ងៃទី 24 ខែធ្នូឆ្នាំ 2016) ។ "យុវជនគណបក្សប្រជាជនខេត្តប៉ៃលិន ជួបប្រជុំគ្នាបូកសារុបលទ្ធផលការងារឆ្នាំ 2016 និងទិសដៅអនុវត្តឆ្នាំ2017, ថ្ងៃទី 27 ខែធ្នូឆ្នាំ 2016 http://www.freshnewsasia.com/index.php/en/localnews/42718-2016-12-27-09-41-55.html (ចូលមើលថ្ងៃទី 27 ខែធ្នូឆ្នាំ 2016) ។ "លោកមឹង សំផន ប្រារព្ធសន្និបាតបូកសរុបលទ្ធផលការងារ និងកម្មវិធីនយោបាយរបស់គណបក្សប្រជាជននៅក្នុងសង្កាត់នានាក្នុងក្រុងបាវិត ថ្ងៃទី 31 ខែធ្នូឆ្នាំ 2016 http://dap-news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93%E1%9E%80%E1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%91%E1%9F%81%E1%9E%9F/25448.html (ចូលមើលថ្ងៃទី 31 ខែធ្នូឆ្នាំ 2016)។

140 អ៊ុនតាក់ (UNTAC) សមាសភាគយោធា "ការរៀបចំនៃក្រសួងការពារជាតិ] "n.d.] រាជរដ្ឋាភិបាលកម្ពុជា "កាលប្បវត្តិនៃកងរាជអាវុធហត្ថកម្ពុជា] "n.d.]

141 រាជរដ្ឋាភិបាលកម្ពុជា "កាលប្បវត្តិនៃកងរាជអាវុធហត្ថ" រាជរដ្ឋាភិបាលកម្ពុជា )RGC អនុក្រឹត្យលេខ (11 អនក្រ ថ្ងៃទី 8 ខែមីនាឆ្នាំ1994។

142 លោកភីធីបាទូ (Peter Bartu) "ឯកសារភ្ជាប់លេខ គ ចំពោះរបាយការណ៍នយោបាយកម្ពុជា" ថ្ងៃទី 19 ខែកញ្ញាឆ្នាំ 2004; លោកប្រ៊ែដ អាដាមស៍

កងរាជអាវុធហត្ថលើផ្ទៃប្រទេស ត្រូវបានសម្ពោធជាផ្លូវការក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៣ ក្រោមបញ្ជាការរបស់លោកកែវ សាមួន ដែលមានលោក សៅ សុខា ជាមេបញ្ជាការរង។[143] លោក កែវ សាមួន ជាមេបញ្ជាការកងរាជអាវុធហត្ថត្រូវបានផ្លាស់ចេញក្នុងខែឧសភា ឆ្នាំ១៩៩៤ ដែលអ្នកជំនួសគាត់ គឺជាអតីតមេបញ្ជាការកងវរសេនាធំលេខ៧០ ឈ្មោះគៀង សាវុធ។[144] កម្លាំងថ្មីនៃកងរាជអាវុធហត្ថជាច្រើននាក់ដែលមកជាមួយលោកគៀងសាវុធ គឺចេញមកពីកងវរសេនាធំចាស់ ដែលពួកគេនោះ កាលពីចុងឆ្នាំ១៩៩១ ធ្លាប់បានចូលរួមក្នុងប្រតិបត្តិការសឹកជាមួយប៉ូលីសបង្ក្រាបការបះបោរប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជានៅក្នុងទីក្រុង ដែលពេលនោះ បណ្តាលឲ្យមនុស្ស ៦ នាក់ស្លាប់ដោយគ្រាប់កាំភ្លើង និងមួយចំនួនទៀតស្លាប់ដោយសារតែការប្រើប្រាស់កម្លាំងហួសប្រមាណ។[145] កម្លាំងថ្មីនៃកងរាជអាវុធហត្ថ គឺជ្រើសរើសជាពិសេសចេញមកពីកងវរសេនាតូចយោធាលេខ២៤៦ របស់កងវរសេនាធំលេខ៧០ ដែលជាអង្គភាពបង្កើតឡើងនៅវៀតណាម ក្នុងខែមិថុនា ឆ្នាំ ១៩៧៨ ក្រោមបញ្ជាកការរបស់លោក ហ៊ុន សែន និងវៀតណាម និងខ្លះមកពីកងនគរបាលយោធា ដែលគេបានរំសាយពីកងវរសេនាធំលេខ៧០ (នៅខែតុលា ឆ្នាំ១៩៩២)។[146]

អ្នកផ្សេងទៀត ត្រូវបានជ្រើសរើសចេញពីអតីតសមាជិកកងនគរបាលយោធាប្រយុទ្ធអា៣ "A-3" របស់ក្រសួងមហាផ្ទៃនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងក្រុមប្រតិបត្តិរបស់អង្គភាពសំងាត់ក្រុមអា "A-Team" របស់ពួកគេ។[147] នគរបាលប្រយុទ្ធរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានបង្កើតនៅខែមីនា

---

(Brad Adams) បានសម្ភាសន៍មន្ត្រីគណបក្សប្រជាជនកម្ពុជា មន្ត្រីកងយោធពលខេមរភូមិន្ទ មន្ត្រីយោធាបារាំងនិងអូស្ត្រាលី ដែលមានមូលដ្ឋាននៅកម្ពុជា និងមន្ត្រីរដ្ឋាភិបាលបារាំង ដែលមានមូលដ្ឋាននៅកម្ពុជានិងប៉ារីស។

[143] រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យលេខ 17 អនក្រ ចុះថ្ងៃទី 18 ខែវិច្ឆិកាឆ្នាំ1993 ។ រាជរដ្ឋាភិបាលកម្ពុជា )RGC) អនុក្រឹត្យលេខ 77 អនក្រ ចុះថ្ងៃទី 21 ខែធ្នូឆ្នាំ1994។ កងកម្លាំងប្រដាប់អាវុធរបស់ "ទំព័រហេង សំរិន១"

[144] រាជរដ្ឋាភិបាលកម្ពុជា " កាលប្បវត្តិ"នៃកងរាជអាវុធហត្ថ រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យលេខ 11 អនក្រ ចុះថ្ងៃទី 8 ខែមីនាឆ្នាំ1994; រាជរដ្ឋាភិបាលកម្ពុជា(RGC) អនុក្រឹត្យលេខ 51 អនក្រ ថ្ងៃទី 25 ខែសីហាឆ្នាំ 1994។

[145] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (COHCHR), កំណត់ហេតុផ្ទៃក្នុងទៅកាន់ការិយាល័យខេត្តនិងក្រុមត្រួតពិនិត្យតាមដានការបោះឆ្នោត1998; អង្គការលើកលែងទោសអន្តរជាតិ "រដ្ឋកម្ពុជា ៖ ការអភិវឌ្ឍសិទ្ធិមនុស្ស ថ្ងៃទី១ ខែតុលាឆ្នាំ១៩៩១ ដល់ថ្ងៃទី៣១ ខែមករាឆ្នាំ១៩៩២" (ASA23 / 02/92) ខែមេសា 1992។

[146] "ផ្នែកនៃប្រវត្តិសាស្ត្រ" និង "កងទ័ពស្ម័គ្រចិត្តវៀតណាម (កងទ័ពជើងគោកវៀតណាម)" បានចុះផ្សាយនៅក្នុងវេបសាយ http://www.vnmilitaryhistory.net/index.php?topic=16326.160;wap2 (ចូលមើលនៅថ្ងៃទី 7 ខែវិច្ឆិកាឆ្នាំ 2014); Carney " កងកម្លាំងប្រដាប់អាវុធ "ហេង សំរិន ទំព័រ១៦០" ។ បទសម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់របស់កងរាជអាវុធហត្ថ, នៅរាជធានីភ្នំពេញ ថ្ងៃទី 30 ខែសីហាឆ្នាំ 2013។

[147] សម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់នៃកងរាជអាវុធហត្ថ (GRK) ថ្ងៃទី10 ខែវិច្ឆិកាឆ្នាំ1995, COHCHR, ក្រដាសព្រាងគ្មានចំណងជើង (ប្រវត្តិរំលោភសិទ្ធិ

ឆ្នាំ១៩៨៦ និងធ្វើប្រតិបត្តិការរហូតដល់ខែវិច្ឆិកាឆ្នាំ១៩៩១ បានប្រព្រឹត្តអំពើសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ ដោយមូលហេតុនយោបាយ ក្នុងអំឡុងពេលបង្ក្រាបសកម្មភាពបះបោរនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០។ ការរំលោភបំពានទាំងនេះ ជួនកាលត្រូវបានធ្វើឡើងដោយមានការសម្របសម្រួលជាមួយទាហាន និងនគរបាលសាមញ្ញក្នុង "កងកម្លាំងចម្រុះ" របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា។[148] កម្លាំងប្រដាប់អាវុធនៃក្រុមអា "A-Team" ដែលរួមមានបុគ្គលិកដែលបានផ្លាស់ពីកងវរសេនាតូចលេខ៧០ ជាពិសេសកងវរសេនាតូចលេខ២៤៦ និងអតីតកងវរសេនាតូចនគរបាលយោធា បានធ្វើឃាតមន្ត្រីគណបក្សហ៊្វុនស៊ិនប៉ិច និងមន្ត្រីបក្សប្រឆាំងផ្សេងៗទៀត អំឡុងពេលនៃការបោះឆ្នោតឆ្នាំ១៩៩៣។[149] កម្លាំងជាច្រើនក្នុងជួរកងរាជអាវុធហត្ថថ្មី បង្កើតនៅឆ្នាំ១៩៩៣ គឺជាសមាភាពចាស់ចេញពីអតីតនគរបាលប្រយុទ្ធដែលគេធ្វើឲ្យរស់ឡើងវិញ ឬអាចនិយាយម្យ៉ាងទៀតថា ស្ថាប័នកងរាជអាវុធហត្ថថ្មី គឺជាកន្លែងដែលអតីតបុគ្គលិក ឬកម្លាំងក្រុមអា "A-Team" រកឃើញការងារថ្មី និងជាកន្លែងសម្រាប់ទទួលភារកិច្ចថ្មី។[150]

ស្របទៅនឹងការរៀបចំចម្រុះរវាងគណបក្សហ៊្វុនស៊ិនប៉ិច-គណបក្សប្រជាជនកម្ពុជា ផ្អែកតាមលទ្ធផលបោះឆ្នោត កងរាជអាវុធហត្ថបានដាក់បញ្ចូលមនុស្ស និងមន្ត្រីហ៊្វុនស៊ិនប៉ិចមួយចំនួនទៅក្នុងកងកម្លាំងនេះ ដោយមន្ត្រីខ្លះពីគណបក្សរាជានិយមនេះមានអំណាចបញ្ជាទៀតផង។ ក៏ប៉ុន្តែ ការពិតជាក់ស្តែង កងរាជអាវុធហត្ថស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណបក្សប្រជាជនកម្ពុជា ចាប់តាំងពីការចាប់ផ្តើមដំបូងមកម្ល៉េះ។[151]

ថ្វីបើតាមផ្លូវការ កងយោធពលខេមរភូមិន្ទកម្ពុជា (RCAF) ជាផ្នែកមួយក្រោយការបោះឆ្នោត ត្រូវរាយការណ៍ទៅអគ្គភាពបញ្ជាផ្ទាល់របស់ខ្លួន ដូចជាអគ្គសេនាធិការកំពូលក៏ដោយចុះ ក៏កងរាជអាវុធហត្ថនៅតែមានស្វ័យភាពពីអង្គភាពបញ្ជានេះ ហើយត្រូវបានគេ "ដាក់ឲ្យស្ថិតក្រោមបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រី (សហនាយករដ្ឋមន្ត្រី ក្នុងអាណត្តិ១៩៩៣)" ដែលអំណាច និងវិសាលភាពនៃសកម្មភាពរបស់ពួកគេ ត្រូវបាន

---

មនុស្សនៅកម្ពុជា ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ២០០៤)។

[148] គណបក្សប្រជាជនកម្ពុជា, ប្រវត្តិនៃការតស៊ូ, ទំព័រ 48; COHCHR, ក្រដាសព្រាងមិនមានចំណងជើង, ថ្ងៃទី 4 ខែមិថុនាឆ្នាំ 2004; វិទ្យុភ្នំពេញថ្ងៃទី 2 ខែតុលាឆ្នាំ1990 វិទ្យុភ្នំពេញថ្ងៃទី 11 ខែតុលាឆ្នាំ 1990។

[149] COHCHR, ក្រដាសព្រាងគ្មានចំណងជើង, ថ្ងៃទី4 ខែមិថុនា ឆ្នាំ 2004។

[150] បទសម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់កងរាជអាវុធហត្ថ (GRK) ថ្ងៃទី 30 ខែសីហាឆ្នាំ 2013។ "ប្រេសិតអំពាវនាវ ឱ្យដកកងរាជអាវុធហត្ថ, ភ្នំពេញប៉ុស្ដិ៍ពីថ្ងៃទី 21 ខែវិច្ឆិកាដល់ថ្ងៃទី 4 ខែធ្នូឆ្នាំ 1997 ។ COHCHR, កំណត់ហេតុផ្ទៃក្នុង ទៅកាន់ការិយាល័យខេត្តនិងក្រុមឃ្លាំមើលការបោះឆ្នោត ឆ្នាំ1998។

[151] សម្ភាសន៍ជាមួយនាយកងរាជអាវុធហត្ថជាន់ខ្ពស់ ថ្ងៃទី 10 ខែវិច្ឆិកាឆ្នាំ 1995។

កំណត់។ កងរាជអាវុធហត្ថ ត្រូវបានគេផ្តល់អំណាចឲ្យអនុវត្តការងារជានគរបាលយុត្តិធម៌ និងរដ្ឋបាលនៅទូទាំងប្រទេស ដើម្បីបង្ក្រាបបទឧក្រិដ្ឋ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ដែលការងារបង្ក្រាបនេះ គេធ្វើទាំងទៅលើបុគ្គលិកយោធា និងទាំងជនស៊ីវិល ហើយតាមបែបបទនេះ គេអាចចាប់ខ្លួនទាំងពីរ គឺទាំងបុគ្គលិកយោធា ទាំងជនស៊ីវិល និងប្រគល់ពួកគេយកទៅឃុំក្រោមអំណាចតុលាការ ដើម្បីតុលាការស៊ើបអង្កេតនិងជំនុំជម្រះ។ នៅក្រោមបញ្ជាការនាយករដ្ឋមន្ត្រី កងរាជអាវុធហត្ថ ក៏ត្រូវបានគេអនុញ្ញាតឱ្យចេញកម្លាំង និងអនុវត្តអំណាចរបស់ពួកខ្លួន តាមការស្នើសុំរបស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងដទៃទៀត រួមទាំងតាមរយៈប្រតិបត្តិការសឹកពិសេស។

ទីស្នាក់ការកណ្តាលកងរាជអាវុធហត្ថ ត្រូវបានដឹកនាំដោយមេបញ្ជាការតែម្នាក់ ដែលបំពេញតួនាទីដោយការពិគ្រោះយោបល់ជាមួយនាយករដ្ឋមន្ត្រី (សហនាយករដ្ឋមន្ត្រី)។ មេបញ្ជាការកងកម្លាំងកងរាជអាវុធហត្ថគ្រប់គ្រងផ្ទាល់លើទីបញ្ជាការ "កម្លាំងផ្ទៃប្រទេស" ដែលត្រូវបានដាក់ពង្រាយកងកម្លាំងជាទៀងទាត់នៅជុំវិញប្រទេស ទីបញ្ជាការកងកម្លាំងប្រដាប់អាវុធចល័ត មានដាក់ពង្រាយនៅគ្រប់ទីកន្លែង និងអង្គភាពទីបញ្ជាការនគរបាលយោធា ដែលប្រតិបត្តិការនៅទូទាំងប្រទេស ក្នុងករណីនៃគោលដៅប្រតិបត្តិការ គឺជាបុគ្គលិកយោធា។[152]

នៅគ្រាចុងក្រោយ ទីបញ្ជាការអគ្គសេនាធិការ ត្រូវបានគេរៀបចំជាប្រាំស្នងការដ្ឋាន ៖ ស្នងការដ្ឋានព័ត៌មាន និងសន្តិសុខ ស្នងការដ្ឋានផែនការប្រតិបត្តិការ ស្នងការដ្ឋានស្រាវជ្រាវ និងយុត្តិធម៌ ស្នងការដ្ឋានស្វែងរកប្រភពកម្លាំង និងស្នងការដ្ឋានភស្តុភារ និងបច្ចេកវិជ្ជា។[153] បន្ទាប់ពីការបញ្ជាក់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ដែលចែងថា កងរាជអាវុធហត្ថ មានអំណាចដូចនគរបាលស៊ីវិល បានជម្រុញឲ្យមន្ត្រីកងរាជអាវុធហត្ថ ដកហូតអំណាចពីនគរបាលស៊ីវិល។[154] សេនាធិការកងរាជអាវុធហត្ថក្រុង និងខេត្ត ត្រូវបានដាក់

---

[152] ប៉ុល សារឿន, យុទ្ធសាស្ត្រ DFID, ទំព័រ 32 ។ រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យលេខ 09 អនក្រ ថ្ងៃទី 22 កុម្ភៈ 1994។ រាជរដ្ឋាភិបាលកម្ពុជា )RGC) អនុក្រឹត្យលេខ 77 អនក្រ ចុះថ្ងៃទី 21 ខែធ្នូឆ្នាំ 1994 ។ រាជរដ្ឋាភិបាលកម្ពុជា," កាលប្បវត្តិ "នៃកងរាជអាវុធហត្ថ

[153] រាជរដ្ឋាភិបាលកម្ពុជា (RGC), អនុក្រឹត្យលេខ 136 អនក្របក ថ្ងៃទី25 ខែសីហាឆ្នាំ 2009។

[154] "រំលឹកខួបអនុស្សាវរីយ៍លើកទី 22 និងបញ្ចុះបធម្មសីលាសាងសង់អាគារបញ្ជាការដ្ឋានរាជអាវុធហត្ថលើផ្ទៃប្រទេស"ថ្ងៃទី 14 ខែកក្កដាឆ្នាំ 2015 http://beta.nokorwatnews.com/?p=33153#sthash.TtDOhdmU.dpuf (ចូលមើលថ្ងៃទី14 ខែកក្កដាឆ្នាំ 2015)។ រាជរដ្ឋាភិបាលកម្ពុជា (RGC) ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា)2007), http://www.wipo.int/wipolex/en/text.jsp?file_id=240881, ជំពូក 2-4 (ចូលមើលថ្ងៃទី10 ខែកក្កដាឆ្នាំ 2015) លោកស្ទីវ ហឺឌឺ (Steve Heder) "កម្ពុជាក្នុងឆ្នាំ2010 ការពង្រឹងបន្ថែមរបស់ហ៊ុនសែន" ការស្ទង់មតិអាស៊ី លេខ51 លេខ 1 ខែខែមករា/កុម្ភៈ:2011) ទំព័រ 208-209។

ក្រោម "ការដឹកនាំបញ្ជាដោយផ្ទាល់ពីបញ្ជាការ"នៃកងរាជអាវុធហត្ថថ្នាក់ជាតិ ខណៈពួកគេ (កងរាជអាវុធហត្ថក្រុង និងខេត្ត) គ្រប់គ្រងលើកងរាជអាវុធហត្ថនៅថ្នាក់ស្រុក និងឃុំ។[155] ក៏ប៉ុន្តែ ដូចនគរបាល និងកងទ័ព នៅកម្រិតទាំងនេះដែរ កងរាជអាវុធហត្ថមូលដ្ឋាន ត្រូវរាយការណ៍ទៅគណៈបញ្ជាការឯកភាពក្រុង ខេត្ត និងស្រុក ដែលដឹកនាំដោយអភិបាលរដ្ឋបាលនៃដែនដីទាំងនេះ ដែលមានអំណាចបង្ក្រាបអ្វីៗគ្រប់យ៉ាង ពីចលនាប្រឆាំងប្រដាប់អាវុធ សកម្មភាពព្រហ្មទណ្ឌធម្មតា ដែលគេចាត់ទុកថា ជាការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ។[156]

លោក គៀង សាវុធ មានកេរ្តិ៍ឈ្មោះល្បីល្បាញខាងអាក្រក់ ជាអ្នកគាំទ្រដ៏ស្មោះស្ម័គ្ររបស់គណបក្សប្រជាជនកម្ពុជា និងជាអ្នករំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរម្នាក់។ ប្រទេសបារាំងបានផ្តល់ការបណ្តុះបណ្តាល និងផ្តល់មូលនិធិដល់ប្រតិបត្តិការជាច្រើនរបស់កងរាជអាវុធហត្ថ នៅដើមឆ្នាំដំបូងៗ។ ប៉ុន្តែ ទីប្រឹក្សាយោធាជាន់ខ្ពស់បារាំងដែលឈរជើងនៅកម្ពុជា នៅពេលនោះនិយាយថា "យើងមានបញ្ហាជាច្រើនជាមួយលោក គៀង សាវុធ។ គាត់ត្រូវបានតែងតាំងដោយគណបក្សប្រជាជនកម្ពុជា។ ប្រទេសបារាំងចង់បាននរណាម្នាក់ផ្សេងទៀតដែលមានកេរ្តិ៍ឈ្មោះល្អជាងនេះ។ យើងបានដឹងអំពីគាត់តាំងពីដំបូងមកម៉្លេះ។"[157]

មន្ត្រីជាន់ខ្ពស់បារាំងម្នាក់ទៀតនៅពេលនោះ បាននិយាយថា ប្រទេសបារាំង បានដឹងភ្លាមៗថា លោក គៀង សាវុធ គឺជាបញ្ហាធ្ងន់ធ្ងរ។ យើងដឹងថា គាត់ជាអតីតសមាជិកជាន់ខ្ពស់នៃក្រុមអា (A-Teams) ។ មន្ត្រីវៀតណាម បានប្រាប់មន្ត្រីបារាំងអំពីលោក គៀង សាវុធ តាំងពីដំបូង ពីព្រោះពួកគេមិនចូលចិត្តគាត់ដែរ។ បារាំងដឹងពីតួនាទីរបស់គាត់នៅក្នុងអំពើហិង្សា ហើយថា លោក គៀង សាវុធ ជាប់ពាក់ព័ន្ធជាមួយពួកម៉ាហ្វីយ៉ា តាមរយៈបនល្បែងកាស៊ីណូ ហើយគាត់ជាអ្នកផ្តល់លុយកខ្វក់ទាំងនេះឱ្យទៅលោក ហ៊ុន សែន។ ប៉ុន្តែ វាបានស៊ីពេល ២ ទៅ ៣ ឆ្នាំ សម្រាប់រដ្ឋាភិបាលបារាំង ដើម្បីទទួលស្គាល់ទាំងស្រុងនូវតួនាទីរបស់លោក គៀង សាវុធ នៅក្នុងអំពើហិង្សានិងអំពើពុករលួយ។[158]

---

[155] រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យលេខ 09 អនក្រ, ថ្ងៃទី 2 កុម្ភៈ ឆ្នាំ1994; រាជរដ្ឋាភិបាលកម្ពុជា )RGC) អនុក្រឹត្យលេខ 56 អនក្រ ចុះថ្ងៃទី 21 ខែកញ្ញា ឆ្នាំ1994 ។ រាជរដ្ឋាភិបាលកម្ពុជា )RGC) អនុក្រឹត្យលេខ 44 អនក្របក ថ្ងៃទី 27 ខែឧសភាឆ្នាំ1995។

[156] រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យលេខ 11 អនក្រ ថ្ងៃទី 8 ខែមិនា 1994; រាជរដ្ឋាភិបាលកម្ពុជា )RGC) អនុក្រឹត្យលេខ 22 អនក្រ ថ្ងៃទី 9 ខែឧសភាឆ្នាំ 1994; រាជរដ្ឋាភិបាលកម្ពុជា, "កាលប្បវត្តិនៃរាជកងរាជអាវុធហត្ថ។) រាជរដ្ឋាភិបាលកម្ពុជា" RGC) អនុក្រឹត្យលេខ 156 អនក្របក ថ្ងៃទី 31 ខែមីនា ឆ្នាំ 2014 ។

[157] ប្រ៊ែដ អាដាមស៍ (Brad Adams) សម្ភាសន៍ជាមួយមន្ត្រីយោធាបារាំង ដែលសុំមិនបញ្ចេញឈ្មោះ ព្រោះគាត់មិនមានការអនុញ្ញាតឱ្យនិយាយជាសាធារណៈ នៅថ្ងៃទី 29 ខែមិថុនាឆ្នាំ 2001។

[158] ប្រ៊ែដ អាដាមស៍ (Brad Adams) សម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់បារាំង ដែលសុំមិនបញ្ចេញឈ្មោះទីក្រុងប៉ារីស ថ្ងៃទី13 ខែតុលាឆ្នាំ 2000។

យោងទៅតាមមន្ត្រីជាន់ខ្ពស់បារាំងម្នាក់ ដែលឈរជើងនៅកម្ពុជានៅពេលនោះ "មន្ត្រីអមស្ថានទូតបារាំងផ្នែកនគរបាល និងយោធាការពារជាតិ បានសរសេររបាយការណ៍ជាច្រើនអំពីលោក គៀង សាវុធ។ ឯកអគ្គរដ្ឋទូតបារាំងលោក ឡេ លីដិច (Le Lidec) បានដឹងទាំងអស់អំពីលោកគៀង សាវុធ តាំងពីដំបូងម៉្លេះ។ លោក គៀង សាវុធ គឺជាម្ចាស់បនស្រីទាំងអស់ដែលមានទីតាំងនៅជិតក្លឹបម៉ាទីនី (Martini Club) និងបានចូលរួមក្នុងការជួញដូរគ្រឿងញៀន នៅឆ្នាំ ១៩៩៥ ដល់ ១៩៩៦ ។ គាត់ក៏ជួញដូរក្មេងស្រីដែរ។ គាត់គ្រាន់តែជាជនយូកូងម្នាក់ ហើយគ្មានគុណសម្បត្តិវិជ្ជាជីវៈអ្វីទាល់តែសោះ។ ប៉ុន្តែ បារាំងត្រូវការគាត់នៅដើមដំបូងនៃគម្រោងនេះ (បង្កើតអង្គភាពកងរាជអាវុធហត្ថ)។[159] ក្រោយមក បារាំងបានស្នើឱ្យលោក ហ៊ុន សែន ដកលោក គៀង សាវុធ ចេញបន្ទាប់ពីកងកម្លាំងរបស់គាត់បានវាយប្រហារបាញ់បោះជាសាធារណៈយ៉ាងទូលំទូលាយទៅលើផ្ទះរបស់មន្ត្រីនគរបាលកម្ពុជាជាន់ខ្ពស់មួយរូបនៅភ្នំពេញ ដែលត្រូវបានគេចោទថា បណ្តាលមកពីជម្លោះលើប្រាក់ចំណូលពីការជួញដូរគ្រឿងញៀន។ លោក ឡេ លីដិច (Le Lidec) ចង់ឱ្យដកលោក គៀង សាវុធចេញ បន្ទាប់ពីគាត់បាញ់បោះទៅលើផ្ទះរបស់លោក ហេង ពៅ។ នេះគឺជារឿងធ្ងន់ធ្ងរចុងក្រោយ ដែលគួរឲ្យអៀនខ្មាស់ហួសប្រមាណ ប្រសិនបើធ្វើមិនដឹងមិនឮរឿងនេះ"។[160] អនុប្រធានលោក គៀង សាវុធ គឺលោក សៅ សុខាត្រូវបានតែងតាំងជាអ្នកស្នងតំណែងលោក គៀង សាវុធ។ បើតាមមន្ត្រីដដែល បារាំងក៏ដឹងដែរថា លោក សៅ សុខា ក៏ "ពាក់ព័ន្ធក្នុងបទល្មើសព្រហ្មទណ្ឌ និងអំពើហិង្សាដែរ"។[161]

ជាប្រមុខសេនាធិការនៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលមានអំណាចបញ្ជាផ្ទាល់លើកងរាជអាវុធហត្ថអន្តរាគមន៍ចល័តលើផ្ទៃប្រទេស ដែលរួមមានកងថ្មើរជើង កងរថពាសដែក និងកងទោចក្រយានយន្ត លោក សៅ សុខា ទទួលបានការពេញចិត្តខ្លាំងឡើងខាងនយោបាយ ពីលោក ហ៊ុន សែន ជាពិសេសក្រោយពីលោកបានចាប់ខ្លួនដោយផ្ទាល់នូវមន្ត្រីកងកម្លាំងសន្តិសុខសំខាន់ៗរបស់គណបក្សប្រជាជនកម្ពុជា ដែលបានប៉ុនប៉ងធ្វើរដ្ឋប្រហារមិនបានសម្រេច ដើម្បីបណ្តេញលោក ហ៊ុន សែន និងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៤ ។[162]

---

[159] ប្រ៊ែដ អាដាមស៍ (Brad Adams) សម្ភាសន៍ជាមួយមន្ត្រីបារាំងដែលសុំមិនបញ្ចេញឈ្មោះថ្ងៃទី 21 ខែឧសភាឆ្នាំ 2001។

[160] ដូចខាងលើដដែល Ibid.

[161] ដូចខាងលើដដែល Ibid.

[162] រាជរដ្ឋាភិបាលកម្ពុជា (RGC), ជីវប្រវត្តិឯកឧត្តមនាយឧត្តមសេនីយ៍ ផ្កាយមាសបួនសៅសុខា។ អង្គការសហប្រជាជាតិ, ការិយាល័យតំណាងអគ្គលេខាធិការប្រចាំកម្ពុជា )UNOSGRC) "កងយោធពលខេមរភូមិន្ទកម្ពុជាឆ្នាំ "1995; សម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់នៃកងរាជអាវុធហត្ថកថ ថ្ងៃទី 10 ខែវិច្ឆិកា ឆ្នាំ1995។ កាសែតដំណឹងពេលព្រឹក ថ្ងៃទី 5 ខែកក្កដាឆ្នាំ 1994; បទសម្ភាសន៍ជាមួយសៅសុខាថ្ងៃទី 11 ខែធ្នូឆ្នាំ 2007 ។

ដោយដឹងថា គាត់ងាយរងគ្រោះក្នុងការដកពីអំណាចដោយកងកម្លាំងសន្តិសុខ ដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា ចាប់តាំងពីពេលនោះមក  លោកហ៊ុន សែន បានប្រែក្លាយកងរាជអាវុធហត្ថ ឱ្យទៅជាស្ថាប័នដ៏សំខាន់បំផុតសម្រាប់ទ្រទ្រង់ការកាន់អំណាចរបស់គាត់។[163]  តួនាទីរបស់កងរាជអាវុធហត្ថ ត្រូវបានលើកកម្ពស់បន្ថែមទៀត ដោយសារមុខងារដ៏សំខាន់របស់កងកម្លាំងនៃកងរាជអាវុធហត្ថ ជាពិសេស កងកម្លាំងប្រដាប់អាវុធដែលដឹកនាំដោយលោក សៅ សុខា ក្រោយមកបានដើរតួនាទីនៅក្នុងការធ្វើរដ្ឋប្រហារខែកក្កដា ឆ្នាំ១៩៩៧ របស់លោក ហ៊ុន សែន កម្ទេចចោលគណបក្សហ៊្វុនស៊ិនប៉ិច។

ជារង្វាន់លើកទឹកចិត្ត នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៧ លោក សៅ សុខា ត្រូវបានតែងតាំងជាទីប្រឹក្សារបស់លោក ហ៊ុន សែន ដែលមានឋានៈស្មើរអនុរដ្ឋលេខាធិការ។[164] ក្នុងខែឧសភា ឆ្នាំ១៩៩៩ លោក សៅ សុខាត្រូវបានតែងតាំងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលគាត់មានតំណែងនេះចាប់តាំងពីពេលនោះរហូតមក។[165] បន្ទាប់មកទៀត នៅខែមករា ឆ្នាំ២០០៩ លោក សៅ សុខា ត្រូវបានតែងតាំងជាអគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ។[166]

## នគរបាលកម្ពុជាឆ្នាំ ពី១៩៧៩ ដល់បច្ចុប្បន្ន

### *ក្រសួងមហាផ្ទៃ និងនគរបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា* (PRK)

ស្ថាប័នប៉ូលីសកម្ពុជាសព្វថ្ងៃនេះ ត្រូវបានបង្កើតឡើងនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅពេលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ចាប់កំណើតឡើង។[167] រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទីមួយរបស់សាធារណរដ្ឋប្រជាមា

---

163 UNOSGRC "របាយការណ៍ប្រចាំខែសម្រាប់ ខែឧសភាឆ្នាំ 1996" ។

164 រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រឹត្យលេខ ឆស/រកត/ 0797/88 ថ្ងៃ២៤ ខែកក្កដា ឆ្នាំ១៩៩៧។

165 រាជរដ្ឋាភិបាលកម្ពុជា (RGC), "សៅ សុខា ផ្កាយមាសបួន។ "

166 រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រឹត្យលេខនស/រកត /010/061 ថ្ងៃទី 22 ខែមករាឆ្នាំ 2009។

167 ហ៊ុនសែន "ការថ្លែងសុន្ទរកថានៅខួបលើកទី 65 នៃការបង្កើតនគរបាលជាតិ" ថ្ងៃទី16 ខែឧសភា ឆ្នាំ 2010 ។ http://cnv.org.kh/?p=1151 (ចូលមើលថ្ងៃទី 30 ខែមិថុនាឆ្នាំ 2010)។

និតកម្ពុជា គឺលោក ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជា ដែលបានស្លាប់ក្នុងឆ្នាំ២០១៥។ លោក ត្រូវបានគេទទួលស្គាល់ថា ជាអ្នកនាំមុខក្នុងការរៀបចំ និងបង្កើតកម្លាំងប៉ូលីសនេះ។[168] លោក ជា ស៊ីម ជាអតីតសមមិត្តមេដឹកនាំខ្មែរក្រហមនៅតំបន់បូព៌ានៃបក្សកុម្មុយនីស្តកម្ពុជា (CPK) និងមានជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីនោះ មុនពេលឆ្លងដែនចូលទៅក្នុងប្រទេសវៀតណាម ក្នុងឆ្នាំ១៩៧៨ ហើយបានចូលរួមប្រឆាំងការដឹកនាំរបស់ប៉ុល ពត នៃបក្សកុម្មុយនិស្តកម្ពុជា។[169]

នៅក្នុងគ្រាដែលមានការគំរាមកំហែងផ្នែកយោធាទៅលើរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ពីកម្លាំងទ័ពព្រៃខ្មែរក្រហម ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ត្រូវបានគេផ្តល់អំណាចឱ្យ "រៀបចំបញ្ជា និងដឹកនាំ" គ្រប់កម្រិតនៃកងកម្លាំងនគរបាលប្រជាជន។ ទាំងនេះ ត្រូវបានគេកំណត់ថា ជា "កងកម្លាំងប្រដាប់អាវុធដែលជាកម្មសិទ្ធិរបស់បក្ស" ដែលត្រូវបានចាត់តាំងដើម្បី "ការពារសន្តិសុខនយោបាយ" និង "រក្សាសណ្តាប់ធ្នាប់សង្គម" ដោយការប្រយុទ្ធប្រឆាំងនឹងសត្រូវនយោបាយ និងឧក្រិដ្ឋកម្មធម្មតារបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា។ កាលនោះ ក្រសួងមហាផ្ទៃក៏ទទួលខុសត្រូវផងដែរក្នុងការធានាភាពស្មោះត្រង់ ផ្នែកនយោបាយរបស់នគរបាលនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា និងមានអំណាចបញ្ជាឱ្យប៉ូលីសចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួន សួរចម្លើយ និងកសាងសំណុំរឿងផ្លូវច្បាប់ និងដាក់គុក "ជនគោលដៅ" ដែលគេចោទពីបទល្មើសនយោ បាយ និងបទឧក្រិដ្ឋសាមញ្ញជាទូទៅ។ ក្រសួងនេះទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សារដ្ឋមន្រ្តីរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងការបំពេញការងារ និងសម្រេចភារកិច្ចទាំងអស់ ដែលរួមមានការដំឡើងសក្តិ ការបញ្ចុះសក្តិ ការផ្ទេរ និងការបណ្តេញមន្រ្តីនគរបាល តាមបង្គាប់របស់ក្រុមប្រឹក្សា ដែលដឹកនាំដោយលោក ហ៊ុន សែន ចាប់ពីខែមករា ឆ្នាំ១៩៨៥ បន្ទាប់ពីកំចាត់លោក ប៉ែន សុវណ្ណ ចេញនៅឆ្នាំ១៩៨១ និងការស្លាប់របស់លោក ចាន់ ស៊ី នៅឆ្នាំ១៩៨៤។ ដើម្បីអនុវត្តការងាររបស់ខ្លួន ក្រសួងនេះត្រូវបានបែងចែកជា ៧ នាយកដ្ឋាន រួមទាំងនាយកដ្ឋានសន្តិសុខប្រជាជន និងនាយកដ្ឋាននគរបាលប្រជាជន។[170]

---

168 "ប្រវត្តិសាស្រ្តនៃអគ្គមហាធម្មពោធិសាលជាស៊ីម " (ថ្ងៃទី 11 ខែមិថុនាឆ្នាំ 2015) http://www.dap-news.com/2011-06-14-02-39-55 / 92837-2015-06-08- 10-10-39.html (ចូលមើលថ្ងៃទី 8 ខែមិថុនាឆ្នាំ 2015); ហ៊ុនសែន "ថ្លែងសុន្ទរកថានៅខួបលើកទី 65 នៃការបង្កើតនគរបាលជាតិ" ថ្ងៃទី 16 ខែឧសភាឆ្នាំ 2010 ។ http://cnv.org.kh/?p=1151 (ចូលមើលថ្ងៃទី 30 ខែមិថុនាឆ្នាំ 2010)។

169 "កម្ពុជា ៖ ការស្លាប់របស់ជា ស៊ីម បង្ហាញពីការបរាជ័យរបស់តុលាការខ្មែរក្រហម" ការចេញផ្សាយព័ត៌មានរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ថ្ងៃទី 8 ខែមិថុនាឆ្នាំ 2015។ https://www.hrw.org/news/2015/06/08/cambodia-chea-sim-death - show-failing-khmer-rouge-court ។

170 សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK), អនុក្រឹត្យលេខ 04 អនក ចុះថ្ងៃទី 11 ខែមករាឆ្នាំ 1983។

ទោះបីជាក្រសួងមានអំណាចលើនគរបាលនៅថ្នាក់ជាតិក៏ដោយ ក៏នៅថ្នាក់ក្រុង ខណ្ឌ ស្រុក ឃុំ និងកម្រិតក្រោមៗទៀត នគរបាលក្រសួងមហាផ្ទៃត្រូវសហការជាមួយថ្នាក់ដឹកនាំបក្សប្រជាជនបដិវត្តន៍កម្ពុជានៅទីនោះដែរ។[171] អំណាចរបស់គណបក្ស និងអំណាចរដ្ឋ លើកងកម្លាំងសន្តិសុខ ត្រូវបានពង្រីកដល់យោធាផងដែរ ហើយការដឹកនាំមានប្រសិទ្ធិភាពតាមរយៈ "គណៈបញ្ជាការឯកភាព" ដែលគ្រប់គ្រង និងសម្របសម្រួលកិច្ចប្រតិបត្តិការរួមគ្នាជាញឹកញាប់ដោយ "កងកម្លាំងចម្រុះ" មកពីអង្គភាពសន្តិសុខផ្សេងៗគ្នា។[172]

លក្ខណៈវិនិច្ឆ័យដំបូងបង្អស់សម្រាប់ការជ្រើសរើសចូល និងដំឡើងបុណ្យសក្តិនៅក្នុងជួរនគរបាល គឺភាពស្មោះត្រង់ខាងនយោបាយ និងនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ មន្ត្រីនគរបាលមានដល់ជាង ១០,០០០ នាក់ (មួយម៉ឺន)។ ពួកគេត្រូវបានប្រគល់ភារកិច្ចបង្ក្រាបរាល់ក្រុមអ្នកប្រឆាំងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវត្តមានវៀតណាមនៅកម្ពុជា ក្នុងនោះ មានក្រុមខ្មែរក្រហម ឬក៏ក្រុមផ្សេងទៀត រួមទាំង "សត្រូវបិទមុខ" នៅក្នុងជួររបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាខ្លួនឯង។[173]

នៅក្នុងការអនុវត្តជាក់ស្តែង ចំណុចនេះមានន័យថា នគរបាលមានទិសដៅកំចាត់ចោលខ្មាំងបីប្រភេទ គឺខ្មាំងបះបោរប្រដាប់អាវុធ ក្រុមប្រឆាំងដែលមានអង្គការចាត់តាំងប៉ុន្តែអហឹង្សា និងក្រុមប្រឆាំងសន្តិវិធីជាបុគ្គល។ ការបង្ក្រាបរបស់នគរបាលបែបនេះ ត្រូវបានធ្វើឡើងជាប្រចាំ ដែលជាការរំលោភបំពានលើសិទ្ធិមនុស្ស រួមមានទាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តបែបបន្ទាបបន្ថោក អមនុស្សធម៌ ឬឃោរឃៅ ការឃុំឃាំងតាមអំពើចិត្ត ដោយគ្មានការចោទប្រកាន់ ឬសវនាការ ឬការកាត់សេចក្តីដោយអយុត្តិធម៌។ ការធ្វើទារុណកម្ម ត្រូវបានអនុវត្តជាទូទៅលើអ្នកជាប់ឃុំ ដោយផ្តាច់ទំនាក់ទំនងរបស់ពួកគេទៅអ្នកដទៃទាំងស្រុងខណៈកំពុងសួរចម្លើយ ការដាក់ឲ្យឯកោពីពិភពលោកខាងក្រៅ និងសូម្បីតែពីអ្នកទោសរួមគ្នាក៏ដោយ ជាញឹកញាប់គឺដាក់នៅក្នុង "គុកងងឹត" ការទំនាក់ទំនងជាមួយសាច់ញាតិ ជាធម្មតា ត្រូវស្ថិតក្រោមការដាក់កំហិតយ៉ាងធ្ងន់ធ្ងរក្នុងអំឡុងពេលឃុំឃាំងអ្នកទោស។ តុលាការត្រូវបានប្រើប្រាស់ជាឧបករណ៍គំរាមកំហែងប្រឆាំងនឹងអ្នកទោសទាំងឡាយណា ដែលមិនព្រមសារភាពក្រោមការធ្វើទារុណកម្ម។ ប៉ូលិសបានប្រាប់ជនជាប់ឃុំថា

---

[171] សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK), "មតិណែនាំនិងបទបញ្ជាស្តីពីការតស៊ូប្រឆាំងនឹងពួកអ្នកប្រឆាំងនឹងបដិវត្តន៍ និងការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ល្អក្នុងស្ថានភាពថ្មី" 1979; សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK), សេចក្តីសម្រេចលេខ 143 សរច, ថ្ងៃទី 20 ខែវិច្ឆិកា ឆ្នាំ1981; សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK), អនុក្រឹត្យលេខ 04 អនក ចុះថ្ងៃទី 11 ខែមករា ឆ្នាំ1983។

[172] សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK), គណៈកម្មាធិការគ្រប់គ្រងកិច្ចការបក្សរាជធានីភ្នំពេញ "ការឆ្លើយឆ្លងអមបញ្ជា ៖ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចប្រជុំគណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ" 333 KoABPh-DA, ថ្ងៃទី 18 ខែវិច្ឆិកាឆ្នាំ 1982 ។

[173] គណបក្សប្រជាជនកម្ពុជា, ប្រវត្តិនៃការតស៊ូ, ទំព័រ 41-52 ។

ប្រសិនបើពួកគេមិនប្រើឱកាស "សារភាព" តុលាការប្រជាជនបដិវត្តន៍ នឹងកាត់ទោសពួកគេឱ្យជាប់ពន្ធនាគាររយៈពេលយូរ ជារៀងរហូត ឬឱ្យស្លាប់តែម្តង។ អ្នកទោសដែលត្រូវបានដោះលែងឱ្យមានសេរីភាព ត្រូវបានប៉ូលីសព្រមានមិនឱ្យនិយាយអំពីការធ្វើបាប ដែលជាបទល្មើសដែលប៉ូលីសបានប្រព្រឹត្តិទៅលើពួកគេ ឬនិយាយពីការឈឺចាប់ បើមិនដូច្នេះទេនឹងចាប់ខ្លួនមកវិញ។ យោងតាមអតីតមន្ត្រីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នគរបាលមិនត្រូវបានដាក់ទោសចំពោះការធ្វើទារុណកម្ម ឬការធ្វើបាបអ្នកជាប់ឃុំឡើយ បើទោះបីជាមានបទបញ្ញត្តិច្បាប់ឲ្យដាក់ទោសចំពោះអំពើបែបនេះក៏ដោយ។ ផ្ទុយទៅវិញ ការដាក់វិន័យជួនកាលត្រូវបានធ្វើឡើងប្រឆាំងនឹងនគរបាលណា ដែលយោគយល់មានចិត្តសណ្តោសប្រណី ឬនគរបាលណាមានមនោសញ្ចេតនាជាមួយអ្នកទោស ដូចជាការអនុញ្ញាតឱ្យអ្នកទោសទាក់ទងជាមួយសាច់ញាតិ នាំយកម្ហូបអាហារ ឬថ្នាំពេទ្យ។ គិតត្រឹមពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ មានអ្នកទោសនយោបាយជាង៥000 នាក់ (ប្រាំពាន់) ត្រូវបានជាប់ឃុំឃាំងនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ភាគច្រើននៃពួកគេស្ថិតក្រោមការឃុំខ្លួនដោយប៉ូលិស។[174]

ចាប់តាំងពីឆ្នាំ១៩៨១មក ក្រសួងមហាផ្ទៃត្រូវបានដឹកនាំដោយសមមិត្តមន្ត្រីជាន់ខ្ពស់បក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលមិនមានប្រវត្តិជាខ្មែរក្រហម និងគ្មានទំនាក់ទំនងជាប្រវត្តិសាស្ត្រទៅនឹងលោកហ៊ុន សែនឡើយ។[175] នៅក្នុងខែកក្កដាឆ្នាំ ១៩៨៩ លោក ហ៊ុន សែន បានចុះហត្ថលេខាលើអនុក្រឹត្យមួយ ដែលកំណត់ឡើងវិញនូវមុខងាររបស់ក្រសួងមហាផ្ទៃ ដោយកាត់បន្ថយច្រើន និងរៀបចំរចនាសម្ព័ន្ធឡើងវិញនូវអំណាចជាក់លាក់របស់ខ្លួនលើប៉ូលីស។ ភារកិច្ចចម្បងរបស់ក្រសួងនេះ គឺនៅតែការពារអ្វីដែលត្រូវគេហៅថា "សន្តិសុខនយោបាយនិងសណ្តាប់ធ្នាប់សង្គម" ដើម្បីទប់ស្កាត់អ្នកដែល "ធ្វើសកម្មភាពប្រឆាំង ឬបំផ្លាញរដ្ឋ" និងបង្ក្រាបឧក្រិដ្ឋជនទូទៅ។ ក្រសួងខ្លួនឯងនៅតែមានអំណាចជាតិ ដើម្បីស៊ើបអង្កេត និងស្រាវជ្រាវឧក្រិដ្ឋកម្ម ចាប់ខ្លួន ឃាត់ខ្លួននិងកសាងករណីព្រហ្មទណ្ឌ ប្រឆាំងនឹងគោលដៅ និងយកករណីពិសេសតាមសេចក្តីណែនាំជាក់លាក់របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីរបស់រដ្ឋកម្ពុជា (SOC)។

ក្រសួងមហាផ្ទៃ បានបាត់បង់អំណាចបញ្ជាទៅលើនគរបាលថ្នាក់ក្រោមជាតិ តែអាចនៅរក្សាភារកិច្ចដូចជាការហ្វឹកហ្វឺននគរបាល និងត្រួតពិនិត្យការងាររបស់ពួកគេ។ នៅក្នុងបរិបទនេះ ប៉ូលីសក្រុង ខេត្ត ស្រុក និង

[174] អង្គការលើកលែងទោសអន្តរជាតិ កំណត់សម្គាល់ដែលមានចំណងជើងថា "ពន្ធនាគារក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ថ្ងៃទី "4 ខែសីហា ឆ្នាំ1986 រៀបចំសម្រាប់អង្គការលើកលែងទោសអន្តរជាតិ ការដាក់ពន្ធនាគារនិងការធ្វើទារុណកម្មនយោបាយ (ASA 23/05/87) (ទីក្រុងឡុងដ៍ ៖ខែមិថុនា ឆ្នាំ1987)។

[175] កាសែតអេស្តេកា (SPK) ថ្ងៃទី 17 ខែតុលាឆ្នាំ 1981; SPK, 18 មីនា 1986; Vickery, Kampuchea, ទំព័រ 80។

ឃុំ/សង្កាត់ និងកងជំនួយអន្តរាគមន៍ ត្រូវបានដាក់ក្រោម "ការគ្រប់គ្រងផ្ទាល់" របស់អាជ្ញាធរនៅកម្រិតទាំងនោះ រួមជាមួយកងទ័ព និងកងកម្លាំងសន្តិសុខផ្សេងទៀតដែលត្រូវបានដាក់ក្រោមគណៈបញ្ជាការឯកភាព។ ប៉ូលីសក្រោមបញ្ជាការបែបនេះ ដោះស្រាយទាំងសន្តិសុខនយោបាយ និងរឿងព្រហ្មទណ្ឌទូទៅ។[176]

ក្នុងពេលជាមួយគ្នានេះ ក្រសួងមហាផ្ទៃត្រូវបានពង្រីកទៅជានាយកដ្ឋានចំនួន ២០ ដែលមានពីរសំខាន់បំផុតសម្រាប់ការអនុវត្តការងារប៉ូលីសនយោបាយពិសេសរបស់ក្រសួង មានជាអាទិ៍ "នាយកដ្ឋានប្រឆាំងចារកម្ម" (ការពារនយោបាយទី១) និង "នាយកដ្ឋានប្រឆាំងក្រុមប្រតិកិរិយា" (ការពារនយោបាយទី២)។ និងនាយកដ្ឋានដាច់ដោយឡែកមួយ ដែលមានអំណាចជានគរបាលជាតិទាក់ទងនឹងឧក្រិដ្ឋកម្មទូទៅ គឺទទួលខុសត្រូវលើអង្គភាពជំនាញតូចតាចៗ ដូចជាឧក្រិដ្ឋកម្មព្រហ្មទណ្ឌ និងឧក្រិដ្ឋកម្មសេដ្ឋកិច្ច។[177]

## អ៊ុនតាក់ ក្រសួងមហាផ្ទៃ និងប៉ូលីស

អនុក្រឹត្យរបស់រដ្ឋកម្ពុជា (SOC) ដែលបានប្រកាសជាផ្លូវការភ្លាមៗបន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ បានបញ្ជាក់សាជាថ្មីអំពីការទទួលខុសត្រូវជាទូទៅរបស់ក្រសួងមហាផ្ទៃចំពោះ "ការការពារសន្តិសុខនយោបាយ" និង "សណ្តាប់ធ្នាប់សាធារណៈ" ក៏ប៉ុន្តែក្រសួងនេះនៅតែមិនមានអំណាចដោយផ្ទាល់លើប៉ូលីសថ្នាក់ក្រោមជាតិ។ ប៉ុន្តែ ក្រសួងមហាផ្ទៃនៅតែរក្សាការបញ្ជាលើកងកម្លាំងប៉ូលីសឯកទេសដែលគេបានបង្កើតឡើងកាលពីមុន រួមទាំងប៉ូលីសដែលទទួលខុសត្រូវក្នុងការបង្ក្រាបសកម្មភាពប្រឆាំងនឹងរដ្ឋកម្ពុជា (SOC)។ ក្នុងចំណោមនោះ វានៅតែមាននាយកដ្ឋានចំនួន ២០ ដែលក្នុងនោះមាន៤នាយកដ្ឋាន ដែលមានភារកិច្ចជានគរបាលនយោបាយពិសេសរបស់ជាតិ ដែលត្រូវបានគេរៀបចំចាត់តាំងផ្ទៃក្នុងជា "កងកម្លាំងរក្សាសន្តិសុខនយោបាយ" ១, ២, ៣ និង ៤ ។[178]

---

[176] វិទ្យុភ្នំពេញ ថ្ងៃទី 6 ខែឧសភា ឆ្នាំ1988 ថ្ងៃទី10 ខែឧសភា ឆ្នាំ1988; រដ្ឋកម្ពុជា )SOC) អនុក្រឹត្យលេខ 73 អនក្រចុះថ្ងៃទី11 ខែកក្កដាឆ្នាំ1989។ យូអិន (UN) "របាយការណ៍បេសកកម្មស្វែងរកការពិតនៃអង្គការសហប្រជាជាតិស្តីពីរចនាសម្ព័ន្ធបច្ចុប្បន្ននិងការអនុវត្តរដ្ឋបាលនៅកម្ពុជាថ្ងៃទី 24 ខែមេសាដល់ថ្ងៃទី 9 ខែឧសភាឆ្នាំ1990" ខែមិថុនាឆ្នាំ1990 ទំព័រ 47 ។ បេសកកម្មស្ទាបស្ទង់របស់អង្គការសហប្រជាជាតិនៅកម្ពុជា ៖ សន្តិសុខសាធារណៈ និងនគរបាលស៊ីវិលនៅក្នុងរដ្ឋកម្ពុជា ទំព័រទី "29 ទំព័រ 31។

[177] រដ្ឋកម្ពុជា )SOC), អនុក្រឹត្យលេខ 73 អនក្រចុះថ្ងៃទី 11 ខែកក្កដាឆ្នាំ 1989។

[178] រដ្ឋកម្ពុជា )SOC) អនុក្រិត្យ 26 អនក្រ ថ្ងៃទី១ ខែវិច្ឆិកាឆ្នាំ១៩៩១។

រួមជាមួយនាយកដ្ឋានអង្គរក្ស កម្លាំងដែលការពារសន្តិសុខនយោបាយទាំងនោះ ស្ថិតនៅក្រោមអនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស៊ិន សេន ជាអនុប្រធានម្នាក់ក្នុងចំណោមអនុប្រធានបួននាក់អមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃគឺលោក ស៊ិន សុង។ លោក ស៊ិន សេន និងលោកស៊ិន សុង គឺជាអតីតខ្មែរក្រហមពីតំបន់បូព៌ា ដែលបានឆ្លងចូលទៅប្រទេសវៀតណាមក្នុងឆ្នាំ១៩៧៧។ ក្នុងតារាងរាយនាមថ្មី ក្រុមការពារសន្តិសុខនយោបាយទី១ ទទួលខុសត្រូវចំពោះអ្វីដែលគេហៅថា "ការប្រឆាំងនឹងវិទ្ធង្សនា" ដែលមានន័យថា "ប្រយុទ្ធប្រឆាំងគណបក្សដទៃ ឬក្រុមផ្សេង" រួមទាំងការដាក់ពង្រាយអង្គភាពចល័តជម្រើសនៅគ្រប់ទីកន្លែងក្នុងផ្ទៃប្រទេស។ នាយកដ្ឋានការពារសន្តិសុខនយោបាយទី២ ទទួលខុសត្រូវចំពោះ "ប្រមូលព័ត៌មានសម្ងាត់"។ នាយកដ្ឋានការពារសន្តិសុខនយោបាយទី៣ ទទួលខុសត្រូវលើអន្តោប្រវេសន៍ និងបញ្ហាពាក់ព័ន្ធ។ នាយកដ្ឋានការការពារសន្តិសុខនយោបាយទី៤ ជាទូទៅទទួលខុសត្រូវក្នុងការការពារពិធីការដំឡើងបុណ្យសក្តិ និងពិធីជួបជុំរបស់រដ្ឋកម្ពុជា (SOC) ចំណែកឯនាយកដ្ឋានអង្គរក្សដែលដាច់ដោយឡែកពីនេះ ត្រូវទទួលខុសត្រូវចំពោះការការពារបុគ្គលនិងក្រុមបុគ្គលជាក់លាក់ណាមួយ។ ជាមួយគ្នានឹងនាយកដ្ឋានសន្តិសុខនយោបាយទាំងបួនរបស់ក្រសួងនេះ មានមន្ត្រីប៉ូលិសចំនួន ៤,៦៩០ នាក់ (បួនពាន់ប្រាំមួយរយហាសិប) ក្នុងចំណោមមន្ត្រីប៉ូលីស ៤៧,៦៨៤ នាក់ (បួនម៉ឺនប្រាំពីរពាន់ប្រាំមួយរយប៉ែតបួន) ដែលជាកម្លាំងគ្រប់ប្រភេទនៅទូទាំងប្រទេស។[179] ប៉ូលីសក្រុង, ខេត្តនិងស្រុក ត្រូវអនុវត្តមុខងារសន្តិសុខនយោបាយតំបន់របស់ខ្លួន ដែលរៀបចំជាការិយាល័យនៅតាមស្នងការនគរបាលស្រុក ខេត្ត ក្រុង និងអធិការដ្ឋានរៀងៗខ្លួន។[180]

ក្រសួងមហាផ្ទៃ ក៏នៅតែមាននាយកដ្ឋានបទល្មើសព្រហ្មទណ្ឌ និងបទល្មើសសេដ្ឋកិច្ច ដែលផ្តោតលើឧក្រិដ្ឋកម្មទូទៅដែលធ្ងន់ធ្ងរ រួមទាំងបទឧក្រិដ្ឋកម្មទាក់ទងនឹងទ្រព្យសម្បត្តិ និងគ្រឿងញៀន។ នគរបាលព្រហ្មទណ្ឌទូទៅ និងព្រហ្មទណ្ឌសេដ្ឋកិច្ច នៅថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឲ្យមើលថែការិយាល័យជាមួយស្នងការនគរបាល និងអធិការដ្ឋាននគរបាលនៅទីនោះ។[181]

អាណត្តិនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសសម្រាប់អ៊ុនតាក់ ក្នុងការអនុវត្តការគ្រប់គ្រងដោយផ្ទាល់លើមុខងារជាក់លាក់នានារបស់រដ្ឋកម្ពុជា (SOC) គណបក្សប្រឆាំងហ៊្វុនស៊ីនប៉ិច និងអតីតអំណាចរដ្ឋបាលទ័ព

---

[179] អង្គការសហប្រជាជាតិ "ការស្វែងមតិរបស់អង្គការសហប្រជាជាតិ" ទំព័រ 5-6, 14-15, 26, 28-31 និង 40-41។

[180] អង្គការសហប្រជាជាតិ បេសកកម្ម"ស្ទាបស្ទង់របស់អង្គការសហប្រជាជាតិ ឧបសម្ព័ន្ធ "3 និង 4; អ៊ុនតាក់ (UNTAC) "បញ្ជីឈ្មោះអាជ្ញាធររបស់រដ្ឋាភិបាលរដ្ឋកម្ពុជាស្នងការដ្ឋាន" អ៊ុនតាក់" "នគរបាលខេត្តបន្ទាយមានជ័យ "21 ខែឧសភាឆ្នាំ 1993។

[181] អង្គការសហប្រជាជាតិ បេសកកម្ម"ស្ទាបស្ទង់របស់អង្គការសហប្រជាជាតិ ឧបសម្ព័ន្ធ "3 និង 4; ស្នងការដ្ឋាន"នគរបាលខេត្តបន្ទាយមានជ័យ " ថ្ងៃទី21 ខែឧសភាឆ្នាំ 1993។

ព្រៃដទៃទៀត នៅក្នុងប្រទេសកម្ពុជានាពេលនោះ រួមទាំង "សន្តិសុខសាធារណៈ" ផងដែរ។[182] បេសកកម្មស្ទង់មតិរបស់អង្គការសហប្រជាជាតិ ដែលបានធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ នៅខែវិច្ឆិកាដល់ខែធ្នូ ឆ្នាំ១៩៩១ បានបកស្រាយចំណុចនេះថា ក្រសួងមហាផ្ទៃក៏ត្រូវរួមបញ្ចូលក្រោមការគ្រប់គ្រងរបស់អ៊ុនតាក់ដែរ។[183] ក៏ប៉ុន្តែ មុនការមកដល់នៃអ៊ុនតាក់ គណបក្សប្រជាជនកម្ពុជា បានរៀបចំឡើងវិញនូវផ្នែកខ្លះរបស់រដ្ឋបាលរដ្ឋកម្ពុជា (SOC) របស់ខ្លួន។ បញ្ហានេះ គឺថានៅចុងខែមករា ឆ្នាំ១៩៩២ គណបក្សប្រជាជនកម្ពុជា បានបង្កើតក្រសួងថ្មីមួយ ដាក់ឈ្មោះថា ក្រសួងសន្តិសុខជាតិ ដោយបំបែកខ្លួនចេញពីក្រសួងមហាផ្ទៃ ជាមួយមុខងារការពារសន្តិសុខនយោបាយ និងថែរក្សាមុខងារសណ្តាប់ធ្នាប់សាធារណៈ។[184] ចំណែកក្រសួងមហាផ្ទៃដែលត្រូវបានកាត់បន្ថយទំហំ មានរដ្ឋមន្ត្រីស ខេង ជាជនស៊ីវិល ទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយ ការបណ្តុះបណ្តាល អធិការកិច្ច និងសកម្មភាពស្ថិតិទាក់ទងទៅនឹងការរៀបចំនៃរដ្ឋបាលដែនដី។[185] លោក ស ខេង ដែលបានកាន់តំណែងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃរហូតមកដល់សព្វថ្ងៃ គឺមានតួនាទីដូចគ្នាដដែល។

រីឯរដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ គឺលោក ស៊ិន សុង ដោយមានលោក ស៊ិន សេន ជាអនុរដ្ឋមន្ត្រី។[186] អតីតនាយកដ្ឋានការពារសន្តិសុខនយោបាយ ត្រូវបានផ្តល់ឈ្មោះថ្មី។ អ្វីដែលសំខាន់បំផុតនោះ គឺនាយកដ្ឋានការពារសន្តិសុខនយោបាយទី១ (ហៅថា ស២១) ដែលឥឡូវនេះហៅថា ជានាយកដ្ឋានប្រឆាំងភេរវកម្ម និងនាយកដ្ឋានការពារសន្តិសុខនយោបាយលេខទី២ (ហៅថា ស២២) ដែលឥឡូវនេះហៅថា នាយកដ្ឋានស្រាវជ្រាវចារកិច្ច។[187] តាមច្បាប់ អនុប្រធាន និងមន្ត្រីសន្តិសុខជាតិផ្សេងៗជាច្រើនទៀតរបស់នាយកដ្ឋានមានអំណាចនគបាលយុត្តិធម៌ ប៉ុន្តែមន្ត្រីក្រសួងមហាផ្ទៃមិនមានអំណាចនេះទេ។[188]

---

182 អង្គការសហប្រជាជាតិ "កម្ពុជា ៖ អ៊ុនតាក់ (UNTAC)។

183 អង្គការសហប្រជាជាតិ បេសកកម្ម"ស្ទាបស្ទង់របស់អង្គការសហប្រជាជាតិ " ទំព័រ ៤ ។

184 វិទ្យុភ្នំពេញថ្ងៃទី 30 ខែមករាឆ្នាំ 1992។

185 កាសែត SPK ថ្ងៃទី31 ខែមករា ឆ្នាំ1992; អ៊ុនតាក់, "នរណាជានរណា", អ៊ុនតាក់, "បញ្ជីបេក្ខជននៃក្រសួងមហាផ្ទៃនៃរដ្ឋកម្ពុជា ថ្ងៃទី "12 ខែសីហាឆ្នាំ 1992 ។

186 អ៊ុនតាក់ "សៀវភៅមគ្គុទ្ទេសក៏ទូរស័ព្ទរបស់រដ្ឋលេខ 14 ខែកញ្ញាឆ្នាំ1992"; UNTAC, "នរណាជានរណា "។

187 អ៊ុនតាក់ "បញ្ជីឋានន្តរសក្តិនៃក្រសួងសន្តិសុខជាតិ" លោក ម៉ក់ ជីតូ, លិខិតជូនចំពោះអ្នកនិពន្ធនាយក "ការអះអាងគ្មានការទទួលខុសត្រូវ បានធ្វើឱ្យអង្គការការពារសិទ្ធិ ទទួលបានការទទួលស្គាល់តិចតួច" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 16 ខែវិច្ឆិកាឆ្នាំ 2012 php / 2012111659766 / National- news / reckless-claim-rights-organization-little-credit.html (ចូលមើលនៅថ្ងៃទី 16 ខែវិច្ឆិកាឆ្នាំ 2012) ។

188 រដ្ឋកម្ពុជា (SOC), ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី 29 ខែមករាឆ្នាំ 1993។

## ១៩៩៣ ៖ ក្រសួងមហាផ្ទៃ និងនគរបាលនៃរាជរដ្ឋាភិបាលកម្ពុជា

ក្រោមការដឹកនាំនៃរដ្ឋាភិបាលចម្រុះបណ្តោះអាសន្ន បន្ទាប់ពីការបោះឆ្នោតអ៊ុនតាក់ នៅខែឧសភាឆ្នាំ ១៩៩៣ ក្រសួងមហាផ្ទៃ និងក្រសួងសន្តិសុខជាតិ ត្រូវបានច្របាច់បញ្ចូលគ្នាឡើងវិញទៅជាក្រសួងមហាផ្ទៃ និងសន្តិសុខជាតិតែមួយគត់ ដែលមានសហប្រធានពីគណបក្សហ្វុនស៊ិនប៉ិច គឺព្រះអង្គម្ចាស់ ពោត្តម រណឫទ្ធិ និងពីគណបក្សប្រជាជនកម្ពុជា គឺលោក ហ៊ុន សែន ធ្វើជាសហរដ្ឋមន្ត្រី។[189] គណបក្សនីមួយៗ បាន តែងតាំងអនុរដ្ឋមន្ត្រីម្នាក់ ឱ្យបំពេញកិច្ចការក្រសួងប្រចាំថ្ងៃ។ លោក ស៊ិន សេន ត្រូវបានតែងតាំងពីគណបក្សប្រជាជនកម្ពុជា។[190]

ក្នុងនាមជាសហរដ្ឋមន្ត្រី លោក ហ៊ុន សែន បានចាត់ទុក "សន្តិសុខសាធារណៈ" ជាអាទិភាពដោយសង្កត់ធ្ងន់លើតួនាទីរបស់នគរបាលរហូតដល់កម្រិតឃុំ ដើម្បីជានាការបង្ក្រាបនូវអ្វីដែលគាត់ហៅថា "ពួកជ្រុលនិយមជន ពួកឱកាសនិយម និងអ្នកក្លែងបន្លំ" ដែលលោកបានចោទប្រកាន់ថា កំពុងរំខានសន្តិសុខ។[191]

បន្ទាប់ពីការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានៅខែកញ្ញា ឆ្នាំ១៩៩៣ និងការបង្កើតរាជរដ្ឋាភិបាលកម្ពុជា រួមគ្នារវាងរណឫទ្ធិ និងហ៊ុនសែន ជានាយករដ្ឋមន្ត្រីទីមួយ និងទីពីរ លោកស ខេង ពីគណបក្សប្រជាជនកម្ពុជា និងលោក យូ ហុកគ្រី មកពីគណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច បានក្លាយជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមានលោក អ៊ឹម ឈុនលឹម ពីគណបក្សប្រជាជនកម្ពុជា និងមន្ត្រីមួយរូបទៀតពីហ្វ៊ុនស៊ិនប៉ិច ជារដ្ឋលេខាធិការពីររូបដើមដំបូងគេរបស់ក្រសួងនេះ និងបន្ទាប់មកគឺមានលោក ស៊ិន សេន ជាមួយមន្ត្រីហ្វ៊ុនស៊ិនប៉ិចមួយរូបទៀតត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការដំបូងរបស់ក្រសួងនេះដែរ។[192]

---

[189] "ព្រះអង្គម្ចាស់នរោត្តមរណឫទ្ធិ ស្តីពីការត្រួតពិនិត្យការពារជាតិ, ក្រសួងមហាផ្ទៃ "កាសែត AFP, ក្រុងភ្នំពេញ ថ្ងៃទី 22 ខែមិថុនាឆ្នាំ 1993 ។

[190] វិទ្យុរាជធានីភ្នំពេញ នៅថ្ងៃទី 19 ខែកក្កដាឆ្នាំ 1993។ លោកស៊ិនសុង ត្រូវបានជំនួសដោយលោក ស៊ិន សិន បន្ទាប់ពីស៊ីនសុងបានចូលរួមនៅក្នុង "ការបំបែកខ្លួន "ក្លែងក្លាយមួយរបស់គណបក្សប្រជាជន នៅខែមិថុនា ឆ្នាំ1993 ដើម្បីដាក់សម្ពាធសម្តេចសីហនុ ហ្វ៊ុនស៊ិនប៉ិច និងអ៊ុនតាក់ ដើម្បីឲ្យយល់ព្រមលើរដ្ឋាភិបាលចម្រុះ។ ហ៊ុនសែន បានលុបចោលស៊ិនសុងលើលេសថា ស៊ិនសុងនិងអ្នកផ្សេងទៀត បានធ្វើសកម្មភាពដោយគ្មានការយល់ព្រមពីហ៊ុនសែននិងគណបក្សប្រជាជន។ ក្រោយមក ស៊ិនសុងបានសងសឹកដោយការប៉ុនប៉ងរដ្ឋប្រហារ នៅថ្ងៃទី 2 ខែកក្កដាឆ្នាំ1994 ដែលបានបរាជ័យ។ ស៊ិនសុងបានភៀសខ្លួនទៅប្រទេសថៃ។

[191] វិទ្យុភ្នំពេញថ្ងៃទី 18 ខែសីហាឆ្នាំ 1993។

[192] វិទ្យុភ្នំពេញថ្ងៃទី 29 ខែតុលាឆ្នាំ1993, រាជរដ្ឋាភិបាលកម្ពុជា )RGC) ក្រឹត្យ, ថ្ងៃទី 1 ខែវិច្ឆិកាឆ្នាំ 1993 ។

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងលោក ហ៊ុន សែន បានចុះហត្ថលេខាលើអនុក្រឹត្យថ្មីមួយ ដោយបញ្ជាក់ថា ការិយាល័យនៃក្រសួងមហាផ្ទៃមាន "សមត្ថកិច្ចគ្រប់គ្រងគ្រប់រដ្ឋបាលខេត្តក្រុងទាំងមូល គ្រប់គ្រងនគរបាលជាតិកម្ពុជា និងការពារសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ" នៃព្រះរាជាណាចក្រ។ អំណាចគ្រប់គ្រងមូលដ្ឋានរបស់ក្រសួងនេះ រួមមានការប្រមូលទិន្នន័យស្ថិតិ ដូចជា ទិន្នន័យអ្នកចុះឈ្មោះអ្នកបោះឆ្នោត និងព័ត៌មានស្តីពីជនបរទេសនៅក្នុងប្រទេស ការទទួលរបាយការណ៍ជាទៀងទាត់ និងសំណើដាក់លាក់ពីរដ្ឋបាលមូលដ្ឋានសុំកម្លាំងសន្តិសុខឱ្យធ្វើសកម្មភាព និងការលុបចោលបទបញ្ជារបស់ក្រុង និងខេត្តនៅពេលចាំបាច់។ ពួកគេត្រួតពិនិត្យតាមដាន និងទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ អំពីសកម្មភាពរបស់ក្រុងនិងខេត្ត ប៉ុន្តែមិនមែនអំពីសកម្មភាពរបស់ប៉ូលីសទេ។[193] នៅខែមករាឆ្នាំ១៩៩៦ បទប្បញ្ញត្តិនៃអនុក្រឹត្យនេះត្រូវបានបញ្ជាក់ជាថ្មីនៅក្នុងច្បាប់ថ្មី ដែលបានចែងឡើងវិញនូវអំណាចទូទៅរបស់ក្រសួង ប៉ុន្តែបានទុកចំណុចលំអិតដាក់លាក់នានាទៅក្នុងអនុក្រឹត្យ និងច្បាប់រដ្ឋបាលដាច់ដោយឡែកផ្សេងទៀត។[194] ច្បាប់រដ្ឋបាលថ្មីនេះ បានរក្សាទុកនូវខ្លឹមសារច្បាប់របស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបែងចែកនគរបាល ជាថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ។ នគរបាលថ្នាក់កណ្តាល គឺសំដៅដល់ "ក្រសួងមហាផ្ទៃ" ដែលជួនកាលហៅថា ប៉ូលីសនៃនាយកដ្ឋានកណ្តាលពិសេស ឬនាយកដ្ឋានរង។[195]

យោងតាមអនុក្រឹត្យឆ្នាំ១៩៩៣ អំណាចប៉ូលីសជាក់លាក់របស់ក្រសួងមហាផ្ទៃ រួមមាន ការស៊ើបអង្កេតឧក្រិដ្ឋ ការចាប់ខ្លួន និងការឃុំខ្លួន និងការបញ្ជូនឯកសារសំណុំរឿង និងភស្តុតាងទៅជំនុំជម្រះ បូកនឹងការការពារព្រំដែនប្រទេស និងខ្សែបន្ទាត់ទំនាក់ទំនង និងត្រួតពិនិត្យការប្រើប្រាស់អាវុធ និងគ្រាប់រំសេវផ្ទុះ។ រចនាសម្ព័ន្ធរបស់ការិយាល័យក្រសួង រួមមានអគ្គនាយកដ្ឋាននគរបាលជាតិ ដែលដឹកនាំដោយមន្ត្រីមួយរូប

---

193 រាជរដ្ឋាភិបាលកម្ពុជា )RGC) អនុក្រឹត្យលេខ 16 អនក្រ ថ្ងៃទី ២០ ខែធ្នូ 1993 ។

194 រាជរដ្ឋាភិបាលកម្ពុជា )RGC) ព្រះរាជក្រមលេខ នស/រកម/0196/08 ថ្ងៃទី 24 ខែមករាឆ្នាំ 1996។

195 រាជរដ្ឋាភិបាលកម្ពុជា )RGC) "អនុក្រឹត្យលេខ 27 អនក្របក ថ្ងៃទី 30 ខែមករាឆ្នាំ 2009 "អាជ្ញាធរថៃប្រគល់ឱ្យអាជ្ញាធរកម្ពុជានូវឃាតកខ្មែរម្នាក់ដែលបានចោរប្លន់និងបាញ់សម្លាប់ជនជាតិជប៉ុនម្នាក់" Khmerload ថ្ងៃទី 4 ខែឧសភាឆ្នាំ2013, http://www.khmerload.com/news/13106 (ចូលមើលថ្ងៃទី 20 ខែឧសភាឆ្នាំ 2013) ។ "ជនដៃដល់ពីរនាក់និងជនសមគំនិតបីនាក់ដែលជាប់ឃុំក្នុងករណីប្លន់ម៉ូតូ និងសម្លាប់" ថ្ងៃទី 30 ខែតុលាឆ្នាំ 2012, http://www.yolprom.com/news/20121030-349 (ចូលមើលនៅថ្ងៃទី១ ខែវិច្ឆិកាឆ្នាំ 2012)។

*ដែលបានទទួលតំណែងថ្មីទើបបង្កើត គឺអគ្គនាយកនគរបាលជាតិ ស្ថិតក្រោមនាយកដ្ឋាននេះ មានអង្គភាពនគរបាលអន្តរាគមន៍ និងនាយកដ្ឋានកណ្តាលចំនួនប្រាំ។ នាយកដ្ឋានកណ្តាលទាំងប្រាំនោះ គឺនាយកដ្ឋានកណ្តាលនគរបាលព្រំដែន នាយកដ្ឋានសណ្តាប់ធ្នាប់សាធារណៈ នាយកដ្ឋានកណ្តាលផ្នែកយុត្តិធម៌ (នាយកដ្ឋាននគរបាលយុត្តិធម៌) នាយកដ្ឋានកណ្តាលផ្នែកសន្តិសុខ និងនាយកដ្ឋានកណ្តាលផ្នែកមធ្យោបាយ ដែលនាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានម្នាក់ ដែលមានឋានៈស្មើនឹងអគ្គនាយករងនៃនគរបាលជាតិ ។ យោងតាមអង្គការលេខដែលជាផ្នែកមួយនៃអនុក្រឹត្យ អគ្គនាយកដ្ឋាននគរបាលជាតិ មានបន្ទាត់អំណាចគ្រប់គ្រងទៅលើស្នងការនគរបាលរាជធានី និងខេត្ត ហើយតាមរយៈខ្សែបន្ទាត់អំណាចនេះ ក៏គ្រប់គ្រងតៗទៅលើអធិការដ្ឋាននគរបាលស្រុក និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ប៉ុន្តែនាយកដ្ឋានកណ្តាល ពុំមានអំណាចបែបនេះទេ។ អំណាចរបស់ពួកគេ គឺទៅលើតែបុគ្គលិកក្រោមបង្គាប់ក្នុងនាយកដ្ឋារបស់ខ្លួនផ្ទាល់តែប៉ុណ្ណោះ។*[196]

*នៅពេលនោះ តំណែងប៉ូលិសជាច្រើន រួមទាំងអគ្គនាយកនគរបាលជាតិផង នៅតែមិនទាន់មានអ្នកចូលបំពេញ ឬអ្នកកាន់ការនៅឡើយ ទុកឱកាសឲ្យលោក ស៊ិន សេន នៅទទួលបន្ទុកយ៉ាងមានប្រសិទ្ធភាពលើនគរបាលថ្នាក់ជាតិ។*[197] *រួមដៃជាមួយ លោក ស៊ិន សុង គាត់ (ស៊ិន សេន) បានដើរតួយ៉ាងសំខាន់ក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារប្រឆាំងនឹង លោក ហ៊ុន សែន និងព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ នៅថ្ងៃទី២ ខែកក្កដាឆ្នាំ ១៩៩៤ ដែលការបះបោរប្រដាប់អាវុធនោះទទួលបានការគាំទ្រពីលោក ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជា និងលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលការជំរុញឲ្យធ្វើដូច្នេះ ពីព្រោះតែពួកគេខកចិត្ត មិនពេញចិត្តនឹងតំណែងជាន់ខ្ពស់ដែលពួកគេបានទទួលក្នុងរដ្ឋាភិបាលចម្រុះ។*

---

[196] នៅក្រោមនាយកដ្ឋានកណ្តាលសន្តិសុខ មាននាយកដ្ឋានបួនគឺ ៖ ព័ត៌មានទូទៅ  អតីត)ស22), ប្រឆាំងភេរវកម្ម អតីត ស២១, ជនបរទេសនិងអង្គរក្ស។ នៅក្រោមនាយកដ្ឋានកណ្តាលយុត្តិធម៌ មានបីគឺ ៖ នគរបាលប្រឆាំងបទឧក្រិដ្ឋកម្ម នគរបាលសេដ្ឋកិច្ច និងនគរបាលបច្ចេកទេសនិងវិទ្យាសាស្ត្រ។ នៅក្រោមនាយកដ្ឋានកណ្តាលសាធារណៈ មាននាយកបួននាយកដ្ឋានគឺ ៖ សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ នគរបាលការពារ និងនគរបាលរដ្ឋបាល។ រាជរដ្ឋាភិបាលកម្ពុជា (RGC)  អនុក្រឹត្យលេខ 16 អនក្រចុះថ្ងៃទី 20 ខែធ្នូឆ្នាំ 1993។

[197] រាជរដ្ឋាភិបាលកម្ពុជា (RGC), អនុក្រឹត្យលេខ 16 ចុះថ្ងៃទី 20 ខែធ្នូឆ្នាំ 1993។

ជាលទ្ធផលនៃរដ្ឋប្រហារបរាជ័យ លោក ស៊ិន សុង បានភៀសខ្លួនទៅប្រទេសវៀតណាម ហើយបន្ទាប់មកទៅប្រទេសថៃ ជាកន្លែងដែលគាត់នៅទីនោះអស់ពេលជាច្រើនឆ្នាំ ខណៈដែលលោក ស៊ិន សេនត្រូវបានគេចាប់ខ្លួន និងជាប់គុក។ ផ្ទះរបស់លោក ជា ស៊ីម ត្រូវបានហ៊ុំព័ទ្ធ តែលោក ហ៊ុន សែនត្រូវបានគេបញ្ចុះបញ្ចូលមិនឱ្យចាប់ខ្លួនគាត់។ លោក ជា ស៊ីម និងស ខេង បានបាត់បង់អំណាចយ៉ាងច្រើននៅក្នុងគណបក្សប្រជាជនកម្ពុជា ដោយរួមទាំងការត្រួតត្រាលើនគរបាលដែលនៅសេសសល់។[198]

នៅក្នុងបរិបទនេះ ច្បាប់ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី បានចែងនៅក្នុងមាត្រាទី២ថា រដ្ឋាភិបាល "ត្រួតត្រា បញ្ជា និងប្រើប្រាស់កងទ័ព នគរបាល និងកងកម្លាំងប្រដាប់អាវុធដទៃទៀត និងគ្រប់គ្រងការដឹកនាំសកម្មភាពរបស់ពួកគេ។[199]" មាត្រា៩ បានផ្តល់អំណាចដល់នាយករដ្ឋមន្ត្រីឱ្យ "បញ្ជាសកម្មភាពទាំងអស់របស់រាជរដ្ឋាភិបាលក្នុងគ្រប់វិស័យទាំងអស់។" មាត្រាទី១៥ បានប្រគល់ឲ្យនាយករដ្ឋមន្ត្រីនូវអំណាចតែងតាំង ផ្ទេរ និងដកចេញមន្ត្រីយោធា "ជាន់ខ្ពស់" និងមន្ត្រីដទៃទៀត ដោយមិនចាំបាច់យោងទៅអាជ្ញាធរដទៃទៀត។[200] ការបកស្រាយផ្លូវច្បាប់របស់គណបក្សប្រជាជនកម្ពុជាលើច្បាប់នេះ បានដាក់ឱ្យនាយករដ្ឋមន្ត្រីជាអ្នកបញ្ជា "ផ្ទាល់" លើកម្លាំងនគរបាល និងកងកម្លាំងប្រដាប់អាវុធ តាំងពីពេលនោះមក។[201]

អនុក្រឹត្យចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៤ ដែលចុះហត្ថលេខាដោយព្រះអង្គម្ចាស់ រណឫទ្ធិ និង លោក ហ៊ុន សែន បានរុះរើក្រសួងមហាផ្ទៃ ហើយប្រគល់តំណែងអគ្គនាយកនគរបាលជាតិ ឱ្យទៅលោក ហុក ឡង់ឌី តាមជម្រើសផ្ទាល់ខ្លួនរបស់ លោក ហ៊ុន សែន។ អនុក្រឹត្យនេះ បានចែងថា នាយកដ្ឋាននគរបាលរបស់ក្រសួង ត្រូវស្ថិតក្រោមលោក ហុក ឡង់ឌី តែម្នាក់គត់ រួមបញ្ចូលទាំងនគរបាលអន្តរាគមន៍ នគរបាលប្រឆាំងគ្រឿងញៀន នគរបាលព្រំដែនគោក នគរបាលព្រំដែនទឹក និងនគរបាលព្រំដែនបច្ចេកទេស។[202] បន្តបន្ទាប់មកទៀត នាយកដ្ឋាននគរបាលក្រសួងមហាផ្ទៃដែលបានបង្កើតបន្ថែមទាំងអស់ ត្រូវបានគេដាក់ក្រោមការគ្រប់គ្រងតាមវិធីនេះ រួមទាំងនគរបាលទេសចរណ៍ នគរបាលការពារឧត្តុនិយម នគរបាលការពារការដ្ឋាន

---

198 ប្រ៊ែដ អាដាមស៍ )Brad Adams), "ការប្រារព្ធខួបគម្រប់នៃការប៉ុនប៉ងការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ" ខេមបូឌាដេលីថ្ងៃទី 2 ខែកក្កដាឆ្នាំ 2014, https://www.cambodiadaily.com/opinion/marking-the-anniversary-of-cambodian-coupempt- 62966/ ( ចូលមើលថ្ងៃទី 4 ខែកក្កដាឆ្នាំ 2014) ។

199 រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រមលេខ 02 / នស /94 ថ្ងៃទី 20 ខែកក្កដាឆ្នាំ 1994។

200 រាជរដ្ឋាភិបាលកម្ពុជា (RGC), "ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ថ្ងៃទី "20 ខែកក្កដាឆ្នាំ 1994។

201 យឿន, ច្បាប់, ទំព័រ 324-315។

202 រាជរដ្ឋាភិបាលកម្ពុជា (RGC), អនុក្រឹត្យលេខ 94 អនក្រ ចុះថ្ងៃទី 23 ខែសីហាឆ្នាំ 1994។

ដូរមនុស្ស និងការពារអនីតិជន និងបញ្ហាការដ្ឋានបញ្ហាការពារ។[203]

ការតែងតាំងមន្ត្រីកងកម្លាំងសន្តិសុខនៅថ្នាក់ជាន់ខ្ពស់ទាំងនេះ នៅតែជាបុព្វសិទ្ធិរបស់នាយករដ្ឋមន្ត្រី ហើយនាយកដ្ឋានកណ្តាលក្រសួងមហាផ្ទៃទាំងបួន ត្រូវបានដាក់នៅក្នុងប្រភេទដាច់ដោយឡែកពីគ្នា ដោយមិនមែនស្ថិតក្រោមការដឹកនាំទាំងស្រុងរបស់អគ្គមេបញ្ជាការនគរបាលជាតិទេ។ នាយកដ្ឋានកណ្តាលទាំងបួននោះ គឺនគរបាលសន្តិសុខ នគរបាលយុត្តិធម៌ នគរបាលសណ្តាប់ធ្នាប់សាធារណៈ និងមធ្យោបាយ។[204] ដើម្បីត្រួតលើកងកម្លាំងនៃផ្នែកផ្សេងៗទាំងឡាយរបស់ក្រសួង និងដើម្បីធ្វើឱ្យលោក ស ខេង ចុះខ្សោយ លោក ហ៊ុន សែន បានជំរុញឱ្យមាន "ទីប្រឹក្សាសម្រាប់ក្រសួងមហាផ្ទៃ និងកិច្ចការសន្តិសុខជាតិ" ផ្ទាល់របស់ខ្លួន គឺលោក អែម សំអាន ដែលត្រូវបានគេតែងតាំងទៅកាន់ក្រសួងមហាផ្ទៃ។[205] នៅឆ្នាំ១៩៩៥ លោក ហ៊ុន សែន បានទទួលជោគជ័យក្នុងការតែងតាំងលោក អែម សំអាន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលតំណែងនេះបានធក់យកអំណាចពីមុនៗរបស់មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា មានដូចជាលោក ស៊ិន សុង និង លោក ស៊ិន សេន។ ចាប់ពីពេលនោះមក លោក អែម សំអាន បានក្លាយជារដ្ឋលេខាធិការជាន់ខ្ពស់នៅក្នុងក្រសួង ជាតំណែងដែលគាត់កាន់កាប់រហូតដល់ថ្ងៃមរណភាពរបស់គាត់នៅខែមីនា ឆ្នាំ២០១៨។[206]

យោងតាមការសម្រេចចិត្តឆ្នាំ២០០៦ ទោះបីជាលោក ស ខេង ដឹកនាំ និងចាត់ចែងជាផ្លូវការនូវ "សកម្មភាពទាំងអស់" របស់ក្រសួងក៏ដោយ ក៏លោកមិនមាន "ការគ្រប់គ្រងផ្ទាល់" លើកម្លាំងប៉ូលីស ហើយជាពិសេសមិនមានអំណាចគ្រប់គ្រងលើផ្នែកសន្តិសុខកណ្តាលរបស់ក្រសួងទេ។ ផ្ទុយទៅវិញ រដ្ឋលេខាធិការលោក អែម សំអាន មានសិទ្ធិអំណាច "ជួយ" គាត់ទាក់ទងនឹងមុខងារបញ្ជាទាំងពីរ។[207] ប្រការនេះ បានជានា

---

[203] រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រឹត្យលេខ នស /0610/467 ថ្ងៃទី 8 ខែមិថុនាឆ្នាំ 2010។

[204] រាជរដ្ឋាភិបាលកម្ពុជា (RGC) អនុក្រឹត្យលេខ 135 អនក្របក ស្តីពីការតែងតាំងនិងការផ្ទេរតំណែងនគរបាលជាតិ ថ្ងៃទី 29 ខែកក្កដាឆ្នាំ 1996។ រាជរដ្ឋាភិបាលកម្ពុជា (RGC), អនុក្រឹត្យលេខ 94 អនក្រ ថ្ងៃទី 23 សីហា 1994 ។

[205] បទសម្ភាសន៍ជាមួយអតីតមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ថ្ងៃទី17 ខែតុលា ឆ្នាំ1997 (PGC), អនុក្រឹត្យលេខ 02 អនក្រ ថ្ងៃទី17 ខែកក្កដា ឆ្នាំ1993 ។ "ការផ្លាស់ប្តូរមន្ត្រីប៉ូលីសដែលជាប់ឃុំឃាំង "រស្មីកម្ពុជា (Reaksamei Kampuchea) ថ្ងៃទី20 ខែកក្កដា ឆ្នាំ1994 ។

[206] "ប្រភពអំពីការផ្លាស់ប្តូរក្រសួងការពារជាតិ ដែលអាចធ្វើទៅបាន "រស្មីកម្ពុជា ថ្ងៃទី 19 ខែវិច្ឆិកាឆ្នាំ 1995។ បទសម្ភាសន៍ជាមួយអតីតមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ថ្ងៃទី 17 ខែតុលាឆ្នាំ 1997, http://www.interior.gov.kh/en/structure-chart (ចូលមើលថ្ងៃទី 29 ខែធ្នូឆ្នាំ 2014)។ "ជាឧត្តមសេនីយ៍និងជារដ្ឋបុរសសន្តិភាព អែមសំអាន បានស្លាប់នៅព្រឹកព្រលឹមថ្ងៃទី 24 ខែមីនាឆ្នាំ 2018" ថ្ងៃទី 24 ខែមីនាឆ្នាំ 2014, https: //www.dap-news.com/kh/bls/68219.html (ចូលមើលថ្ងៃទី 25 ខែមីនាឆ្នាំ 2018 ) ។

[207] រាជរដ្ឋាភិបាលកម្ពុជា (RGC) សេចក្តីសម្រេច 494 សសរ ថ្ងៃទី 26 ខែមិថុនាឆ្នាំ 2006។

អំណាចរបស់លោក អែម សំអាន ដើម្បីចុះហត្ថលេខាលើបទបញ្ជាដែលមានកំរិតខ្ពស់ទៅកាន់នគរបាលថ្នាក់កណ្តាល។[208]

លោក ហុក ឡុងឌី ដែលបានដឹកនាំក្រុមនគរបាលចូលរួមធ្វើរដ្ឋប្រហារនៅខែកក្កដា ឆ្នាំ១៩៩៧ (លោក ស ខេងបានបដិសេធមិនចូលរួម) នៅតែជាអគ្គនាយកនគរបាល ហើយបន្ទាប់មកជាអគ្គស្នងការនគរបាលជាតិ រហូតដល់ស្លាប់ក្នុងហេតុការណ៍ធ្លាក់ឧទ្ធម្ភាគចក្រក្នុងខែវិច្ឆិកា ឆ្នាំ២០០៨ ដែលបន្ទាប់មកតំណែងនេះត្រូវបានបំពេញដោយក្មួយប្រសារប្រុសរបស់លោក ហ៊ុន សែន គឺលោក នេត សាវឿន។[209]

## ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា និងនគរបាលបច្ចុប្បន្ន

តាមផ្លូវច្បាប់ និងតាមការអនុវត្តជាក់ស្តែង អគ្គស្នងការនគរបាលជាតិ លោក នេត សាវឿន បានចែករំលែកអំណាចបញ្ជាលើនគរបាលថ្នាក់កណ្តាល ជាមួយលោក អែម សំអាន។[210] ដូចគ្នានឹងក្រោមរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែរ លោកក៏ចែកអំណាចបញ្ជាលើនគរបាលក្រុង ខេត្ត និងនគរបាលមូលដ្ឋានដទៃទៀត ជាមួយអភិបាលខេត្ត ក្រុង និងឃុំ ក្នុងដែនសមត្ថភាពរបស់ខ្លួន ក្នុងនាមជាប្រធានគណៈបញ្ជាការឯកភាព លើកងកម្លាំងសន្តិសុខទាំងអស់ ក្នុងតំបន់រដ្ឋបាលរបស់ពួកគេ។[211] គិតត្រឹមឆ្នាំ២០១៤ ចំនួននគរបាលសរុបនៅក្នុងប្រទេសកម្ពុជា ត្រូវបាននិយាយជាផ្លូវការថា មាន ៥២,០០០នាក់ (ប្រាំម៉ឺនពីរពាន់)។[212] នៅខែកុម្ភៈ ឆ្នាំ២០១៦ លោក ហ៊ុន សែន បានបញ្ជាឱ្យជ្រើសរើសបុគ្គលិកប៉ូលីសថ្មីចំនួន ៤,៥០០ (បួនពាន់ប្រាំរយ) នាក់ក្នុងរយៈពេលប្រាំពីរខែ ដើម្បីជំនួសប៉ូលីសដែលបានចាកចេញពីការងារចាប់តាំងពីឆ្នាំ២០១៤ ដោយ

---

208 ក្រុមចាប់ជម្រិតដែលត្រូវបានចាប់ខ្លួននៅភ្នំពេញនឹងត្រូវនិរទេស, ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី 8 ខែមករាឆ្នាំ 2013, http://www.phnompenhpost.com/national/%E2%80%98extortionists%E2%80%99-arrested-phnom- penh-be-deported (ចូលមើលនៅថ្ងៃទី 10 ខែមករាឆ្នាំ 2013)។

209 "ឧត្តមសេនីយ៍នេត សាវឿន ក្មួយប្រសាររបស់លោកហ៊ុនសែន ត្រូវបានគេយកធ្វើជាមេប៉ូលីស "សម្លេងសហរដ្ឋអាមេរិ ជាភាសាខ្មែរ ថ្ងៃទី 11 ខែវិច្ឆិកាឆ្នាំ 2008 https://khmerisation.wordpress.com/2008/11/12/gen-neth-savoeun-hun-sens-nephew-in-law-tapped-as-police-chief/ ចូល)មើលថ្ងៃទី 25 ខែសីហាឆ្នាំ 2012)។

210 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC( "កំណត់សម្គាល់លើកិច្ចប្រជុំជាមួយប្រធាននិងអនុប្រធានគណៈកម្មការសន្តិសុខ" ថ្ងៃទី 29 ខែសីហាឆ្នាំ 2006 ។

211 រាជរដ្ឋាភិបាលកម្ពុជា (RGC), អនុក្រឹត្យលេខ 22 អនក្រ ចុះថ្ងៃទី 9 ខែឧសភា ឆ្នាំ1994, រាជរដ្ឋាភិបាលកម្ពុជា (RGC) អនុក្រឹត្យលេខ 156 អនក្របក ចុះថ្ងៃទី 31 ខែមីនាឆ្នាំ 2014 ។

212 គណបក្សប្រជាជនកម្ពុជា, ប្រវត្តិនៃការតស៊ូ, ទំព័រ 188 ។

និយាយថា នេះគឺជាការចាំបាច់ ដើម្បី "រក្សាសណ្តាប់ធ្នាប់សាធារណៈ" និងដើម្បី "សន្តិសុខសង្គម"។[213] គិតត្រឹមខែធ្នូឆ្នាំ២០១៧ តួលេខផ្លូវការសម្រាប់ប៉ូលីសនៅទូទាំងប្រទេសគឺ ៥៨,១៩៨ នាក់ (ប្រាំម៉ឺន ប្រាំបីពាន់មួយរយកៅសិបប្រាំបី) ក្នុងនោះមាន ១៧,៨៩៧ នាក់ (មួយម៉ឺនប្រាំពីរពាន់ ប្រាំបីរយកៅសិបប្រាំពីរ) នៅកម្រិតកណ្តាល។[214]

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ប្រធាន និងអនុប្រធាននៃនាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលដទៃមួយចំនួនទៀត រួមទាំងប្រធាន និងអនុប្រធាននៃនាយកដ្ឋានក្រោមបង្គាប់របស់ពួកគេ និងនាយកដ្ឋានមួយចំនួនផ្សេងទៀត ព្រមទាំងបុគ្គលិកដែលដឹកនាំការិយាល័យផ្សេងៗ ក្រោមបង្គាប់នាយកដ្ឋានផ្សេងៗគ្នា គឺជាមន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ ដែលមានយុត្តាធិការកំរិតជាតិ។ អភិបាល និងអភិបាលរងរាជធានី ខេត្ត និងខណ្ឌ និងមេឃុំជនបទ និងក្រុង ក៏ជាមន្ត្រីនគរបាលយុត្តិធម៌ដែរ ប៉ុន្តែមានយុត្តាធិការតែក្នុងមូលដ្ឋានរបស់ខ្លួនប៉ុណ្ណោះ។ ចំណែក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅតែមិនមានអំណាចផ្នែកនគរបាលយុត្តិធម៌ដដែល។[215]

នៅខែមេសា ឆ្នាំ២០១៤ រចនាសម្ព័ន្ធធំពីរទៀតត្រូវបានបង្កើតឡើង នោះគឺ អគ្គនាយកដ្ឋានថ្មីចំនួនពីរៈ មួយសម្រាប់ជនអន្តោប្រវេសន៍ ឌ. (គ្រប់គ្រងលើជនបរទេស) ដែលដឹកនាំដោយឧត្តមសេនីយ៍សុខ ផល និងមួយទៀតសម្រាប់អត្តសញ្ញាណ (ឌ. ឯកសារអត្តសញ្ញាណកម្ពុជា រួមទាំងឯកសារសម្រាប់ប្រើប្រាស់ក្នុងប្រទេសនិងលិខិតឆ្លងដែន) ដែលដឹកនាំដោយឧត្តមសេនីយ៍ ម៉ៅ ចាន់ដារ៉ា។[216]

---

[213] "នគរបាលជាតិពង្រឹង 'សន្តិសុខ' ដោយមាននគរបាលថ្មី ៤,៥០០ នាក់ភ្នំពេញប៉ុស្តិ៍ថ្ងៃទី "12 ខែកុម្ភៈ ឆ្នាំ 2016 http://www.phnompenhpost.com/national-police-bolster-security-4500-new-cops (ចូលមើលថ្ងៃទី 13 ខែកុម្ភៈឆ្នាំ 2016); "ក្រសួងមហាផ្ទៃពន្យល់ព័ត៌មានអំពីការជ្រើសរើសកងកម្លាំងប៉ូលីសជាតិចំនួន 4,500 បន្ថែមទៀត ថ្ងៃទី"12 ខែកុម្ភៈឆ្នាំ 2016" http://www.dap-news.com/2011-06-14-02-39-55/108830-2016 -02-12-14-24-27.html (ចូលមើលថ្ងៃទី 13 ខែកុម្ភៈឆ្នាំ 2016)

[214] របាយការណ៍ចុងក្រោយបង្ហាញថា កម្ពុជាមានមន្ត្រីនគរបាលជាតិ ជិត៦ម៉ឺននាក់ នៅទូទាំងប្រទេស។

[215] រាជរដ្ឋាភិបាលកម្ពុជា (RGC), ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (2007), មាត្រា 60, 67, 68, http://www.wipo.int/wipolex/en/text.jsp?file_id=240881 (ចូលមើលថ្ងៃទី 10 ខែកក្កដាឆ្នាំ 2015) ។ ការអនុវត្តកន្លងមកគឺថា នាយកដ្ឋានកណ្តាលនិងនាយកដ្ឋានថ្នាក់ក្រោម ក៏មានអំណាចខ្លះលើការិយាល័យប៉ូលីសក្រុងនិងក្រុង ជាមួយនឹងមុខងារទទួលខុសត្រូវដូចគ្នាផងដែរ ត្រង់ថាវាក៏ស្ថិតនៅក្រោមអំណាចរបស់ស្នងការនគរបាលរាជធានីនិងខេត្តដែរ។ សូមមើលឧទាហរណ៍ អង្គការលេខដែលបង្កើតឡើងដោយក្រសួងមហាផ្ទៃ មានអគ្គស្នងការនគរបាលជាតិ នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្មសេដ្ឋកិច្ច ការិយាល័យប៉ូលីសខេត្ត/ក្រុងប្រឆាំងឧក្រិដ្ឋកម្មសេដ្ឋកិច្ច" លើរចនាសម្ព័ន្ធនៃនគរបាលប្រឆាំងឧក្រិដ្ឋកម្មសេដ្ឋកិច្ច " ]n.d. [ប៉ុន្តែចុះកាលបរិច្ឆេទតាមបរិបទរហូតដល់ឆ្នាំ 2014 ។

[216] "រាជរដ្ឋាភិបាលសម្រេចបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍និងអត្តសញ្ញាណប័ណ្ណ" ថ្ងៃទី 2 ខែមេសាឆ្នាំ 2014, http: //www.dap-news.com/2011-06-14-02-39-55/84120-2014-04-02 -07-49-59.html (ចូលមើលថ្ងៃទី 5 ខែមេសាឆ្នាំ 2014); ពិធីសម្ពោធអគ្គនាយកដ្ឋានចំនួន២ និងពិធីតែងតាំងអគ្គ

*អគ្គនាយកដ្ឋានថ្មីទាំងពីរនេះបង្កើតឡើងដោយច្របាច់បញ្ចូលក្រសួងមហាផ្ទៃដែលមានស្រាប់ជាមួយអង្គភាពនគរបាលមួយចំនួន បង្កើតជាអង្គភាពពិសេសដែលមានឋានៈប្រហាក់ប្រហែលនឹងក្រសួង។ អគ្គនាយកដ្ឋានទាំងពីរត្រូវបានបញ្ជាក់ថា ជាស្ថាប័នដាច់ដោយឡែកពីនគរបាលជាតិ បើទោះជាផ្លូវការនៅតែជាផ្នែកមួយរបស់ក្រសួងមហាផ្ទៃក៏ដោយចុះ ប៉ុន្តែមិនដាក់ឱ្យស្ថិតនៅក្រោមលោក ស ខេង ជារដ្ឋមន្ត្រីនោះឡើយ។*

*គំនិតផ្តួចផ្តើមសំខាន់ៗមួយទៀតនាពេលថ្មីៗនេះ គឺការបង្កើតឡើងវិញ ដែលចាប់ផ្តើមក្នុងខែសីហា ឆ្នាំ ២០១៥ នូវកងកម្លាំងមួយ ដែលស្រដៀងនឹងនគរបាលប្រយុទ្ធអា៣ (A3) ដែលគេបានបង្កើតក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា កាលពីឆ្នាំ ១៩៨៦ និងបន្ទាប់មកត្រូវបានគេរំលាយចោលជាផ្លូវការនៅឆ្នាំ ១៩៩១។ នៅខណៈ ក្រុមអា៣ (A3) ត្រូវបានបង្កើតឡើងជាកងកម្លាំងយោធា ដើម្បីប្រយុទ្ធនឹងពួកខ្មែរក្រហម កម្លាំងប៉ូលីសថ្មីដែលមានឈ្មោះថា "កម្លាំងអន្តរាគមន៍ពិសេស " នេះត្រូវបានបង្កើតឡើង ដើម្បីប្រយុទ្ធប្រឆាំងនឹងសត្រូវនយោបាយស្របច្បាប់ និងសត្រូវសំខាន់ៗរបស់រដ្ឋាភិបាល។ ជាមួយសមត្ថភាពក្នុងការប្រើ "អាវុធថ្មើរជើង" រួមទាំងកាំភ្លើងឈ្មបបាញ់ស៊ីបផង កម្លាំងពិសេសនេះ ត្រូវបានដាក់ឱ្យចូលរួមព្រម*

---

នាយកនិងជាប្រធានបណ្ឌិតសភានគរបាលកម្ពុជានា ថ្ងៃទី 23 ខែមេសាឆ្នាំ 2014 ។ http://www.dap-news.com/2011-06-14-02-39-55/85236-2014-04-23-10-24-47.html (បានមើលថ្ងៃទី១ ខែឧសភាឆ្នាំ២០១៤); "នាយកនៃនាយកដ្ឋានអន្តោប្រវេសន៍និងអត្តសញ្ញាណប័ណ្ណថ្មីៗបានចូលស្បថសច្ចា" ខេមបូឌាដេលីថ្ងៃទី 25 ខែមេសាឆ្នាំ 2014 http://www.cambodiadaily.com/news/heads-of-new-departments-of-immigration-identification-sworn-in -57344 / (ចូលមើលថ្ងៃទី 25 ខែមេសាឆ្នាំ 2014); "ឯកឧត្តមឧត្តមសេនីយ៍ឯកឌីវិជ្ជាត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ" នៅថ្ងៃទី 8 ខែសីហាឆ្នាំ 2014។ ក្រោមនេះ នាយកកំពូលរបស់ពួកគេប្រើអំណាចរួមគ្នាជាមួយអភិបាលស្រុក និងមេបញ្ជាការប៉ូលីសជុំវិញការងារអន្តោប្រវេសន៍និងឯកសារអត្តសញ្ញាណប៉ូលីសក្នុងខេត្តនិងក្រុង ដែលជាទូទៅត្រូវបានគ្រប់គ្រងដោយស្នងការរងស្នងការរងនៅថ្នាក់ទាំងនេះ។ "សេចក្តីប្រកាសផ្ទេរនិងការតែងតាំងអនុប្រធានស្នងការរងនៅខេត្តបន្ទាយមានជ័យ ថ្ងៃទី "25 ខែមិថុនាឆ្នាំ 2014 " http://www.dap-news.com/2011-06-14-02-39-55/89301-2014-06-25-12-50-54.html (ចូលមើលថ្ងៃទី 25 ខែមិថុនាឆ្នាំ 2014) ។ ឯកឧត្តមសុខផលបានចូលរួមក្នុងការតែងតាំងស្នងការរងទទួលបន្ទុកផ្នែកអន្តោប្រវេសន៍នៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ថ្ងៃទី28 ខែមិថុនា ឆ្នាំ2014។ http://www.dap-news.com/2011-06-14-02-39-55/89503-2014-06-28-05-28-08.html (ចូលមើលថ្ងៃទី 29 ខែមិថុនាឆ្នាំ 2014)។ "ពិធីប្រកាសផ្ទេរនិងតែងតាំងតំណែងនិងតម្លើងបនៈសក្តិដល់មន្ត្រីនគរបាលខេត្តស្វាយរៀងថ្ងៃទី "19 ខែកក្កដាឆ្នាំ 2014 "http://www.nokorwatnews.com/detailnews.php?newsid=43132&mnu=2&cid=4 (accessed July 30, 2014); "ឧត្តមសេនីយ៍សុខ ផល បានដឹកនាំក្រុមការងារចុះត្រួតពិនិត្យនិងស្ទាបស្ទង់ជាជាតិវៀតណាមដែលរស់នៅបឹងទន្លេសាប" ថ្ងៃទី24 ខែសីហាឆ្នាំ 2014 ។ http://www.dap-news.com/2011-06-14-02-39-55/93545-2014-08-24-03-40-26.html (ចូលមើលថ្ងៃទី 24 ខែសីហាឆ្នាំ 2014); "នាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ រិះគន់យ៉ាងខ្លាំងលើការបង្ក្រាបជនជាតិវៀតណាម ដែលស្នាក់នៅខុសច្បាប់ចំនួន ១២ នាក់ថ្ងៃទី "30 ខែតុលាឆ្នាំ2014។ http://nokorwatnews.com/detailnews.php?newsid=46502&mnu=2&cid=4#sthash.ubVTo4Sl.dpbs (ចូលមើលថ្ងៃទី 3 ខែវិច្ឆិកាឆ្នាំ 2014) ។ "នាយកដ្ឋានអន្តោប្រវេសន៍ ផ្សព្វផ្សាយការងារអន្តោប្រវេសន៍នៅឯស្នងការខេត្តពោធិសាត់ ទី "14 ខែមករាឆ្នាំ 2015, http://www.dap-news.com/2011-06-14-02-39-55/102828-2015-01-14-02-58-59.html (ចូលមើលថ្ងៃទី 20 ខែមករាឆ្នាំ 2015) ។ "ឧត្តមសេនីយ៍សុខផល អគ្គនាយករងអន្តោប្រវេសន៍ ប្រគល់រថយន្តនិងកុំព្យូទ័រ ស្នងការខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល" ថ្ងៃទី10 ខែកុម្ភៈឆ្នាំ 2015, http://www.dap-news.com/2011-06-14-02-39-55/86109-2015-02-10- 07-18-33.html (ចូលមើលថ្ងៃទី12 ខែកុម្ភៈឆ្នាំ2015)។

*គ្នាជាមួយកងទ័ពក្នុងការ "បង្ការស្ថានភាពអាក្រក់ " ដែលអាចត្រូវបានបង្កឡើងដោយ "ពួកអមិត្ត" របស់រដ្ឋាភិបាល និងអ្នកដទៃ ដែលមាននិន្នាការប្រឆាំង នៅពេលនគរបាលសាមញ្ញ មិនអាចគ្រប់គ្រងស្ថានភាពបែបនេះបាន។*[217]

## I. ឧត្តមសេនីយ៍ប៉ុល សារឿន មេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ

### *ជាមួយខ្មែរក្រហម ឆ្នាំ១៩៦៨-១៩៧៨*

*យោងតាមជីវប្រវត្តិរបស់គាត់ជាមន្ត្រីសម័យខ្មែរក្រហម លោក ប៉ុល សារឿន ហៅម៉ម រ៉ុន កើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៤៨ នៅភូមិព្រៃអង្គ្រង ឃុំជ្រៃធំ ស្រុករមាសហែក ខេត្តស្វាយរៀង។ គាត់បានចូលរួមក្នុងចលនាខ្មែរក្រហមនៅខែមីនា ឆ្នាំ ១៩៦៨ និងបានក្លាយជាសមាជិករបស់បក្សកុម្មុយនិស្តកម្ពុជា នៅឆ្នាំ ១៩៧១។*[218] *បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមនៅខែមេសា ឆ្នាំ១៩៧៥ គាត់គឺជាសមាជិក ហើយបន្ទាប់មកក៏ឡើងជាអនុប្រធានអគ្គសេនាធិការយោធភូមិភាគបូព៌ា របស់បក្សកុម្មុយនីស្តកម្ពុជា មើលការខុសត្រូវលើការិយាល័យសន្តិសុខតំបន់ ដែលមានឈ្មោះថា ស៧៩ (S79) ជាកន្លែងដែលសមាជិកយោធាជាច្រើននៅភូមិភាគបូព៌ា ត្រូវបានគេចោទប្រកាន់ពីបទក្បត់បដិវត្តន៍ និងចាប់ឃុំខ្លួនដោយគ្មានការចោទប្រកាន់ ឬការកាត់ក្តី និងជាញឹកញាប់ ត្រូវបានគេធ្វើទារុណកម្ម ក្នុងអំឡុងពេលសួរចម្លើយ ហើយក្រោយមក ត្រូវបានគេ*

---

[217] "អគ្គស្នងការដ្ឋាននគរបាលជាតិ នឹងបណ្តុញកងកម្លាំងនគរបាលណា ដែលមិនបានចូលរួមជាទៀងទាត់ក្នុងការហ្វឹកហ្វឺន" ថ្ងៃទី 15 ខែតុលាឆ្នាំ 2015 http://kampucheathmey.com/kpt/?p=88126 (ចូលមើលថ្ងៃទី 15 ខែតុលាឆ្នាំ 2015)។ "កងកម្លាំងនគរបាលជាតិ រៀនយុទ្ធសាស្ត្រពីកងវរសេនាតូចលេខ911" ថ្ងៃទី16 ខែតុលាឆ្នាំ 2015, https://www.cambodiadaily.com/news/national-police-force-learn-tactics- from-911-brigade-97355 / (ចូលមើលនៅថ្ងៃទី17 ខែតុលាឆ្នាំ2015)

[218] មជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារលេខ I08276 "ជីវប្រវត្តិរបស់លោកម៉មរ៉ុន ហៅ ប៉ុលសារឿនប្រធាននយោបាយនៃភូមិភាគបូព៌ា" http://www.d.dccam.org/Database/Lod/details.php?keyword=&numRecords= 100 & ទំព័រ =530 & idnum = I08276 & lang = eng (ចូលមើលថ្ងៃទី22 ខែកញ្ញាឆ្នាំ 2012); នៅលើប័ណ្ណចុះឈ្មោះបណ្តោះអាសន្នឆ្នាំ 2017 ថ្ងៃខែឆ្នាំកំណើតរបស់គាត់ត្រូវបានគេចុះនៅថ្ងៃទី18 ខែសីហាឆ្នាំ1949 (ឯកសារ 05-703-073)។ ការមិនដឹង ឬក្លែងបន្លំអាយុលើឯកសារផ្លូវការ គឺជារឿងធម្មតានៅក្នុងប្រទេសកម្ពុជា ដូច្នេះថ្ងៃខែឆ្នាំកំណើតផ្លូវការ អាចត្រូវបានទទួលយកតាមតំលៃចំពោះមុខ។ ដូច្នេះក្នុងរបាយការណ៍នេះ ថ្ងៃខែឆ្នាំកំណើតទាំងអស់ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាផ្លូវការ។

ប្រហារជីវិតតាមអំពើចិត្ត ឬឃុំសម្រាប់ "ការរៀនសូត្រឡើងវិញ"។ ការរៀនសូត្រឡើងវិញ កើតឡើងនៅកន្លែងដែលគ្រប់គ្រងដោយលោក ប៉ុល សារឿន។[219]

នៅពេលប៉ុល ពត អគ្គលេខាបក្សកុម្មុយនិស្តកម្ពុជា ចាប់ផ្តើមធ្វើការបោសសំអាត និងសម្លាប់មនុស្សជាទូទៅ នៅភូមិភាគបូព៌ា ក្នុងខែឧសភា ឆ្នាំ១៩៧៨ លោក ប៉ុល សារឿនបានរត់គេចខ្លួនចូលទៅក្នុងព្រៃ ជាទីដែលគាត់បានព្យាយាមរៀបចំក្រុមប្រដាប់អាវុធ ដើម្បីងើបប្រឆាំងទៅនឹងការបោសសំអាត និងការសម្លាប់ប្រជាជនយ៉ាងរង្គាលនៅភូមិភាគបូព៌ាដោយពួកខ្មែរក្រហមប៉ុល ពត។[220] នៅពេលការបះបោរនេះបរាជ័យ គាត់បានភៀសខ្លួនទៅជ្រកកោនក្នុងប្រទេសវៀតណាម នៅខែកញ្ញា ឆ្នាំ១៩៧៨ ដោយចូលរួមជាមួយអតីតសមមិត្តហ៊ុន សែន យោធាភូមិភាគបូព៌ា។[221]

## ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ១៩៧៩-១៩៩១

នៅពេលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ចាប់កំណើត នៅខែមករា ឆ្នាំ១៩៧៩ លោកប៉ុល សារឿន បានក្លាយជាប្រធានរដ្ឋបាល ខេត្តតាកែវ និងជាប្រធានបក្សកុម្មុយនិស្តរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា (បក្សប្រជាជនបដិវត្តន៍កម្ពុជា)នៅទីនោះ។[222] គាត់បានទទួលប្រយោជន៍ពីគោលនយោបាយវៀតណាម ក្នុងការជ្រើសរើសអតីតកម្មាំងទាហានរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានឆន្ទៈក្នុងការសហការ ក្នុងការកសាងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយមិនគិតពីតួនាទីរបស់ពួកគេនៅក្នុងរបបខ្មែរក្រហម។[223]

នៅក្នុងសមត្ថភាពទាំងនេះ លោក ប៉ុល សារឿន បានមើលការខុសត្រូវលើការបង្កើត និងលើកិច្ចប្រតិបត្តិការ

---

219 ឯកសាររបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក "SUBJ IIR 6 024 055 97 / បទសម្ភាសន៍ជាមួយមៅ ភូក អតីតអនុប្រធានបណ្តាញនារសារកុម្មុយនីស្តខ្មែរក្រហមតំបន់បូព៌ា" Kiernan, របបប៉ុលពត, ទំព័រ 395; បទសម្ភាសន៍ជាមួយអតីតយុទ្ធជនខ្មែរក្រហមនៅតំបន់បូព៌ាថ្ងៃទី 15 ខែមេសាឆ្នាំ1981 និងថ្ងៃទី 26 ខែឧសភាឆ្នាំ 1981 ជុំរុំខៅអ៊ីដាង (Khao I Dang) ប្រទេសថៃ។

220 បទសម្ភាសន៍ជាមួយអតីតសមមិត្តម៉ែនចាន់ តំបន់បូព៌ា, រាជធានីភ្នំពេញថ្ងៃទី 6 ខែសីហាឆ្នាំ1990។

221 Kiernan, របបប៉ុលពត, ទំព័រ 392-411, 440-442; Carney ទំព័រទី "កងទ័ពប្រដាប់អាវុធរបស់ហេងសំរិន" 153-160។ ជីវប្រវត្តិសង្ខេបរបស់ប៉ែនសុវណ្ណ ទំព័រ 129-154; "ប៉ែនសុវណ្ណចេញដើម្បីដោះស្រាយពិន្ទុចាស់កាសែត "ភ្នំពេញប៉ុស្តិ៍ពីថ្ងៃទី 16 ដល់ថ្ងៃទី 29 ខែឧសភាឆ្នាំ 1997។ ហេងសំរិន, ព្រះអម្ចាស់ដ៏ឧត្តម, ទំព័រ 99-152; Pribbenow "ឧត្តមសេនីយ៍ទាំង 5 រូប" ទំព័រ 459-484 ។

222 វិទ្យុភ្នំពេញថ្ងៃទី 2 ខែមេសាឆ្នាំ 1980, ភ្នំពេញ SPK ថ្ងៃទី 26 ខែមិថុនាឆ្នាំ1984 និងថ្ងៃទី 13 ខែមករាឆ្នាំ1987។

223 ហ្គោតមែន, កម្ពុជាបន្ទាប់ពីខ្មែរក្រហមទំព័រ 68, 75 ។

នៃប្រព័ន្ធសន្តិសុខខេត្ត រួមទាំងកន្លែងឃុំឃាំង ជាកន្លែងដែលប្រជាជនដែលជាប់ចោទពីការប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងការកាន់កាប់របស់វៀតណាម ត្រូវបានគេចាប់ឃុំដោយគ្មានការចោទប្រកាន់ ឬគ្មានការជំនុំជម្រះ។ អ្នកខ្លះត្រូវបានគេចោទប្រកាន់ថា ជាប់ពាក់ព័ន្ធនឹងយុទ្ធនាការទ័ពព្រៃខ្មែរក្រហមប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា ឬក្រុមអ្នកតស៊ូមិនមែនកុម្មុយនីស្តប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា ខណៈដែលអ្នកជាប់ឃុំផ្សេងៗទៀត ត្រូវបានគេចោទប្រកាន់ពីបទប្រឆាំងនយោបាយដែលអហិង្សា។ អ្នកទោសនយោបាយរាប់រយនាក់ ត្រូវបានឃុំឃាំងនៅក្នុងពន្ធនាគារខេត្តតាកែវ។ មនុស្សជាច្រើន ត្រូវទទួលរងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ ដើម្បីឱ្យពួកគេ "សារភាព" ថាជា "ប៉ុល ពត" (ខ្មែរក្រហម)។[224] ការសម្រេចចិត្តអំពីរយៈពេលយូរប៉ុណ្ណាដែលអ្នកទោសនឹងត្រូវឃុំឃាំង ត្រូវបានធ្វើឡើងដោយគណៈកម្មាធិការខេត្តដែលដឹកនាំដោយលោក ប៉ុល សារឿន។[225] គណៈកម្មាធិការ ក៏ត្រួតត្រាលើពន្ធនាគារ ដែលប្រតិបត្តិការនៅថ្នាក់ស្រុកផងដែរ។[226]

ដោយថ្លែងប្រកាសថា ពេញចិត្តនឹងការបំពេញតួនាទីរបស់លោក ប៉ុល សារឿននៅក្នុងខេត្តតាកែវ លោក ហ៊ុនសែន បានធ្វើឱ្យអតីតសមមិត្តបក្សកុម្មុយនីស្តកម្ពុជាតំបន់បូព៌ាម្នាក់នេះ ក្លាយជាអនុរដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាមេអគ្គសេនាធិការនៃកងកម្លាំងប្រដាប់អាវុធរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា នៅខែសីហា ឆ្នាំ១៩៨៨ ដែលជាផ្នែកមួយនៃការលើកទឹកចិត្តអតីតសមាជិកខ្មែរក្រហមជាច្រើននាក់ឲ្យចូលទៅក្នុងតំណែងសំខាន់ៗរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា។[227] ការលើកស្ទួយត្រូវបានបន្តធ្វើដោយការតំឡើងសក្តិរបស់លោក ប៉ុល សារឿននៅខែមេសា ឆ្នាំ១៩៨៩ ទៅកាន់គណៈកម្មាធិការមជ្ឈិម និងការិយាល័យនយោបាយរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា។[228] បន្ទាប់ពីការប្តូរឈ្មោះពីគណបក្សប្រជាជនបដិវត្តន៍កម្ពុជា មកជាគណបក្សប្រជាជនកម្ពុជាក្នុងឆ្នាំ១៩៩១ លោក ប៉ុល សារឿនបានក្លាយជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្ស។[229]

---

[224] គណៈកម្មាធិការមេធាវីសិទ្ធិមនុស្សអន្តរជាតិ (LCIHR), កំណត់សម្គាល់ពីបទសម្ភាសន៍ជាមួយអតីតអ្នកទោសនៅគុកខេត្តតាកែវ, ព្រំដែនថៃ-កម្ពុជា ថ្ងៃទី 2 ខែមីនាឆ្នាំ1985 បានរៀបចំសម្រាប់ LCIHR, *Kampuchea: After the Worst កម្ពុជា៖ បន្ទាប់ពីអាក្រក់បំផុត* (ញូវយ៉កឆ្នាំ1985)។

[225] LCIHR, កំណត់សម្គាល់លើការឃុំខ្លួននយោបាយដែលមិនទាន់បានបញ្ជាក់ នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា, ខែវិច្ឆិកា ឆ្នាំ1984, បានរៀបចំសម្រាប់ LCIHR, *កម្ពុជា ៖ បន្ទាប់ពីអាក្រក់បំផុត* ។

[226] LCIHR, កំណត់សម្គាល់ដែលមានចំណងជើងថា "ចំនួនជនជាប់ឃុំ", ខែវិច្ឆិកា ឆ្នាំ1984, បានរៀបចំសម្រាប់ LCIHR, *កម្ពុជា៖ បន្ទាប់ពីអាក្រក់បំផុត*។

[227] វិទ្យុភ្នំពេញ ថ្ងៃទី 17 ខែមេសាឆ្នាំ 1993។ វិទ្យុភ្នំពេញ ថ្ងៃទី 20 ខែសីហាឆ្នាំ 1988។ សាព័តមាន SPK ថ្ងៃទី 23 ខែសីហាឆ្នាំ 1988។

[228] វិទ្យុ 228 ភ្នំពេញ នៅថ្ងៃទី 11 ខែមេសាឆ្នាំ 1989។

[229] វិទ្យុភ្នំពេញថ្ងៃទី 11 ខែមករាឆ្នាំ 1992។

ជាមេអគ្គសេនាធិការកំពូល លោក ប៉ុល សារឿន មានអំណាចបញ្ជាលើកងកម្លាំងប្រដាប់អាវុធនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាទាំងមូល។[230] ដោយឆ្លុះបញ្ចាំងនូវសារៈសំខាន់របស់ខ្លួននៅក្នុងវង្វង់ដ៏ខ្ពស់បំផុតនៃគណបក្សកាន់អំណាច គាត់ត្រូវបានគេចាត់ទុកថា ជាឥស្សរជនដ៏មានឥទ្ធិពលបំផុតនៅក្នុងកងកម្លាំងប្រដាប់អាវុធ។[231] ដូច្នេះ គាត់រីករាយនឹងអំណាចបញ្ជាលើកងកម្លាំងប្រដាប់អាវុធ ក្នុងការចាប់មនុស្សពាក់ព័ន្ធនឹងនយោបាយដាក់គុក ដែលជាការអនុវត្តន៍ដែលគាត់ធ្លាប់បានធ្វើនៅខេត្តតាកែវ ៖ ដោយការឃុំឃាំងតាមអំពើចិត្ត បំពានលើនីតិវិធីតុលាការ និងមានលក្ខណៈជាទារុណកម្ម ឬទណ្ឌកម្មឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក ដែលអនុវត្តនៅក្នុងមូលដ្ឋានយោធា នៅកម្រិតជាតិ ថ្នាក់តំបន់ ខេត្ត និងកងអង្គភាព។[232]

ការឃុំឃាំងនៅកន្លែងយោធាលើជនសង្ស័យខាងនយោបាយ ជាទូទៅស្ទើរតែគ្មានការចោទប្រកាន់ ឬការកាត់សេចក្តីទាល់តែសោះ ហើយអ្នកទោសជាច្រើន ត្រូវបានឃុំឃាំងដោយផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់មិនត្រឹមត្រូវ និងបំផ្លើស ឬជាការចោទក្លែងក្លាយលើសកម្មភាពប្រឆាំង។ បញ្ហាទាំងនេះ ជាញឹកញាប់កើតចេញពីកស្តុតាងដែលមិនគួរឱ្យទុកចិត្ត ដែលកើតចេញពីការធ្វើទារុណកម្ម លក្ខខណ្ឌហិង្សានៃការជាប់ឃុំឃាំង និងទម្រង់នៃការបង្ខិតបង្ខំដទៃទៀត ដែលត្រូវបានគេធ្វើទៅលើជនសង្ស័យនយោបាយ និងជនសង្ស័យដទៃទៀតជាធម្មតា។[233] ការធ្វើទារុណកម្មនៅក្នុងមន្ទីរឃុំឃាំងយោធាប្រព្រឹត្តទៅដោយងាយស្រួល ក៏ដោយសារអ្នកទោសត្រូវបានគេផ្តាច់ទំនាក់ទំនងពីពិភពលោកខាងក្រៅ សូម្បីតែពីអ្នកទោសគ្នាឯងក៏មិនឱ្យមានទំនាក់ទំនងនឹងគ្នាដែរ នៅក្នុងអំឡុងពេលកំពុងសួរចម្លើយ ។ ជារឿយៗ អ្នកទោសត្រូវគេដាក់ឃុំក្នុង "គុកងងឹត" សម្រាប់រយៈពេលយូរ។[234]

---

[230] សាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) អនុក្រឹត្យលេខ 25 អនក្រ ចុះថ្ងៃទី 20 ខែវិច្ឆិកាឆ្នាំ 1985។

[231] អ៊ិនតាក់ "របាយការណ៍ស្តីពីការប្រជុំជាមួយធូ ថុន "ថ្ងៃទី 21 ខែមិថុនាឆ្នាំ 1992។

[232] អង្គការលើកលែងទោសអន្តរជាតិ, កំណត់មានចំណងជើងថា "ពន្ធនាគារនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា(PRK)" ថ្ងៃទី 4 ខែសីហាឆ្នាំ1986, រៀបចំសម្រាប់អង្គការលើកលែងទោសអន្តរជាតិ, ការដាក់ពន្ធនាគារនយោបាយ។

[233] អង្គការលើកលែងទោសអន្តរជាតិ, កំណត់សម្គាល់ដែលមានចំណងជើងថា "គំរូមួយនៃការចាប់ខ្លួននិងការដាក់គុកនយោបាយ ថ្ងៃទី "25 ខែសីហាឆ្នាំ 1986, រៀបចំសម្រាប់អង្គការលើកលែងទោសអន្តរជាតិ, ការផ្តន្ទាទោសនយោបាយ។

[234] អង្គការលើកលែងទោសអន្តរជាតិ កំណត់សម្គាល់ដែលមានចំណងជើងថា "ពន្ធនាគារនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) "ថ្ងៃទី 4 ខែសីហាឆ្នាំ 1986 រៀបចំសម្រាប់អង្គការលើកលែងទោសអន្តរជាតិ, ការដាក់ពន្ធនាគារនយោបាយ។

ក្នុងចំណោមការកិច្ចជាច្រើនរបស់លោក ប៉ុល សារឿន ដែលជាអគ្គមេបញ្ជាការជាន់ខ្ពស់ គឺការទទួលខុសត្រូវចំពោះ "ស្នងការស្រាវជ្រាវ" ឬ អង្គភាពស៊ើបការណ៍សម្ងាត់ ដែលជាផ្នែកសំខាន់មួយ ដែលត្រូវបានគេហៅតាមកូដគុយ១០១ (Q101)។ គុយ១០១ (Q101) ចាត់ចែងបណ្តាញភ្នាក់ងារ ក្លែងខ្លួនជាមនុស្សសាមញ្ញដោយកំណត់ក្រុមសត្រូវដែលគេបានសង្ស័យ ដែលប្រតិបត្តិការរបស់មន្ត្រីស៊ើបការណ៍យោធា ត្រូវបានគេផ្តល់អំណាចឲ្យឃុំខ្លួន និងសួរចម្លើយ។[235] គុយ១០១ មានអំណាចបញ្ជាចាប់ខ្លួននៅពាសពេញប្រទេស រួមទាំងសកម្មភាពទាំងឡាយដែលគេសង្ស័យថា ជាសកម្មភាពសត្រូវនៅក្នុងជួរកងកម្លាំងប្រដាប់អាវុធ និងក្រសួងការពារជាតិ ក៏ដូចជាមនុស្សផ្សេងទៀតដែលសកម្មភាពរបស់ពួកគេ បានប៉ះពាល់ដល់យោធា។ ដូចអ្នកជាប់ឃុំឃាំងនយោបាយដទៃទៀតដែរ អ្នកដែលស្ថិតក្នុងការឃុំឃាំងរបស់ គុយ១០១ ត្រូវបានគេឃុំដោយគ្មានការចោទប្រកាន់ ឬការកាត់ក្តីឡើយ ហើយជារឿយៗ ត្រូវរងការធ្វើទារុណកម្ម។[236]

## ប៉ុល សារឿន និងអ៊ុនតាក់ឆ្នាំ១៩៩១-១៩៩៣

លោក ប៉ុល សារឿន នៅតែស្ថិតក្នុងតំណែងអំណាចយោធា តាមរយៈការបោះឆ្នោតដែលរៀបចំដោយអង្គការសហប្រជាជាតិ ហៅកាត់ថា អ៊ុនតាក់ នៅខែឧសភា ឆ្នាំ១៩៩៣។ លោកក៏មានឥទ្ធិពលយ៉ាងខ្លាំងទៅលើខេត្តតាកែវផងដែរ។ នៅទីនោះ ក៏ដូចជានៅកន្លែងដទៃទៀតក្នុងប្រទេសកម្ពុជាដែរ គណបក្សប្រជាជនកម្ពុជា បានបង្ក្រាបកិច្ចខិតខំប្រឹងប្រែងរបស់អ៊ុនតាក់ ដែលបានខិតខំបង្កើតបរិយាកាសនយោបាយអព្យាក្រឹត្យសម្រាប់ការបោះឆ្នោត។[237] លោក ប៉ុល សារឿន ជាបេក្ខជនឈរឈ្មោះបោះឆ្នោតលេខ១ នៅខេត្តតាកែវ និងបានជួយគ្រប់គ្រងសកម្មភាពយុទ្ធនាការ របស់គណបក្សប្រជាជនកម្ពុជានៅទីនោះ ដោយប្រតិបត្តិការតាមកងយោធា ប៉ូលីស និងរដ្ឋបាលស៊ីវិល ដែលត្រួតត្រាដោយគណបក្សប្រជាជនកម្ពុជា ដើម្បីអនុវត្តន៍នូវ "ការពង្រឹងមូលដ្ឋាន" របស់គណបក្សប្រជាជនកម្ពុជា។[238] ដល់ទីបញ្ចប់ ការត្រួតត្រារបស់គណបក្សប្រជាជន

---

[235] សាធារណរដ្ឋប្រជាមានិតកម្ពុជា(PRK) អនុក្រឹត្យលេខ 25 អនក្រ ចុះថ្ងៃទី 20 ខែវិច្ឆិកាឆ្នាំ 1985។ អ៊ុនតាក់ សមាសភាគយោធា រចនាសម្ព័ន្ធកម្លាំង" ៖ កងកម្លាំងប្រដាប់អាវុធរដ្ឋកម្ពុជា (SOC)" ថ្ងៃទី 16 ខែកញ្ញាឆ្នាំ 1992, ទំព័រ 5-7។

[236] អង្គការលើកលែងទោសអន្តរជាតិ ("ការធ្វើបច្ចុប្បន្នភាពលើអ្នកទោសនយោបាយ" AI/23/001/1991) ខែមីនា ឆ្នាំ1991; អង្គការលើកលែងទោសអន្តរជាតិ, កំណត់ហេតុដែលមានចំណងជើងថា "ការចងក្រងទិន្នន័យស្តីពីពន្ធនាគារ/ជំរំ បុគ្គលិក និងអង្គភាព ឬអង្គការចាត់តាំងដែលមានអំណាចអនុវត្តការចាប់ចង និងការសួរចម្លើយ" ខែមិថុនា ឆ្នាំ1986, រៀបចំសម្រាប់អង្គការលើកលែងទោសអន្តរជាតិ, កាតដាក់ទោសនយោបាយ, អង្គការលើកលែងទោសអន្តរជាតិ, កំណត់សម្គាល់មានចំណងជើងថា "អាជ្ញាធរទូទាំងប្រទេស អនុវត្តការចាប់ខ្លួនខាងនយោបាយក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជា" ថ្ងៃទី 28 ខែសីហាឆ្នាំ1986, រៀបចំសម្រាប់អង្គការលើកលែងទោសអន្តរជាតិ, ការដាក់ពន្ធនាគារផ្នែកនយោបាយ។

[237] អ៊ុនតាក់ "របាយការណ៍ស្តីពីការសម្ភាសន៍"

[238] គណបក្សប្រជាជន "បញ្ជៅបេក្ខជន" ៖ តាកែវ] "n.d.]។ អ៊ុនតាក់ (UNTAC) "របាយការណ៍ស្តីពីការសម្ភាសន៍" អ៊ុនតាក់ "អនុសាសន៍សម្រាប់

កម្ពុជាទៅលើយោធាខេត្ត ត្រូវបានរឹតបន្តឹង ការឃោសនារបស់មន្ត្រី និងមនុស្សរបស់គណបក្សប្រជាជនកម្ពុជា បានកើនកាន់តែខ្លាំងឡើងៗ ហើយអង្គភាពខេត្ត និងកងកម្លាំងប្រដាប់អាវុធដទៃទៀត បានចុះទៅតាមភូមិ និងដឹកនាំសាងសង់អាគារគណបក្ស សកម្មភាពយុទ្ធនាការបោះឆ្នោត និងអនុវត្តការឃ្លាំមើលសមាជិកនៃប្រជាពលរដ្ឋ ដែលពួកគេសង្ស័យថា បានគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសេរីនិយមព្រះពុទ្ធសាសនា និងក្រុមប្រឆាំងដទៃទៀត។[239]

កិច្ចប្រតិបត្តិការដោយផ្អែកលើកងកម្លាំងចម្រុះនៃប្រតិបត្តិការរួមគ្នាដោយកងកម្លាំងសន្តិសុខទាំងអស់ នគរបាលខេត្តតាកែវ បានចូលរួមសកម្មភាពជាច្រើន ដើម្បីទប់ស្កាត់ និងបង្ក្រាបសកម្មភាពគណបក្សប្រឆាំងស្របច្បាប់ដោយ រួមទាំងប្រតិបត្តិការសម្ងាត់ដោយអង្គភាពដែលគេហៅថា ក្រុមអា "A teams"។ ទិដ្ឋភាពមួយទៀតរបស់គណបក្សប្រជាជនកម្ពុជា គឺ "ការពង្រឹងមូលដ្ឋាន" នៅខេត្តតាកែវគឺការប្រើប្រាស់ "កម្លាំងប្រតិកម្ម" ប្រឆាំងនឹងគណបក្សប្រឆាំង។ ទាំងនេះរួមមានកងជំនួយជាជនស៊ីវិល ដែលបានធ្វើសកម្មភាពប្រឆាំងនឹងក្រុមប្រឆាំង តាមការញុះញង់របស់ប៉ូលីស ប៉ុន្តែពួកគេមិនបង្ហាញថា មានទំនាក់ទំនងជាមួយនឹងប៉ូលីសទេ។[240]

ក្រោមការឃ្លាំមើលរបស់លោក ប៉ុល សារឿន យុទ្ធនាការឃោសនាបោះឆ្នោតឆ្នាំ១៩៩៣ នៅខេត្តតាកែវ មានលក្ខណៈពិសេសដោយការធ្វើឃាតសមាជិក និងអ្នកគាំទ្ររបស់គណបក្សហ៊្វុនស៊ិនប៉ិច និងសមាជិក និងអ្នកគាំទ្ររបស់គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា រួមទាំងការវាយប្រហារគ្រាប់បែក និងការចាប់ខ្លួនតាមអំពើចិត្តនៃសកម្មជនប្រឆាំង។[241]

## ប៉ុល សារឿន និងក្មួយៗក្រោយពេលអ៊ុនតាក់ ឆ្នាំ១៩៩៣-១៩៩៦

---

បេសកកម្មត្រួតពិនិត្យ" ថ្ងៃទី 25 មេសា 1993។

[239] អ៊ុនតាក់ "ការរកឃើញរបស់ក្រុមត្រួតពិនិត្យ៖ បញ្ហាយោធា "ថ្ងៃទី14 ខែមេសាឆ្នាំ 1993។ ការរកឃើញរបស់ក្រុមត្រួតពិនិត្យ

[240] អ៊ុនតាក់ ឯកសារ"ខេត្តតាកែវ"ថ្ងៃទី 15 ខែមិនា ឆ្នាំ1993 ទំព័រទី 1-2។ សូមមើលផងដែរក្រុមការងារគ្រប់គ្រងអ៊ុនតាអនុសាសន៍សម្រាប់ "បេសកកម្មត្រួតពិនិត្យថ្ងៃទី25 ខែមីនា ឆ្នាំ1993 និងក្រុមការងារគ្រប់គ្រងអ៊ុនតាក់ "កិច្ចប្រជុំផែនការត្រួតពិនិត្យក្រុម2 - អំពិល" [n.d]។

[241] សមាសភាពបោះឆ្នោតអ៊ុនតាក់ របាយការណ៍"CC&E/ខេត្តតាកែវ "ថ្ងៃទី5 ខែមករា ឆ្នាំ1993 ។ សមាសភាពបោះឆ្នោតអ៊ុនតាក់ របាយការណ៍" CC&E/ខេត្តតាកែវ "ថ្ងៃទី15 ខែកុម្ភៈ ឆ្នាំ1993។ ផ្នែកព័ត៌មាន/អប់រំរបស់អ៊ុនតាក់ "សារតាខេត្តតាកែវ] "n.d. ] អ៊ុនតាក់ "ក្រុមត្រួតពិនិត្យ"ខែមិនាឆ្នាំ1993។ អ៊ុនតាក់ "ឧប្បត្តិហេតុ និងបញ្ហាពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត "ថ្ងៃទី27 ខែតុលា ឆ្នាំ1993។

*បន្ទាប់ពីការបោះឆ្នោតរៀបចំដោយអ៊ុនតាក់ និងការបង្កើតរដ្ឋាភិបាលចម្រុះ លោក ប៉ុល សារឿន ត្រូវបានបញ្ចុះស័ក្តទៅជាមេបញ្ជាការរងនៃអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទថ្មី (RCAF) ដើម្បីទុកកន្លែងឱ្យអ្នកតែងតាំងថ្មីៗពីគណបក្សគណបក្សហ៊្វុនស៊ីនប៉ិច ។*[242]

*ក្នុងអំឡុងពេលរដ្ឋប្រហារបរាជ័យ របស់មេដឹកនាំគណបក្សប្រជាជនកម្ពុជាប្រឆាំងនឹងលោក ហ៊ុន សែន និងសម្តេចក្រុមព្រះ នរោត្តមរណៈ ឫទ្ធិ នៅខែកក្កដា ឆ្នាំ១៩៩៤ អគ្គសេនាធិការដែលសមាសភាពភាគច្រើនស្មោះត្រង់នឹងសហនាយករដ្ឋមន្ត្រី ហើយលោក ប៉ុល សារឿន គឺជាមន្ត្រីពីគណបក្សប្រជាជនកម្ពុជាដែលគាំទ្រសហនាយករដ្ឋមន្ត្រីទាំងពីរខ្លាំងបំផុត។*[243] *ប្រការនេះ បានធ្វើឱ្យឥទ្ធិពលនយោបាយរបស់លោក ប៉ុល សារឿន កើនឡើងជាថ្មី ដែលបានផ្តល់ឱ្យគាត់នូវអំណាចគ្រប់គ្រងកាន់តែច្រើនឡើងៗ ទៅលើអង្គភាពកងយោធពលខេមរភូមិន្ទ ដែលនិយមគណបក្សប្រជាជនកម្ពុជា និងកម្លាំងគុយ១០១ (Q101)។*[244]

*ក្នុងអំឡុងពេលនេះ កងយោធពលខេមរភូមិន្ទមានជាប់ពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិមនុស្សជាច្រើន ដែលជារឿយៗពាក់ព័ន្ធនឹងប្រតិបត្តិការយោធាដែលបន្តធ្វើប្រឆាំងនឹងពួកបះបោរខ្មែរក្រហមដែលនៅសេសសល់ ឬពាក់ព័ន្ធនឹងអំពើប្រព្រឹត្តរបស់មន្ត្រី និងយុទ្ធជនរបស់កងយោធពលខេមរភូមិន្ទ ក្នុងការរឹបអូសទ្រព្យសម្បត្តិ របស់អ្នកដទៃ និងការបណ្តេញចេញដោយបង្ខំចំពោះប្រជាជនដែលទាមទារសិទ្ធិកាន់កាប់ដីធ្លី និងតាមរយៈការលក់ដីទៅឱ្យអ្នកវិនិយោគបរទេស ជាដើម។ ទាហាននៃកងយោធពលខេមរភូមិន្ទ ក៏បានចូលរួមក្នុងការកាប់សម្លាប់ និងការរំលោភសេពសន្ថវៈ។ មន្ត្រីស៊ើបការណ៍យោធា ជាពិសេស បានបង្កើតមណ្ឌលឃុំឃាំងសម្ងាត់ ដែលមានការធ្វើទារុណកម្ម និងសម្លាប់មនុស្ស ទៀតផង។*[245]

*អំពើរំលោភបំពានដ៏អាក្រក់បំផុតខ្លះ ត្រូវបានប្រព្រឹត្តដោយអង្គភាពអន្តរាគមន៍របស់កងយោធពលខេមរភូមិន្ទ ដែលឆ្លើយឆ្លងដោយផ្ទាល់ទៅកាន់អគ្គសេនាធិការកំពូល។ ដូចនៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាដែរ ជាញឹកញាប់មនុស្សត្រូវបានឃុំខ្លួនដោយខុសច្បាប់ ដោយគ្មានការចោទប្រកាន់ ឬការកាត់ក្តី*

---

[242] PGC, ក្រេត, 5 កក្កដា 1993; KOC "បញ្ជីមន្ត្រីជាន់ខ្ពស់។"

[243] កោះសន្តិភាពថ្ងៃទី 28 ខែកញ្ញាឆ្នាំ 1994។

[244] បទសម្ភាសន៍ជាមួយញឹក ប៊ុនឆៃ, ភ្នំពេញថ្ងៃទី 14 ខែវិច្ឆិកា ឆ្នាំ1995។

[245] អង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែនរ៉ាយវ៉ច្ឆ, ប្រទេសកម្ពុជានៅសង្គ្រាម (ញូវយ៉ក1995), ទំព័រ 77-78; អង្គការលើកលែងទោសអន្តរជាតិ ព្រះរាជា" ណាចក្រកម្ពុជា ៖ ការថយចុះការគោរពសិទ្ធិមនុស្ស) "ASA 23/02/96) ខែឧសភាឆ្នាំ 1996 ទំព័រ 33 ។

ដោយលាបពណ៌តាមតែអំពើចិត្តទៅលើជនរងគ្រោះថា ជា "ខ្មែរក្រហម"។ អ្នកជាប់ឃុំខ្លះ ត្រូវបានគេសម្លាប់ភ្លាមៗនៅទីវាល។[246]

ក្នុងចំណោមកងយោធពលខេមរភូមិន្ទ ដែលរំលោភបំពានខ្លាំងបំផុត គឺកងសឹករងលេខស៩១ (S91) របស់គុយ១០១ ក្នុងខេត្តបាត់ដំបង ដែលមានទីតាំងស្ថិតនៅក្នុងយោធភូមិភាគ ៥ ។ អង្គភាពស៩១ មានសមាសភាពមកពីទីបញ្ជាការគុយ១០១ នៅរាជធានីភ្នំពេញ និងពីអគ្គសេនាធិការយោភូមិភាគ ៥ ដែលសុទ្ធតែជាមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជា ។[247] តាមរយៈបណ្តាញទាំងពីរនេះ ពួកគេរាយការណ៍ទៅអគ្គសេនាធិការកំពូល និងជាពិសេស ទៅលោក ប៉ុល សារឿន។[248]

បន្ទាប់ពីការបោះឆ្នោតខែឧសភា ឆ្នាំ១៩៩៣ អង្គភាពស៩១ បានផ្តោតលើការចាប់ពង្រត់ ទារុណកម្ម និងការសម្លាប់ក្រៅប្រព័ន្ធតុលាការ បទឧក្រិដ្ឋទូទៅ ការចាប់ពង្រត់អ្នកជំនួញ ដើម្បីឱ្យបង់ប្រាក់លោះ និងការធ្វើឃាតអ្នកគាំទ្រខ្មែរក្រហម។ ការសម្លាប់បានបន្តរហូតដល់យ៉ាងហោចណាស់ខែមករា ឆ្នាំ១៩៩៤ ខណៈដែលការឃុំឃាំងខុសច្បាប់ និងការជំរិតយកប្រាក់បានបន្តមានរហូតដល់ពាក់កណ្តាលឆ្នាំនោះ។ ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាល បានរាយការណ៍លទ្ធផលនៃការស៊ើបអង្កេតរបស់ពួកគេទៅកាន់រដ្ឋាភិបាល។ រដ្ឋាភិបាលបានណែនាំដល់អគ្គសេនាធិការកំពូល ឱ្យនាំជនល្មើសដែលត្រូវបានចោទប្រកាន់ទៅរកយុត្តិធម៌ ប៉ុន្តែមិនមានសកម្មភាពនោះកើតឡើងឡើយ។[249] ក្រោមការគាបសង្កត់ជាសាធារណៈ រដ្ឋាភិបាលពេលនោះ បានបង្កើតគណៈកម្មាការស៊ើបអង្កេតពិសេសមួយ ប៉ុន្តែ

---

[246] អង្គការលើកលែងទោសអន្តរជាតិ, "ការវាយប្រហារដោយទាហានលើអ្នកភូមិបន្ទាយ ឃុំក្រគរ ស្រុកក្រចេះ ខេត្តក្រចេះ" (AI Index ASA 23/04/94) ថ្ងៃទី 21 ខែមេសា ឆ្នាំ1994។ អង្គការលើកលែងទោសអន្តរជាតិ "អ្នកភូមិបីនាក់ (មិនស្គាល់ឈ្មោះ) ពីភូមិសីលា បឹងកំពឹងពួយ ខេត្តបាត់ដំបង) "AI Index ASA 23/05/94) ថ្ងៃទី 16 ខែឧសភា ឆ្នាំ1994។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែនរ៉ៃត៍វ៉ច្ឆ, ប្រទេសកម្ពុជានៅសង្គ្រាម (ញូវយ៉ក1995), ទំព័រ 58-64; អង្គការលើកលែងទោសអន្តរជាតិ ព្រះរាជាណាចក្រកម្ពុជា" ៖ ការថយចុះការគោរពសិទ្ធិមនុស្ស"(ASA 23/02/96) ខែឧសភា ឆ្នាំ1996 ទំព័រ 38 ។ អង្គការលើកលែងទោសអន្តរជាតិ ព្រះរាជាណាចក្រកម្ពុជា" ៖ នៅតែរង់ចាំយុត្តិធម៌ ៖ កុមារនៅក្រាំងកន្តួង) "ASA 23/005/2002) ខែកញ្ញា ឆ្នាំ 2002។

[247] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ប្រទេសកម្ពុជានៅសង្គ្រាម ញូវយ៉ក ៖ 1995, ទំព័រ 67-69។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, បទសម្ភាសន៍ជាមួយញឹកប៊ុនឆៃ, ថ្ងៃទី13 ខែមករា ឆ្នាំ2004 ។

[248] បទសម្ភាសន៍ជាមួយញឹក ប៊ុនឆៃ ភ្នំពេញថ្ងៃទី 14 ខែវិច្ឆិកាឆ្នាំ 1995។

[249] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ប្រទេសកម្ពុជានៅសង្គ្រាម ញូវយ៉ក) ៖ 1995), ទំព័រ 77-78។ អង្គការលើកលែងទោសអន្តរជាតិ ព្រះរាជាណាចក្រកម្ពុ" ជា ៖ ការថយចុះការគោរពសិទ្ធិមនុស្ស) "ASA 23/02/96) ខែឧសភា ឆ្នាំ1996 ទំព័រ 33 ។

ទោះបីជាគណៈកម្មាការបានរកឃើញតាមការចោទប្រកាន់ទាំងនោះក៏ដោយ ជាការពិត ក៏គ្មាននរណាម្នាក់ត្រូវបាននាំខ្លួនមកកាត់ទោស ចំពោះឧក្រិដ្ឋកម្មរបស់អង្គភាពស៩១ដែរ។[250]

ក្នុងឆ្នាំ១៩៩៦ លោក ប៉ុល សារឿន គឺជាមន្ត្រីយោធាជាន់ខ្ពស់បំផុតរបស់គណបក្សប្រជាជនកម្ពុជា ដែលគាំទ្រសំណើរបស់លោក ហ៊ុន សែន ក្នុងការចាត់វិធានការប្រដាប់អាវុធប្រឆាំងនឹងហ៊្វុនស៊ិនប៉ិច ជាពិសេសដើម្បី "រំលាយ" ក្បាលម៉ាស៊ីនយោធារបស់គណបក្សនេះ។[251] លោក ប៉ុល សារឿន ក៏បានដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តការសម្រេចចិត្តរបស់លោក ហ៊ុន សែន ក្នុងការពង្រឹងតំណែងយោធារបស់គណបក្សប្រជាជនកម្ពុជា ដើម្បីទប់ទល់នឹងហ៊្វុនស៊ិនប៉ិច ដោយការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការបញ្ចុះបញ្ចូលអូសទាញមេបញ្ជាការយោធាខ្មែរក្រហម តាមរយៈការចរចារដោយសម្ងាត់ ដែលជំរុញឱ្យពួកគេផ្តាច់ចេញពីការដឹកនាំរបស់ប៉ុល ពត និងចូលរួមជាមួយកងយោធពលខេមរភូមិន្ទ ជាសមាជិកគណបក្សប្រជាជនកម្ពុជា។[252]

ក្នុងចំណោមមេបញ្ជាការខ្មែរក្រហមទីមួយ ដែលលោក ប៉ុល សារឿនបានបញ្ចុះបញ្ចូលឱ្យចុះចូល គឺលោក កែវ ពង់ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៩៦ ហើយត្រូវបានតែងតាំងជាមេបញ្ជាការរងនៃយោធភូមិភាគ ៣ ។[253] លោក ប៉ុល សារឿន ក៏បានដឹកនាំក្រុមយោធាគណបក្សប្រជាជនកម្ពុជា ដែលក្រោយមកបានផ្តួចផ្តើមឱ្យមានការពិភាក្សាជាមួយមេបញ្ជាការខ្មែរក្រហម ដែលមានទំនាក់ទំនងជាមួយអតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃរបបខ្មែរក្រហម គឺលោក អៀង សារី និងបានបង្កើតព្រឹត្តិការណ៍ឲ្យមានការចុះចូលរបស់ពួកគេ ហើយបន្ទាប់មក មានលោក អៀង សារី ខ្លួនឯង ក៏បានចុះចូល នៅក្នុងខែសីហា ឆ្នាំ១៩៩៦។[254]

---

[250] រាជរដ្ឋាភិបាលកម្ពុជា )RGC) សេចក្តីសម្រេចលេខ 74 សសរ ចុះថ្ងៃទី 11 ខែកក្កដាឆ្នាំ 1994។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស, ប្រទេសកម្ពុជានៅសង្គ្រាម ញូវយ៉ក ៖ 1995), ទំព័រ 77-78។ អង្គការលើកលែងទោសអន្តរជាតិ ព្រះរាជាណាចក្រកម្ពុជា" ៖ ការថយចុះការគោរពសិទ្ធិមនុស្ស) "ASA 23/02/96) ខែឧសភា ឆ្នាំ1996 ទំព័រ 33 ។

[251] UNOSGRC "របាយការណ៍ប្រចាំខែ សម្រាប់ខែឧសភាឆ្នាំ 1996" ។

[252] UNOSGRC "របាយការណ៍ប្រចាំសប្តាហ៍ទី 92 ដែលគ្របដណ្តប់លើរយៈពេលចាប់ពីថ្ងៃទី 20 ដល់ 26 ឧសភា 1996" ។ UNOSGRG, "របាយការណ៍ប្រចាំខែ សម្រាប់ខែវិច្ឆិកា ឆ្នាំ1996" សម្ភាសន៍ជាមួយលោកប៉ុលសារឿនថ្ងៃទី 28 ខែមិថុនា ឆ្នាំ1997។

[253] វិទ្យុភ្នំពេញ ថ្ងៃទី 15 ខែសីហាឆ្នាំ 1996។ UNOSGRC "របាយការណ៍ប្រចាំខែសម្រាប់ខែតុលាឆ្នាំ 1996" "អ្នកចុះចូលខ្មែរក្រហម សុំតំណែងក្នុងរដ្ឋាភិបាល" រស្មីកម្ពុជាថ្ងៃទី 22 ខែសីហា ឆ្នាំ1996។

[254] UNOSGRC "របាយការណ៍ប្រចាំសប្តាហ៍ទី103 គ្របដណ្តប់រយៈពេលពីថ្ងៃទី 2 ដល់ថ្ងៃទី 8 ខែកញ្ញាឆ្នាំ1996" វិទ្យុភ្នំពេញថ្ងៃទី 8 ខែសីហាឆ្នាំ 1996 ។ "ខ្មែរក្រហមចុះចូលជាន់ខ្ពស់ តាមការរាយការណ៍មកថា ស្ថិតនៅទីក្រុងបាងកក "AFP ភ្នំពេញថ្ងៃទី 8 ខែសីហាឆ្នាំ1996។ UNOSGRC, JW "ករណីចុះចូល ៖ និយាយជាមួយវរៈសេនីយ៍វង្សគីមហានថ្ងៃទី "14 ខែសីហាឆ្នាំ1996។ UNOSGRC "របាយការណ៍ប្រចាំសប្តាហ៍ទី 103 គ្របដណ្តប់រយៈពេលចាប់ពីថ្ងៃទី 2 ដល់ថ្ងៃទី 8 ខែកញ្ញា ឆ្នាំ1996" ។ ការិយាល័យនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (COUNCHR) បានធ្វើបទសម្ភាសន៍នៅភូមិដូង ឃុំភ្នំម៉ាឡៃ ខេត្តបន្ទាយមានជ័យ ថ្ងៃទី 27 ខែកញ្ញា

## *នៅសម័យរដ្ឋប្រហារខែកក្កដា ឆ្នាំ១៩៩៧ របស់លោក ហ៊ុន សែន*

*នៅខែមិថុនា ឆ្នាំ១៩៩៧ លោក ប៉ុល សា រឿន បានពង្រឹងកិច្ចប្រឹងប្រែងជំនួសលោក ហ៊ុន សែន ដើម្បីនាំយកកងទ័ព និងមេដឹកនាំខ្មែរក្រហមទាំងអស់ មកកាន់គណបក្សប្រជាជនកម្ពុជា លើកលែងតែមន្ត្រីជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជាបីរូបរបស់ខ្មែរក្រហម គឺ ប៉ុល ពត នួន ជា និងតា ម៉ុក។ លោក ប៉ុល សា រឿន ពន្យល់ថា ការបញ្ចុះបញ្ចូលពួកខ្មែរក្រហមទាំងនោះ ឱ្យចូលជាសមាជិកគណបក្សប្រជាជនកម្ពុជា គឺវិធីទាញយកកម្លាំងឱ្យមកគាំទ្រ ដូចគ្នានឹងរូបលោក និងអតីតខ្មែរក្រហមដទៃទៀត ដែលមានមុខតំណែងក្នុងគណបក្សប្រជាជនកម្ពុជាដែរ។ លោកក៏បានប្រកាសផងដែរថា ដើម្បីទប់ស្កាត់បញ្ហាប្រឈមដែលកើតចេញពីការប៉ុនប៉ងរបស់គណបក្សហ៊្វុនស៊ីនប៉ិច ក្នុងការប្រកួតប្រជែងជាមួយគណបក្សប្រជាជនកម្ពុជា សម្រាប់ការរៀបចំការបោះឆ្នោតរដ្ឋសភា ដែលគ្រោងធ្វើនៅខែកក្កដា ឆ្នាំ១៩៩៨ នោះ "វាត្រូវតែមានសង្គ្រាមតូចមួយមុនការបោះឆ្នោត" ដែលនេះជាការបង្ហាញថា គណបក្សប្រជាជនកម្ពុជា មានផែនការចាប់ខ្លួននាយករដ្ឋមន្ត្រីទី១ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ដែលភ្លាមៗក្រោយមក ព្រះអង្គក៏បានប្រញាប់ប្រញ៉ាល់គៀសខ្លួនចេញពីប្រទេសកម្ពុជា។*

*លោក ប៉ុល សារឿន គឺជាមន្ត្រីយោធាជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជា ដែលប្រកៀកស្មាជា មួយលោក ហ៊ុន សែន ក្នុងការធ្វើរដ្ឋប្រហារប្រឆាំងនឹងគណបក្សហ្វ៊ុនស៊ិនប៉ិចកាលពីថ្ងៃទី៥-៦ ខែ កក្កដា ឆ្នាំ១៩៩៧។ ជានយោបាយ រដ្ឋប្រហារនេះបានតម្រង់គោលដៅទៅរកព្រះអង្គម្ចាស់ នរោត្តមរណឫទ្ធិ ប៉ុន្តែជាគោលដៅយោធា គឺតម្រង់ទៅអគ្គមេបញ្ជាការរងទី១ ឧត្តមសេនីយ៍ញឹក ប៊ុនឆៃ ដែលបញ្ជាកងកម្លាំងហ្វ៊ុនស៊ីនប៉ិច និងជាមេបញ្ជាការដែលមានតែឈ្មោះរបស់លោក ប៉ុល សារឿន នៅក្នុងអគ្គសេនាធិការកំពូល។*

---

ឆ្នាំ 1996 ។ UNOSGRC, "របាយការណ៍ប្រចាំខែសម្រាប់ខែវិច្ឆិកាឆ្នាំ 1996" COHCHR, "និយាយជាមួយអ៊ុំវ៉ាន់ ថ្ងៃទី "26 ខែមករាឆ្នាំ 1997។ COHCHR, "អ៊ុំវ៉ាន់, ភូមិដូង, ម៉ាឡៃ ថ្ងៃទី "26 ខែមករាឆ្នាំ 1997។ COHCHR "អ៊ីឈៀន) អតីតមេបញ្ជាការកងពលធំលេខ 415 នៃកម្ពុជាប្រជាធិបតេយ្យ, អភិបាលក្រុងប៉ៃលិន, ថ្ងៃទី 27 ខែមករាឆ្នាំ 1997។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (COHCHR) "លោក ព្រំ ស៊ូ អភិបាលរងខេត្តបន្ទាយមានជ័យ អតីតមេបញ្ជាការកងពលតូច 519 រាជធានីភ្នំពេញ ថ្ងៃទី "22 ខែមករាឆ្នាំ 1997; វិទ្យុភ្នំពេញថ្ងៃទី 16 ខែសីហាឆ្នាំ 1996; COHCHR "Phon Phaen (អតីតមេបញ្ជាការកងពលធំ 705 នៃកម្ពុជាប្រជាធិបតេយ្យ, បច្ចុប្បន្នអភិបាលស្រុកសំពៅលូនខាងលិច 250" ថ្ងៃទី 25 ខែមករាឆ្នាំ1997។

លោក ប៉ុល សារឿន បាននៅជាមួយលោក ហ៊ុន សែន និងមេបញ្ជាការកលយុទ្ធរដ្ឋប្រហារ គន់ គីម នៅពេលដែលលោក ហ៊ុន សែន ប្រកាសថា សមាជិកនៃក្បាលម៉ាស៊ីនហ៊្វុនស៊ីនប៉ិចដែលលោកចង់ "កម្ទេចឱ្យសាបសូន្យ" តាំងពីឆ្នាំ១៩៩៦ មកនោះ ត្រូវតែ "បោសសំអាតចេញឱ្យអស់" ដែលពាក្យទាំងនេះត្រូវបានខ្មែរក្រហមប្រើជំនួសឱ្យពាក្យថា 'សម្លាប់' ។[255]

ខណៈលោក គន់ គីម សម្របសម្រួលកម្លាំងធ្វើរដ្ឋប្រហារ លោក ប៉ុល សារឿនក៏បានចេញបញ្ជា ជាពិសេសដល់លោក កែវ ពង្ស ដែលជាខ្មែរក្រហមទើបចុះចូលថ្មីៗ ឲ្យធ្វើការវាយប្រហារជាបន្តបន្ទាប់ ដោយប្រើអង្គភាពកងកម្លាំងពិសេស ដែលភាគច្រើនជាកម្លាំងចុះចូល។ កងកម្លាំងរបស់លោក បានបើកការវាយប្រហារបោសសម្អាតចេញពីកំពង់ស្ពឺភាគខាងលិចរាជធានីភ្នំពេញ ឆ្លងកាត់ទីក្រុងទៅទិសខាងកើត។ កងទ័ពរបស់លោក កែវ ពង្ស បានវាយប្រហារតំបន់មូលដ្ឋានសំខាន់ៗរបស់លោក ញឹក ប៊ុនឆៃ នៅភាគខាងលិចរាជធានី និងបន្ទាប់មកវាយប្រហារលើលំនៅឋានរបស់លោក ញឹក ប៊ុនឆៃនៅក្នុងទីក្រុង មុនពេលបង្ខំឱ្យគាត់ និងមន្ត្រីហ៊្វុនស៊ីនប៉ិចដែលសេសសល់ ព្យាយាមរត់គេចខ្លួននៅថ្ងៃទី៦ ខែកក្កដា ដោយមានការដេញតាមពីក្រោយជាប់ៗ[256] ទោះបីជាលោក ញឹក ប៊ុនឆៃ បានរត់ចេញ ហើយបានធ្វើដំណើរតាមផ្លូវរបស់លោកទៅកាន់ប្រទេសថៃហើយក្តី ក៏កងទ័ពរបស់លោក កែវ ពង្ស បានចាប់ខ្លួនមន្ត្រីជាន់ខ្ពស់របស់គណបក្សហ៊្វុនស៊ិនប៉ិច រួមទាំងសមាជិកអគ្គសេនាធិការកំពូលផង ហើយពួកគេត្រូវបានប្រហារជីវិត។[257] យោងតាមរបាយការណ៍សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ប្រចាំកម្ពុជា ចុះកាលបរិច្ឆេទ ថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧ ពួកគេស្ថិតក្នុងចំណោមជនរងគ្រោះដែលត្រូវបានសម្លាប់ចោលយ៉ាងហោចណាស់ ៤១ នាក់ និង "អាចរហូតដល់ ៦០ នាក់" ដែលរងគ្រោះ ក្នុងការសម្លាប់ក្រៅប្រព័ន្ធតុលាការ ដោយមូលហេតុខាងនយោបាយ" បន្ទាប់ពីរដ្ឋប្រហារ។[258] មន្ត្រីគណបក្សហ៊្វុនស៊ីនប៉ិចដែលគេចាប់បានមួយចំនួន ត្រូវបានគេនាំទៅឲ្យលោក ប៉ុល

---

[255] បទសម្ភាសន៍ជាមួយប៉ុល សារឿន ថ្ងៃទី 28 ខែមិថុនាឆ្នាំ1997។ បទសម្ភាសន៍ជាមួយហ៊ុន សែន នៅភ្នំពេញថ្ងៃទី 21 ខែកញ្ញាឆ្នាំ 2007 សូមមើល ECCC, ការិយាល័យសហចៅក្រមស៊ើបអង្កេត("ដីកាបិទ") D427 ភាសាអង់គ្លេសទំព័រ (48, 51, 58, 188, 202-5, 233-4, 266) ។

[256] លោកប្រ៊ែដ អាដាមស៍ (Brad Adams) សម្ភាសន៍ជាមួយអតីតមន្ត្រីស្ថានទូតអាមេរិក នៅខែមេសា ឆ្នាំ2000 ជាមួយ Brad Adams ។ លោក Brad Adams សម្ភាសជាមួយមន្ត្រីយោធាអូស្ត្រាលី ដែលឈរជើងនៅកម្ពុជាពេលមានរដ្ឋប្រហារ, ថ្ងៃទី 17 ខែធ្នូឆ្នាំ 2001 ។ សម្ភាសជាមួយមន្ត្រីកងយោធពលខេមរភូមិន្ទ សុំមិនបញ្ចេញឈ្មោះ ឆ្នាំ 2001 ។ Brad Adams សម្ភាសជាមួយមន្ត្រីយោធានិងមន្ត្រីស៊ីវិលគណបក្សប្រជាជនកម្ពុជា មន្ត្រីអង្គការសហប្រជាជាតិ អ្នកស្រុកនៅមូលដ្ឋាន។ សម្ភាសន៍ជាមួយលោកហ៊ុនសែននា ថ្ងៃទី21 ខែកញ្ញា ឆ្នាំ2007។

[257] COHCHR, "ការពិនិត្យពតបទសម្ភាសន៍ ថ្ងៃទី 28 ខែកក្កដា ឆ្នាំ1997" ថ្ងៃទី 4 ខែសីហាឆ្នាំ 1997; COHCHR "សម្ភាសជាមួយសាកសពអង្គរក្សលោក ញឹក ប៊ុនឆៃ អាយុ 29 ឆ្នាំ នៅថ្ងៃទី 18 ខែកក្កដាឆ្នាំ 1997" ថ្ងៃទី 20 ខែកក្កដាឆ្នាំ 1997។

[258] អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ប្រាប់ពួកគេថា ខ្ញុំចង់សម្លាប់ពួកគេ" ៖ ពីរទសវត្សរ៍នៃនិទណ្ឌភាពនៅក្នុងប្រទេសកម្ពុជារបស់លោកហ៊ុនសែន 2012 https://www.hrw.org/report/2012/11/13/tell-them-i-want-kill-them/two-decades-impunity-hun-sens-cambodia, ទំព័រ 40 ។

សារឿន មុនពេលពួកគេបាត់ខ្លួន។[259]

## ប៉ុល សារឿន ជានាយសេនាធិការបន្ទាប់ពីរដ្ឋប្រហារ ឆ្នាំ១៩៩៧-២០០៩

បន្ទាប់ពីរដ្ឋប្រហារ លោក ប៉ុល សារឿន ត្រូវបានផ្តល់រង្វាន់ ដោយការដំឡើងតំណែងបន្ថែមជាទីប្រឹក្សារបស់អគ្គមេបញ្ជាការកំពូលរបស់កងយោធពលខេមរភូមិន្ទ (បច្ចុប្បន្ន សម្រាប់លោក ហ៊ុនសែន ម្នាក់គត់ ដែលមានឋានៈសក្តិស្មើរដ្ឋមន្ត្រី)។[260] ក្នុងខែកុម្ភៈ ឆ្នាំ ១៩៩៩ លោក ប៉ុល សារឿនត្រូវបានតែងតាំងជាប្រធានអគ្គសេនាធិការចម្រុះ និងជាមេបញ្ជាការរងជាន់ខ្ពស់របស់កងយោធពលខេមរភូមិន្ទ។[261] ចាប់តាំងពីនេះមកអំណាចពិតលើកងយោធពលខេមរភូមិន្ទ គឺលោក ប៉ុល សារឿន លោកគន់ គីម និងពួកមេបញ្ជាការយោធភូមិភាគមួយចំនួន ដែលបានប្តេជ្ញាជាទារួមគ្នាក្នុងការរក្សាតំណែងនាយករដ្ឋមន្ត្រីរបស់លោក ហ៊ុន សែន។[262]

ក្នុងទសវត្សរ៍ក្រោយមកទៀត ការរំលោភជាច្រើនត្រូវបានប្រព្រឹត្តដោយអង្គភាពកងយោធពលខេមរភូមិន្ទ ដែលស្ថិតក្រោមការបញ្ជាផ្ទាល់នៃអគ្គសេនាធិការចម្រុះរបស់លោក ប៉ុល សារឿន ឬឆ្លើយតបតាមបញ្ជាកងទ័ពជើងគោក ជើងអាកាស ឬកងនាវា។ ការរំលោភរួមមាន ការចាប់រំលោភសេពសន្ថវៈ ការសម្លាប់ក្រៅប្រព័ន្ធតុលាការ ឬការប៉ុនប៉ងសម្លាប់ ការឃុំឃាំងតាមអំពើចិត្ត និងការធ្វើទារុណកម្ម ឬការធ្វើទុក្ខបុកម្នេញធ្ងន់ធ្ងរដទៃទៀតទៅលើប្រជាពលរដ្ឋដែលគេបានឃុំឃាំង ឬឃាត់ខ្លួនដោយយោធា។[263] អង្គភាពដែលពាក់ព័ន្ធរួមមាន កងពលធំថ្មើរជើងលេខ២ កងពលតូចថ្មើរជើងលេខ៧០ កងពលតូចពិសេសឆ័ត្រយោងលេខ៩១១ កងពលតូចថ្មើរជើងលេខ១ កងពលតូចអន្តរាគមន៍ពិសេសលេខ១១ កងពលតូចអន្តរាគមន៍លេខ១២ និងកងពលតូចអន្តរាគមន៍លេខ១៤។ នៅក្រោមបញ្ជាការកំពូលរួមគ្នា និងក្រោមបញ្ជារបស់អគ្គសេនាធិការចម្រុះ គឺមានអង្គភាពស្រាវជ្រាវ និងចារកម្ម ដែលគេនៅតែស្គាល់ថា ជាគុយ១០១ (Q១០១) ។[264] អង្គភាពកងយោធពលខេមរភូមិន្ទជាប់ពាក់ព័ន្ធក៏កាន់តែច្រើនឡើងៗក្នុងការប្លាមយកដីធ្លីយ៉ាងហឹង្សា មានទាំងការរឹប

---

[259] ឯកសាររបស់ COHCHR "សម្ភាសជាមួយ [លុប] នៃក្រុងកំពតទី [លុប] 15 ខែមេសា ឆ្នាំ 1998 ។ "

[260] រាជរដ្ឋាភិបាលកម្ពុជា, ព្រះរាជក្រឹត្យលេខ ដស/រកត/0897/148 ថ្ងៃទី 11 ខែសីហាឆ្នាំ 1997។

[261] រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រឹត្យលេខ ដសរ /ពត/0199/22 ថ្ងៃទី 24 ខែកុម្ភះ ឆ្នាំ1999 ។

[262] ប្រ៊ែដ អាដាមស៍ (Brad Adams) បទសម្ភាសន៍ជាមួយថ្នាក់ក្រោមលោកប៉ុលសារឿននៅទីក្រុងប៉ារីសឆ្នាំ 2004។

[263] ពីប្រភពដដែល Ibid.

[264] បញ្ជាការជាន់ខ្ពស់កងយោធពលខេមរភូមិន្ទទី264, "ការចាត់ចែងបញ្ជាការជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ ឆ្នាំ "2006 ។ "តំណែងសំខាន់ៗសម្រាប់កូនប្រុសនាយករដ្ឋមន្ត្រី", ភ្នំពេញប៉ុស្ត៍, ថ្ងៃទី 16 ខែមករាឆ្នាំ 2012, http://www.phnompenhpost.com/national/key-post-premier%E2%80%99s-son (ចូលមើលថ្ងៃទី 22 ខែតុលាឆ្នាំ 2015) ។

អូសយកដី ដើម្បីប្រើប្រាស់ដោយអង្គភាពខ្លួនឯងជំនួសឱ្យមន្ត្រីយោធា ឬមន្ត្រីរដ្ឋាភិបាល ឬសម្រាប់លក់ដូរ ឬផ្តល់ជាសម្បទានដល់ក្រុមហ៊ុនឯកជន ឬការរួមបញ្ចូលគ្នានៃអ្នកទទួលផលជាច្រើន។[265] នៅពេលខ្លះ ពួកគេបានដាក់ពង្រាយបង្ការការធ្វើបាតុកម្មរបស់កម្មករ ដូចដែលកងពលតូចលេខ៩១១ បានធ្វើកាលពីខែឧសភា ឆ្នាំ២០០៦ ។[266]

ឧប្បត្តិហេតុផ្សេងៗទៀត នៅក្នុងសម័យកាលនេះ ក៏ទាក់ទងទៅនឹងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់លោក ប៉ុល សារឿនផងដែរ។ ឧទាហរណ៍ក្នុងឆ្នាំ ២០០៤ ពួកទាហានដែលយាមដីរបស់លោក ប៉ុល សារឿន នៅខណ្ឌ ៤ នៃខេត្តព្រះសីហនុ បានវាយដំយ៉ាងធ្ងន់ធ្ងរទៅលើបុរសម្នាក់ ដែលបានបើកម៉ូតូកាត់លើដីរបស់លោក ប៉ុល សារឿន។ ទាហានម្នាក់នាក់ក្នុងចំណោមពួកគេ ក្រោយមកបានគំរាមសម្លាប់ស្ត្រីម្នាក់ដែលសង្ស័យថា បានឃើញហេតុការណ៍នេះ។[267]

## លោក ប៉ុល សារឿន ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ចាប់តាំងពីឆ្នាំ២០០៩

នៅខែមករា ឆ្នាំ២០០៩ លោក ប៉ុល សារឿន ត្រូវបានតែងតាំងជាមេបញ្ជាការកំពូលរបស់កងយោធពលខេមរភូមិន្ទ ខណៈដែលលោក គន់ គីម ជំនួសលោក ប៉ុល សារឿន ជាមេអគ្គសេនាធិការចំរុះ។[268] ក្នុងអំឡុងរវាងខែមករាឆ្នាំ ២០០៩ និងការបោះឆ្នោតជាតិលើកក្រោយ នៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៣ យោងតាមតួលេខដែលបានចងក្រងឡើងដោយអ្នកឃ្លាំមើលសិទ្ធិមនុស្ស នៅកម្ពុជា បានឱ្យដឹងថា ចំនួននៃការរំលោភសិទ្ធិមនុស្ស និងការរំលោភបំពានផ្សេងៗទៀត ពាក់ព័ន្ធនឹងកងយោធពលខេមរភូមិន្ទ បានថយចុះបន្តិច។ យ៉ាងណាក៏ដោយ ពួកគេនៅតែបន្តពាក់ព័ន្ធការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងការប៉ុនប៉ងសម្លាប់ ការធ្វើទារុណកម្ម និងការរំលោភធ្ងន់ធ្ងរផ្សេងៗ និងជួនកាលការរឹបអូសដីធ្លីដោយហិង្សា។[269]

---

[265] ពីប្រភពដដែល Ibid.

[266] ពីប្រភពដដែល Ibid.

[267] ពីប្រភពដដែល Ibid.

[268] រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រឹត្យលេខ នស /រក /0109/069 ថ្ងៃទី 22 ខែមករាឆ្នាំ 2009។

[269] ពីប្រភពដដែល Ibid.

ក្នុងអំឡុងយុទ្ធនាការឃោសនាបោះឆ្នោត ឆ្នាំ២០១៣ លោក ប៉ុល សារឿន បានបង្ហាញពីការប្រកាន់បក្សនយោបាយពិតប្រាកដរបស់លោក ដោយធ្វើយុទ្ធនាការជាសាធារណៈឱ្យគណបក្សប្រជាជនកម្ពុជា ធ្វើជាប្រធានក្រុមការងារគណបក្សសម្រាប់ខេត្តព្រះសីហនុ។ នៅទីនោះ លោកបានដាស់តឿនអ្នកបោះឆ្នោត ឱ្យមិនគោរពតាមការឃោសនារបស់គណបក្សសង្គ្រោះជាតិដែលជាបក្សប្រឆាំង និងជំនួសមកវិញ ត្រូវរួមគ្នាធានាការបោះឆ្នោតឲ្យគណបក្សប្រជាជនឲ្យបានច្រើនកុះករ។[270] លោកបានដឹកនាំការប្រមូលផ្តុំចុងក្រោយនៃយុទ្ធនាការខេត្តរបស់គណបក្សប្រជាជនកម្ពុជា។[271] លោកក៏បានទៅមើលមូលដ្ឋាននយោបាយចាស់របស់គាត់នៅខេត្តតាកែវ ដើម្បីគាំទ្រលោក ហ៊ុន សែន និងមេដឹកនាំកំពូលៗដទៃទៀតរបស់គណបក្សប្រជាជនកម្ពុជា ដោយអះអាងពីសមិទ្ធផលរបស់ពួកគេដើម្បីប្រជាជនកម្ពុជា។[272]

បន្ទាប់ពីការបោះឆ្នោត លោក ប៉ុល សារឿនបានច្រានចោលការចោទប្រកាន់ដែលគួរឱ្យទុកចិត្តអំពីការក្លែងបន្លំ និងភាពមិនប្រក្រតីនៃការបោះឆ្នោតដែលបានរៀបចំឡើងដោយគណបក្សប្រជាជនកម្ពុជា និងបានគាំទ្រលទ្ធផលដែលបានប្រកាសជាផ្លូវការថា ជាការពិត និងនិយាយគាំទ្រដល់ការចាត់វិធានការខាងផ្លូវច្បាប់ប្តឹងប្រឆាំងលោក សម រង្ស៊ី។[273] លោក ប៉ុល សារឿន បានធ្វើជាអធិបតីក្នុងការដំឡើងទីស្នាក់ការថ្មីរបស់គណបក្សប្រជាជនកម្ពុជា នៅខេត្តព្រះសីហនុ និងបានបង្ហាញមុខឆ្លោឡើង នៅឯពិធីជួបជុំជាតិ ថ្ងៃងពីការកើតឡើងនៃគណបក្សប្រជាជនកម្ពុជា។[274]

បន្ទាប់ពីការបង្ក្រាបដោយហិង្សាលើបាតុករ និងបាតុកម្មរបស់កម្មករកាលពីថ្ងៃទី ២ ដល់ថ្ងៃទី ៣ ខែមករា

---

[270] "លោក ប៉ុលសារឿន ៖ វាចាំបាច់ត្រូវដឹងពីរបៀបគ្រប់គ្រងសមាជិកម្នាក់ៗ ដើម្បីកុំឲ្យចាញ់ឃោសនារបស់បក្សប្រឆាំង "ថ្ងៃទី 27 ខែឧសភា, http://www.dap-news.com/2011-06-14-02-39-55 /64813-2013-05-27-08-02-47.html (ចូលមើលថ្ងៃទី 28 ខែឧសភាឆ្នាំ 2013) ។

[271] "លោកប៉ុលសារឿនដឹកនាំសមាជិកជាង ៦,០០០ នាក់ក្នុងដំណើរបញ្ចប់ការឃោសនាបោះឆ្នោតនៅខេត្តព្រះសីហនុ  ថ្ងៃទី"26 ខែកក្កដាឆ្នាំ 2013 http://www.dap-news.com/2011-06-14-02-39-55/69186-2013 -07-26-10-15-54.html (ចូលមើលថ្ងៃទី 26 ខែកក្កដាឆ្នាំ 2013) ។

[272] "ឧត្តមសេនីយ៍ប៉ុល សារឿនសម្ពោធដាក់ឱ្យដំណើរការសមិទ្ធផលព្រែកបាស ថ្ងៃទី "3 ខែមិថុនាឆ្នាំ 2013, http://www.dap-news.com/2011-06-14-02-39-55/65229-2013-06-03-02 -51-02.html (ចូលមើលនៅថ្ងៃទី 4 ខែមិថុនាឆ្នាំ 2013) ។

[273] ឧត្តមសេនីយ៍ប៉ុល សារឿន គាំទ្រសេចក្តីថ្លែងរបស់រដ្ឋាភិបាលថ្កោលទោសលោកសមរង្ស៊ី "ថ្ងៃទី 7 ខែមេសាឆ្នាំ 2014, http://www.dap-news.com/2011-06-14-02-39-55 / 84466-2014-04-07- 07-11-12.html (ចូលមើលនៅថ្ងៃទី 4 ខែមេសាឆ្នាំ 2014)។

[274] "ការប្រកាសផ្ទេរភារកិច្ចជាប្រធានគណបក្សប្រជាជនកម្ពុជា នៅខេត្តព្រះសីហនុ និងខេត្តព្រៃវែង" ថ្ងៃទី 1 ខែមីនាឆ្នាំ 2014 http: //www.dap-news.com/2011-06-14-02-39-55 / 81908-2014-03-01-01-39-58.html (ចូលមើលនៅថ្ងៃទី 2 ខែមីនាឆ្នាំ 2014); "ទោះបីជាប្រធានគណបក្សមិនមានវត្តមានក៏ដោយ ក៏គណបក្សប្រជាជនកម្ពុជារំលឹកខួបលើកទី 63 នៅក្នុងរចនាបទដែរខេមបូឌាដេលី "ថ្ងៃទី 30 ខែមិថុនាឆ្នាំ 2014 ។ http://www.cambodiadaily.com/news/despite-party-president-absence-cpp-marks-63rd-anniversary in-style-62735 /(មើលថ្ងៃទី1កក្កដាឆ្នាំ 2016)។

ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញក្នុងអំឡុងពេលដែលកងពលតូច៩១១ និងកងពលតូច៧០ បានចូលរួមចាប់ខ្លួន និងកាន់កាប់តំបន់កម្មកររងចក្រ នៅជាយរាជធានីភ្នំពេញ លោក ប៉ុល សារឿន បានសរសើរលោក ហ៊ុន សែន សម្រាប់ការគាំទ្ររបស់គាត់ចំពោះការចូលរួមចំណែករបស់កងយោធពលខេមរភូមិន្ទក្នុងការថែរក្សា "ស្ថិរភាពនិងសណ្តាប់ធ្នាប់សង្គម"។[275] នៅខែកុម្ភៈ ឆ្នាំ ២០១៤ លោក ហ៊ុន សែនបានបញ្ចូលគាត់ទៅក្នុងគណៈកម្មាធិការគ្រប់គ្រងមួយទទួលបន្ទុកចាត់វិធានការប្រឆាំងនឹងការតវ៉ារបស់កម្មករ ដែលគេចាត់ទុកថា ខុសច្បាប់។[276]

នៅឆ្នាំ ២០១៥ និងឆ្នាំ២០១៦ លោក ប៉ុល សារឿន បានបន្តធ្វើកិច្ចការសាធារណៈ ក្នុងនាមគណបក្សប្រជាជនកម្ពុជា ដោយថ្កោលទោសគណបក្សសង្គ្រោះជាតិ ក្នុងបំណងការពារសមិទ្ធផលជាច្រើនរបស់គណបក្សប្រជាជនកម្ពុជា ហើយបានកោតសរសើរចំពោះការដឹកនាំរបស់លោក ហ៊ុន សែន ដែលបានព្រមានថា ប្រសិនបើគណបក្សសង្គ្រោះជាតិ ព្យាយាមកំចាត់លោកប៉ុល សារឿន នោះលោក ប៉ុល សារឿននឹងកៀរគរកងយោធពលខេមរភូមិន្ទ ដើម្បីទប់ស្កាត់ការព្យាតាមនេះ។[277]

នៅថ្ងៃទី ៩ខែកក្កដា ឆ្នាំ ២០១៦ យោងតាមរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ ដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា លោក ប៉ុល សារឿន បានអំពាវនាវដល់យោធាទាំងមូលថា យោធាត្រូវកំចាត់ចោល

---

[275] "អគ្គបញ្ជាការជួបជុំបូកសារុបការងារហ្វឹកហ្វឺនឆ្នាំ 2013" ថ្ងៃទី22 ខែមករា 2014, http://edition.kpt-news.com/local-news/2977-2014-01-22-08-51-50.html (ចូលមើលថ្ងៃទី 22 ខែមករាឆ្នាំ 2014) ។

[276] លោកហ៊ុនសែនបានបន្ថែមមេបញ្ជាការកងទ័ពទៅកាន់គណៈកម្មាធិការប្រឆាំងកូដកម្ម "ខេមបូឌាដេលីថ្ងៃទី 21 ខែកុម្ភៈឆ្នាំ 2014, http://www.cambodiadaily.com/news/hun-sen-adds-armed-forces-chiefs-to-strike-committee- 52873 / (ចូលមើលនៅថ្ងៃទី 26 ខែកុម្ភៈឆ្នាំ 2014) ។

[277] "ឧត្តមសេនីយ៍ប៉ុល សារឿន និងលោកអូសម៉ាន ហាសាន ជួបនិងជជែកគ្នាជាមួយបងប្អូនប្រុសស្រីបងប្អូនឥស្លាមប្រមាណ 500 នាក់នៅខេត្តព្រះសីហនុ "ថ្ងៃទី 10 ខែតុលាឆ្នាំ 2015 http://www.dap-news.com/2011-06-14-02 -39-55 / 96790-2015-08-10-03-36-06.html (ចូលមើលថ្ងៃទី 10 ខែសីហាឆ្នាំ 2015)។ "មេបញ្ជាការកងទ័ព ជំរុញឱ្យកងយោធាទាំងអស់ បិទមាត់បុគ្គលណាដែលនិន្នាការរបស់គេ ធ្វើឱ្យមានអស្ថិរភាពសម្រាប់ជាតិនិងសង្គម" ថ្ងៃទី 15 ខែកញ្ញាឆ្នាំ 2015, http://www.dap-news.com/2011-06-14-02-39- 55 / 99154-2015-09-15-07-43-36.html (ចូលមើលថ្ងៃទី 15 ខែកញ្ញាឆ្នាំ 2015) ។ "កងទ័ពបានប្រកាសថ្កោលទោសចំពោះអ្នកទាំងឡាយដែលមួលបង្កាច់រដ្ឋាភិបាលអំពីករណីដែនទីនិងព្រំដែន" ថ្ងៃទី 10 ខែកញ្ញាឆ្នាំ 2015 http://www.dap-news.com/2011-06-14-02-39-55/98875-2015 -09-10-10-37-10.html (ចូលមើលថ្ងៃទី 10 ខែកញ្ញាឆ្នាំ 2015)។ ទីបញ្ជាការជាន់ខ្ពស់បានកោះប្រជុំបូកសារុបការងារឆ្នាំ 2015 និងទិសដៅឆ្នាំ2016 (ចូលមើលថ្ងៃទី 9 ខែមករាឆ្នាំ 2016) ។ "ប្រមូលផ្តុំគ្នានៅខេត្តព្រះសីហនុ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី37 នៃទិវាជ័យជំនះ 7 មករា "ថ្ងៃទី 7 ខែមករាឆ្នាំ 2016, http://kampucheathmey.com/kpt/?p=139775 (ចូលមើលថ្ងៃទី 7 ខែមករាឆ្នាំ 2016)"លោកប៉ុលសារឿន ផ្តល់ការណែនាំអំពីគុណតម្លៃនៃសន្តិភាពដល់សកម្មជនសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ "ថ្ងៃទី 25 ខែសីហាឆ្នាំ 2015, http://www.dap-news.com/2011-06-14-02-39-55 / 97747-2015-08-24-05-26-18.html (ចូលមើលថ្ងៃទី 25 ខែសីហាឆ្នាំ 2015); "ហ៊ុនសែនព្រមានក្រុមប្រឆាំង ដោយប្រើកងកម្លាំងប្រដាប់អាវុធ" ខេមបូឌាដេលីថ្ងៃទី 20 ខែតុលាឆ្នាំ 2015, https://www.cambodiadaily.com/news/hun-sen-warns-opposition-of-backlash-by-armed-forces- 97603 / (ចូលមើលនៅថ្ងៃទី 21 ខែតុលាឆ្នាំ 2015)។

ភ្លាមៗ នូវបុគ្គលណា ដែលមានចិត្តគំនិតចង់បំផ្លាញសន្តិភាព ដែលបង្កឱ្យមានចលាចលសង្គមនៅក្នុងប្រទេសកម្ពុជា និងដូចគ្នានេះ” ដោយពន្យល់ថា កងទ័ពត្រូវតែ "បណ្តេញពួកកម្លាំងជ្រុលនិយមឲ្យទាន់ពេលវេលា ដែលកំពុងតែជំរុញឱ្យមានអស្ថិរភាពនៅក្នុងសង្គមជាតិ ហើយជាពិសេស ត្រូវទប់ស្កាត់ឲ្យបានដាច់ខាតនូវការរំដើបរំជួលនៃភាពច្របូកច្របល់ ឬសកម្មភាពណាមួយ ដែលមានស្មារតីចង់បំផ្លាញសន្តិភាព គឺត្រូវតែលុបបំបាត់ចោលភ្លាមៗ។[278]

ចាប់តាំងពីចុងឆ្នាំ២០១៦ លោក ប៉ុល សារឿនសង្កត់ធ្ងន់ទៅលើតួនាទីសំខាន់ៗរបស់កងយោធពលខេមរភូមិន្ទ ក្នុងការថែរក្សាសន្តិសុខ និងស្ថិរភាពផ្ទៃក្នុង ដោយផ្តល់តម្លៃលើការរក្សាសន្តិភាពនៅក្នុងប្រទេស និងអរគុណដល់ការដឹកនាំនិងគោលនយោបាយរបស់លោក ហ៊ុន សែន ដែលធ្វើឲ្យកម្ពុជាមានការអភិវឌ្ឍសេដ្ឋកិច្ច។[279] លោកបានបញ្ជាក់ថា តួនាទីរបស់កងយោធពលខេមរភូមិន្ទ រួមមាន "ការបង្ក្រាបបទល្មើស "ដែលផ្ទុយនឹងសន្តិសុខ និងស្ថេរភាពនយោបាយ។[280] ឧទាហរណ៍ នៅថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ២០១៧ លោកបានប្រកាសថា ដើម្បីបំពេញបេសកកម្មនេះ និងបេសកកម្មផ្សេងទៀត កងយោធពលខេមរភូមិន្ទកំពុងរីករាយនឹងអត្ថប្រយោជន៍នៃការអភិវឌ្ឍសន្តិភាពរបស់កម្ពុជា ដែលកំពុងត្រូវបានពង្រឹង និងពង្រីកបន្ថែមទៀត។[281]

---

[278] "មេបញ្ជាការកងទ័ព ៖ វាជាការចាំបាច់ដើម្បីលុបបំបាត់និងការសំអាតភ្លាមៗនូវបុគ្គលណាដែលចិត្តគំនិតចង់ធ្វើឱ្យខូចសន្តិភាព" (http://bayontv.com.kh/archives/71756, ថ្ងៃទី 5 ខែកក្កដាឆ្នាំ 2016 (ចូលមើលខែកក្កដា ថ្ងៃទី 6 ខែឆ្នាំ 2016) "ទប់ស្កាត់សកម្មភាពដែលមានគំនិតធ្វើឱ្យខូចដល់សន្តិភាពនៅកម្ពុជា" (ថ្ងៃទី 10 ខែកក្កដាឆ្នាំ 2016) http://beta.nokorwatnews.com/?p=108665, (ចូលមើលថ្ងៃទី 10 ខែកក្កដាឆ្នាំ 2016) ។

[279] "លោកប៉ុលសារឿន ៖ កម្ពុជាមិនត្រឹមតែអាចថែរក្សាសន្តិសុខផ្ទៃក្នុងប៉ុណ្ណោះទេ ថែមទាំងជួយដល់ប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិផងដែរ "ថ្ងៃទី 2 ខែវិច្ឆិកាឆ្នាំ 2016, http://www.freshnewsasia.com/index.php/en/localnews/38427-2016- 11-02-07-05-17.html (ចូលមើលនៅថ្ងៃទី 2 ខែវិច្ឆិកាឆ្នាំ 2016)។ "លោកប៉ុលសារឿនរៀបចំកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលការងារក្នុងរយៈពេល 9 ខែដំបូងនៃឆ្នាំ និងកាតព្វកិច្ចភ្លាមៗរបស់កងទ័ព ថ្ងៃទី 3 ខែវិច្ឆិកាឆ្នាំ2016, http: //www.freshnewsasia.com/index.php/en/localnews/38528 -2016-11-03-08-35-05.html (ចូលមើលថ្ងៃទី 3 ខែវិច្ឆិកាឆ្នាំ2016)។ "ឧត្តមសេនីយប៉ុលសារឿន ៖ កម្ពុជាទទួលបានឯករាជ្យតាមរយៈមាគ៌ានៃចលនាកងទ័ព និងប្រធានបទក្រោមការដឹកនាំរបស់សម្តេចនរោត្តមសីហនុ” ថ្ងៃទី 8 ខែវិច្ឆិកាឆ្នាំ 2016, http://www.freshnewsasia.com/index.php/en/localnews/38872- 2016-11-08-04-22-42.html (ចូលមើលនៅថ្ងៃទី 8 ខែវិច្ឆិកាឆ្នាំ 2016)។"ឧត្តមសេនីយប៉ុលសារឿន ៖ សន្តិភាពគឺផ្ទុយទៅនឹងសង្គ្រាម ប៉ុន្តែយើងទាំងអស់គ្នាត្រូវតែផ្តោតទៅលើគោលបំណងតែមួយពោលគឺការថែរក្សាសន្តិភាព” ថ្ងៃទី 22 ខែវិច្ឆិកាឆ្នាំ 2016, http://www.freshnewsasia.com/index.php/en/localnews/ 39875-2016-11-22-03-48-13.html (ចូលមើលនៅថ្ងៃទី 22 ខែវិច្ឆិកាឆ្នាំ 2016) ។

[280] "ឧត្តមសេនីយប៉ុល សារឿន ជំរុញពួកមេបញ្ជាការកងទ័ពទាំងអស់ ឲ្យបន្តយកចិត្តទុកដាក់កសាងនិងពង្រឹងវិធីការពារជាតិ ដើម្បីធ្វើឱ្យពួកគេមានភាពរឹងមាំគ្រប់ទិដ្ឋភាព” 27 ខែធ្នូឆ្នាំ 2016, http://www.freshnewsasia.com/index.php/en/localnews / 42701-2016-12-27-07-06-40.html (ចូលមើលនៅថ្ងៃទី 27 ខែធ្នូឆ្នាំ 2016) ។

[281] "ឧត្តមសេនីយ៍ប៉ុលសារឿន ៖ ប្រទេសនេះមានសន្តិភាព ផ្តល់ឱកាសឲ្យកងទ័ព ពង្រឹងនិងពង្រីកសមត្ថភាពរបស់ខ្លួន, ការធ្វើឱ្យវាមុតស្រួចជាងមុន "ថ្ងៃទី 1 ខែកុម្ភៈ, 2017, http://dap- news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93%E1%9E%80%E 1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%91%E1%9F%81%E1%9E%9F/28048.html (ចូលមើលនៅថ្ងៃទី 1 ខែកុម្ភៈឆ្នាំ 2017) ។

*នៅចុងខែកុម្ភៈ លោកបានប្រកាសថា" ជាធ្នឹងខ្នងដ៏រឹងមាំរបស់ជាតិ" កងយោធពលខេមរភូមិន្ទត្រូវប្តេជ្ញាទប់ស្កាត់ដាច់ខាតនូវ "បដិវត្តពណ៌។[282] " នៅខែមីនាឆ្នាំ ២០១៦ លោកបានទទូចជាសាធារណៈថា ប្រជាពលរដ្ឋទាំងអស់ត្រូវតែមាន "ជំនឿមុតមាំ និងរឹងមាំ" លើភាពជាអ្នកដឹកនាំរបស់ លោក ហ៊ុន សែន។[283] លោកមានប្រសាសន៍ក្នុងខែមីនាថា អ្នកណាដែលចោទថា រដ្ឋាភិបាល ត្រូវទទួលខុសត្រូវចំពោះការបាត់បង់ទឹកដីកម្ពុជាទៅឲ្យវៀតណាម ត្រូវតែ "ចាប់ដាក់គុកដោយមិនលើកលែងឡើយ" ។[284] នៅខែដដែលនោះ បន្ទាប់ពីលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ទទួលមរណភាព លោក ប៉ុល សារឿន ជាបណ្តោះអាសន្ន បានជំនួសតំណែងមន្ត្រីស៊ីវិលជាន់ខ្ពស់នេះ ដោយធ្វើជាប្រធានក្រុមការងារដែលទទួលខុសត្រូវក្នុងខេត្តតាកែវអស់រយៈពេលជាច្រើនខែ បន្ថែមលើការទទួលខុសត្រូវដែលមានស្រាប់របស់គាត់ សម្រាប់ការពង្រឹងអំណាចរបស់គណបក្សប្រជាជនកម្ពុជា នៅខេត្តព្រះសីហនុ ដូច្នេះហើយមានន័យថា គាត់បានវិលត្រឡប់មកកាន់តំណែងដែលមានអំណាចលើតំណែងនយោបាយរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ ១៩៨០ ដែលជាតំណែងដើមរបស់គាត់ កាលដែលគាត់ជាប្រធានបក្ស និងរដ្ឋបាលខេត្តតាកែវ។[285]*

*លោក ប៉ុល សារឿន បានធ្វើសេចក្តីថ្លែងការណ៍ជាបន្តបន្ទាប់ គាំទ្រដល់ការបង្ក្រាបលើគណបក្សសង្គ្រោះជាតិ ដែលបានចាប់ផ្តើមជាមួយនឹងការចាប់ខ្លួនលោក កឹម សុខា មេដឹកនាំគណបក្សនេះកាលពីថ្ងៃទី ៣ ខែកញ្ញាឆ្នាំ ២០១៧ និងបន្តរហូតមកដល់បច្ចុប្បន្ន។ ឧទាហរណ៍ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ នៅឯពិធី*

---

282 ឧត្តមសេនីយ៍ប៉ុលសារឿន ៖ កងទ័ពកម្ពុជា ត្រូវតែការពារសន្តិភាពយ៉ាងរឹងមាំ និងប្រឆាំងនឹងបដិវត្តពណ៌ដាច់ខាត "ថ្ងៃទី 27 ខែកុម្ភៈឆ្នាំ 2017 http://www.freshnewsasia.com/index.php/en/localnews/48277-2017-02-27-12-05 -08.html (ចូលមើលថ្ងៃទី 27 ខែកុម្ភៈឆ្នាំ 2017)។

283 "ឧត្តមសេនីយ៍ប៉ុលសារឿនបានទទូចឲ្យប្រជាពលរដ្ឋទាំងអស់ មានសេចក្តីជំនឿយ៉ាងជ្រាលជ្រៅនិងរឹងមាំក្នុងការដឹកនាំរបស់សម្តេចតេជោហ៊ុន សែន ក្នុងការអភិវឌ្ឍនិងលើកកម្ពស់ជីវភាពរស់នៅកាន់តែប្រសើរឡើង" ថ្ងៃទី 26 ខែមិនាឆ្នាំ 2017 http://www.freshnewsasia.com/index.php/en /localnews/50758-2017-03-26-07-21-24.html (ចូលមើលថ្ងៃទី 27 ខែមីនាឆ្នាំ 2017) ។

284 "ឧត្តមសេនីយ៍ប៉ុលសារឿន នឹងដាក់ពន្ធនាគារអ្នកទាំងឡាយដែលចោទរាជរដ្ឋាភិបាលពីការប្រគល់ដីឱ្យវៀតណាម" ថ្ងៃទី 29 ខែមីនាឆ្នាំ2017, http: //www.dap-news.com/kh/%E1%9E%96%E1%9F%90%E1 E1% 9E% 80% E% 1% 9% 92% E1% 9E% 93% E1% E1% 9E% 98% E1% 9E% B% e% q% E1% 9F% 92% E1% 9E% 9A% E1% 9E% 91% E1% 9F% 81% E1% 9E 9E% B% E1% 9E% 84% E1% 9E% 94% E1% 9F% 92% % 9F / 33397.html (ចូលមើលថ្ងៃទី 29 ខែមីនាឆ្នាំ 2017) ។

285 "ឧត្តមសេនីយ៍ប៉ុល សារឿនត្រូវបានតែងតាំងដោយសម្តេចតេជោ ជាប្រធានក្រុមការងារថ្នាក់កណ្តាល ដើម្បីជួយខេត្តតាកែវជំនួសសម្តេចសុខ អាន ថ្ងៃទី20 ខែមីនា ឆ្នាំ2017 http: // dap-news.com/kh/%E1%9E%96 E1% 9E% 9%% E%% E% E% E% E% E% E% E9% E1% 9E% 93% E1% 9E% B% E1% 9E% 84% E1% 9E% 94% E1% 9F% 92% E1% 9E% 9A% E1% 9E% 91% E1% 9F% 81% E1% 9E% 9F / 32564.html (ចូលមើលថ្ងៃទី 20 ខែមីនាឆ្នាំ 2017)។ "សម្តេចសាយ ឈុំ នឹងតែងតាំងលោក ប៉ុល សារឿន ជាប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជា ដើម្បីជួយដល់ខេត្តតាកែវជំនួសសម្តេចសុខអាន" ថ្ងៃទី 22 ខែមីនាឆ្នាំ 2017, http: // dap-news.com/kh/%E1% 9E% 96% E1% 9F% 90% E1% 9E% 8F% E1% 9F% 8C% E1% 9E% 98% E1% 9E% B6% E1% 9E% 93% E1% 9E% 80% E 1% 9F E1% 9E% 9E% 9F% 92% E1% 9E% 9A% E1% 9E% 91% E1% 9F% 81% 92% E1% 9E% 93% E1% 9E% B% E1% 9E% 84% E1% 9E% 94% E1% 9F% 92% % E1% 9E% 9F/ 32713.html (ចូលមើលថ្ងៃទី 22 ខែមីនាឆ្នាំ 2017)។ "តួនាទីថ្មីរបស់មេបញ្ជាការកងយោធពលខេមរភូមិន្ទ" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 22 ខែមីនាឆ្នាំ 2017, http://www.phnompenhpost.com/national/new-role-rcaf-chief (ចូលមើលថ្ងៃទី 22 ខែមីនាឆ្នាំ 2017) ។

ប្រមូលផ្តុំមេបញ្ជាការកងយោធពលខេមរភូមិន្ទ លោកបានណែនាំមេបញ្ជាការទាំងនោះឱ្យបង្កើនការប្រុងប្រយ័ត្ន ដើម្បីប្រឆាំងនឹង "មនុស្សដែលមានគំនិតមិនល្អ" និង "ពួកជ្រុលនិយម" ដែលលោកបានព្រមានថា នៅតែមានបំណងបង្ក "សកម្មភាពដែលនាំមកនូវភាពវឹកវរនៅក្នុងសង្គម"។[286] នៅក្នុងការបង្ហោះហ្វេសប៊ុកបីថ្ងៃក្រោយមក លោកបានពន្យល់ថា "ដើម្បីរក្សាសន្តិភាព និងសន្តិសុខជាតិ កម្ពុជាប្រឆាំងដាច់ខាតនឹងសកម្មភាពណាមួយ និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ដែលផ្ទុត់គំនិតនេះ គឺជាការបង្កើតហេតុផលសម្រាប់ការបែកបាក់សាមគ្គីភាពជាតិ ក្រោមផ្លាកប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ក្នុងគោលបំណងបម្រើផលប្រយោជន៍នយោបាយរបស់បុគ្គល ឬមនុស្ស និងជនបរទេសមួយក្តាប់តូច។"[287] ក្នុងអំឡុងសុន្ទរកថាមួយទៅកាន់វគ្គបណ្តុះបណ្តាលយោធានៅថ្ងៃទី ២២ ខែតុលាឆ្នាំ២០១៨ លោក ប៉ុល សារឿន បានប្រកាសថា ករណីយកិច្ចចម្បងទី១ របស់កងយោធពលខេមរភូមិន្ទគឺ "ការប្រើកម្លាំងអនុវត្តរាល់សកម្មភាពដែលចាំបាច់ ដើម្បីទប់ស្កាត់គណបក្សសង្គ្រោះជាតិ និងក្រុម" ជ្រុលនិយម " ដទៃទៀត ពីការអនុវត្តគំរោងការធ្វើបដិវត្តពណ៌របស់ពួកគេ។[288] នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៧ លោកបានថ្កោលទោសលោក សម រង្ស៊ី ដែលបាននិរទេសខ្លួននៅក្រៅប្រទេសថា ជាជនក្បត់ជាតិ ហើយម្តងទៀត បានប្រកាសថា កងយោធពលខេមរភូមិន្ទនឹងមិនអនុញ្ញាតឱ្យមានបដិវត្តពណ៌នៅកម្ពុជាទេ។[289]

---

[286] មេដឹកនាំកងយោធពលខេមរភូមិន្ទ អំពាវនាវឲ្យត្រៀមខ្លួនរួចរាល់នៅថ្ងៃព្រហស្បត៍ទី 12 ខែតុលាឆ្នាំ 2017។

[287] នាយឧត្តមសេនីយ៍ប៉ុលសារឿន ជំរុញឲ្យទាហានទាំងអស់ ត្រូវចូលរួមការពារបញ្ហាសន្តិសុខ ការប៉ះឆ្នោតព្រឹទ្ធសភា និងប៉ះឆ្នោតសកលឲ្យបានល្អ ក្តាប់កម្លាំងឲ្យបាន និងធ្វើឲ្យបាន។

[288] នាយឧត្តមសេនីយ៍ប៉ុលសារឿន ៖ កងយោធពលខេមរភូមិន្ទប្រឆាំងដាច់ខាត និងមិនបណ្តោយឲ្យក្រុមជ្រុលនិយមណាមួយ ឬនរណាម្នាក់ មកបំផ្លិចបំផ្លាញសុខសន្តិភាពរបស់ប្រជាជនកម្ពុជាបានឡើយ។

[289] នាយឧត្តមសេនីយ៍ប៉ុលសារឿន ប្រកាសមិនឲ្យបដិវត្តពណ៌កើតឡើងនៅកម្ពុជាដាច់ខាត ហើយហៅលោកសមរង្សីជាជនក្បត់ជាតិ។

## II. ឧត្តមសេនីយ៍គន់ គីម មេបញ្ជាការរងជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ អគ្គបញ្ជាការចម្រុះនៃកងយោធពលខេមរភូមិន្ទ

### *លោក គន់ គីម ជាមួយខ្មែរក្រហម ១៩៧០-១៩៧៨*

*លោក គន់ គីម មានដើមកំណើតនៅភូមិចាន់ទូង ឃុំស្រឡប់ ស្រុកត្បូងឃ្មុំដែលឥឡូវនេះជាខេត្តដែលមានឈ្មោះដូចគ្នាដែលពីមុនជាខេត្តកំពង់ចាម។*[290] *ថ្ងៃកំណើតជាផ្លូវការគឺនៅថ្ងៃទី ១ ខែមករា ឆ្នាំ១៩៥៤ ។*[291] *គាត់គឺជាកងជីវពលខ្មែរក្រហមនៅក្នុងតំបន់ភូមិភាគបូព៌ារបស់ខ្លួន ហើយបន្ទាប់មកជាអង្គរក្សសម្រាប់លេខាធិការនៃស្រុកត្បូងឃ្មុំ ក្នុងតំបន់២១ ក្នុងភូមិភាគបូព៌ា ។*[292]

*បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជា ដណ្តើមអំណាចបាននៅខែមេសា ឆ្នាំ១៩៧៥ គាត់បានក្លាយជាប្រធានការិយាល័យសន្តិសុខស្រុកត្បូងឃ្មុំ។*[293] *ក្នុងតួនាទីនេះ គាត់ត្រូវបានគេចោទថា ជាអ្នកត្រួតពិនិត្យលើការចាប់ខ្លួន ការធ្វើទារុណកម្ម និងការប្រហារជីវិតសត្រូវ ដែលជាប់ចោទថា ជាខ្មាំងបដិវត្តន៍ នៅក្នុងស្រុកដែលរួមមានសមាជិកជនជាតិភាគតិចឥស្លាម និងការរំលោភបំពានផ្សេងៗ ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគាំទ្រដោយអង្គការសហប្រជាជាតិ បានអះអាងថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍។*[294]

---

[290] បទសម្ភាសន៍ជាមួយប្រជាពលរដ្ឋមូលដ្ឋានក្នុងស្រុកត្បូងឃ្មុំ អ្នកភូមិក្នុងតំបន់នៃខេត្តកំពង់ចាម នាថ្ងៃទី 30 ខែតុលាឆ្នាំ 2005។

[291] បញ្ជីឯកសារ ចុះឈ្មោះអ្នកបោះបណ្តោះអាសន្ន ឆ្នាំ 2017 លេខ 10-786-216។

[292] បទសម្ភាសន៍ជាមួយ អ៊ុងផាន ថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ 2001 បទសម្ភាសន៍ជាមួយ អតីតក្រុមអ្នកតំណាង CPK ស្រុកត្បូងឃ្មុំ នៅរាជធានីភ្នំពេញ ថ្ងៃទី 5 ខែកុម្ភៈ ឆ្នាំ 2011។

[293] បទសម្ភាសន៍ស៊ីជំរៅជាមួយ អតីតក្រុមអ្នកតំណាង CPK ស្រុកត្បូងឃ្មុំ នៅរាជធានីភ្នំពេញ ថ្ងៃទី 5 ខែកុម្ភៈ ឆ្នាំ 2011 លោក Henri Locard "តំបន់ 20 ទៅ 24 ភូមិភាគបូព៌ា បានអង្កេតពីថ្ងៃទី 24-26 ខែសីហា  ឆ្នាំ 1993" បទសម្ភាសន៍ជាមួយប្រជាពលរដ្ឋមូលដ្ឋាន រស់នៅក្នុងស្រុកត្បូងឃ្មុំ កាលពីថ្ងៃទី 15 ខែធ្នូ ឆ្នាំ 2014។

[294] អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា )ECCC ឯកសារលេខ (D313/1.2.12; COHCHR "ព័ត៌មានពីអតីតអនុប្រធានពន្ធនាគារ ខេត្តកំពង់ចាម ថ្ងៃទី 23 ខែកក្កដា ឆ្នាំ 1997" ថ្ងៃទី 30 ខែកក្កដា ឆ្នាំ 1997 COHCHR "ការអភិវឌ្ឍនយោបាយ និងយោធា ពាក់ព័ន្ធនឹងរដ្ឋប្រហារ" បទសម្ភាសន៍ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ក្នុងស្រុកត្បូងឃ្មុំ ថ្ងៃទី 15 ខែធ្នូ ឆ្នាំ 2014 ECCC ការិយាល័យសហចៅក្រមស៊ើបអង្កេត ) "ការបិទបញ្ចប់"D427 អង់គ្លេស ទំព័រ (55-58, 108-196។

## *លោក គន់ គីម ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) និងរដ្ឋកម្ពុជា (SOC) ១៩៧៩-១៩៩១*

*លោក គន់ គីម បានគេចផុតពីការបោសសំអាតជាទូទៅមួយរបស់ប៉ុល ពត នៅភូមិភាគបូព៌ាក្នុងខែឧសភា ឆ្នាំ១៩៧៨ ហើយក៏បានចូលរួមជាមួយខ្មែរក្រហមភូមិភាគបូព៌ាផ្សេងទៀត ដែលប៉ុនប៉ងប្រមូលផ្តុំអ្នកតស៊ូទប់ទល់នឹងការបោសសំអាតនេះ។*[295]

*ដូចគ្នានឹងអតីតសមាជិកខ្មែរក្រហមដទៃទៀតដែរ លោក គន់ គីម បានទទួលប្រយោជន៍ពីគោលនយោបាយរបស់វៀតណាម ក្នុងការផ្តល់ការងារដល់អតីតខ្មែរក្រហម ដោយមិនគិតពីអតីតភាពរបស់ពួកគេ ដរាបណាពួកគេបានបង្ហាញភាពស្មោះត្រង់នយោបាយរបស់ខ្លួន ចំពោះសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយជាពិសេស ប្រសិនបើពួកគេពេញចិត្តនឹងការឧបត្ថម្ភពីអតីតមេដឹកនាំតំបន់បូព៌ា ដែលកាន់មុខតំណែងខ្ពស់ ក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជា។*[296] *ដូចគ្នាដែរ ស្របតាមគោលនយោបាយ របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា លោក គន់ គីម មិនបានបន្តតំណែងនៅត្បូងឃ្មុំទៀតទេ ដោយប្រជាពលរដ្ឋនៅទីនោះ បានទាមទារឱ្យដាក់ទណ្ឌកម្មគាត់ ចំពោះការប្រព្រឹត្តរបស់គាត់ក្នុងនាមជាប្រធានការិយាល័យសន្តិសុខនៅតំបន់២១ ក្នុងរបបខ្មែរក្រហម។*[297]

*ជាជំនួសមកវិញ លោក គន់ គីមត្រូវបានគេបញ្ជូនទៅកាន់ខេត្តកណ្តាល ជាកន្លែងដែលគាត់មិនត្រូវបានគេស្គាល់ ហើយក្រោយមកក៏បានក្លាយជាបុគ្គលិកសំខាន់នៅទីនោះ មានការទទួលខុសត្រូវចំពោះការចាប់ខ្លួនអ្នកនយោបាយ និងប្រតិបត្តិការពន្ធនាគារខេត្ត និងកន្លែងផ្សេងទៀត។*[298] *នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ ពន្ធនាគារខេត្តកណ្តាល នៅតាខ្មៅ បានឃុំខ្លួនមនុស្សប្រមាណពីររយនាក់ ដោយគ្មានការចោទប្រកាន់ ឬកាត់ក្តីពីបទល្មើសនយោបាយ និងពីបទចោទព្រហ្មទណ្ឌ។*[299] *ការស៊ើបអង្កេតត្រូវបានធ្វើឡើងតាម*

---

[295] COHCHR "ព័ត៌មានពីអតីតអនុប្រធានពន្ធនាគារ ខេត្តកំពង់ចាម ថ្ងៃទី 23 ខែកក្កដា ឆ្នាំ 1997" ថ្ងៃទី 30 ខែកក្កដា ឆ្នាំ 1997។

[296] (សាធារណរដ្ឋប្រជាមានិតកម្ពុជា) សេចក្តីសម្រេចស្តីពីបញ្ហានៃក្រុមការងារ ]"n.d.] Gottesman: *កម្ពុជាបន្ទាប់ពីខ្មែរក្រហម* ទំព័រ 33, 46, 54, 60, 67-68។

[297] COHCHR "ព័ត៌មានពីអតីតអនុប្រធានពន្ធនាគារ ខេត្តកំពង់ចាម ថ្ងៃទី 23 ខែកក្កដា ឆ្នាំ 1997" ថ្ងៃទី 30 ខែកក្កដា ឆ្នាំ 1997 COHCHR "ការវិវត្តន៍ផ្នែកនយោបាយ និងយោធា ពាក់ព័ន្ធនឹងរដ្ឋប្រហារ"។

[298] បទសម្ភាសន៍ជាមួយ អ៊ុង ផន ថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ 2001 បទសម្ភាសន៍ អ៊ុនតាក់ជាមួយ ពិន ដាំ ថ្ងៃទី 17 ខែកក្កដា ឆ្នាំ 1992 ។

[299] LCIHR, កំណត់សម្គាល់មានចំណងជើងថា "ចំនួនជនជាប់ឃុំ" ខែវិច្ឆិកា ឆ្នាំ 1984 បានរៀបចំសម្រាប់ LCIHR៖ *បន្ទាប់ពីស្ថានភាពអាក្រក់បំផុត*។

*រយៈការធ្វើទារុណកម្ម គឺជាទម្លាប់ អ្នកខ្លះត្រូវបានគេវាយដំយ៉ាងខ្លាំង។ អ្នកខ្លះទៀតបានធ្វើអត្តឃាត ឬបានស្លាប់ ដោយសារការខ្វះអាហារូបត្ថម្ភ និងជំងឺផ្សេងៗ។*[300] *អ្នកដែលត្រូវបានឃាត់ខ្លួន រួមមានទាំងមន្ត្រីផ្ទាល់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវបានគេចោទពីបទទាក់ទងជាមួយពួកអ្នកតស៊ូមិនមែនកុម្មុយនិស្ត ប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា។*[301]

*នៅពេលមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ លោក គន់ គីម បានធ្វើជាអភិបាលរងទីមួយនៃខេត្តកណ្តាលរួចទៅហើយ និងជាសមាជិកថ្នាក់ដឹកនាំនៃគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ប្រចាំខេត្ត។*[302] *គាត់បានដើរតួនាទីយ៉ាងសំខាន់ ក្នុងអំពើហិង្សានយោបាយរបស់គណបក្សប្រជាជនកម្ពុជា និងធ្វើការបំភិតបំភ័យដទៃទៀតនៅក្នុងខេត្ត ក្នុងគោលបំណងជានាទាញយកជ័យជំនះក្នុងការបោះឆ្នោតពីគណបក្សហ៊្វុនស៊ីនប៉ិច និងគណបក្សប្រឆាំងដទៃទៀត ក្នុងការបោះឆ្នោត ដែលរៀបចំដោយអង្គការសហប្រជាជាតិ(អ៊ុនតាក់) នៅខែឧសភា ឆ្នាំ១៩៩៣។*[303] *យោងតាមឯកសារអ៊ុនតាក់ យុទ្ធវិធីរបស់គណបក្សប្រជាជនកម្ពុជាបែបនោះ បានចាប់ផ្តើមតាំងពីដំបូងនៃអំឡុងពេលបោះឆ្នោត នៅក្នុងខេត្តកណ្តាល ក្នុងនោះរួមមានការប្រព្រឹត្តរំលោភលើរាងកាយមនុស្ស ការឃ្លាំមើលគណបក្សប្រឆាំងដទៃទៀតពីនគរបាល និងមន្ត្រីរដ្ឋបាលរបស់គណបក្សប្រជាជនកម្ពុជា ការបដិសេធមិនទទួលស្គាល់សិទ្ធិរបស់គណបក្សប្រឆាំងក្នុងការបង្កើតការិយាល័យ និងការនិយាយបំផ្លើសថា គណបក្សនយោបាយប្រឆាំង ជាអ្នក "រំខានសណ្តាប់ធ្នាប់សង្គម"។*[304] *ពេលវេលាចេះតែកន្លងទៅ ក៏មានរបាយការណ៍កាន់តែច្រើនឡើងអំពីការយាយី និងការបំភិតបំភ័យ និងឧប្បត្តិហេតុបាញ់ប្រហារ និងឃាតកម្មជាបន្តបន្ទាប់ ដែលក្នុងនោះមានបុគ្គលិកអាជ្ញាធរមូលដ្ឋាន នគរបាល និងយោធារបស់គណបក្សប្រជាជនកម្ពុជា ត្រូវបានជាប់ពាក់ព័ន្ធ។*[305] *អ៊ុនតាក់ក៏បានរាយការណ៍ផងដែរថា*

---

300 LCIHR, កំណត់សម្គាល់មានចំណងជើងថា "(សាធារណរដ្ឋប្រជាមានិតកម្ពុជា) ការដកស្រង់" ខែវិច្ឆិកា ឆ្នាំ 1984 បានរៀបចំសម្រាប់ LCIHR៖ *បន្ទាប់ពីស្ថានភាពអាក្រក់បំផុត។*

301 LCIHR កំណត់សម្គាល់ លើបទសម្ភាសន៍ជាមួយ អតីតអ្នកទោសក្នុងពន្ធនាគារខេត្តកណ្តាល ថ្ងៃទី 2 ខែមីនា ឆ្នាំ 1985 រៀបចំសម្រាប់ LCIHR, *បន្ទាប់ពីស្ថានភាពអាក្រក់បំផុត*។

302 អ៊ុនតាក់ "នរណា ជានរណា"

303 បទសម្ភាសន៍អ៊ុនតាក់ជាមួយ ពិន ដាំ បទសម្ភាសន៍អ៊ុនតាក់ជាមួយ កាន ម៉ាន ថ្ងៃទី 2 ខែឧសភា ឆ្នាំ 1993។

304 អ៊ុនតាក់ ខេត្តកណ្តាល" របាយការណ៍សកម្មភាព ពីថ្ងៃទី 8-16 ខែសីហា ឆ្នាំ 1992" អ៊ុនតាក់ "ខេត្តកណ្តាល របាយការណ៍សកម្មភាព ពីថ្ងៃទី 15-30 ខែកញ្ញា ឆ្នាំ 1992" អ៊ុនតាក់ ខេត្តកណ្តាល" របាយការណ៍សកម្មភាព ពីថ្ងៃទី 1-15 ខែតុលា ឆ្នាំ 1992" អ៊ុនតាក់ "របាយការណ៍សកម្មភាព សម្រាប់ខេត្តកណ្តាល ពីថ្ងៃទី 4-29 ខែមករា ឆ្នាំ 1993។"

305 អ៊ុនតាក់ របាយការណ៍សកម្មភាព" សម្រាប់ខេត្តកណ្តាល ពីថ្ងៃទី 7 ខែវិច្ឆិកា ដល់ថ្ងៃទី 8 ខែធ្នូ ឆ្នាំ 1992" អ៊ុនតាក់ "របាយការណ៍សកម្មភាព ខេត្តក

លោក គន់ គីមបានចូលរួមក្នុងការបណ្តេញចេញដោយបង្ខំ អនុវត្តការរុះរើលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ថែមទាំងបានប៉ុនប៉ងក្លែងបន្លំ បញ្ចុះបញ្ចូលជនរងគ្រោះថា អ៊ុនតាក់ជាអ្នកនៅពីក្រោយការបណ្តេញរុះរើផ្ទះរបស់ពួកគេ ប៉ុន្តែទន្ទឹមនឹងគ្នានោះលោក គន់ គីមក៏បានស្នើឱ្យផ្នែកប៉ូលីសស៊ីវិលអ៊ុនតាក់ សហការជាមួយខ្លួនធ្វើអន្តរាគមន៍ប្រឆាំងពលរដ្ឋអ្នកតវ៉ា ។[306] ការប៉ះទង្គិចគ្នារវាងអាជ្ញាធរខេត្ត និងប្រជាជន បានកើតឡើងពីរឿងជម្លោះដីធ្លី ដែលជាប្រធានបទ ត្រូវបានពិភាក្សាច្រើនរវាងអ៊ុនតាក់ និងលោក គន់ គីម ដែលជារឿងធ្ងន់ធ្ងរ ហើយជារឿយៗ ត្រូវបានបដិសេធដោយមន្ត្រីខេត្តចំពោះការទទួលស្គាល់ឯកសារដីធ្លីរបស់ប្រជាជនដែលត្អូញត្អែរអំពីការបង្ខំឱ្យចាកចេញពីដីរបស់ពួកគេ។[307]

## លោក គន់ គីម និងរដ្ឋាភិបាលចម្រុះក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣

ក្រោមការព្រមព្រៀងគ្នាក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ រដ្ឋាភិបាលចម្រុះរវាងហ្វ៊ុនស៊ិនប៉ិច និងស៊ីភីភី (FUNCINPE-CPP) បានត្រូវបង្កើតឡើង។ អភិបាលរងគន់ គីម ប្រចាំខេត្តកណ្តាលត្រូវស្ថិតនៅក្រោមអភិបាលខេត្តមកពីគណបក្សហ្វ៊ុនស៊ីនប៉ិច។ ក្នុងពេលនោះដែរ គាត់ត្រូវបានតែងតាំងជាមន្ត្រីជាន់ខ្ពស់របស់នគរបាលខេត្ត។[308] ក្នុងតំណែងទាំងនេះ គាត់បានគំរាមកំហែងដល់មន្ត្រីគណបក្សហ្វ៊ុនស៊ិនប៉ិចដោយចំហក្នុងអំឡុងពេលកិច្ចប្រជុំផ្សេងៗ។ ក្នុងខណៈនោះដែរ ក៏បានប្រមូលសកម្មជនគណបក្សប្រជាជនកម្ពុជាដោយសម្ងាត់នៅក្នុងខេត្ត ហើយបញ្ជាឱ្យពួកគេឃ្លាំមើលមន្ត្រីហ្វ៊ុនស៊ិនប៉ិច និងសកម្មជននយោបាយនានាមកពីគណបក្សប្រឆាំងតូចៗ។[309]

ក្នុងឆ្នាំ ១៩៩៤-៩៥ លោក គន់ គីម ជាឧបករណ៍ជំនួយរបស់លោក ហ៊ុន សែន ដែលបានចាប់ផ្តើមបង្កើតទីស្នាក់ការថ្មី សម្រាប់សកម្មភាពនយោបាយ និងយោធារបស់គាត់នៅក្នុងតំបន់ទួលក្រសាំងនៃខេត្តកណ្តាល

---

ណ្តាល ពីថ្ងៃទី 1 ខែកុម្ភៈ ដល់ថ្ងៃទី 2 ខែមីនា ឆ្នាំ 1993"; អ៊ុនតាក់ "របាយការណ៍សកម្មភាព សម្រាប់ខេត្តកណ្តាល ពីថ្ងៃទី 4 ដល់ថ្ងៃទី 29 ខែមករា ឆ្នាំ 1993" អ៊ុនតាក់ "ឧប្បត្តិហេតុ និងបញ្ហានានា ពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត "ថ្ងៃទី 27 ខែតុលា ឆ្នាំ 1993 ។

[306] អ៊ុនតាក់ "ខេត្តកណ្តាល របាយការណ៍សកម្មភាព ពីថ្ងៃទី 25 ដល់ថ្ងៃទី 31 ខែកក្កដា ឆ្នាំ 1992" ។

[307] អ៊ុនតាក់ "ខេត្តកណ្តាល របាយការណ៍សកម្មភាព ពីថ្ងៃទី 15 ដល់ថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 1992" អ៊ុនតាក់ "ខេត្តកណ្តាល របាយការណ៍សកម្មភាព ពីថ្ងៃទី 1 ដល់ថ្ងៃទី 15 ខែតុលា ឆ្នាំ 1992។

[308] បទសម្ភាសន៍ជាមួយហ៊ុនសែន ថ្ងៃទី 21 ខែកញ្ញា ឆ្នាំ 2007។

[309] . អ៊ុនតាក់ "បទសម្ភាសន៍ជាមួយ ចក់ សារិក " ថ្ងៃទី10 ខែកញ្ញា ឆ្នាំ 1993 ។

ដែលត្រូវបានគេចោទថា ជាផ្នែកមួយនៃការបញ្ជូនមូលនិធិបានមកពីការគំរាមទារប្រាក់ និងការស៊ីសំណូកក្នុងស្រុក។[310] ក្រោយពីនោះមក លោក ហ៊ុន សែន មានមូលដ្ឋានគ្រឹះប្រកបដោយប្រសិទ្ធភាព ចេញពីបរិវេណដែលមានការការពារកាន់តែរឹងមាំនៅឯទួលក្រសាំង ដែលចាប់ពីនោះមក គាត់ក៏បានដឹកនាំកងកម្លាំងប្រដាប់អាវុធរបស់កងយោធពលខេមរភូមិន្ទ និងកងកម្លាំងសន្តិសុខដទៃទៀត ក្រោមការគ្រប់គ្រងរបស់គាត់ផ្ទាល់។[311] ខេត្តកណ្តាលក៏បានបម្រើជាអាងស្តុកសម្រាប់ការជ្រើសរើសកងកម្លាំងទាំងនោះ។[312]

នៅឆ្នាំ១៩៩៥ លោក គន់ គីម បានរៀបចំសារសំខាន់មួយស្តីពីការគាំទ្រជាសាធារណៈដល់លោក ហ៊ុន សែន បន្ទាប់ពីចាប់ឃុំព្រះកាយសម្តេចក្រុមឃុន នរោត្តម សេរីវុធ រដ្ឋមន្ត្រីក្រសួងការបរទេសរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលជាអ្នករិះគន់ខ្លាំងបំផុតម្នាក់របស់នាយករដ្ឋមន្ត្រីទី២ ។[313] លោក គន់ គីម ក៏បានរៀបចំទទួលលោក ហ៊ុន សែន ឱ្យមានការថ្លែងសុន្ទរកថាមួយនៅខេត្តកណ្តាល ដែលពេលនោះលោក ហ៊ុន សែន បានបញ្ជាឲ្យសមាសភាពគណបក្សប្រជាជនកម្ពុជាពីកងយោធពលខេមរភូមិន្ទ កងពលលេខ៧០ អង្គភាពចារកម្មនៃកងកម្លាំងប្រដាប់អាវុធបញ្ជាការកំពូល បុគ្គលិកកងកម្លាំងប្រដាប់អាវុធទូទៅ ផ្នែកស៊ើបការណ៍ និងប្រឆាំងភេរវកម្ម របស់ប៉ូលីសជាតិ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស (GRK) ត្រូវ"ចាត់វិធានការទុកជាមុន" ដើម្បី"កំចាត់ចោលទាំងស្រុង" នូវអ្វីដែលគាត់ហៅថា "ពួកភេរវករ" ដែលប្រឆាំងនឹងគាត់ បំផ្លាញ "សំបុកភេរវករ" ហើយសម្លាប់ពួកគេ ប្រសិនបើចាំបាច់ ព្រោះថា ប្រសិនបើពួកគេត្រូវបានអនុញ្ញាតឱ្យរស់នៅ ពួកគេអាចជា "ដង្កូវបំផ្លាញសង្គម និងប្រទេសជាតិ"។[314] នេះជាការវិវត្តមួយក្នុងចំណោមសកម្មភាពដែលបានកើតឡើងជាច្រើន ដែលត្រូវបានសង្កេតឃើញដោយអ្នកសង្កេតការណ៍ជាច្រើន ដែលជាផ្នែកមួយនៃការចាប់ផ្តើមរបស់លោក ហ៊ុន សែន ក្នុងការ "ពង្រីកពង្រឹងកម្លាំងរដ្ឋប្រហារប្រឆាំងនឹងរាជរដ្ឋាភិបាល

---

310 កងវរសេនាតូចពិសេស កងទ័ពទី 2 PM" កម្ពុជាថ្ងៃនេះ ថ្ងៃទី 29 ខែវិច្ឆិកា ឆ្នាំ 1995 បទសម្ភាសន៍ជាមួយ ពិន ដាំ ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 1997។

311 "ហ៊ុន សែន គាំទ្រអ្នកចុះចូលពីនរោត្តម រណរិទ្ធ នៅពេលការមិនចុះសម្រុងគ្នាកាន់តែរីកធំ" AFP តាខ្មៅ ថ្ងៃទី 19 ខែមេសា ឆ្នាំ1997 "យោធាកម្ពុជាសន្យាថារក្សាអព្យាក្រឹត្យភាព ប៉ុន្តែការគំរាមកំហែងនៅតែមាន "Reuters ក្រុងភ្នំពេញ ថ្ងៃទី27 ខែមេសា ឆ្នាំ1997 "ប្រទេសកម្ពុជា៖ រដ្ឋប្រហារបែបទន់ (Soft Coup) " សេដ្ឋវិទូរ ថ្ងៃទី26 ខែមេសា ឆ្នាំ1997។

312 អង្គភាពអង្គរក្សលោក ហ៊ុន សែន "សំណើរបំពេញកងកម្លាំងចំនួន 1.500 នាក់ ដោយស្នើសុំ 283 នាក់ យកចេញពីប្រតិបត្តិការសឹករងយោធាភូមិភាពខេត្តកណ្តាល) "135/97) ថ្ងៃទី 26 ខែមេសា ឆ្នាំ 1997។

313 "ហ៊ុន សែន និយាយថា គ្រោះថ្នាក់ឃាតកម្មនៅតែមាន" កាសែតដឹខេមបូឌា ដេលី ថ្ងៃទី 27 ខែវិច្ឆិកា ឆ្នាំ 1995។

314 វិទ្យុភ្នំពេញ, ថ្ងៃទី 26 ខែវិច្ឆិកា ឆ្នាំ 1995។

ដែលខ្លួនគាត់គឺជាផ្នែកមួយនៃរដ្ឋាភិបាលដែរ ក្នុងគោលបំណង "សំដៅទៅរក "ការបំផ្លាញគណបក្សប្រឆាំងទាំងអស់មុនពេលការបោះឆ្នោតខាងមុខ" ដែលគ្រោងធ្វើនៅឆ្នាំ១៩៩៨។[315]

យោងតាមកំណត់ត្រាអង្គការសហប្រជាជាតិ ក្នុងកិច្ចប្រជុំសម្ងាត់របស់មេដឹកនាំគណបក្សប្រជាជនកម្ពុជា នៅខែមេសា ឆ្នាំ១៩៩៦ លោក គន់ គីម បានថ្លែងគាំទ្រលោក ហ៊ុន សែន ដែលស្នើឱ្យកងកម្លាំងប្រដាប់អាវុធក្រោមការគ្រប់គ្រងរបស់គណបក្សប្រជាជនកម្ពុជា ប្រើកម្លាំងដើម្បីដោះស្រាយជម្លោះជាមួយហ៊្វុនស៊ិនប៉ិច។[316] នៅខែឧសភា បន្ទាប់ពីលោក ហ៊ុន សែន បានប្រាប់សកម្មជនគណបក្សប្រជាជនកម្ពុជា នៅខេត្តកណ្តាលថា លោកបានត្រៀមខ្លួនរួចហើយ ដើម្បីចេញពីទីបញ្ជាការរបស់លោកនៅក្នុងខេត្ត ដើម្បីប្រើ "កណ្តាប់ដៃដែក" ប្រឆាំងនឹងគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនយោបាយប្រឆាំងថ្មីមួយដែលដឹកនាំដោយលោក សម រង្ស៊ីនោះ នគរបាលដែលគាំទ្រលោក គន់ គីម ក៏បានបាញ់ទៅលើអាកាស ដើម្បីរារាំងគណបក្សសមរង្ស៊ី មិនឱ្យធ្វើសកម្មភាព នៅក្នុងខេត្តនេះ។[317] របាយការណ៍របស់អង្គការសហប្រជាជាតិបានចេញផ្សាយថា បន្ទាប់មកលោក គន់ គីម បានក្លាយជាជនដៃដៅរបស់ លោក ហ៊ុន សែន ហើយត្រូវលោក ហ៊ុន សែន តែងតាំងផ្លូវការ ជា "បេសកជនពិសេស" របស់គាត់។[318]

បន្ទាប់ពីមានការវាយប្រហារដោយគ្រាប់បែកដៃ នៅពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៩៧ ទៅលើបាតុកម្ម ដឹកនាំដោយលោក សម រង្ស៊ី ដែលក្នុងនោះមនុស្សយ៉ាងហោចណាស់១៦នាក់ត្រូវបានសម្លាប់ និងលើសពី១៥០នាក់ ទៀតត្រូវបានរងរបួស មន្ត្រីការិយាល័យស៊ើបអង្កេតសហព័ន្ធអាមេរិក (FBI) ដែលបានមកប្រទេសកម្ពុជា ស៊ើបអង្កេតលើហេតុការណ៍វាយប្រហារនោះ ទទួលបានដំណឹងអំពីការចោទប្រកាន់ថា លោក គន់ គីម មានជាប់ពាក់ព័ន្ធនៅក្នុងប្រតិបត្តិការគប់គ្រាប់បែកនេះ តាមរយៈជួយធានាឲ្យជនល្មើសរួចផុតពីការចាប់ខ្លួន ។[319] ក្រោយការវាយប្រហារនេះមក ការឃាត់ខ្លួនសមាជិកគណបក្សសមរង្ស៊ីជាច្រើននាក់នៅខេត្តក

---

[315] "អំពើពុករលួយបំផ្លាញអនាគតកម្ពុជា" អូស្រ្តាលីចុងសប្តាហ៍ ថ្ងៃទី 25 ខែវិច្ឆិកា ឆ្នាំ 1995។

[316] "របាយការណ៍ប្រចាំខែសម្រាប់ខែឧសភាឆ្នាំ 1996"។

[317] UNOSGRC របាយការណ៍ប្រចាំសប្តាហ៍ លេខ 89 គ្របដណ្តប់រយៈពេលចាប់ពីថ្ងៃទី 27 ខែមេសាដល់ថ្ងៃ ទី 5 ខែឧសភា ឆ្នាំ 1996" UNOSGRC "របាយការណ៍ប្រចាំសប្តាហ៍ លេខ 95 គ្របដណ្តប់រយៈពេលចាប់ពី ថ្ងៃទី 16 ដល់ 23 ខែមិថុនា ឆ្នាំ 1996"។

[318] UNOSGRC "របាយការណ៍ប្រចាំខែ សម្រាប់ខែមករា ឆ្នាំ 1997" អត្ថបទ "ផ្កាយព្រឹកចក្រ "វ៉ាំឡូ ថ្ងៃទី 14 ខែសីហា ឆ្នាំ 1997។

[319] ហ៊្វុនស៊ិនប៉ិច "របាយការណ៍ពិសេស" ថ្ងៃទី8 និង 14 ខែឧសភា ឆ្នាំ 1997; លិខិតពី James P. Doran សមាជិកបុគ្គលិកវិជ្ជាជីវៈ ផ្នែកកិច្ចការអាស៊ីប៉ូពាំ នៅគណៈកម្មាធិការព្រឹទ្ធសភាអាមេរិក ស្តីពីទំនាក់ទំនងបរទេស ទៅកាន់ Jesse Helms ប្រធានគណកម្មាធិការ ទំនាក់ទំនងបរទេស ព្រឹទ្ធសភាសហរដ្ឋ

*ណ្ដាលក៏កើតមាន។*[320]

## *លោក គន់ គីម រដ្ឋប្រហារឆ្នាំ ១៩៩៧ និង ការបោះឆ្នោតឆ្នាំ ១៩៩៨*

*ក្នុងប៉ុន្មានថ្ងៃមុនរដ្ឋប្រហារ កងកម្លាំងស្មោះត្រង់នឹងលោក ហ៊ុន សែន បានដកអាវុធពីកងអង្គរក្សការពារសម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិមួយចំនួនធំ ហើយបានគំរាមកងកម្លាំងដែលនៅសេសសល់របស់ព្រះអង្គដោយការចាប់ខ្លួន ប្រសិនបើពួកគេមិនព្រមចុះចាញ់។ ក្រុមរបស់លោក ជា ស៊ីម និង លោក ស ខេង ព្រមទាំងសម្ព័ន្ធមិត្តរបស់ពួកគេទាំងពីរនៅក្នុងគណបក្សប្រជាជនកម្ពុជា ក្នុងនោះមានអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទលោក កែ គឹមយ៉ាន ផងបានប្រឆាំងនឹងអំពើបះបោរប្រដាប់អាវុធនេះ។ ប៉ុន្តែលោក ហ៊ុន សែន ពឹងផ្អែកលើកងកម្លាំងសន្តិសុខដែលមានភក្តីភាពចំពោះគាត់ រួមមានកងអង្គរក្សរបស់គាត់ ក្រុមកងទ័ពដែលគាំទ្រគាត់ កងរាជអាវុធហត្ថ (GRK) និងប៉ូលិស ដើម្បីអនុវត្តសកម្មភាពនេះ។*[321]

*លោក ហ៊ុន សែន បានបញ្ជាឱ្យធ្វើរដ្ឋប្រហារនៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ ចេញពីមូលដ្ឋានទួលក្រសាំងរបស់គាត់ ក្នុងខេត្តកណ្ដាល ប្រឆាំងគណបក្សហ៊្វុនស៊ិនប៉ិច និងក៏បានតម្រង់គោលដៅកំចាត់នេះទៅលើគណបក្សសមរង្ស៊ីដែរ ។ លោក គន់ គីម នៅក្បែរលោក ហ៊ុន សែន ដើរតួជាគូឈ្លួយផ្នែកសឹក និងជាមេបញ្ជាការផ្នែកយុទ្ធសាស្ត្រ ក្នុងប្រតិបត្តិការប្រឆាំងនឹងអ្វីដែលលោក ហ៊ុន សែនបានថ្កោលទោសថា ជា "កម្លាំងអនាធិបតេយ្យ" ដែលគាត់ប្រើសម្រាប់អ្នកប្រឆាំងនឹងគាត់ ។*[322] *លោក គន់ គីមបានបញ្ជាទៅអង្គភាពគណបក្សប្រជាជនកម្ពុជា ដែលស្មោះស្ម័គ្រនឹងលោក ហ៊ុន សែន ឲ្យធ្វើការវាយប្រហារ រួមទាំងកម្លាំងដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់លោកផង។*[323] *ក្នុងចំណោមអ្នកទាំងនោះ មានកងកម្លាំងពីតំបន់*

---

អាមេរិក ថ្ងៃទី 21 ខែកញ្ញា ឆ្នាំ 1999។

[320] COHCHR "ការចាប់ខ្លួនមន្ត្រីគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលបានរាយការណ៍ នៅតាមខេត្តនានា] "n.d. ]។

[321] អង្គការឃ្លាំមើលសិទ្ធិមនុស្សយូមែនរ៉ៃត៍វ៉ច្ឆ " ប្រាប់ពួគេថា ខ្ញុំចង់សម្លាប់ពួកគេ" ទំព័រ40 ។

[322] កិច្ចសម្ភាសន៍ជាមួយ ហ៊ុន សែន ថ្ងៃទី 21 ខែកញ្ញា ឆ្នាំ 2007

[323] (Brad Adams) កិច្ចសម្ភាសជាមួយ មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជន និងកងកម្លាំងរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច និងមន្ត្រីស៊ីវិល ថ្ងៃទី 27 ខែវិច្ឆិកា ឆ្នាំ 1999 ថ្ងៃទី 23 កុម្ភៈ ឆ្នាំ 2000 និង ថ្ងៃទី 15 ខែកុម្ភៈ ឆ្នាំ 2000 ។ COHCHR "ព័ត៌មានពី សំ កន្និថា និង ម៉ៅញ សុផាន "ថ្ងៃទី 19 ខែកក្កដា ឆ្នាំ 1997 (Brad Adams) បទសម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់ របស់កងយោធពលខេមរភូមិន្ទ នៅថ្ងៃទី 1 ខែមីនា ឆ្នាំ 2001 និង ថ្ងៃទី 15 ខែកុម្ភៈ ឆ្នាំ 2000។

*ប្រតិបត្តការសឹករង និងប៉ូលីសខេត្តកណ្តាល។[324] សារបញ្ជារបស់លោក ហ៊ុន សែន បានបញ្ជាក់ថា ពួកគេត្រូវតែ "បោសសំអាត" កម្លាំងអនាធិបតេយ្យ និងកំចាត់ចោលពួកវាឱ្យស្អាតទាំងអស់ ។ពាក្យថា បោសសំអាត និងកំចាត់ចោលគឺជាពាក្យដែលខ្មែរក្រហមនិយមប្រើជំនួសឱ្យពាក្យថា "ប្រហារជីវិត"។[325]*

*រដ្ឋប្រហារដ៏ជោគជ័យរបស់លោក ហ៊ុនសែន ត្រូវបានបន្តដោយរលកនៃការកាប់សម្លាប់ក្រៅប្រព័ន្ធតុលាការ ការបូជាសពដែលគេមិនស្គាល់អត្តសញ្ញាណ នៅក្នុងស្ថានភាពគួរឱ្យសង្ស័យ ការធ្វើទារុណកម្ម និងការឃុំឃាំងតាមអំពើចិត្ត។ ជនរងគ្រោះភាគច្រើន គឺជាសមាជិកនៃកងកម្លាំងសន្តិសុខរបស់ហ៊ុនស៊ិនប៉ិច។[326] លោក គន់ គីម ទទួលខុសត្រូវគ្រប់គ្រងលើការតាមដានសកម្មជនគណបក្សប្រឆាំងនៅខេត្តកណ្តាល។[327] សាកសពមួយចំនួន ត្រូវបានគេប្រទះឃើញនៅមិនឆ្ងាយពីទួលក្រសាំង។[328] សាកសពដទៃទៀត ត្រូវបានគេប្រទះឃើញនៅទីតាំងផ្សេងទៀត ក្នុងខេត្តកណ្តាល ជាកន្លែងដែលមានការដាក់ពង្រាយកងកម្លាំងដែលស្មោះស្មគ្រចំពោះលោក គន់ គីម។[329]*

*ភ្លាមៗបន្ទាប់ពីរដ្ឋប្រហារ លោក គន់ គីម នៅខណៈជាអភិបាលរងខេត្តកណ្តាល ក៏មានតួនាទីគ្រប់ គ្រងបញ្ជាលើកងយោធពលខេមរភូមិន្ទថែមទៀត។[330] នៅខែសីហា លោក ហ៊ុន សែន បានផ្តល់ឱ្យគាត់នូវឋានៈថ្មីទៀត គឺឋានៈជារដ្ឋមន្ត្រីរដ្ឋាភិបាល។[331] គាត់ក៏ បានផ្តល់ឲ្យផងដែរនូវតំណែងមួយទៀតគឺ "ជាទីប្រឹក្សាកិច្ច*

---

[324] (Brad Adams) បទសម្ភាសជាមួយមន្ត្រីអង្គការសហប្រជាជាតិ និងមន្ត្រីគណបក្សប្រជាជនជាច្រើន ឆ្នាំ 1997, 1998, 1999, 2000, 2001; (Brad Adams) បទសម្ភាសជាមួយមន្ត្រីប៉ូលីសខេត្ត ថ្ងៃទី 21 ខែធ្នូ ឆ្នាំ 2002 ។

[325] បទសម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា ថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2004 បទសម្ភាសន៍ជាមួយ ហ៊ុន សែន ថ្ងៃទី 21 ខែកញ្ញា ឆ្នាំ 2007 សូមមើល ECCC ការិយាល័យសហចៅក្រមស៊ើបអង្កេត "ដីកាបិទ" (D427 English) ទំព័រ 48, 51, 58, 188, 202-5, 233-4 និង 266 ។

[326] អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ប្រាប់ពួកគេថា ខ្ញុំចង់សម្លាប់ពួកគេ" ទំព័រ 40។

[327] បទសម្ភាសន៍ជាមួយ ពិន ដាំ រាជធានីភ្នំពេញ ថ្ងៃទី 8 ខែកក្កដា ឆ្នាំ 1997។

[328] COHCHR "សាកសពទាហានអណ្តែតទឹក នៅទន្លេបាសាក់ ពី 3 ទៅ 5 នាក់ - ក្នុងស្រុកស្អាង ខេត្តកណ្តាល" ថ្ងៃទី 29 ខែកក្កដា ឆ្នាំ 1997។

[329] COHCHR "ព័ត៌មានពីលោកឧត្តមសេនីយ៍ឯក អ៊ំ ពិសិដ្ឋ មេបញ្ជាការរង នៃអង្គភាព អន្តរាគមន៍អគ្គសេនាធិការ និងប្រពន្ធរបស់គាត់ "ថ្ងៃទី 20 ខែកក្កដា ឆ្នាំ 1997; COHCHR "ព័ត៌មានពីប្រពន្ធរបស់ លោក សេរី កុសល ថ្ងៃទី 22 ខែកក្កដា ឆ្នាំ 1997" ថ្ងៃទី 22 ខែកក្កដា ឆ្នាំ 1997; COHCHR "ការចោទប្រកាន់ពីឧក្រិដ្ឋកម្ម ក្រៅប្រព័ន្ធច្បាប់ "ថ្ងៃទី 31 ខែកក្កដា ឆ្នាំ 1997 COHCHR "លទ្ធភាពនៃការ កំណត់អត្តសញ្ញាណ នៃ មនុស្សបីនាក់ដែលត្រូវបានធ្វើឃាត តាមបណ្តោយផ្លូវជាតិ 6A" ថ្ងៃទី 7 ខែសីហា ឆ្នាំ 1997; COHCHR "ព័ត៌មានពី ប្រភពហ៊ុនស៊ិនប៉ិច "ថ្ងៃទី 8 ខែសីហា ឆ្នាំ 1997; COHCHR "សង្ខេបឃាតកម្មទាំងបី នៅលើផ្លូវជាតិលេខ 6A ឆ្លងកាត់ស្ពានជ្រោយចង្វារ "ថ្ងៃទី 10 ខែសីហា ឆ្នាំ 1997។

[330] COHCHR "ការវិវត្តន៍ផ្នែកនយោបាយ និងយោធា ពាក់ព័ន្ធនឹងរដ្ឋប្រហារ"។

[331] ចក្រវ៉ាល ថ្ងៃទី 14 ខែសីហា ឆ្នាំ 1997។

*ការទូទៅ" របស់លោក ហ៊ុន សែន។[332] លោក គន់ គីម បានផ្តល់ឱកាសប្រើប្រាស់ទាំងឋានានុក្រមផ្នែកនយោបាយ និងយោធារបស់គាត់ដែលកាន់តែខ្ពស់នេះ រកលុយពីការកាប់ឈើទាំងស្របច្បាប់ និងខុសច្បាប់ ដោយប្រើប្រាស់កងកម្លាំងយោធាយោធភូមិភាគ ២ និង៤ ក្នុងការសហការជាមួយអភិបាលខេត្តកំពង់ចាម លោក ហ៊ុន ណេង ដែលជាបងប្រុសរបស់លោក ហ៊ុន សែន និងសាច់ញាតិលោក ហ៊ុន សែន ដទៃទៀត។[333]*

*ទាំងនេះ បានជួយឱ្យលោក គន់ គីម បង្កើនកម្លាំង និងចំនួនថវិកាសម្រាប់យុទ្ធនាការឃោសនារបស់គណបក្សប្រជាជនកម្ពុជា សម្រាប់ការបោះឆ្នោតជាតិនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបានធ្វើឱ្យគណបក្សប្រជាជនកម្ពុជា អាចប្រជែងឈ្នះ មេដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី ដែលទើបនឹងបង្កើត។ ទោះបីកាន់តំណែងជាមន្ត្រីយោធាជាន់ខ្ពស់ម្នាក់ក៏ដោយ ក៏លោក គន់ គីមបានធ្វើយុទ្ធនាការឃោសនាយ៉ាងស្វិតស្វាញសម្រាប់គណបក្សប្រជាជនកម្ពុជា ក្នុងខេត្តកណ្តាល។[334] ក្នុងយុទ្ធនាឃោសនាបោះឆ្នោតមានហ្វូងមនុស្សជាច្រើនចូលរួមគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី ធ្វើឱ្យប្រជាជនមួយចំនួនក្នុងគណបក្សប្រជាជនកម្ពុជាមានការភ្ញាក់ផ្អើល និងព្រួយបារម្ភដោយសារតែការកើនឡើងនូវចំនួនអ្នកប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជា ហើយគណបក្សមួយនេះក៏បានចាប់ផ្តើមរៀបចំ "សេណារីយ៉ូសម្រាប់ករណីដ៏អាក្រក់បំផុត"។[335] នៅពាក់កណ្តាលខែកក្កដា ចលនាកងទ័ពចំណុះគណបក្សប្រជាជនកម្ពុជា ក៏បានចាប់ផ្តើម។ នោះគឺជាការឆ្លុះបញ្ចាំងនៃការចល័តទ័ពរបស់លោក គន់ គីមនៃសមាសភាពទ័ពចំណុះលោក ហ៊ុន សែន នៅក្នុងកងយោធពលខេមរភូមិន្ទ កងពលតូចលេខ៧០ និងលេខ៩១១ យោធភូមិភាគពិសេស (រួមទាំងខេត្តកណ្តាល) និងយោធភូមិនភាគ ២ ដោយធ្វើតេស្តសាកល្បងនូវភាពត្រៀមខ្លួនរួចជាស្រេច ក្នុងករណីដែលលោក ហ៊ុន សែន ជួបបញ្ហានយោបាយ ។[336] នៅមុនថ្ងៃបោះឆ្នោត លោក ហ៊ុន សែន បានបញ្ជាឱ្យមានការរៀបចំដើម្បីប្រឆាំងតបតចេញពីខេត្តកណ្តាល និងពីកន្លែងដទៃផ្សេងទៀត*

---

332 វិហារកាតូលិកអាស៊ី ឯកសារលេខ 1/2000-16/01/2000: លោក Francois Ponchaud, "កម្ពុជា :ចំណុចមួយលើស្ថានភាពនយោបាយ និងសង្គម ចាប់ពីថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 1999 ដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1999" ខែមករា ឆ្នាំ 2001 ។

333 Global Witness, ទៅដល់ទីកន្លែង ...អនាគតរបស់ប្រទេសកម្ពុជានៅលើការផ្លាស់ប្តូរ ខែមិនា ទីក្រុងឡុងដ៍ ឆ្នាំ1998។

334 COHCHR "ប្រព័ន្ធផ្សព្វផ្សាយ និងការបោះឆ្នោត៖ ស្ថិតិដែលបានធ្វើបច្ចុប្បន្នភាព ថ្ងៃទី 23 ខែកក្កដា ឆ្នាំ 1998។"

335 "បុរសខ្លាំងកម្ពុជា ដែលមានអារម្មណ៍ថា កំដៅនៃគណបក្សប្រឆាំង ឈ្នះការគាំទ្រ " Reuters ភ្នំពេញ ថ្ងៃទី 12 ខែកក្កដា ឆ្នាំ 1998។

336 គណបក្សសមរង្ស៊ី "បណ្តឹងឧទ្ធរណ៍ដើម្បីអោយមានដំណើរការបោះឆ្នោតដែលគ្មានយោធា" ភ្នំពេញ ថ្ងៃទី 16 ខែកក្កដា ឆ្នាំ 1998 បទសម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា ថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2004។

ប្រសិនបើគណបក្សប្រឆាំងឈ្នះការបោះឆ្នោត។[337]

នៅក្នុងព្រឹត្តិការណ៍នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា បានប្រកាសថា គណបក្សប្រជាជនឈ្នះ ៤១ ភាគរយនៃការបោះឆ្នោត ស្មើនឹង៦៤អាសនៈក្នុងចំណោមអាសនៈចំនួន ១២២ នៅក្នុងសភាជាតិ។ គណបក្សប្រជាជនកម្ពុជា ចាញ់យ៉ាងធ្ងន់ធ្ងរនៅមណ្ឌលខេត្តកណ្ដាល ឆ្លុះបញ្ចាំងពីការបាត់បង់ប្រជាប្រិយភាពរបស់លោក គន់ គីម និងលោក ហ៊ុន សែន នៅទីនោះ។ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី បានជំទាស់ទាំងស្រុង ទាក់ទងនឹងការរាប់សន្លឹកឆ្នោត និងការអនុវត្តរូបមន្តបែងចែកអាសនៈ ដោយចោទប្រកាន់ថា មានការក្លែងបន្លំ និងការបកស្រាយមិនត្រឹមត្រូវតាមរូបមន្ត។[338] ជាការឆ្លើយតប អាជ្ញាធរមូលដ្ឋានរបស់គណបក្សប្រជាជនកម្ពុជា បានធ្វើយុទ្ធនាការរំខាន និង គំរាមកំហែង ប្រឆាំងនឹងសកម្មជនគណបក្សហ៊្វុនស៊ិនប៉ិច និងសកម្មជនគណបក្សសមរង្ស៊ី ញុំាងឱ្យមនុស្សរាប់រយនាក់ភ័យខ្លាចរត់ទៅជ្រកកោននៅការិយាល័យបក្សនៅតាមបណ្ដាខេត្ត និងទីក្រុង។[339] នៅខេត្តកណ្ដាល ប្រតិបត្តិការបង្រ្កាបបំភិតបំភ័យនេះ ត្រូវបានរៀបចំឡើង ដោយ លោក គន់ គីម ដោយមានការជ្រោមជ្រែងពីកងកម្លាំងប៉ូលិស និងកងរាជអាវុធហត្ថ។[340]

នៅថ្ងៃទី១៨-១៩ ខែសីហា ឆ្នាំ១៩៩៨ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី បានស្នើសុំអាជ្ញាធររាជធានីភ្នំពេញ "ធ្វើបាតុកម្មដោយសន្តិវិធី និងអហិង្សា" នៅថ្ងៃទី២៣ ខែសីហា ដើម្បីទាមទារឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ដោះស្រាយបណ្ដឹងអំពីការបោះឆ្នោត។[341] ជាការឆ្លើយតប "គណៈបញ្ជាការ" រាជធានីភ្នំពេញរបស់គណបក្សប្រជាជនកម្ពុជា រួមទាំងស្នងការនគរបាលរាជធានីភ្នំពេញ លោក នេត សាវឿន បានផ្ដើមប្រជុំជាទៀងទាត់ ដើម្បីរៀបចំផែនការ របៀបការពារ និងបង្រ្កាបការជួបជុំគ្នា ដោយធ្វើតាមបញ្ជាផ្ទាល់របស់លោក ហ៊ុន សែន លោក គន់ គីម មេនគរបាលជាតិ លោក ហុក ឡុងឌី និងមេ

---

[337] COHCHR, "អនុស្សរណៈ " ថ្ងៃទី 16 ខែកក្កដា ឆ្នាំ 1998។

[338] អង្គការវិបត្តិអន្តរជាតិ "ការបោះឆ្នោតនៅប្រទេសកម្ពុជា" ថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 1998។

[339] អង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែនរ៉ៃត៍វ្ជ "ប្រទេសកម្ពុជា៖ សកម្មជនគណបក្សប្រឆាំងក្លាយជាគោលដៅសងសឹកក្រោយការបោះឆ្នោត " ថ្ងៃទី 10 ខែសីហា ឆ្នាំ 1998។

[340] អង្គការខុមហ្វ្រែល (COMFREL) និងនិកហ្វិក (NICFEC)៖បញ្ជីឈ្មោះរដ្ឋសភាអាណត្តិទី 3 ឆ្នាំ 2003-2008 (ភ្នំពេញ :ខែមិថុនាឆ្នាំ 2005) ទំព័រ 93។

[341] គណបក្សសមរង្ស៊ី "ជូនចំពោះអភិបាលរាជធានីភ្នំពេញ" ថ្ងៃទី 18 ខែសីហា ឆ្នាំ 1998។ គណបក្សហ៊្វុនស៊ិនប៉ិក និងគណបក្សសមរង្ស៊ី "ជូនចំពោះអភិបាលរាជធានីភ្នំពេញ "ថ្ងៃទី 19 ខែសីហា ឆ្នាំ 1998។

*បញ្ហាការវេងកងរាជអាវុធហត្ថជាតិលោក សៅ សុខា។[342] ទោះជាមានការខិតខំប្រឹងប្រែងរបស់កងកម្លាំងសន្តិសុខខេត្ត ជាពិសេសពីនគរបាលខេត្តកណ្តាល និងក្រុមកងអាវុធហត្ថ ដើម្បីទប់ស្កាត់អ្នកគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច និងអ្នកគាំទ្រគណបក្សសមរង្ស៊ី មិនឱ្យចូលមកក្នុងរាជធានីភ្នំពេញក្តី ក៏ហ្វូងមនុស្ស ១០,០០០ (មួយម៉ឺន)នាក់ មកពីទីក្រុង និងទីជនបទ បានមកចូលរួមបាតុកម្មនៅថ្ងៃទី២៣ ខែសីហា នៅក្នុងទីក្រុងភ្នំពេញ។[343] នៅថ្ងៃទី២៤ ខែសីហា អ្នកគាំទ្រគណបក្សប្រឆាំង បានចាប់ផ្តើមអង្គុយនៅសួនច្បារវត្តបទុមវត្តីទល់មុខអាគារសភាជាតិ (ក្បែរព្រះបរមរាជវាំង)ដែលត្រូវបានគេសន្មត់ដាក់ថា "ទីលានប្រជាធិបតេយ្យ"។[344] នៅថ្ងៃទី២៦ ខែសីហា ប្រព័ន្ធផ្សព្វផ្សាយគាំទ្រគណបក្សប្រជាជនកម្ពុជា បានរាយការណ៍ថា អ្នកគាំទ្រ៤០,០០០ (បួនម៉ឺន)នាក់របស់គណបក្សប្រជាជនកម្ពុជា បានត្រៀមខ្លួនជាស្រេច ដើម្បីប្រឆាំងនឹងបាតុកម្ម ហើយគណបក្សប្រជាជនកម្ពុជានៅខេត្តកណ្តាល បានសន្យាថា នឹងរៀបចំកងកម្លាំងឱ្យបានទំហំប៉ុននោះ។[345]*

*ដោយមិនអើពើចំពោះបញ្ហានេះ និងការគំរាមកំហែងផ្សេងៗទៀត បាតុករអ្នកគាំទ្រគណបក្សប្រឆាំង បានចាប់ផ្តើមហែរក្បួនជាបន្តបន្ទាប់ ហើយបាតុកម្មទ្រង់ទ្រាយធំនៅរាជធានីភ្នំពេញកាន់តែរីកសាយភាយ ខណៈដែលមានការប្រមូលផ្តុំកាន់តែច្រើនឡើងនៅទីលានប្រជាធិបតេយ្យ អំពាវនាវឱ្យលោក ហ៊ុន សែន ចុះចេញពីតំណែង។[346] នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៨ គ្រាប់បែកដៃបីគ្រាប់ត្រូវបានគេគ្រវែងចូលទៅក្នុងបរិវេណគេហដ្ឋានដែលគ្មានមនុស្សរស់នៅរបស់លោក ហ៊ុន សែន នៅកណ្តាលរាជធានីភ្នំពេញ។ អង្គការសហប្រជាជាតិ បានសន្និដ្ឋានថា ការវាយប្រហារនេះទំនងជាត្រូវបានរៀបចំឡើងដោយលោក ហុក ឡុងឌី ដើម្បីបង្កើតលេសបង្ក្រាបសកម្មភាពតវ៉ារបស់គណបក្សប្រឆាំង។[347] ភ្លាមៗក្រោយហេតុការណ៍បំផ្ទុះគ្រាប់បែក លោក*

---

[342] បទសម្ភាសន៍ជាមួយ មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា ថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2004។

[343] COHCHR "របាយការណ៍តាមដាន តាមទូរស័ព្ទ ពីខេត្តកណ្តាល "ថ្ងៃទី23 ខែសីហា ឆ្នាំ 1998។ "មនុស្សរាប់ពាន់នាក់ ប្រឆាំងនឹងការហាមឃាត់ និងការចូលរួមការតវ៉ា នៅកម្ពុជា "Reuters ថ្ងៃទី 23 ខែសីហា ឆ្នាំ 1998។

[344] គណបក្សសមរង្ស៊ី "មនុស្សរាប់ពាន់នាក់ បានចាប់ផ្តើមចូលឧទ្យាន"ថ្ងៃទី 24 ខែសីហា ឆ្នាំ 1998 "ការប្រឆាំងនៅកម្ពុជា ក្នុងការតវ៉ាប្រឆាំងនឹងការបោះឆ្នោត "Reuters ភ្នំពេញ ថ្ងៃទី 24 ខែសីហា ឆ្នាំ 1998" ការតវ៉ាចំពោះការបោះឆ្នោតនៅកម្ពុជា នៅតែបន្តកើតឡើង នៅក្រៅរដ្ឋសភា"។ AFP ភ្នំពេញ ថ្ងៃទី 24 ខែសីហា ឆ្នាំ 1998។

[345] "គណបក្សប្រឆាំងកម្ពុជា នៅប្រកាន់ជំហររឹងមាំខណៈប្រឈមនឹងស្ថានការគួរអោយភ័យខ្លាច "Reuters ភ្នំពេញ ថ្ងៃទី 26 ខែសីហា ឆ្នាំ 1998 ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួនពី Demelza Stubbings នៃអង្គការលើកលែងទោសអន្តរជាតិ ថ្ងៃទី 26 ខែសីហា ឆ្នាំ 1998។

[346] "បុរសខ្លាំងកម្ពុជា អំពាវនាវឱ្យមានការ រួបរួមដោះស្រាយវិបត្តិរាំរ៉ៃ "AFP សៀមរាប ថ្ងៃទី 3 ខែកញ្ញា ឆ្នាំ 1998 "ការប្រុងប្រយ័ត្នរបស់សម្តេចសីហនុលើការចាប់អារម្មណ៍អំពីការបោះឆ្នោត" Reuters ភ្នំពេញ ថ្ងៃទី 4 ខែកញ្ញា ឆ្នាំ 1998។ "ការប្រឆាំងក្នុងខែមីនា នៅកម្ពុជា និយាយអំពីកូនសោរស្លាប់ " Reuters ភ្នំពេញ ថ្ងៃទី 6 ខែកញ្ញា ឆ្នាំ 1998។ "គណបក្សប្រឆាំងកម្ពុជា អំពាវនាវឱ្យ ហ៊ុន សែន ចុះចេញពីតំណែង "ក្យូដូ ភ្នំពេញ ថ្ងៃទី 6 ខែកញ្ញា ឆ្នាំ 1998។ "ពលរដ្ឋកម្ពុជា 15 000 នាក់ ប្រឆាំងនឹង ហ៊ុន សែន កាលពីខែមីនា" អូស្ត្រាលី ថ្ងៃទី 7 ខែកញ្ញា ឆ្នាំ 1998។

[347] COHCHR "ការវាយប្រហារដោយគ្រាប់បែកដៃ ទៅលើលំនៅដ្ឋានរបស់ លោក ហ៊ុន សែន ថ្ងៃទី 7 ខែកញ្ញា ឆ្នាំ 1998" ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 1998។

*ហ៊ុន សែន បានប្រកាសថា ព្រឹត្តិការណ៍នេះគឺជាតឹកតាងបញ្ជាក់ថា គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី ពិតជាបានប៉ុនប៉ង "ធ្វើបដិវត្តន៍ ដូចជារដ្ឋប្រហារ ពិតប្រាកដ"។[348] គាត់បានប្រកាសថា ពួកបាតុករត្រូវតែចាកចេញពីទីលានប្រជាធិបតេយ្យ ហើយបាតុកម្មផ្សេងទៀត ត្រូវតែបញ្ចប់នៅពាក់កណ្តាលអធ្រាត្រ ហើយថា "ដល់ពេលវេលា ដើម្បីចាប់ខ្លួនមេខ្លោងអ្នករៀបចំបាតុកម្មទាំងអស់នេះហើយ "។[349] បន្ទាប់មក កងកម្លាំងនគរបាលចំរុះ កងរាជអាវុធហត្ថ និងកងទាហាន បានវាយលុកយ៉ាងហិង្សាចូលបំបែកហ្វូងបាតុករអហិង្សានៅទីលានប្រជាធិបតេយ្យ និងវាយលុកបំបែកការប្រមូលផ្តុំអ្នកតវ៉ាផ្សេងៗទៀត ប៉ុន្តែមិនអាចបង្ក្រាបបាតុកម្មបានទេ។ ភាពចលាចលសង្គមបានបន្ត ហើយកាន់តែរីកធំឡើងក្នុងរយៈពេលជាច្រើនថ្ងៃ ច្រើនយប់បន្ទាប់ ទោះបីមានប្រតិបត្តិការពីកម្លាំងចម្រុះថ្មី និងហិង្សាក៏ដោយ។[350]*

*បើទោះជាមេដឹកនាំជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា និងមេបញ្ជាការកងកម្លាំងសន្តិសុខមួយចំនួន មិនចង់ឱ្យមានអំពើហឹង្សាកាន់តែខ្លាំងជាងនេះក្តី ក៏លោក ហ៊ុន សែន និងលោក គន់ គីម នៅថ្ងៃទី ១១ ខែកញ្ញា បានបញ្ជូនកម្លាំងបាតុករស្លៀកពាក់ស៊ីវិលប្រមាណ១០,០០០ (មួយម៉ឺន) នាក់ ដែលគាំទ្រគណបក្សប្រជាជនកម្ពុជាពីខេត្តកណ្តាល ចូលមករាជធានីភ្នំពេញ។ ដៃកាន់អាវុធ ដំបងឬស្សី និងកាំភ្លើងខ្លី ពួកគេបានវាយប្រហារ*

---

[348] "លោក ហ៊ុន សែន នៃប្រទេសកម្ពុជា បន្ទោសគណបក្សប្រឆាំង ចំពោះគ្រាប់បែកដៃ" Reuters, សៀមរាប ថ្ងៃទី 7 ខែកញ្ញា ឆ្នាំ 1998។

[349] "ឧសានវាទនៃបញ្ហាដំបូងនៅកម្ពុជា សម្រាប់បាតុករដែលត្រូវបែកខ្ញែក "AFP ភ្នំពេញ ថ្ងៃទី 7 ខែកញ្ញា ឆ្នាំ 1998។ "អ្នកតវ៉ានៅកម្ពុជា ត្រូវបានសម្លាប់នៅពេលប៉ូលីសបំបែកបាតុកម្ម "AFP ភ្នំពេញថ្ងៃទី 7 កញ្ញា ឆ្នាំ 1998។ "ផ្ទះរបស់មេដឹកនាំកម្ពុជាត្រូវវាយប្រហារ "AFP ភ្នំពេញថ្ងៃទី 7 ខែកញ្ញា ឆ្នាំ 1998។

[350] "សមរង្ស៊ី នៃកម្ពុជា មានសេរីភាព។ អ្នកប្រឆាំនឹង ហ៊ុន សែន" ភ្នំពេញ ថ្ងៃទី 8 ខែកញ្ញា ឆ្នាំ 1998។ នគរបាល"បង្ក្រាបកុប្បកម្ម ទៅបោសសំអាតអ្នកតវ៉ាប្រឆាំងកម្ពុជា "AFP ភ្នំពេញ ថ្ងៃទី 8 ខែកញ្ញា ឆ្នាំ 1998 "នគរបាលបង្ក្រាបកុប្បកម្មកម្ពុជា បំបែកហ្វូងអ្នកប្រឆាំង ហ៊ុន សែន "AFP ភ្នំពេញ ថ្ងៃទី 8 ខែកញ្ញា ឆ្នាំ 1998 ។ "នគរបាលបង្ក្រាបកុប្បកម្ម បំបែកបាតុកម្ម នៅកម្ពុជា "AP ភ្នំពេញ ថ្ងៃទី 8 ខែកញ្ញា ឆ្នាំ 1998 ។ "ប៉ូលិសបំបែកបាតុកកម្ម "នៅកម្ពុជា AP ភ្នំពេញ ថ្ងៃទី 8 ខែកញ្ញា ឆ្នាំ 1998 ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស "អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្កោលទោស អំពើហិង្សា និងការបង្ក្រាបរបស់នគរបាល ប្រឆាំងនឹងបាតុករ នៅកម្ពុជា ថ្ងៃទី 9 ខែកញ្ញា ឆ្នាំ 1998។ នគរបាល" និងក្រុមមនុស្សប៉ះទង្គិចគ្នា នៅថ្ងៃទីបី នៅកម្ពុជា "New York Times, ថ្ងៃទី9 ខែកញ្ញា ឆ្នាំ1998។ "ព្រះសង្ឃត្រូវបានគេបាញ់សម្លាប់ ខណៈដែលប៉ូលិសប៉ះទង្គិច ជាមួយក្រុមអ្នកតវ៉ា នៅរាជធានីនៃប្រទេសកម្ពុជា "AFP ភ្នំពេញ ថ្ងៃទី 9 ខែកញ្ញា ឆ្នាំ 1998។ "ហ្វូងបាតុកម្មប្រមូលផ្តុំឡើងវិញ ដុតបញ្ជេះនៅកន្លែងដែលព្រះសង្ឃត្រូវបានបាញ់" AP ភ្នំពេញ ថ្ងៃទី 9 ខែកញ្ញា ឆ្នាំ 1998។ "បាត់ខ្លួនព្រះសង្ឃ ប្រហែលជាស្លាប់" VOA ថ្ងៃទី 9 ខែកញ្ញា ឆ្នាំ 1998។ "ឱកាសម្រាប់កម្ពុជាអាប់អួរ ប៉ុន្តែនៅតែមានក្តីសង្ឃឹម "Reuters ភ្នំពេញ ថ្ងៃទី 9 ខែកញ្ញា ឆ្នាំ 1998 "ព្រះសង្ឃស្លាប់ ក្នុងការប៉ះទង្គិច នៅកម្ពុជា "BBC ភ្នំពេញ ថ្ងៃទី 9 ខែកញ្ញា ឆ្នាំ 1998 "ព្រះសង្ឃខ្មែរ ត្រូវបានវាយដំ ភ័យខ្លាច ឈប់បន្ត "Reuters ភ្នំពេញ ថ្ងៃទី 15 ខែកញ្ញា ឆ្នាំ 1998 "កងយោធាកម្ពុជា បានបើកផ្លូវឡើងវិញ ក្រោយពីការតវ៉ា "ការផ្សាយរបស់អូស្រ្តាលី ភ្នំពេញ ថ្ងៃទី 9 ខែកញ្ញា ឆ្នាំ 1998។ "ម្នាក់បានត្រូវរបួស នៅពេលប៉ូលីសកម្ពុជាបើកការបាញ់ប្រហារ ទៅលើអ្នកតវ៉ាដែលរឹងទទឹង "AFP ភ្នំពេញ ថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 1998 ។ ប្រជាជនកម្ពុជា" ប៉ះទង្គិចជាមួយប៉ូលីស សម្រាប់ថ្ងៃទីបួន ក្នុងការប្រឆាំងនឹង ការហាម ឃាត់ការប្រមូលផ្តុំគ្នា "AFP ភ្នំពេញ ថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 1998 ។ "ការប៉ះទង្គិចគ្នា បានបែកខ្ញែកនៅជិតវាំង "Reuters ភ្នំពេញ ថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 1998។ "នគរបាល កំចាត់ពួកអ្នកតវ៉ាកម្ពុជា "AP ភ្នំពេញ ថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 1998។ "មនុស្សរាប់ពាន់នាក់ នៅតាមដងផ្លូវ ក្នុងរាជធានីភ្នំពេញ ស្រែកអបអរចំពោះសន្តិភាព "ញូវយ៉កថៃមស៍ ថ្ងៃទី 11 ខែកញ្ញា ឆ្នាំ 1998។ "ការប្រឆាំងនឹងរដ្ឋាភិបាលយ៉ាងធំ កាលពីខែមីនា ត្រូវបានបំបែក នៅកម្ពុជា "Reuters ភ្នំពេញ ថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 1998។ "ការតវ៉ារបស់ប្រជាជនកម្ពុជា បានធ្វើឱ្យមានមនុស្សរាប់ពាន់នាក់ នៅតាមដងផ្លូវនានានៃរាជធានី "AFP ភ្នំពេញ ថ្ងៃទី 10 ខែកញ្ញា ឆ្នាំ 1998។

*ទៅលើក្រុមអ្នកតវ៉ាប្រឆាំង និងអ្នកនៅជិតកន្លែងកើតហេតុ ខ្លះស្លាប់ និងរបួស ហើយប៉ូលិស និងកងអាវុធហត្ថ បានចាប់មនុស្សរាប់សិបនាក់ ហើយបង្ខាំងមួយចំនួនមិនឱ្យអ្នកណាចូលជួប។[351] បាតុកម្មបានបន្តដោយមានការប្រយុទ្ធគ្នាតាមផ្លូវ ពីមុខ ពីក្រោយ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា នៅពេលកងកម្លាំងលោក ហ៊ុន សែន បានគ្រប់គ្រងឡើងវិញទាំងស្រុងនៅលើដងផ្លូវទាំងអស់។[352]ដល់ពេលនេះ យ៉ាងហោចណាស់មានមនុស្ស ២១ នាក់ត្រូវបានសម្លាប់ ក្នុងនោះមានពីរនាក់គ្រងចីវរជាព្រះសង្ឃ និង៦០នាក់ផ្សេងទៀតយ៉ាងតិចរបួសធ្ងន់ដែលត្រូវការព្យាបាលនៅមន្ទីរពេទ្យ ហើយក្នុងនោះ១៦ នាក់រងរបួសដោយគ្រាប់កាំភ្លើង ។[353]*

## *លោក គន់ គីម ឆ្នាំ១៩៩៩-២០១២*

---

[351] "ក្រុមប៉ូលីសរបស់ហុក ឡុងឌី ធ្វើសកម្មភាព បន្ទាប់ពីទៀ បាញ់ បដិសេធ "ភ្នំពេញប៉ុស្ដិ៍ ពីថ្ងៃទី12-17 ខែកញ្ញា ឆ្នាំ1998។ បទសម្ភាសន៍ជាមួយមន្ត្រីគណបក្សប្រជាជនជាន់ខ្ពស់ ថ្ងៃទី18 ខែកញ្ញា ឆ្នាំ2004។ "បាតុកម្មបានរីករាលដាលពេញរាជធានីភ្នំពេញ "ភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី12 ខែកញ្ញា ឆ្នាំ1998។ សេចក្ដីថ្លែងការណ៍របស់ ជា ស៊ីម ប្រធានរដ្ឋសភា "ថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 1998។ បទសម្ភាសន៍ជាមួយមន្ត្រីគណបក្សប្រជាជនជាន់ខ្ពស់ ថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2004។ "មនុស្សម្នាក់បានស្លាប់ នៅពេលដែលហ្វូងបាតុករ កំពុងដើរក្បួន" Reuters ភ្នំពេញ ថ្ងៃទី 11 ខែកញ្ញា ឆ្នាំ 1998។ "នគរបាលបានបញ្ជាឱ្យឆ្មក់ និងបោសសម្អាតសាកសព "វីអូអេ ភ្នំពេញ ថ្ងៃទី 11 ខែកញ្ញា ឆ្នាំ 1998។ "អ្នកតវ៉ាម្នាក់ទៀតត្រូវបានគេសម្លាប់ក្នុងបាតុកម្ម នៅកម្ពុជា "Kyodo ភ្នំពេញ ថ្ងៃទី 11 ខែកញ្ញា ឆ្នាំ 1998។ "ម្នាក់ត្រូវបានសម្លាប់ និងរងរបួសជាច្រើននាក់ នៅពេលអ្នកគាំទ្រគណបក្សប៉ះទង្គិចគ្នា នៅកម្ពុជា "AP ភ្នំពេញ 11 កញ្ញា 1998។ "ក្រុមអ្នកតវ៉ាកម្ពុជា បានប្រយុទ្ធគ្នា នៅពេលដែលព្រះមហាក្សត្រ អំពាវនាវ ដើម្បីសន្តិភាព "AFP ភ្នំពេញ ថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 1998។ "ការតវ៉ាធ្លាក់ចូលទៅក្នុងសង្គ្រាមដ៏កខ្វក់" *The Australia* ថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 1998។ "អ្នកគាំទ្ររដ្ឋាភិបាល ទឹកជំនន់រាជធានី" Reuters ភ្នំពេញ ថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 1998។ "បាតុកម្មនៅកម្ពុជា" វីអូអេ ភ្នំពេញ ថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 1998។ "អំពើហឹង្សាធ្វើឱ្យខកខាន ដល់ផែនការប្រមូលផ្ដុំគ្នានៅកម្ពុជា "ថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 1998។  យ៉ាងហោចណាស់មនុស្ស"5 នាក់ត្រូវរងរបួស នៅពេលក្បួនបាតុកម្មបានប៉ះទង្គិចគ្នានៅតាមដងផ្លូវ"។ AFP ភ្នំពេញ ថ្ងៃទី12 កញ្ញា ឆ្នាំ1998។ "ពួកបាតុករកម្ពុជាប្រយុទ្ធគ្នា នៅពេលដែលព្រះមហាក្សត្រអំពាវនាវ ដើម្បីសន្តិភាព "AFP ភ្នំពេញ ថ្ងៃទី 12 កញ្ញា1998។ "ព្រះអង្គម្ចាស់រណឫទ្ធិ ណែនាំឱ្យមានការសម្រុះសម្រួល"APភ្នំពេញ ថ្ងៃទី13 កញ្ញា ឆ្នាំ1998។ "អ្នកគាំទ្ររដ្ឋាភិបាល ខែមីនា នៅកម្ពុជា "AP ភ្នំពេញថ្ងៃទី13 កញ្ញា ឆ្នាំ1998។

[352] "ក្រុមគាំទ្ររដ្ឋាភិបាលប្រដាប់ដោយអាវុធ ទាមទារផ្លូវក្នុងរាជធានីវិញ "AFP ភ្នំពេញ ថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 1998។ "ដំណាក់កាលធំៗ ក្នុងខែមីនា របស់រដ្ឋាភិបាល នៅកម្ពុជា "Reuters ភ្នំពេញ ថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 1998 ។ ការតវ៉ា"នៅតែបន្ត ខណៈដែលគណបក្សប្រឆាំងកម្ពុជា ស្វែងរកការពិភាក្សាជាមួយ ព្រះមហាក្សត្រ "AFP ភ្នំពេញ ថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 1998។ សកម្មជនកម្ពុជា" ត្រូវគេវាយដំ ចាប់ខ្លួន "AP ភ្នំពេញ ថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 1998។ "ការអំពាវនាវរបស់ រណរិទ្ធ ដល់អ្នកគាំទ្រឱ្យបញ្ឈប់ "Reuters ភ្នំពេញ ថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 1998។ "ប៉ូលីសកម្ពុជាបាញ់ ដើម្បីបំបែកហ្វូងអ្នកតវ៉ា " Reuters ភ្នំពេញ ថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 1998។ "35 នាក់ ត្រូវចាប់ខ្លួន ក្នុងពេលបង្ក្រាបបាតុករ នៅកម្ពុជា "Kyodo ភ្នំពេញ 14 កញ្ញា 1998។ "សកម្មជនកម្ពុជា ត្រូវគេវាយដំ ចាប់ខ្លួន "AP ភ្នំពេញថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 1998។ "សកម្មជនកម្ពុជា ដង្ហែរក្បួន ប្រឆាំងហ៊ុនសែន នៅតាមដងផ្លូវនានា ថ្ងៃទី "14 ខែកញ្ញា ឆ្នាំ 1998។ គណបក្សប្រឆាំង" និយាយថា កម្ពុជានៅ "ចំនុចផ្លាស់ប្ដូរ"ថ្វីបើមានអំពើហិង្សាតាមដងផ្លូវតែច្រើនក៏ដោយ ។ "AFP ភ្នំពេញ ថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 1998។ "គណបក្សកម្ពុជាដទៃទៀត យល់ព្រមជួបប្រជុំ "AP ភ្នំពេញ ថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 1998។ អង្គការលើកលែងទោសអន្តរជាតិ "ការភ័យខ្លាចនៃការធ្វើទារុណកម្ម /  ការភ័យខ្លាចចំពោះសុវត្ថិភាព  /ភាពភ័យខ្លាចនៃការបាត់ខ្លួន " (ASA23/25/98) ថ្ងៃទី 15 ខែកញ្ញា ឆ្នាំ 1998។ "រាជធានីកម្ពុជាស្ងប់ស្ងាត់ ក្រោយពីការតវ៉ា "Reuters ភ្នំពេញ ថ្ងៃទី 15 ខែកញ្ញា ឆ្នាំ 1998។ "រាជធានីភ្នំពេញមានភាពស្ងប់ស្ងាត់ ភាពតានតឹង ការបន្តកិច្ចពិភាក្សា " Reuters ភ្នំពេញ ថ្ងៃទី 15 ខែកញ្ញា ឆ្នាំ 1998។

[353] "សេចក្ដីថ្លែងការ របស់លោកឯកអគ្គរដ្ឋទូត Thomas Hammarberg អ្នកតំណាង ពិសេស នៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា" ទីក្រុងញូវយ៉ក ថ្ងៃទី 16 ខែកញ្ញា ឆ្នាំ1998។ "អង្គការសហប្រជាជាតិ ព្រួយបារម្ភយ៉ាងខ្លាំងចំពោះការស្លាប់ និងការបាត់បង់នៅកម្ពុជា " Reuters ភ្នំពេញ ថ្ងៃទី 16 ខែកញ្ញា ឆ្នាំ 1998។ "ការស្លាប់កើនឡើង" វីអូអេ ភ្នំពេញ ថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 1998។ អង្គការលើកលែងទោសអន្តរជាតិ ព្រះ" បាតុកម្ម :រាជាណាចក្រកម្ពុជាត្រូវបានកម្ទេច ដោយប្រើកងកម្លាំងលើស លុប) "ASA23/26/98) ថ្ងៃទី 22 ខែកញ្ញា ឆ្នាំ 1998។

ដោយអះអាងថា គណបក្សប្រជាជនកម្ពុជា បានឈ្នះការបោះឆ្នោតនៅឆ្នាំ១៩៩៨ លោក ហ៊ុន សែន បានតែងតាំងលោក គន់ គីម ជាមេបញ្ជាការរងជាន់ខ្ពស់របស់កងយោធពលខេមរភូមិន្ទ នៅខែវិច្ឆិកា ឆ្នាំ១៩៩៩។[354] លោក គន់ គីម ជាជនរំលោភសិទ្ធិមនុស្សដ៏ល្បីឈ្មោះ ប៉ុន្តែលោក ហ៊ុន សែន បានពន្យល់ថា គ្មានហេតុផលអ្វីដែលគាត់គួរយកកំណត់ត្រារំលោភសិទ្ធិមនុស្សរបស់លោក គន់ គីម មកពិចារណាទេ។[355] នៅមុនការបោះឆ្នោតសភាជាតិបន្ទាប់ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៣ លោក គន់ គីម ដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំផែនការយថាហេតុទុកជាមុន របស់លោក ហ៊ុន សែន ដើម្បីដោះស្រាយតាមមធ្យោបាយយោធា ឬរៀបចំទប់ទល់នឹងការគំរាមកំហែងខាងនយោបាយទៅលើអំណាចរបស់លោក ហ៊ុន សែន តាមរយៈសន្លឹកឆ្នោត ឬតាមរយៈបាតុកម្មទ្រង់ទ្រាយធំក្នុងអំឡុងពេល និងក្រោយពេលបោះឆ្នោត។ ចាប់ពីពេលទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួនកាន់តែច្រើន លោក គន់ គីម ជាថ្មីម្តងទៀត ក៏បានរួមចំណែកកាន់តែច្រើនទៅក្នុងយុទ្ធនាការឃោសនារបស់គណបក្សប្រជាជនកម្ពុជា ដែលជាផ្នែកមួយជួយឱ្យគាត់ឡើងអំណាចបុណ្យស័ក្កកាន់តែខ្ពស់ត្រដែតជាងគេ បើប្រៀបធៀបទៅនឹងមន្ត្រីជាន់ខ្ពស់នៃគណបក្សប្រជាជនកម្ពុជាផ្សេងទៀត។[356]

ក្នុងឆ្នាំ២០០៩ លោក គន់ គីម ត្រូវបានឡើងឋានៈជាមេអគ្គសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ ហើយចាប់តាំងពីពេលនោះមក គាត់បានទទួលបន្ទុកផ្នែកកងទ័ព កងទ័ពជើងទឹក និងទ័ពអាកាស។[357] ក្នុងឆ្នាំ២០០៩នេះដែរ គាត់ក៏បានក្លាយជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនកម្ពុជា ជាស្ថាប័នកំពូល ដែលបង្កើតគោលនយោបាយរបស់បក្សជាផ្លូវការ។[358] ទាំងនេះ បានឆ្លុះបញ្ចាំងពីការភ័យខ្លាចរបស់នាយករដ្ឋមន្ត្រីដែលថា បើគ្មានបុរសដូច គន់ គីមនៅក្នុងតំណែងខ្ពស់នេះទេ គាត់អាចបាត់បង់អំណាច។[359] នៅពេលដែលលោក ហ៊ុន សែន បានលើកឡើងក្នុងសុន្ទរកថាមួយទៅកាន់

---

354 "គោរពអធិបតេយ្យភាពរបស់យើង" Asiaweek.com (www.asiaweek/magazine/99/1126/nat.cambodia2.hunsen.html), ថ្ងៃទី 26 ខែវិច្ឆិកា ឆ្នាំ 1999 (ចូលមើលថ្ងៃទី 21 ខែសីហា ឆ្នាំ 2012)។

355 លោក Francois Ponchaud "ប្រទេសកម្ពុជា :ចំណុចនៅលើស្ថានភាពនយោបាយ និងសង្គម ពីថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 1999 ដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1999" វិហារកាតូលិកអាស៊ី ឯកសារលេខ 1/2000-16/01/2000: ខែមករា ឆ្នាំ 2001។

356 បទសម្ភាសជាមួយ មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា ថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2004។

357 លោក Steve Heder "កម្ពុជាក្នុងឆ្នាំ 2010: ការពង្រឹងបន្ថែម របស់សម្តេច ហ៊ុន សែន "Asian Survey Vol 51 លេខ 1 (មករា កុម្ភៈ/2011) ទំព័រ 208។

358 http://www.cpp.org.kh/site/struture/12/3 ចូលមើលថ្ងៃទី 3 ខែមិថុនា ឆ្នាំ 2013)។

359 "មន្ត្រីកងយោធពលខេមរភូមិន្ទកម្ពុជា "ដឺខេបូឌាដេលី ថ្ងៃទី 11 ខែមេសា ឆ្នាំ 2011។

កងកម្លាំងសន្តិសុខ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១១ លោកបានសន្មត់ថា ប្រតិបត្តិការរបស់គណបក្សប្រជាជនកម្ពុជា ត្រូវតែគិតថា "សន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងស្ថេរភាព មានភាពផុយស្រួយ ដែលអាចប្រែក្លាយទៅជាភាពវឹកវរ គ្រប់ពេលដោយមិនអាចទស្សទាយជាមុនបានទេ"។ គាត់បានព្រមានថា ត្រូវតែមានវិធានការគិតទុកជាមុន ដើម្បីរារាំងបញ្ហាទាំងនេះ។[360]

## នៅក្នុងការបោះឆ្នោតឆ្នាំ ២០១៣ និងចាប់តាំងពីនោះមក

ការកើនឡើងនៃអំពើហិង្សា ដោយកងយោធពលខេមរភូមិន្ទ និងកងកម្លាំងសន្តិសុខដទៃទៀត ក្នុងឆ្នាំ ២០១២ ហាក់ដូចជា បានរៀបចំឡើង ដើម្បីធានាជ័យជម្នះដ៏ធំធេងសម្រាប់គណបក្សប្រជាជនកម្ពុជាក្នុងការបោះឆ្នោតសភាជាតិ ដែលបានគ្រោងទុកនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដែលក្នុងនោះគណបក្សសង្គ្រោះជាតិ ទើបបានបង្កើតថ្មី ដឹកនាំដោយលោក សម រង្ស៊ី ប្រធាន និងលោក កឹម សុខា អនុប្រធានទំនងជាប្រឈមនឹងបញ្ហាដ៏ធំ។[361]

លោក គន់ គីមមានតួនាទីសំខាន់ ក្នុងការអនុវត្តសកម្មភាព គោលនយោបាយបក្ស ក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត ឆ្នាំ ២០១៣។ គាត់ជាប្រធានមណ្ឌលរបស់គណបក្សប្រជាជនកម្ពុជា – ក្រុមការងារដើម្បីចុះ

---

[360] ហ៊ុន សែន "ថ្លែងសុន្ទរកថា ក្នុងពិធីបិទសន្និបាតបូកសរុប ឆ្នាំ 2010 និងទិសដៅ ឆ្នាំ 2011 - សន្និសិទ "ថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ ២០១១។http://www.cnv.org.kh/2011_releases/24feb11_stocktaking_moi_speech.html (ចូលមើលថ្ងៃទី 1 ខែមីនា ឆ្នាំ 2011) ហ៊ុន សែន មតិយោបល់ដែលបាន"ជ្រើសរើសនៅពេលបិទសន្និបាទប្រចាំឆ្នាំ 2010 របស់ក្រសួងមហាផ្ទៃ និង សន្និសីទស្តីពីការកំណត់ទិសដៅឆ្នាំ 2011" ថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2011 ។ http://www.cnv.org.kh/2011_releases/24feb11_stocktaking_moi_comments.html (ចូលមើលថ្ងៃទី 1 ខែមីនា ឆ្នាំ 2011)។ ហ៊ុន សែន "ថ្លែងសុន្ទរកថា ក្នុងពិធីអបអរសាទរខួបលើកទី 100 នៃទិវានារីអន្តរជាតិ 8 មីនា" ថ្ងៃទី 7 ខែមីនា ឆ្នាំ 2011។ http://www.cnv.org.kh/2011_releases/07mar11_100th_women_day_speech.html (ចូលមើលថ្ងៃទី ២៩ ខែមីនា ឆ្នាំ 2011)។

[361] អង្គការឃ្លាំមើលសិទ្ធិមនុស្ស របាយការណ៍ពិភពលោក (2013), (ញូវយ៉ក  អង្គការឃ្លាំមើលសិទ្ធិមនុស្ស ឆ្នាំ 2013) កម្ពុជា http://www.hrw.org/world-report/2013/country-chapters/cambodia?page=1; "សេចក្តីថ្លែងការណ៍រួម របស់គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស"  ថ្ងៃទី 17 ខែកក្កដា ឆ្នាំ 2012។ http://www.nationalrescueparty.org/en/our_party/(accessedAugust22, 2012); "ចលនាប្រជាធិបតេយ្យ នៃការសង្គ្រោះជាតិ" http://www.nationalrescueparty.org/our_party/cdmn/ (ចូលមើលថ្ងៃទី 22 ខែសីហា ឆ្នាំ 2012) កម្ពុជា: ការកើនឡើងនៃអំពើហិង្សាការប្រើតុលាការខុសការបង្ក្រាបពីក្រោយការបោះឆ្នោតថ្នាក់ជាតិ ឆ្នាំ 2013" ការចេញផ្សាយព័ត៌មាន របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី 1 ខែកុម្ភៈ ឆ្នាំ 2013។ http://www.hrw.org/news/2013/02/01/cambodia- escalating-violence-misuse-courts; "គណបក្សប្រឆាំងធំ ចំនួនពីរនៅកម្ពុជាបានចូលរួមកម្លាំងគ្នាប្រកួតប្រជែងនឹង ការគ្រប់គ្រងអំណាច 27 ឆ្នាំរបស់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅឯការបោះឆ្នោតទូទៅមួយនៅខែកក្កដាខាងមុខ" បុរសម្នាក់បាននិយាយកាល ថ្ងៃពុធទី 2 ខែតុលា ឆ្នាំ 2012។ http://live.channelnewsasia.com/news/asiapacific/afp_asiapacific/cambodia-s-two-main-opposition-parties-team- up-to-fight-pm-hun-sen/333298.html (ចេញនៅថ្ងៃទី 10 ខែតុលា ឆ្នាំ 2012) "អ្នកវិភាគនិយាយថា ការច្របាច់បញ្ចូលគ្នា រវាងគណបក្សប្រឆាំង មានឱកាសឈ្នះ" វីអូអេ ថ្ងៃទី 28 ខែមិថុនា ឆ្នាំ 2012។ http://www.voacambodia.com/content/opposition-merger-means-a-chance-to-win-analyst-says-160700365/1405480.html (ចេញនៅថ្ងៃទី 28 ខែមិថុនា ឆ្នាំ 2012)។

*ជួយខេត្តឧត្តរមានជ័យ ដែលគាត់បានឈរឈ្មោះជាបេក្ខជនគណបក្សប្រជាជនកម្ពុជា និងបានធ្វើយុទ្ធនាការយ៉ាងប្រុងប្រយ័ត្ន សម្រាប់ខ្លួនគាត់ និងសម្រាប់គណបក្ស។*[362]

*កម្ពុជាត្រូវបានធ្លាក់ចូលក្នុងវិបត្តិសិទ្ធិមនុស្ស ដោយគ្មានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ទេ នៅឆ្នាំ ២០១៣ ក្នុងនោះ គណបក្សប្រជាជនកម្ពុជា បានគ្រប់គ្រងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ធ្វើឲ្យគណបក្សប្រជាជនកម្ពុជាឈ្នះ ៦៨ អាសនៈ ទល់នឹង ៥៥ អាសនៈ របស់គណបក្សសង្គ្រោះជាតិ។ ភ្លាមៗនោះ គណបក្សសង្គ្រោះជាតិ បានប្រកាសប្ដេជ្ញាតវ៉ាប្រឆាំងលទ្ធផលបោះឆ្នោតដែលប្រកាសដោយគ.ជ.ប នោះ តាមរយៈការធ្វើបាតុកម្មទ្រង់ទ្រាយធំប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជា ដូចកាលពីឆ្នាំ ១៩៩៨។ នឹកដល់ព្រឹត្តិការណ៍នោះ លោក ហ៊ុន សែន ក៏បានចេញបង្ហាញខ្លួនជាសាធារណៈលើកដំបូង ក្រោយការបោះឆ្នោត ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៣ ប្រកាសព្រមានម្ដងហើយម្ដងទៀតថា សកម្មភាពធ្វើបាតុកម្មតវ៉ាណាមួយអាចនឹងត្រូវប្រឆាំងតបវិញដោយកម្លាំងមហាជនគាំទ្រគណបក្សប្រជាជនកម្ពុជា ដែលជាយុទ្ធសាស្ត្រដូចគ្នារៀបចំដោយលោក គន់ គីម កាលពី ១៥ ឆ្នាំមុន។*[363] *ប្រតិបត្តិការដែលមានការគាំទ្រដោយកងយោធពលខេមរភូមិន្ទ ណែនាំដោយលោក ហ៊ុន សែន បានរារាំងការប៉ុនប៉ងរបស់គណបក្សសង្គ្រោះជាតិ ដើម្បីរៀបចំការជួបជុំគ្នានៅខេត្តកំពង់ចាម និងខេត្តឧត្តរមានជ័យ។ ឧត្តរមានជ័យ ជាខេត្តមួយ*

---

[362] "ឯកឧត្តម គន់ គីម និងភរិយាគាត់ គៀង ចាន់ឌី គន់ គីម ជួបជុំ និងជជែកជាមួយប្រជាពលរដ្ឋ និងសមាគមនារី នៅក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ" ថ្ងៃទី 19 ខែ មិថុនា ឆ្នាំ 2013។ http://kpt-news.com/local-news/29563-2013-06-19-08-09-08.html (ចេញនៅថ្ងៃទី 20 ខែមិថុនា ឆ្នាំ 2013) "គណកម្មាធិការរៀបចំការបោះឆ្នោត ចេញបញ្ជីឈ្មោះជាផ្លូវការ របស់បេក្ខជនគណបក្សប្រជាជន ឈរឈ្មោះសម្រាប់ការបោះឆ្នោត ជាសមាជិករដ្ឋសភាក្នុងឆ្នាំ 2013 "ថ្ងៃទី 4 ខែឧសភា ឆ្នាំ 2013 http://www.dap-news.com/2011-06-14-02-39-55/63399-2013-05-04-08-32-18.html (ចេញនៅថ្ងៃទី  4 ខែឧសភា ឆ្នាំ 2013)។ "ឯកឧត្តម គន់ គីម និងភរិយា គាត់ គៀង ចាន់ឌី គន់ គីម ជួបជុំ និងជជែកជាមួយប្រជាពលរដ្ឋ និងសមាគមនារី នៅទីក្រុងសំរោង ខេត្តឧត្តរមានជ័យ" ថ្ងៃទី 19 ខែមិថុនា ឆ្នាំ 2013 http://kpt-news.com/local-news/29563-2013-06-19-08-09-08.html (ចូលមើលថ្ងៃទី 20 ខែមិថុនា ឆ្នាំ 2013) "គណៈកម្មាធិការបញ្ជាការបង្រួបបង្រួម នៃសមរភូមិមុខ បានបូកសរុបការងារ រយៈពេលប្រាំមួយខែនៃ ឆ្នាំ 2013 និងផ្ដល់កិត្តិយស ដល់មេបញ្ជាការកងទ័ពជួរមុខ "ថ្ងៃទី 19 ខែមិថុនា ឆ្នាំ 2016 ។ http://kpt-news.com/local-news/29529-2013-06-19-03-01-02.html (ចូលមើលថ្ងៃទី 19 ខែមិថុនា ឆ្នាំ 2016); "លោក គន់ គីម ចុះមកពង្រឹងគណបក្ស នៅខេត្តឧត្តរមានជ័យ" ថ្ងៃទី 3 ខែឧសភា ឆ្នាំ 2013។ http://www.dap-news.com/2011-06-14-02-39-55/63355-2013-05-03-08-51-01.html (ចូលមើលថ្ងៃទី 3 ខែឧសភា ឆ្នាំ 2013)។ "លោក គន់ គីម ចុះទៅជជែកជាមួយសមាជិកគណបក្ស" (), ថ្ងៃទី 16 ខែមករា ឆ្នាំ 2013។ http://www.dap-news.com/2011-06-14-02-39-55/56103-2013-01-16-08-29-52.html (ចូលមើលថ្ងៃទី 21 ខែមករា ឆ្នាំ 2013)។ "លោក គន់ គីម ជួបជុំ និងជជែកជាមួយសមាជិកបក្ស ក្នុងឃុំចំនួន 3 នៃស្រុកអន្លង់វែងកាលពីថ្ងៃទី 2 ខែឧសភា ឆ្នាំ 2013។ http://www.dap-news.com/2011-06-14-02-39-55/63286-2013-05-02-08-36-47.html (ចូលមើលថ្ងៃទី 3 ខែឧសភា ឆ្នាំ 2013)។

[363] សម្ដេចតេជោ៖ គ្មានអ្នកណាមានសិទ្ធិមកបង្ខំឱ្យហ៊ុន សែនចុះចេញពីអំណាចបានទេ, ថ្ងៃទី31 ខែកក្កដា ឆ្នាំ2013; http://kptnews.com/index.php?option=com_content&view=article&id=31558:2013-07-31-13-14-25&catid=1:latest&Itemid=65 (accessed July 31, 2013); "នាយករដ្ឋមន្ត្រី៖ យើងក៏អាចបាតុកម្មបានដែរ," កាសែតភ្នំពេញប៉ុស្ដិ៍, ថ្ងៃទី 26 ខែ កុម្ភៈ ឆ្នាំ 2014, http://www.phnompenhpost.com/national/we-can-protest-too-pm (ចូលមើលថ្ងៃទី29 ខែកុម្ភៈ ឆ្នាំ2014)។

*ដែលគ្រប់ដណ្តប់ដោយនយោបាយរបស់លោក គន់ គីម។ ជនស៊ីវិល និងកងទ័ពដែលគាំទ្រគាត់ បានធ្វើបាតុកម្ម រារាំងមេដឹកនាំគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី មិនឲ្យមានការប្រមូលផ្តុំ ជួបប្រជុំកិច្ចការនយោបាយបាននៅស្រុកអន្លង់វែង។*[364]

*នៅរាជធានីភ្នំពេញ រដ្ឋាភិបាលបានដាក់ពង្រាយនគរបាលប្រដាប់អាវុធ កងរាជអាវុធហត្ថ និងកងយោធាចំនួនយ៉ាងច្រើន ដើម្បីរារាំងបង្ក្រាបគណបក្សសង្គ្រោះជាតិ ដែលបានត្រៀបចំការធ្វើបាតុកម្មដោយសន្តិវិធី និងរារាំងបង្ក្រាបក្រុមសហជីព និងកម្មកររោងចក្រ មិនឱ្យធ្វើកូដកម្មអហិង្សាទាមទារដំឡើងបប្រាក់ខែគោល និងបង្កើនលក្ខខណ្ឌការងារឲ្យល្អប្រសើររបស់ពួកគេ។ យ៉ាងហោចណាស់មានមនុស្ស ៦ នាក់បានស្លាប់ដោយសារការប្រើកម្លាំងដែលមិនចាំបាច់ដោយកងរាជអាវុធហត្ថ និងប៉ូលីស រួមទាំងឧប្បត្តិហេតុនៃការបាញ់សំដៅចូលទៅក្នុងហ្វូងមនុស្ស ដោយគ្រាប់កាំភ្លើងពិត។*[365] *ថ្វីបើគ្មានការស្លាប់ក្រោយការបោះឆ្នោតពាក់ព័ន្ធនឹងអង្គភាពយោធាក៏ដោយ ក៏អង្គភាពពីរមានមូលដ្ឋាននៅភ្នំពេញ ហើយនៅក្រោមអគ្គសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ គឺកងពលតូចលេខ៩១១ និងលេខ៧០ នៃកងយោធពលខេមរភូមិន្ទមានជាប់ពាក់ព័ន្ធក្នុងប្រតិបត្តិការវាយបំបែក ឬរារាំងកូដកម្ម និងភាពចលាចលក្នុងសង្គមនៅពេលនោះ។*

*ទន្ទឹមនឹងនេះដែរ ក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈ ក្រោយៗមកទៀតក្នុងឆ្នាំ២០១៤ លោក គន់ គីម បានបន្តសំដែងការគាំទ្រគណបក្សប្រជាជនកម្ពុជា ដូចនៅមុនពេលបោះឆ្នោតដែរ ដោយប្រកាសគាំទ្រលទ្ធផលបោះឆ្នោត លើកសរសើរពីភាពជាអ្នកដឹកនាំនយោបាយរបស់លោក ហ៊ុន សែន គាំទ្រប្រតិបត្តិការបង្ក្រាបរបស់កងកម្លាំងយោធា និងកងកម្លាំងសន្តិសុខដទៃទៀត និងគំរាមប្តឹងប្រឆាំងនឹងលោក សម រង្ស៊ី ថាជាអ្នកបង្ក ឬញុះញង់ឱ្យមាន "អស្ថិរភាពសង្គម" នៅក្នុងប្រទេសកម្ពុជា។*[366]

---

[364] វេទិកាគណបក្សសង្គ្រោះជាតិ ត្រូវបានរំខាន នៅក្នុងខេត្តកំពង់ចាម។ (LICADHO), Flash News, ថ្ងៃទី 26 ខែមករា ឆ្នាំ 2014។ http://www.licadho-cambodia.org/flashnews.php?perm=32 ចូលមើលថ្ងៃទី 30 ខែមករា ឆ្នាំ ២០១៤។ គណបក្សប្រឆាំង ៖ ជនស៊ីវិលរារាំងមន្ត្រីបក្សសង្គ្រោះជាតិ នៅតាមដងផ្លូវ ក្នុងខេត្តឧត្តរមានជ័យ ជាយោធាបង្កប់" ថ្ងៃ 9 ខែមិថុនា ឆ្នាំ 2014។ http://vodhotnews.com/22025 (ចូលមើលថ្ងៃទី10 ខែមិថុនា ឆ្នាំ 2014)។ វីដេអូបីរឿងជាកម្មសិទ្ធរបស់ អង្គការការឃ្លាំមើលសិទ្ធិមនុស្ស។

[365] អង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែនរ៉ៃត៍វច្ឆះ "ការដាក់ពាក្យ របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ដើម្បីពិនិត្យមើលឡើងវិញ នូវប្រទេសកម្ពុជា ដោយគណៈកម្មាធិការសិទ្ធិមនុស្សជាមុន មុនពេលអនុម័តបញ្ជីបញ្ហា "ថ្ងៃទី 6 ខែមិថុនា ឆ្នាំ 2014។ http://www.hrw.org/news/2014/06/06/human-rights-watch- submission-review-cambodia-human-rights-committee.

[366] បញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ" អង្គការនៃបញ្ជាការដ្ឋានខេមរភូមិន្ទ" ២០០៦; Brad Adams," កងពលតូច ៩១១ មានប្រវត្តិឃោរឃៅមុនកូដកម្មរោងចក្រកាត់ដេរ" ដឹខេមបូឌាដេលីថ្ងៃទី ៩ ខែមករាឆ្នាំ ២០១៤ http://www.hrw.org/news/2014/01/09/brigade-911-hadbrutal-history-garment-factory-strike (ចូលមើលថ្ងៃទី ២២ ខែមករាឆ្នាំ ២០១៤(; " នៅពេលដែលវិស័យកាត់ដេរធ្វើកូដកម្ម Loom, ទាហានបានឃ្លាំមើល

*លោក គន់ គីម បានបន្តចេញសេចក្តីថ្លែងការណ៍បែបនេះ ក្នុងឆ្នាំ២០១៥ និង២០១៦ បញ្ជូនសារដូចគ្នាទៅ បុគ្គលិកយោធា និងជនស៊ីវិល ដែលក្នុងឱកាសទាំងនោះ លោកស្លៀកពាក់ក្នុងឯកសណ្ឋានកងយោធពល ខេមរភូមិន្ទផង និងក្នុងឯកសណ្ឋានគណបក្សប្រជាជនកម្ពុជាផង។ ដូចជា នៅពេលចុះពង្រឹងគណបក្ស ប្រជាជនកម្ពុជាមូលដ្ឋាន នៅខេត្តឧត្តរមានជ័យ លោក គន់ គីម ស្លៀកពាក់ឯកសណ្ឋានគណបក្សប្រជាជន កម្ពុជា ខណៈចាប់ផ្តើមយុទ្ធនាការឃោសនាបោះឆ្នោតនៅទីនោះ។[367] លោក គន់ គីម ក៏បានធ្វើជាអធិបតីក្នុង*

---

រោងចក្រ″ ខេមបូឌាដេលីថ្ងៃទី ២៧ ខែកុម្ភៈឆ្នាំ ២០១៤ ttp://www.cambodiadaily.com/archives/as-garment-sector-strikes-loomsoldiers-watch-over-factories-53275/ (នាយឧត្តមសេនីយ៍ គន់ គីម និងនាយឧត្តមសេនីយ៍ ជា តារា ប្រជុំការងារផ្សព្វផ្សាយឆ្នាំ២០១៣ និងទិសដៅអនុវត្ត បន្ដល់មេបញ្ជាការកងឯកភាពសមរភូមិមុខ) ថ្ងៃទី ៨ ខែកុម្ភៈឆ្នាំ ២០១៤ http://www.dap-news.com/2011-06-14-02-39-55/80503-2014-02-08-06-39-48.html (ចូលមើលថ្ងៃទី ៨ ខែកុម្ភៈឆ្នាំ ២០១៤ ។(គណៈបញ្ជាការសមរភូមិកម្ពុជាថៃ) ជូនពរសម្តេចតេជោ ថ្ងៃទី៤ មេសា ២០១៤ http://www.cen.com.kh/localnews/show_detail/19?token=ODJhOWJjNm (ចូលមើលថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០១៤ ។ ឧត្តមសេនីយ៍(គន់ គីម សម្ពោធអគារសាលប្រជុំ កងពលតូចលេខ៨ តេជោ ថ្ងៃទី១២ ខែមេសា ២០១៤។ http://www.dap-news.com/2011-06-14-02-39-55/84844-2014-04-12-06-29-45.html (ចូលមើលថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៤ ។ នាយឧត្តមសេនីយ៍ (គន់ គីម អញ្ជើញកិច្ចប្រជុំពង្រីកការងារសេនាធិការចម្រុះកងទ័ព ) http://www.dap-news.com/2011-06-14-02-39-55/85065-2014-04-21-06-55-20.html, ថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០១៤ ។ នាយឧត្តមសេនីយ៍ គន់ គីម ចុះសួរសុខទុក្ខកងទ័ព នៅអង្គភាពកងពលតូចលេខ៥២ ថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ http://www.dap-news.com/2011-06-14-02-39-55/85840-2014-05-03-04-03-26.html (ចូលមើលថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៤ ។(នាយឧត្តមសេនីយ៍ គន់ គីម ចុះពិនិត្យមើលការអភិវឌ្ឍន៍មជ្ឈមណ្ឌលយោធិនពិការនៅកំពត ថ្ងៃទី ៩ ខែឧសភា ឆ្នាំ ២០១៤ http://www.dap-news.com/2011-06-14-02-39-55/88146-2014-06-09-08-47-27.html (ចូលមើលថ្ងៃទី 9 ខែមិថុនា ឆ្នាំ ២០១៤(។ គណបក្សប្រជាជនកម្ពុជាខេត្តឧត្តមានជ័យ បានប្រជុំបូកសារុបលទ្ធផលបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី២  ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤ http://edition.bayontv.com.kh/bayontv-national-news/26676-2014-05-29-13-46-38.html (ចូលមើលថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៤។( គណៈបញ្ជាការសមរភូមិកម្ពុជាថៃ ស្នើឲ្យចាត់ការតាមផ្លូវច្បាប់ចំពោះលោក សម រង្ស៊ី  ថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០១៤ http://www.cen.com.kh/localnews/show_detail/19?token=ZWY2YWYzMm (ចូលមើលថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៤(។

[367] អាវរងារបស់សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតបានបន្តជូនដល់កងទ័ពនៅប៉ៃលិន, ចេញផ្សាយថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2015។ http://kampucheathmey.com/kpt/?p=99118 (ចូលមើលថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2015)។ "នាយឧត្តមសេនីយ៍ គន់ គីម នាំយកអាវរងាផ្តល់ជូនកងទ័ពជើងទឹក" ចេញផ្សាយថ្ងៃ ទី 15 ខែវិច្ឆិកា ឆ្នាំ 2015 http://beta.nokorwatnews.com/?p=59964 (ចូលមើលថ្ងៃទី 16 ខែវិច្ឆិកា ឆ្នាំ 2015)។ "លោក គន់ គីម សរសើរការខិតខំរបស់មន្ត្រីក្រុមការងារគណបក្សប្រជាជន ស្រុកអន្លង់វែង" ថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2016 http://www.dap-news.com/2011-06-14-02-39-55/109705-2016-02-24-06-59-36.html ចេញផ្សាយថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2016 (ចូលមើលថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2016)។ "ខេត្តឧត្តរមានជ័យអបអរខួបលើកទី 37 នៃទិវាជ័យជំនះ 7 មករា"  ចេញផ្សាយថ្ងៃទី10 ខែមករា ឆ្នាំ 2016 http://kampucheathmey.com/kpt/?p=138577 (ចូលមើលថ្ងៃទី 12 ខែមករា ឆ្នាំ 2016)។ "លោក គន់ គីម ប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចចិត្តរបស់អង្គសន្និបាតគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនលើកទី 39 " ចេញផ្សាយថ្ងៃទី 24 ខែមករា ឆ្នាំ 2016 http://www.dap-news.com/2011-06-14-02-39-55/107519---------cpp---.html (ចូលមើលថ្ងៃទី 24 ខែមករា ឆ្នាំ 2016)។ "លោក គន់ គីម រំឭកដល់មន្ត្រីដែលស្ថិតនៅក្រោមអំណាចរបស់គាត់ ពួកគេត្រូវតែស្វែងយល់ ពីទុក្ខសោករបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន"។ http://www.dap-news.com/2011-06-14-02-39-55/110067-2016-02-29-00-56-26.html (ចូលមើលថ្ងៃទី 29 ខែកុម្ភៈ ឆ្នាំ 2016) ។ "ថ្នាក់ដឹកនាំគណបក្សប្រជាជនខេត្តឧត្តរមានជ័យ រៀបចំកិច្ចប្រជុំបូកសរុបការងារ ឆ្នាំ 2015 ដើម្បីពង្រឹងការងារតាមមូលដ្ឋាន ថ្ងៃទី "13 ខែធ្នូ ឆ្នាំ 2015។ http://beta.nokorwatnews.com/?p=65620#sthash.bafm2ukj.dpuf (ចូលមើលថ្ងៃទី 15 ខែធ្នូ ឆ្នាំ 2015) "ឧត្តមសេនីយ៍ គន់ គីម អញ្ជើញជាអធិបតី ក្នុងពិធីប្រជុំប្រចាំខែ ដើម្បីបូកសរុបការងារ គណបក្សប្រជាជន សម្រាប់ខែមេសា និងដាក់គោលដៅទៅមុខ សម្រាប់ខែមីនា″ ថ្ងៃទី30 ខែមេសា ឆ្នាំ 2016។ http://beta.nokorwatnews.com/?p=91856 (ចូលមើលថ្ងៃទី 1 ខែឧសភា ឆ្នាំ 2016)។ "លោក គន់ គីម ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារគណ

*ពិធីស្វាគមន៍ចំពោះអ្នកដែលត្រូវបានគេរាយការណ៍ថា បានចាកចេញពីគណបក្សប្រឆាំងមកចូលក្នុងគណបក្សប្រជាជនកម្ពុជាដែរ។*[368]

*ការវាយប្រហារដ៏សាហាវឃោរឃៅ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ ទៅលើសមាជិករដ្ឋសភានៃគណបក្សប្រឆាំងពីររូប គឺលោក គង់ សុភា និងលោក ញ៉យ ចំរើន ពីគណបក្សសង្គ្រោះជាតិ ត្រូវបានធ្វើឡើងដោយមន្ត្រីចារកម្មបីនាក់ មកពីមូលដ្ឋានកងអង្គរក្សរបស់លោក ហ៊ុន សែន ដឹកនាំបញ្ជាដោយឧត្តមសេនីយ៍ឯក ឌៀង សារុន ដែលជាមនុស្សជំនិតផង និងជាអ្នកការពារលោក គន់ គីម ជាយូរមកហើយផង។ ការវាយប្រហារនេះ បានកើតឡើងពាក់ព័ន្ធនឹងបាតុកម្មដែលរៀបចំឡើង ដោយគណបក្សប្រជាជនកម្ពុជា ទាមទារឱ្យអនុប្រធានគណបក្សសង្គ្រោះជាតិ ចេញពីតំណែងជាអនុប្រធានទី១ រដ្ឋសភា វាជាប្រតិបត្តិការមួយ ដែលអង្គភាពកងអង្គរក្ស និងអង្គការចាត់តាំងយុវជនបក្សប្រជាជនកម្ពុជា ដើរតួនាទីយ៉ាងសំខាន់។*[369] *ក្នុងព្រឹត្តិការណ៍នេះ លោក គន់ គីម ខ្លួនឯងអនុវត្តន៍អំណាចជាច្រើនតួនាទី ក្នុងនោះលោកដើរតួនាទីជាមេអគ្គសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទផង ក្នុងនាមជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្សប្រជាជនកម្ពុជា ទទួលបន្ទុកកិច្ចការនយោបាយបក្សដោយផ្ទាល់ និងរដ្ឋបាលស៊ីវិលក្នុងផ្នែកយោធភូមិភាគ ៤ ផង និងក្នុងតួនាទីជាអនុប្រធានគណៈបញ្ជាការឯកភាពរបស់កងយោធពលខេមរភូមិន្ទសម្រាប់សមរភូមិព្រំដែនកម្ពុជា-ថៃ ជាកន្លែងដែលអង្គភាពកងអង្គរក្សមានមូលដ្ឋាននៅទីនោះ ហើយបានចេញញត្តិមួយពីប្រាសាទព្រះវិហារក្នុងនាមមន្ត្រី និងកងទ័ពរបស់ខ្លួនគាំទ្រការទាមទារឱ្យដកលោក កឹម សុខា ចេញពីតំណែងជាអនុប្រធានទី១រដ្ឋសភា។*[370]

---

បក្ស នៅស្រុកអន្លង់វែង" ថ្ងៃទី 25 ខែកុម្ភៈ ឆ្នាំ 2016។ http://beta.nokorwatnews.com/?p=80031 (ចូលមើលថ្ងៃទី 26 ខែកុម្ភៈ ឆ្នាំ 2016)។

[368] អូន ភាព "គណបក្សកាន់អំណាចបានអះអាងពីការចុះចូលដ៏ច្រើនផ្សេងទៀត" ដឹខេមបូឌាដេលី ថ្ងៃទី 28 ខែធ្នូ ឆ្នាំ 2015។ https://www.cambodiadaily.com/news/ruling-party-claims-another-mass-defection-104015/ (ចូលមើលថ្ងៃទី 29 ខែធ្នូ ឆ្នាំ 2015)។

[369] អង្គការឃ្លាំមើលសិទ្ធិមនុស្ស; កម្ពុជា៖ *អូសទាញចេញពីឡាន ហើយវាយដំ (Draged and Beaten*): (តួនាទីរបស់រដ្ឋាភិបាលកម្ពុជា ក្នុងខែតុលា ឆ្នាំ 2015 ការវាយប្រហារទៅលើអ្នកនយោបាយគណបក្សប្រឆាំង )ថ្ងៃទី 26 ខែឧសភា ឆ្នាំ 2016)។ https://www.hrw.org/report/2016/05/26/dragged-and-beaten/cambodian- governments-role-october-2015-attack-opposition.

[370] "ឧត្តមសេនីយ៍ គន់ គីម តំណាងឲ្យមន្ត្រីទាំងអស់ មន្ត្រីគ្មានបេសកកម្ម និងទាហាន ស្នើសុំសម្តេច ហេង សំរិន ឱ្យដក លោក កឹម សុខា" ថ្ងៃទី 26 ខែតុលា ឆ្នាំ 2015។ http://www.dap-news.com/2011-06-14-02-39-55/101417-2015-10-26-09-04-53.html ចូលមើលថ្ងៃទី 26 ខែតុលា ឆ្នាំ 2016។

*ការប្រមូលផ្តុំប្រឆាំងលោក កឹម សុខា ក៏បានធ្វើឡើងនៅតំបន់យោធា និងរដ្ឋអំណាចនយោបាយក្រោមការគ្រប់គ្រងរបស់លោក គន់ គីម ដែរ ដូចជាក្នុងឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ នារសៀលថ្ងៃទី ២៦ ខែតុលា។ នៅពេលនោះ គេសង្កេតឃើញសមាជិកយោធាពីររូបក្នុងឯកសណ្ឋានយោធា ប្រដាប់ដោយអាវុធធុនធ្ងន់ មកពីកងពលធំអន្តរាគមន៍លេខ ២ នៃកងយោធពលខេមរភូមិន្ទ និងអ្នកស្លៀកសំលៀកបំពាក់ស៊ីវិល សំដែងការតវ៉ាប្រឆាំងនឹងលោក កឹម សុខា។ ហើយអ្នកតវ៉ាខ្លះទៀត ក៏បានអំពាវនាវឱ្យមានការបណ្តេញលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ចេញពីរដ្ឋសភាផងដែរ។*[371]

*នៅឆ្នាំ២០១៦ លោក គន់ គីម បានបន្តកាន់តួនាទីរបស់គាត់ជាមេបញ្ជាការចម្រុះនៃកងយោធពលខេមរភូមិន្ទ ផង និងជាសមាជិកនៃមេដឹកនាំកំពូលរបស់គណបក្សប្រជាជនកម្ពុជាផង ដើម្បីចេញបទបញ្ជាដែលមានចរិតនយោបាយដល់អង្គភាពនានាដោយផ្ទាល់ដែលនៅក្រោមអំណាចរបស់គាត់។ ឧទាហរណ៍ៈ លោក គន់ គីម បានណែនាំកងពលតូចអន្តរាគមន៍លេខ១ កាលពីខែឧសភាថា ត្រូវតែសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បី "ប្រឆាំងដាច់ខាតចំពោះអ្នកទាំងឡាយណាដែលមានល្បិច និងបង្កើតភាពចលាចល" ដែលជាទង្វើត្រូវចាត់ទុកថា ធ្វើឱ្យខូចប្រយោជន៍ដល់រដ្ឋាភិបាល។*[372] *ដូចគ្នានេះដែរ គាត់បានណែនាំក្រុមយោធាយោធភូមិភាគ ១ "មិនអនុញ្ញាតឱ្យមានបដិវត្តពណ៌ ដោយមនុស្សអាក្រក់មួយក្តាប់តូច មកបំបែកបំបាក់បង្កើតភាពចលាចល ឬ ធ្វើឱ្យមានអស្ថិរភាព"។*[373] *នៅថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០១៦ គាត់បានណែនាំកងពលធំអន្តរាគមន៍លេខ៣ ឱ្យអនុវត្តបទបញ្ជាមេបញ្ជាការកំពូល ចេញថ្ងៃទី៥ ខែកក្កដា របស់លោក ប៉ុល សារឿន ដើម្បី "កំចាត់ និងលុបបំបាត់ចោល" អ្នកដែលមានគំនិតប្រឆាំង។*[374] *នៅថ្ងៃដដែលនោះដែរ លោក គន់ គីម*

---

[371] "ប្រជាពលរដ្ឋ និង ក្រុមបាតុករ ខេត្តឧត្តរមានជ័យ ការដកលោក កឹម សុខា ចេញពីតំណែងអនុប្រធានរដ្ឋសភា" ថ្ងៃទី 26 ខែតុលា ឆ្នាំ 2015។ http://www.dap-news.com/2011-06-14-02-39-55/101420-2015-10-26-09-09-05.html (ចូលមើលថ្ងៃទី 26 ខែតុលា ឆ្នាំ 2016)។ "គណបក្សប្រជាជន ខេត្តឧត្តរមានជ័យ គាំទ្រសកម្មភាព ដើម្បីតវ៉ាចំពោះការដក កឹម សុខា ពីអនុប្រធានរដ្ឋសភា "ថ្ងៃទី 26 ខែតុលា ឆ្នាំ 2016។ http://www.dap-news.com/2011-06-14-02-39-55/101424-cpp-.html (ចូលមើលថ្ងៃទី 26 ខែតុលា ឆ្នាំ 2015)។ "ប្រជាពលរដ្ឋ និងទាហានជាង 500 នាក់ នៅស្រុកបន្ទាយអំពិល បានដាក់ញត្តិ ស្នើសុំឱ្យដកលោក កឹម សុខា ចេញពីតំណែងអនុប្រធានទី 1 នៃរដ្ឋសភា" ថ្ងៃទី 26 ខែតុលា ឆ្នាំ 2015។ http://kampucheathmey.com/kpt/?p=93686 (ចូលមើលថ្ងៃទី 26 ខែតុលា ឆ្នាំ 2015)។

[372] ឧត្តមសេនីយ៍ គន់ គីម អញ្ជើញជាអធិបតីក្នុងពិធីកិច្ចប្រជុំបូកសរុប ការងារគណបក្សប្រជាជន ប្រចាំខែមេសា និងដាក់គោលដៅឆ្ពោះទៅមុខសម្រាប់ខែឧសភា" ថ្ងៃទី 27 ខែមេសា ឆ្នាំ2016។ http://beta.nokorwatnews.com/?p=91856 (ចូលមើលថ្ងៃទី 1 ខែឧសភា ឆ្នាំ2016)។ "ឧត្តមសេនីយ៍គន់ គីម ចូលរួមកិច្ចប្រជុំ ដើម្បីពិនិត្យមើលលទ្ធផលនៃការងារអន្តរាគមន៍ របស់កងពលតូចលេខ 1" ថ្ងៃទី 10 ខែឧសភា ឆ្នាំ 2015។ http://beta.nokorwatnews.com/?p=95033 (ចូលមើលថ្ងៃទី 11 ខែឧសភា ឆ្នាំ 2016)។

[373] "ឧត្តមសេនីយ៍ គន់ គីម យកអាវភ្លៀង ជូនដល់កងទ័ព ដែលការពារខ្សែព្រំដែន ក្នុងខេត្តស្ទឹងត្រែង "ថ្ងៃទី 17 ខែឧសភា ឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/24302-2016-05-16-11-59-10.html (ចូលមើលថ្ងៃទី 18 ខែឧសភា ឆ្នាំ 2016)។

[374] "ឧត្តមសេនីយ៍ គន់ គីម ផ្តល់ឋានៈដល់មន្ត្រី នៅសមរភូមិមុខព្រំដែនកម្ពុជា ថៃ -" ថ្ងៃទី 8 កក្កដា ឆ្នាំ 2016។

ត្រូវបានអញ្ជើញឱ្យចូលរួមតាមខ្សែវីដេអូក្នុងកិច្ចប្រជុំប្រចាំសប្ដាហ៍ក្នុងទីស្ដីការគណរដ្ឋមន្ត្រីជាមួយលោក ហ៊ុន សែន ដែលមិនធ្លាប់មានពីមុនមក ដែលការចូលរួមនេះវាបានលើកមុខមាត់នយោបាយរបស់គាត់កាន់តែខ្ពស់ត្រដែតថែមទៀត។[375]

នៅឆ្នាំ២០១៦ដដែល ក្នុងសមត្ថកិច្ចរបស់គាត់ជាអគ្គលេខាធិការនៃសមាគមអតីតយុទ្ធជនកម្ពុជា ដែលមានអំណាចទូទាំងប្រទេស លោក គន់ គីម បានធ្វើដំណើរគ្រប់កន្លែង ដើម្បីដាក់បទបញ្ជាដល់សមាជិករបស់ខ្លួនឲ្យ "ប្រឆាំងដាច់ខាតនូវទង្វើទាំងឡាយ" ដែលរដ្ឋាភិបាលចាត់ថា "ជាបីសាចដែលញុះញង់នាំទៅដល់ការបែកបាក់សង្គមជាតិ"។ គាត់បញ្ជាក់ប្រាប់ពួកគេថា វាជាកាតព្វកិច្ចរបស់សមាជិកសមាគមដែលត្រូវគោរពតាម ដើម្បី "រក្សាសន្តិភាព" នៅក្នុងប្រទេសកម្ពុជា ដោយ "មិនត្រូវអនុញ្ញាតឱ្យមនុស្សមួយក្ដាប់តូចដែលមានបំណងអាក្រក់បំផ្លាញវាឡើយ។[376]"

នៅចុងឆ្នាំ២០១៦ លោក គន់ គីម បានរំលឹកឡើងម្ដងទៀតអំពីតួនាទីរបស់យោធា ថាជាកម្លាំងសម្រាប់រក្សានូវអ្វីដែលគាត់ចាត់ទុកថាជា "សន្តិសុខ និងសណ្ដាប់ធ្នាប់ល្អរបស់សង្គមជាតិ"។ លោក គន់ គីមបានសង្កត់ធ្ងន់លើតួនាទីរបស់លោកជាប្រតិភូរបស់លោក ហ៊ុន សែន ក្នុងការធានាបំពេញតួនាទីយោធានេះ ហើយសន្យាថា កងយោធពលខេមរភូមិន្ទនឹង "ប្រឆាំងយ៉ាងម៉ឺងម៉ាត់ចំពោះអ្នកទាំងឡាយណាដែលប្រព្រឹត្តមិនស្មោះត្រង់ និងគ្មានសីលធម៌ ដែលតែងប្រឌិតរឿងឥតឈប់ឈរ ដើម្បីមួលបង្កាច់ និងធ្វើប្រជាភិថុតិក្នុងបំណងអាក្រក់ប៉ុនប៉ងផ្ដួលរំលំរាជរដ្ឋាភិបាល" "តាមរូបភាពទ្រង់ទ្រាយណាមួយក៏ដោយ" ត្រូវតែប្រឆាំង

---

http://beta.nokorwatnews.com/?p=108418 (ចូលមើលថ្ងៃទី 9 ខែកក្កដា ឆ្នាំ 2016)។

375 "ឧត្តមសេនីយ៍ គន់ គីម អនុប្រធានបញ្ជាការជាន់ខ្ពស់ និងជាអគ្គមេបញ្ជាការកងទ័ពចម្រុះ ចូលរួមសន្និបាត ពេញអង្គ តាមរយៈ (ការប្រជុំតាមវីដេអូ) នៅទីស្ដីការគណរដ្ឋមន្ត្រី ថ្ងៃទី 8 ខែកក្កដា ឆ្នាំ 2016។ http://beta.nokorwatnews.com/?p=108289 (ចូលមើលថ្ងៃទី 9 ខែកក្កដា ឆ្នាំ 2016)។

376 "ឧត្តមសេនីយ៍ គន់ គីម អំពាវនាវឱ្យអតីតយុទ្ធជន បន្តរួបរួមគ្នាជាធ្លុងមួយ" ថ្ងៃទី 1 ខែសីហា ឆ្នាំ 2016។ http://dap-news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93%E1%9E%80%E 1%9F%92%E1%9E%93%E1% 9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%91%E1%9F%81%E1%9E%9F/12191.html (ចូលមើលថ្ងៃទី 1 ខែសីហា ឆ្នាំ 2016)។ "លោក គន់ គីម ជួបសមាជិកសមាគមអតីតយុទ្ធជន និងអ្នកចូលនិវត្តន៍ ជាង 200 នាក់ នៅស្រុកស្រីសន្ធរ"។ http://whttp://www.dap-news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93%E1%9E%80%E 1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%91%E1%9F%81%E1%9E%9F/6956.html (ចូលមើលថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2016)។

*ដាច់ខាត។[377] នៅខែមេសា ឆ្នាំ២០១៧ គាត់បានបញ្ជាក់ចំពោះកងទ័ពជើងទឹកនៃកងយោធពលខេមរភូមិន្ទ ថា នេះក៏ជាការងាររបស់ពួកគេដែលត្រូវបំពេញផងដែរ។[378]*

*លោក គន់ គីម បានរៀបរាប់អំពីតួនាទីរបស់សមាគមអតីតយុទ្ធជន ដោយអំពាវនាវឱ្យសមាជិកទាំងអស់ ចូលរួមជាមួយគ្នាដើម្បីរក្សាសន្តិភាពនិង "ភាពស្ងប់ស្ងាត់" និង "ធ្វើអ្វីដែលត្រូវធ្វើ" ដើម្បីទប់ស្កាត់ការផ្លាស់ប្តូរ ជោគជ័យនៃគោលនយោបាយរបស់លោក ហ៊ុន សែន។[379] គាត់បានពន្យល់ថា នេះរួមបញ្ចូលទាំងការធ្វើ សកម្មភាពជា "ភ្នាក់ងារ ជាភ្នែក និងជាត្រចៀក" នៃកងកម្លាំងសន្តិសុខ នៅថ្នាក់មូលដ្ឋានតាមបណ្តាខេត្ត នានា និងទាក់ទងគ្នាជាមួយអ្នកនៅភ្នំពេញ។[380] គាត់បានណែនាំអតីតយុទ្ធជន ឱ្យឃើញលោក ហ៊ុន សែន ថាជា "មេដឹកនាំដែលមានគុណសម្បត្តិពីធម្មជាតិ និងពោរពេញទៅដោយគុណធម៌ និងសប្បុរសធម៌។[381]*

---

[377] "ឧត្តមសេនីយ៍ គន់ គីម យកអាវភ្លៀង ទៅចែកជូន កងកម្លាំងប្រដាប់អាវុធ ក្នុងខេត្តកំពង់ឆ្នាំង" ថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/localnews/38620-2016-11-04-08-42-42.html (ចូលមើលថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2016)។ "ឧត្តមសេនីយ៍ គន់ គីម រំឭកកងទ័ពជើងទឹក ឱ្យចេញទៅការពារ អធិបតេយ្យភាព ដែនដី" ថ្ងៃទី 26 ខែមីនា ឆ្នាំ 2017។ http://www.freshnewsasia.com/index.php/en/localnews/50752-2017-03-26-06-18-52.html (ចូលមើលថ្ងៃទី 26 ខែមីនា ឆ្នាំ 2017)។

[378] កងទ័ពជើងទឹក ថា ការពារឯក"ភាពជាតិ" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី 5 ខែមេសា ឆ្នាំ 2017។ http://www.phnompenhpost.com/national/navy- told-defend-national-unity (ចូលមើលថ្ងៃទី 6 ខែមេសា ឆ្នាំ 2017)។

[379] ឧត្តមសេនីយ៍ គន់ គីម ជួបពិភាក្សាជាមួយ និងសាកសួរ សុខទុក្ខ អតីតយុទ្ធជនកម្ពុជាចំនួន 535 នាក់ នៅទៅក្រុងពោធិ៍សាត់" នៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/localnews/38622-2016-11-04-08-38-08.html (ចូលមើលថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2016)។ "ឧត្តមសេនីយ៍ គន់ គីម ចែកអាវអាវភ្លៀងជាង 4.000 អាវ ជាអំណោយពីសម្តេច តេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ដល់អង្គភាពទ័ព ការពារព្រំដែន" ថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/38746-2016-11-06-13-33-34.html (ចូលមើលថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2016)។ "ឧត្តមសេនីយ៍ គន់ គីម: គោលនយោបាយ ឈ្នះឈ្នះរបស់សម្តេចតេជោ បានធ្វើឱ្យកម្ពុជាបញ្ចប់សង្គ្រាម និងមានភាពស្និទ្ធិស្នាល ប្រកបដោយភាពស្ងប់ស្ងាត់ និងសន្តិភាព" ថ្ងៃទី 8 ខែវិច្ឆិកា ឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/localnews/38736-2016-11-06-08-18-30.html (ចូលមើលថ្ងៃទី 8 ខែវិច្ឆិកា ឆ្នាំ 2016)។ "ឧត្តមសេនីយ៍ គន់គីម ៖ អតីតយុទ្ធជនគឺជាវីរបុរសពិតរបស់យើង អាជ្ញាធរគ្រប់លំដាប់ ត្រូវតែយកចិត្តទុកដាក់ចំពោះពួកគេ" ថ្ងៃទី 20 ខែវិច្ឆិកា ឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/localnews/39716-2016-11-20-02-26-56.html (ចូលមើលថ្ងៃទី 20 ខែវិច្ឆិកា ឆ្នាំ 2016) ។

[380] "ឧត្តមសេនីយ៍ គន់ គីម ជជែកជាមួយ និងជូនដំណឹងអំពីការផ្តល់លំនៅដ្ឋានចំនួន 4 ដល់អតីតយុទ្ធជន នៅខេត្តសៀមរាប" ថ្ងៃទី 11 ខែធ្នូ ឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/localnews/41481-2016-12-11-16-55-28.html (ចូលមើលថ្ងៃទី 11 ខែធ្នូ ឆ្នាំ 2016)។ "ឧត្តមសេនីយ៍ គន់ គីម ជួប និងជជែកជាមួយអតីតយុទ្ធជន នៅខេត្តព្រះសីហនុ និងសម្រេចចិត្តសាងសង់ផ្ទះចំនួន 4 សម្រាប់អតីតយុទ្ធជនក្រីក្រលំបាក" ថ្ងៃទី 25 ខែមីនា ឆ្នាំ 2017។ http://www.freshnewsasia.com/index.php/en/localnews/50693-2017-03-25-07-27-00.html (ចូលមើលថ្ងៃទី 25 ខែមីនា ឆ្នាំ 2017)។ លោក កែប ជុតិមា លោក ម៉ម ប៊ុនហេង និងលោក ប៉ា សុជាតិវង្ស ផ្តល់ថវិការចំនួន 73 លានរៀល ដើម្បីដោះស្រាយបញ្ហាអតីតយុទ្ធជន" ថ្ងៃទី 22 ខែធ្នូ ឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/localnews/42370-2016-12-22-00-31-18.html (ចូលមើលថ្ងៃទី 22 ខែធ្នូ ឆ្នាំ 2016) ថ្ងៃទី 30 ខែមករា ឆ្នាំ 2017។ http://dap-news.com/kh/%E1%9E%96%E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93%E1%9E%80%E1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%91%E1%9F%81%E1%9E%9F/27856.html (ចូលមើលថ្ងៃទី 30 ខែមករាឆ្នាំ 2017)។

[381] "សម្តេច កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ផ្តល់ផ្ទះប្រាំមួយខ្នង ជូនអតីតយុទ្ធជន នៅខេត្តកំពត នៅពេលខួបកំណើតរបស់គាត់" ថ្ងៃទី 14 ខែធ្នូ ឆ្នាំ

*យ៉ាងហោចណាស់ ចាប់តាំងពីចុងឆ្នាំ២០១៦មក អនុប្រធានរបស់លោក គន់ គីម ដែលជាអគ្គលេខាធិការនៃសមាគមអតីតយុទ្ធជន គឺឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត ដែលជាកូនប្រុសច្បងរបស់លោក ហ៊ុន សែន។*[382] *ស្របពេលគ្នានោះដែរ លោក គន់ គីម ក៏បន្តកាន់តួនាទីជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមគណបក្សប្រជាជនកម្ពុជា និងជា "មន្ត្រីយោធាជាន់ខ្ពស់" ត្រួតពិនិត្យការងាររបស់គណបក្សប្រជាជនកម្ពុជា ក្នុងខេត្តឧត្តរមានជ័យ ជាខេត្តដែលគាត់ទទួលខុសត្រូវដោយផ្ទាល់ចំពោះការងាររបស់គណបក្សរួមទាំងការងាររៀបចំការបោះឆ្នោត នៅឆ្នាំ ២០១៧ និង ២០១៨ ផងដែរ។*[383]

*ថ្មីៗនេះ លោក គន់ គីម ក៏បានប្រកាសគាំទ្រការបំផ្លិចបំផ្លាញទាំងស្រុងនៃគណបក្សសង្គ្រោះជាតិ និងការចោទប្រកាន់រឿងផែនការបដិវត្តពណ៌ ដែលត្រូវបានចាប់ផ្តើមដោយការចាប់ខ្លួនលោក កឹម សុខា។ ថ្លែងក្នុងសមត្ថភាពជាអគ្គលេខាធិការនៃសមាគមអតីតយុទ្ធជន លោក គន់ គីម បញ្ជាក់ថា ក្នុងនាមលោកតំណាងឱ្យសមាជិកទាំងអស់ លោកមាន "កំហឹងយ៉ាងខ្លាំង" និងសូម "ថ្កោលទោសទាំងស្រុង" នូវ "អំពើក្បត់ជាតិ" របស់លោក កឹម សុខា និងគាំទ្រទាំងស្រុងចំពោះការចាត់វិធានការប្រឆាំងនឹងលោក កឹម សុខា និង "សហព័ន្ធរបស់គាត់" ចំពោះឧក្រិដ្ឋកម្ម" របស់ពួកគេដែលមិនអាចលើកលែងបានឡើយ។*[384]

*នៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៧ លោក គន់ គីម បានថ្លែងក្នុងវគ្គហ្វឹកហ្វឺនកងពលតូចលេខ ៩១១ ដោយណែនាំថា ត្រូវតែ "ជំទាស់ដាច់ខាតនូវរាល់មហិច្ឆតាអាក្រក់ ដែលចង់ធ្វើបដិវត្តពណ៌"។*[385] *លោកបានលើកយកសារនេះមកនិយាយឡើងវិញម្តងទៀតនៅក្នុងសុន្ទរកថាកាលពីថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៧ ទៅកាន់កងពលតូចអន្តរាគមន៍លេខ ១ នៃកងយោធពលខេមរភូមិន្ទ នៅខេត្តកំពង់ឆ្នាំង។*[386] *នៅថ្ងៃទី ២៤ ខែតុលា*

2016" http://www.freshnewsasia.com/index.php/en/localnews/41798-2016-12-14-11-21-11.html (ចូលមើលថ្ងៃទី 14 ខែធ្នូឆ្នាំ 2016)។

382 "លោក ហ៊ុន ម៉ាណែត៖ រាជរដ្ឋាភិបាលមិនបោះបង់ចោលអតីតយុទ្ធជនទេ គឺតែងតែយកចិត្តទុកដាក់ចំពោះពួកគេទាំងអស់គ្នា" ថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2016។ http://www.dap-news.com/kh/top-news/22926.html (ចូលមើលថ្ងៃទី 2 ខែធ្នូ ឆ្នាំ 2016)។

383 "លោក គន់ គីម ណែនាំសមាជិកគណបក្សប្រជាជន នៅក្នុងខេត្តឧត្តរមានជ័យ ឱ្យសម្លឹងមើលទុកលំបាករបស់ប្រជាពលរដ្ឋជាអាទិភាព " ថ្ងៃទី 20 ខែវិច្ឆិកា ឆ្នាំ 2016។ http://www.freshnewsasia.com/index.php/en/localnews/39741-2016-11-20-11-28-38.html (ចូលមើលថ្ងៃទី 20 ខែវិច្ឆិកា ឆ្នាំ 2016)។ "ផែនការ 5 ឆ្នាំ របស់គណបក្សប្រជាជនកម្ពុជា ខេត្តឧត្តរមានជ័យបញ្ហាសំខាន់ៗ : កំពុង ដោះស្រាយ ប្រឈមមុខដោយប្រជាពលរដ្ឋ និងកែលម្អការផ្តល់សេវា "ថ្ងៃទី 2 ខែមករា ឆ្នាំ 2017។ http://www.freshnewsasia.com/index.php/en/localnews/43284-2017-01-02-05-43-54.html (ចូលមើលថ្ងៃទី 2 ខែមករា ឆ្នាំ 2017)។ "លោក គន់ គីម ប្រាប់ក្រុមការងារគណបក្ស ឲ្យខិតខំប្រឹងប្រែងដោះស្រាយបញ្ហានានា សម្រាប់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន" ថ្ងៃទី 17 ខែមីនា ឆ្នាំ 2017។ http://www.freshnewsasia.com/index.php/en/localnews/50008-2017-03-17-06-48-23.html (ចូលមើលថ្ងៃទី 17 ខែមីនា ឆ្នាំ 2017)។

384 អតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស ប្រកាសថ្កោលទោសទង្វើក្បត់ជាតិ លោក កឹម សុខា និងគាំទ្រចំណាត់របស់រាជរដ្ឋាភិបាល។

385 នាយឧត្តមសេនីយ៍គន់ គីម ប្រាប់កងទ័ពឆ័ត្រយោង៩១១ ឲ្យរួមគ្នាប្រឆាំងរាល់ការប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាល។

386 នាយឧត្តមសេនីយ៍គន់គីម ប្រាប់កងទ័ពទាំងអស់ នៅកងពលតូចអន្តរាគមន៍លេខ១ ឲ្យរួមគ្នាប្រឆាំងរាល់ការប៉ុនប៉ង ផ្តួលរំលំរាជរដ្ឋាភិបាលស្រប

*ឆ្នាំ២០១៧ លោកបានបញ្ជាឱ្យកងពលធំលេខ១១ នៃកងយោធពលខេមរភូមិន្ទ ក្នុងខេត្តតាកែវ ចូលរួមក្នុង "ការប្រយុទ្ធប្រឆាំងនឹងអ្វីៗដែលលោកថា មានបំណងបង្កើតអស្ថេរភាព និងបដិវត្តពណ៌ ដូចដែលត្រូវបានរៀបចំ ដោយមេដឹកនាំនៃគណបក្សប្រឆាំង លោក កឹម សុខា និងលោក សម រង្ស៊ី។[387] ថ្ងៃនៅក្នុងសមត្ថភាពទាំងពីររបស់គាត់ គឺមេអគ្គសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ និងជាអគ្គលេខាធិការនៃសមាគមអតីតយុទ្ធជន និងក្នុងនាមនៃបុគ្គលិកយោធាសកម្មការងារ និងបុគ្គលិកយោធាចូលនិវត្តន៍ទាំងអស់ លោក គន់ គីម នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៧ បានប្រកាសចូលរួមយ៉ាងពេញទំហឹង តាមការវិនិច្ឆ័យរបស់តុលាការកំពូលចំពោះការរំលាយគណបក្សសង្គ្រោះជាតិចោល ដោយសារតែជាប់ចោទពាក់ព័ន្ធក្នុង "អំពើក្បត់ជាតិ" ដែលមិនអាចអត់អោនបាន និងតាមការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យមានវិធានជាមុនបន្ថែមទៀត ប្រឆាំងនឹងផែនការបដិវត្តពណ៌និងអ្នកនយោបាយ "បម្រើផលផលប្រយោជន៍បរទេស"។[388]*

## III. ឧត្តមសេនីយ៍សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថជាតិ និងអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ

### *លោក សៅ សុខា ក្នុងឆ្នាំ ១៩៧៧-១៩៧៨*

*ថ្ងៃកំណើតផ្លូវការរបស់លោក សៅ សុខា គឺនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៦១ និងកើតនៅខេត្តស្វាយរៀង។[389] ក្នុងបទសំភាសន៍ឆ្នាំ២០០០ គាត់បានប្រាប់ថា ឪពុកម្តាយរបស់គាត់គឺជាកសិករ។ គាត់បានសិក្សាត្រឹមថ្នាក់ទី ៥ ។ គាត់មានបងប្អូនប្រាំនាក់ ប៉ុន្តែទាំងអស់ត្រូវបានសម្លាប់ក្នុងអំឡុងរបបខ្មែរក្រហម។[390] គាត់បានទៅប្រទេសវៀតណាមនៅចុងឆ្នាំ១៩៧៧ ក្នុងពេលកងទ័ពវៀតណាមឈ្លានពានប្រទេសកម្ពុជាប្រឆាំងនឹងខ្មែរ*

---

ច្បាប់ ដឹកនាំដោយសម្តេចតេជោហ៊ុនសែន។

[387] នាយឧត្តមសេនីយ៍គន់គីម នាំអាវរងាររបស់សម្តេចតេជោហ៊ុនសែនជាងបីពាន់អាវ ជូនកងទ័ពនិងអំពាវនាវឲ្យកងទ័ពរួមគ្នាការពារសន្តិភាពប្រឆាំងក្រុមជនក្បត់ជាតិ។

[388] នាយឧត្តមសេនីយ៍គន់គីម កងទ័ពនិងអតីតយុទ្ធកម្ពុជា ប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះតុលាការកំពូល កាត់រំលាយគណបក្សសង្គ្រោះជាតិ និងគាំទ្រអនុសាសន៍ទាំងស្រុងរបស់សម្តេចតេជោហ៊ុន សែន។

[389] រាជរដ្ឋាភិបាលកម្ពុជា (RGC), "ឧត្តមសេនីយ៍ផ្កាយមាសបួនសៅ សុខា " បញ្ជីឈ្មោះអ្នកបោះឆ្នោតបណ្តោះអាសន្ន 2017, ឯកសារ 05-977-306។

[390] ប្រ៊ែដ អាដាមស៍ (Brad Adams) បទសម្ភាសន៍ជាមួយសៅ សុខាថ្ងៃទី 22 ខែកុម្ភៈឆ្នាំ 2000 រាជធានីភ្នំពេញ។

*ក្រហមនៅខេត្តស្វាយរៀង។[391] នៅឆ្នាំ១៩៧៨ វៀតណាមបានចាត់តាំងលោក សៅ សុខា ធ្វើការឲ្យលោក ហ៊ុន សែន គឺជាពេលដែលលោកបានក្លាយជាអង្គរក្សរបស់លោក ហ៊ុន សែន ។[392] លោកក៏បានដើរតួជាអ្នកនាំសាររបស់លោក ហ៊ុន សែន នៅក្នុងអង្គភាពចល័ត ហើយក៏ត្រូវបានដាក់បញ្ចូលទៅក្នុងកងវរសេនាតូចប្រឆាំងប៉ុល ពតដែលទើបបានបង្កើតឡើងដោយលោក ហ៊ុន សែន នៅក្នុងប្រទេសវៀតណាម។[393]*

## *លោក សៅ សុខា និងសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា ១៩៧៩-១៩៩១*

*បន្ទាប់ពីការបង្កើតរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅខែមករា ឆ្នាំ១៩៧៩ លោក សៅ សុខាត្រូវបានចាត់តាំងទៅកាន់កងពលធំលេខ ១ ដែលមានភារកិច្ចការពារទីក្រុងភ្នំពេញ។[394] កងពលធំនេះ មានកងវរសេនាតូចចំនួន ៤ មានជាអាទិ៍ កងវរសេនាតូចលេខ ២៤៦ អង្គភាពសំខាន់របស់ខ្លួន និងអង្គភាពមួយទៀតក្នុងចំណោមនោះ ដែលត្រូវបានបង្កើតឡើងដោយលោក ហ៊ុន សែន នៅវៀតណាម។[395] កងពលធំលេខ ១ គឺជាស្នូលសម្រាប់អង្គការចាត់តាំង និងជាការជ្រើសរើសសម្ព័ន្ធយុវជនបក្សកុម្មុយនីស្តរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវបានបង្កើតឡើងវិញនៅក្នុងជួរកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា ដែលដឹកនាំដោយស្នងការនយោបាយកំពូលរបស់ក្រសួងការពារជាតិ។[396] លោក សៅ សុខា ដើរតួក្នុងសកម្មភាពពង្រឹងនយោបាយទាំងនេះ ក្នុងចំណោមយុវវ័យយោធា។[397] កងពលធំលេខ ១ ក៏បានធ្វើការហ្វឹកហ្វឺនផ្នែកយោធា និងនយោបាយទៅលើអ្នកជ្រើសរើសថ្មីសម្រាប់អង្គភាពយោធារបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាដទៃទៀត នៅទូទាំងប្រទេស។[398]*

---

391 ពីប្រភពដដែល Ibid. បទសម្ភាសន៍លោក Peter Bartu ជាមួយសៅសុខារាជធានីភ្នំពេញថ្ងៃទី 11 ខែធ្នូឆ្នាំ 2007។

392 ពីប្រភពដដែល Ibid.

393 រាជរដ្ឋាភិបាលកម្ពុជា (RGC) "ឧត្តមសេនីយ៍ផ្កាយមាសបួនសៅសុខា "ហ៊ុនសែន " ហ៊ុនសែន, សុន្ទរកថាដែលបានជ្រើសរើសនៅឯពិធីបិទមហាសន្និបាតវិសាមញ្ញនៃអ្នកតំណាងទូទាំងប្រទេសនៃសមាគមអតីតយុទ្ធជនកម្ពុជា និងការប្រារព្ធខួបលើកទី ៣ នៃទិវាអតីតយុទ្ធជនកម្ពុជាថ្ងៃទី 21 ខែមិថុនាឆ្នាំ 2010" http://cnv.org.kh/speech-at-the-closing-ceremony-of- extra-ordinary-congress-of-representatives-of-cambodian-veteran-association-nationwide-and-3rd-anniversary-of- cambodian-veteran-day/ (ចូលមើលថ្ងៃទី 23 ខែកញ្ញាឆ្នាំ 2010)។ បទសម្ភាសន៍ជាមួយលោកសៅសុខា រាជធានីភ្នំពេញថ្ងៃទី11 ខែធ្នូ ឆ្នាំ2007 "ជាផ្នែកមួយនៃប្រវត្តិសាស្ត្រ) "M9t phan lich sU'), QDND។

394 វិទ្យុភ្នំពេញថ្ងៃទី 17 ខែកុម្ភៈឆ្នាំ 1979។ SPK ថ្ងៃទី 22 ខែមីនាឆ្នាំ 1979។ វិទ្យុភ្នំពេញថ្ងៃទី 8 ខែមេសាឆ្នាំ 1979។

395 ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស COHCHR សម្ភាសជាមួយមន្ត្រីសន្តិសុខថ្ងៃទី 16 មិនាឆ្នាំ 2004 ។ "ជាផ្នែកមួយនៃប្រវត្តិសាស្ត្រ " (M9t phan lich sU '), QDND។

396 វិទ្យុភ្នំពេញ, ថ្ងៃទី 8 ខែធ្នូឆ្នាំ 1979។

397 រាជរដ្ឋាភិបាលកម្ពុជា (RGC), "ឧត្តមសេនីយ៍ផ្កាយមាសបួន សៅសុខា។ "

398 សារព័ត៌មានអេស្តេកា (SPK), ថ្ងៃទី 1 ខែមីនាឆ្នាំ 1980។ វិទ្យុភ្នំពេញថ្ងៃទី 5 ខែមីនាឆ្នាំ 1980 ។ វិទ្យុភ្នំពេញថ្ងៃទី 23 ខែមេសាឆ្នាំ 1980។ វិទ្យុភ្នំពេញថ្ងៃទី 26 ខែមេសាឆ្នាំ 1980។

លើសពីនេះ កងពលធំលេខ ១ បានធ្វើប្រតិបត្តិការសកម្មនៅក្នុង និងជុំវិញរាជធានីភ្នំពេញ ដើម្បី "ពង្រឹងអំណាចបដិវត្តន៍" របស់រដ្ឋបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយការបង្ក្រាបសត្រូវដែលគេបានចោទប្រកាន់ថា "ក្លែងបន្លំខ្លួនក្នុងចំណោមប្រជាជន" និង "ការកម្ទេច" មនុស្សដែលបក្សប្រជាជនបដិវត្តន៍កម្ពុជាចាត់ទុកថា "ពួកប្រតិកិរិយា" ដោយអះអាងថា នៅខែមិថុនាឆ្នាំ១៩៨០ ពួកគេបានចាប់ខ្លួនខ្មាំងសត្រូវនយោបាយចំនួន ១៥៥នាក់។[399] នៅក្រោមរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា អ្នកដែលត្រូវបានចោទថាជាខ្មាំង មិនមែនត្រឹមតែជាក្រុមសំណល់ខ្មែរក្រហមដឹកនាំដោយប៉ុលពតប៉ុណ្ណោះទេ ប៉ុន្តែរួមបញ្ចូលទាំងក្រុមទាំងឡាយណាដែលប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា មានអាវុធក្តី មិនមានអាវុធក្តី។[400] ក្រោយមកទៀតក្នុងអំឡុងឆ្នាំ១៩៨០ កងពលធំលេខ ១ ត្រូវបានបំបែកទៅជាក្រុមៗ ហើយដាក់ពង្រាយនៅតាមជនបទ ដើម្បីប្រយុទ្ធប្រឆាំងនឹងសត្រូវ។ នៅឆ្នាំ១៩៨១ ក្រុមទាំងនោះត្រូវបានរំសាយ ហើយបានផ្តល់កម្លាំងទៅឲ្យអង្គភាពដទៃទៀតនៃកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា ដែលរួមមានកងវរសេនាធំលេខ ៧០ នៅរាជធានីភ្នំពេញ ដែលកម្លាំងនេះត្រូវបានផ្ទេរមកពីកងវរសេនាតូចលេខ ២៤៦ដែរ។[401]

បន្ទាប់មក លោក សៅ សុខា ត្រូវបានបញ្ជូនទៅប្រទេសវៀតណាម ដើម្បីទទួលការអប់រំកម្រិតខ្ពស់។[402] គាត់បានវិលត្រឡប់មកកម្ពុជាវិញនៅឆ្នាំ១៩៨៣ ហើយបានចូលបម្រើការងារឡើងវិញនៅឧត្តមស្នងការនយោបាយរបស់ក្រសួងការពារជាតិ ដែលគាត់មានតួនាទីបង្រៀនដល់បុគ្គលិកយោធា ដើម្បីឱ្យមានភាពស្មោះត្រង់ខាងនយោបាយចំពោះបក្សប្រជាជនបដិវត្តន៍កម្ពុជា និងជួយពង្រីកសមាជិកភាពរបស់បក្ស។[403] កិច្ចការសាបព្រួសមនោគមវិជ្ជានេះ រួមបញ្ចូលទាំងការបង្រៀនថា សកម្មភាពរបស់កងទ័ព គឺរាប់បញ្ចូលទាំងការជីករំលើងចោលនូវឫស្សគល់នៃ "កងកម្លាំងលាក់ខ្លួន" របស់ខ្មាំងសត្រូវក្នុងចំណោមប្រជាជន ដែលការងារនេះគឺមានសារសំខាន់ស្មើនឹងប្រតិបត្តិការយោធារបស់កងទ័ពដែរ។[404] អ្នករៀនសូត្រត្រូវបានគេប្រាប់

---

[399] វិទ្យុភ្នំពេញនៅថ្ងៃទី 18 ខែមិថុនាឆ្នាំ 1980។

[400] វិទ្យុភ្នំពេញថ្ងៃទី 17 ខែតុលាឆ្នាំ 1980។

[401] វិទ្យុភ្នំពេញ ភ្នំពេញថ្ងៃទី 22 ខែមករាឆ្នាំ 1981 "ផ្នែកមួយនៃប្រវត្តិសាស្ត្រ" ( M9t phan lich sU '), QDND។ អ៊ុនតាក់ "អង្គការនៃក្រសួងការពារជាតិ " កងវរសេនាធំ "លេខ70"ថ្ងៃទី 30 ខែមិថុនាឆ្នាំ 1992។

[402] វិទ្យុភ្នំពេញ ភ្នំពេញថ្ងៃទី 22 ខែមករាឆ្នាំ 1981 "ផ្នែកមួយនៃប្រវត្តិសាស្ត្រ) "M9t phan lich sU '), QDND។ វិទ្យុភ្នំពេញថ្ងៃទី 27 ខែឧសភាឆ្នាំ 1981។

[403] ភ្នំពេញវិទ្យុ, ថ្ងៃទី 13 ខែមករាឆ្នាំ 1984។ វិទ្យុភ្នំពេញថ្ងៃទី 6 ខែមីនាឆ្នាំ 1984។ បទសម្ភាសន៍ជាមួយសៅ សុខាថ្ងៃទី 11 ខែធ្នូឆ្នាំ 2007។

[404] សារព័ត៌មានអេស្ពេកា (SPK), ថ្ងៃទី 28 ខែឧសភាឆ្នាំ 1986។

ផងដែរថា ពួកយោធាទទួលខុសត្រូវក្នុងការរក្សាសណ្តាប់ធ្នាប់សង្គម។[405] អនុលោមតាមការអប់រំនយោបាយបែបនេះ អង្គភាពកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា នៅគ្រានោះ ក៏បានចាប់ខ្លួនមនុស្សជាច្រើន ដែលរងការចោទប្រកាន់ថា ជាចារកម្មសត្រូវ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០។[406]

នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ លោក សៅ សុខា ក៏បានចូលរួមក្នុងប្រតិបត្តិការស៊ើបការណ៍សម្ងាត់របស់ក្រសួងការពារជាតិ ដែលជា "អង្គភាពស៊ើបអង្កេតស្រាវជ្រាវ" ក្រោមអគ្គសេនាធិការរបស់ក្រសួង។[407] ប្រតិបត្តិការនេះ មានសិទ្ធិចាប់ខ្លួនមនុស្សនៅទូទាំងប្រទេសកម្ពុជា រួមទាំងអ្នកជាប់សង្ស័យថា មានសកម្មភាពរបស់សត្រូវ នៅក្នុងកងកម្លាំងប្រដាប់អាវុធ និងក្រសួងការពារជាតិ ក៏ដូចជាមនុស្សផ្សេងទៀត ដែលសកម្មភាពរបស់ពួកគេបានប៉ះពាល់ដល់យោធា។[408] នៅឆ្នាំ១៩៩០ លោក សៅ សុខា ត្រូវបានផ្លាស់ជាបណ្តោះអាសន្នឱ្យទៅនៅក្នុងកងពលធំលេខ១៨៦ របស់កងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា (RPAFK) និងបានប្រយុទ្ធក្នុងសមរភូមិនៅខេត្តបាត់ដំបងភាគខាងលិចកម្ពុជា។[409] ដូចជាអង្គភាពកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា (RPAFK)ដទៃទៀតដែរ កងពលធំលេខ១៨៦ បានធ្វើការចាប់ខ្លួនខាងនយោបាយ។[410]

ចាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១ លោក សៅ សុខា មានជាប់ពាក់ព័ន្ធយ៉ាងច្រើនជាមួយអង្គភាពទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលជាផ្នែកមួយនៃយុទ្ធនាការចាប់ខ្លួននិងឃុំឃាំងមនុស្សដោយផ្អែកលើមូលដ្ឋាននយោបាយ និងដែលជាទូទៅស្ទើរតែគ្មានការចោទប្រកាន់ ឬការកាត់ក្តីអ្វីឡើយ ហើយត្រូវបានដាក់ឲ្យស្ថិតក្រោមការធ្វើទារុណកម្ម។[411] ពន្ធនាគាររបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា រួមបញ្ចូលទាំងបន្ទាយដែលគ្រប់គ្រងដោយយោធា នៅថ្នាក់ជាតិ ថ្នាក់តំបន់ ខេត្ត និងអង្គភាព។

មនុស្សដែលគេសង្ស័យថា ជាប់«ពាក់ព័ន្ធ»នឹងសត្រូវ និងជាអ្នកស៊ើបការណ៍ឱ្យសត្រូវដែលត្រូវបានចាប់ខ្លួន

---

405 វិទ្យុភ្នំពេញថ្ងៃទី 3 ខែមករាឆ្នាំ 1989។

406 វិទ្យុភ្នំពេញថ្ងៃទី 17 ខែសីហាឆ្នាំ 1984។ វិទ្យុទីក្រុងភ្នំពេញ ថ្ងៃទី 1 ខែតុលាឆ្នាំ 1987។ វិទ្យុភ្នំពេញថ្ងៃទី 24 ខែមករាឆ្នាំ 1990។

407 បទសម្ភាសន៍ជាមួយសៅសុខា ថ្ងៃទី11 ខែធ្នូឆ្នាំ 2007។ សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ អនុក្រឹត្យលេខ25 អនក្រ ចុះថ្ងៃទី20 ខែវិច្ឆិកាឆ្នាំ 1985។

408 អង្គការលើកលែងទោសអន្តរជាតិ, កម្ពុជា៖ ការដាក់ពន្ធនាគារ និងការធ្វើទារុណកម្មនយោបាយ (ទីក្រុងឡុងដ៍1987)។ LCIHR, *បន្ទាប់ពីស្ថានការណ៍អាក្រក់បំផុត។*

409 បទសម្ភាសន៍ជាមួយ សៅ សុខា ថ្ងៃទី 11 ខែធ្នូឆ្នាំ 2007។

410 វិទ្យុភ្នំពេញថ្ងៃទី 12 ខែមីនាឆ្នាំ 1984។

411 អង្គការលើកលែងទោសអន្តរជាតិ, កម្ពុជា៖ ការដាក់ពន្ធនាគារនិងការធ្វើទារុណកម្មនយោបាយ (ទីក្រុងឡុងដ៍1987)។ LCIHR, *បន្ទាប់ពីស្ថានការណ៍អាក្រក់បំផុត។*

ដោយពួកឈ្លបភូមិ និងឃុំត្រូវបានប្រគល់ទៅឲ្យមន្ត្រីយោធាជាន់ខ្ពស់។ នៅថ្នាក់ជាតិ ស្នងការស្រាវជ្រាវជូនកាលដាក់អ្នកទោសនៅក្នុងបន្ទាយយោធារបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានបង្កើតឡើងនៅសង្កាត់ទួលស្វែង រាជធានីភ្នំពេញ ប៉ុន្តែមានមណ្ឌលឃុំឃាំងពិសេសមួយ នៅខណ្ឌទួលគោក និងមជ្ឈមណ្ឌលឃុំឃាំងសម្ងាត់តូចៗជាច្រើន។ មនុស្សមួយចំនួនដែលត្រូវបានសួរចម្លើយដោយស្នងការស្រាវជ្រាវ ត្រូវបានបញ្ជូនទៅពន្ធនាគារក្រសួងមហាផ្ទៃ ឬពន្ធនាគាររាជធានីភ្នំពេញ ដែលគេស្គាល់ថា ជាគុកតេ៣ (T3)។[412]

## លោក សៅ សុខា ក្នុងសម័យអ៊ុនតាក់ និងក្រោយអ៊ុនតាក់ ឆ្នាំ១៩៩១-១៩៩៦

ក្នុងអំឡុងពេលអ៊ុនតាក់ លោក សៅ សុខា ត្រូវបានគេដាក់ភារកិច្ចឲ្យធ្វើការទំនាក់ទំនងជាមួយកងកម្លាំងប្រដាប់អាវុធរបស់អង្គការសហប្រជាជាតិនៅខេត្តកំពង់ធំ ដែលជាសមរភូមិដ៏សំខាន់មួយជាមួយខ្មែរក្រហម។ បន្ទាប់ពីការបោះឆ្នោតនៅខែឧសភា ឆ្នាំ១៩៩៣ គាត់ត្រូវបានចាត់តាំងទៅកាន់កងរាជអាវុធហត្ថ (GRK)។[413] គាត់គឺជានាយទាហានដំបូងគេក្នុងចំណោមនាយទាហាផ្សេងទៀតមកពីគណបក្សប្រជាជនកម្ពុជា ដែលចូលរួមជាមួយកងរាជអាវុធហត្ថលើផ្ទៃប្រទេស ហើយបានក្លាយជាមេបញ្ជាការរងនៃកងកម្លាំងរាជអាវុធហត្ថជាតិក្នុងការបើកសម្ពោធជាផ្លូវការនៃកងកម្លាំងនេះនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៣។[414] គាត់ក៏ជានាយអគ្គសេនាធិការកងរាជអាវុធហត្ថ ដោយបញ្ជាផ្ទាល់ទៅលើកងកម្លាំងអន្តរាគមន៍ចល័តជាតិនៃរាជអាវុធហត្ថ រួមទាំងកងទ័ពថ្មើរជើង រថពាសដែក និងកងកម្លាំងម៉ូតូ។[415]

លោក សៅ សុខា និងកងរាជអាវុធហត្ថ (GRK) បានរះឡើងតាមការវាយតម្លៃរបស់លោក ហ៊ុន សែន បន្ទាប់ពីលោក សៅ សុខា បានចាប់ខ្លួនដោយផ្ទាល់នូវមន្ត្រីកងកម្លាំងសន្តិសុខសំខាន់ៗរបស់គណបក្សប្រជាជនកម្ពុជា ដែលប៉ុនប៉ងផ្តួលរំលំលោក ហ៊ុន សែន និងព្រះអង្គម្ចាស់រណឫទ្ធិ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៤។ លោក សៅ សុខា បានធ្វើសកម្មភាពចាប់ខ្លួនមន្ត្រីទាំងនោះតាមបញ្ជាទូរស័ព្ទពីលោក ហ៊ុន សែន ក្រោយពី

---

412 ពីប្រភពដដែល Ibid.

413 រាជរដ្ឋាភិបាលកម្ពុជា (RGC), "ឧត្តមសេនីយផ្កាយមាសបួនសៅ សុខា "

414 រាជរដ្ឋាភិបាលកម្ពុជា (RGC) "កាលប្បវត្តិនៃកងរាជអាវុធហត្ថ "រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យលេខ 11 អនក្រ ថ្ងៃទី 8 ខែមីនាឆ្នាំ 1994។ ប្រវត្តិសាស្រ្តឧត្តមសេនីយ៍សៅ សុខា។ រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ 17 អនក្រ ចុះថ្ងៃទី 18 ខែវិច្ឆិកាឆ្នាំ 1993 ។ រាជរដ្ឋាភិបាលកម្ពុជា )RGC) អនុក្រឹត្យលេខ 77 អនក្រ ចុះថ្ងៃទី 21 ខែធ្នូឆ្នាំ1994។

415 រាជរដ្ឋាភិបាលកម្ពុជា (RGC), "ឧត្តមសេនីយ៍ផ្កាយមាសបួនសៅ សុខា។" UNOSGRC "កងយោធពលខេមរភូមិន្ទកម្ពុជា"ឆ្នាំ1995 ។

*លោក ហ៊ុន សែនបានទទួលដំណឹងពីលោក នេត សាវឿន ស្នងការនគរបាលរាជធានីភ្នំពេញ អំពីការប៉ុនប៉ងធ្វើរដ្ឋប្រហារ ។*[416]

*នៅពេលដែលកងរាជអាវុធហត្ថលើផ្ទៃប្រទេសត្រូវបានគេពង្រីកនៅឆ្នាំ១៩៩៤-៩៦ អ្នកឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានកត់ត្រាពីការជាប់ពាក់ព័ន្ធរបស់កងកម្លាំងនេះ នៅក្នុងឧក្រិដ្ឋកម្មផ្សេងៗរាប់ចាប់ពីការជម្រិតទារលុយនៅតាមចិញ្ចើមផ្លូវ រហូតដល់ការជួញដូរគ្រឿងញៀន។ មកដល់ឆ្នាំ១៩៩៦ អ្នកឃ្លាំមើលបានចងក្រងឯកសារអំពីការរំលោភសិទ្ធិមនុស្សរបស់កងរាជអាវុធហត្ថខ្មែរជាច្រើន រួមមានការសម្លាប់ ការធ្វើទារុណកម្ម និងការរំលោភបំពានផ្សេងៗទៀត។*[417] *កងរាជអាវុធហត្ថខ្មែរ ក៏ត្រូវបានផ្សារភ្ជាប់ទៅនឹងសកម្មភាពអាជីវកម្មខុសច្បាប់ ដែលជួនកាលនាំទៅរកការប្រឈមមុខគ្នាដោយហិង្សាជាមួយប៉ូលីស។*[418]

## *លោក សៅ សុខា និងរដ្ឋប្រហាររបស់លោក ហ៊ុន សែន ឆ្នាំ ១៩៩៧*

*កងរាជអាវុធហត្ថ និងលោក សៅ សុខា បានដើរតួយ៉ាងសំខាន់នៅក្នុងការធ្វើរដ្ឋប្រហារនៅថ្ងៃទី៥ និង ៦ ខែកក្កដាឆ្នាំ ១៩៩៧ ប្រឆាំងនឹងគណបក្សហ៊្វុនស៊ិនប៉ិច និងការរៀបចំមុនរដ្ឋប្រហារ។ បុគ្គលជាគោលដៅចម្បងរបស់ប្រតិបត្តិការរបស់លោក ហ៊ុន សែន គឺឧត្តមសេនីយ៍ញឹក ប៊ុនឆៃ ជាមេដឹកនាំកងទ័ពគណបក្សហ៊្វុនស៊ិនប៉ិច។ ចលនាយោធារបស់គណបក្សប្រជាជនកម្ពុជាមុនពេលធ្វើរដ្ឋប្រហារទៅលើហ៊្វុនស៊ិនប៉ិច រួមបញ្ចូលទាំងការវាយប្រហាររបស់កងរាជអាវុធហត្ថ ទៅលើមូលដ្ឋានហ៊្វុនស៊ិនប៉ិចនៅព្រៃកតាទែន ភាគខាងជើងនៃរាជធានីភ្នំពេញ។*[419]

---

[416] សម្ភាសន៍ជាមួយមន្ត្រីប៉ូលីសទី 10 ខែវិច្ឆិកាឆ្នាំ 1995។ បទសម្ភាសន៍ជាមួយសៅ សុខាថ្ងៃទី 11 ខែធ្នូឆ្នាំ 2007 ទំនប់វារីអគ្គីសនី ដំណឹងពេលព្រឹក ថ្ងៃទី 5 ខែកក្កដាឆ្នាំ 1994 ។

[417] COHCHR "ការរំលោភសិទ្ធិមនុស្សដោយសមាជិកនៃកងកម្លាំងសន្តិសុខ" (អនុស្សរណៈដាក់ជូនឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស"( ថ្ងៃទី 27 ខែកុម្ភៈ ឆ្នាំ1996 ។

[418] ពីប្រភពដដែល Ibid.

[419] បទសម្ភាសន៍ជាមួយមន្ត្រីហ្វ៊ុនស៊ិនប៉ិច ថ្ងៃទី 2 ខែកក្កដាឆ្នាំ 1997។

*នៅថ្ងៃទី ៥-៦ ខែកក្កដា មណ្ឌលបញ្ជារដ្ឋប្រហាររបស់លោក ហ៊ុន សែនសម្រាប់ទីក្រុងភ្នំពេញ ត្រូវបានដឹកនាំដោយអគ្គស្នងការនគរបាលជាតិ លោក ហុក ឡុងឌី ចំណែកឯមេបញ្ជាការកងកម្លាំងរាជអាវុធហត្ថ គឺលោក គៀង សាវុធ និងលោក សៅ សុខា ជាបញ្ជាការរងនិងចូលរួមជាមួយដោយលោក នេត សាវឿន។[420] នេះមិនមែនជាឋានានុក្រមនយោបាយដែលបង្កើតឡើយដោយកងយោធពលខេមរភូមិន្ទ ដែលលោក ហ៊ុន សែន មិនអាចពឹងផ្អែកបាននោះទេ ប៉ុន្តែវាគឺជារចនាសម្ព័ន្ធនយោបាយដែលលោក ហ៊ុន សែន បានបង្កើតឡើងសម្រាប់គោលបំណងធ្វើរដ្ឋប្រហារប្រដាប់អាវុធយ៉ាងមានប្រសិទ្ធភាព ជាមួយកងរាជអាវុធហត្ថដែលបានទទួលការហ្វឹកហាត់យ៉ាងស្ទាត់ជំនាញ ដែលជាធាតុផ្សំដ៏សំខាន់មួយ។ ហើយក្នុងអំឡុងពេលរដ្ឋប្រហារនោះ លោក សៅ សុខាមានទំនាក់ទំនងដោយផ្ទាល់ជាមួយលោក ហ៊ុន សែនលើបញ្ហាកលយុទ្ធ។[421] តាមការវាយតម្លៃរបស់លោក ហ៊ុន សែន មេបញ្ជាការកងរាជអាវុធហត្ថលោក គៀង សាវុធ មិនបានបំពេញការងារល្អប្រសើរក្នុងការប្រយុទ្ធនោះទេ។ ផ្ទុយទៅវិញលោក សៅ សុខាបានជួយច្រើនក្នុងរដ្ឋប្រហារនោះ គឺលោកបានដឹកនាំកងទ័ពផ្តួលរំលំទ័ពហ៊្វុនស៊ីនប៉ិចនៅភាគខាងលិចរាជធានីភ្នំពេញ។[422]*

*លោក សៅ សុខា ក៏បានដឹកនាំការវាយប្រហារបន្ត កម្ទេចកងទ័ពគណបក្សហ៊្វុនស៊ិនប៉ិចនៅទីកន្លែងដទៃទៀតក្នុងរាជធានីឱ្យទាល់ច្រក បង្ខំឱ្យមន្ត្រីគណបក្សហ៊្វុនស៊ីនប៉ិចភៀសខ្លួនចេញក្នុងភាពច្របូកច្របល់។[423] កងទ័ពរបស់លោក សៅ សុខា បានបន្តដេញតាមកម្លាំងស្មោះត្រង់នឹងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ[424] ដែលពួកគេហៅថាជា"កម្លាំងអនាធិបតេយ្យ" ។ លោក សៅ សុខា បានបញ្ជាឱ្យកងកម្លាំងរដ្ឋប្រហារ "បោសសម្អាតចេញ .. ឲ្យស្អាត និងកំចាត់ចោលឱ្យអស់" ជាពាក្យនិយមប្រើរបស់ពួកខ្មែរក្រហមសំដៅដល់ការប្រហារជីវិត។[425] ជ័យជម្នះរបស់លោក ហ៊ុន សែន អមដោយរលកនៃការសម្លាប់ក្រៅប្រព័ន្ធតុលាការ ការដុតបូជាសាកសពដែលមិនដឹងអត្តសញ្ញាណដែលជាករណីដ៏គួរឲ្យសង្ស័យ ការធ្វើទារុណកម្ម និងការឃុំខ្លួន*

420 ប្រ៊ែដ អាដាមស៍ សម្ភាសមន្ត្រីយោធាគណបក្សប្រជាជន និងហ៊្វុនស៊ីនប៉ិច។ សម្ភាសន៍ជាមួយលោកហ៊ុនសែន នាថ្ងៃទី 21 កញ្ញាឆ្នាំ 2007។

421 ប្រ៊ែដ អាដាមស៍ (Brad Adams) បទសម្ភាសន៍ជាមួយសៅសុខា ថ្ងៃទី 22 កុម្ភៈ ឆ្នាំ2000។ Brad Adams សម្ភាសយោធាអូស្ត្រាលី ថ្ងៃទី 2 មីនា 2000 ។

422 កិច្ចសម្ភាសន៍ជាមួយហ៊ុនសែនថ្ងៃទី 21 ខែកញ្ញាឆ្នាំ 2007។

423 ប្រ៊ែដ អាដាមស៍ (Brad Adams) សម្ភាសជាមួយមន្ត្រីយោធានិងមន្ត្រីស៊ីវិលគណបក្សប្រជាជន។

424 ប្រ៊ែដ អាដាមស៍ (Brad Adams) សម្ភាសជាមួយសម្ព័ន្ធយោធាបរទេស។

425 បទសម្ភាសន៍ជាមួយហ៊ុនសែន ថ្ងៃទី 21 ខែកញ្ញាឆ្នាំ 2007។ ពីប្រភពប្រភពព័ត៌មាន Ibid . ECCC ការិយាល័យសហចៅក្រមស៊ើបអង្កេត"ដីកាបិទ" ( D427) ថ្ងៃទី 15 ខែកញ្ញាឆ្នាំ 2010 ទំព័រ 48, 51, 58, 188, 202-5, 233-4, និង 266 ។

តាមអំពើចិត្ត ភាគច្រើនជនរងគ្រោះគឺជាសមាជិកនៃកងកម្លាំងសន្តិសុខរបស់ហ៊ុនស៊ិនប៉ិច។[426] អ្នកតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា លោកថូម៉ាស ហាំម៉ាប៊ឺក (Thomas Hammarberg) នៅពេលនោះ បានរាយការណ៍ថា ទីស្នាក់ការកណ្តាលកងរាជអាវុធហត្ថលើផ្ទៃប្រទេសនៅទួលគោក ត្រូវបានគេប្រើប្រាស់ដើម្បីឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់មនុស្ស។[427]

អ្នកស៊ើបអង្កេតសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក៏បានរកឃើញថា ទាហានហ៊ុនស៊ិនប៉ិចដែលត្រូវចាប់ខ្លួនយ៉ាងហោចណាស់ ៣០ នាក់ត្រូវបានឃុំឃាំងដោយកងរាជអាវុធហត្ថ ដើម្បីសួរចម្លើយនៅសាលាកងអាវុធហត្ថកំបូល ជាកន្លែងដែលពួកគេត្រូវបានគេធ្វើទារុណកម្ម។ បន្ទាប់មក ពួកគេត្រូវបានបញ្ជូនទៅកាន់មណ្ឌលឃុំឃាំងក្បែរព្រលានយន្តហោះពោធិ៍ចិនតុង ដើម្បី "អប់រំឡើងវិញ។[428]" លើសពីនេះទៀត លោក សៅ សុខាបានជួយជ្រោមជ្រែង និងសមគំនិតក្នុងការលាក់បាំងការទទួលខុសត្រូវរបស់អង្គភាពកងយោធពលខេមរភូមិន្ទដទៃទៀតក្នុងការសម្លាប់មន្ត្រីជាន់ខ្ពស់គណបក្សហ៊ុនស៊ិនប៉ិចក្រៅប្រព័ន្ធច្បាប់នៅក្រៅរាជធានីភ្នំពេញ។[429]

ទីបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក៏បានជាប់ពាក់ព័ន្ធក្នុងការរំលោភសិទ្ធិអ្នកជាប់ឃុំម្នាក់ដោយបង្ខំឱ្យធ្វើសក្ខីកម្មក្លែងបន្លំប្រឆាំងនឹងមេបញ្ជាការហ៊ុនស៊ិនប៉ិចលោក ញឹក ប៊ុនឆៃ ដែលបានរត់គេចពីការតាមចាប់ខ្លួនដោយកងកម្លាំងរបស់លោក ហ៊ុន សែន។ អ្នកជាប់ឃុំជាមន្ត្រីហ៊ុនស៊ិនប៉ិចម្នាក់ ដែលត្រូវបានចាប់ខ្លួនដោយកងរាជអាវុធហត្ថ នៅភ្នំពេញ ហើយត្រូវបាននាំទៅទួលគោក ជាទីដែលគាត់រងទារុណកម្ម និងគំរាមសម្លាប់ ដើម្បីបង្ខំគាត់ឱ្យសរសេរសារភាពថា លោកញឹក ប៊ុនឆៃបានប្រព្រឹត្តអំពើខុសច្បាប់។[430]

លោក សៅ សុខា និយាយថា៖ "អំឡុងពេលប្រយុទ្ធគ្នា បទបញ្ជាត្រូវបានបញ្ជាចេញពីមេដឹកនាំយោ

---

[426] ការឃ្លាំមើលសិទ្ធិមនុស្ស "ប្រាប់ពួកគេថា ខ្ញុំចង់សម្លាប់ពួកគេ" ទំព័រ40 ។

[427] COHCHR, ក្រដាសព្រាងមិនមានចំណងជើង ថ្ងៃទី 4 ខែមិថុនាឆ្នាំ 2004។

[428] "ប្រទេសកម្ពុជា ៖ មន្ត្រីអ.ស.ប. ស្តីពីរបាយការណ៍ "ស៊ីចង្វាក់គ្នា","គួរឱ្យទុកចិត្ត" លើការធ្វើទារុណកម្ម ។"AFP ភ្នំពេញ ថ្ងៃទី20 ខែកក្កដាឆ្នាំ1997 ។

[429] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស COHCHR "ការសម្ភាសន៍ជាមួយទាហានខ្មែរក្រហម ដែលនៅក្រោមការត្រួតត្រារបស់លោក ភុន ភាព នៅជំរំកំបូល ជិតព្រំដែនខេត្តកណ្តាលនិងខេត្តកំពង់ស្ពឺ" ថ្ងៃទី 28 ខែកក្កដាឆ្នាំ 1997 ។

[430] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស COHCHR, "សេចក្តីសង្ខេបនៃការសម្ភាសន៍ជាមួយវរសេនីឯកកងយោធពលខេមរភូមិន្ទកម្ពុជា (ដែលលាក់ឈ្មោះ) "ថ្ងៃទី 24 ខែកក្កដាឆ្នាំ 1997 ។

បាយ។ ឋានានុក្រមយោធាធម្មតាប្រើការមិនបានទេ។ ប្រសិនបើទាហានចូលចិត្តអ្នកនយោបាយណាម្នាក់ ទាហាននោះត្រូវតែធ្វើតាមអ្នកនយោបាយម្នាក់នោះ។ មិនមានឋានានុក្រមអ្វីទាំងអស់ក្នុងអំឡុងពេលនេះ។ ខ្ញុំដឹងថា តើខ្ញុំត្រូវស្តាប់អ្នកណា។ នៅក្នុងស្ថានភាពបែបនេះ យើងត្រូវតែដឹងថា តើយើងកំពុងឈរនៅជាមួយអ្នកណា”។[431]

ដោយត្រូវបានទទួលស្គាល់នូវភាពស្មោះត្រង់ខាងនយោបាយរបស់គាត់ក្នុងអំឡុងរដ្ឋប្រហារ លោក សៅ សុខា ត្រូវបានតែងតាំងជាទីប្រឹក្សារបស់លោក ហ៊ុន សែន ដែលមានឋានៈស្មើនឹងអនុរដ្ឋលេខាធិការនៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ១៩៩៧ ។[432]

ការរំលោភបំពាននានាដែលជាប់ពាក់ព័ន្ធជាមួយកងរាជអាវុធហត្ថ ត្រូវបានជំរុញឲ្យតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា អំពាវនាវឱ្យរំលាយចោលអង្គភាពកងរាជអាវុធហត្ថ។[433]

## លោក សៅ សុខា និងការបោះឆ្នោតឆ្នាំ១៩៩៨

កងរាជអាវុធហត្ថក៏បានចូលរួមផងដែរនៅក្នុងការបង្ក្រាបគណបក្សប្រឆាំង និងការតវ៉ារបស់ពលរដ្ឋប្រឆាំងលទ្ធផលបោះឆ្នោតខែកក្កដា ឆ្នាំ១៩៩៨ ដែលគណបក្សប្រជាជនកម្ពុជារងការចោទថា ក្លែងបន្លំសន្លឹកឆ្នោត និងប្រព្រឹត្តភាពមិនប្រក្រតីនានា[434]

កងរាជអាវុធហត្ថ ស្ថិតក្នុងចំណោមកងម្ទាំងទាំងឡាយ ដែលគណៈបញ្ជាការរាជធានីភ្នំពេញរបស់គណ

---

[431] ប្រ៊ែដ អាដាមស៍ (Brad Adams) បទសម្ភាសន៍ជាមួយសៅសុខា ថ្ងៃទី 22 ខែកុម្ភៈឆ្នាំ 2000។

[432] រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រឹត្យលេខ ចស/រកត/ 0797/88 កក្កដា 24, 1997 ។

[433] រាយការណ៍ដោយឯកអគ្គរដ្ឋទូត Thomas Hammarberg តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ នាថ្ងៃទី 13 ខែវិច្ឆិកា ឆ្នាំ1997។ លោកបានមានប្រសាសន៍ថា "បើសិនជាកងរាជអាវុធហត្ថមិនដាក់ឲ្យនៅស្ថិតក្រោមនីតិរដ្ឋយ៉ាងតឹងរឹងនិងមានប្រសិទ្ធិភាព មិនដាក់ឲ្យនៅអព្យាក្រឹត្យភាពតឹងរឹងនៅពេលអនុវត្តអាណត្តិការងាររបស់ខ្លួនទេ និងមិនបង្ហាញពីប្រសិទ្ធភាពវិជ្ជាជីវៈរបស់ខ្លួនទេ នោះវាគួរតែត្រូវបានរំលាយចោល។

[434] "ការបោះឆ្នោតរបស់ប្រទេសកម្ពុជាប្រែទៅជាជូចត់" អង្គការ International Crisis Group ចេញផ្សាយព័ត៌មាន ថ្ងៃទី 10 ខែកញ្ញាឆ្នាំ 1998។

បក្សប្រជាជនកម្ពុជា បានដាក់ពង្រាយដើម្បីប្រឆាំងនឹងការតវ៉ា។[435] ក្នុងអំឡុងពេលប្រតិបត្តិការ កងកម្លាំងសន្តិសុខបានសម្លាប់មនុស្សយ៉ាងហោចណាស់ ២១ នាក់ ដែលមួយចំនួនបានស្លាប់ដោយសារតែការប្រើប្រាស់កម្លាំងហួសប្រមាណ មិនចាំបាច់ និងយ៉ាងសាហាវ ហើយអ្នកផ្សេងទៀតត្រូវបានគេសម្លាប់ក្រៅប្រព័ន្ធតុលាការ នៅក្នុងមន្ទីរឃុំឃាំងរបស់កងសន្តិសុខ។ យ៉ាងហោចណាស់មនុស្ស ៦០ នាក់ទៀតបានរងរបួស។[436] ក្នុងចំណោមអ្នកស្លាប់ទាំងនោះ មានមនុស្សពីរនាក់ដែលសាកសពរបស់ពួកគេត្រូវបានគេកប់នៅក្នុងផ្នូររាក់ៗ ហើយលើដងខ្លួនមានស្លាកស្នាមត្រូវបានគេធ្វើទារុណកម្មមុនពេលត្រូវបានគេបាញ់ច្រើនគ្រាប់ ដែលជាសញ្ញាបញ្ជាក់ពីស្ទីលនៃការប្រហារជីវិតមនុស្ស។[437] ក្រុមអ្នកស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិ បានរកឃើញថា មុនត្រូវសម្លាប់ គេឃើញមន្ត្រីប៉ូលីសស្លៀកពាក់ឯកសណ្ឋានស៊ីវិលបាននាំយកមនុស្សពីរនាក់នោះទៅប្រគល់ឱ្យកងរាជអាវុធហត្ថនៅភ្នំពេញថ្មី ហើយអ្នកទាំងពីរនោះត្រូវបានសម្លាប់នៅក្នុងមន្ទីរឃុំឃាំងរបស់យកងរាជអាវុធហត្ថនៅទីនោះ នៅថ្ងៃទី ៩ ខែកញ្ញា។[438]

## លោក សៅ សុខា ១៩៩៩-២០០៨

នៅខែឧសភា ឆ្នាំ ១៩៩៩ លោក សៅ សុខា ត្រូវបានតែងតាំងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃ

[435] ការសម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា ថ្ងៃទី 18 ខែកញ្ញាឆ្នាំ 2004។ រាជរដ្ឋាភិបាលកម្ពុជា, "ឧត្តមសេនីយ៍ផ្កាយមាសបួនសៅសុខា" "ក្រុមខ្លាហោះ Flying Tigers 'បានកើនឡើងទ្វេដង ខេមបូឌាដេលីថ្ងៃទី "2 ខែមេសាឆ្នាំ 1998។ "ព្រះសង្ឃត្រូវបានគេបាញ់សម្លាប់ ខណៈដែលប៉ូលិសប៉ះទង្គិចជាមួយក្រុមអ្នកតវ៉ានៅរាជធានីភ្នំពេញ ។"AFP, ភ្នំពេញ, ថ្ងៃទី 9 ខែកញ្ញាឆ្នាំ 1998 ។ "ហ្វូងបាតុកម្មប្រមូលផ្តុំម្តងទៀត ដោយដាក់កម្រងផ្កានៅកន្លែងដែលព្រះសង្ឃត្រូវគេបាញ់សម្លាប់", AP ភ្នំពេញថ្ងៃទី 9 ខែកញ្ញាឆ្នាំ 1998។ "ព្រះសង្ឃបាត់ខ្លួន ភ័យខ្លាចគេសម្លាប់ "VOA ថ្ងៃទី 9 ខែកញ្ញាឆ្នាំ 1998 ។ "ឱកាសសម្រាប់កិច្ចព្រមព្រៀងកម្ពុជា ប៉ុន្តែនៅតែមានសង្ឃឹម "Reuters ក្រុងភ្នំពេញ ថ្ងៃទី 9 ខែកញ្ញាឆ្នាំ 1998។ "ព្រះសង្ឃពុទ្ធសាសនាបានស្លាប់״ នៅកម្ពុជាការប៉ះទង្គិចគ្នា "BBC ភ្នំពេញថ្ងៃទី 9 ខែកញ្ញាឆ្នាំ1998។ "ព្រះសង្ឃខ្មែរដែលត្រូវគេវាយដំ ភ័យខ្លាច គេចខ្លួន "Reuters ភ្នំពេញថ្ងៃទី 15 ខែកញ្ញា ឆ្នាំ1998 ។

[436] "សេចក្តីថ្លែងរបស់លោកឯកអគ្គរដ្ឋទូត Thomas Hammarberg អ្នកតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា" ញូវយ៉កថ្ងៃទី 16 ខែកញ្ញាឆ្នាំ 1998។ អ។ ស។ ប។ ព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបាត់បង់ជីវិតនៅកម្ពុជា "Reuters ក្រុងភ្នំពេញថ្ងៃទី 16 ខែកញ្ញាឆ្នាំ 1998។ VOA ភ្នំពេញថ្ងៃទី 18 ខែកញ្ញាឆ្នាំ 1998 ។ អង្គការលើកលែងទោសអន្តរជាតិ "ព្រះរាជាណាចក្រកម្ពុជា ៖ បាតុកម្មត្រូវបានកម្ទេចដោយការប្រើប្រាស់កម្លាំងហួសកំរិត" (ASA 23/26/98) ថ្ងៃទី 22 ខែកញ្ញាឆ្នាំ 1998 ។

[437] "អង្គការសហប្រជាជាតិ ជីកកកាយសាកសពពីរពីផ្នូររាក់ៗនៅជិតទីក្រុងភ្នំពេញ "AFP ក្រុងភ្នំពេញថ្ងៃទី10 ខែកញ្ញាឆ្នាំ1998។

[438] "សេចក្តីថ្លែងរបស់លោកឯកអគ្គរដ្ឋទូត Thomas Hammarberg អ្នកតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា" ទីក្រុងញូវយ៉ក ថ្ងៃទី 16 ខែកញ្ញាឆ្នាំ1998។ "អង្គការសហប្រជាជាតិព្រួយបារម្ភយ៉ាងខ្លាំងពីការស្លាប់ ការបាត់ខ្លួននៅកម្ពុជា״Reuter ភ្នំពេញថ្ងៃទី 16 ខែកញ្ញាឆ្នាំ1998 ។

ប្រទេស។ គាត់នៅតែស្ថិតក្នុងតំណែងនេះចាប់តាំងពីពេលនោះមក។[439] ការឡើងស័ក្តិនៅឆ្នាំ១៩៩៩នោះ ជាក់ ស្តែងណាស់ គឺជារង្វាន់មួយទៀតសម្រាប់លោក សៅ សុខា ដែលបានផ្តល់សេវានយោបាយដល់លោក ហ៊ុន សែន។ ចំពោះនាយករដ្ឋមន្ត្រី ហ៊ុន សែន លោក សៅ សុខា បំពេញការងារបានល្អជាងលោក គៀង សាវុធ ឆ្ងាយណាស់។[440] លោក គៀង សាវុធត្រូវបានផ្លាស់ប្តូរទៅកាន់តំណែងមិនបញ្ជាកម្លាំងនៅឯក្រសួង ការពារជាតិ។ ការតំឡើងស័ក្តិលោក សៅ សុខា នេះធ្វើឡើងស្របគ្នាជាមួយការបញ្ចូលឈ្មោះគាត់ទៅក្នុង សមាជិកភាពនៃគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ដែលបង្កើត ឡើងដោយលោក ហ៊ុន សែន មានភារកិច្ច "បង្ការ និងចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីដោះ ស្រាយរាល់បញ្ហាកូដកម្ម និងបាតុកម្មទាំងអស់" នៅទីកន្លែងណាក៏ដោយ ដែលអាចកើតមាន។[441] គណៈកម្ម ការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញានេះ គឺបង្កើតឡើងក្នុងគោលដៅបង្ក្រាប លើអ្នកប្រឆាំងខាងនយោបាយ និងចលនាកម្មករ ដែលកំពុងកើនឡើងដែលភាគច្រើនជាកម្មការនីរោង ចក្រ។

ខណៈមានភាពតានតឹង និងការប្រឈមមុខដាក់គ្នាខ្លាំងជាមួយកងកម្លាំងប៉ូលីស កងរាជអាវុធហត្ថត្រូវបាន គេចាត់ទុកថា ជាកម្លាំងមានប្រសិទ្ធភាពប្រតិបត្តិការខ្ពស់។[442] យោងតាមអ្នកឃ្លាំមើលសិទ្ធិមនុស្សនៅកម្ពុជា ប្រសិទ្ធភាពប្រតិបត្តិការខ្ពស់នេះ រាប់បញ្ចូលទាំងការពាក់ព័ន្ធក្នុងការរំលោភសិទ្ធិមនុស្សដែលចេះតែកើន ចំនួនឡើងជាបន្តបន្ទាប់ក្នុងទសវត្សរ៍ចុងក្រោយនេះ។[443]

លោក សៅ សុខា បានបន្តទទួលបទបញ្ជាតែពីលោក ហ៊ុន សែន រួមទាំងអំឡុងការបង្ក្រាបមិនធម្មតាលើ កុបកម្មប្រឆាំងថៃនៅខែមករា ឆ្នាំ២០០៣ ដែលបណ្តាលឱ្យមានការបណ្តេញថៃ និងដុតស្ថានទូតថៃ និងក្រុម ហ៊ុនមួយចំនួនដែលគ្រប់គ្រងដោយជនជាតិថៃ។ កងរាជអាវុធហត្ថ ត្រូវបានគេដាក់ពង្រាយ នៅពេលដែល

---

439 រាជរដ្ឋាភិបាលកម្ពុជា (RGC), "ឧត្តមសេនីយ៍ផ្កាយមាសបួនសៅសុខា។ "

440 សម្ភាសន៍ជាមួយមន្ត្រីសន្តិសុខ ថ្ងៃទី 30 ខែសីហាឆ្នាំ 2013។ ECCCកំណត់" ហេតុពីឧត្តមសេនីយ៍ អែម សាម៉ន ថ្ងៃទី 11 ខែកញ្ញាឆ្នាំ 2006 ។ "

441 រាជរដ្ឋាភិបាលកម្ពុជា (RGC), សេចក្តីសម្រេចលេខ 07 សសរ ថ្ងៃទី 29 ខែមករាឆ្នាំ 1999 ។

442 Bartu "ឯកសារភ្ជាប់ C ។

443 ក្រាហ្វិចដែលចេញដោយសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (អង្គការលីកាដូដែល រៀបរាប់ពីស្ថិតិសំរាប់ឆ្នាំ2001 ដល់ 2011 ថ្ងៃទី 29 ខែកក្កដា ឆ្នាំ 2013 (ឯកសារស្ថិតក្នុងការកាន់កាប់របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សយូម៉ែនរ៉ៃត៍វច្ឆ)។

*លោកហ៊ុន សែនខ្លួនឯង ហាមឃាត់បញ្ជា។[444] បន្ទាប់ពីនោះមក ជាមួយនឹងការបោះឆ្នោតសភាជាតិ ដែលគ្រោងធ្វើនៅខែកក្កដា ឆ្នាំ២០០៣ កងកម្លាំងសន្តិសុខត្រូវបានបញ្ជាឱ្យចាប់ផ្តើមរៀបចំបង្ការ ឬទប់ស្កាត់បាតុកម្មក្រោយការបោះឆ្នោត ឬភាពចលាចលផ្សេងៗទៀត។ នៅចុងខែកុម្ភៈ ឆ្នាំ ២០០៣ ប៉ូលីស និងរាជអាវុធហត្ថចំនួន ៥០០-៧០០ នាក់បានធ្វើសមយុទ្ធប្រឆាំងបាតុកម្ម ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងសហការគ្នា ដើម្បីបញ្ចប់ការតវ៉ាណាមួយ។[445] សមយុទ្ធនេះ ដើរស្របទៅនឹងការហាមឃាត់ទូទាំងប្រទេសក្នុងឆ្នាំ២០០៣ និងហួសពីនេះ ដោយមិនឲ្យមានការជួបជុំគ្នាដោយសន្តិវិធី ដូចជាកូដកម្ម និងការតវ៉ាប្រឆាំងនឹងការរំលោភយកដី។ ការហាមឃាត់នេះ ពឹងផ្អែកទៅលើការបកស្រាយច្បាប់(បាតុកម្ម) ឆ្នាំ១៩៩១ តាមអំពើចិត្ត ដោយយល់ខុសថា ច្បាប់នោះអនុញ្ញាតឱ្យអាជ្ញាធរហាមឃាត់ការធ្វើបាតុកម្មតាមឆន្ទៈរបស់ខ្លួន។[446] បន្ទាប់ពីការបោះឆ្នោតឆ្នាំ២០០៣ កម្លាំងចម្រុះនៃកងរាជអាវុធហត្ថ និងប៉ូលីសចម្រុះ កាន់តែប្រើអំពើហិង្សាច្រើនឡើងបំបែកការជួបប្រជុំ និងការហែក្បួននៅភ្នំពេញ និងបណ្តាខេត្ត ដែលព្យាយាមជំនះនឹងបម្រាម។ កម្លាំងចំរុះតែងតែប្រើកម្លាំងហួសប្រមាណក្នុងប្រតិបត្តិការទាំងនេះ ដោយធ្វើឱ្យរបួសដល់សិស្សនិស្សិត កម្មករ និងអ្នកដទៃទៀត ដែលជួនកាលបណ្តាលឱ្យរបួសធ្ងន់ធ្ងរ។ ប្រតិបត្តិការទាំងនេះ ក៏បានកើនឡើងនៅក្នុងទំហំតាមដែលពួកគេចង់បាន ដើម្បីធ្វើការគាបសង្កត់ទូលំទូលាយបន្ថែមទៀត។ ឧទាហរណ៍ នៅទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៦ កងរាជអាវុធហត្ថ និងនគរបាលប្រដាប់ដោយកាំភ្លើងយន្ត ដំបងដំបងឆក់ កាំភ្លើងខ្លី កាំភ្លើងឧស្ម័នបង្ហូរទឹកភ្នែក ខែលការពារកុបកម្ម និងរថយន្តពន្លត់អគ្គីភ័យប្រើកាណុងបាញ់ទឹក បានរារាំងផ្លូវធំៗទាំងអស់មកកាន់រាជធានីភ្នំពេញ ដើម្បីប៉ុនប៉ងរារាំងកម្មករ និងអ្នកដទៃទៀត កុំឱ្យប្រមូលផ្តុំគ្នា។[447] យ៉ាងហោច ចាប់ពីឆ្នាំ២០០៦មក កងរាជអាវុធហត្ថបានចាប់ផ្តើមប្រើប្រាស់កាំភ្លើង*

---

[444] Bartu "ឯកសារភ្ជាប់ C ។

[445] កម្ពុជាថ្មីថ្ងៃទី 27 ខែកុម្ភៈឆ្នាំ 2003

[446] "ប្រទេសកម្ពុជា ៖ ច្បាប់ថ្មីស្តីអំពីការធ្វើបាតុកម្ម" សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស ចេញផ្សាយនៅថ្ងៃទី 29 ខែតុលាឆ្នាំ 2009 https://www.fidh.org/en/region/asia/cambodia/The-new-Law-on- ច្បាប់ថ្មីស្តីពីបាតុកម្ម (Access ថ្ងៃទី 16 ខែសីហាឆ្នាំ 2015) ។

[447] អង្គការ Global Witness ត្រូវមានសិទ្ធិបន្តនីត្យានុកូលភាពរបស់ខ្លួននៅកម្ពុជា "គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ចេញផ្សាយថ្ងៃទី16 ខែធ្នូឆ្នាំ2002, http://www.licadho-cambodia.org/pressrelease.php?perm=24 (ចូលមើលថ្ងៃទី 28 ខែវិច្ឆិកាឆ្នាំ 2015) ។ អង្គការសិទ្ធិមនុស្សលីកាដូ (លីកាដូ អំពើហិង្សាផ្ទុះឡើងអំឡុងបាតុកម្មការងារ នៅខេត្តកណ្តាលនិងកំពង់ឆ្នាំង" អង្គការលីកាដូ )LICADHO) អត្ថបទចុះថ្ងៃទី 26 ខែសីហាឆ្នាំ 2004 ។ http://www.licadho-cambodia.org/articles/20040826 00:00:00/12/index.html (ចូលមើលថ្ងៃទី១ ខែកញ្ញាឆ្នាំ 2015)។ គណៈកម្មាធិការប្រព្រឹត្តិកម្ម ការបង្ក្រាបលើការប្រមូលផ្តុំនិងបាតុកម្មដោយអាជ្ញាធររាជធានីភ្នំពេញ ចាប់តាំងពីខែមករា ឆ្នាំ2003 (ភ្នំពេញខែវិច្ឆិកាឆ្នាំ 2004) ។ អង្គការសិទ្ធិមនុស្សលីកាដូ៖ ការដាក់កំហិតលើសេរីភាពនៃការជួបជុំនៅកម្ពុជា ភ្នំពេញ ខែធ្នូ ឆ្នាំ2005 ទំព័រទី 3-4, 6, 9។ អង្គការសិទ្ធិមនុស្សលីកាដូ (លីកាដូ), សេរីភាពខាងការជួបជុំគ្នានៅកម្ពុជា ៖ ខែធ្នូឆ្នាំ 2005 ដល់ខែកញ្ញាឆ្នាំ 2006 (ភ្នំពេញខែវិច្ឆិកាឆ្នាំ 2006)។ "វិធានការហិង្សាដែលត្រូវបានប្រើដើម្បីបញ្ចប់កូដកម្មកម្មកររោងចក្រប្រាយស្កាយនៅកម្ពុជា" អង្គការលីកាដូ )LICADHO) ការចេញផ្សាយព័ត៌មានថ្ងៃទី 26 ខែវិច្ឆិកាឆ្នាំ 2006 ។ "ការរំលោភ

*ស្វ័យប្រវត្តិ ដើម្បីបំបែកបាតុកម្ម។*[448]

*នៅរាជធានីភ្នំពេញ និងកន្លែងផ្សេងទៀត កងរាជអាវុធហត្ថក៏បានចូលរួមជាញឹកញាប់ក្នុងការបណ្តេញដោយបង្ខំ និងដោយខុសច្បាប់ឱ្យអ្នកស្រុកចេញពីដីធ្លីរបស់ពួកគាត់ ដែលពួកគេមានសិទ្ធិ ឬបានទាមទារសិទ្ធិ ប៉ុន្តែមិនត្រូវបានកាត់ក្តីដោយយុត្តិធម៌ដោយតុលាការ។*[449] *កងរាជអាវុធហត្ថ បានព្យាយាមរារាំងក្រុម*

---

បំពានលើសកម្មជនដីធ្លីដោយខុសច្បាប់ នៅរាជធានីភ្នំពេញ" អង្គការលីកាដូ )LICADHO) ការចេញផ្សាយព័ត៌មានថ្ងៃទី 17 ខែតុលាឆ្នាំ 2007 ។ "អំពើហិង្សាប្រឆាំងនឹងសមាជិកសហជីពត្រូវបានថ្កោលទោស) អង្គការលីកាដូ "LICADHO) ចេញផ្សាយព័ត៌មានថ្ងៃទី 7 ខែកុម្ភៈ ឆ្នាំ 2008 ។ "ការបង្ក្រាបបាតុកម្មដោយសន្តិវិធីដោយកម្មករនិងគ្រូ", អង្គការលីកាដូ )LICADHO), សេចក្តីប្រកាសព័ត៌មានថ្ងៃទី7 ខែសីហាឆ្នាំ 2008 ។ អង្គការលីកាដូ (LICADHO) ការវាយលុកនិងការគំរាមកំហែងប្រឆាំងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ 2008-2009 (ភ្នំពេញ ៖ ខែកញ្ញាឆ្នាំ 2010), www.licadho-cambodia.org/.../1432010- HRDReport2008-2009Final-EN; អង្គការលីកាដូ )LICADHO), របាយការណ៍សកម្មភាព ៖ ការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស (ភ្នំពេញ ខែធ្នូឆ្នាំ2008 )ទំព័រទី 4-5 ។

[448] គណៈកម្មាធិការប្រព្រឹត្តិកម្ម ការបង្ក្រាបលើការប្រមូលផ្តុំនិងបាតុកម្មដោយអាជ្ញាធររាជធានីភ្នំពេញ ចាប់តាំងពីខែមករាឆ្នាំ 2003 (ភ្នំពេញខែវិច្ឆិកាឆ្នាំ 2004)។ អង្គការសិទ្ធិមនុស្សលីកាដូ សេរីភាពខាងការជួបជុំគ្នានៅកម្ពុជា ៖ ខែធ្នូឆ្នាំ 2005 ដល់ខែកញ្ញាឆ្នាំ2006 (ភ្នំពេញខែវិច្ឆិកាឆ្នាំ 2006) ។ អង្គការលីកាដូ )LICADHO) របាយការណ៍សកម្មភាព ៖ លើកកម្ពស់និងការពារសិទ្ធិមនុស្ស (ភ្នំពេញ ខែធ្នូឆ្នាំ 2007) ទំព័រ 2 ។

[449] "ការរំលោភបំពានជាបន្តបន្ទាប់លើដីធ្លីនៅរាជធានីភ្នំពេញ បន្តធ្វើឱ្យមានភាពក្រីក្រនិងអំពើហិង្សា។ " អង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO), ការចេញផ្សាយព័ត៌មានថ្ងៃទី 19 ខែកញ្ញាឆ្នាំ 2005។ "សេចក្តីថ្លែងការណ៍រួមស្តីពីការបណ្តេញចេញនៃភូមិសំបុកចាបដែលចេញផ្សាយនៅ "ថ្ងៃទី7 ខែមិថុនាឆ្នាំ 2006 ។ "កម្លាំងលើសលប់ដែលត្រូវបានប្រើនៅក្នុងការបណ្តេញចេញដីក្រហម" ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋានការចេញផ្សាយព័ត៌មានថ្ងៃទី 30 ខែសីហាឆ្នាំ 2007) ។ "ក្រុមហ៊ុនអភិវឌ្ឍន៍ 7NG បន្តដៅលើអ្នកភូមិដែលរស់ជាប់រដ្ឋសភាជាតិកម្ពុជា "អង្គការលីកាដូ (LICADHO) ចេញផ្សាយព័ត៌មានថ្ងៃទី 4 ខែតុលាឆ្នាំ 2007 ។ អង្គការលីកាដូ )LICADHO), របាយការណ៍សកម្មភាព ៖ "ការលើកកំពស់ និងការការពារសិទ្ធិមនុស្ស" ភ្នំពេញ ខែធ្នូ ឆ្នាំ2007 ទំព័រទី 1-2, 6; "អំពើហិង្សាកាន់តែច្រើននៅក្នុងករណីជម្លោះដីធ្លីនៅរាជធានីភ្នំពេញ" ស្ពានឆ្លងដែន, ការចេញផ្សាយព័ត៌មានថ្ងៃទី 22 ខែកុម្ភៈឆ្នាំ 2008 ។ អង្គការលីកាដូ (LICADHO)៖ ដីធ្លីដីសហគមន៍ដីក្រហម ត្រូវបានពន្យល់ (ភ្នំពេញ ខែមករាឆ្នាំ2008)។ http://www.licadho- cambodia.org%2Freports%2Ffiles%2F118DeyKrahormCommunityLandCaseExplained.pdf; អង្គការលីកាដូ (LICADHO) របាយការណ៍សកម្មភាពប្រចាំឆ្នាំ ៖ លើកកម្ពស់និងការពារសិទ្ធិមនុស្ស (ភ្នំពេញខែធ្នូ2008) ទំព័រទី១ ។ "ឧស្ម័នបង្ហូរទឹកភ្នែកនិងគ្រាប់កាំភ្លើងក្នុងអំឡុងពេលនៃការបណ្តេញចេញដោយបង្ខំចុងក្រោយបង្អស់នៅក្នុងរាជធានីភ្នំពេញ" អង្គការលីកាដូ )LICADHO) ការចេញផ្សាយព័ត៌មានថ្ងៃទី 28 ខែកុម្ភៈឆ្នាំ 2008។ http://www.licadho-cambodia.org/articles/20080228 00:00:00/72/index.html; http://www.licadho-cambodia.org/articles/20070208 00:00:00/51/index.html; អង្គការលីកាដូ (LICADHO) ការដណ្តើមយកដីធ្លីនិងភាពក្រីក្រនៅកម្ពុជា ៖ ភាពអាថ៌កំបាំងនៃការអភិវឌ្ឍន៍ (ភ្នំពេញ ខែឧសភាឆ្នាំ2009) ទំព័រទី13 ។ អង្គការសិទ្ធិមនុស្សលីកាដូ៖ ការរឹតត្បិតសេរីភាពនៃការជួបជុំគ្នានៅកម្ពុជា (ភ្នំពេញខែធ្នូ 2005) ទំព័រ 5 ។ "កងរាជអាវុធហត្ថខេត្តកំពត បានប្រមូលផ្តុំ ដើម្បីការពារដីសម្បទានរបស់សមាជិកព្រឹទ្ធសភាគណបក្សកាន់អំណាច" អង្គការលីកាដូ (LICADHO) ចេញផ្សាយព័ត៌មានថ្ងៃទី 8 ខែកុម្ភៈ ឆ្នាំ2007 ។ "ការបណ្តេញចេញពីដីធ្លីដោយបង្ខំពីទីក្រុងមាត់សមុទ្រដែលស្ងប់ស្ងាត់នៃប្រទេសកម្ពុជា" អង្គការលីកាដូ(LICADHO) ចេញផ្សាយព័ត៌មានថ្ងៃទី 20 ខែមេសាឆ្នាំ 2007 ។ "ការបណ្តេញចេញដោយបង្ខំនិងដោយខុសច្បាប់ចំនួន 105 គ្រួសារ នៅក្រុងព្រះសីហនុ "អង្គការលីកាដូ៖ ចេញផ្សាយព័ត៌មានថ្ងៃទី10 ខែកក្កដាឆ្នាំ 2007។ ការបណ្តេញចេញពីដីធ្លី នៅក្រុងព្រះសីហនុ ៖ ការចាប់ខ្លួនមនុស្ស 13 នាក់ត្រូវបានដោះលែង និងការផ្តល់សម្បទានដីសង្គមកិច្ចដល់គ្រួសារក្រីក្រ "អង្គការលីកាដូ )LICADHO) ការចេញផ្សាយព័ត៌មានថ្ងៃទី 27 ខែមេសាឆ្នាំ 2007។ "រដ្ឋាភិបាលត្រូវតែចាត់វិធានការលើអំពើហិង្សានៅដីក្រែង អង្គការលីកាដូ " )LICADHO) ចេញផ្សាយព័ត៌មានថ្ងៃទី 5 ខែតុលាឆ្នាំ 2007 ។ អង្គការលីកាដូ )LICADHO), របាយការណ៍សកម្មភាព ៖ លើកកម្ពស់ និងការពារសិទ្ធិមនុស្ស (ភ្នំពេញ ខែធ្នូ ឆ្នាំ 2007) ទំព័រទី 2 ។ អង្គការលីកាដូ (LICADHO), របាយការណ៍សកម្មភាពប្រចាំឆ្នាំ ៖ លើកកម្ពស់និងការពារសិទ្ធិមនុស្ស (ភ្នំពេញ ខែធ្នូ ឆ្នាំ 2008) ទំព័រទី 2 ។ អង្គការលីកាដូ (LICADHO) ការដណ្តើមយកដីធ្លីនិងភាពក្រីក្រនៅកម្ពុជា ៖ ភាពអាថ៌កំបាំងនៃការអភិវឌ្ឍន៍ (ភ្នំពេញ ខែឧសភាឆ្នាំ 2009) ទំព័រទី 24 ។ "ការបណ្តេញចេញនិងការដណ្តើមយកដីធ្លី ពាសពេញប្រទេសកម្ពុជា) អង្គការលីកាដូ "LICADHO) ចេញផ្សាយ

អ្នកឃ្លាំមើលសិទ្ធិមនុស្ស និងអ្នកកាសែតពីការឃ្លាំមើលការបណ្តេញចេញ និងអ្នកភូមិត្រូវបានរារាំងមិនឱ្យប្រមូលផ្តុំ ដើម្បីតវ៉ានឹងការជំនុំជម្រះមិនយុត្តិធម៌។[450] នៅខែមីនា ឆ្នាំ២០០៥ កងរាជអាវុធហត្ថស្ថិតក្នុងចំណោមកងកម្លាំងសន្តិសុខ ដែលបានបើកការបាញ់ប្រហារក្នុងអំឡុងពេលបណ្តេញចេញនៅខេត្តបន្ទាយមានជ័យ ដោយបានសម្លាប់មនុស្ស ៥ នាក់និង ៤០ នាក់ទៀតរងរបួស។[451] នៅខែវិច្ឆិកា ឆ្នាំ២០០៧ កងរាជអាវុធហត្ថ សហការជាមួយប៉ូលីស និងកងទ័ពនៅខេត្តព្រះវិហារ បណ្តេញអ្នកស្រុកចេញពីដីមួយកន្លែងដែលក្នុងប្រតិបត្តិការបណ្តេញនោះស្ត្រីម្នាក់ត្រូវបានបាញ់សម្លាប់ខណៈកំពុងឈរជាមួយកូនៗរបស់គាត់ ហើយអ្នកភូមិម្នាក់ទៀតក៏រងគ្រាប់កាំភ្លើងស្លាប់ដែរ។[452] បន្ទាប់មកទៀតនៅខែមីនា ឆ្នាំ២០០៨ កងរាជអាវុធហត្ថម្នាក់បានបាញ់អ្នកតវ៉ាជាអ្នកភូមិម្នាក់នៅខេត្តព្រះសីហនុឱ្យរបួស។[453]

នៅពេលនោះ កងរាជអាវុធហត្ថជាន់ខ្ពស់ច្រើនរូបរងការចោទថា ជាប់ពាក់ព័ន្ធកាន់តែខ្លាំងឡើងក្នុងការកាប់ឈើខុសច្បាប់។[454] កិច្ចខិតខំប្រឹងប្រែងរបស់លោក ជាម ច័ន្ទនី ប្រធានគណៈកម្មាធិការកិច្ចការការពារជាតិនៃគណបក្សប្រឆាំងសមរង្ស៊ី ក្នុងការពិនិត្យមើលការកាប់ឈើខុសច្បាប់ និងបញ្ហាផ្សេងទៀត បែរជារងការចាប់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៥ ដោយកងរាជអាវុធហត្ថ ដែលបានប្រឌិតរឿងចោទប្រកាន់ថា លោក ជាម ច័ន្ទនី ជាមេដឹកនាំឃុបឃិតបង្កើតកងទ័ពខុសច្បាប់ដើម្បី «ផ្តួលរំលំរដ្ឋាភិបាល»។ [455] " គាត់ត្រូវបានផ្តន្ទាទោសដាក់គុកប្រាំពីរ(៧) ឆ្នាំ ដោយតុលាការយោធា បើទោះបីជាគាត់បានទទួលការលើកលែងទោសពីព្រះ

---

ព័ត៌មានថ្ងៃទី 2 ខែមេសាឆ្នាំ 2010 ។ អង្គការលីកាដូ (LICADHO) ការវាយប្រហារនិងការគំរាមកំហែង ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ 2008-2009 (ភ្នំពេញខែកញ្ញាឆ្នាំ 2010) ទំព័រ 33 ។

[450] លិខិតចំហដោយសហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH), មជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាននិងការបណ្តេញចេញ, អង្គការឃ្លាំមើលសិទ្ធិមនុស្ស និងអង្គការលើកលែងទោសអន្តរជាតិ ស្តីពីការបណ្តេញចេញដោយបង្ខំនៃអ្នកភូមិបឹងកក់នៅក្នុងក្រុងភ្នំពេញ។ ថ្ងៃទី 4 ខែធ្នូឆ្នាំ 2008។ អ្នកភូមិកម្ពុជាត្រូវបានកាត់ទោសឱ្យជាប់គុកមួយឆ្នាំនៅក្នុងវិវាទដីធ្លី ដែលមានអាយុកាលវែងឆ្ងាយ "អង្គការលីកាដូ (LICADHO) ចេញផ្សាយព័ត៌មានថ្ងៃទី 27 វិច្ឆិកាឆ្នាំ 2009 ។

[451] អង្គការ CHRAC តម្លៃដីខ្ពស់ ៖ ការបណ្តេញចេញដោយមានការសម្លាប់មនុស្សនៅភូមិក្បាលស្ពាន (ភ្នំពេញ៖ ខែសីហាឆ្នាំ 2005); "ការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនៃករណីឃាតកម្មនៅភូមិក្បាលស្ពាន "CHRAC ចេញផ្សាយនៅថ្ងៃទី 16 ខែសីហាឆ្នាំ 2005 ។ អង្គការសិទ្ធិមនុស្សលីកាដូនៅកម្ពុជា៖ ស្ថេរភាពដែលមានតែសម្បកក្រៅ (ភ្នំពេញ៖ឧសភា 2006) ទំព័រ 5 ។

[452] "ការស៊ើបអង្កេតដែលចាំបាច់សម្រាប់ការបាញ់ប្រហារនៅខេត្តព្រះវិហារ" អង្គការលីកាដូ (LICADHO) សេចក្តីប្រកាសព័ត៌មានថ្ងៃទី 16 ខែវិច្ឆិកាឆ្នាំ 2007 ។ "ការបណ្តេញចេញពីប្រាសាទព្រះវិហារ - វិធានការចាំបាច់លើការសម្លាប់និងការលួចប្លន់" អង្គការលីកាដូ (LICADHO) ចេញផ្សាយព័ត៌មានថ្ងៃទី 22 ខែវិច្ឆិកាឆ្នាំ 2007 ។

[453] អង្គការលីកាដូ៖ ការវាយប្រហារ និងការគំរាមកំហែងប្រឆាំងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ 2008-2009 (ភ្នំពេញ៖កញ្ញាឆ្នាំ 2010), ទំព័រទី 37 ។

[454] អង្គការ Global Witness; ចែកលុយគ្នា (Take a Cut)៖ អំពើពុករលួយជាប្រព័ន្ធ និងការកាប់ឈើខុសច្បាប់នៅក្នុងជម្រកសត្វព្រៃអូរ៉ាល់ ក្នុងប្រទេសកម្ពុជា-- ករណីសិក្សា (ទីក្រុងឡុងដ៍៖ ខែវិច្ឆិកាឆ្នាំ2004) ទំព័រទី 6-7, 27-28, 31-32, 35, 38-40, 47។

[455] សម្ភាសន៍ជាម ច័ន្ទនីថ្ងៃទី15 ខែមករាឆ្នាំ 2004 ។

មហាក្សត្រក្នុងឆ្នាំ២០០៦ ក៏ដោយចុះ។[456]

នៅមុនការបោះឆ្នោតក្នុងខែកក្កដា ឆ្នាំ២០០៨ កងរាជអាវុធហត្ថបានបិទការហែរក្បួនរបស់គណបក្សប្រឆាំង បិទស្ថានីយវិទ្យុខេត្តដែលផ្សាយអំពីគណបក្សសមរង្ស៊ី និងកម្មវិធីគណបក្សប្រឆាំងដទៃទៀត។ កងរាជអាវុធហត្ថក៏បានចូលរួមរារាំងការត្រួតពិនិត្យការបោះឆ្នោតឯករាជ្យ និងចាប់ខ្លួននិពន្ធនាយកកាសែត**មនសិការខ្មែរ** ដែលជិតស្និទ្ធនឹងគណបក្សសមរង្ស៊ី គឺលោក ដាំ សុិត បន្ទាប់ពីលោកបានបោះពុម្ពផ្សាយអត្ថបទចោទប្រកាន់ រដ្ឋមន្ត្រីការបរទេសលោក ហោ ណាំហុង ថា មានជាប់ពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្មែរក្រហមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម។[457]

## លោក សៅ សុខា ត្រូវបានឡើងសក្តិបន្ថែមទៀត ឆ្នាំ២០០៩-២០១២

បន្ទាប់ពីការបោះឆ្នោតឆ្នាំ២០០៨ លោក ហ៊ុន សែន បានពង្រឹងកម្លាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថនៅក្នុងកងកម្លាំងសន្តិសុខថែមទៀត។[458] ជាទីប្រឹក្សារបស់នាយករដ្ឋមន្ត្រី និងជាសមាជិកគណៈកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជាស្រាប់ហើយនោះ លោក សៅ សុខាត្រូវបានឡើងសក្តិឱ្យមានឋានៈស្មើនឹងរដ្ឋមន្ត្រី។[459] នៅខែមករា ឆ្នាំ២០០៩ ជាផ្នែកមួយនៃការកែលម្អភាពជាអ្នកដឹកនាំរបស់កងយោធពលខេមរភូមិន្ទ ដើម្បីឱ្យលោក ហ៊ុន សែន ក្តោបក្តាប់កងកម្លាំងប្រដាប់អាវុធកាន់តែពេញដៃនោះ លោក សៅ សុខា ត្រូវបានតម្លើងស័ក្កមួយថ្នាក់ទៀត គឺជាមេបញ្ជាការរងជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ។[460]

ទន្ទឹមនឹងនេះដែរ សកម្មភាពចូលរួមរបស់កងរាជអាវុធហត្ថនៅក្នុងការរំលោភសិទ្ធិមនុស្សបានកើនឡើង ក្នុង

---

[456] "កម្ពុជា ៖ អ្នកតំណាងគណបក្សប្រឆាំងត្រូវបានដាក់ពន្ធនាគារបន្ទាប់ពីសវនាការកាត់ក្តីដ៏អាម៉ាស" អង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែនរ៉ៃត៍វ៉ច្ឆ៖ ការចេញផ្សាយព័ត៌មានថ្ងៃទី 10 ខែសីហាឆ្នាំ 2005 http://www.hrw.org/news/2005/08/08/cambodia-opposition-mp-jailed-after-sham-trial.

[457] អង្គការលីកាដូ (LICADHO), សេរីភាពខាងការជួបជុំគ្នានៅកម្ពុជា ៖ ខែធ្នូឆ្នាំ 2005 ដល់ខែកញ្ញាឆ្នាំ 2006 (ភ្នំពេញ ៖ វិច្ឆិកា 2006) ទំព័រទី 7 ។ អង្គការសិទ្ធិមនុស្សលីកាដូ៖ (ការរឹតត្បិតលើសេរីភាពបញ្ចេញមតិនៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់កម្ពុជា) ភ្នំពេញ ៖ ឧសភា 2009) ទំព័រ 23 ។ "ការចាប់ខ្លួនអ្នកសង្កេតការណ៍បោះឆ្នោត បង្ករឲ្យមានការភ័យខ្លាច៖ អង្គការលីកាដូ ((LICADHO) ការចេញផ្សាយព័ត៌មានថ្ងៃទី 31 ខែកក្កដាឆ្នាំ 2008 ។ "លោក ដាំ សិដ្ឋ ចាកចេញទៅអាមេរិកស្ងាត់ៗ" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 18 ខែសីហាឆ្នាំ 2008 http://www.phnompenhpost.com/national/dam-sith-quietly-leaves-america (ចូលមើលថ្ងៃទី 12 ខែមករាឆ្នាំ 2015)។

[458] រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រឹត្យ នស /នស/រពត/0908/1054 ថ្ងៃទី 24 ខែកញ្ញាឆ្នាំ 2008។

[459] រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រឹត្យ នស/នស/រពត / 1008/1083 ថ្ងៃទី 4 ខែតុលាឆ្នាំ 2008។

[460] រាជរដ្ឋាភិបាលកម្ពុជា (RGC), ព្រះរាជក្រឹត្យលេខ នសរ/ពត /0109/061 ថ្ងៃទី 22 ខែមករាឆ្នាំ 2009។

នោះរួមទាំងករណីថ្មីៗនៃការចូលរួមជាមួយប៉ូលីស និងកងយោធា នៅក្នុងការបណ្តេញពលរដ្ឋចេញពីដីធ្លី និងផ្ទះសម្បែងដោយបង្ខំ និងការប្រើប្រាស់កម្លាំងហួសប្រមាណ នៅក្នុងការបំបែកការតវ៉ាដែលប្រឆាំងនឹងការប្លាមយកដីធ្លីនៅតាមជនបទ និងទីក្រុង។[461] ក្នុងឧប្បត្តិហេតុមួយនៅខេត្តកណ្តាលកាលពីខែមករា ឆ្នាំ ២០០៩ ខ្មាន់កាំភ្លើងជាកងរាជអាវុធហត្ថ បានបាញ់ឱ្យរបួសបុរសពីរនាក់។[462] ករណីមួយទៀតនៅក្នុងខេត្តសៀមរាប ក្នុងខែមីនា ឆ្នាំ២០០៩ កងរាជអាវុធហត្ថបានបាញ់អ្នកភូមិគ្មានអាវុធបួននាក់ឲ្យរងរបួស។[463]

នៅក្នុងខែតុលាឆ្នាំ២០០៩ រដ្ឋសភាជាតិដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា បានបោះឆ្នោតបង្កើតច្បាប់ថ្មីមួយស្តីពីការធ្វើបាតុកម្ម ដែលក្នុងនោះមានបទប្បញ្ញត្តិមួយចំនួនត្រូវបានបកស្រាយខុសថា អាជ្ញាធរមានអំណាចផ្តាច់មុខសិទ្ធិមិនអនុញ្ញាតឱ្យមានការប្រមូលផ្តុំណាមួយ ប្រសិនបើពួកគេគិតថា ការប្រមូលផ្តុំនោះអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ ដូច្នេះ គណបក្សប្រជាជនកម្ពុជា បានផ្តល់ភ្លើងខៀវឱ្យកងរាជអាវុធហត្ថ និងកម្លាំងសន្តិសុខដទៃទៀតថា ពួកគេអាចបន្តបង្ក្រាបតាមអំពើចិត្ត និងយ៉ាងមានប្រសិទ្ធភាពទៅលើការជួបប្រជុំដោយសន្តិវិធី ជាពិសេសបង្ក្រាបទៅលើការប៉ុនប៉ងប្រមូលផ្តុំណាមួយនៅក្រៅទីលានប្រជាធិបតេយ្យដែលច្បាប់អនុញ្ញាត ។[464]

ក្រោយពីអនុម័តច្បាប់បាតុកម្មនេះហើយ ប្រតិបត្តិការបណ្តេញចេញពីដីធ្លី និងការបំបែកការប្រមូលផ្តុំ

---

[461] "អំពើឃោរឃៅរបស់កងរាជអាវុធហត្ថក្នុងអំឡុងពេលចាប់ច្បាមយកដីធ្លីដោយខុសច្បាប់(លីកាដូ LICADHO) ការចេញផ្សាយព័ត៌មានថ្ងៃទី 18 ខែមករាឆ្នាំ 2009។ "នគរបាល និងកងកម្លាំងយោធា បានដុត និងឈូសកម្ទេចលំនៅដ្ឋាន នៅអំឡុងពេលនៃការបណ្តេញចេញដី នៅភាគពាយ័ព្យប្រទេសកម្ពុជា" អង្គការលីកាដូ )LICADHO) ចេញផ្សាយព័ត៌មានថ្ងៃទី19 ខែវិច្ឆិកាឆ្នាំ 2009 ។ "អ្នកដឹកនាំសហគមន៍ប្រមូលផ្តុំគ្នាដើម្បីសិទ្ធិដីធ្លី នៅរាជធានីភ្នំពេញ" អង្គការលីកាដូ  សេចក្តីប្រកាសព័ត៌មានថ្ងៃទី (លីកាដូ)21 ខែមិថុនាឆ្នាំ2010។ អង្គការសិទ្ធិមនុស្សលីកាដូ "លីកាដូថ្កោលទោសអំពើហិង្សានៅខេត្តកំពង់ស្ពឺ " (LICADHO) សេចក្តីប្រកាសព័ត៌មានថ្ងៃទី 10 ខែមិថុនាឆ្នាំ 2011។ "ការបាញ់ប្រហារចំនួនប្រាំដងទៅលើការតវ៉ាលើជម្លោះដីធ្លីក្នុងរយៈពេលពីរខែ បង្ហាញពីការកើនឡើងគួរឱ្យព្រួយបារម្ភក្នុងការប្រើប្រាស់កម្លាំងសម្លាប់" អង្គការលីកាដូ (សេចក្តីថ្លែងការណ៍ ថ្ងៃទី 26 ខែមករាឆ្នាំ 2012) ។

[462] អង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO), ការវាយប្រហារនិងការគំរាមកំហែងប្រឆាំងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ 2008-2009 (ភ្នំពេញ ៖ ខែកញ្ញាឆ្នាំ 2010) ទំព័រ 50 ។

[463] រដ្ឋាភិបាលត្រូវតែចាត់វិធានការលើអំពើហិង្សាលើជីក្រែង ) អង្គការលីកាដូ"LICADHO) សេចក្តីថ្លែងការណ៍ថ្ងៃទី 21 ខែមិនាឆ្នាំ 2009 "ដោះស្រាយវិបត្តិដីធ្លីនៅកម្ពុជាក្នុងតុលាការ មិនមែនដោយគ្រាប់កាំភ្លើងទេ" អង្គការឃ្លាំមើលសិទ្ធិមនុស្សចេញផ្សាយព័ត៌មានថ្ងៃទី 12 ខែកញ្ញាឆ្នាំ 2009, http://www.hrw.org/news/2009/09/12/solve-cambodia-s-land-crisis-courts-not-bullets; អង្គការលីកាដូ (LICADHO), របាយការណ៍សកម្មភាព ៖ លើកកម្ពស់និងការពារសិទ្ធិមនុស្ស៖ (ភ្នំពេញ៖ ខែធ្នូឆ្នាំ 2010) ទំព័រទី1 ។ អង្គការលើកលែងទោសអន្តរជាតិ, របាយការណ៍អង្គការលើកលែងទោសអន្តរជាតិឆ្នាំ 2010 (London, 2010), http://www.amnesty.org/en/region/cambodia/report-2010# ។

[464] FIDH, វិភាគច្បាប់ស្តីពីបាតុកម្មអនុម័តដោយរដ្ឋសភាក្នុងខែតុលាឆ្នាំ 2009 (ប៉ារីស ៖ តុលា 2009)។

*អនុវត្តន៍ដោយកងរាជអាវុធហត្ថធ្វើឡើងជាបន្តបន្ទាប់។ គោលដៅនៃការបំបែកការប្រមូលផ្តុំ នៅតែតម្រង់លើក្រុមអ្នកតវ៉ារឿងដីធ្លី និងកម្មករធ្វើកូដកម្ម។ កម្លាំងភាគច្រើន ដែលចុះធ្វើសកម្មភាពទាំងនេះ គឺជាកម្លាំងចម្រុះ មានទាំងប៉ូលិស មានទាំងទាហាន។ ក្នុងការបង្ក្រាបនោះ ជួនកាលមានទាំងការបាញ់ប្រហារ ទាំងការវាយដំ ទាំងការចាប់ខ្លួនផង។* [465] *កងរាជអាវុធហត្ថ និងកងកម្លាំងសន្តិសុខដទៃទៀត បានប៉ុនប៉ងបិទច្រកចូលទីក្រុងភ្នំពេញទាំងស្រុង ដើម្បីរារាំងអ្នកតវ៉ាមិនឱ្យចូលរាជធានី។*[466]

*ការរំលោភបំពាននានារបស់កងរាជអាវុធហត្ថ ត្រូវបានគេមើលឃើញកាន់តែច្បាស់ នៅពេលកងរាជអាវុធហត្ថ បង្កើនការគំរាមសម្លាប់ និងការបំភិតបំភ័យតាមរូបភាពផ្សេងៗ ទៅលើអ្នកកាសែត និងសកម្មជនសង្គមស៊ីវិល ក្នុងបំណងរារាំងពួកគេ មិនឱ្យស៊ើបអង្កេតការចោទប្រកាន់របស់សាធារណជនដែលថា កងរាជអាវុធហត្ថ មានការពាក់ព័ន្ធក្នុងការកាប់ឈើ និងជួញដូរឈើប្រណិតខុសច្បាប់។*[467] *កងរាជអាវុធហត្ថ ក៏បានបិទការប៉ុនប៉ងរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងការដឹកនាំសិក្ខាសាលាសិទ្ធិមនុស្ស និងសិក្ខាសាលាបណ្តុះ*

---

[465] អង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO) របាយការណ៍សកម្មភាព ៖ លើកកម្ពស់និងការការពារសិទ្ធិមនុស្ស (ភ្នំពេញ ៖ ខែធ្នូឆ្នាំ 2011) ទំព័រទី 1 ។ អង្គការលីកាដូ (LICADHO) ការវាយប្រហារ និងការគំរាមកំហែងប្រឆាំងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ 2008-2009 (ភ្នំពេញ ៖ ខែកញ្ញាឆ្នាំ 2010)។ "ការវាយដំ និងចាប់ខ្លួនអ្នកភូមិបឹងកក់ចំនួន 11 នាក់ " មជ្ឈមណ្ឌលសិទ្ធិលំនៅដ្ឋាន និងការផន្ទាទោស" សេចក្តីប្រកាសព័ត៌មានថ្ងៃទី 21 ខែមេសាឆ្នាំ 2011 ។ "ប៉ូលីសបំបែកបាតុកម្មដោយកម្មករកាត់ដេរចំនួន 2,000 នាក់។ កម្មករ 8 នាក់រងរបួស 2 នាក់ត្រូវបានចាប់ខ្លួន "ADHOC ចេញផ្សាយព័ត៌មានថ្ងៃទី 8 ខែឧសភាឆ្នាំ 2011 ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍(CLEC) សម្ព័ន្ធជំរឿន និងការពារសិទ្ធិមនុស្ស (LICADHO) សេចក្តីប្រកាសព័ត៌មានថ្ងៃទី18 ខែសីហាឆ្នាំ 2011។ អង្គការលីកាដូ; សេរីភាពបញ្ចេញមតិនៅកម្ពុជា៖ ប្រជាធិបតេយ្យថ្លិនភ្លែក (The Illusion of Democracy) ភ្នំពេញ ៖ ខែធ្នូឆ្នាំ 2010) ទំព័រទី 8-10, 13។ អង្គការលីកាដូ (LICADHO), ការយល់ខុសនៃការវិវឌ្ឍន៍៖ (The Delusion of Progress)៖ ច្បាប់កម្ពុជាមួយចំនួនរំលោភសេរីភាពបញ្ចេញមតិ (ភ្នំពេញ ៖ ខែតុលាឆ្នាំ 2011) ទំព័រ 28 ។ អង្គការលីកាដូ  (LICADHO), របាយការណ៍សកម្មភាព ៖ ការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស៖ (ភ្នំពេញ ខែធ្នូ ឆ្នាំ 2011) ទំព័រទី 2, 9; "បញ្ឈប់និទណ្ឌភាពនៃអំពើហិង្សាដោយកាំភ្លើង ៖ ចាប់ខ្លួន និងចោទប្រកាន់អ្នកបាញ់បោះនៅស្វាយរៀង"អង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO) និងមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) សេចក្តីប្រកាសព័ត៌មានថ្ងៃទី 21 ខែកុម្ភៈឆ្នាំ 2012។ អង្គការលីកាដូ (LICADHO) ការវាយលុក និងការគំរាមកំហែងប្រឆាំងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ 2010-2012 (ភ្នំពេញ :  ខែធ្នូ ឆ្នាំ2012) ទំព័រទី 13, ទី 15, 28, 34, 36-37, 45-46, 52, 56។ អង្គការសិទ្ធិមនុស្សលីកាដូ (លីកាដូ, 2012) នៅក្នុងការពិនិត្យឡើងវិញ៖ ការប្រើកម្លាំងប្រឆាំងនឹងការតវ៉ាដោយសន្តិភាព (ភ្នំពេញ ខែកុម្ភះ ឆ្នាំ 2013), http://www.licadho-cambodia.org/articles/20130213 20:55:00/134/index.html.

[466] "កម្មករនិយោជិតប្រមូលផ្តុំដើម្បីទាមទារប្រាក់ឈ្នួលអប្បបរមាប្រសើរជាង" ADHOC - CCHR - CLEC - LICADHO ការចេញផ្សាយព័ត៌មានថ្ងៃទី 25 ខែកក្កដាឆ្នាំ 2010 ។)

[467] អង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO), ការរឹតត្បិតលើសេរីភាពបញ្ចេញមតិនៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់កម្ពុជា ភ្នំពេញ) ៖ ឧសភា 2009) ទំព័រទី 25, 27, 28។ "អ្នកតវ៉ាដីធ្លីចំនួន 30 នាក់ត្រូវបានចាប់ខ្លួនក្នុងការប៉ះទង្គិចជាមួយប៉ូលីសយោធាកម្ពុជា" អង្គការលីកាដូចេញផ្សាយថ្ងៃទី 24 ខែសីហាឆ្នាំ 2009 http://www.licadho-cambodia.org/articles/20090824 00:00:00 /97 / index.htm។ អង្គការលីកាដូ (LICADHO), ការវាយប្រហារនិងការគំរាមកំហែងប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ 2008-2009 (ភ្នំពេញ ៖ ខែកញ្ញាឆ្នាំ 2010), ទំព័រ 339, 46, 50។ អង្គការលីកាដូ )LICADHO) សេរីភាពបញ្ចេញមតិនៅកម្ពុជា ៖ ប្រជាធិបតេយ្យថ្លិនភ្លែក (The Illusion of Democracy) (ភ្នំពេញ ខែធ្នូឆ្នាំ 2010) ទំព័រ 29 ។ អង្គការលីកាដូ (LICADHO) ការវាយប្រហារនិងការគំរាមកំហែងប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ 2010-2012 (ភ្នំពេញ ៖ ខែធ្នូឆ្នាំ 2012) ទំព័រ 35 ។

បណ្តាលស្របច្បាប់ដទៃទៀត ដោយពួកគេចាត់ទុកថា ជាការប្រមូលផ្តុំខុសច្បាប់។[468]

មានឧប្បត្តិហេតុអាក្រក់ខ្លាំងចំនួនពីរក្នុងឆ្នាំ២០១២ ពាក់ព័ន្ធនឹងកងរាជអាវុធហត្ថ។ ទីមួយ គឺការបាញ់សម្លាប់សកម្មជនបរិស្ថានល្បីឈ្មោះ លោក ឈុត វុទ្ធី នៅថ្ងៃទី ២៦ ខែមេសាឆ្នាំ ២០១២ ដែលការសម្លាប់នេះបង្ហាញពីការជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយសកម្មភាពអាជីវកម្មខុសច្បាប់របស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស។ គាត់ត្រូវបានគេបាញ់សម្លាប់បន្ទាប់ពីមន្ត្រីអាវុធហត្ថ និងឆ្មាំសន្តិសុខពីក្រុមហ៊ុនដែលជាប់ពាក់ព័ន្ធក្នុងការកាប់ឈើខុសច្បាប់ បានរារាំងគាត់ដោយខុសច្បាប់ពីការកត់ត្រានូវសកម្មភាពខុសច្បាប់របស់ពួកគេ។ ថ្វីបើកាលៈទេសៈពិតប្រាកដនៃការស្លាប់របស់លោក ឈុត វុទ្ធី នៅតែមិនច្បាស់ក្តី ក៏ការកាត់ក្តីនៅក្នុងសំណុំរឿងនេះ បានបង្ហាញថា គឺធ្វើឡើងក្នុងបំណងបិទបាំង និងការពារអ្នកដែលទទួលខុសត្រូវចំពោះការស្លាប់របស់គាត់ និងបន្តបិទបាំងអាជីវកម្មខុសច្បាប់របស់ពួកគេ។[469] សាលក្រមកាត់ទោសត្រូវបានធ្វើឡើងដោយផ្អែកលើលទ្ធផលនៃការស៊ើបអង្កេតធ្វើឡើងដោយគណៈកម្មការចម្រុះមួយ ដែលបានបង្កើតឡើងតាមបញ្ជារបស់លោក ហ៊ុន សែន ដែលគណៈកម្មការចម្រុះនោះ មានលោក សៅ សុខា ជាសមាជិកម្នាក់ដែរ។[470]

ចំណែកឧប្បត្តិហេតុទី២វិញ គឺកើតឡើងនៅក្នុងខែឧសភា ឆ្នាំ២០១២ នៅពេលកងរាជអាវុធហត្ថក្នុងចំណោមកងកម្លាំងសន្តិសុខចម្រុះ បានដឹកនាំប្រតិបត្តិការទ្រង់ទ្រាយធំមួយបង្ក្រាបសកម្មភាពដែលអាជ្ញាធរចោទថា ជាចលនាអបគមន៍ នៅភូមិប្រម៉ា ខេត្តក្រចេះ ជាកន្លែងដែលប្រជាពលរដ្ឋតវ៉ាប្រឆាំងក្រុមហ៊ុនចំការកៅស៊ូ ដែលអ្នកភូមិចោទថា បានច្បាមយកដីធ្លីប្រជាជន។[471] កម្លាំងប្រដាប់អាវុធបានបាញ់សម្លាប់ក្មេងស្រីអាយុ ១៤ ឆ្នាំម្នាក់ឈ្មោះហេង ចន្ថា។ ខណៈសម្តែងមរណទុក្ខចំពោះការស្លាប់របស់កុមារីហេង ចន្ថា លោក

---

468 អង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO), ការយល់ខុសនៃការវិវឌ្ឍន៍៖ (The Delusion of Progress)៖ ច្បាប់កម្ពុជាមួយចំនួនរំលោភសេរីភាពបញ្ចេញមតិ (ភ្នំពេញ៖ ខែតុលាឆ្នាំ 2011) ទំព័រទី 26 ។ អង្គការលីកាដូ (LICADHO) ការវាយប្រហារនិងការគំរាមកំហែងប្រឆាំងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ 2010-2012 (ភ្នំពេញ ៖ ខែធ្នូ ឆ្នាំ 2012) ទំព័រទី 50-51 ។

469 អង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែនរ៉ៃត៍វច្ឆ, " ប្រាប់ពួកគេទៅថា ខ្ញុំចង់សម្លាប់ពួកគេ "ទំព័រ 58-63 (Tell Them That I Want to Kill Them)

470 "គណៈកម្មាធិការកម្ពុជា ដើម្បីស៊ើបអង្កេតការសំលាប់សកម្មជនបរិស្ថាន" VOA ថ្ងៃទី 29 ខែមេសាឆ្នាំ 2012, http://www.voanews.com/content/cambodian-committee-to-investigate-killing-of-environmental-activist- 149559265/370493 ។ html (ចូលមើលថ្ងៃទី 23 ខែតុលាឆ្នាំ 2012)។ "សកម្មជនបរិស្ថាននៅកម្ពុជាចុចឃាតកម្មស៊ើបអង្កេត" VOA, ថ្ងៃទី 1 ខែឧសភាឆ្នាំ 2012, http://www.voanews.com/content/cambodian-environmental-activists-press-murder-probe- 149818385 / 370247.html (ចូលមើលនៅថ្ងៃទី 23 ខែតុលាឆ្នាំ 2012) 2012)។ "ក្រុមគ្រួសារនៃសាកសពបុរសសួរសំណួរផ្លូវការ", ខេមបូឌាដេលី, ថ្ងៃទី 30 ខែមេសាឆ្នាំ 2012។ "ការសម្លាប់លោក ឈុត វុទ្ធី" អាដហុកចេញផ្សាយនៅថ្ងៃទី 4 ខែឧសភាឆ្នាំ 2012 http://adhoc-cambodia.org/?p=1593 (ចូលមើលថ្ងៃទី 23 ខែតុលាឆ្នាំ 2012) ។

471 អង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO), សំណុំរឿងលោកម៉ម សូណាង់ដូ ត្រូវបានពន្យល់ភ្នំពេញ ៖ (ខែសីហា ឆ្នាំ 2012) ទំព័រទី ១ ។

ហ៊ុន សែន ក៏បានអះអាងដោះសារដោយគ្មានមូលដ្ឋានថា ប្រតិបត្តិការបង្ក្រាបនេះ វាជាការចាំបាច់ដើម្បីទប់ស្កាត់ការរីកលូតលាស់នៃចលនាបំបែករដ្ឋ។ លោក ហ៊ុន សែន ក៏យកឱកាសនេះត្អូញត្អែរឌីដងឱ្យអាមេរិកដែរថា គេគួរលើកយកការព្រួយបារម្ភចំពោះការស្លាប់របស់កុមារី ហេង ចន្ថា នេះ ទៅប្រឆាំងនឹងអំពើឃោរឃៅរបស់អាមេរិកនៅក្នុងប្រទេសអាហ្វហ្កានីស្ថាន (Afghanistan) វិញទៅ។[472]

## លោក សៅ សុខា ការបោះឆ្នោត ឆ្នាំ២០១៣ ព្រឹត្តិការណ៍ក្រោយការបោះឆ្នោត និងចាប់តាំងពីពេលនោះមក

នៅខណៈការបោះឆ្នោតខែកក្កដា ឆ្នាំ២០១៣ ខិតជិតមកដល់ កងរាជអាវុធហត្ថបានចាប់ផ្តើមពង្រឹងសមត្ថភាពរបស់ខ្លួនដោយ "ការហ្វឹកហ្វឺនថែរក្សាសណ្តាប់ធ្នាប់សាធារណៈ" ត្រៀមទប់ទល់ប្រឆាំងបាតុកម្ម។ ក្នុងការអនុវត្តន៍បទបញ្ជារបស់លោក សៅ សុខា ការហ្វឹកហាត់នេះផ្តោតលើរបៀបប្រមូលផ្តុំកម្លាំងច្រើនរបស់កងរាជអាវុធហត្ថ ដើម្បីទប់ទល់នឹងការតវ៉ាតាមទីប្រជុំជន និងស្ថានការណ៍ចលាចល ដោយដាក់ពាយកាំភ្លើងវាយប្រហារ និងរថពាសដែក រួមជាមួយឧស្ម័នបង្ហូរទឹកភ្នែក និងកាំភ្លើងបាញ់ទឹកបំបែកបាតុករ និងការចាប់ខ្លួនបាតុករដោយការភ្ជង់កាំភ្លើង សូម្បីតែនៅពេលបាតុករគ្មានអាវុធក៏ដោយ ដូចដែលបានបង្ហាញនៅក្នុងការបោះពុម្ពផ្សាយរបស់កងរាជអាវុធហត្ថ។ ការហ្វឹកហ្វឺន ក៏បានសង្កត់ធ្ងន់ទៅលើការប្រើប្រាស់កម្លាំងក្នុងយុទ្ធសាស្ត្រត្រួតត្រាហ្វូងមនុស្ស ដូចជា "ការរុញច្រាន" "ការវាយលុក និងការវាយសម្រុក" "ការចូលបិទខ្ទប់ និងបញ្ឈប់" និង "ការហ៊ុំព័ទ្ធ"។[473]

ទោះបីជាមានរបាយការណ៍ថ្មីស្តីពីការចូលរួមរបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងការរំលោភបំពានសិទ្ធិមនុស្សក៏ដោយ ក៏លោក សៅ សុខាគាំទ្រជាចំហចំពោះគណបក្សប្រជាជនកម្ពុជា និងបន្តគាំទ្រឱ្យលោក

---

[472] "កម្ពុជា ៖ បន្ទាប់ពីអាមេរិក, អាស៊ានចាកចេញ, ការរិះគន់តាមសារព័ត៌មានត្រូវជាប់ពន្ធនាគារ" អង្គការឃ្លាំមើលសិទ្ធិមនុស្ស ចេញផ្សាយព័ត៌មាន ថ្ងៃទី 17 ខែកក្កដាឆ្នាំ 2012, http://www.hrw.org/news/2012/07/17/cambodia-after-us -anan-leave-media-critic-jailed។ "ហ៊ុន សែនតម្រង់គោលដៅដាក់សហរដ្ឋអាមេរិកក្នុងថ្លែងសុន្ទរកថា, កម្ពុជាខេលី នៅថ្ងៃទី 15 ខែមិថុនាឆ្នាំ 2012, https://sahrika.com/2012/06/15/hun-sen-takes-aim-at-us-during-speech/ ( ចូលមើលថ្ងៃទី 25 ខែមិថុនាឆ្នាំ 2016) ។

[473] "សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថកំបូល អនុវត្តជាក់ស្តែងហ្វឹកហ្វឺនរក្សាសណ្តាប់ធ្នាប់។" ទស្សនាវដ្តីកងរាជអាវុធហត្ថ, ឆ្នាំទី 18 លេខ 49 ឆ្នាំ 2012) , ទំព័រ 31-33។ "ស្នងការដ្ឋានចំណុះឲ្យកងរាជអាវុធហត្ថលើផ្ទៃប្រទេសបានបិទបញ្ចប់កិច្ចប្រជុំបូកសរុបលទ្ធផលឆ្នាំ 2012 និងគោលដៅឆ្នាំ 2013" "ទស្សនាវដ្តីកងរាជអាវុធហត្ថ ឆ្នាំទី)19 លេខ 52 ឆ្នាំ 2013) ទំព័រទី 11 ។ "Kettling" គឺកលយុទ្ធកំលាំងសន្តិសុខមួយ ដែលទាក់ទងនឹងការបង្កើតកំលាំងដ៏ធំនៃកម្លាំងបុគ្គលិកសន្តិសុខ ដែលក្រោយមកផ្លាស់ទៅមានហ្វូងមនុស្សនៅក្នុងតំបន់មានកំណត់មួយ។

ហ៊ុន សែនធ្វើជានាយករដ្ឋមន្ត្រី ក្នុងអំឡុងយុទ្ធនាការឃោសនាបោះឆ្នោតឆ្នាំ២០១៣។[474] លោក សៅ សុខា បាននិយាយដូច្នេះនៅក្នុងខេត្តស្វាយរៀង ជាខេត្តកំណើតរបស់លោក ក្នុងឋានៈជាប្រធានក្រុមការងារស្រុករបស់គណបក្សប្រជាជនកម្ពុជា ដែលត្រូវបានចាត់តាំងឱ្យទៅខេត្តនេះ។[475]

ការចោទប្រកាន់ដ៏គួរឱ្យជឿទុកចិត្តបានលើភាពមិនប្រក្រតី ដែលធ្វើឲ្យប៉ះពាល់លទ្ធផលចុងក្រោយនៃការបោះឆ្នោត បាននាំឱ្យមានបាតុកម្មដឹកនាំដោយគណបក្សសង្គ្រោះជាតិកាលពីខែសីហា ឆ្នាំ ២០១៣ ។ គណបក្សសង្គ្រោះជាតិ បានអំពាវនាវឱ្យមានការស៊ើបអង្កេត កំណែទម្រង់ការបោះឆ្នោត ការបោះឆ្នោតសារឡើងវិញ និងលោក ហ៊ុន សែន ចុះចេញពីតំណែង។ ដើម្បីរារាំង និងទប់ស្កាត់ការតវ៉ាដោយសន្តិវិធី រដ្ឋាភិបាលបានចាប់ផ្តើមដាក់ពង្រាយនគរបាលប្រដាប់អាវុធជាច្រើន កងរាជអាវុធហត្ថ និងជួនកាលកងទ័ពនៅក្នុងរាជធានីភ្នំពេញ និងទីក្រុងដទៃទៀត។ ការដាក់ពង្រាយទាំងនេះ ក៏មានបំណងការពារ និងបំបែកកូដកម្មរបស់កម្មករ ដែលទាមទារឡើងប្រាក់ខែគោល និងលក្ខខណ្ឌការងារប្រសើរឡើង។[476]

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ រដ្ឋាភិបាលបានដាក់ពង្រាយនគរបាល កងរាជអាវុធហត្ថ និងកងកម្លាំងសន្តិសុខជាច្រើនផ្សេងទៀត ដើម្បីទប់ស្កាត់ការប្រកាសផែនការជួបជុំដ៏ធំ និងជាបន្តបន្ទាប់នៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញរបស់គណបក្សសង្គ្រោះជាតិ។ ធ្វើសកម្មភាពក្រោមការបញ្ជារបស់លោក ហ៊ុន សែន លោក សៅ សុខា ក្នុងចំណោមកងកម្លាំងដទៃទៀត បានព្យាយាមបិទច្រកចូលរាជធានី ដើម្បីរារាំងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ ចូលក្នុងទីក្រុង។ កម្លាំងនគរបាល និងកម្លាំកងរាជអាវុធហត្ថក្រុង និងនៅផ្ទៃប្រទេសទាំងមូលបានត្រៀមធ្វើសកម្មភាព ដែលក្នុងនោះកម្លាំងរាជអាវុធហត្ថតាមបណ្តាខេត្តទូទាំងប្រទេសត្រូវបានដឹកតាមបញ្ជារបស់លោក សៅ សុខា ឱ្យមកឈរជើងត្រៀមនៅទីតាំងសំខាន់ៗជុំវិញរាជធានី

---

[474] អង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO) គូសបង្ហាញស្ថិតិសម្រាប់ឆ្នាំ 2012-2013 ថ្ងៃទី 29 ខែកក្កដាឆ្នាំ 2014 (ឯកសារក្នុងការកាន់កាប់របស់អង្គឃ្លាំមើលសិទ្ធិមនុស្សេ្យា៖ "នគរបាលវាយដំអ្នកតវ៉ានៅបឹងកក់, ធ្វើឱ្យមនុស្សប្រាំនាក់រងរបួស "អង្គការលីកាដូ (LICADHO) ចេញផ្សាយព័ត៌មានថ្ងៃទី 13 ខែមីនាឆ្នាំ 2013 ។ អង្គការលីកាដូ (LICADHO), ឆ្នាំ 2013 ក្នុងការពិនិត្យឡើងវិញ ៖ ការថយចុះនូវការប្រមូលផ្តុំ និងការបញ្ចេញមតិ នៅក្នុងប្រទេសកម្ពុជា ភ្នំពេញ៖ ខែមីនាឆ្នាំ 2014) http: //www.licadho-cambodia.org/articles/20140319 14:22: 00/140 / index.htm (ចូលមើលនៅថ្ងៃទី 4 ខែមេសាឆ្នាំ 2014) ។

[475] "លោក ជា សំណាង បាននាំយកអំណោយទៅប្រគេនព្រះសង្ឃនៅវត្តម្រាមចាស់", ថ្ងៃទី 29 ខែតុលាឆ្នាំ 2012, http://www.dap-news.com/2011-06-14-02-39-55/51707-2012-10-29-04-31-58.html (ចូលមើលថ្ងៃទី 29 ខែតុលាឆ្នាំ 2012) ។

[476] ពីប្រភពដដែល Ibid.

ភ្នំពេញ។ ក៏ប៉ុន្តែ នៅព្រឹកព្រលឹមស្រាងៗការបង្ហាញខ្លួនដ៏ច្រើនសន្ធឹកសន្ធាប់នៃចំនួនមនុស្សដែលធ្វើដំណើរពីគ្រប់ច្រកល្ហកទៅចូលរួមការប្រមូលផ្តុំរបស់គណបក្សសង្គ្រោះជាតិ បានធ្វើឱ្យកងកម្លាំងសន្តិសុខមិនអាចទប់ទល់ឈ្នះ។[477]

ការប្រមូលផ្តុំគ្នាក៏បានប្រព្រឹត្តទៅ ហើយបានធ្វើទៅដោយសន្តិវិធី ប៉ុន្តែកងកម្លាំងសន្តិសុខនៅតែស្ថិតក្នុងទីតាំងរបស់ពួកគេ ហើយបានរាំងខ្ទប់អ្នកគាំទ្រគណបក្សសង្គ្រោះជាតិ និងប្រជាពលរដ្ឋរាប់ពាន់នាក់ផ្សេងទៀតនៅទីក្រុងភ្នំពេញ មិនឱ្យវិលត្រលប់មកផ្ទះវិញ។ កងរាជអាវុធហត្ថ និងប៉ូលិស ព្រមទាំងកងកម្លាំងប្រដាប់អាវុធដទៃទៀតដែលប្រដាប់ដោយកាំភ្លើងវែង និងកាំភ្លើងខ្លី ត្រូវបានដាក់ពង្រាយនៅជិតក្បាលថ្នល់ និងស្ពានមុន្នីវង្ស ភាគអាគ្នេយ៍នៃរាជធានីភ្នំពេញ បង្កឱ្យមានចលាចលសង្គម។

កងកម្លាំងសន្តិសុខជាច្រើនបានបាញ់ឧស្ម័នបង្ហូរទឹកភ្នែក និងបន្ទាប់មកក៏បាញ់គ្រាប់ពិត។ អ្នកឈរមើលម្នាក់ត្រូវបានបាញ់ស្លាប់ ដែលប្រហែលជាត្រូវគ្រាប់កាំភ្លើងរបស់ប៉ូលីស។ កងរាជអាវុធហត្ថ ក៏បានបាញ់កាំភ្លើងគ្រាប់ពិត ដើម្បីបំបែកហ្វូងមនុស្សដែលដើរឆ្ពោះសំដៅទៅរកពួកគេពីទីកន្លែងដែលអ្នកឈរមើលត្រូវបានគេបាញ់សម្លាប់។ ទោះជាយ៉ាងណា ក្នុងពេលនោះគ្មាននរណាម្នាក់ត្រូវគ្រាប់កាំភ្លើងទៀតទេ។[478]

កងរាជអាវុធហត្ថ ក៏ស្ថិតក្នុងចំណោមកងកម្លាំងចម្រុះ ដែលបានបង្ហាញខ្លួននៅកន្លែងកើតហេតុនៃការបាញ់ប្រហារ ដោយប៉ូលីសក្នុងអំឡុងកិច្ចខិតខំប្រឹងប្រែង ដើម្បីបំបែកកូដកម្មរបស់កម្មករនៅថ្ងៃទី១២ ខែវិច្ឆិកាឆ្នាំ ២០១៣។ បន្ទាប់ពីជនរងគ្រោះ ដែលជាអ្នកឈរមើលម្នាក់ទៀតត្រូវបានបាញ់សម្លាប់ដោយមិនរើសមុខកម្លាំងកងរាជអាវុធហត្ថ ក៏បានមកដល់ដើម្បីជួយកម្លាំងប៉ូលិសគ្រប់គ្រងតំបន់នោះ។ ក្នុងពេលបង្ក្រាបនោះ ប៉ូលីស និងកងរាជអាវុធហត្ថ បានប្រើដំបងវាយដំបុរសវ័យក្មេងជាច្រើននាក់នៅក្នុងតំបន់នោះ។ ការវាយដំបានបណ្តាលឱ្យរងរបួសដល់មនុស្សយ៉ាងហោចណាស់ ២៦ នាក់។[479]

---

[477] ការសម្ភាសន៍ជាមួយមន្ត្រីកងកម្លាំងសន្តិសុខកម្ពុជាថ្ងៃទី 15-16 ខែកញ្ញាឆ្នាំ 2013។

[478] "កម្ពុជា ៖ ដោះលែងអ្នកទាំង ៦ នាក់ដែលត្រូវបានគេចាប់ខ្លួនតាមអំពើចិត្តអំឡុងពេលចលាចល" ការចេញផ្សាយព័ត៌មានរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សយូមែនរ៉ៃវច្ឆ (Hunan Rights Watch) ថ្ងៃទី 20 ខែកុម្ភៈឆ្នាំ 2014។http://www.hrw.org/news/2014/02/19/cambodia-free-6-randomly-arrested-during-unrest.

[479] "កម្ពុជា ៖ ការជំនុំជម្រះករណីស្ទឹងមានជ័យបង្កើតកំហុសធ្ងន់ធ្ងរចេញផ្សាយ " ថ្ងៃទី 11 ខែឧសភាឆ្នាំ 2014 http://www.hrw.org/news/2014/05/11/cambodia-steung-meanchey-trial-deeply-flawed.

កងរាជអាវុធហត្ថរាជធានី បានដើរតួយ៉ាងសំខាន់ក្នុងការសម្លាប់មនុស្សធ្ងន់ធ្ងរបំផុត ក្រោយការបោះឆ្នោត ជាពិសេសពាក់ព័ន្ធនឹងកម្មករ។ នៅយប់ថ្ងៃទី ២-៣ ខែមករា ឆ្នាំ២០១៤ គណៈបញ្ជាការឯកភាពពិសេស ដែលដឹកនាំដោយប្រធាននាយកដ្ឋានកណ្តាលនៃនគរបាលយុត្តិធម៌រាជធានី លោក ម៉ក់ ជីតូ បានដាក់ពង្រាយនគរបាលស្រុក នគរបាលរាជធានី និងកងរាជអាវុធហត្ថរាប់រយនាក់ ដើម្បីបោសសំអាតកម្មករ ដែលបិទខ្ទប់ផ្លូវថ្នល់ (ផ្លូវវេងស្រេង) នៅជាយក្រុងភ្នំពេញ។ ការប៉ះទង្គិចគ្នាដោយហិង្សាបានផ្ទុះឡើង បណ្តាលឱ្យភាគីកម្មករមួយចំនួនបានគប់ដុំថ្ម ឈើ និងដបសាំង ព្រមទាំងវាយប្រហារទៅលើទ្រព្យសម្បត្តិ ខណៈដែលកងកម្លាំងសន្តិសុខ ដែលពួកគេខ្លះរងរបួស បានបាញ់ឧស្ម័នបង្ហូរទឹកភ្នែក គ្រាប់បែកផ្សែង និង បាញ់គ្រាប់ពិតនៅពេលខ្លះ។[480] នៅព្រឹកថ្ងៃទី ៣ ខែមករា អាជ្ញាធរគណៈបញ្ជាការឯកភាព បានបញ្ជូន កម្លាំងកងអាវុធហត្ថយ៉ាងច្រើនបន្ថែមទៀត ដើម្បីដណ្តើមកាន់កាប់តំបន់នេះ ដែលមួយចំនួនបានបាញ់ កាំភ្លើងសម្លាប់ដោយមិនរើសមុខ បណ្តាលឱ្យស្លាប់មនុស្ស ៥ នាក់ និងចាប់ខ្លួន១០នាក់ផ្សេងទៀត។ តំបន់ នេះក្រោយមក ត្រូវបានកាន់កាប់ដោយទាហានកងពលតូចលេខ ៧០។ អ្នកដែលត្រូវបានចាប់ និងឃុំខ្លួន ទាំង ១០ នាក់នោះ ក្រោយមកត្រូវបានផ្តន្ទាទោសដោយការព្យួរទោស ទោះបីគ្មានភស្តុតាងប្រឆាំងពួកគេក៏ ដោយ ។ ម្នាក់ក្នុងចំណោមជនរងគ្រោះដទៃទៀតដែលរងការវាយប្រហារពីកងរាជអាវុធហត្ថ ក្រោយមក បានស្លាប់ដោយសាររបួសរបស់គាត់។[481]

នៅថ្ងៃទី៤ ខែមករាឆ្នាំ ២០១៤ រដ្ឋាភិបាលបានប្រកាសបិទទីលានប្រជាធិបតេយ្យទាំងស្រុង នៅរាជធានី ភ្នំពេញ ដោយប្រើកងរាជអាវុធហត្ថ រួមនឹងកងកម្លាំងសន្តិសុខដទៃទៀតបោសសម្អាតលែងឱ្យមានបាតុករ នៅក្នុងទីលាន និងហាមឃាត់តាមតែអំពើចិត្ត បំបិទសេរីភាពនៃការជួបប្រជុំដោយសន្តិវិធីរហូតដល់ខែសីហា ឆ្នាំ២០១៤។ ចាប់ពីខែមករារហូតដល់ខែសីហា ឆ្នាំ២០១៤ កងកម្លាំងសន្តិសុខចម្រុះ មានទាំងកងរាជអាវុធ ហត្ថផង បានហាមរារាំងមិនឱ្យមានមនុស្ស ឬជួបជុំគ្នាឡើយ ។[482]

---

480 ពីប្រភពដដែល Ibid.

481 ពីប្រភពដដែល Ibid.

482 "កម្ពុជា ៖ ត្រូវទម្លាក់ចោលករណីប្រឆាំងអ្នកនយោបាយជំទាស់ " ការចេញផ្សាយរបស់អង្គការសិទ្ធិមនុស្ស យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី ១៧ ខែកក្កដាឆ្នាំ 2014, http://www.hrw.org/news/2014/07/17/cambodia-drop-cases-against-opposition-politicians.។

នៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈជាបន្តបន្ទាប់ក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៤ លោក សៅ សុខា ក្នុងនាមជាមន្ត្រីកងរាជអាវុធហត្ថ បានបន្តបញ្ចេញជំហរនិយមគណបក្សប្រជាជនកម្ពុជារបស់លោកកាន់តែច្បាស់ ដោយប្រកាសគាំទ្រគណបក្សប្រជាជនកម្ពុជានៅក្នុងការបោះឆ្នោត និងលទ្ធផលបោះឆ្នោត។ នៅថ្ងៃទី ២ ខែសីហា ឆ្នាំ២០១៣ ក្រោយការបោះឆ្នោត លោក សៅ សុខា បានកោះប្រជុំមន្ត្រីអាវុធហត្ថជាង ៥០០ (ប្រាំរយ) នាក់មកពីទូទាំងប្រទេស ដែលលោកបានប្រកាសថា ការបោះឆ្នោតគឺ "សេរី យុត្តិធម៌ និងមានតម្លាភាព" ដូច្នេះ ចូរគាំទ្រលទ្ធផលផ្លូវការ និងច្រានចោលការព្រួយបារម្ភអំពីការក្លែងបន្លំ និងភាពមិនប្រក្រតី។[483] នៅក្នុងខែតុលា លោក សៅ សុខា បានចាប់ផ្តើមគាំទ្រលទ្ធផលបោះឆ្នោតផ្លូវការ ហើយបានបញ្ជាឱ្យមន្ត្រីអាវុធហត្ថទាំងអស់ឲ្យធ្វើដូចគ្នានេះ។[484] ក្នុងអំឡុងពេលនៃការធ្វើសមយុទ្ធសព្វាវុធរាជអាវុធហត្ថ នៅថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ លោក សៅ សុខា បានលើកឡើងថា "អ្នកដែលស្រឡាញ់ជាតិ" ត្រៀមខ្លួនរួចជាស្រេចដើម្បីប្រយុទ្ធប្រឆាំងនឹងចលាចលណាមួយ ដែលលោកពន្យល់ផងដែរថា "វត្តមានយោធាដ៏រឹងមាំ" នៅក្នុងរាជធានីភ្នំពេញគឺដើម្បី "រៀបចំរក្សាសន្តិសុខ" ។ ទន្ទឹមនឹងនេះដែរ លោកបានប្រកាសថា ការដាក់ពង្រាយកម្លាំងបានធ្វើឱ្យលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ "ភ័យខ្លាច" ដោយថ្កោលទោសលោក សម រង្ស៊ី ថាជា "ទាសករ" នៃផលប្រយោជន៍ជនបរទេស។ លោកចោទថា លោក សម រង្ស៊ី ជារឿយៗបានទទូចឱ្យរដ្ឋាភិបាលបរទេសកាត់ជំនួយមកឲ្យកម្ពុជា។[485]

រយៈពេលជាងពីរសប្តាហ៍បន្ទាប់ពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ ដែលជាថ្ងៃកងរាជអាវុធហត្ថបាញ់សម្លាប់កម្មករ លោក សៅ សុខា ក៏បានថ្លែងសារនៅក្នុងសន្និសីទប្រចាំឆ្នាំរបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ខណៈថ្លែងថ្កោលទោសបាតុកម្មក្រោយការបោះឆ្នោតដែលអំពាវនាវឱ្យលោក ហ៊ុន សែនចុះចេញពីតំណែងនោះ លោក សៅ សុខា បានថ្លែងការពារលោក ហ៊ុន សែន ថាជាប្រមុខស្របច្បាប់របស់រដ្ឋាភិបាល និងបានស្តីបន្ទោសអំពើហិង្សា និងការស្លាប់មនុស្សទៅលើអ្នកផ្សេង ដែលលោកហៅថា ជន "បាតដៃទី៣" និង "ក្រុមជ្រុលនិយម " ដែលសមាជិករបស់ពួកនេះ "បានរៀបចំការញុះញង់ដើម្បីផ្តួលរំលំរាជរដ្ឋាភិបាល"។[486] នៅ

---

[483] "លោកសៅ សុខា ៖ កងរាជអាវុធហត្ថបានបំពេញតួនាទីរបស់ខ្លួនយ៉ាងល្អ ក្នុងអំឡុងពេលយុទ្ធនាការនិងការបោះឆ្នោត " ថ្ងៃទី 3 ខែសីហាឆ្នាំ 2013 http://www.cen.com.kh/localnews/details_more/19?token=YjVkYjYyOW (ចូលមើលនៅថ្ងៃទី 5 ខែសីហាឆ្នាំ 2013)។

[484] "កងរាជអាវុធហត្ថខេត្តកោះកុង បើកសម័យប្រជុំសិក្សាស្តីពីផែនការផ្សព្វផ្សាយសៀវភៅស ស្តីពីការបោះឆ្នោតទូទៅ" ថ្ងៃទី 21 ខែតុលាឆ្នាំ 2103, http://www.dap-news.com/2011-06-14-02 -39-55 / 74126 - lr-.html (ចូលមើលនៅថ្ងៃទី 1 ខែវិច្ឆិកាឆ្នាំ 2013)។

[485] "កងរាជអាវុធហត្ថសាកល្បងអាវុធជាការកសាងសន្តិសុខក្នុងរាជធានីភ្នំពេញ ខេមបូឌាដេលីថ្ងៃអង្គារទី "17 ខែតុលាឆ្នាំ 2013 ។

[486] "កងរាជអាវុធហត្ថប្រកាសប្តេជ្ញាការពាររដ្ឋធម្មនុញ្ញនិងរាជរដ្ឋាភិបាល" ថ្ងៃទី 23 ខែមករាឆ្នាំ 2014 http://www.cen.com.kh/localnews/show_detail/

ក្នុងសុន្ទរកថានៅឯទីស្នាក់ការកណ្តាលនៃកងរាជអាវុធហត្ថ នៅរាជធានីភ្នំពេញនៅថ្ងៃទី ១ ខែមេសា ឆ្នាំ ២០១៤ លោក សៅ សុខា បានចេញបញ្ជាថ្មីមួយ ឱ្យមេបញ្ជាការកងរាជអាវុធហត្ថទាំងអស់ ប្រឆាំងនឹងការទាមទារក្រោយការបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ ដោយឲ្យបង្កើនសកម្មភាពរបស់កងរាជអាវុធហត្ថ ដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈ។ លោកថា គណបក្សសង្គ្រោះជាតិ អាចនឹងបន្តប្រើប្រាស់គោលនយោបាយភេរវកម្ម ដើម្បីគាំទ្រការទាមទាររបស់ខ្លួន និងអះអាងថា បាតុកម្មទាមទារផ្លាស់ប្តូរមេដឹកនាំកម្ពុជានោះ គឺនឹងគ្មានលទ្ធផលអ្វីក្រៅតែពីអាចនាំមកនូវភាពអវិជ្ជមានដល់ប្រទេសជាតិប៉ុណ្ណោះទេ។[487]

នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ លោក សៅ សុខា បានចុះទៅខេត្តស្វាយរៀង ក្នុងនាមជាប្រធានក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជា អមដំណើរជាមួយមានមន្ត្រីអាវុធហត្ថក្រោមបង្គាប់ និងរៀបចំចាត់ចែងដោយមន្ត្រីគណបក្សប្រជាជនកម្ពុជា។ ពួកគេបានអំពាវនាវឱ្យកងរាជអាវុធហត្ថខេត្ត អនុវត្តគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា។[488] នៅក្នុងកិច្ចប្រជុំកងរាជអាវុធហត្ថជាតិ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០១៤ លោក សៅ សុខាបានអំពាវនាវឱ្យកងរាជអាវុធហត្ថ នៅទូទាំងប្រទេស ចាត់វិធានការទាន់ពេលវេលា ប្រឆាំងនឹងអ្វីដែលលោកបានថ្កោលទោសថា ជា "ចលនាបង្កផលប៉ះពាល់អវិជ្ជមានដល់ស្ថេរភាពសង្គម និងសណ្តាប់ធ្នាប់សង្គម"។[489]

នៅក្នុងសន្និសីទប្រចាំឆ្នាំរបស់កងរាជអាវុធហត្ថ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ លោក សៅ សុខាបានចាត់ទុកសកម្មភាពរបស់កងរាជអាវុធហត្ថក្នុងខែមករា ឆ្នាំ២០១៤ ថាជាទង្វើត្រឹមត្រូវ និងចាំបាច់ដើម្បីដោះស្រាយបញ្ហាបាតុកម្មរបស់ពួកប្រឆាំង។ លោកបានរៀបរាប់ថា ការប្រមូលផ្តុំទាំងនោះគឺជា "ល្បិចរបស់ពួកបំផ្លិចបំផ្លាញ" ដែលមានបំណង "រុញច្រានប្រទេសកម្ពុជាឱ្យធ្លាក់ក្នុងភាពចលាចល" និងបង្កើតការផ្លាស់ប្តូរ

135?token=ZjMyODQwYm (ចូលមើលនៅថ្ងៃទី 26 ខែមករាឆ្នាំ 2014) ។

[487] មេបញ្ជាការនៃកងរាជអាវុធហត្ថ បញ្ជាឱ្យថ្នាក់ដឹកនាំគ្រប់ផ្នែកទាំងអស់ បង្កើនសកម្មភាពដើម្បីការពារសន្តិសុខសង្គម ខណៈពេលដែលគណបក្សប្រឆាំងបានបន្តបង្ហាញការទាមទារ "ថ្ងៃទី 1 ខែមេសាឆ្នាំ 2014 http://edition.bayontv.com.kh/bayontv-national-news/24314-2014-04-01-08-21-41.html (ចូលមើលនៅថ្ងៃទី 1 ខែមេសាឆ្នាំ 2014) ។

[488] "កងរាជអាវុធហត្ថខេត្តស្វាយរៀង អបអរសាទរខួបលើកទី 21 នៃការបង្កើតកងរាជអាវុធហត្ថ" ថ្ងៃទី 21 ខែកក្កដាឆ្នាំ 2014 http://www.dap-news.com/2011-06-14-02- 39-55 / 90923-2014- 07-21-03-16-28.html (ចូលមើលនៅថ្ងៃទី 21 ខែកក្កដាឆ្នាំ 2014)។

[489] "កងរាជអាវុធហត្ថ ប្រជុំបូកសារុបលទ្ធផលការងារនៅក្នុងឆ្នាំចាស់ និងរៀបចំផែនការសម្រាប់ឆ្នាំថ្មី, ថ្ងៃទី31 ខែធ្នូឆ្នាំ 2014, http://www.nokorwatnews.com/detailnews.php?newsid=48669&mnu= 2 & cid = 4 (ចូលមើលនៅថ្ងៃទី 2 ខែមករាឆ្នាំ 2015) ។

នយោបាយ រួមទាំងផ្តួលរលំរដ្ឋាភិបាលរបស់លោក ហ៊ុន សែន។ លោក សៅ សុខា បន្តទៀតថា លោកបានតបតវិញដោយប្រើប្រាស់កលយុទ្ធ ឬយុទ្ធសាស្ត្រដែលឆ្លុះបញ្ចាំងពីមេរៀនបែបអវិជ្ជមានរបស់អាដូល ហ៊ីត្លែរ (Adolf Hitler) និងរៀនពីយុទ្ធសាស្ត្រកងទ័ពព្រៃរបស់ពួកកុម្មុយនិស្តវៀតណាម។ លោកប្រកាសថា "និយាយដោយស្មោះត្រង់ទៅ ខ្ញុំបានរៀនពីហ៊ីត្លែរ" ហើយពន្យល់ទថា វិធីដោះស្រាយដ៏ល្អបំផុតក្នុងការដោះស្រាយជាមួយខ្មាំងសត្រូវ គឺប្រើកងកម្លាំងធំដើម្បីយកឈ្នះកម្លាំងតូចៗ ដែលការលើកឡើងរបស់លោក សៅ សុខា នេះផ្ទុយពីយុទ្ធសាស្ត្រធ្វើសង្គ្រាមរបស់កម្លាំងប្រដាប់អាវុធនៃគណបក្សប្រជាជនកម្ពុជា ដែលបានរៀនសូត្រពីគ្រូវៀតណាម។[490] សុន្ទរកថារបស់លោក សៅ សុខា ឆ្លុះបញ្ចាំងពីក្បួនយុទ្ធសាស្ត្ររបស់កងយោធពលខេមរភូមិន្ទ ផ្អែកតាមលទ្ធិ ឬយុទ្ធសាស្ត្ររបស់អាដូល ហ៊ីត្លែរ(Adolf Hitler) ដែលជាអ្នកបំផ្លាញខ្លួនឯង តាមរយៈការប្រយុទ្ធប្រឆាំងនឹងសត្រូវដ៏ច្រើនអនេកក្នុងពេលតែមួយនៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទី ២។[491]

ស្របពេលគ្នានេះដែរ កងរាជអាវុធហត្ថនៅក្រុងភ្នំពេញ និងនៅតាមខេត្ត បានបន្តបំបែក ឬរាំងខ្ទប់ការជួបជុំដោយសន្តិវិធី ការហែក្បួនបាតុកម្ម និងកូដកម្ម រួមទាំងព្រឹត្តិការណ៍ផ្សេងៗរបស់គណបក្សសង្គ្រោះជាតិ។ ជួនកាលពួកគេប្រើកម្លាំងហួសប្រមាណ និងចូលរួមក្នុងការបណ្តេញចេញដោយហិង្សាជាញឹកញាប់ និងបានគំរាមដល់អ្នកណា ដែលប៉ុនប៉ងបញ្ចេញសកម្មភាព ដែលអាជ្ញាធរចាត់ទុកថា ជាអំពើខុសច្បាប់ ។[492]

---

[490] "ប្រទេសកម្ពុជា ៖ មេបញ្ជាការទទួលស្គាល់ការប្រើកម្លាំងដោយលំអៀង" ចេញផ្សាយនៅថ្ងៃទី 24 ខែមករាឆ្នាំ 2015, https://www.hrw.org/news/2015/01/24/cambodia-commander-admits-partisan-use-force.។

[491] សុវ៉ាត, គោលនយោបាយឈ្នះឈ្នះ, ទំព័រ 330។

[492] "ខណៈសាលាដំបូងកំពុងសវនាការចោទប្រកាន់ក្រុមអ្នកតវ៉ា ហ្វូងអ្នកគាំទ្រវាយតប់គ្នាជាមួយក្រុមប៉ូលីស នៅខាងក្រៅតុលាការ" កាសែតដឹខេមបូឌាដេលី ថ្ងៃទី 4 ខែមករាឆ្នាំ 2014 https://www.cambodiadaily.com/archives/court-charges-protesters-as-supporters-police-scuffle-outside-50079/ (ចូលមើលថ្ងៃទី 6 ខែមករាឆ្នាំ 2014) ។ ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 10 ខែមករាឆ្នាំ 2014 http://www.phnompenhpost.com/national/freedom-park-tune-cut-short (មើលនៅថ្ងៃទី 11 មករា ឆ្នាំ 2014)។ ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 13 ខែមករាឆ្នាំ 2014 http://www.phnompenhpost.com/national/freedom-park-tune-cut-short ) ចូលមើលនៅថ្ងៃទី 14 ខែ មករា ឆ្នាំ 2014) ។ "គណបក្សសង្គ្រោះជាតិលុបចោលកិច្ចប្រជុំ ដោយមានអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជាចូលអុកឡុក៖ ដឹខេមបូឌាដេលី ថ្ងៃទី22 មករា ឆ្នាំ 2014, http://www.cambodiadaily.com/news/cnrp-cancels-meeting-as-cpp- supporters-turn-out-in-force-50938/ (មើលនៅថ្ងៃទី 23 ខែមករាឆ្នាំ 2014); ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 22 ខែមករាឆ្នាំ 2014 http://www.phnompenhpost.com/national/cnrp-meet-halted-amid-intimidation (ចូលមើលនៅថ្ងៃទី 23 ខែមករាឆ្នាំ 2014) ។ "នៅពេលមានការគាំទ្រពីគណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិអំពាវនាវឱ្យមានការជួបជុំគ្នាមួយ" កាសែត ដឹខេមបូឌាដេលីថ្ងៃទី 27 ខែមករាឆ្នាំ 2014 http://www.cambodiadaily.com/news/amid-outpouring-of-cpp-support-cnrp-calls-another-rally -51050 / (ចូលមើលថ្ងៃទី 28 ខែមករាឆ្នាំ 2014); ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 27 ខែមករាឆ្នាំ 2014 http://www.phnompenhpost.com/national/rock-and-hard-place (ចូលមើលថ្ងៃទី 28 ខែមករាឆ្នាំ 2014) ។ "ការជួបប្រជុំរបស់វិទ្យុសំបុកឃ្មុំ ត្រូវបានបំបែកដោយហិង្សា, ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី 27 ខែមករាឆ្នាំ 2014, http://www.phnompenhpost.com/national/beehive-rally-violently- broken (ចូលមើលនៅថ្ងៃទី 28 ខែមករាឆ្នាំ 2014) ។ កាសែតភ្នំពេញប៉ុស្តិ៍ថ្ងៃទី 29 ខែមករាឆ្នាំ 2014 http://www.phnompenhpost.com/national/media-beatings-condemned (ចូលមើលថ្ងៃទី 30 ខែមករាឆ្នាំ 2014) ។ ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 29 ខែមករាឆ្នាំ 2014 "បុរសម្នាក់ត្រូវបានគេចោទប្រកាន់ពីបទបាញ់កាំភ្លើងឱ្យបាញ់កាំភ្លើង", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី 29 ខែមករាឆ្នាំ 2014.

http://www.phnompenhpost.com/national/man-charged-firing-slingshot-protesters (ចូលមើលថ្ងៃទី 30 ខែមករាឆ្នាំ 2014) ។ " Lawmaker's Morning at Park Ended by District Guards," The Cambodia Daily, " ថ្ងៃទី 3 ខែមេសាឆ្នាំ 2014។ http://www.cambodiadaily.com/news/lawmakers-morning-at-park-ended-by-district-guards-55636/ (ចូលមើលនៅថ្ងៃទី 4 ខែមេសាឆ្នាំ 2014) ។ "មន្ត្រីរាជការបានវាយប្រហារនៅពិធីអនុស្សាវរីយ៍ខ្មែរក្រហម" ថ្ងៃទី 18 ខែមេសាឆ្នាំ 2014 http://www.cambodiadaily.com/news/city-official-attacked-at-khmer-rouge-memorial-ceremony-56700/ ( បានចូលដំណើរការនៅថ្ងៃទី 19 ខែមេសាឆ្នាំ 2014) ។ "គណបក្សសង្គ្រោះជាតិរៀបចំការជួបជុំកិលទូទាំងរាជធានី ។ "ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 5 ខែឧសភាឆ្នាំ 2014 http://www.phnompenhpost.com/national/cnrp-holds-citywideroll -rally (ចូលមើលថ្ងៃទី 5 ខែឧសភាឆ្នាំ 2014)។ "កងទ័ពបញ្ឈប់ការជួបជុំរបស់គណបក្សសង្គ្រោះជាតិនៅខេត្តកំពង់ចាម" ដឹខេមបូឌាដេលីថ្ងៃទី 5 ខែឧសភាឆ្នាំ 2014 http://www.cambodiadaily.com/news/military-stops-cnrp-rally-in-k-cham-58012 / (ចូលមើលថ្ងៃទី 6 ខែឧសភា( 2014)។ "វត្តមានរបស់ប៉ូលីស មានក្រុមកូដករនៅម្ខាង" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 8 ខែឧសភាឆ្នាំ 2014 ។ http://www.phnompenhpost.com/national/police-presence-has-strikers-dgege (accessed May 9, 2014) ។ "កសិករត្រូវបានរាំងមិនឲ្យដាក់ញត្តិកាកបាទក្រហម" ខេមបូឌាដេលីថ្ងៃទី 22 ខែឧសភាឆ្នាំ 2014 http://www.cambodiadaily.com/news/farmers-blocked-from- red-cross-59339 / (ចូលមើលនៅថ្ងៃទី 23 ខែឧសភាឆ្នាំ 2014)។ គណបក្សសង្គ្រោះជាតិ ត្រូវបានហាមឃាត់មិនឲ្យចូលសួរសុខទុក្ខអ្នកភូមិនៅខេត្តរតនគិរី ក្នុងវិវាទដីធ្លី "ថ្ងៃទី 28 ខែឧសភាឆ្នាំ 2014, http://www.cambodiadaily.com/news/cnrp-blocked-from-visiting-rkiri-villagers-in-land- dispute- 59791 / (ចូលមើលថ្ងៃទី 29 ខែឧសភាឆ្នាំ 2014) ។ "ព្រះសង្ឃតវ៉ាប្រឆាំងនឹងវិទ្យាស្ថាន" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 30 ខែឧសភាឆ្នាំ 2014 http://www.phnompenhpost.com/national/monks-protest-over-institute (ចូលមើលថ្ងៃទី ១ ខែឧសភា ឆ្នាំ 2014)។ "កងរាជអាវុធហត្ថ បាំងផ្លូវបញ្ឈប់ព្រះសង្ឃពីការហែរក្បួន" ខេមបូឌាដេលីថ្ងៃទី 30 ខែឧសភាឆ្នាំ 2014, http://www.cambodiadaily.com/news/military-police- barricade-road-to-stop-monks-from-marching-60022/ (ចូលមើលនៅថ្ងៃទី 1 ខែមិថុនាឆ្នាំ 2014); "អ្នកភូមិដែលត្រូវបានរាំងមិនឱ្យដាក់ពាក្យបណ្តឹង" ខេមបូឌាដេលីថ្ងៃទី 10 ខែមិថុនាឆ្នាំ 2014, http://www.cambodiadaily.com/news/villages-blocked-from-delivering- complaint-60883 / (ចូលមើលថ្ងៃទី 11 ខែមិថុនាឆ្នាំ 2014)។ "ការហែក្បួនត្រូវបានគេរាំង ខណៈពេលការតវ៉ាពីសំណាក់រោងចក្រនៅតែបន្ត "ថ្ងៃទី 13 ខែមិថុនាឆ្នាំ 2014, http://www.cambodiadaily.com/news/march-blocked-as-factory-protest-continues-61333/ (ចូលមើលនៅថ្ងៃទី 14 ខែមិថុនាឆ្នាំ 2014)។ "បុរសម្នាក់ត្រូវបានគេចាប់ខ្លួន និងការបាញ់នៅលើវិវាទដីធ្លី នៅថ្ងៃទី 4 ខែកក្កដាឆ្នាំ 2014, http://www.cambodiadaily.com/news/man- arrested-shots-fired-at-land-dispute-protest-63224/ (ចូលមើលថ្ងៃទី 5 ខែកក្កដាឆ្នាំ 2014)។ "ការប៉ះទង្គិចគ្នានៅស្ថានទូតវៀតណាម" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 9 ខែកក្កដាឆ្នាំ 2014 http://www.phnompenhpost.com/national/clash-vietnam-embassy; ដឹខេមបូឌាដេលីថ្ងៃទី 6 ខែសីហាឆ្នាំ 2014 http://www.cambodiadaily.com/news/police-block-villagers-march-to-hun- sense-house-65804 / (ចូលមើលថ្ងៃទី 7 ខែសីហាឆ្នាំ 2014) ។ "ក្រុមអ្នកដើរក្បួនសន្តិភាពបានវាយដំ", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី 13 ខែសីហាឆ្នាំ 2014, http://www.phnompenhpost.com/national/peaceful-marchers-beaten (ចូលមើលថ្ងៃទី14 ខែសីហា ឆ្នាំ2014)។ "ការចាប់ខ្លួនអ្នកភូមិ ដែលមានជម្លោះជាមួយក្រុមហ៊ុនខេឌីស៊ី (KDC) ក្នុងពេលថ្មីៗ (Fresh Arrest For Embattled KDC Villagers) "ដឹខេមបូឌាដេលី "ការចាប់ខ្លួនអ្នកភូមិ ដែលមានជម្លោះជាមួយក្រុមហ៊ុនខេឌីស៊ី (KDC) ក្នុងពេលថ្មីៗ (ថ្ងៃទី 13 ខែសីហា ឆ្នាំ 2014) http://www.cambodiadaily.com/news/fresh-arrests-for-embattled-kdc-villagers-66343/ (ចូលមើលថ្ងៃទី 14 ខែសីហាឆ្នាំ 2014); "សាលាក្រុងបិទការជិះទោចក្រយានយន្តប្រឆាំងនឹងគម្រោងវារីអគ្គិសនី", ដឹខេមបូឌាដេលីថ្ងៃទី 18 ខែសីហាឆ្នាំ 2014 http://www.cambodiadaily.com/news/city- hall-blocks-bike-ride-against-koh-kong-hydro-project-66695/ (ចូលមើលថ្ងៃទី 19 ខែសីហាឆ្នាំ 2014) ។ "មន្ត្រីទទួលបន្ទុកជំនួញបានស្តីបន្ទោសលើទំនាស់ដីធ្លីនៅខេត្តក្រចេះ" ថ្ងៃទី 19 ខែសីហាឆ្នាំ 2014 http://www.cambodiadaily.com/news/officials-trade-blame-over-kratie- land dispute- 66774 / (ចូលមើលថ្ងៃទី 20 ខែសីហាឆ្នាំ 2014) "ការប៉ះទង្គិចគ្នានៅឯការតវ៉ានៅកោះ SEZ, ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី 4 ខែវិច្ឆិកាឆ្នាំ 2014, http://www.phnompenhpost.com/national/clash-koh-kong-sez-protest (ចូលមើលនៅថ្ងៃទី 5 ខែវិច្ឆិកាឆ្នាំ 2014) ។ "ព្រះសង្ឃពីរអង្គត្រូវបានចាប់ខ្លួនពីបទដឹកជញ្ជូនទង់ជាតិ" ដឹខេមបូឌាដេលីថ្ងៃទី 13 ខែវិច្ឆិកាឆ្នាំ 2014 http://www.cambodiadaily.com/news/two-monks-arrested- defrocked for transport-flag-72224 / (ចូលមើលនៅថ្ងៃទី ១៤ ខែវិច្ឆិកាឆ្នាំ២០១៤) ។ "ប៉ូលីសរាំងខ្ទប់ការហែរក្បួនសិទ្ធិមនុស្សនៅខេត្តតាកែវ" ថ្ងៃទី 6 ខែធ្នូឆ្នាំ 2014 https://www.cambodiadaily.com/news/police-block-human-rights-march-in-takeo- 73733 / (ចូលមើលនៅថ្ងៃទី 7 ខែធ្នូ , 2014)។ "បន្ទាប់ពីការចាប់ខ្លួន ការភ័យខ្លាចបន្សល់តែវត្តអារាម" ខេមបូឌាដេលីថ្ងៃទី 15 ខែវិច្ឆិកាឆ្នាំ 2104, http://www.cambodiadaily.com/news/after-arrests-fear-permeates-outcast-pagoda-72385/ (ចូលមើលថ្ងៃទី 16 ខែវិច្ឆិកាឆ្នាំ 2014) ។ "អ្នកភូមិដែលមានជម្លោះដីធ្លី បានបោះបង់ការដើរ 300 គីឡូម៉ែត្រមករាជធានីភ្នំពេញ " ថ្ងៃទី 2 ខែធ្នូឆ្នាំ 2014 https://www.cambodiadaily.com/news/land-dispute-villagers-call-off-300-km-march- ទៅ -phnom-penh-73401/; http://vodhotnews.com/26409 (ចូលមើលថ្ងៃទី 3 ខែមករាឆ្នាំ 2015)។ "អ្នកភូមិ

*នៅឆ្នាំ២០១៥ និងឆ្នាំ ២០១៦ លោក សៅ សុខាបានបន្តចូលរួមនៅក្នុងការពង្រឹងមូលដ្ឋានរបស់គណបក្សប្រជាជនកម្ពុជា ហើយក៏ដើរតួយ៉ាងចំហជាអ្នកលើកដំកើងគណបក្សប្រជាជនកម្ពុជា និងគាំទ្រការគ្រប់គ្រងរបស់លោក ហ៊ុន សែន។ លោក សៅ សុខា ធ្វើបទបង្ហាញថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាមេដឹកនាំដ៏អស្ចារ្យបំផុតរបស់កម្ពុជា ចាប់តាំងពីសម័យអង្គរដ៏រុងរឿងរបស់ព្រះរាជាណាចក្រ និងបានលើកឡើងថាការផ្លាស់ប្តូរលោក ហ៊ុន សែន ចេញនឹងនាំឲ្យមានការវិលមកវិញនូវអំពើប្រល័យពូជសាសន៍ ប៉ុល ពតម្តងទៀត។[493] ការប្រកាសរបស់លោក សៅ សុខានេះ មិនត្រឹមតែឆ្លុះបញ្ចាំងពីសមាជិកភាពរបស់គណៈកម្មាធិ*

ពីរនាក់ត្រូវបានឃុំខ្លួនក្នុងអំឡុងពេលធ្វើការតវ៉ាបិទផ្លូវនៅខេត្តសៀមរាប" ថ្ងៃទី 6 ខែមករាឆ្នាំ 2015 https://www.cambodiadaily.com/news/two-villagers-detained-during-roadblock- protest-in-siem-reap- 75395 / (ចូលមើលថ្ងៃទី 7 ខែមករាឆ្នាំ 2015)។ "ការចាប់ខ្លួនសកម្មជននៅខេត្តព្រះវិហារ" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 15 ខែមករាឆ្នាំ 2015 http://www.phnompenhpost.com/national/activist-arrest-preah-vihear (ចូលមើលថ្ងៃទី 16 ខែមករាឆ្នាំ 2015)។ "ផ្ទះជាច្រើនត្រូវបានបំផ្លាញក្នុងជម្លោះ" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 31 ខែមករាឆ្នាំ 2014 http://www.phnompenhpost.com/national/more-houses-razed- ជម្លោះ (ចូលមើលថ្ងៃទី 1 ខែកុម្ភៈឆ្នាំ 2014) ។ "អាជ្ញាធរដុតផ្ទះ 60 ខ្នងនៅខេត្តពោធិ៍សាត់ "ខេមបូឌាដេលីថ្ងៃទី 13 ខែកុម្ភៈឆ្នាំ 2014 http://www.cambodiadaily.com/news/authorities-burn-60-homes-in-pursat-province-52093/ (ចូលមើលថ្ងៃទី 14 ខែកុម្ភៈឆ្នាំ 2014) , 2014); "អ្នកកាន់កាប់បុរីកីឡា បានដកចេញដោយអហិង្សា" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 14 ខែកុម្ភៈឆ្នាំ 2014 http://www.phnompenhpost.com/national/borei-keila-occupiers -violently-remove (ចូលមើលថ្ងៃទី 15 ខែកុម្ភៈឆ្នាំ 2014) ។ "អ្នកភូមិនៅខេត្តក្រចេះបិទផ្លូវ បន្ទាប់ពីអាជ្ញាធរដុតផ្ទះ" ថ្ងៃទី 14 ខែកុម្ភៈឆ្នាំ 2014, http://www.cambodiadaily.com/news/kratie-villagers-block-road-after-officials-torch-homes-52232/ ( ចូលមើលថ្ងៃទី 15 ខែកុម្ភៈឆ្នាំ 2014) ។ "ប៉ូលីសបានកម្ទេចផ្ទះសម្បែងនៅខេត្តក្រចេះជាលើកទី 2" ខេមបូឌាដេលីថ្ងៃទី 27 ខែកុម្ភៈឆ្នាំ 2014, http://www.cambodiadaily.com/news/police-demolish-shelters-of-kratie-families-for-second-time- 53291 / (ចូលមើលថ្ងៃទី 28 ខែកុម្ភៈឆ្នាំ 2014); "ប្រជាពលរដ្ឋប្តឹងអភិបាលខេត្តប៉ៃលិន" ថ្ងៃទី 4 ខែមីនាឆ្នាំ 2014 http://www.cambodiadaily.com/news/families-file-complaint-over-pailin-governor-53443/ (ចូលមើលថ្ងៃទី 5 ខែមីនាឆ្នាំ 2014)។ "អ្នកភូមិត្រូវបានចោទប្រកាន់ពីបទឈូសឆាយដីខុសច្បាប់" ខេមបូឌាដេលីថ្ងៃទី 11 ខែមីនាឆ្នាំ 2014 http://www.cambodiadaily.com/news/villagers-charged-with-illegally-clearing-land-53859/ (ចូលមើលនៅថ្ងៃទី 12 ខែមីនាឆ្នាំ 2014) ; "អាជ្ញាធរនៅខេត្តមណ្ឌលគិរីដុតលំនៅដ្ឋាន ដែលខុសច្បាប់", ខេមបូឌាដេលី ថ្ងៃទី 17 ខែមីនាឆ្នាំ 2014, http://www.cambodiadaily.com/news/mondolkiri-authorities-torch-illegal-dwellings-54292/ (ចូលមើលនៅថ្ងៃទី 18 ខែមីនាឆ្នាំ 2014) ។ "គ្រួសារសុំឱ្យហ៊ុនសែនជួយយកកសិដ្ឋានមកវិញ "ខេមបូឌាដេលីថ្ងៃទី 6 ខែឧសភាឆ្នាំ 2014, http://www.cambodiadaily.com/news/families-ask-hun-sen-for-help-to-reclaim-farms- 58137 / (ចូលមើលនៅថ្ងៃទី 7 ខែឧសភាឆ្នាំ 2014) ។ "ផ្ទះរតនគិរីត្រូវបានគេដុតបំផ្លាញពេលអាជ្ញាធរចូលមក" ខេមបូឌាដេលីថ្ងៃទី 22 ខែឧសភាឆ្នាំ 2014 http://www.cambodiadaily.com/news/ratanakkiri-homes-razed-as-authorities-move-in-59341/ (ចូលមើលថ្ងៃទី 23 ខែឧសភា( 2014)។ ខេមបូឌាដេលីថ្ងៃទី 3 ខែវិច្ឆិកាឆ្នាំ 2014 ៖ "អ្នកភូមិបិទផ្លូវហាយវេ បន្ទាប់ប៉ូលីសដុតផ្ទះ", ថ្ងៃទី 3 ខែវិច្ឆិកាឆ្នាំ 2014, http://www.cambodiadaily.com/news/villagers-block-highway-after-police-raze-homes-71632/ (បានចូលមើលនៅថ្ងៃទី 4 ខែវិច្ឆិកា 2014); "អាជ្ញាធរ និងសហគមន៍អន្ទះអន្ទែងនៅពេលការកំណត់ពេលបណ្តេញចេញជិតមកដល់" ថ្ងៃទី 11 ខែវិច្ឆិកាឆ្នាំ 2014, http://www.cambodiadaily.com/news/authorities-community-dig-in-as-eviction-deadline-nears-72025/ (ចូលមើលនៅថ្ងៃទី 12 ខែវិច្ឆិកាឆ្នាំ 2014) ។ "អាជ្ញាធរខេត្តពោធិ៍សាត់ចាប់ខ្លួនស្ត្រី ដុតលំនៅដ្ឋាន" ថ្ងៃទី 24 ខែវិច្ឆិកាឆ្នាំ 2014 http://www.cambodiadaily.com/news/pursat-authorities-arrest-woman-raze-homes-72888/ (ចូលមើលថ្ងៃទី 25 ខែវិច្ឆិកាឆ្នាំ 2014 )។ "ប៉ូលីសបានបាញ់ទៅលើអ្នកយកព័ត៌មាន", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី 10 ខែមីនាឆ្នាំ 2014, http://www.phnompenhpost.com/national/police-%E2%80%98fired-reporters%E2%80%99 (ចូលមើលថ្ងៃទី 11 ខែមីនាឆ្នាំ 2014) ។ "ការប្រើអំពើហិង្សារបស់រដ្ឋាភិបាលប្រឆាំងនឹងអ្នកយកព័ត៌មានត្រូវបានថ្កោលទោស", ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី 21 ខែមេសាឆ្នាំ 2014, http://www.phnompenhpost.com/national/state-violence-against-reporters-condemned (ចូលមើលថ្ងៃទី 22 ខែមេសាឆ្នាំ 2014) ។

[493] "លោក សៅ សុខា ប្រធានក្រុមការងារចុះជួយស្រុករមាសហែក ដោយអញ្ជើញឯកឧត្តមលោកជំទាវលោកលោកស្រីអញ្ជើញចូលរួមជាអធិបតីក្នុងពិធីពិនិត្យមើលលទ្ធផលនៃសកម្មភាពការងារ "ថ្ងៃទី 30 ខែសីហាឆ្នាំ 2015។

ការកណ្ដាលរបស់គណបក្សប្រជាជនកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចុះបញ្ជាំងនៅក្នុងការតែងតាំងថ្មីរបស់គាត់កាលពីខែកញ្ញា ឆ្នាំ២០១៥ទៅក្នុងគណៈកម្មាធិការមជ្ឈឹមទទួលបន្ទុកផែនការឃោសនា និងអប់រំ ដែលជាអង្គការចាត់តាំងមានភារកិច្ចពិសេសក្នុងការជួយឱ្យគណបក្សប្រជាជនកម្ពុជាយកឈ្នះគណបក្សសង្គ្រោះជាតិក្នុងការបោះឆ្នោតនាពេលខាងមុខៗ[494]

នៅចុងឆ្នាំ២០១៦ លោក សៅ សុខា បានបញ្ជាឱ្យមានការបណ្ដុះបណ្ដាលថ្មីមួយទៅលើកងរាជអាវុធហត្ថជាតិ និងរាជអាវុធហត្ថដទៃទៀត ដែលមានកងរាជអាវុធហត្ថនៅទីក្រុងភ្នំពេញចូលរួមផង នូវរបៀបដោះស្រាយជាមួយក្រុមដែលគេចាត់ទុកថា គំរាមកំហែងដល់ "សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ"ៗ នេះរួមបញ្ចូលការអនុវត្តហ្វឹកហ្វឺនប្រើអាវុធទៅលើបាតុករ និងការប្រើប្រាស់កាំភ្លើងបាញ់ប្រឆាំងនឹងពួកគេផងដែរៗ[495] កងរាជអាវុធហត្ថនៅគ្រានេះ ក៏បានទទួលរថពាសដែកផងដែរ ដែលអ្នកនាំពាក្យរបស់លោក សៅ សុខា បានបញ្ជាក់ថា អាចនឹងយកទៅត្រូវប្រើក្នុងប្រតិបត្តិការរក្សា "សណ្ដាប់ធ្នាប់សាធារណៈ និងដើម្បីការពារសន្តិសុខ"ៗ[496] ក្នុងរយៈពេលនេះលោក សៅ សុខា បានអំពាវនាវឱ្យមន្ត្រីកងរាជអាហត្ថបោះឆ្នោតឲ្យបាន "ត្រឹមត្រូវ" នៅក្នុងការបោះឆ្នោតនាពេលខាងមុខ ជាការដាស់តឿនដែលអ្នកនាំពាក្យរបស់លោកបានបញ្ជាក់អះអាងថា គឺសំដៅបោះឆ្នោតឱ្យនាយករដ្ឋមន្ត្រី ដែលបានដឹកនាំយើងឱ្យល្អ នោះគឺនាយករដ្ឋមន្ត្រីហ៊ុន សែន ដែលបានដឹកនាំប្រទេសឱ្យមានការអភិវឌ្ឍនៅថ្ងៃនេះៗ[497] ទន្ទឹមនឹងនោះ លោក សៅ សុខា បានត្រួតពិនិត្យសកម្មភាពរៀបចំចាត់ចែង និងឃោសនារបស់មន្ត្រីគណបក្សប្រជាជនកម្ពុជានៅក្នុងតំបន់ខ្លះនៃខេត្តស្វាយរៀងដែលជាស្រុកកំណើតរបស់គាត់ៗ[498]

---

[494] "លោកឧត្តមសេនីយ៍សៅ សុខា អញ្ជើញជាអធិបតីប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី 37 នៃទិវាជ័យជម្នះ 7 មករា។ ថ្ងៃ 7 មករា 2016 ។ http://kampucheathmey.com/kpt/?p=139561 (ចូលមើលថ្ងៃទី 7 ខែមករាឆ្នាំ 2016) ។ លោកឧត្តមសេនីយ៍សៅសុខា ប្រារព្ធពិធីអបអរសាទរខួបលើកទី 65 នៃការបង្កើតគណបក្សប្រជាជនកម្ពុជា ថ្ងៃទី 26 ខែមិថុនាឆ្នាំ 2016 http://www.freshnewsasia.com/index.php/en/27463-2016-06-26-01 -47-25.html (ចូលមើលថ្ងៃទី 26 ខែមិថុនាឆ្នាំ 2016) ។

[495] គណបក្សប្រជាជនកម្ពុជា តែងតាំងផ្កាយទាំងអស់ក្នុងជួរគណៈកម្មាធិការឃោសនាថ្មីរបស់ខ្លួន" ខេមបូឌាដេលីថ្ងៃទី 4 ខែកញ្ញាឆ្នាំ 2015 https://www.cambodiadaily.com/news/cpp-names-all-star-lineup-on-its-new -propaganda-committee-93376 / (ចូលមើលថ្ងៃទី 5 ខែកញ្ញាឆ្នាំ 2015); "ឧត្តមសេនីយ៍សៅសុខា អញ្ជើញគោរពវិញ្ញាណខ័ន្ធនៃអ្នកដែលបានស្លាប់ក្នុងសម័យប៉ុលពត នៅស្រុកមោសហែក" ថ្ងៃទី 20 ឧសភា 2016 http://www.freshnewsasia.com/index.php/en/24610-2016-05 -20-02-41-51.html (ចូលមើលនៅថ្ងៃទី 20 ខែឧសភាឆ្នាំ 2016) ។ "Training Photo Raising Eyebrows "ភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី 13 ខែធ្នូឆ្នាំ 2016 http://www.phnompenhpost.com/national/training-photos-raising-eyrerows (ចូលមើលថ្ងៃទី 14 ខែធ្នូឆ្នាំ 2016) ។

[496] "ក្បាលម៉ាស៊ីននគរបាលយោធា "ភ្នំពេញប៉ុស្ដិ៍ថ្ងៃទី 12 ខែមករាឆ្នាំ 2017 http://www.phnompenhpost.com/national/military- police-machines) ចូលមើលថ្ងៃទី 13 ខែមករាឆ្នាំ 2017) ។

[4]97 កងរាជអាវុធហត្ថប្រាប់ថា "ត្រូវប្រើសំឡេងឆ្នោតឲ្យត្រឹមត្រូវ ។ "ភ្នំពេញប៉ុស្ដិ៍ថ្ងៃទី 15 ខែធ្នូឆ្នាំ 2016 http://www.phnompenhpost.com/national/use-vote-correctly-military-police-told (ចូលមើលនៅថ្ងៃទី 16 ខែធ្នូឆ្នាំ 2016 ។

*លោក សៅ សុខាបានគាំទ្រដោយគ្មានអល់ឯកចំពោះការបំផ្លាញចោលទាំងស្រុងនូវគណបក្សសង្គ្រោះជាតិ ដែលបានចាប់ផ្តើមដោយការចាប់ឃុំខ្លួនមេដឹកនាំគណបក្សនេះ គឺលោក កឹម សុខា នៅថ្ងៃទី៣ ខែកញ្ញាឆ្នាំ ២០១៧ និងបន្តរហូតមកដល់បច្ចុប្បន្ន ដោយប្រើលេសក្លែងក្លាយចោទគណបក្សសង្គ្រោះជាតិថា បានប៉ុនប៉ងប្រព្រឹត្តអំពើក្បត់ជាតិតាមរយៈធ្វើបដិវត្តពណ៌។ ភ្លាមៗនោះ លោក សៅ សុខាបានប្រកាសគាំទ្រការឃុំឃាំងលោក កឹម សុខា។[499] នៅក្នុងវគ្គបណ្តុះបណ្តាលមួយសម្រាប់មន្ត្រីកងរាជអាវុធហត្ថ នៅថ្ងៃទី ៥ ខែតុលា ឆ្នាំ ២០១៧ លោក សៅ សុខាបានថ្លែងទៅកាន់សិក្ខាកាមថា ពួកគេត្រូវធ្វើតាមការបញ្ជា គឺ "យ៉ាងពិសេស និងដាច់ខាតមិនត្រូវឱ្យមានបដិវត្តពណ៌ឡើយ" ហើយត្រូវតែការពាររដ្ឋាភិបាលដែលដឹកនាំដោយលោក ហ៊ុន សែន។[500] នៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ មិនយូរប៉ុន្មានក្រោយពីធ្វើជាអធិបតីកិច្ចប្រជុំរបស់សមាជិកគណបក្សប្រជាជនកម្ពុជា នៅក្នុងខេត្តស្វាយរៀង លោក សៅ សុខាបានប្រកាសគាំទ្រយ៉ាងពេញទំហឹង និងថា គ្រប់កងរាជអាវុធហត្ថទាំងអស់ត្រូវគាំទ្រសាលដីការបស់តុលាការកំពូល ដែលបានសម្រេចរំលាយគណបក្សសង្គ្រោះជាតិ ដោយសារ "អំពើក្បត់ជាតិ" និងគាំទ្រការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យមានវិធានការបង្ការជាមុនបន្ថែមទៀត ប្រឆាំងនឹងគម្រោងការណ៍បដិវត្តពណ៌ និងអ្នកនយោបាយ "ដែលបម្រើផលប្រយោជន៍បរទេស"។[501] នៅថ្ងៃទី ៦ ខែធ្នូ ឆ្នាំ២០១៧ លោក សៅ សុខា បានប្រកាសថា លោក សម រង្ស៊ី ដែលកំពុងនិរទេសខ្លួននៅក្រៅប្រទេស គឺជាជនក្បត់ជាតិ ហើយក៏បានប្រកាសទៀតថា កងរាជអាវុធហត្ថ "ស្មោះត្រង់ដាច់ខាត" ចំពោះលោក ហ៊ុន សែន។[502]*

[499] "លោក សៅ សុខា មានសេចក្តីសោមនស្សរីករាយក្នុងពិធីសន្និបាតបូកសារុបលទ្ធផលនៃការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សប្រជាជន នៅក្នុងឃុំម្រាម "ថ្ងៃទី 24 ខែធ្នូឆ្នាំ 2016 http://www.freshnewsasia.com/index.php/en/localnews/42529 -2016-12-24-11-20-59.html (ចូលមើលថ្ងៃទី 24 ខែធ្នូឆ្នាំ 2016); ភ្នំពេញប៉ុស្តិ៍ថ្ងៃទី 27 ខែធ្នូឆ្នាំ 2016 http://www.phnompenhpost.com/national/sokha- ទាហាន-upward-cpp (ចូលមើលថ្ងៃទី 28 ខែធ្នូឆ្នាំ 2016)។ "លោកសៅសុខាធ្វើពិធីបុណ្យខួបលើកទី 38 នៃទិវាជ័យជំនះ 7 មករា នៅស្រុករមាសហែក ថ្ងៃទី៧ ខែមករា 2017 http://www.freshnewsasia.com/index.php/en/localnews/43743-2017- 01-07-03- 43-19.html (ចូលមើលថ្ងៃទី 7 ខែមករាឆ្នាំ 2017)។ "លោកសៅសុខាចូលរួមយ៉ាងរីករាយក្នុងពិធីសម្ពោធសាងសង់បង្គោលថ្ម និងសាងសង់សាលមួយ ដែលចំណាយថវិកាចំនួន 110,000 ដុល្លារ" ថ្ងៃទី 14 ខែមករាឆ្នាំ 2017 http://www.freshnewsasia.com/index.php/en/localnews/44410- 2017-01-14-03-53-40.html (ចូលមើលនៅថ្ងៃទី 14 ខែមករាឆ្នាំ 2017) ។

[500] នាយឧត្តមសេនីយ៍សៅសុខា អញ្ជើញបិទសិក្ខាម ដែលសិក្សាវគ្គបំប៉ននៅសាលាកំបូល, កងកម្លាំងត្រូវអនុវត្តម៉ឺងម៉ាត់នូវបទបញ្ជា និងដាច់ខាតត្រូវការពាររាជរដ្ឋាភិបាលដឹកនាំដោយសម្តេចតេជោហ៊ុនសែន។

[501] លោកសៅសុខា អញ្ជើញជាអធិបតីក្នុងពិធីត្រួតពិនិត្យលទ្ធផលការងារគណបក្សប្រជាជនកម្ពុជា ស្រុករមាសហែក។ នាយឧត្តមសេនីយ៍សៅសុខា ប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះតុលាការកំពូល កាត់រំលាយគណបក្សសង្គ្រោះជាតិ។ ឧត្តមសេនីយ៍ឯករ័ត្នស្រ៊ាង ប្រកាសគាំទ្រពេញទំហឹងចំពោះតុលាការកំពូល សំរេចរំលាយគណបក្សសង្គ្រោះជាតិ និងគាំទ្រអនុសាសន៍ទាំងស្រុងរបស់សម្តេចតេជោហ៊ុនសែន។

[502] នាយឧត្តមសេនីយ៍សៅសុខា ប្រកាសថ្កោលទោសសម្តីញុះញង់របស់ទណ្ឌិត សមរង្ស៊ី និងអាវុធហត្ថទូទាំងប្រទេស ត្រៀមរួចជាស្រេចការពារសន្តិភាពជូនរាជរដ្ឋាភិបាល និងប្រជាជន។

# IV. នាយឧត្តមសេនីយ៍ផ្កាយមាស ៤ នេត សាវឿន អគ្គស្នងការនគរបាលជាតិ

## *លោក នេត សាវឿន នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា ឆ្នាំ ១៩៧៩-១៩៩១*

*ថ្ងៃខែឆ្នាំកំណើតផ្លូវការរបស់លោក នេត សាវឿន គឺថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ១៩៦០។*[503] *គាត់គឺជាសមាជិកដំបូងម្នាក់ ក្នុងចំណោមសមាជិកដំបូងបំផុតផ្សេងទៀត នៃកងកម្លាំងនគរបាលប្រជាជន ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង បានក្លាយជាមន្ត្រីសួរចម្លើយជាន់ខ្ពស់ម្នាក់ ជាមួយនគរបាលរាជធានីភ្នំពេញ។*[504] *គាត់បានឡើងតំណែងយ៉ាងឆាប់រហ័ស នៅក្នុងជួរនគរបាល ដោយបានក្លាយជាប្រធានការិយាល័យរដ្ឋបាលនៃនគរបាលក្រុង បន្ទាប់មក ក្លាយជាប្រធានការិយាល័យព្រហ្មទណ្ឌនៃនគរបាលក្រុង។*[505] *ត្រឹមឆ្នាំ ១៩៨៣ គាត់ជាអនុប្រធានទីមួយនៃនគរបាលរាជធានី។*[506] *ក្នុងអំឡុងពេលនោះ នគរបាលក្រុង កំពុងពាក់ព័ន្ធនឹងការចាប់ខ្លួនមនុស្សជាច្រើនតាមទំនើងចិត្ត ក្រោមហេតុផលនយោបាយ និងហេតុផលផ្សេងទៀត។*[507]

*ក្នុងឆ្នាំ១៩៨៤ អតីតនគរបាលម្នាក់ដែលជាអ្នកធ្វើការជាមួយលោក នេត សាវឿន បានពន្យល់អំពីការដំឡើងតំណែងនេះថា៖ "លោក នេត សាវឿន នៃនគរបាលក្រុងភ្នំពេញ បានក្លាយជាមនុស្សដ៏មានឥទ្ធិពល ដោយសារគាត់មានភាពឃោរឃៅខ្លាំងក្នុងការសួរចម្លើយ។ គាត់ថែមទាំងធ្លាប់បាញ់មនុស្សនៅក្នុងពេលសួរ*

---

503 "ការរក្សាភាពស្មោះត្រង់" ***ខេមបូឌា ដេលី*** ថ្ងៃទី១៧-១៨ ខែមករា ឆ្នាំ២០០៩ Peter Bartu "របាយការណ៍៖ ស្ថានភាពនយោបាយនៅកម្ពុជា" ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៩ Bertil Lintner "គ្រូសាររីករាយដ៏ធំមួយនៅកម្ពុជា" **Asia Times Online** ថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៧ http://www.atimes.com/atimes/Southeast_Asia/IC20Ae03.html (ចូលមើល នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨)។

504 មានអត្តលេខ ០០៦៦។ សូមមើលរាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ នស១២៣៩/១១០៨/រកត/ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៨, អង្គការ លើកលែងទោស អន្តរជាតិ "Amnesty International" មានកំណត់ត្រា ដាក់ចំណងជើងថា "ការចងក្រងទិន្នន័យស្ដីពី បុគ្គលិកពន្ធនាគារ/មណ្ឌលកែប្រែ និងអង្គភាព ឬ ស្ថាប័ន ដែលមានសិទ្ធិអនុវត្តការចាប់ខ្លួន និង សួរចម្លើយ" ខែមិថុនា ឆ្នាំ១៩៨៦ ដែលត្រូវរៀបចំសម្រាប់អង្គការ Amnesty International ***ការដាក់ពន្ធនាគារ ក្រោមហេតុផលនយោបាយ។***

505 ការសម្ភាសន៍ជាមួយអតីតនគរបាលម្នាក់, ទីក្រុងប៉ារីស ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៩ LCIHR មានកំណត់ត្រា ដាក់ចំណងជើងថា "អត្ថបទដកស្រង់ស្ដីពីសាធារណរដ្ឋប្រជាមានិតកម្ពុជា" ខែវិច្ឆិកា ឆ្នាំ១៩៨៤ ដែលត្រូវរៀបចំចងក្រងសម្រាប់ LCIHR ***បន្ទាប់ពីមានស្ថានភាពអាក្រក់បំផុត។***

506 វិទ្យុភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៨៣ LCIHR មានកំណត់ត្រា ស្ដីពី ការសម្ភាសន៍ជាមួយអតីតមន្ត្រីនគរបាលក្រុងភ្នំពេញ ព្រំដែនថៃ-កម្ពុជា ខែតុលា ឆ្នាំ១៩៨៤ អង្គការ Amnesty International មានកំណត់ត្រា ដាក់ចំណងជើងថា "ការចងក្រងទិន្នន័យ ស្ដីពី បុគ្គលិកពន្ធនាគារ/មណ្ឌលកែប្រែ និងអង្គភាព ឬ ស្ថាប័ន ដែលមានសិទ្ធិអនុវត្តការចាប់ខ្លួន និង សួរចម្លើយ" ខែមិថុនា ឆ្នាំ១៩៨៦ ដែលត្រូវរៀបចំចងក្រងសម្រាប់អង្គការ Amnesty International ***ការដាក់ពន្ធនាគារ ក្រោមហេតុផលនយោបាយ។***

507 LCIHR មានកំណត់ត្រា ដាក់ចំណងជើងថា "ចំនួនទណ្ឌិត" ខែវិច្ឆិកា ឆ្នាំ១៩៨៤ ដែលត្រូវរៀបចំចងក្រងសម្រាប់ LCIHR ***បន្ទាប់ពីមានស្ថានភាពអាក្រក់បំផុត។***

*ចម្លើយទៀតផង។ កាលពីមុន គាត់គ្រាន់តែជាប្រធានផ្នែកព្រហ្មទណ្ឌប៉ុណ្ណោះ ប៉ុន្តែដោយសារគាត់គឺជាមនុស្សសាហាវ គាត់បានទទួលការដំឡើងឋានៈជាបន្តបន្ទាប់ ហើយនៅពេលនេះ គាត់គឺជាស្នងការរងទីមួយ។ បច្ចុប្បន្ននេះ គាត់ជាអ្នកសួរចម្លើយក្នុងករណីសំខាន់ៗបំផុត មិនត្រឹមតែករណីព្រហ្មទណ្ឌទេ ប៉ុន្តែថែមទាំងករណីនយោបាយផងដែរ។ ពេលខ្លះ នៅពេលដែលគាត់អផ្សុក គាត់ក៏ហៅនរណាម្នាក់មកវាយដំលេង ដើម្បីជាការកម្សាន្ត។ គ្មាននរណាម្នាក់ហ៊ានតវ៉ានឹងសកម្មភាពរបស់គាត់ឡើយ ដោយសារគ្រប់គ្នាខ្លាចគាត់ និងខ្លាចអំណាចរបស់គាត់។"*[508]

*នៅពេលលោកកំពុងទទួលបន្ទុកការិយាល័យព្រហ្មទណ្ឌនៃនគរបាលរាជធានីភ្នំពេញ ជាទូទៅ លោក នេត សាវឿន ចាត់ចែងការធ្វើទារុណកម្មលើជនជាប់ឃុំដែលត្រូវបានចាប់ខ្លួនតាមទំនើងចិត្ត ដោយគ្មានការជំនុំជម្រះនៅក្នុងពន្ធនាគារក្រុង "ប៉េ.ហ្ស៊ី"* ("P.J.") (P.J. *គឺអក្សរកាត់នៃពាក្យ* "police judiciaire" *ប្រែថា* "***នគរបាលយុត្តិធម៌***" *ដែលជាមុខងារដើមរបស់គុកនេះ នៅមុនឆ្នាំ១៩៧៥)។ នៅក្នុងអំឡុងពេលដំបូងនៃរបបនេះ ជនជាប់ឃុំមួយចំនួន ក្នុងចំណោមជនជាប់ឃុំទាំងនេះ ត្រូវបានបញ្ជូនទៅប្រហារជីវិតដោយគ្មានការជំនុំជម្រះ ដោយសារពួកគេត្រូវបានគេចាត់ទុកថា ក្បាលរឹងក្នុងពេលសួរចម្លើយ។*[509] *អ្នកជាប់ឃុំមួយចំនួនបានស្លាប់នៅក្នុងមន្ទីរឃុំឃាំង និងត្រូវកប់នៅបរិវេណខាងក្រោយគុក* P.J*។*[510] *លោក នេត សាវឿន ក៏ត្រូវបានចោទប្រកាន់ដែរថា ក្រោមការដឹកនាំរបស់លោក នគរបាលនៅក្នុងរាជធានី មានជាប់ពាក់ព័ន្ធនឹងអំពើគំរាមទារប្រាក់ ការចាប់ជម្រិតទារប្រាក់ និងការទទួលសំណូកជាប្រព័ន្ធ។*[511]

*ពេលពិភាក្សាអំពីការប្រើប្រាស់ទារុណកម្មរបស់នគរបាល អតីតមន្ត្រីនគរបាលម្នាក់បានថ្លែងថា ទោះជា*

---

[508] LCIHR មានកំណត់ត្រា ស្ដីពីការសម្ភាសន៍ជាមួយអតីតមន្ត្រីនគរបាលក្រុងភ្នំពេញ ព្រំដែនថៃ-កម្ពុជា ខែតុលា ឆ្នាំ១៩៨៩ ដែលត្រូវរៀបចំចងក្រងសម្រាប់ LCIHR ***បន្ទាប់ពីស្ថានភាពអាក្រក់បំផុត។***

[509] LCIHR មានកំណត់ត្រា ស្ដីពី ការសម្ភាសន៍ ព្រំដែនថៃ-កម្ពុជា ខែវិច្ឆិកា ឆ្នាំ១៩៨៩ ដែលត្រូវរៀបចំចងក្រងសម្រាប់ LCIHR ***បន្ទាប់ពីមានស្ថានភាពអាក្រក់បំផុត,*** អង្គការ Amnesty International មានកំណត់ត្រា ស្ដីពី ការសម្ភាសន៍នានា ព្រំដែនថៃ-កម្ពុជា ខែកុម្ភៈ ឆ្នាំ១៩៨៦ ដែលត្រូវរៀបចំចងក្រងសម្រាប់អង្គការ Amnesty International ***ការដាក់ពន្ធនាគារ ក្រោមហេតុផលនយោបាយ។***

[510] LCIHR មានកំណត់ត្រា ដាក់ចំណងជើងថា "អត្ថបទដកស្រង់ស្ដីពី សាធារណរដ្ឋប្រជាមានិតកម្ពុជា" ខែវិច្ឆិកា ឆ្នាំ១៩៨៩ ដែលត្រូវរៀបចំចងក្រងសម្រាប់ LCIHR ***បន្ទាប់ពីមានស្ថានភាពអាក្រក់បំផុត។***

[511] LCIHR មានកំណត់ត្រា ស្ដីពី ការសម្ភាសន៍, ព្រំដែនថៃ-កម្ពុជា ខែវិច្ឆិកា ឆ្នាំ១៩៨៩ ដែលត្រូវរៀបចំចងក្រងសម្រាប់ LCIHR ***បន្ទាប់ពីមានស្ថានភាពអាក្រក់បំផុត,*** អង្គការ Amnesty International មានកំណត់ត្រា ស្ដីពី ការសម្ភាសន៍នានា, ព្រំដែនថៃ-កម្ពុជា ខែកុម្ភៈ ឆ្នាំ១៩៨៦ ដែលត្រូវរៀបចំចងក្រងសម្រាប់អង្គការ Amnesty International ***ការដាក់ពន្ធនាគារ ក្រោមហេតុផលនយោបាយ។***

អំពើទាំងនេះត្រូវហាមឃាត់ជាផ្លូវការក៏ដោយ ក៏នៅក្នុងការអនុវត្តជាក់ស្តែង អំពើនេះត្រូវបានលើកលែងឱ្យ ហើយថែមទាំងទទួលបានការលើកទឹកចិត្តឱ្យប្រព្រឹត្តពីសំណាក់ទីប្រឹក្សាជាន់ខ្ពស់របស់កងកម្លាំងសន្តិសុខ នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងទីប្រឹក្សាជំនាញការវៀតណាមទៀតផង ដែលពេលខ្លះបាន ចំអកឡកឡាយដល់បទប្បញ្ញត្តិ និងមេរៀននានាថា ជាការប្រឌិតដ៏មានប្រយោជន៍ នាំឱ្យការធ្វើទារុណកម្ម កាន់តែមានភាពងាយស្រួល ហើយអះអាងថា ទារុណកម្មមិនបានកើតឡើងឡើយ។[512] បច្ចេកទេសធ្វើ ទារុណកម្មដែលត្រូវបានប្រើលើជនជាប់ឃុំដោយសារបទល្មើសធម្មតា និង អ្នកជាប់ឃុំដោយសាររឿង នយោបាយ មានដូចជា ការឆក់ដោយចរន្តអគ្គិសនី និងការធ្វើឱ្យថប់ដង្ហើម ដោយប្រើថង់ផ្លាស្ទិក។ "ការ សារភាព" ដោយបង្ខំក៏ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការចាប់ខ្លួនបន្ថែមទៀតផងដែរ។[513]

ក្រៅពីពន្ធនាគារ P.J នៅមានមន្ទីរឃុំឃាំងផ្សេងទៀត ក្រោមការគ្រប់គ្រងរបស់នគរបាលក្រុង ដែលជន សង្ស័យត្រូវបានឃុំខ្លួនដោយគ្មានការជំនុំជម្រះ ហើយជាញឹកញាប់ ទទួលរងនូវការធ្វើទារុណកម្ម។ មន្ទីរឃុំ ឃាំងទាំងនេះ រាប់បញ្ចូលទាំងផ្នែកមួយនៃពន្ធនាគារជាតិ ក្នុងរាជធានីភ្នំពេញ ឈ្មោះថា គុកតេ៣ (T-3) មណ្ឌលអប់រំកែប្រែនៅព្រៃសដែលស្ថិតនៅជាយក្រុង និងមន្ទីរឃុំឃាំងបណ្តោះអាសន្នផ្សេងៗទៀត នៅថ្នាក់ ស្រុក និងថ្នាក់ឃុំ។[514]

## លោក នេត សាវឿន និង អ៊ុនតាក់ ឆ្នាំ ១៩៩១ ដល់ឆ្នាំ ១៩៩៣

គិតត្រឹមពេលមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ខែតុលា ឆ្នាំ១៩៩១ លោក នេត សាវឿន ត្រូវបានដំ ឡើងតំណែងទៅជាមេដឹកនាំកងកម្លាំងនគរបាលក្រុងភ្នំពេញ ដែលត្រូវហៅថា ជាស្នងការនគរបាល។[515]

---

[512] អង្គការ Amnesty International មានកំណត់ត្រា ដាក់ចំណងជើងថា "របាយការណ៍ ស្តីពី ទារុណកម្មលើអ្នកទោសនយោបាយ នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា" [គ្មានកាលបរិច្ឆេទ] ដែលត្រូវបានរៀបចំចងក្រងសម្រាប់អង្គការ Amnesty International ***ការដាក់ពន្ធនាគារ ក្រោមហេតុផលនយោបាយ,*** Gottesman ***កម្ពុជាបន្ទាប់ពីរបបខ្មែរក្រហម*** ទំព័រ ២៤៩។

[513] LCIHR មានកំណត់ត្រា ដាក់ចំណងជើងថា "អត្ថបទដកស្រង់ស្តីពី សាធារណរដ្ឋប្រជាមានិតកម្ពុជា" ខែវិច្ឆិកា ឆ្នាំ១៩៨៤ ដែលត្រូវរៀបចំចងក្រងសម្រាប់ LCIHR ***បន្ទាប់ពីមានស្ថានភាពអាក្រក់បំផុត។***

[514] LCIHR មានកំណត់ត្រា ដាក់ចំណងជើងថា "ចំនួនទណ្ឌិត" ខែវិច្ឆិកា ឆ្នាំ១៩៨៤ ដែលត្រូវរៀបចំចងក្រងសម្រាប់ LCIHR ***បន្ទាប់ពីមានស្ថានភាពអាក្រកបំផុត,*** LCIHR មានកំណត់ត្រា ដាក់ចំណងជើងថា "អត្ថបទដកស្រង់ ស្តីពីសាធារណរដ្ឋប្រជាមានិតកម្ពុជា" ខែវិច្ឆិកា ឆ្នាំ១៩៨៤ ដែលត្រូវរៀបចំចងក្រងសម្រាប់LCIHR ***បន្ទាប់ពីមានស្ថានភាពអាក្រក់បំផុត។***

[515] អ៊ុនតាក់ "បញ្ជីឈ្មោះអាជ្ញាធររដ្ឋាភិបាល" ***រស្មីកម្ពុជា*** ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ "នាយឧត្តមសេនីយ៍ នេត សាវឿន ក្មួយប្រសារលោក ហ៊ុន សែន ជាប្រធាននគរបាល" ***VOA*** កម្មវិធីផ្សាយជាភាសាខ្មែរ ភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ http://khmerization.blogspot.com/2008/11/gen-neth-

លោកក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រី ហ៊ុន គឹមឡេង ដែលជាកូនស្រីរបស់លោក ហ៊ុន ណេង បងប្រុសលោក ហ៊ុន សែន និង ជាអភិបាលខេត្តកំពង់ចាម។[516] នៅក្នុងរាជធានី លោក នេត សាវឿន បានបម្រើការងារជាផ្នែកមួយនៃគណៈកម្មាធិការរាជធានីនៃគណបក្សប្រជាជនកម្ពុជា ដែលក្នុងនោះមានអភិបាលរងទីមួយនៃរាជធានីភ្នំពេញ គឺលោក ហុក ឡង់ឌី ដែលនៅពេលនោះ អ្នកទាំងពីរត្រូវបានគេមើលឃើញថា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នា។ លោក នេត សាវឿន បានធ្វើការងារជាមួយលោក ហុក ឡង់ឌី ក្នុងប្រតិបត្តិការគំរាមកំហែង និង បំភិតបំភ័យគណបក្សនយោបាយផ្សេងៗ ដែលប្រកួតប្រជែងនឹងគណបក្សប្រជាជនកម្ពុជា ដើម្បីយកឈ្នះក្នុងការបោះឆ្នោតដែលរៀបចំដោយអ៊ុនតាក់។[517]

## *លោក នេត សាវឿន ចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៧*

យោងតាមមន្ត្រីជាន់ខ្ពស់នានានៃគណបក្សហ្វ៊ុនស៊ិនប៉ិច លោក នេត សាវឿន មានជាប់ពាក់ព័ន្ធយ៉ាងស៊ីជម្រៅ នៅក្នុងអំពើហិង្សាលើសមាជិកគណបក្សហ្វ៊ុនស៊ិនប៉ិច ក្នុងសម័យអ៊ុនតាក់ ទើបគណបក្សហ្វ៊ុនស៊ិនប៉ិចបានប្រាប់គណបក្សប្រជាជនកម្ពុជាថា ខ្លួន(ហ្វ៊ុនស៊ិនប៉ិច) នឹងមិនឯកភាពឱ្យលោក នេត សាវឿន មានតួនាទីផ្លូវការណាមួយនៅក្នុងរដ្ឋាភិបាលចម្រុះ ក្រោយសម័យអ៊ុនតាក់នោះទេ។[518]

នៅខែកក្កដា ឆ្នាំ១៩៩៤ លោក នេត សាវឿន បានដើរតួនាទីសំខាន់ ក្នុងការទប់ស្កាត់ការប៉ុនប៉ងធ្វើរដ្ឋប្រហារទម្លាក់លោក ហ៊ុន សែន ដោយមន្ត្រីគណបក្សប្រជាជនកម្ពុជា ដែលមិនពេញចិត្តចំពោះការត្រួតត្រារបស់គាត់នៅក្នុងគណបក្ស។[519] ក្រោយពេលចាប់ខ្លួន និងដកតំណែងអ្នករៀបចំសំខាន់ៗនៃរដ្ឋប្រហារនោះ

---

savoeun-hun-sens-nephew-in-law.html (ចូលមើល នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨)។

[516] ***រស្មីកម្ពុជា*** ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ "ឧត្តមសេនីយ៍ នេត សាវឿន ក្មួយប្រសារលោក ហ៊ុន សែន ជាប្រធាននគរបាល" ***VOA*** កម្មវិធីផ្សាយជាភាសាខ្មែរ ភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ http://khmerization.blogspot.com/2008/11/gen-neth-savoeun-hun-sens-nephew-in-law.html (ចូលមើលនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨), "ការរក្សាភាពស្មោះត្រង់" ***ខេមបូឌា ដេលី*** ថ្ងៃទី១៧-១៨ ខែមករា ឆ្នាំ២០០៤, Peter Bartu "របាយការណ៍៖ ស្ថានភាពនយោបាយ នៅកម្ពុជា" ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៤, Bertil Lintner "គ្រួសាររីកវាយដ៏ធំមួយ នៅកម្ពុជា" **Asia Times Online** (ថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៧) http://www.atimes.com/atimes/Southeast_Asia/IC20Ae03.html (ចូលមើល នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨), អ៊ុនតាក់ "បញ្ជីឈ្មោះ អាជ្ញាធររដ្ឋាភិបាល"។

[517] អ៊ុនតាក់ "តើនរណា ជានរណា", អ៊ុនតាក់ "របាយការណ៍ពិសេស ស្តីពី សកម្មភាពសង្ខេបនៃ Civpol PP" ថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៩៣។

[518] ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីជាន់ខ្ពស់ ហ្វ៊ុនស៊ិនប៉ិច ឆ្នាំ១៩៩៩-២០០០។

[519] ***ដំណឹងពេលព្រឹក*** ថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៩៤។

លោក នេត សាវឿន ក៏បានក្លាយជាមនុស្សសំខាន់ បម្រើឱ្យបំណងរយៈពេលវែងរបស់លោក ហ៊ុន សែន ក្នុងការប្រមូលផ្តុំកងកម្លាំងសន្តិសុខទាំងអស់ រួមទាំងនគរបាលឱ្យមកនៅក្រោមការគ្រប់គ្រងរបស់គាត់។[520]

តាមរយៈលោក នេត សាវឿន និង លោក ហុក ឡុង់ឌី ដែលត្រូវបានតែងតាំងជាអគ្គស្នងការនគរបាលជាតិ នៅខែសីហា ឆ្នាំ១៩៩៤ លោក ហ៊ុន សែន បានធ្វើវិទ្ធង្សនាបំផ្លាញឋានានុក្រមគ្រប់គ្រងបញ្ជារបស់នគរបាលជាតិ ដោយស្ទើរតែរំលងមន្ត្រីនគរបាលមកពីគណបក្សហ្វ៊ុនស៊ិនប៉ិចទាំងស្រុង។ ក្នុងការក្តោបយកអំណាចនគរបាលមកកាន់កាប់នេះ លោក ហ៊ុន សែន ក៏បានផាត់ចោលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមកពីគណបក្សប្រជាជនកម្ពុជាខ្លួនឯងដែរ គឺ លោក ស ខេង ដែលជាគូប្រជែងរបស់លោក ហ៊ុន សែន ក្នុងគណបក្ស។ លោក ស ខេង គឺជាមន្ត្រីគណបក្សប្រជាជនកម្ពុជាម្នាក់ ជាប់ពាក់ព័ន្ធក្នុងរដ្ឋប្រហារបរាជ័យ (ដែលប៉ុនប៉ងទម្លាក់សហនាយករដ្ឋមន្ត្រី នៅខែកក្កដា ឆ្នាំ១៩៩៤)។[521] អ្នកទាំងពីរ (លោក នេត សាវឿន និង លោក ហុក ឡុង់ឌី) ជាប់ឈ្មោះក្នុងចំណោមជាមេខ្លោងចាត់ចែងអោយមានឃាតកម្មនយោបាយ សកម្មភាពប៉ុនប៉ងធ្វើមនុស្សឃាតជាបន្តបន្ទាប់ អំពើចាប់ជម្រិត និងសកម្មភាពហិង្សានយោបាយផ្សេងទៀត សំដៅវាយប្រហារលើប្រព័ន្ធផ្សព្វផ្សាយ សហជីព និងអ្នកផ្សេងទៀតដែលរិះគន់លោក ហ៊ុន សែន។[522] លោក នេត សាវឿន ក៏ជាប់សង្ស័យថា មានជាប់ពាក់ព័ន្ធក្នុងព្រឹត្តិការណ៍វាយប្រហារដោយគ្រាប់បែកដៃ លើលោក សម រង្ស៊ី កាលពីថ្ងៃទី៣០ ខែ មីនា ឆ្នាំ១៩៩៧។[523]

## នេត សាវឿន ក្នុងពេលរដ្ឋប្រហាររបស់លោក ហ៊ុន សែន ឆ្នាំ១៩៩៧ និងការបោះឆ្នោតឆ្នាំ ១៩៩៨

ក្នុងអំឡុងពេលនៃរដ្ឋប្រហាររបស់លោក ហ៊ុន សែន នៅខែកក្កដា ឆ្នាំ១៩៩៧ លោក នេត សាវឿន ត្រូវបានគេរាយការណ៍ថា បានដើរតួនាទីជាមេបញ្ជាការសមរភូមិសម្រាប់កងកម្លាំងប្រដាប់អាវុធ ដែលបានវាយប្រហារលើគណបក្សប្រឆាំងនៅទីប្រជុំជនក្នុងក្រុងភ្នំពេញ ដោយធ្វើប្រតិបត្តិការជាមួយនឹងលោក ហុក ឡុង់

---

[520] Bartu "ស្ថានភាពនយោបាយ"។

[521] រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ៩៤ អនក្រ. ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៤ ការសម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់នៃក្រសួងសុខាភិបាល ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៧។

[522] ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីស៊ីវិល និងមន្ត្រីនគរបាលនៃគណបក្សប្រជាជនកម្ពុជា ភ្នំពេញ ឆ្នាំ១៩៩៩-២០០២។

[523] COHCHR ឯកសារចងក្រង ទាក់ទងនឹងជីវប្រវត្តិ ឆ្នាំ២០០៣, អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ "ប្រាប់ពួកគេទៅថា ខ្ញុំចង់សម្លាប់ពួកគេ" ទំព័រ ៣៥-៣៨។

ឌី ដែលជាអ្នកគ្រប់គ្រងលើរចនាសម្ព័ន្ធបញ្ជាការនៅទីប្រជុំជននោះ ក្នុងនោះក៏មានមេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេសគឺ លោក សៅ សុខា ផងដែរ។[524] លោក នេត សាវឿន ក៏ត្រូវបានគេចោទប្រកាន់ផងដែរថា បានស្ថិតក្នុងចំណោមអ្នករៀបចំអំពើឃាតកម្មលើអ្នកស្មោះស្ម័គ្រនឹងគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលនៅសេសសល់ក្នុងជួររដ្ឋាភិបាលក្រោយរដ្ឋប្រហារផងដែរ ដែលឃាតកម្មទាំងនោះត្រូវបានប្រព្រឹត្តដោយក្រុមនគរបាលពិឃាត នៅក្នុងដំណើរឆ្ពោះទៅរកការបោះឆ្នោតសកាជាតិបន្ទាប់ទៀតនៅខែកក្កដា ឆ្នាំ១៩៩៨។[525]

បន្ទាប់មក លោក នេត សាវឿន គឺជាសមាជិកម្នាក់នៃ "គណៈបញ្ជាការ" ដែលដឹកនាំដោយអភិបាលរងរាជធានីភ្នំពេញ មកពីគណបក្សប្រជាជនកម្ពុជាគឺ លោក ជា សុផារ៉ា ដែលជាអ្នកគ្រប់គ្រងការបង្ក្រាបដ៏ហិង្សាលើបាតុកម្មប្រឆាំងនឹងការលួចបន្លំសន្លឹកឆ្នោតក្នុងការបោះឆ្នោតសភាជាតិ កាលពីខែកក្កដា ឆ្នាំ១៩៩៨។ ក្រោមបញ្ជាផ្ទាល់ពីលោក ហ៊ុន សែន បេសកជនពិសេសរបស់គាត់ គឺលោក គន់ គីម លោកហុក ឡង់ឌី និង លោក សៅ សុខា គណៈបញ្ជាការនេះបានដាក់ពង្រាយកងកម្លាំងសន្តិសុខ រួមទាំង កងកម្លាំងនគរបាលរាជធានីភ្នំពេញ ប្រឆាំងនឹងបាតុកម្មនានា ក្នុងខែសីហា-កញ្ញា ឆ្នាំ១៩៩៨ ដែលបាតុកម្មមួយចំនួនត្រូវបានរៀបចំដោយគណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សសម រង្ស៊ី ហើយបាតុកម្មខ្លះទៀតត្រូវបានធ្វើឡើងដោយគ្មានការរៀបចំពីបក្សប្រឆាំងទាំងនោះទេ។ កងកម្លាំងសន្តិសុខបានសម្លាប់មនុស្សយ៉ាងតិច ២១ នាក់ ក្នុងនោះមួយចំនួនបានស្លាប់ដោយសារការប្រើប្រាស់កងកម្លាំងប្រកបដោយគ្រោះថ្នាក់ច្រើនហួសប្រមាណ និងមួយចំនួនផ្សេងទៀតត្រូវបានសម្លាប់ក្រៅប្រព័ន្ធតុលាការផ្សេងទៀត នៅក្នុងមន្ទីរឃុំឃាំងរបស់អង្គភាពសន្តិសុខ។[526] យ៉ាងហោចណាស់មានមនុស្ស ៦០នាក់ផ្សេងទៀត បានរងរបួសនៅក្នុងប្រតិបត្តិការបង្ក្រាបរបស់ពួកគេ។[527]

---

[524] ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីយោធា មន្ត្រីនគរបាល និងមន្ត្រីស៊ីវិលជាច្រើន នៃគណបក្សប្រជាជនកម្ពុជា, ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីយោធាជាន់ខ្ពស់នៃគណបក្សហ្វ៊ុនស៊ិនប៉ិច ការសម្ភាសន៍ជាមួយ លោក ហ៊ុន សែន ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧។

[525] ការសម្ភាសន៍របស់លោក Brad Adams ជាមួយអ្នកចូលរួមដែលបានសារភាព និងមន្ត្រីនគរបាល ព្រមទាំងមន្ត្រីផ្សេងទៀតនៃគណប្រជាជនកម្ពុជា

[526] សម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា ថ្ងៃ១៨ ខែកញ្ញា ឆ្នាំ២០០៤ ឧទាហរណ៍ សូមមើល "ការចំណាយទ្វេដងរបស់ក្រុមខ្លាហោះ" ខេមបូឌា ដេលី ថ្ងៃទី២ ខែមេសា ឆ្នាំ១៩៩៨ "ព្រះសង្ឃត្រូវបានបាញ់សុគត នៅពេលនគរបាលប៉ះទង្គិចជាមួយក្រុមបាតុករ នៅក្នុងរាជធានីនៃប្រទេសកម្ពុជា" AFP ភ្នំពេញ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៩៨ "ក្រុមបាតុករប្រមូលផ្តុំម្តងទៀត ការបូជាសពនៅកន្លែងដែលព្រះសង្ឃត្រូវបានបាញ់សុគត" AP ភ្នំពេញ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៩៨, "ព្រះសង្ឃកំពុងបាត់ខ្លួន ការភ័យខ្លាចចំពោះការស្លាប់" VOA ភ្នំពេញ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៩៨, "ឱកាសសម្រាប់កិច្ចព្រមព្រៀងកម្ពុជា ងងឹតអាប់អួរ ប៉ុន្តែនៅមានសង្ឃឹម" Reuters ភ្នំពេញ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៩៨, "ការសុគតរបស់ព្រះសង្ឃ នៅក្នុងការប៉ះទង្គិចគ្នា នៅកម្ពុជា" BBC ភ្នំពេញ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៩៨, "ព្រះសង្ឃខ្មែររងការវាយដំ ភ័យខ្លាច មិនចូលរួម" Reuters ភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨។

[527] "សេចក្តីថ្លែងការណ៍របស់ឯកអគ្គរដ្ឋទូតគឺ លោក Thomas Hammerberg តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការងារសិទ្ធិមនុស្ស ប្រចាំកម្ពុជា" ញូវយ៉ក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៨, "ការព្រួយបារម្ភយ៉ាងខ្លាំងរបស់អង្គការសហប្រជាជាតិ ដោយសារការស្លាប់ ការបាត់ខ្លួន នៅកម្ពុជា" Reuters ភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៨, "ចំនួនមនុស្សស្លាប់កើនឡើង" VOA ភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៨, អង្គការ

## *លោក នេត សាវឿន ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៨*

*គិតត្រឹមឆ្នាំ២០០០ លោក នេត សាវឿន បានចាកចេញពីតួនាទីជាស្នងការនគរបាលរាជធានីភ្នំពេញ និង បានក្លាយជាប្រធាននាយកដ្ឋានកណ្តាលយុត្តិធម៌ ស្ថិតក្រោមការបញ្ជារបស់លោកហុក ឡង់ឌី ទទួលខុសត្រូវចំពោះនគរបាលយុត្តិធម៌ថ្នាក់ជាតិដែលស៊ើបអង្កេតបទល្មើសទូទៅ និងបទល្មើសសេដ្ឋកិច្ច។*[528] *គាត់បានបន្តចូលរួមក្នុងការគាបសង្កត់ក្រោមហេតុផលនយោបាយលើក្រុមនយោបាយប្រឆាំងគណបក្សប្រជាជនកម្ពុជា ដូចជា ការឃុំខ្លួនតាមទំនើងចិត្ត នូវមន្ត្រីក្រសួងមហាផ្ទៃ ដែលគណបក្សប្រជាជនកម្ពុជាបានចាត់ទុកថា មិនស្មោះត្រង់ និងបានដកតំណែងពួកគេ ក្រោយពេលដោះលែង។*[529]

*នៅខែកុម្ភៈ ឆ្នាំ២០០៣ ដោយសារមានការផ្ទុះឡើងនូវកុបកម្មដ៏ហិង្សាប្រឆាំងនឹងប្រទេសថៃនៅក្នុងរាជធានីភ្នំពេញ ដែលរួមទាំងការបណ្តេញស្ថានទូតថៃនៅទល់មុខក្រសួងមហាផ្ទៃផង លោក នេត សាវឿន មានឈ្មោះជាអនុប្រធាន ក្នុងចំណោមអនុប្រធានមួយចំនួនទៀត នៃអ្វីដែលនៅពេលនោះ ត្រូវបានគេដាក់ឈ្មោះថ្មីឱ្យថា អគ្គស្នងការដ្ឋាននគរបាលជាតិ។*[530] *លោក នេត សាវឿន ក៏បានផ្លាស់ពីនាយកដ្ឋានកណ្តាលយុត្តិធម៌ ទៅកាន់នាយកដ្ឋានកណ្តាលសន្តិសុខវិញ ដោយបម្រើការនៅក្នុងអង្គភាពសំខាន់នេះ ដើម្បីរក្សាអំណាចរបស់លោក ហ៊ុន សែន រហូតដល់លោក សុខ ផល មកជំនួសគាត់នៅខែកក្កដា ឆ្នាំ២០០៣។*[531]

## *លោក នេត សាវឿន ក្នុងតួនាទីជាអគ្គស្នងការនគរបាលជាតិ ចាប់ពីឆ្នាំ២០០៨ មកទល់បច្ចុប្បន្ន*

*ការបញ្ចូលលោក នេត សាវឿន ជាស្នងការរងរបស់លោក ហុក ឡង់ឌី ត្រូវបានគេមើលឃើញជាទូទៅថា នៅថ្ងៃណាមួយគាត់នឹងឡើងទៅកាន់តំណែងកំពូលនេះ។ គាត់បានជំនួសលោក ហុក ឡង់ឌី បន្ទាប់ពីលោក*

---

Amnesty International "ព្រះរាជាណាចក្រកម្ពុជា៖ បាតុកម្មប៉ះទង្គិចនឹងការប្រើប្រាស់កងកម្លាំងហួសប្រមាណ" (ASA 23/26/98) ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ១៩៩៨។

[528] រាជរដ្ឋាភិបាលកម្ពុជា សេចក្តីសម្រេចលេខ ៦៤ សសរ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០។

[529] COHCHR ឯកសារចងក្រងទាក់ទងនឹងជីវប្រវត្តិ ឆ្នាំ២០០៣។

[530] ***ចក្រវាឡ*** ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៣ "ការផ្លាស់ប្តូរតំណែងនគរបាល ឆ្លុះបញ្ចាំងអំពីកុបកម្ម សម្ព័ន្ធមិត្តចាស់" ***ខេមបូឌា ដេលី*** ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ ២០០៣, មានកំណត់ត្រាទៅកាន់ ECCC ពីឧត្តមសេនីយ៍ ឯម សំអាន ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៦, រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ២៨ អនក្រ ចុះ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២។

[531] COHCHR ឯកសារចងក្រងទាក់ទងនឹងជីវប្រវត្តិ ឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ៦៦៦ អនក្រ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៣។

ហុក ឡង់ឌី បានស្លាប់នៅក្នុងការធ្លាក់ឧទ្ធម្ភាគចក្រនៅខែវិច្ឆិកា ឆ្នាំ២០០៨ ដែលនៅពេលនោះ គាត់ត្រូវបាន ដំឡើងឋានៈទៅជានាយឧត្ដមសេនីយ៍ផ្កាយមាស៤។[532]

នៅពេលនោះ ឋានានុក្រមជាផ្លូវការនៃការបញ្ជាប្រតិបត្តិការលើនគរបាលរាជធានី ខេត្ត និងនគរបាលនៅ តាមមូលដ្ឋានផ្សេងទៀត ត្រូវបានផ្លាស់ប្ដូរ ដោយសេចក្ដីសម្រេចថ្នាក់រដ្ឋមន្ត្រីមួយ នៅខែមិថុនា ឆ្នាំ២០០៦ ដើម្បីរំលងគូបដិបក្ខរបស់លោក ហ៊ុន សែន នៅក្នុងគណបក្សប្រជាជនកម្ពុជា ដែលនោះគឺលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយបានសម្រេចឱ្យបញ្ជាចេញពីលោក ហ៊ុន សែន ក្នុងនាមជានាយករដ្ឋមន្ត្រី ទៅ កាន់កងកម្លាំងទាំងនោះ តាមរយៈរដ្ឋលេខាធិការទទួលបន្ទុកនៃក្រសួងនេះ។ សេចក្ដីសម្រេចដដែលនេះ ក៏ បានដកហូតការគ្រប់គ្រងស្របច្បាប់របស់អគ្គស្នងការលើនាយកដ្ឋានកណ្ដាលសន្តិសុខនគរបាលជាតិផង ដែរ។[533] ទោះជាយ៉ាងណា សេចក្ដីសម្រេចនេះ បានធ្វើឱ្យគាត់មានអំណាចគ្រប់គ្រងដោយផ្ទាល់លើ នគរបាលយុត្តិធម៌នៅថ្នាក់កណ្ដាលនៃនាយកដ្ឋានកណ្ដាលយុត្តិធម៌ នាយកដ្ឋានកណ្ដាលសណ្ដាប់ធ្នាប់ សាធារណៈ (រាប់បញ្ចូលទាំងនគរបាលរដ្ឋបាល សណ្ដាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គមនៅថ្នាក់ កណ្ដាល) នាយកដ្ឋាននគរបាល អន្តរាគមន៍នៅថ្នាក់កណ្ដាល ដែលក្នុងនោះមានកម្លាំងប្រឆាំងបាតុកម្ម និង នាយនគរបាលបញ្ជាការ។[534]

ចាប់តាំងពីលោក នេត សាវឿន ឡើងកាន់តំណែងថ្នាក់កំពូលនៅអគ្គស្នងការដ្ឋាននគរបាលជាតិមក មន្ត្រី នគរបាលនៃអគ្គស្នងការនគរបាលជាតិ បានចូលរួមជាមួយនឹងនគរបាលនៃនាយកដ្ឋានកណ្ដាលសន្តិសុខ និងកងកម្លាំងនគរបាលនៅថ្នាក់ក្រោមជាតិ នៅក្នុងការស៊ើបអង្កេត ឬចាប់ខ្លួន និងការដាក់ពន្ធនាគារជាបន្ត បន្ទាប់ ក្រោយការជំនុំជម្រះក្រោមហេតុផលនយោបាយចំពោះអ្នកដែលត្រូវចោទប្រកាន់ដោយមិនត្រឹមត្រូវ ថា ជាប់ពាក់ព័ន្ធក្នុងផែនការក្បត់ជាសម្ងាត់។[535] អ្នកទាំងនេះរួមមាន សកម្មជនសិទ្ធិមនុស្ស ដែលជាគោល

[532] "ឧត្ដមសេនីយ៍ នេត សាវឿន ក្មួយប្រសារលោក ហ៊ុន សែន ជាប្រធាននគរបាល" ***VOA*** កម្មវិធីផ្សាយជាភាសាខ្មែរ ភ្នំពេញ ថ្ងៃទី១១ ខែ វិច្ឆិកា ឆ្នាំ២០០៨ http://khmerization.blogspot.com/2008/11/gen-neth-savoeun-hun-sens-nephew-in-law.html (ចូលមើល នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨), រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ នស/រកត/១១០៨/១២៣៨ ចុះថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០០៨។

[533] រាជរដ្ឋាភិបាលកម្ពុជា សេចក្ដីសម្រេចលេខ ៥៩៥ សសរ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៦។

[534] ក្រសួងមហាផ្ទៃ "ការរៀបចំកងកម្លាំងនគរបាលជាតិ" ឆ្នាំ២០០៦, អ៊ីន យឿន, ច្បាប់រដ្ឋបាល (*នីតិមុខងារសាធារណៈ*) (ភ្នំពេញ ឆ្នាំ២០១៣) ទំព័រ ៣៧៦-៣៧៨ ដូចបានឆ្លុះបញ្ចាំងនៅក្នុងរាជរដ្ឋាភិបាល ព្រះរាជក្រឹត្យលេខ នស/០៦១០/៥៦៧ ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០។

[535] ពីប្រភពដដែល (Ibid.)

ដៅ ដើម្បីដាក់ទណ្ឌកម្មចំពោះការងារការពារសិទ្ធិមនុស្សរបស់ពួកគេ ដូចជា លោក លាង សុខជឿន ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល២ឆ្នាំ នៅក្នុងខែសីហា ឆ្នាំ២០១០។[536] អ្នកទាំងនេះក៏រាប់បញ្ចូលទាំងមនុស្ស ១៣នាក់ ដែលត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារនៅក្នុងខែមេសា ឆ្នាំ ២០១៤ ដោយរងការចោទប្រកាន់ដោយគ្មានភស្តុតាងថា មានជាប់ពាក់ព័ន្ធក្នុងសកម្មភាពរបស់ចលនារណសិរ្សរំដោះជាតិខ្មែរផងដែរ។[537]

នគរបាលយុត្តិធម៌នៅថ្នាក់កណ្តាលរបស់លោក នេត សាវឿន ក៏ជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួនតាមទំនើងចិត្តចំពោះបាតុករប្រឆាំងនឹងការរំលោភដីធ្លីដោយអ្នកជំនួញទាំងឡាយ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយមន្ត្រីថ្នាក់ខ្ពស់របស់រដ្ឋាភិបាល ដូចជា ក្រុមហ៊ុន KDC ដែលជារបស់ប្រពន្ធលោក ស៊ុយ សែម ដែលបច្ចុប្បន្ននេះជារដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលផងដែរ។[538] កងកម្លាំងនគរបាលអន្តរាគមន៍នៅថ្នាក់កណ្តាលបានចូលរួមនៅក្នុងការបំបែកដោយបង្ខំទៅលើបាតុកម្មរបស់កម្មកររោងចក្រ ដោយបង្ករបួសស្នាមយ៉ាងធ្ងន់ធ្ងរដល់កម្មករ និងបានចូលរួមក្នុងការបណ្តេញពលរដ្ឋក្រីក្រនៅទីក្រុងឱ្យចាកចេញពីលំនៅស្ថានរបស់ពួកគេដោយបង្ខំ បន្ទាប់ពីពួកគេបដិសេធមិនទទួលយកការផ្តល់សំណងមិនសមរម្យសម្រាប់ការផ្លាស់ប្តូរទីលំនៅទៅតំបន់ថ្មី ដូចករណីពលរដ្ឋរស់នៅតំបន់បូរីកីឡា ក្នុងទីក្រុងភ្នំពេញដែលកំពុងបន្តជាដើម។[539] បន្ថែមលើនេះទៀត ពួកគេមានជាប់ពាក់ព័ន្ធនឹងការប៉ុនប៉ងបិទបាំងការឃុំខ្លួនតាមទំនើងចិត្ត និងការធ្វើបាបពលរដ្ឋកម្ពុជា ដែលត្រូវបានក្រុមហ៊ុនមានជាប់ពាក់ព័ន្ធនឹងនយោបាយ ជ្រើសរើសទៅធ្វើការនៅក្រៅប្រទេស ដូចក្នុងករណីឆ្នាំ២០១១ ដែលពាក់ព័ន្ធនឹងក្រុមហ៊ុនធីអ៊ែនភី (T&P)ជាដើម។[540]

---

[536] "កម្ពុជា ៖ ដោះលែងមន្ត្រីជាបុគ្គលិកខាងសិទ្ធិមនុស្ស ៖ ម្ចាស់ជំនួយគួរកៀបសង្កត់រដ្ឋាភិបាលឱ្យឈប់រុកគួនក្រុមសិទ្ធិមនុស្ស។" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១http://www.hrw.org/news/2011/07/14/cambodia-free-human-rights-worker.

[537] កម្ពុជា ៖ ទម្លាក់ចោលករណី "ការរៀបចំផែនការក្បត់ជាសម្ងាត់៖ ច្រានចោលការចោទប្រកាន់ ចំពោះមនុស្ស ១៣នាក់ ពីបទរៀបចំផែនការផ្តួលរំលំរដ្ឋាភិបាល។" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤ http://www.hrw.org/news/2014/04/09/cambodia-drop-treacherous- plotting-case.

[538] ពីប្រភពដដែល (Ibid.)

[539] ពីប្រភពដដែល (Ibid);"កម្ពុជា ៖ កងកម្លាំងសន្តិសុខ វាយដំបាតុករទាមទារសិទ្ធិផ្ទះសម្បែង។" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤ https://www.hrw.org/news/2014/02/14/cambodia-security-forces-beat-housing-rights-protesters.

[540] ពីប្រភពដដែល (Ibid.);អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ,"*ពួកគេបានបោកប្រាស់យើងគ្រប់ជំហាន*"៖ *ការរំលោភបំពានលើពលករ តាមផ្ទះកម្ពុជា ដែលទៅធ្វើការងារនៅប្រទេសម៉ាឡេស៊ី* ឆ្នាំ២០១១https://www.hrw.org/sites/default/files/reports/cambodia1111webwcover.pdf, p.35.

## លោក នេត សាវឿន ក្នុងពេលបោះឆ្នោតឆ្នាំ ២០១៣ និងចាប់ពីពេលនោះមក

មុនពេល ក្នុងពេល និង ក្រោយពេលបោះឆ្នោតសភាជាតិ ឆ្នាំ២០១៣ លោក នេត សាវឿន បានបង្ហាញជំហរ គាំទ្រគណបក្សប្រជាជនកម្ពុជា ដោយឥតប្រែប្រួល។ ក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត លោកបានគ្រប់គ្រងសកម្មភាពរបស់ក្រុមការងារគណបក្សប្រជាជនកម្ពុជា ដែលបានទទួលការចាត់តាំង ឱ្យធ្វើការងារនៅក្នុងស្រុកចំនួនបីនៃខេត្តព្រៃវែង ដោយគាត់បានថ្លែងនៅក្នុងកិច្ចប្រជុំមួយនៅទីនោះថា វាគឺជាការកិច្ចរបស់មន្ត្រីជាន់ខ្ពស់ទាំងអស់នៃគណបក្សប្រជាជនកម្ពុជា ដូចជាខ្លួនគាត់ផ្ទាល់ ក្នុងការចូលរួមបំពេញការងារនៅតាមមូលដ្ឋានបែបនេះ។ អ្នកដឹកនាំក្រុមការងារនោះបានពន្យល់ថា អង្គភាពបែបនេះផ្តល់របាយការណ៍ស្តីពីស្ថានភាពនៅមូលដ្ឋានដល់ថ្នាក់ដឹកនាំ ដូចជាលោក នេត សាវឿន។[541] នៅក្នុងការជួបជុំក្រុមនគរបាលមួយកាលពីដើមខែមីនាឆ្នាំ២០១៣ លោក នេត សាវឿន បាននិយាយថា នឹងមានបញ្ហាជាច្រើន ទាក់ទងនឹងការបោះឆ្នោត ដោយសារ "ជនបរទេសមានបំណង និងប្រមូលផ្តុំគ្នាដើម្បីពង្រឹងគណបក្សប្រឆាំងនានាតទល់នឹងគណបក្សកាន់អំណាច។"[542]

ចាប់ពីខែសីហា ឆ្នាំ២០១៣ រដ្ឋាភិបាលបានចាប់ផ្តើមដាក់ពង្រាយនគរបាល កងរាជអាវុធហត្ថ និងជួនកាលកងយោធាប្រដាប់អាវុធយ៉ាងច្រើននៅក្នុងទីក្រុងភ្នំពេញ ដើម្បីរារាំង និងបង្ក្រាបបាតុកម្មរបស់គណបក្សសង្គ្រោះជាតិ និងការប្រមូលផ្តុំផ្សេងទៀត ដូចជា កូដកម្មដោយកម្មករដើម្បីទាមទារដំឡើងប្រាក់ឈ្នួល និងកែលម្អលក្ខខណ្ឌការងារ។ នៅខែកញ្ញា និងវិច្ឆិកា ឆ្នាំ២០១៣ និង ម្តងទៀត នៅដើមខែមករា ឆ្នាំ២០១៤ នគរបាលថ្នាក់កណ្តាល និងកងកម្លាំងនគរបាលផ្សេងទៀត រួមទាំងក្រុមនាយនគរបាលបញ្ជាការ នៅក្រោមលោក នេត សាវឿន ដោយប្រតិបត្តិការជាមួយកងរាជអាវុធហត្ថ និងជួនកាល មានការគាំទ្រពីកងយោធាផង បានចូលរួមក្នុងការវាយប្រហារលើបាតុករ កូដករ និងកុបករ ដោយសម្លាប់ពួកគេមួយចំនួន បង្ករបួសស្នាម និងចាប់ខ្លួនពួកគេជាច្រើន ក្រោមហេតុផលថា ដើម្បីរក្សាសណ្តាប់ធ្នាប់សង្គម និងសន្តិសុខសាធារ

---

[541] "លោក ពិន ពិសិដ្ឋ ចុះពិនិត្យ និងសិក្សាស្ថានភាពផ្លូវ និងការជីកអណ្តូង សម្រាប់ពលរដ្ឋ នៅឃុំក្អៀងរាយ" (= J 6u' = ), ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/56292-2013-01-19-07-33-17.html; http://khmerization.blogspot.com/2008/11/gen-neth-savoeun-hun-sens-nephew-in-law.html (ចូលមើលនៅថ្ងៃទី២២ ខែ មករា ឆ្នាំ២០១៣)។

[542] "អគ្គស្នងការនគរបាលជាតិ ៖ មានបញ្ហាជាច្រើន នៅពេលបោះឆ្នោតឆ្នាំ២០១៣" ( s s Cfl • s rrn bl s.), ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១ http://www.cen.com.kh/localnews/details_more/19?token=MDRkMzczYT#.UTdRP6OD9UM (ទទួលបាន ឬ បានអាន នៅថ្ងៃទី១២ ខែមីនា ឆ្នាំ ២០១៣)។

ណៈ និងដាក់ទណ្ឌកម្មអ្នកល្មើសច្បាប់។[543] យ៉ាងហោចណាស់ មនុស្សប្រាំពីរនាក់បានស្លាប់ដោយសារការប្រើប្រាស់កងកម្លាំងប្រកបដោយគ្រោះថ្នាក់ និងច្រើនលើសលប់ ឬ ដោយមិនចាំបាច់ ដោយកងរាជអាវុធហត្ថ និងនគរបាល រួមទាំងតាមរយៈការបាញ់ប្រហារទៅលើក្រុមបាតុករ ដោយប្រើប្រាស់គ្រាប់កាំភ្លើងពិត។[544]

លោក នេត សាវឿន បានប្រកាសជាសាធារណៈនូវការគាំទ្ររបស់គាត់ ចំពោះសកម្មភាពរបស់កងកម្លាំងសន្តិសុខទាំងនោះ និងបន្តបង្ហាញនូវភក្តីភាពរបស់លោកចំពោះគណបក្សប្រជាជនកម្ពុជា ហើយបានថ្កោលទោសគណបក្សប្រឆាំង។ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ លោកបានកោតសរសើរនគរបាលចំពោះភាពអង់អាចរបស់ពួកគេ ក្នុងអំឡុងពេលនៃ "ការប្រឈមមុខដាក់គ្នានានា" កើតចេញពីបាតុកម្ម "មិនប្រក្រតី" របស់គណបក្សសង្គ្រោះជាតិ ដែលលោកចាត់ទុកថាជា "ការញុះញង់" ក្នុងគោលបំណងផ្តួលរំលំរដ្ឋាភិបាល។[545] នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៤ លោកបាននិយាយជំនួសមុខកងកម្លាំងនគរបាលកម្ពុជាទាំងមូល ដោយប្រកាសថ្កោលទោសលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ តាមរយៈការចោទប្រកាន់ដោយគ្មានមូលដ្ឋានច្បាស់ លាស់ថា លោក សម រង្ស៊ី បានប្រព្រឹត្តអំពើខុសច្បាប់។[546] ផ្ទុយពីនេះ នៅក្នុងសារជូនពរថ្ងៃខួបកំណើតលោក ហ៊ុន សែន នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤វិញ លោក នេត សាវឿន បានរៀបរាប់អំពីលោក ហ៊ុន សែនថា ជា "មនុស្សដែលមានប្រាជ្ញាវាងវៃក្រៃលែង នៅក្នុងភាពជាអ្នកដឹកនាំនៃប្រទេសកម្ពុជា" រួមទាំងការរក្សាសណ្តាប់ធ្នាប់សង្គមនៅក្នុងប្រទេស។[547]

---

[543] "កម្ពុជា ៖ ការកាត់ទោសនៅស្ទឹងមានជ័យ ប្រកបដោយកំហុសយ៉ាងជ្រាលជ្រៅ" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ច ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៤ https://www.hrw.org/news/2014/05/11/cambodia-steung-meanchey-trial-deeply-flawed; "កម្ពុជា ៖ ដោះលែងមនុស្ស ៦នាក់ ដែលត្រូវបានចាប់ខ្លួនដោយចៃដន្យក្នុងអំឡុងពេលនៃបាតុកម្ម" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ច ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤ http://www.hrw.org/node/252822.

[544] អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ច "ការដាក់ស្នើរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ច សម្រាប់ឱ្យ គណៈកម្មាធិការសិទ្ធិមនុស្ស ពិនិត្យស្ថានភាព នៅកម្ពុជា" ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៤។

[545] "នាយឧត្តមសេនីយ៍ ដាក់ចេញផែនការ ដើម្បីឱ្យនគរបាលជាតិបង្កើនបន្ថែមទៀត លើការពង្រឹងសន្តិសុខ នៅពេលគិតថា អាចមានការរៀបចំបាតុកម្មជាថ្មី", ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៣ http://edition.bayontv.com.kh/bayontv-national-news/22986-2014-03-07-03-53-01.html, (ចូលមើល នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៤), "សមត្ថកិច្ចកំពុងបង្កើនការពង្រឹងសន្តិសុខ នៅពេលបទល្មើសព្រហ្មទណ្ឌនៅក្នុងទីក្រុងភ្នំពេញ បានចាប់ផ្តើមកើនឡើង", ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ http://edition.bayontv.com.kh/ bayontv-national-news/23422-2014-03-14-12-57-31.html (ចូលមើល នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤)

[546] "នាយឧត្តមសេនីយ៍ នេត សាវឿន ថ្កោលទោសលោក សម រង្ស៊ី", ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/84483-2014-04-07-09-14-12.html (ចូលមើល នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៤)

[547] "នាយឧត្តមសេនីយ៍ នេត សាវឿន ផ្ញើសារជូនពរ សម្តេចតេជោ ហ៊ុន សែន", ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/84087-2014-04-02-03-46-35.html (ចូលមើល នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤)។

នៅក្នុងសុន្ទរកថា នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៤ លោក នេត សាវឿន បានថ្លែងថា ស្ថានភាពសន្តិសុខនៅក្នុងប្រទេស កាន់តែយ៉ាប់យ៉ឺននៅក្នុងឆ្នាំ២០១៤ ដោយសារបាតុកម្មក្នុងរឿងវិវាទដីធ្លី និងផ្ទះសម្បែង បញ្ហាសិទ្ធិមនុស្ស និងច្បាប់ការងារ។ លោកបាននិយាយថា បញ្ហាទាំងនេះកើតឡើងដោយសារមានការជ្រៀតជ្រែកចូលពីសំណាក់អ្នកនយោបាយ សង្គមស៊ីវិល និងសហជីពមួយចំនួន ដែលលោកបានចោទពួកគេដោយមិនត្រឹមត្រូវថា មានចេតនាបង្កអំពើហិង្សា។ លោកបានកោតសរសើរនគរបាលដែលបានដោះស្រាយ "កលល្បិចដ៏ពិសពុល" ទាំងនេះ តាមរយៈការស្តារឡើងវិញនូវសណ្តាប់ធ្នាប់សាធារណៈ ដោយបានសង្កត់ធ្ងន់ថា នគរបាលបានធ្វើកិច្ចការទាំងនេះ ដោយសហប្រតិបត្តិការជាមួយអាជ្ញាធររាជធានី និងកងរាជអាវុធហត្ថ (GRK)។ លោក នេត សាវឿន បានបញ្ជាក់ថា "ជនអនាធិបតេយ្យនិយម" ២៣ នាក់ ដែលបានបង្កហេតុញុះញង់ និងប្រព្រឹត្តអំពើហិង្សាដោយផ្ទាល់ ត្រូវបានចាប់ខ្លួននៅក្នុងប្រតិបត្តិការរបស់កងកម្លាំងសន្តិសុខនោះ។ តាមការពិត គ្មានភស្តុតាងបញ្ជាក់ថា ជនណាម្នាក់ក្នុងចំណោមជនទាំង២៣នាក់ ដែលក្នុងនោះមានអ្នកការពារសិទ្ធិមនុស្សដ៏ល្បីល្បាញផងដែរនោះ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែងឡើយ ប៉ុន្តែទោះបីយ៉ាងណា ពួកគេនៅតែត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ តែទោសនោះត្រូវបានព្យួរ។[548]

ជាផ្នែកមួយនៃការបង្កើនការបង្ក្រាបរបស់រដ្ឋាភិបាលលើគណបក្សប្រឆាំងក្នុងអំឡុងឆមាសទីពីរនៃឆ្នាំ២០១៥ តុលាការបានចេញដីកាចាប់ខ្លួនលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥។ ដីការនេះបានឈានរហូតដល់ការកាត់ទោសដាក់ពន្ធនាគារលើលោក សម រង្ស៊ី ដែលត្រូវបានសម្រេចកាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ ដែលបានផ្តន្ទាទោសលោកក្រោមបទចោទមានលក្ខណៈនយោបាយថា បានញុះញង់ឱ្យមានការរើសអើង ទាក់ទងនឹងការអត្ថាធិប្បាយរបស់លោក សម រង្ស៊ី អំពីតួនាទីរបស់មន្ត្រីរាជរដ្ឋាភិបាលជាន់ខ្ពស់ម្នាក់ នៅក្នុងរបបខ្មែរក្រហម។[549] សេចក្តីអត្ថាធិប្បាយរបស់លោកក៏បានក្លាយជាកម្មវត្ថុនៃបណ្តឹងរបស់មន្ត្រីរូបនោះ ទៅកាន់តុលាការបារាំងផងដែរ ប៉ុន្តែតុលាការកំពូលបារាំងបានសំរេចនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ ថា សំដី (របស់លោក សម រង្ស៊ី) "មិនបានធ្វើហួសពីដែនកំណត់

[548] "កម្ពុជា ៖ ទុកជាមោឃៈ នូវការផ្តន្ទាទោសសកម្មជន ២៥នាក់, កម្មករ ៖ វត្តតាងមិនគ្រប់គ្រាន់ ត្រូវបានបង្ហាញនៅក្នុងការជំនុំជម្រះ ដែលមានលក្ខណៈនយោបាយ" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ហ្យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៤ http://www.hrw.org/news/2014/06/01/cambodia-quash-convictions-25- activists-workers.

[549] សាលាដំបូងរាជធានីភ្នំពេញ "សាលក្រមលេខ ៣២ 'ធ'" ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១, របាយការណ៍អង្គការសិទ្ធិមនុស្សអន្តរជាតិ ហ្យូមែនរ៉ៃត៍វ៉ច្ឆ (២០១៦) (ញូវយ៉ក៖ អង្គការសិទ្ធិមនុស្សអន្តរជាតិ ហ្យូមែនរ៉ៃត៍វ៉ច្ឆ ២០១៦) កម្ពុជា https://www.hrw.org/world-report/2016/country-chapters/cambodia.

នៃសេរីភាពក្នុងការបញ្ចេញមតិរិះគន់អ្នកនយោបាយឡើយ”។[550] លោក សម រង្ស៊ី ស្ថិតនៅក្រៅប្រទេសកម្ពុជា ក្នុងពេលចេញដីកានោះ ហើយលោកបានជ្រើសរើសមិនវិលត្រលប់មកប្រទេសកម្ពុជាវិញទេ។ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ លោក នេត សាវឿន មានឈ្មោះនៅក្នុងគណៈកម្មាធិការមួយ ដែលដឹកនាំដោយរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកនគរបាលជាតិ និងនាយកដ្ឋានកណ្តាលសន្តិសុខ គឺនាយឧត្តមសេនីយ៍ ឯម សំអាន។ គណៈកម្មាធិការនេះមានភារកិច្ចចាប់ខ្លួនលោក សម រង្ស៊ី នៅពេលណាដែលអាចធ្វើបាន។[551]

ក្នុងអំឡុងឆ្នាំ២០១៦ លោក នេត សាវឿន បានបន្តប្រតិបត្តិការរបស់លោកជាសាធារណៈជាមន្ត្រីរបស់គណបក្សប្រជាជនកម្ពុជា ដោយផ្សព្វផ្សាយគោលនយោបាយរបស់គណបក្ស ធ្វើសកម្មភាពនានាដើម្បីគាំទ្រគណបក្សប្រជាជនកម្ពុជា សំដៅយកឈ្នះការបោះឆ្នោតនៅពេលខាងមុខ និងសម្តែងការគាំទ្រចំពោះការបន្តធ្វើជាមេដឹកនាំប្រទេសកម្ពុជារបស់លោក ហ៊ុន សែន។[552] លោកនាយករដ្ឋមន្ត្រី បានព្រមានថា ប្រសិនបើគណបក្សសង្គ្រោះជាតិព្យាយាមដកលោក នេត សាវឿន អគ្គស្នងការនគរបាលជាតិនឹងប្រមូលផ្តុំកងកម្លាំងនគរបាលរបស់ខ្លួនដើម្បីទប់ស្កាត់ការប៉ុនប៉ងនោះ។[553] នៅខែមិថុនា ឆ្នាំ២០១៦ កងនគរបាលមកពីទូទាំងប្រទេស បានចាប់ផ្តើមប្រមូលផ្តុំនៅសាលានគរបាលជាតិ ក្នុងខេត្តកំពង់ស្ពឺ ដើម្បីចូលរួមវគ្គហ្វឹកហ្វឺនបន្ថែមអំពី “ការប្រឆាំងនឹងបាតុកម្ម” ក្រោមអធិបតីភាពនៃអគ្គស្នងការ ហើយវគ្គនេះត្រូវបន្តរហូតដល់ខែកញ្ញា។[554]

---

550 តុលាការនៃបណ្ឌិតសភា អង្គជំនុំជម្រះ លេខ No. N`0-83.771 F-P+B, No.2357, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១

551 “រាជរដ្ឋាភិបាលសម្រេចបង្កើតគណៈកម្មាធិការមួយ ដើម្បីអនុវត្តដីការចាប់ខ្លួនលោកសម រង្ស៊ី, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ http://www.dap-news.com/2011-06-14-02-39-55/102630-2015-11-16-02-29-44.html (ចូលមើល នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥)។

552 “នាយឧត្តមសេនីយ៍ នេត សាវឿន និយាយថា មន្ត្រីជាសមាជិកគណបក្សប្រជាជនកម្ពុជា ត្រូវតែធ្វើអំពើល្អ និងលុបបំបាត់ភាពអសកម្ម” ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ http://kampucheathmey.com/kpt/?p=179884 (ចូលមើល នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦), “អំណោយរបស់ សម្តេច ស ខេង និង នាយឧត្តមសេនីយ៍ នេត សាវឿន ត្រូវបាននាំទៅចែកជូនឃុំចំនួន ២ នៅខេត្តព្រៃវែង” ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៦ http://www.freshnewsasia.com/index.php/en/25784-2016-06-04-10-49-45.html (ចូលមើល នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៦)។

553 “លោក ហ៊ុន សែន ព្រមានគណបក្សប្រឆាំងអំពី ប្រតិកម្មខ្លាំងក្លាដោយកងកម្លាំងប្រដាប់អាវុធ” *ខេមបូឌៀ ដេលី* ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ https://www.cambodiadaily.com/news/hun-sen-warns-opposition-of-backlash-by-armed-forces-97603/ (ចូលមើល នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥)។

554 “លោក ហ៊ុន សែន ព្រមានគណបក្សប្រឆាំងអំពី ប្រតិកម្មខ្លាំងក្លាដោយកងកម្លាំងប្រដាប់អាវុធ” *ខេមបូឌៀ ដេលី* ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ https://www.cambodiadaily.com/news/hun-sen-warns-opposition-of-backlash-by-armed-forces-97603/ (ចូលមើល នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥)។

ភ្លាមៗក្រោយពីសន្និបាតគណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា នៅខែធ្នូ ឆ្នាំ២០១៦ លោក នេត សាវឿន បានបញ្ជូនមន្ត្រីក្រោមបង្គាប់ម្នាក់ឱ្យទៅធ្វើការងារពង្រឹងមូលដ្ឋានជំនួសមុខគាត់។[555] ចាប់ពីពាក់កណ្តាលខែតុលា រហូតដល់ចុងខែវិច្ឆិកា ឆ្នាំ២០១៦ កងកម្លាំងនគរបាលជាតិរបស់គាត់ បានទទួលការហ្វឹកហ្វឺនរយៈពេល ៤៥ថ្ងៃ អំពីការគ្រប់គ្រងកុបកម្ម សំដៅទប់ស្កាត់ និងបង្ក្រាបអ្វីដែលត្រូវបានចាត់ទុកថាជា "អំពើញុះញង់" ក្នុងបំណងបង្កើត "បដិវត្តពណ៌"។[556] នៅក្នុងរយៈពេលនោះ លោក នេត សាវឿន បានបញ្ជាក់សារជាថ្មីថា តួនាទីសំខាន់របស់នគរបាល គឺ "រក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ល្អនៅក្នុងសង្គម" ដោយសង្កត់ធ្ងន់ជាថ្មីថា នៅក្នុងការអនុវត្តជាក់ស្តែង ដៃគូប្រតិបត្តិការជាទូទៅរបស់ខ្លួននៅក្នុងការអនុវត្តចំណាត់ការរបស់នគរបាល គឺកងរាជអាវុធហត្ថ ដែលស្ថិតក្រោមការបញ្ជារបស់លោក សៅ សុខា នៅថ្នាក់ជាតិ និងអ្នកក្រោមបង្គាប់របស់ពួកគេនៅថ្នាក់មូលដ្ឋាន ស្របតាមមាគ៌ាកងកម្លាំងចម្រុះ។[557]

របាយការណ៍មួយរបស់ក្រសួងមហាផ្ទៃ ក្នុងខែកុម្ភៈ ឆ្នាំ២០១៧ ដែលបូកសរុបសមិទ្ធផលឆ្នាំ២០១៦ របស់នគរបាលជាតិ បានកោតសរសើរនគរបាលជាតិចំពោះការដោះស្រាយប្រកបដោយជោគជ័យ លើអ្វីដែលរបាយការណ៍នោះហៅថា "ក្រុមជ្រុលនិយម ដែលកំពុងបន្តចិញ្ចឹមមហិច្ឆតាញុះញង់ក្នុងចេតនាបង្កើតភាពចលាចល ភាពឥតសណ្តាប់ធ្នាប់ និងអស្ថិរភាព" នៅពីក្រោយបាតុកម្មជាច្រើន រួមទាំងអ្នកដែលកំពុងប្រើប្រាស់លេសលើកកម្ពស់ "បញ្ហាសិទ្ធិមនុស្ស" ផងដែរ។[558] សម្រាប់ខាងលោក នេត សាវឿនវិញ លោកបានធ្វើ

---

[555] "ទីស្នាក់ការគណបក្សប្រជាជនកម្ពុជា នៅឃុំពានរោង ត្រូវបានជួសជុល និងកែលំអថ្មី លោកប្រធានក្រុមការងារជម្រុញឱ្យសមាជិកបក្សទាំងអស់បង្កើនសកម្មភាពរបស់ខ្លួន" , ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ http://www.freshnewsasia.com/index.php/en/localnews/42501-2016-12-23-12-53-02.html (ចូលមើលនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦)។

[556] "ប្រធានថ្នាក់ជាតិ ប្រាប់នគរបាលប្រឆាំងកុបកម្ម ឱ្យគិតគូរអំពី បដិវត្តពណ៌" ***ខេមបូឌា ដេលី*** ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ https://www.cambodiadaily.com/news/riot-police-told-national-chief-fear-color-revolution-121220/ (ចូលមើលនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៦)។

[557] "នាយឧត្តមសេនីយ៍ នេត សាវឿន ស្នើឱ្យបណ្ឌិតសភានគរបាលប្រជាជនវៀតណាម ធ្វើការស្រាវជ្រាវ ដើម្បីរកមេរៀន និងបទពិសោធន៍ថ្មីៗ ដើម្បីហ្វឹកហ្វឺននគរបាលខ្មែរ" ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៦ http://dap- news.com/kh/%E1%9E%96% E1%9F%90%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93%E1%9E%80%E1%9F%92%E1%9E%93%E1%9E%BB%E1%9E%84%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%91%E1%9F%81%E1%9E%9F/20882.html (ចូលមើល នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៦), "សមត្ថកិច្ចត្រៀមកងកម្លាំងជាង ១០.០០០ នាក់ ដើម្បីការពារសន្តិសុខ និងសណ្តាប់ធ្នាប់ល្អ នៅក្នុងឱកាសបុណ្យអុំទូក នៅពាក់កណ្តាលខែវិច្ឆិកានេះ" ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៦ http://www.freshnewsasia.com/index.php/en/localnews/38608-2016-11-04-06-34-55.html (ចូលមើលនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៦), "ឧត្តមសេនីយ៍ នេត សាវឿន ៖ ចោរមិនមែនជាកម្មសិទ្ធិបញ្ញារបស់នរណាទេ ត្រូវជួយចាប់គ្នាទាំងប៉ូលិស ទាំងប៉េអឹម ដើម្បីបម្រើសន្តិសុខប្រជាពលរដ្ឋ" ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ http://www.freshnewsasia.com/index.php/en/localnews/39068-2016-11-10-06-44-32.html (ចូលមើល នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦)។

[558] "សម្តេចក្រឡាហោម ស ខេង បញ្ជាក់នូវសមិទ្ធផលធំៗចំនួន ៧ ដែលក្រសួងមហាផ្ទៃអាចសម្រេចបាន នៅក្នុងឆ្នាំ២០១៦ កន្លងទៅ" ( .,G rrn bl G s sru t G s s ), ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧http://www.freshnewsasia.com/index.php/en/localnews/47758-2017-02-22-02- 53-20.html (ចូលមើល

ជាអធិបតីភាព នៅក្នុងកិច្ចប្រជុំនាទីក្រុងភ្នំពេញនៅក្នុងខែដដែលនោះ ដើម្បីបូកសរុបសកម្មភាពឆ្នាំ២០១៦ របស់នគរបាលរាជធានីភ្នំពេញនៃអគ្គស្នងការរងរបស់គាត់គឺ លោក ជួន សុវណ្ណ និងបានសម្តែងនូវការអបអរសាទរពួកគេ ចំពោះការងារនៅក្នុងឆ្នាំ២០១៦លើបញ្ហានេះ។[559]

នៅខណៈនោះដែរ លោក នេត សាវឿន បានធ្វើសកម្មភាពត្រៀមសម្រាប់ការបោះឆ្នោត ក្នុងនាមជាប្រធានក្រុមការងារប្រចាំស្រុកស្វាយអន្ទរ និងស្រុកកញ្ច្រៀច ក្នុងខេត្តព្រៃវែង និងជាថ្មីទៀត បានបញ្ជូនមន្ត្រីក្រោមបង្គាប់ឱ្យទៅធ្វើការងារទាំងនោះជំនួសមុខគាត់។[560]

លោក នេត សាវឿន និងកម្លាំងស្ថិតនៅក្រោមបញ្ជារបស់លោក បានដើរតួនាទីដោយផ្ទាល់ក្នុងការចាត់វិធានការកម្ទេចគណបក្សសង្គ្រោះជាតិ។ នៅចុងខែសីហា ២០១៧ លោក នេត សាវឿន ត្រូវបានចាត់តាំងឱ្យស៊ើបអង្កេតអំពីការគាំទ្រពីបរទេសដល់អ្វី ដែលពួកគេកំណត់ថា ជាបដិវត្តពណ៌របស់គណបក្សសង្គ្រោះជាតិ។[561] នៅថ្ងៃដែលនគរបាលចាប់បញ្ជូនលោក កឹម សុខា (ប្រធានគណបក្សសង្គ្រោះជាតិ) ទៅឃុំឃាំង មន្ត្រីនគរបាលជាន់ខ្ពស់ និងនគរបាលកម្រិតធម្មតាទាំងអស់នៃអគ្គស្នងការនគរបាលជាតិរបស់លោក នេត សាវឿន បានថ្កោលទោសលោក កឹម សុខា ថាបានប្រព្រឹត្ត "អំពើក្បត់ជាតិ" និង "ឃុបឃិតជាមួយជនបរទេស" និង

---

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧), "របាយការណ៍ក្រសួងមហាផ្ទៃអួតអំពី ការបង្រ្កាបលើបាតុកម្មនយោបាយ" *ខេមបូឌា ដេលី* ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ https://www.cambodiadaily.com/news/interior-ministry-report-boasts-of-crackdown-on-political-protests-125669/ (ចូលមើល នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧)។

[559] "នាយឧត្តមសេនីយ៍ នេត សាវឿន អញ្ជើញបិទសន្និបាតបូកសរុបការងារសន្តិសុខឆ្នាំ២០១៦ និងលើកទិសដៅឆ្នាំ២០១៧ របស់ស្នងការរាជធានីភ្នំពេញ" ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧ http://www.freshnewsasia.com/index.php/en/localnews/46625-2017-02-09-02-46-01.html (ចូលមើល នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧)។

[560] "នាយឧត្តមសេនីយ៍ នេត សាវឿន ផ្តល់អង្ករជិត ៣០ តោន ចែកជូនប្រជាពលរដ្ឋខ្វះខាតនៅស្រុកស្វាយអន្ទរ និងស្រុកកញ្ច្រៀច,ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៦ http://www.freshnewsasia.com/index.php/en/localnews/39253-2016-11-12-07-30- 23.html (ចូលមើល នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៦), "នាយឧត្តមសេនីយ៍ នេត សាវឿន ស្នើឲ្យក្រុមការងារឃុំ ជំរុញប្រជាពលរដ្ឋឲ្យពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះបោះឆ្នោត" ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៧ http://www.freshnewsasia.com/index .php/en/localnews/43763-2017-01-07-06-05-25.html html (ចូលមើល នៅថ្ងៃទី៧ ខែមករា ឆ្នាំ២០១៧), "នាយឧត្តមសេនីយ៍ នេត សាវឿន ជំរុញឲ្យបេក្ខជនក្រុមប្រឹក្សាឃុំ ចុះស្វែងយល់ សួរសុខទុក្ខជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន", ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ http://www.freshnewsasia.com/index.php/en/localnews/48110-2017-02-25-06-40-50.html (ចូលមើល នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧), "លោក សុខ ខេមរិន ចូលរួមជាអធិបតីក្នុងពិធីឆ្លងសមិទ្ធិផលនានាក្នុងវត្តធម្មកេរ្តិ៍ នៅឃុំកញ្ជៀច ខេត្តព្រៃវែង" ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ http://www.freshnewsasia.com/index.php/en/localnews/45423-2017-01-25- 04-53-11.html (ចូលមើលនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧)។

[561] រដ្ឋាភិបាល ឱ្យពិនិត្យលើមូលនិធិគណបក្ស ជាផ្នែកមួយនៃការស៊ើបអង្កេត "បដិវត្តពណ៌" ថ្ងៃព្រហស្បតិ៍ ទី៣១ ខែសីហា ឆ្នាំ២០១៧។

បានបញ្ជាក់នូវការគាំទ្ររបស់ពួកគេចំពោះការចាប់ខ្លួននោះ។[562] នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧ អគ្គស្នងការនគរបាលជាតិ បានផ្សព្វផ្សាយបទបង្ហាញមួយដែលយោងលើឯកសារនានាចងក្រងដោយលោក ឆាយ ស៊ីណារិទ្ធិ ជាអគ្គស្នងការរងមួយរូបក្នុងចំណោមអគ្គស្នងការរងផ្សេងទៀតរបស់លោក នេត សាវឿន ដែលរៀបចំឡើង ដើម្បីបង្ហាញនូវរចនាសម្ព័ន្ធ និងអង្គការចាត់តាំងនូវអ្វីដែលឯកសារចោទថា ជាផែនការសម្ងាត់ធ្វើបដិវត្តពណ៌ ដោយមានគណបក្សសង្គ្រោះជាតិដើរតួនាទីយ៉ាងសំខាន់ ។ ប៉ុន្តែឯកសារនោះក៏ព្យាយាមទាញបញ្ចូល អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ព្រមទាំងអង្គភាពរដ្ឋាភិបាលអាមេរិក និងអង្គភាពដែលទទួលការគាំទ្រពីរដ្ឋាភិបាលអាមេរិកមួយចំនួនទៀតផងដែរ។[563] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ លោក នេត សាវឿន និង "នគរបាលទូទាំងប្រទេស" បានសម្តែងនូវការគាំទ្រទាំងស្រុងរបស់ពួកគេ ចំពោះសាលដីការំលាយគណបក្សសង្គ្រោះជាតិ របស់តុលាការកំពូល ក្រោមហេតុផលថា គណបក្សនេះមានការពាក់ព័ន្ធក្នុង "អំពើក្បត់ជាតិ" និងគាំទ្រចំពោះការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យចាត់វិធានការជាមុនបន្ថែមទៀត ប្រឆាំងនឹងផែនការធ្វើបដិវត្តពណ៌ និងអ្នកនយោបាយ "ដែលកំពុងបម្រើផលប្រយោជន៍បរទេស"។[564]

---

[562] កម្លាំងនគរបាលទូទាំងប្រទេស ចេញថ្កោលទោសចំពោះទង្វើក្បត់ជាតិរបស់កឹមសុខា ហើយគាំទ្រចំពោះការចាប់ខ្លួន។

[563] កម្លាំងរបស់នាយឧត្តមសេនីយជួនសុវណ្ណប្រកាសថា ធនាគារ មុខជំនួញ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថ្មីៗបំផុត សង្ស័យនៅក្នុង "បដិវត្តពណ៌" ម៉ិច ដារា និង Ananth Baliga ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧, ការវិភាគ៖ រដ្ឋាភិបាលរើសយកផែនការរបស់នគរបាល សម្រាប់បង្ក្រាប "បដិវត្តពណ៌" ម៉ិច ដារា និង Brendan O´Byrne ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ Banks, businesses, and MFIs latest suspects in ʽcolour revolution,´ Mech Dara and Ananth Baliga, October 24, 2017; Analysis: Government picking up police´s blueprint for a ʽcolour revolution´ crackdown, Mech Dara and Brendan O´Byrne, November 29, 2017 ។ កម្លាំងនគរបាលទូទាំងប្រទេស ចេញថ្កោលទោសលើទង្វើក្បត់ជាតិរបស់កឹមសុខា ហើយគាំទ្រចំពោះការចាប់ខ្លួន។

[564] កងទ័ពយោធភូមិភាគ ៤ គាំទ្រចំណាចាត់ការរាជរដ្ឋាភិបាល និងថ្កោលទោសចំពោះទង្វើក្បត់ជាតិរបស់កឹមសុខា ឃុបឃិតបរទេសប៉ុនប៉ងដណ្តើមអំណាច។

## V. ឧត្តមសេនីយ៍ឯកផ្កាយមាស ៣ ជា ម៉ន មេបញ្ជាការរង កងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី ៤

### *លោក ជា ម៉ន នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ពីឆ្នាំ ១៩៧៩ ដល់ ១៩៩១*

*រួមជាមួយនឹងលោក សៅ សុខា និងលោក ជឿន សុវណ្ណថា (សូមមើលព័ត៌មានខាងក្រោម) លោក ជា ម៉ន ដែលមានថ្ងៃខែឆ្នាំកំណើតជាផ្លូវការ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៥២ បាននៅជាមួយលោក ហ៊ុន សែន នៅប្រទេសវៀតណាម ក្នុងឆ្នាំ១៩៧៨ បន្ទាប់ពីលោក ហ៊ុន សែន បានភៀសខ្លួនទៅកាន់ទីនោះ។ ក្នុងនាមជាប្រធាន "គណៈបញ្ជាការលេខ ៥៧៨" នាពេលក្រោយមក លោក ហ៊ុន សែន ក៏បានបង្កើតអង្គភាពប្រដាប់អាវុធ ដើម្បីប្រយុទ្ធជាមួយនឹងរបបខ្មែរក្រហមរបស់ ប៉ុល ពត។[565] គិតត្រឹមឆ្នាំ១៩៨៧ លោក ជា ម៉ន បានក្លាយជាមេបញ្ជាការរងកងពលកងទ័ពជាតិលេខ ១៧៩ ដ៏មានអំណាចនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។[566] អង្គភាពនេះ ប្រតិបត្តិការនៅប៉ែកពាយ័ព្យនៃប្រទេសកម្ពុជា ក្រោមបញ្ជាការនៃយោធភូមិភាគទី ៤ របស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមរបស់ ប៉ុល ពត ដែលនៅសេសសល់ និងក្រុមប្រដាប់អាវុធផ្សេងទៀត ដែលប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដូចជាហ៊្វុនស៊ិនប៉ិច ជាដើម។[567]*

*នៅឆ្នាំ១៩៨៩ លោក ជា ម៉ន បានក្លាយជាមេបញ្ជាការយោធភូមិភាគទី ៤ នៅពេលដែលខេត្តសៀមរាប*

---

[565] បញ្ជីឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតបណ្ដោះអាសន្ន ឆ្នាំ២០១៧ ឯកសារ ០៨-៩៥៥-១៧០, ហ៊ុន សែន "សុន្ទរកថា នៅខួបលើកទី ៤ នៃទិវាអតីតយុទ្ធជនកម្ពុជា" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ http://cnv.org.kh/address-at-the-4th-anniversary-of-cambodian-veterans-day/ (ទទួលបាន ឬ បានអាន នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២), ហ៊ុន សែន "យោបល់នានា ដែលត្រូវបានជ្រើសរើស នៅឯពិធីប្រារព្ធខួបលើកទី ៤ នៃអតីតយុទ្ធជនកម្ពុជា" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ http://cnv.org.kh/selected-comments-at-the-celebration-of-the-4th-anniversary-of-the-cambodian-war- veterans/ (ទទួលបាន ឬ បានអាន នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២) "ផ្នែកនៃប្រវត្តិសាស្ត្រ និង "កងទ័ពស្ម័គ្រចិត្តវៀតណាម" (*quân tình nguy�n Vi�t Nam*), ផ្សព្វផ្សាយនៅក្នុង http://www.vnmilitaryhistory.net/index.php?topic=16326.160;wap2 (ទទួលបាន ឬ បានអាន នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៤) Carney, "កងកម្លាំងប្រដាប់អាវុធរបស់លោក ហេងសំរិន" ទំព័រ ១៦០។

[566] វិទ្យុភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៨៧។

[567] វិទ្យុភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៨៤។

ឧត្តរមានជ័យ និងបន្ទាយមានជ័យ ស្ថិតនៅចំណុះភូមិភាគនេះ។[568] កងទ័ពនៅក្នុងភូមិភាគនេះ រួមមាន "កងកម្លាំងជាប្រចាំ" ដែលរួមមានយ៉ាងហោចណាស់ កងពលតូចមួយ និងកងវិរសេនាធំមួយចំនួន បូករួមនឹងកងវិរសេនាតូចខេត្ត និងស្រុក។[569] កងទ័ពទាំងអស់នេះ បានប្រតិបត្តិការរួម ជាមួយកងពលថ្នាក់កណ្តាល មួយ ឬលើសពីមួយ ដែលត្រូវបានដាក់ពង្រាយនៅក្នុងសមរភូមិ រួមទាំងអង្គភាពចាស់របស់លោក ជា ម៉ន នោះគឺ កងពលលេខ ១៧៩។[570] ដោយធ្វើការងារជាមួយកងជីវពល និងនគរបាលក្នុងមូលដ្ឋាន ជាលក្ខណៈ "ចម្រុះចូលគ្នា" កងកម្លាំងទាំងនេះ ធ្វើការចាប់ខ្លួន "សមាសភាពសត្រូវ ដែលបង្កប់ខ្លួន" និងសមាជិកនៃ "បណ្តាញសត្រូវសម្ងាត់" នៅក្នុងចំណោមពលរដ្ឋ។[571] អ្នកដែលត្រូវចាប់ខ្លួនទាំងនោះ ត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារ ដែលគ្រប់គ្រងដោយយោធាតំបន់ និងពន្ធនាគារថ្នាក់ខេត្ត ជាកន្លែងដែលជនជាប់ឃុំត្រូវបានឃុំឃាំងដោយគ្មានការជំនុំជម្រះ។ ពួកគេភាគច្រើនទទួលទារុណកម្ម ជាទូទៅ គឺនៅមុនពេលបញ្ជូនទៅកាន់ពន្ធនាគារខេត្តរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅក្នុងខេត្តសៀមរាប ក៏ជាកន្លែងដែលពួកគេត្រូវបានឃុំឃាំងដោយគ្មានការជំនុំជម្រះ ដែរ។[572] អ្នកដែលត្រូវចាប់ខ្លួនក៏រួមមានសត្រូវដែលត្រូវបានគេចោទប្រកាន់ ក្នុងតួនាទីនៅក្នុងជួរកងកម្លាំងរដ្ឋាភិបាល ផងដែរ។[573]

## លោក ជា ម៉ន និង អ៊ុនតាក់ ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៣

នៅក្នុងឆ្នាំ១៩៩០ លោក ជា ម៉ន ត្រូវបានផ្លាស់តួនាទីចេញពីមេបញ្ជាការយោធភូមិភាគទី ៤ ប៉ុន្តែបន្ទាប់ពី

---

568 វិទ្យុភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៨៩ វិទ្យុភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៨៩។

569 វិទ្យុភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ វិទ្យុភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៨៩ វិទ្យុភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៨៩ វិទ្យុភ្នំពេញ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៨៩វិទ្យុភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩។

570 វិទ្យុភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៨៩ វិទ្យុភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨៩ វិទ្យុភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩០។

571 វិទ្យុភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៨៩ វិទ្យុភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៨៩ វិទ្យុភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៨៩ វិទ្យុភ្នំពេញ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៩០ វិទ្យុភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៩០ វិទ្យុភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩០។

572 អង្គការ Amnesty International មានកំណត់ត្រា ដាក់ចំណងជើងថា "ពន្ធនាគារនានា នៅក្នុងរបបសាធារណរដ្ឋប្រជាមានិត កម្ពុជា" ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៨៦ ដែលត្រូវរៀបចំចងក្រង សម្រាប់អង្គការ Amnesty International, ការចាប់ដាក់ពន្ធនាគារមានចរិតនយោបាយ និងអង្គការ Amnesty International មានកំណត់ត្រា ស្តីពី ការសម្ភាសន៍ជាមួយអតីតទណ្ឌិតនៃ "ពន្ធនាគារពិសេស នៅក្នុងទីជនបទ ក្នុងខេត្តសៀមរាប" នៅក្នុងកំណត់ត្រាដែលមានចំណងជើងថា "អំពើឃោឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ឬ ទណ្ឌកម្ម លើអ្នកទោសនយោបាយ" ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៨៦ ដែលត្រូវរៀបចំចងក្រង សម្រាប់អង្គការ Amnesty International, ការចាប់ដាក់ពន្ធនាគារមានចរិតនយោបាយ អនុស្សារណៈដែលត្រូវបានរៀបចំចងក្រងសម្រាប់អង្គការ Amnesty International, "របាយការណ៍ស្តីពី បេសកកម្មទៅកាន់ព្រំដែនថៃ-កម្ពុជា" ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩១ អង្គការ Amnesty International, "ការអភិវឌ្ឍន៍ផ្នែកសិទ្ធិមនុស្ស ក្នុងរបបរដ្ឋកម្ពុជា ៖ ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ១៩៩១ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩២" (ASA 23/002/1992).

573 អង្គការ Amnesty International "កម្ពុជា ៖ ការអភិវឌ្ឍន៍ផ្នែកសិទ្ធិមនុស្ស នៅពេលថ្មីៗនេះ" (AI Index: ASA 23/07/90), ខែធ្នូ ឆ្នាំ១៩៩០។

កិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅខែតុលា ឆ្នាំ១៩៩១ មក គាត់បានលេចមុខវិញ នៅក្នុងយោធភូមិភាគ ៤ ជាបញ្ជាការរង។[574] បញ្ជាការភូមិភាគនេះ បន្តត្រួតត្រាលើកងកម្លាំងប្រដាប់អាវុធថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន និងសម្របសម្រួលសកម្មភាពរបស់ពួកគេ ជាមួយនគរបាលខេត្ត និងស្រុក។[575]

យោធភូមិភាគទី ៤ ស្ថិតក្នុងចំណោមតំបន់នានា នៅក្នុងប្រទេសកម្ពុជា ដែលកងកម្លាំងប្រដាប់អាវុធរបស់គណបក្សប្រជាជនកម្ពុជា មានជាប់ពាក់ព័ន្ធធ្ងន់ធ្ងរបំផុត ទៅនឹងការរំលោភសិទ្ធិមនុស្ស ទាក់ទងនឹងការតវ៉ាចំពោះការបោះឆ្នោត រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច។[576] យោងតាមអ៊ុនតាក់ គណបក្សប្រជាជនកម្ពុជា បានរៀបចំគម្រោងវាយប្រហារគណបក្សប្រឆាំងនៅក្នុងយោធភូមិភាគ ៤ នៅក្នុងកិច្ចប្រជុំមួយ ដែលរៀបចំនៅទីបញ្ជាការដ្ឋានក្នុងខេត្តសៀមរាប។

សកម្មភាពទាំងនេះ មានបំណងរាំងខ្ទប់សមត្ថភាពរបស់គណបក្សនយោបាយផ្សេងទៀត មិនឱ្យពង្រីកឥទ្ធិពលរបស់ខ្លួន និងបំបែកពួកគេចេញពីប្រជាជនទូទៅ តាមរយៈការដាក់សម្ពាធ និងបំភិតបំភ័យសាធារណជន ឱ្យសម្រេចចិត្តថា ការបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជា គឺមានសុវត្ថិភាពបំផុត ដែលត្រូវធ្វើ។ នៅក្នុងទីប្រជុំខេត្តសៀមរាប ដែលមានអ៊ុនតាក់តាមឃ្លាំមើលមិនដាក់ភ្នែក គណបក្សប្រជាជនកម្ពុជា ហាក់បានបង្ហាញពីការចូលរួមបើកចំហឱ្យមានសេរីភាពផ្នែកនយោបាយ ប៉ុន្តែនៅតាមទីជនបទគណបក្សនេះនៅតែតាំងចិត្តបង្ហាញនូវការត្រួតត្រាខ្ពស់បំផុតរបស់ខ្លួន។ អ៊ុនតាក់បានរកឃើញភស្តុតាងថា កងកម្លាំងថ្នាក់តំបន់ បានដាក់គ្រាប់មីន និងបានបាញ់កាំភ្លើងជំព្រមាន ដើម្បីរារាំងពលរដ្ឋធម្មតា មិនឱ្យតវ៉ាប្រឆាំងនឹងអំពើពុករលួយ និងការធ្វើបាបរបស់គណបក្សប្រជាជនកម្ពុជា។ កងទ័ពស្លៀកពាក់ឯកសណ្ឋានបានចូលលួចប្លន់យករបស់ទ្រព្យនៅក្នុងផ្សារខេត្តសៀមរាប។ អ៊ុនតាក់ក៏មានហេតុផល ដើម្បីជឿថា កងកម្លាំងថ្នាក់តំបន់ បានបង្កើតក្រុមប្រដាប់អាវុធឱ្យស្លៀកពាក់ស៊ីវិលចូលរួមក្នុងការវាយប្រហារផ្សេងទៀត ដើម្បីប្លន់ និងបំភិតបំភ័យប្រជាពលរដ្ឋ។ បន្ថែមលើនេះទៀត ជាផ្នែកមួយនៃយុទ្ធនាការឃោសនាបោះឆ្នោតជាផ្លូវការរបស់គណបក្សប្រជាជនកម្ពុជា កងទ័ពថ្នាក់តំបន់ បានប្រមូលផ្តុំទៅជាក្រុមចម្រុះជាមួយកងកម្លាំង

---

574 វិទ្យុភ្នំពេញ ថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩០ វិទ្យុភ្នំពេញ ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៩២។

575 អ៊ុនតាក់ ខាងផ្នែកយោធា "ការសម្ភាសន៍ជាមួយមន្ត្រីនយោបាយថ្នាក់តំបន់នៃយោធភូមិភាគទី ៤ វរសេនីយ៍ទោ ឯម សុគន្ធ" ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៣។

576 អ៊ុនតាក់ ខាងផ្នែករដ្ឋបាលស៊ីវិល "របាយការណ៍សកម្មភាពនៃអង្គភាពការពារ រយៈពេល ពីថ្ងៃទី១ ដល់៣១ ខែមករា ឆ្នាំ១៩៩៣" ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៣។

*សន្តិសុខផ្សេងទៀត ដើម្បីចុះតាមភូមិក្នុងគោលបំណងបញ្ចុះបញ្ចូលពលរដ្ឋឱ្យគណបក្សនេះ។*[577]

## *លោក ជា ម៉ន ចាប់ពីរដ្ឋាភិបាលចម្រុះ រហូតដល់ពេលរដ្ឋប្រហារ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ ១៩៩៧*

*លោក ជា ម៉ន បានបន្តធ្វើជាមេបញ្ជាការរងនៃកងយោធភូមិភាគទី ៤ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ និងក្រោយពេលបង្កើតរដ្ឋាភិបាលចម្រុះ គណបក្សហ៊្វុនស៊ិនប៉ិច-គណបក្សប្រជាជនកម្ពុជា និងការបង្កើតកងយោធពលខេមរភូមិន្ទ (RCAF)។*[578] *តំបន់ប្រតិបត្តិការរបស់គាត់ ត្រូវបានពង្រីក តាមរយៈអនុក្រឹត្យនាយករដ្ឋមន្ត្រី ដែលបានកំណត់ថា យោធភូមិភាគទី ៤ គ្របដណ្តប់ខេត្តកំពង់ធំ ព្រះវិហារ និងខេត្តសៀមរាប-ឧត្តរមានជ័យ។ ទោះជាយ៉ាងណា អនុក្រឹត្យនេះបានប្រគល់ខេត្តបន្ទាយមានជ័យ ទៅឱ្យយោធភូមិភាគទី៥។*[579]

*នៅក្នុងយោធភូមិភាគទី ៤ ថ្មី លោក ជា ម៉ន ស្ថិតនៅក្រោមលោក ខាន់ សាវឿន ដែលជាមេបញ្ជាការមកពីគណបក្សហ៊្វុនស៊ិនប៉ិច ប៉ុន្តែអំណាចយោធាលើសលប់ គឺស្ថិតនៅក្នុងដៃគណបក្សប្រជាជនកម្ពុជា។ ដោយសារហេតុនេះ លោក ជា ម៉ន ស្ថិតក្នុងតួនាទីដ៏រឹងមាំក្នុងការរៀបចំប្រតិបត្តិការប្រឆាំងគណបក្សហ៊្វុនស៊ិនប៉ិចនៅក្នុងយោធភូមិភាគទី ៤ ដែលជាផ្នែកមួយនៃរដ្ឋប្រហាររបស់លោក ហ៊ុន សែន នៅថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ ដោយប្រើប្រាស់អង្គភាពយោធាតំបន់ និងមូលដ្ឋាននៅក្រោមបញ្ជាការរបស់គាត់ ដោយសម្របសម្រួលជាមួយកងរាជអាវុធហត្ថ និងកងនគរបាលរបស់គណបក្សប្រជាជនកម្ពុជា នៅក្នុងខេត្តសៀមរាប។*[580] *នៅពេលហេតុការណ៍នោះបានកើតឡើង លោក ខាន់ សាវឿន បានព្យាយាមរៀបចំកិច្ចព្រមព្រៀងមិនប្រយុទ្ធគ្នានៅក្នុងខេត្តសៀមរាប ប៉ុន្តែត្រូវបានទាត់ចោល។*[581] *គណបក្សប្រជាជនកម្ពុជា បានប្រមូលផ្តុំយុទ្ធជនប្រមាណ ៣០០ នាក់ ដើម្បីវាយប្រហារគណបក្សហ៊្វុនស៊ិនប៉ិច ដែលមិនបានវាយបកវិញឡើយ។*[582] *កងទ័ពគណបក្សប្រជាជនកម្ពុជាបានចាប់ខ្លួនអង្គរក្សរបស់លោក ខាន់ សាវឿន ពីរនាក់ ពីកងវរសេនាតូច*

---

[577] អ៊ុនតាក់ អង្គភាពព័ត៌មាន/ការអប់រំ "ដំណើរចុះមូលដ្ឋាន ទៅកាន់ខេត្តសៀមរាប" ថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩៣ អ៊ុនតាក់ អង្គភាពព័ត៌មាន/ការអប់រំ "របាយការណ៍ស្តីពី បរិយាកាសនយោបាយនៅក្នុងខេត្តសៀមរាប ៖ ការពិភាក្សាជាមួយគណបក្សនយោបាយនានា" ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៣។

[578] វិទ្យុភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៤។

[579] រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

[580] វិទ្យុភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៤ ការសម្ភាសន៍ជាមួយមន្ត្រីយោធាជាន់ខ្ពស់នៃគណបក្សហ្វ៊ុនស៊ិនប៉ិច ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៧។

[581] លោក Brad Adams សម្ភាសជាមួយលោក ខាន់ សាវឿន ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១។

[582] ពីប្រភពដដែល (Ibid.)

*អនុតំបន់លេខ ៣ នៅខេត្តសៀមរាប ហើយបន្ទាប់មកបានសម្លាប់ពួកគេ។[583] កងទ័ព និងកងរាជអាវុធហត្ថគណបក្សប្រជាជនកម្ពុជា បានគ្រប់គ្រង និងលួចប្លន់របស់របរពីផ្ទះរបស់មេបញ្ជាការនានានៃគណបក្សហ៊្វុនស៊ិនប៉ិច នៅក្រុងសៀមរាប។ កងទ័ពរបស់គណបក្សហ៊្វុនស៊ិនប៉ិចប្រមាណ ៨០ ទៅ ៩០ នាក់ ត្រូវបានចាប់ខ្លួន ដកអាវុធ និងឃុំឃាំងនៅក្នុងមណ្ឌលហ្វឹកហ្វឺននៃបញ្ជាការដ្ឋានយោធភូមិភាគទី ៤។ កងទ័ពគណបក្សហ៊្វុនស៊ិនប៉ិចជាច្រើនផ្សេងទៀត ដែលត្រូវបានចាប់ខ្លួននៅក្នុងខេត្ត និងស្រុកមួយចំនួន ដូចជា ស្រុកពួក ក៏ត្រូវបានឃុំឃាំងដើម្បីសួរចម្លើយនៅផ្ទះរបស់មេបញ្ជាការយោធភូមិភាគទី ៤ ដែលបានធ្វើការសួរសំនួរមួយចំនួន ដោយខ្លួនគាត់ផ្ទាល់។ ពួកគេជាច្រើននាក់បានទទួលរងនូវការវាយដំនៅពេលសួរចម្លើយ និងបង្ខំឱ្យបង់លុយជាថ្នូរនឹងការដោះលែង។[584]*

*នៅស្រុកវ៉ារិន ខេត្តសៀមរាប ក្នុងយោធភូមិភាគទី ៤ កងទ័ពគណបក្សប្រជាជនកម្ពុជា បានចាប់ខ្លួន និងសម្លាប់បុរសម្នាក់នៅក្នុងមូលដ្ឋាន ដោយពួកគេចោទប្រកាន់បុរសនោះថា បានក្បត់គណបក្សប្រជាជនកម្ពុជា ទៅចូលរួមជាមួយគណបក្សហ៊្វុនស៊ិនប៉ិច។[585] អធិការនគរបាលស្រុកប្រាសាទបាគង និងមេប៉ុស្តិ៍ឃុំកំពង់ភ្លុក បានឃុំខ្លួនទាហានហ៊្វុនស៊ិនប៉ិចបីនាក់ និងអ្នកជំនួញបីនាក់ ដែលមានទំនាក់ទំនងជាមួយគណបក្សហ៊្វុនស៊ិនប៉ិច ហើយអ្នកទាំងអស់ត្រូវបង់លុយសូកប៉ាន់ ដើម្បីទទួលបានសេរីភាពវិញ។ ស្រដៀងគ្នានេះដែរ នៅក្នុងស្រុកក្រឡាញ់ មេបញ្ជាការយោធាគណបក្សប្រជាជនកម្ពុជា បានចាប់ខ្លួនមន្ត្រីជាន់ខ្ពស់ហ៊្វុនស៊ិនប៉ិចនៅក្នុងស្រុកនេះ ដែលមន្ត្រីនោះបានផ្តល់ឈ្មោះរបស់សមាជិកគណបក្សហ៊្វុនស៊ិនប៉ិចផ្សេងទៀត (ឆ្លើយដាក់) នៅពេលសួរចម្លើយ។ មន្ត្រី ១២នាក់ ត្រូវបានឃុំខ្លួន និងតម្រូវឱ្យបង់លុយសូកប៉ាន់ ដើម្បីរួចផុតពីការឃុំ  ឃាំង។ បុរសម្នាក់ ដែលជាមេបញ្ជារងនៃវរសេនាតូចចារកម្មនៃអង្គភាពដែលស្ថិតក្រោមការគ្រប់គ្រងភាគច្រើនរបស់គណបក្សហ៊្វុនស៊ិនប៉ិច ក៏ត្រូវបានឃុំខ្លួននៅក្នុងស្រុកនេះដែរ។ ទោះបីជាគាត់បានប្រគល់ខ្លួន និងអាវុធរបស់គាត់ក៏ដោយ ក៏គាត់នៅទទួលរងការវាយដំរហូតដល់សន្លប់នៅក្នុងពេលសួរចម្លើយដែរ។[586] នៅក្នុងស្រុកក្រឡាញ់នេះផងដែរ យោធាគណបក្សប្រជាជនកម្ពុជា បានចាប់ខ្លួនអ្នកដឹកនាំគណបក្សហ៊្វុន*

---

583 លោក Thomas Hammerberg "អនុស្សរណៈទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវដាក់ជូនដោយតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា" ថ្ងៃ១៣ ខែឧសភា ឆ្នាំ១៩៩៨។

584 COHCHR, "របាយការណ៍ទី២៨ ស្តីពី សកម្មភាពនានានៃការិយាល័យនៅសៀមរាប ខែកក្កដា ឆ្នាំ១៩៩៧" ថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧។

585 លោក Thomas Hammerberg "អនុស្សរណៈ ទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវដាក់ជូនដោយតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា" ថ្ងៃ១៣ ខែឧសភា ឆ្នាំ១៩៩៨។

586 COHCHR, "របាយការណ៍ទី២៨ ស្តីពី សកម្មភាពនានានៃការិយាល័យនៅសៀមរាប ខែកក្កដា ឆ្នាំ១៩៩៧" ថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧។

*ស៊ិនប៊ិចក្នុងមូលដ្ឋានម្នាក់ ចងគាត់ភ្ជាប់នឹងសសរបង្គោល ហើយវាយគាត់នឹងកាំភ្លើងខ្លី ព្រមទាំងវាយដំធ្វើបាបគាត់ ជាច្រើនថែមទៀត។*[587]

*ហ៊ុំព័ទ្ធដោយបញ្ហាទាំងអស់នេះ លោក ខាន់ សាវឿន ជាមួយអ្នកដឹកនាំឯទៀត ព្រមទាំងកងទ័ពគណបក្សហ៊្វុនស៊ិនប៊ិចផ្សេងទៀត បានសម្រេចចិត្តវាយបកវិញ នៅខណៈដកទ័ពទៅកាន់តំបន់ជាប់ព្រំដែនថៃ ជាទីដែលពួកគេបានចាប់ផ្តើមការប៉ុនប៉ងប្រដាប់អាវុធប្រឆាំងលោក ហ៊ុន សែន។*[588]

## *លោក ជា ម៉ន បន្ទាប់ពីរដ្ឋប្រហារ ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០១៣*

*ដោយមានមេបញ្ជាការដែលមានតែឈ្មោះរបស់គាត់ គឺលោក ខាន់ សាវឿន ដែលក្រោយមកបានបាត់ឈ្មោះនោះ លោក ជា ម៉ន បានទទួលតំណែងជាមេបញ្ជាការយោធភូមិភាគទី ៤ ហើយបន្តកាន់តំណែងនេះរហូតមកដល់បច្ចុប្បន្ន។ នៅខែវិច្ឆិកា ឆ្នាំ១៩៩៧ គាត់បានទទួលការចាត់តាំងជាទីប្រឹក្សារបស់លោក ហ៊ុន សែន ដោយមានតួនាទីក្នុងរដ្ឋាភិបាលជាអនុរដ្ឋលេខាធិការ (ក្រោយមកទៀត ឡើងទៅជារដ្ឋលេខាធិការ)។*[589] *នៅឆ្នាំ១៩៩៧ នេះផងដែរ គាត់បានក្លាយទៅជាសមាជិកគណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា និងមេបញ្ជាការរងកងទ័ពជើងគោក។*[590] *ត្រឹមឆ្នាំ២០០៣ លោក ជា ម៉ន បានគ្រប់គ្រងកងទ័ពប្រមាណ ២០.០០០ (ពីរម៉ឺន) នាក់ នៃយោធភូមិភាគទី ៤ រាប់បញ្ចូលទាំងកងពលតូចតំបន់លេខ ៤១ ៤២ និង៤៣ នៅក្នុងកងវរសេនាតូចនានា និងក្រុមកងទ័ពតូចៗផ្សេងទៀត នៅក្នុងផ្នែកសឹករងយោធាចំនួនបួននៃខេត្តសៀមរាប កំពង់ធំ ឧត្តរមានជ័យ និងព្រះវិហារ ដែលមានរចនាសម្ព័ន្ធដល់ថ្នាក់ស្រុក បូករួមនឹងកងវរសេនាតូចមួយចំនួននៃកងកម្លាំងការពារព្រំដែន។ អង្គភាពអន្តរាគមន៍ពិសេសថ្នាក់ជាតិ ២ ក៏ត្រូវបានដាក់ពង្រាយនៅក្នុងយោធភូមិភាគទី ៤ ផងដែរ។*[591]

---

587 COHCHR, "ការប្រាស្រ័យទាក់ទងគ្នាផ្សេងៗ ដែលទទួលបាននៅសប្តាហ៍មុន" ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៧។

588 លោក Brad Adams សម្ភាសជាមួយលោក ខាន់ សាវឿន ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១។

589 រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ ឆស/រកត/១០៩៧/២១១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧, រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ ChS/រកត/១១៩៧/២៤៦ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៧, រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ នស/រកត/២០០៨/១០៨៣ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៨។

590 គ្មានចំណងជើង http://www.cpp.org.kh/category.php?mnu=3 (ចូលមើល នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០១) "ពិធីបិទវគ្គហ្វឹកហ្វឺន និងក្បួនព្យុះហយាត្រាយោធានៃកងវរសេនាតូចលេខ ១ ផ្នែកសឹករងយោធាខេត្តកំពង់ធំ" ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ http://kpt-news.com/local-news/29212-2013-06-13-06-15-50.html (ចូលមើល នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣)។

591 ស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា "គម្រោងក្របខណ្ឌការងារយោធា-នយោបាយ" ឆ្នាំ២០០៣ បញ្ជាការជាន់ខ្ពស់ RCAF "ការរៀបចំអគ្គបញ្ជាការ

ក្នុងអំឡុងពេលឈានទៅរកការបោះឆ្នោតសភាជាតិឆ្នាំ១៩៩៨ យោធភូមិភាគទី ៤ បានបន្តចូលរួមនៅក្នុងឃាតកម្មនយោបាយ ដែលផ្ដោតលើគណបក្សហ៊្វុនស៊ិនប៉ិច។[592] តុលាការនៃរាជរដ្ឋាភិបាលកម្ពុជា បានទទួលការណែនាំមិនឱ្យកាត់ក្ដីករណីបែបនេះឡើយ។[593] ក្នុងរយៈពេលនេះផងដែរ យោធភូមិភាគទី ៤ ទទួលការចោទប្រកាន់អំពីការសម្លាប់ក្រៅប្រព័ន្ធតុលាការ មិនពាក់ព័ន្ធនឹងនយោបាយ ហើយជនរងគ្រោះត្រូវបានចោទប្រកាន់ថា ជាចោរ។[594] យោងតាមកំណត់ត្រានានានៃអង្គការមិនមែនរដ្ឋាភិបាល ចាប់ពីឆ្នាំ២០០០មក កងកម្លាំងយោធភូមិភាគទី ៤ បានបន្តចូលរួមពាក់ព័ន្ធនឹងឃាតកម្ម ការប៉ុនប៉ងឃាតកម្ម ការបំពារបំពាន និងការគំរាមកំហែងសម្លាប់ និងការបំភិតបំភ័យលក្ខណៈនយោបាយ ការបង្កការភ័យខ្លាច នៅក្នុងចំណោមពលរដ្ឋ។[595] នៅក្នុងបរិបទនៃការរឹបអូសដីធ្លីដោយខុសច្បាប់ និងរំលោភដីធ្លី រួមទាំង ការបណ្ដេញចេញដោយបង្ខំ ផងដែរ កងទ័ពយោធភូមិភាគទី ៤ បានប្រព្រឹត្តិឃាតកម្ម ទារុណកម្ម ការគំរាមសម្លាប់ ការរំលោភសេពសន្ថវៈ ការគំរាមយកប្រាក់ ការបំបាត់ខ្លួនមនុស្ស និងការឃុំខ្លួនតាមទំនើងចិត្ត។[596]

## លោក ជា ម៉ន ក្នុងពេល និងក្រោយពេលបោះឆ្នោតឆ្នាំ ២០១៣

ក្នុងអំឡុងពេលយុទ្ធនាការសម្រាប់ការបោះឆ្នោតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ លោក ជា ម៉ន បានបង្ហាញយ៉ាងចំហក្នុងភាពជាដៃគូនយោបាយរបស់ខ្លួន តាមរយៈការធ្វើយុទ្ធនាការឱ្យគណបក្សប្រជាជនកម្ពុជា នៅក្នុងការប្រកួតប្រជែងជាមួយគណបក្សសង្គ្រោះជាតិ ក្នុងតួនាទីជាប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជា ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។[597] ក្នុងខេត្តឧត្តរមានជ័យ នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៤ កងពលតូចតំបន់៤ និងកងកម្លាំងផ្សេងទៀត នៅក្នុងតំបន់នោះ ដោយពាក់ឯកសណ្ឋាន និងមិនពាក់ឯកសណ្ឋាន

---

RCAF″ ឆ្នាំ២០០៦។

[592] អង្គការ Amnesty International "ព្រះរាជាណាចក្រកម្ពុជា ៖ សិទ្ធិមនុស្សស្ថិតក្នុងហានិភ័យ″ (AI Index ASA 23/04/98) ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៩៨។

[593] ការសម្ភាសន៍ជាមួយមន្ត្រីតុលាការកម្ពុជា ថ្ងៃ៦ ខែមេសា ឆ្នាំ២០១៤។

[594] អង្គការអាដហុក លីកាដូ និងអង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ និទណ្ឌភាពនៅកម្ពុជា ៖ តើជនល្មើសសិទ្ធិមនុស្សគេចចេញពីយុត្តិធម៌ដោយវិធីណា ៖ របាយការណ៍របស់អង្គការ  អាដ ហុក លីកាដូ និងអង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ (ខែមិថុនា ឆ្នាំ១៩៩៩) ទំព័រ ៣០ https://www.licadhocambodia.org/reports/files/21Impunity%20in%20Cambodia.pdf (ចូលមើលនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២)។

[595] ពីប្រភពដដែល Ibid.

[596] ពីប្រភពដដែល Ibid.

[597] "លោក គន់ គីម សម្ពោធអគារ និងសមិទ្ធផលនានារបស់គណបក្សប្រជាជនកម្ពុជា នៅស្រុកត្រពាំងប្រាសាទ″ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១ http://www.kpt-news.com/local-news/29760-2013-06-22-08-16-51.html (ទទួលបាន ឬ បានអាន នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៣)។

បានធ្វើប្រតិបត្តិការរារាំងលោក សម រង្ស៊ី មិនឱ្យរៀបចំការប្រមូលផ្តុំនយោបាយនៅក្នុងស្រុកអន្លង់វែងនៃខេត្តនេះ។[598]

នៅខែមិថុនា ឆ្នាំ២០១៥ លោក ជា ម៉ន បានណែនាំដល់កងទ័ពក្រោមបញ្ជាការរបស់ខ្លួនអំពី "ស្ថានភាពនយោបាយ" នៅក្នុងប្រទេសកម្ពុជា ដោយប្រាប់ពួកគេថា ពួកគេមានភារកិច្ចធ្វើការងារជាមួយកងកម្លាំងសន្តិសុខ និងអាជ្ញាធរស៊ីវិលផ្សេងទៀត ក្នុងការ "តាមដាន និងស្វែងរកគោលដៅ" ដើម្បីបង្ក្រាប ដោយសារពួកគេ "កំពុងបង្កឱ្យមានអសណ្តាប់ធ្នាប់សាធារណៈ" ដែលកងទ័ពត្រូវតែទប់ស្កាត់។[599] ការណែនាំនេះត្រូវបានអនុវត្តតាម នៅខែសីហា តាមរយៈការផ្សព្វផ្សាយក្នុងជួរកងទ័ពនៃយោធភូមិភាគទី៤ អំពីបទបញ្ជារបស់លោក ហ៊ុន សែន នៅខែកក្កដា ឆ្នាំ២០១៥ ថា កងកម្លាំងប្រដាប់អាវុធ ត្រូវតែ "ធានាថា គ្មានបដិវត្តពណ៌" នៅក្នុងប្រទេសកម្ពុជា និងថា ពួកគេត្រូវតែធ្វើកិច្ចការនេះ តាមរយៈ "ការលុបបំបាត់សកម្មភាពនានារបស់ក្រុម ឬគណបក្សណាមួយ" ដែលត្រូវចាត់ទុកថា "ខុសច្បាប់"។[600]

ខណៈនោះដែរ កងទ័ពនៃយោធភូមិភាគទី៤ របស់លោក ជា ម៉ន បានរួមចំណែកពាក់ព័ន្ធក្នុងការរំលោភសិទ្ធិមនុស្សនៅមូលដ្ឋាន និងមានការរំលោភយកដីធ្លី ដែលជួនកាលក៏មានការគំរាមកំហែងពីសំណាក់កងកម្លាំងប្រដាប់អាវុធ ឬជាការគំរាមកំហែងតាមរូបភាពផ្សេងទៀត ផងដែរ។[601]

លោក ជា ម៉ន បានចូលរួមជាមួយមេបញ្ជាការកងកម្លាំងសន្តិសុខផ្សេងទៀត ក្នុងការអបអរសាទរលោក ហ៊ុន សែន ដែលបានបញ្ចប់ការគំរាមកំហែងរបស់គណបក្សសង្គ្រោះជាតិ ចំពោះគណបក្សប្រជាជនកម្ពុជា នៅក្នុងការបោះឆ្នោត និងការបន្តធ្វើជានាយករដ្ឋមន្ត្រីរបស់គាត់។ គាត់បានប្រកាសគាំទ្រទាំងស្រុងចំពោះ

[598] "គណបក្សប្រឆាំង ៖ ជនស៊ីវិលដែលរាំងគណបក្សសង្គ្រោះជាតិ នៅលើផ្លូវ ក្នុងខេត្តឧត្តរមានជ័យ គឺជាយោធាមិនពាក់ឯកសណ្ឋាន", ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៤ http://vodhotnews.com/22025 (ចូលមើលនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤) ខ្សែវីដេអូស្តីពី ព្រឹត្តិការណ៍នានា ដែលអង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ។

[599] "ពិធីបើកវគ្គហ្វឹកហ្វឺនពង្រឹងមន្ត្រី និងកងទ័ពនៃកងវរសេនាតូចលេខ ៩០៨" ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ http://kampucheathmey.com/kpt/?p=24947 (ទទួលបាន ឬ បានអាន នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៥)។

[600] "ការផ្សព្វផ្សាយភារកិច្ច ៦ចំណុចដល់ពលទាហានរបស់សម្តេចតេជោ ហ៊ុន សែន" ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ http://kampucheathmey.com/kpt/?p=58142 (ទទួលបាន ឬ បានអាន នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥) ហ៊ុន សែន "ភារកិច្ចរបស់កងកម្លាំងប្រដាប់អាវុធ) ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥។

[601] ពីប្រភពដដែល Ibid.

*ការចាប់ខ្លួនលោក កឹម សុខា នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧ ដោយនិយាយថា វាគឺជាភាពចាំបាច់ ដើម្បីទប់ស្កាត់ភាពចលាចលប្រកបដោយគ្រោះថ្នាក់ នៅក្នុងសង្គមកម្ពុជា។*[602] *នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧ គាត់បានសច្ចាថា គាត់ និងកងកម្លាំងយោធភូមិភាគទី ៤ របស់គាត់ មានការប្តេជ្ញាចិត្តក្នុងការ "លុបបំបាត់" លោក សម រង្ស៊ី លោក កឹម សុខា និង "ជនក្បត់" ផ្សេងទៀត និងបានបញ្ជាក់នូវសេចក្តីស្រឡាញ់របស់ពួកគេចំពោះលោក ហ៊ុន សែន ។*[603] *នៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ លោក ជា ម៉ន និងមន្ត្រីទាំងអស់ផ្សេងទៀត នៃយោធភូមិភាគទី៤ បានសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងរបស់ពួកគេចំពោះសាលដីការំលាយគណបក្សសង្គ្រោះជាតិ ដោយតុលាការកំពូលពីទោស "ក្បត់ជាតិ" និងការគាំទ្រចំពោះការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យមានការចាត់វិធានការជាមុនបន្ថែមទៀតប្រឆាំងនឹងផែនការធ្វើបដិវត្តន៍ពណ៌ និងអ្នកនយោបាយ "ដែលកំពុងបម្រើផលប្រយោជន៍បរទេស"។*[604]

[602] កម្លាំងនគរបាលទូទាំងប្រទេស ចេញថ្កោលទោសចំពោះទង្វើក្បត់ជាតិរបស់កឹមសុខា ហើយគាំទ្រចំពោះការចាប់ខ្លួន។

[603] កម្លាំងរបស់នាយឧត្តមសេនីយជួនសុវណ្ណប្រកាសថា ធនាគារ មុខជំនួញ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថ្មីៗបំផុត សង្ស័យនៅក្នុង "បដិវត្តពណ៌" ម៉ិច ដារា និង Ananth Baliga ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧, ការវិភាគ៖ រដ្ឋាភិបាលរើសយកផែនការរបស់នគរបាល សម្រាប់បង្ក្រាប "បដិវត្តពណ៌" ម៉ិច ដារា និង Brendan O'Byrne ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ Banks, businesses, and MFIs latest suspects in 'colour revolution,' Mech Dara and Ananth Baliga, ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧; Analysis: រដ្ឋាភិបាលយកផែនការនគរបាលបង្ក្រាបបដិវត្តពណ៌, Mech Dara and Brendan O'Byrne, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧។ កម្លាំងនគរបាលទូទាំងប្រទេស ចេញថ្កោលទោសចំពោះទង្វើក្បត់ជាតិរបស់កឹមសុខា ហើយគាំទ្រចំពោះការចាប់ខ្លួន។

[604] កងទ័ពយោធភូមិភាគ ៤ គាំទ្រចំណាចាត់ការរាជរដ្ឋាភិបាល និងថ្កោលទោសចំពោះទង្វើក្បត់ជាតិរបស់កឹមសុខា ឃុបឃិតបរទេសប៉ុនប៉ងដណ្តើមអំណាច។

## VI. ឧត្តមសេនីយ៍ឯកផ្កាយមាស ៣ ប៊ុន សេង មេបញ្ជាការរងកងទ័ពជើងគោក និង ជាមេបញ្ជាការយោធភូមិភាគទី ៥

### *លោក ប៊ុន សេង នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១*

*ថ្ងៃខែឆ្នាំកំណើតផ្លូវការរបស់លោក ប៊ុន សេង គឺ ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៥២។[605] អត្តលេខយោធារបស់គាត់បង្ហាញថា គាត់គឺជាសមាជិកដំបូងម្នាក់នៃកងកម្លាំងប្រដាប់អាវុធនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រហែលជាបានចូលរួមនៅមុនឆ្នាំ១៩៧៩។[606] ត្រឹមឆ្នាំ១៩៩១ គាត់គឺជាមេបញ្ជាការកងទ័ពខេត្តពោធិសាត់ ដែលជាផ្នែកមួយនៃយោធភូមិភាគទី ៥ នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨៨ ហើយដំបូងឡើយរួមមានខេត្តបាត់ដំបង និងពោធិសាត់។ ការបង្កើតភូមិភាគនេះ គឺនៅចំពេលដែលតំបន់នេះជាសមរភូមិសំខាន់ ដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាវាយប្រហារប្រឆាំងនឹងកងទ័ពខ្មែរក្រហមរបស់ ប៉ុល ពត ដែលនៅសេសសល់ និងក្រុមប្រដាប់អាវុធផ្សេងទៀត ដូចជា ក្រុមដែលគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច។ ក្នុងនាមជាមេបញ្ជាការម្នាក់នៅក្នុងខេត្តមួយនៃយោធភូមិភាគទី ៥ លោក ប៊ុន សេង គឺជាសមាជិកម្នាក់នៃគណៈសេនាធិការបញ្ជាការ ដែលគ្រប់គ្រងប្រតិបត្តិការនៅទូទាំងតំបន់នេះ។[607] នៅក្នុងខេត្តពោធិសាត់ គាត់គ្រប់គ្រងដោយផ្ទាល់លើកងវរសេនាតូចចំនួនប្រាំពីរ បូករួមនឹងអង្គភាពគាំទ្រនានាទៀតផងដែរ។[608]*

### *លោក ប៊ុន សេង និង អ៊ុនតាក់ ចាប់ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ១៩៩៣*

*ក្នុងអំឡុងពេលក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស យោធភូមិភាគទី ៥ គឺជាភូមិភាគមួយ ក្នុងចំណោមភូមិភាគចំនួនបី ដែលកងកម្លាំងប្រដាប់អាវុធនៃគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន ជាប់ពាក់ព័ន្ធ*

---

[605] បញ្ជីឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតបណ្តោះអាសន្នឆ្នាំ២០១៧ ឯកសារ០០-៧៥៧-៩០៨។

[606] រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ ChS/រកត/១០៩៧/២១១ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧ (ផ្តល់អត្តលេខ ១៥៥ ដល់លោក ប៊ុន សេង ដែលជាការបង្ហាញថា បានចូលរួមនៅឆ្នាំ១៩៧៩ យ៉ាងយូរបំផុត)។

[607] អ៊ុនតាក់ "តើនរណាជានរណា" វិទ្យុភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩០ អ៊ុនតាក់ សេចក្តីសង្ខេបអំពីយោធា "CPAF ក្នុងផ្នែក ៨" ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩២។

[608] អ៊ុនតាក់ "តើនរណាជានរណា"។

យ៉ាងធ្ងន់ធ្ងរបំផុតក្នុងការរំលោភសិទ្ធិមនុស្សទាក់ទងនឹងការបោះឆ្នោតឆ្នាំ១៩៩៣។[609]

នៅក្នុងយោធភូមិភាគទី ៥ ដោយប្រតិបត្តិការតាមរយៈអង្គភាពយោធាតំបន់ និងកងកម្លាំងសន្តិសុខផ្សេងទៀត គណបក្សប្រជាជនកម្ពុជា បានអនុវត្តយុទ្ធនាការដ៏ពេញលេញ ក្នុងការគាបសង្កត់ផ្នែកនយោបាយដោយហិង្សា ក្នុងគោលបំណងរារាំងគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រឆាំងផ្សេងទៀត មិនឱ្យធ្វើសកម្មភាពនយោបាយស្របច្បាប់ និងបំភិតបំភ័យប្រជាពលរដ្ឋ ឱ្យបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា។ កងទ័ពទាំងនេះពាក់ព័ន្ធនឹងការគំរាមកំហែងយកប្រាក់ ការរំលោភសេពសន្ថវៈ និងអ្វីដែលអ្នកស៊ើបអង្កេតអង្គការសហប្រជាជាតិកំណត់ថាជា "ភាពហិង្សានិយម" ដោយបង្កើតបរិយាកាសភ័យខ្លាចជារួម ក្នុងចំណោមទាំងក្រុមប្រឆាំងនានា និងទាំងប្រជាពលរដ្ឋសាមញ្ញ។[610]

ដូចបានបង្ហាញខាងលើ មន្ត្រីមកពីសេនាធិការយោធភូមិភាគទី ៥ ដែលមានលោក ប៊ុន សេង ជាសមាជិក បានធ្វើការរួមគ្នាជាមួយមន្ត្រីមកពីយោធាចារកម្មនៅទីក្រុងភ្នំពេញក្នុងអង្គភាព ស៩១ ដែលបានប្រព្រឹត្តអំពើរំលោភសិទ្ធិធ្ងន់ធ្ងរមួយចំនួននៅក្នុងយោធភូមិភាគទី ៥ ក្នុងសម័យអ៊ុនតាក់។[611] ស៩១ ចាប់ឃុំខ្លួន និងសម្លាប់សមាជិក និងអ្នកគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច ព្រមទាំងរៀបចំការវាយប្រហារលើការិយាល័យគណបក្សហ៊្វុនស៊ិនប៉ិច រាប់បញ្ចូលទាំងប្រតិបត្តិការ ដែលបានសម្លាប់សកម្មជនរបស់គណបក្សហ៊្វុនស៊ិនប៉ិចផងដែរ។[612] បន្ទាប់ពីការបោះឆ្នោតនៅខែឧសភា ឆ្នាំ១៩៩៣មក ស៩១ បានផ្តោតលើការសម្លាប់ក្រៅប្រព័ន្ធតុលាការចំពោះជនល្មើសទូទៅ និងចាប់ជម្រិតអ្នកជំនួញ ដើម្បីទារប្រាក់។ ការសម្លាប់ ការឃុំខ្លួនខុសច្បាប់ និងការគំរាមយកប្រាក់របស់ក្រុមនេះ បានបន្តរហូតដល់ឆ្នាំ១៩៩៤ ដោយគ្មាននរណាម្នាក់ ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មរបស់ ស៩១ ឡើយ។[613]
នៅខណៈនោះដែរ អនុក្រឹត្យរបស់នាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៣ បានពង្រីកយោធភូមិ

---

[609] ផ្នែករដ្ឋបាលស៊ីវិលនៃអ៊ុនតាក់ "របាយការណ៍សកម្មភាពនៃអង្គភាពការពារ សម្រាប់រយៈកាលពីថ្ងៃទី១-៣១ ខែមករា ឆ្នាំ១៩៩៣" ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៣។

[610] អ៊ុនតាក់ អង្គភាពព័ត៌មាន/ការអប់រំ "បរិយាកាសនយោបាយនៅខេត្តបាត់ដំបង" ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩២, អ៊ុនតាក់ អង្គភាពព័ត៌មាន/ការអប់រំ "របាយការណ៍ស្តីពី ការបំភិតបំភ័យផ្នែកនយោបាយ នៅខេត្តបាត់ដំបង" ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៣។

[611] អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ***កម្ពុជានៅក្នុងសង្គ្រាម*** (ញូវយ៉ក៖ ឆ្នាំ១៩៩៥) ទំព័រ ៦៧-៦៩ COHCHR ការសម្ភាសន៍ជាមួយលោក ញឹក ប៊ុនឆៃ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩។

[612] អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ***កម្ពុជានៅក្នុងសង្គ្រាម*** (ញូវយ៉ក៖ ឆ្នាំ១៩៩៥) ទំព័រ ៦៩-៧២។

[613] អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ***កម្ពុជានៅក្នុងសង្គ្រាម*** (ញូវយ៉ក៖ ឆ្នាំ១៩៩៥) ទំព័រ ៧៧-៧៨, អង្គការ Amnesty International "ព្រះរាជាណាចក្រកម្ពុជា ៖ ការចុះថយនូវការគោរពសិទ្ធិមនុស្ស" (ASA 23/02/96) ខែឧសភា ឆ្នាំ១៩៩៦។

ភាគទី ៥ ដោយបញ្ចូលខេត្តទីបីមួយទៀត គឺខេត្តបន្ទាយមានជ័យ ដែលពីមុនមកជាផ្នែកមួយនៃយោធភូមិភាគទី ៤។[614] ពេលនោះលោក ប៊ុន សេង គឺជាមេបញ្ជាការរងម្នាក់ ក្នុងចំណោមមេបញ្ជាការរងផ្សេងទៀតនៃយោធភូមិភាគទី ៥។ មេបញ្ជាការរងម្នាក់ទៀតគឺលោក យៅ ឈាន ជាសមាជិកម្នាក់នៃក្រុមមិនមែនកុម្មុយនីស្ត ដែលមានជំហរមិនច្បាស់លាស់ចំពោះគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា ហើយមេបញ្ជាការរងទីបី គឺលោកថ្វាង ចង់ សុវណ្ណារិទ្ធិ ដែលជាមន្ត្រីគណបក្សហ៊្វុនស៊ិនប៉ិច។[615]

នៅខែវិច្ឆិកា ឆ្នាំ១៩៩៦ ជាផ្នែកមួយនៃការវិវឌ្ឍនៅតាមបណ្ដាខេត្តនានា ឆ្ពោះទៅកាន់ការប្រឈមមុខគ្នារបស់លោក ហ៊ុន សែន ជាមួយនឹងគណបក្សហ៊្វុនស៊ិនប៉ិចនៅទីក្រុងភ្នំពេញ គណបក្សប្រជាជនកម្ពុជា បានដាក់ចេញនូវយុទ្ធនាការដកហូតអាវុធពីគណបក្សហ៊្វុនស៊ិនប៉ិច នៅខេត្តបាត់ដំបង ដោយចោទថាអាវុធទាំងនោះជាអាវុធខុសច្បាប់។ គណបក្សហ៊្វុនស៊ិនប៉ិច បានប្រឆាំងតបតនឹងយុទ្ធនាការនោះ។[616] នៅដើមខែធ្នូ ឆ្នាំ១៩៩៦ ការប៉ះទង្គិចប្រដាប់អាវុធបានកើតឡើងនៅក្នុងខេត្តនោះ រវាងកងកម្លាំងយោធភូមិភាគទី ៥ និងកងកម្លាំងគណបក្សហ៊្វុនស៊ិនប៉ិច។[617] គណបក្សហ៊្វុនស៊ិនប៉ិច នៅតែបន្តរក្សាជំហរតបត ហើយការប្រយុទ្ធគ្នាក៏កើតមានជាបន្តបន្ទាប់។

នៅពេលលោក ហ៊ុន សែន ធ្វើរដ្ឋប្រហារ នៅខែកក្កដា ឆ្នាំ១៩៩៧ មេបញ្ជាការមកពីគណបក្សហ៊្វុនស៊ិនប៉ិច នៅក្នុងយោធភូមិភាគទី ៥ បានប្រតិកម្មខុសៗគ្នា។ លោក យៅ ឈាន បានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា។[618] មេបញ្ជាការរងតំបន់ មកពីគណបក្សហ៊្វុនស៊ិនប៉ិច លោក ថ្វាង ចង់ សុវណ្ណារិទ្ធិ បានធ្វើដំណើរទៅទីក្រុងភ្នំពេញ ជាទីដែលគាត់ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលដោយគណបក្សប្រជាជនកម្ពុជា ក្រោយពីមានការផ្ដល់ដំណឹងដល់លោក ហ៊ុន សែន អំពី ទីតាំងរបស់គាត់។[619] នៅខេត្តបាត់ដំបង មន្ត្រីមួយចំនួនរបស់

---

[614] រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

[615] រាជរដ្ឋាភិបាលកម្ពុជា សេចក្ដីសម្រេចលេខ ០៨ សសរ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៧ COHCHR "ព័ត៌មានពី [ត្រូវបានដកចេញ] មេបញ្ជាការរងរបស់អង្គភាពអន្តរាគមន៍នៃសេនាធិការ និងប្រពន្ធរបស់គាត់" ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៧។

[616] UNOSGRG, "របាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ១៩៩៦"។

[617] UNOSGRC, របាយការណ៍លេខ ៥៧២"។

[618] ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីយោធាជាន់ខ្ពស់នៃគណបក្សហ្វ៊ុនស៊ិនប៉ិច ខែកក្កដា ឆ្នាំ១៩៩៧។

[619] COHCHR "ព័ត៌មានពី [ត្រូវបានដកចេញ] មេបញ្ជាការរងរបស់អង្គភាពអន្តរាគមន៍នៃសេនាធិការ និងប្រពន្ធរបស់គាត់" ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៧, COHCHR "ព័ត៌មានពី [ត្រូវបានដកចេញ] ថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៩៧" ថ្ងៃទី២២ ខែ កក្កដា ឆ្នាំ១៩៩៧, UNHCR "ព័ត៌មានពីប្រភពនៅគណបក្សហ្វ៊ុនស៊ិនប៉ិច" ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៩៧។

គណបក្សហ៊្វុនស៊ិនប៉ិច ត្រូវបានចាប់ខ្លួន ប៉ុន្តែគ្មាននរណាម្នាក់ត្រូវបានសម្លាប់ឡើយ ហើយអ្នកដែលជាប់ឃុំឃាំង ត្រូវបានដោះលែងនៅពេលក្រោយមក ខណៈអ្នកផ្សេងទៀតបានភៀសខ្លួនទៅកាន់ព្រំដែនជាប់ប្រទេសថៃ ដើម្បីចូលរួមជាមួយលោក ញឹក ប៊ុនឆៃ ដែលជាមេបញ្ជាការជាន់ខ្ពស់ មកពីគណបក្សហ៊្វុនស៊ិនប៉ិច នៅទីនោះ។[620]

នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៧ មន្ត្រីគណបក្សប្រជាជនកម្ពុជា ដែលបញ្ជាលើយោធភូមិភាគទី ៥ លោក ហ៊ុល សាវ៉ន ដែលលោក ហ៊ុន សែន ជឿថា អនុវត្តការងារមិនបានល្អ នៅក្នុងពេលរដ្ឋប្រហារ ត្រូវបានផ្ទេរទៅកាន់ទីក្រុងភ្នំពេញ។[621] នៅថ្ងៃជាមួយគ្នានោះ លោក ប៊ុន សេង ដែលលោក ហ៊ុន សែន ជឿជាក់ថា អនុវត្តការងារបានល្អ ត្រូវបានចាត់តាំងជាទីប្រឹក្សារបស់លោក ហ៊ុន សែន ដែលមានឋានៈ នៅក្នុងរដ្ឋាភិបាលជាអនុរដ្ឋលេខាធិការ (ហើយក្រោយមក ឡើងជារដ្ឋលេខាធិការ)។[622] គាត់ក៏បានក្លាយជាសមាជិកនៃគណៈកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជាផងដែរ។[623] មួយរយៈក្រោយមក លោក យៅ ឈាន បានទទួលតំណែងជាមេបញ្ជាការយោធភូមិភាគទី ៥ ហើយលោក ប៊ុន សេង បន្តនៅធ្វើជាមេបញ្ជាការរង ប៉ុន្តែលោកប៊ុន សេង បានឡើងជំនួសគាត់ នៅខែមករា ឆ្នាំ១៩៩៩ និងបានក្លាយជាមេបញ្ជាការរងកងទ័ពជើងគោកលើផ្ទៃប្រទេស។[624]

នៅពេលនោះ ខណៈការបោះឆ្នោតសកលខែកក្កដា ឆ្នាំ១៩៩៨ ខិតជិតមកដល់ មន្ត្រីគណបក្សហ៊្វុនស៊ិន

---

[620] ការសម្ភាសន៍របស់លោក Brad Adams ជាមួយលោក ញឹក ប៊ុនឆៃ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០១ COHCHR "សេចក្តីរាយការណ៍អំពី ការចាប់ខ្លួនមន្ត្រីគណបក្សហ្វ៊ុនស៊ិនប៉ិច នៅតាមខេត្តនានា" [គ្មានកាលបរិច្ឆេទ], ការសម្ភាសន៍ជាមួយលោក ខាន់ សាវឿន និងលោក ញឹក ប៊ុនឆៃ ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៧។

[621] ការសម្ភាសន៍ជាមួយលោក ខាន់ សាវឿន និងលោក ញឹក ប៊ុនឆៃ ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៧, រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ ChS/រកត ០៧៩៧/១០១ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៧។

[622] ការសម្ភាសន៍ជាមួយលោក ខាន់ សាវឿន និងលោក ញឹក ប៊ុនឆៃ ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៧, រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ ChS/រកត/២០០៨/១០៨៣ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៨។

[623] http://www.cpp.org.kh/category.php?mnu=3 (ទទួលបាន ឬ បានអាន នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១២)។

[624] រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ ChS/រកត/១០៩៧/២១១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧, រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២៣ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៩៩, សូមមើលផងដែរនូវ "គណបក្សប្រជាជនកម្ពុជា គ្រប់គ្រងលើ RCAF កំណែទម្រង់ជាចម្បង ដែលបានសន្យា" Phnom Penh Post ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ http://www.phnompenhpost.com/national/cpp-control-rcaf-major-reforms-promised (ទទួលបាន ឬ បានអាន នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២), "ឧត្តមសេនីយ៍ឯក គីម ប៊ុនថន យកអាវភ្លៀង ទៅចែកជូនអង្គភាពកងកម្លាំង នៅសមរភូមិជួរមុខ" (!: ...), ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/66578-2013-06-21-05-53- 22.html (ទទួលបាន ឬ បានអាន នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣)។

បុិចជាច្រើនត្រូវបានសម្លាប់ នៅយោធភូមិភាគទី ៥។[625] នៅក្នុងជួរគណបក្សប្រជាជនកម្ពុជា គេជឿជាក់ថា ជនល្មើស គឺយោធភូមិភាគទី ៥ និងក្រុមឃាតកដទៃទៀតនៃគណបក្សប្រជាជនកម្ពុជា ហើយតុលាការអាចត្រូវបានណែនាំ មិនឱ្យអើពើអំពីករណីនោះ។[626] ដំណើរឆ្ពោះទៅរកការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងខែកុម្ភៈ ឆ្នាំ២០០២ អមដោយការកើនឡើងនូវអំពើហិង្សានយោបាយប្រព្រឹត្តដោយគណបក្សប្រជាជនកម្ពុជា និងការបំភិតបំភ័យនៅទូទាំងប្រទេស ហើយកងយោធពលខេមរភូមិន្ទនៅតាមទីជនបទ មានការជាប់ពាក់ព័ន្ធនឹងករណីរំលោភបំពានធ្ងន់ធ្ងរបំផុត។ យោងតាមរបាយការណ៍ស្តីពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ "បញ្ហាមានលក្ខណៈស្រួចស្រាវ ជាពិសេស" នៅក្នុងយោធភូមិភាគទី ៥ របស់លោក ប៊ុន សេង។ "ក្នុងករណីខ្លះ សមាជិកយោធា រាប់បញ្ចូលទាំងនាយទាហ៊ាននានា" ផង បានជាប់ពាក់ព័ន្ធនឹងការឃុំខ្លួនដោយខុសច្បាប់នូវសកម្មជននៃគណបក្សមិនកាន់អំណាច ការគំរាមសម្លាប់ ការគំរាមរំលោភសេពសន្ថវៈ និងការប៉ុនប៉ងសម្លាប់"។[627]

ការរំលោភបំពានទាំងនេះ គឺជាផ្នែកមួយនៃការរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំជាងនេះ ដែលបានកើតឡើងជាបន្តបន្ទាប់ ដោយកងកម្លាំងក្រោមការបង្គាប់បញ្ជារបស់លោក ប៊ុន សេង ៖ ចាប់ពីឆ្នាំ១៩៩៩ មក គាត់បានបញ្ជាដោយផ្ទាល់លើកងពលតូចលេខ ៥១ ៥២ និង៥៣ និងផ្នែកសឹករងនានា នៅថ្នាក់ខេត្ត ដោយមានក្រុមកងកម្លាំងនានារហូតដល់ថ្នាក់ស្រុក និងកងវរសេនាតូចការពារព្រំដែន។[628] ចាប់ពីឆ្នាំ២០០០ កងកម្លាំងទាំងនេះ បានជាប់ពាក់ព័ន្ធនឹងការរំលោភដីធ្លី រួមទាំង ការបណ្តេញពលរដ្ឋចេញដោយបង្ខំ ការរំលោភសេពសន្ថវៈ ការគំរាមសម្លាប់ ការបំពារបំពាន ការចាប់ខ្លួនតាមទំនើងចិត្ត ការធ្វើទារុណកម្ម ឃាតកម្ម ការប៉ុនប៉ងមនុស្សឃាត ការគំរាមយកប្រាក់ និងអំពើជួញដូរមនុស្ស ដែលទាំងអស់នេះប៉ះពាល់ដល់ប្រជាពលរដ្ឋសាមញ្ញ។[629] នៅក្នុងបរិបទនៃការបោះឆ្នោតជាតិ ខែកក្កដា ឆ្នាំ២០០៣ កងកម្លាំងនៅក្រោមបញ្ជាលោក ប៊ុន សេង បានជាប់ពាក់ព័ន្ធក្នុងអំពើហិង្សានយោបាយបន្ថែមទៀត រួមមាន ឃាតកម្មនយោបាយ ការប៉ុនប៉ងមនុស្ស

---

[625] Thomas Hammarberg, "អនុស្សារណៈជូនរាជរដ្ឋាភិបាលកម្ពុជា ដែលដាក់ដោយតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា" ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៨។

[626] ការសម្ភាសន៍ជាមួយមន្ត្រីយុត្តិធម៌កម្ពុជា ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៤។

[627] អង្គការសហប្រជាជាតិ៖ តំណាងពិសេសនៃអគ្គលេខាធិការទទួលបន្ទុកការងារសិទ្ធិមនុស្សនៅកម្ពុជា" ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០២ ទំព័រ៤-៥, ៧និង៩។

[628] ស្ថានទូតអាមេរិក នៅកម្ពុជា "គម្រោងក្របខណ្ឌការងារនយោបាយ-យោធា" ឆ្នាំ ២០០៣, រាជរដ្ឋាភិបាលកម្ពុជា បញ្ជាការជាន់ខ្ពស់នៃ RCAF "ការរៀបចំមេបញ្ជាការជាន់ខ្ពស់របស់ RCAF" ឆ្នាំ២០០៦។

[629] ពីប្រភពដដែល Ibid.

ឃាតដោយសារមូលហេតុនយោបាយ ការបំភិតបំភ័យផ្នែកនយោបាយ ការគំរាមសម្លាប់ដោយសារមូលហេតុនយោបាយ និងការឃុំខ្លួនតាមទំនើងចិត្តដោយសារមូលហេតុនយោបាយ។[630]

## លោក ប៊ុន សេង ក្នុងអំឡុងពេល និងក្រោយពេលបោះឆ្នោត ឆ្នាំ២០១៣

ក្នុងអំឡុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោតជាតិខែកក្កដា ឆ្នាំ២០១៣ លោក ប៊ុន សេង បានបង្ហាញយ៉ាងចំហនូវការប្រកាន់បក្សនយោបាយរបស់គាត់ ដោយបានអំពាវនាវឱ្យកងកម្លាំងយោធភូមិភាគទី ៥ គាំទ្រគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ដែលឱ្យលោក ហ៊ុន សែន បន្តធ្វើជានាយករដ្ឋមន្ត្រី។[631] នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣ លោក ប៊ុន សេង បានចែកឯកសារគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា នៅក្នុងកិច្ចប្រជុំមួយជាមួយសមាជិកបក្ស នៅស្រុកសំឡូត និងបានណែនាំពួកគេអំពីរបៀបល្អបំផុតដែលអាចឱ្យគណបក្សប្រជាជនកម្ពុជាឈ្នះការបោះឆ្នោត។[632] នៅថ្ងៃទី២៦ ខែមិថុនា គាត់បានបង្ហាញខ្លួននៅក្នុងពិធីសាសនាមួយនៅខេត្តបាត់ដំបង ហើយគាត់បានជំរុញឱ្យមានការបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា។[633]

ចាប់តាំងពីការបោះឆ្នោតឆ្នាំ២០១៣ មក លោក ប៊ុន សេង បានណែនាំកងកម្លាំងយោធភូមិភាគទី៥ ជាសាធារណៈ ឱ្យគាំទ្រលទ្ធផលនៃការបោះឆ្នោត និងគាំទ្រលោក ហ៊ុន សែន ធ្វើជានាយករដ្ឋមន្ត្រី។[634] បន្ទាប់ពីយោធា និងកងកម្លាំងសន្តិសុខផ្សេងទៀត ប្រើប្រាស់កងកម្លាំងយ៉ាងច្រើនហួសហេតុ និងដោយមិនចាំបាច់ក្នុងការបង្ក្រាបបាតុកម្ម កូដកម្ម និងភាពចលាចលសង្គមនៅចន្លោះខែកញ្ញា ឆ្នាំ២០១៣ និងខែមករា ឆ្នាំ

---

630 ពីប្រភពដដែល Ibid.

631 "ឧត្តមសេនីយ៍ឯក គីម ប៊ុនថន យកអាវភ្លៀងទៅចែកជូនអង្គភាពកងកម្លាំងនៅសមរភូមិជួរមុខ", ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/66578- 2013-06-21-05-53-22.html (ចូលមើល នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣)។

632 "លោក ប៊ុន សេង សំណេះសំណាលជាមួយសមាជិកគណបក្សប្រជាជនកម្ពុជា នៅស្រុកសំឡូត", ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣, http://www.dap-news.com/2011-06-14-02-39-55/61094-2013-03-30- 10-03-45.html (ចូលមើល នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣)។

633 "ការប្រគេនទានវស្សាដល់១៩ វត្ត នៅស្រុកសំឡូត" ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ http://dap-news.com/2011-06-14-02-39-55/67027-2013-06-26-11-07-13.html (ចូលមើល នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣)។

634 "កិច្ចប្រជុំបូកសរុបការងារសន្តិសុខយោធា នៅឆ្នាំ២០១៣ និងទិសដៅបន្ត សម្រាប់ឆ្នាំ២០១៤ នៅកងពលតូច ៥២" ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ http://www.dap- news.com/2011-06-14-02-39-55/80323-2014-02-05-06-54-50.html(ចូលមើល នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤), "យោធភូមិភាគទី ៥ បើកវគ្គហ្វឹកហ្វឺនអំពី ជំនាញសង្គ្រាមក្នុងព្រៃ" ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤;http://www.dap-news.com/2011-06-14-02-39-55/81143-2014-02-19-03-07-20.html, ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤។

*២០១៤ ដែលបានសម្លាប់មនុស្សអស់ ៩នាក់ និងរបួសជាច្រើននាក់ គាត់បានសរសើរគោលនយោបាយរបស់លោក ហ៊ុន សែន ក្នុងការពង្រឹងកងកម្លាំងប្រដាប់អាវុធ ក្នុងន័យការពារជាតិ។*[635]

*នៅពេលនោះ កងកម្លាំងយោធភូមិភាគទី ៩ បានបន្តជាប់ពាក់ព័ន្ធក្នុងការរំលោភសិទ្ធិមនុស្សនៅតាមមូលដ្ឋាន រួមមាន ការបាញ់ប្រហារដោយគ្មានមូលហេតុ ឬអំពើហិង្សាដែលបង្ករបួសស្នាមដល់អ្នកជាប់ពាក់ព័ន្ធនឹងគណបក្សសង្គ្រោះជាតិដែលគ្មានអាវុធ ឬជនស៊ីវិលផ្សេងទៀត ការរំលោភដីធ្លី ហើយពេលខ្លះ មានការគំរាមប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ ឬការគំរាមកំហែងផ្សេងទៀត ព្រមទាំងការគំរាមកំហែងអ្នកសារព័ត៌មាន ដែលព្យាយាមស៊ើបអង្កេតសកម្មភាពខុសច្បាប់របស់ក្រុមយោធា។*[636]

*លោក ប៊ុន សេង បានបង្ហាញការស្វាគមន៍ដូចគ្នានឹងមេបញ្ជាការជាន់ខ្ពស់ផ្សេងទៀតដែរ ចំពោះការរំលាយគណបក្សសង្គ្រោះជាតិ។ នៅពេលលោក កឹម សុខា ត្រូវបានចាប់ខ្លួន លោក ប៊ុន សេង និងមន្ត្រីយោធភូមិភាគទី៥ របស់គាត់ បាននិយាយគាំទ្រថា ការចាប់ខ្លួននេះគឺជាការចាំបាច់ ដើម្បីទប់ស្កាត់ភាពចលាចលប្រកបដោយគ្រោះថ្នាក់នៅក្នុងសង្គមកម្ពុជា។*[637] *កងកម្លាំងក្រោមបញ្ជាការរបស់លោក ប៊ុន សេង បានបន្ទរតាមមេរបស់ពួកគេ ដោយប្រកាសនូវ "ការប្តេជ្ញាចិត្តដាច់ខាតរបស់ពួកគេ ក្នុងការកម្ទេចរាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់" ក្នុងការបង្កើត "បដិវត្តពណ៌"។*[638] *ជាថ្មីម្តងទៀត នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០១៧ ដោយនិយាយជំនួសមុខ កងយោធពលខេមរភូមិន្ទ នៅយោធភូមិភាគទី ៥ លោក ប៊ុន សេង បានប្រកាសនូវ "ការប្រឆាំងដាច់ខាត ចំពោះសកម្មភាពញុះញង់ទាំងអស់" ដោយបុគ្គល "ដែលមានចេតនាមិនល្អ" ដូចជា លោក សម រង្ស៊ី និងលោក កឹម សុខា ដែលលោក ប៊ុន សេង និយាយថា ការញុះញង់របស់ពួកគេមានបំណង "ធ្វើឱ្យខ្មែរបែកបាក់"។ គាត់បានប្រកាសអំពី "សេចក្តីស្រឡាញ់" របស់គាត់ និងកងកម្លាំងរបស់គាត់ ចំពោះលោក ហ៊ុន សែន។*[639] *បន្ទាប់មក នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ លោក ប៊ុន សេង បានប្រកាសនូវការគាំ*

---

[635] "កិច្ចប្រជុំបូកសរុបការងារសន្តិសុខយោធា នៅឆ្នាំ២០១៣ និងទិសដៅបន្ត សម្រាប់ឆ្នាំ២០១៤ នៅកងពលតូច ៥២" ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ http://www.dap- news.com/2011-06-14-02-39-55/80323-2014-02-05-06-54-50.html(ចូលមើល នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤), "យោធភូមិភាគទី ៥ បើកវគ្គហ្វឹកហ្វឺនអំពី ជំនាញសង្គ្រាមក្នុងព្រៃ" ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤;http://www.dap-news.com/2011-06-14-02-39-55/81143-2014-02-19-03-07-20.html, ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤។

[636] ពីប្រភពដដែល Ibid.

[637] កងទ័ពយោធភូមិភាគ ៤ គាំទ្រចំណាចាត់ការរាជរដ្ឋាភិបាល និងថ្កោលទោសចំពោះទង្វើក្បត់ជាតិរបស់កឹម សុខា ឃុបឃិតបរទេសប៉ុនប៉ងដណ្តើមអំណាច។

[638] មេបញ្ជាការនិងទាហានទាំងអស់ ប្រកាសអនុវត្តន៍តាមប្រសាសន៍តេជោក្នុងការកំចាត់ពួកបរទេសឈ្លានពាន និងប្តេជ្ញាកម្ទេចជនធ្វើបដិវត្តន៍។

[639] កងទព័ទាំងអស់នៃបញ្ជាការដ្ឋានយោធភូមិភាគ ៥ ប្រតិកម្មនិងសម្តីសមរង្ស៊ី ដែលអំពាវនាវឲ្យកងកម្លាំងប្រដាប់អាវុធបែកាណុងផ្តួលរំលំរដ្ឋាភិបាល

*ទ្រទាំងស្រុងរបស់គាត់ ចំពោះសាលដីការបស់តុលាការកំពូលដែលសម្រេចរំលាយគណបក្សសង្គ្រោះជាតិ ក្រោមបទជាប់ពាក់ព័ន្ធក្នុង "អំពើក្បត់ជាតិ" ដែលមិនអាចអត់ឱនឱ្យបាន និងបានប្រកាសគាំទ្រចំពោះការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យចាត់វិធានការទប់ស្កាត់បន្ថែមទៀត ប្រឆាំងនឹងផែនការធ្វើបដិវត្តពណ៌ និងអ្នកនយោបាយ "ដែលបម្រើផលប្រយោជន៍បរទេស"។*[640]

## VII. ឧត្តមសេនីយ៍ឯកផ្កាយមាស ៣ ជឿន សុវណ្ណថា មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី ២

*លោក ជឿន សុវណ្ណថា គឺជាអង្គរក្សវ័យក្មេងម្នាក់ ក្នុងចំណោមអង្គរក្សវ័យក្មេងផ្សេងទៀតរបស់លោក ហ៊ុន សែន នៅក្នុងប្រទេសវៀតណាម ក្នុងឆ្នាំ១៩៧៨ នៅពេលលោក ហ៊ុន សែន និរទេសខ្លួនទៅទីនោះ។*[641] *ថ្ងៃខែឆ្នាំកំណើតផ្លូវការរបស់គាត់ គឺថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៥៧។*[642] *គិតត្រឹមឆ្នាំ១៩៩៥ លោក ជឿន សុវណ្ណថា គឺជាមេបញ្ជាការនៃយោធភូមិភាគទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា។*[643] *ភូមិភាគនេះ រួមមានខេត្តកំពង់ចាម*

---

ជាអំពើក្បត់ជាតិសុទ្ធសាធនិងធ្ងន់ធ្ងរណាស់។

640 ឧត្តសេនីយ៍ឯក ប៊ុនសេង ប្រកាសគាំទ្រពេញទំហឹង ចំពោះតុលាការកំពូល ការរំលាយគណបក្សសង្គ្រោះជាតិ និងគាំទ្រអនុសាសន៍ទាំងស្រុងរបស់សម្តេចតេជោហ៊ុនសែន។

641 លោក ហ៊ុន សែន "សុន្ទរកថា នៅពិធីបិទអង្គប្រជុំវិសាមញ្ញនៃអ្នកតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស និងទិវាអតីតយុទ្ធជនកម្ពុជាលើកទី ៣" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ (ចូលមើល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២), លោក ហ៊ុន សែន "សម្រង់ប្រសាសន៍នៅឯពិធីបិទមហាសន្និបាតវិសាមញ្ញនៃអ្នកតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស និងទិវាអតីតយុទ្ធជនកម្ពុជាលើកទីបី" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ http://cnv.org.kh/selected-comments-at-the-closing-of-the-extra-ordinary-general-assembly-of-the-nationwide- representatives-of-the-cambodian-veterans-association-and-the-celebration-of-the-third-anniversary-of-the-camb/ (ចូលមើល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២)" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០, លោក ហ៊ុន សែន "សុន្ទរកថា នៅក្នុងទិវាខួបអតីតយុទ្ធជនលើកទី ៤" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ http://cnv.org.kh/address-at-the-4th-anniversary-of-cambodian-veterans-day/ (ចូលមើល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២), លោក ហ៊ុន សែន "សម្រង់ប្រសាសន៍នៅឯពិធីខួបអតីតយុទ្ធជនកម្ពុជាលើកទី ៤" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ http://cnv.org.kh/selected-comments-at-the-celebration-of-the-4th-anniversary-of-the-cambodian-war-veterans/ (ចូលមើល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២), រាជរដ្ឋាភិបាលកម្ពុជា "នាយឧត្តមសេនីយ៍ផ្កាយមាស បួន សៅ សុខា", លោក ហ៊ុន សែន "សុន្ទរកថា នៅក្នុងពិធីរំលឹកខួបអតីតយុទ្ធជនលើកទី ៤" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ http://cnv.org.kh/address-at-the-4th-anniversary-of-cambodian-veterans-day/ (ចូលមើល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២), លោក ហ៊ុន សែន "សម្រង់ប្រសាសន៍នៅឯពិធីខួបអតីតយុទ្ធជនកម្ពុជាលើកទី ៤" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ http://cnv.org.kh/selected-comments-at-the-celebration-of-the-4th-anniversary-of-the-cambodian-war-veterans/ (ចូលមើល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២)។

642 បញ្ជីអ្នកចុះឈ្មោះបោះឆ្នោតបណ្តោះអាសន្នឆ្នាំ២០១៧ ឯកសារ ០១-៧២៣-៧០៥។

643 រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ៨៩ អនក្រ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៥។

(រួមបញ្ចូលទាំងខេត្តត្បូងឃ្មុំ ដែលជាខេត្តថ្មី) ព្រៃវែង ស្វាយរៀង និងក្រចេះ។[644] រួមជាមួយនឹងយោធភូមិភាគទី ៤ និង៥ យោធភូមិភាគទី ២ គឺស្ថិតក្នុងចំណោមភូមិភាគទាំងបីនៅក្នុងប្រទេស ជាទីដែលកងកម្លាំងប្រដាប់អាវុធគណបក្សប្រជាជនកម្ពុជាបានជាប់ពាក់ព័ន្ធយ៉ាងធ្ងន់ធ្ងរនៅក្នុងការរំលោភសិទ្ធិមនុស្ស ផ្តោតសំខាន់លើគណបក្សនយោបាយប្រឆាំង ក្នុងអំឡុងពេលឆ្ពោះទៅរកការបោះឆ្នោតឆ្នាំ១៩៩៣។[645] ក្នុងឆ្នាំ១៩៩៦ នៅពេលលោក ហ៊ុន សែន ចាប់ផ្តើមស្វែងរកការគាំទ្រចំពោះចំណាត់ការដោយប្រើអាវុធប្រឆាំងនឹងគណបក្សហ៊្វុនស៊ិនប៉ិច ដើម្បី "កម្ទេច" កងយោធារបស់គណបក្សនេះ លោក ជឿន សុវណ្ណថា ស្ថិតក្នុងចំណោមក្រុមមន្ត្រីគណបក្សប្រជាជនកម្ពុជាក្នុងជួរកងយោធពលខេមរភូមិន្ទ ដែលលោក ហ៊ុន សែន ពឹងផ្អែក សម្រាប់ការគាំទ្រដោយមិនរាករេ។[646] ក្នុងការត្រៀមខ្លួនសម្រាប់ការផ្ទុះអាវុធដែលអាចកើតមាននៅពេលនោះ គណបក្សប្រជាជនកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាពីដើមឆ្នាំ១៩៩៧ ក្នុងការជ្រើសរើសមន្ត្រីហ៊្វុនស៊ិនប៉ិច ឱ្យបម្រើការក្នុងយោធភូមិភាគទី២។[647] នៅខែឧសភា និងខែមិថុនា ឆ្នាំ១៩៩៧ ភូមិភាគនេះ បានផ្លាស់ទីកងទ័ពថ្នាក់តំបន់ ដើម្បីទៅពង្រឹងទីតាំងយោធារបស់លោក ហ៊ុន សែន នៅទីក្រុងភ្នំពេញ។[648] នៅថ្ងៃទី១៧ ខែមិថុនា ទាហានតំបន់ បានប៉ុនប៉ងចាប់ខ្លួនមន្ត្រីក្នុងថ្នាក់ដឹកនាំនៃគណបក្សហ៊្វុនស៊ិនប៉ិច នៅខេត្តកំពង់ចាម ប៉ុន្តែមិនទទួលបានជោគជ័យឡើយ។[649]

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៧ កងកម្លាំងយោធភូមិភាគទី ២ បានវាយប្រហារយោធាហ៊្វុនស៊ិនប៉ិច ដោយបានសម្លាប់ទាហានហ៊្វុនស៊ិនប៉ិចម្នាក់ និងធ្វើឱ្យទាហានបីនាក់ផ្សេងទៀតរងរបួស។[650] ការវាយប្រហារនេះស្របគ្នាជាមួយនឹងការចាប់ខ្លួនសមាជិកហ៊្វុនស៊ិនប៉ិច នៅក្នុងភូមិនានានៃខេត្តកំពង់ចាម។ នៅពេលនាយករដ្ឋមន្ត្រីទី១ សម្តេច នរោត្តម រណឫទ្ធិ នៃគណបក្សហ៊្វុនស៊ិនប៉ិច ធ្វើទស្សនកិច្ចនៅខេត្តកំពង់ចាម នៅថ្ងៃទី៣

644 រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

645 អ៊ុនតាក់ ផ្នែករដ្ឋបាលស៊ីវិល "របាយការណ៍សកម្មភាពនៃអង្គភាពការពារ សម្រាប់រយៈពេលចាប់ពីថ្ងៃទី១ ដល់ទី៣១ ខែមករា ឆ្នាំ១៩៩៣" ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៣។

646 UNOSGRC, "របាយការណ៍ប្រចាំខែឧសភា ឆ្នាំ១៩៩៦"; UNOSGRC, "របាយការណ៍លេខ ៥៧២។"

647 COHCHR, "ព័ត៌មានពីអតីតអនុប្រធានពន្ធនាគារខេត្តកំពង់ចាម នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៧" ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧។

648 COHCHR, "ព័ត៌មានពីអតីតអនុប្រធានពន្ធនាគារខេត្តកំពង់ចាម នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៧" ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧។

649 ពីប្រភពដដែល Ibid.

650 COHCHR, "ចារកម្មយោធា និងការប្រយុទ្ធគ្នានៅថ្ងៃទី២ ខែកក្កដា" [គ្មានកាលបរិច្ឆេទ], ការសម្ភាសន៍របស់លោក Brad Adams ជាមួយស្ថានទូតអាមេរិក ខែមេសា ឆ្នាំ២០០០, ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីយោធា ហ្វ៊ុនស៊ិនប៉ិច ដែលបានចុះចូលជាមួយគណបក្សប្រជាជន បន្ទាប់ពីរដ្ឋប្រហារ។

ខែកក្កដា កងទ័ពតំបន់បានចូលរួមនៅក្នុងប្រតិបត្តិការមួយ ក្នុងការដកហូតអាវុធពីអង្គរក្សរបស់លោក ខណៈទ្រង់ នរោត្តមរណឫទ្ធិ បានភៀសព្រះកាយតាមឧទ្ធម្ភាគចក្រត្រលប់ទៅទីក្រុងភ្នំពេញវិញ។[651]

នៅល្ងាចថ្ងៃទី៤ ខែកក្កដា និងព្រឹកថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៩៧ មន្ត្រីហ្វ៊ុនស៊ិនប៉ិចបួននាក់ ដែលមានតួនាទីសំខាន់ នៅក្នុងយោធភូមិភាគទី ២ បានបាត់ខ្លួន បន្ទាប់ពីចូលរួមនៅក្នុងកិច្ចប្រជុំមួយនៅខេត្តកំពង់ចាម ដែលរៀបចំដោយមន្ត្រីជាន់ខ្ពស់នៃគណបក្សប្រជាជនកម្ពុជា។ មន្ត្រីទាំងបួននោះ គឺអនុសេនីយ៍ឯក ប៊ូ សុផល ហៅ ម៉ាក់ យូ គ្លីន ជាមេបញ្ជាការរងនៃ "អង្គភាពបញ្ជាការ" នៃបញ្ជាការដ្ឋានភូមិភាគ ពលទោ យុទ្ធ យឿង ជាអង្គរក្សរបស់អនុសេនីយ៍ឯក ប៊ូ សុផល វរសេនីយ៍ត្រី ជួប ឯម ជាមេបញ្ជាការរងតំបន់ G-២ (ចារកម្ម) និងវរសេនីយត្រី ឡុច តុន មេបញ្ជាការរងតំបន់ G-៣ (ប្រតិបត្តិការ)។ នៅល្ងាចថ្ងៃទី៦ កក្កដា ឬព្រឹកថ្ងៃទី៧ កក្កដា មានគេឃើញអ្នកទាំង៤ត្រូវបានដឹកតាមរថយន្តយោធាឆ្ពោះទៅកាន់ចំការកៅស៊ូចាន់ទូងនៅក្នុងឃុំល្វៀង ស្រុកត្បូងឃ្មុំ ដែលជាតំបន់គ្រប់គ្រងដោយកងវរសេនាតូចចារកម្មនៃយោធភូមិភាគទី ២ និងកងកម្លាំងប្រដាប់អាវុធថ្នាក់ស្រុករបស់គណបក្សប្រជាជនកម្ពុជា។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៩៨ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំប្រទេសកម្ពុជា បានគាស់ឃើញសាកសពបុរសពីរនាក់ ដែលត្រូវបានសម្លាប់នៅទីនោះ។ សាកសពមួយត្រូវបានកំណត់អត្តសញ្ញាណថាជា លោក ប៊ូ សុផល។ សាកសពមួយទៀតប្រហែលជាលោក ជួប ឯម។ ចំណែកដាននៃលោក ឡុច តុន ឬលោក យុទ្ធ យឿង មិនត្រូវបានរកឃើញឡើយ គិតត្រឹមពេលដែលអង្គការសហប្រជាជាតិចេញផ្សាយរបាយការណ៍ស្តីពីករណីទាំងនោះ នៅខែឧសភា ឆ្នាំ១៩៩៨។[652]

កងទ័ពយោធភូមិភាគទី២ បានដើរតួរនាទីយ៉ាងសំខាន់នៅក្នុងរដ្ឋប្រហារនេះ។ តួនាទីខ្លះរបស់ក្រុមនេះ គឺជាផ្នែកមួយនៃការវាយប្រហារដោយមានការរៀបចំត្រឹមត្រូវ ទៅលើគណបក្សហ្វ៊ុនស៊ិនប៉ិចទាំងនៅក្នុង និងជុំវិញទីក្រុងភ្នំពេញ ដែលលោក ហ៊ុន សែន បានប្រកាសឱ្យធ្វើនៅព្រឹកថ្ងៃទី៥ ខែកក្កដា ខណៈកងទ័ពផ្សេងទៀតបានមកដល់តាមក្រោយនៅថ្ងៃដដែលនោះ និងនៅថ្ងៃទី៦ ខែ កក្កដា ដើម្បីពង្រឹងកម្លាំងបន្ថែម ដោយ

[651] COHCHR, "របាយការណ៍ប្រចាំខែកក្កដា (១៩៩៧) នៃការិយាល័យប្រចាំខេត្តកំពង់ចាម", *AFP* "នាយករដ្ឋមន្ត្រីបន្ទោសលោក ហ៊ុន សែន អំពីឧប្បត្តិហេតុនោះ" ថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៩៧។

[652] Thomas Hammarberg, "អនុស្សារណៈជូនរាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវដាក់ដោយតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា" ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៨។

*កាន់កាប់បានច្រកចូលសំខាន់មួយក្នុងចំណោមច្រកចូលសំខាន់ផ្សេងទៀតនៃទីក្រុងភ្នំពេញ គឺស្ពានច្បងកាត់ទន្លេសាបទៅកាន់តំបន់ជ្រោយចង្វារ ហើយបន្ទាប់មក វាយប្រហារទីស្នាក់ការកណ្តាលគណបក្សហ៊្វុនស៊ិនប៉ិច នៅជិតស្ពានទូតបារាំង។*[653]

*ក្នុងអំឡុងពេលរដ្ឋប្រហារនោះ កងទ័ពយោធភូមិភាគទី២ ក៏បានបើកប្រតិបត្តិការទូទៅមួយ ដើម្បីដកហូតអាវុធពីកងកម្លាំងហ៊្វុនស៊ិនប៉ិចទាំងអស់នៅខេត្តកំពង់ចាម ក្រោយមកពួកគេបានចូលលុកលុយលួចយករបស់របរផ្សេងៗពីការិយាល័យគណបក្សហ៊្វុនស៊ិនប៉ិច។ ក្នុងអំឡុងពេលប្រតិបត្តិការនេះ មន្ត្រីគណបក្សហ៊្វុនស៊ិនប៉ិចជាច្រើនរូបផ្សេងទៀតត្រូវបានចាប់ខ្លួន។ សាកសពមួយចំនួននៃមន្ត្រីហ៊្វុនស៊ិនប៉ិចត្រូវបានគេប្រទះឃើញអណ្តែតតាមដងទន្លេមេគង្គដែលហូរច្បងកាត់ខេត្តនេះ ប៉ុន្តែមន្ត្រីហ៊្វុនស៊ិនប៉ិចដែលជាប់ឃុំផ្សេងទៀតត្រូវបានដោះលែងដោយគ្មានបញ្ហាអ្វី ក្រោយពេលពួកគេបង់ប្រាក់សំណូករួច។*[654] *នៅខេត្តព្រៃវែង មន្ត្រីហ៊្វុនស៊ិនប៉ិចត្រូវបានឃុំខ្លួននៅក្នុងមូលដ្ឋានយោធភូមិភាគទី២ ប៉ុន្តែក្រោយមកត្រូវបានដោះលែងវិញ។ មន្ត្រីផ្សេងទៀតប្រឈមមុខនឹងការជំនុំជម្រះយ៉ាងតក់ក្រហល់ ដែលពួកគេទទួលបានការព្យួរទោសដាក់ពន្ធនាការ ក្រោមបទចោទប្រកាន់ដែលផ្អែកលើព័ត៌មានមិនពិត។*[655]

*រយៈពេលពីរសប្តាហ៍កន្លះ ក្រោយរដ្ឋប្រហារ លោក ជឿន សុវណ្ណថា បានទទួលការតែងតាំងជាទីប្រឹក្សារបស់លោក ហ៊ុន សែន ដែលមានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ។*[656]

---

[653] ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីយោធាបារាំងដែលឈរជើងនៅក្នុងប្រទេសកម្ពុជា ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០១, ការសម្ភាសន៍របស់លោក Brad Adams ជាមួយទាហាននៃកងយោធពលខេមរភូមិន្ទ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០១, ការសម្ភាសន៍របស់លោក Brad Adams ជាមួយឯកអគ្គរដ្ឋទូតកាណាដា គឺលោក Gorden Longmuir ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១, ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ ថ្ងៃទី១ ខែមីនា ឆ្នាំ២០០១, ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីយោធាជាន់ខ្ពស់នៃគណបក្សហ៊្វុនស៊ិនប៉ិច ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០១, ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីយោធាជាន់ខ្ពស់នៃគណបក្សហ៊្វុនស៊ិនប៉ិច ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០១, COHCHR, "របាយការណ៍ប្រចាំខែកក្កដា (ឆ្នាំ១៩៩៧) នៃការិយាល័យ ប្រចាំខេត្តកំពង់ចាម", COHCHR, "ការស៊ើបអង្កេតនៅខេត្តកំពង់ចាមនៅថ្ងៃទី២៣-២៥ខែកក្កដា ឆ្នាំ១៩៩៧" ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧។

[654] ពីប្រភពដដែល (Ibid.);COHCHR, "ព័ត៌មានពីប្រភពផ្សេងៗ" ថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៧, COHCHR, "របាយការណ៍សកម្មភាពទី៥សម្រាប់ខែកក្កដាឆ្នាំ១៩៩៧" ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧ "ការចាប់ខ្លួនមន្ត្រីគណបក្សហ៊្វុនស៊ិនប៉ិច នៅតាមបណ្តាខេត្តនានា" [គ្មានកាលបរិច្ឆេទ], ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីជាន់ខ្ពស់ខេត្ត ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០០, COHCHR, "ការចាប់ខ្លួនមន្ត្រីគណបក្សហ៊្វុនស៊ិនប៉ិច នៅតាមបណ្តាខេត្តនានា" [គ្មានកាលបរិច្ឆេទ]។

[655] ពីប្រភពដដែល (Ibid.)

[656] រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ ChS/រក/០៧៩៧/៨៥ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៧។

*កងទ័ពយោធភូមិភាគទី ២ ក៏ជាប់ពាក់ព័ន្ធក្នុងអំពើហិង្សានយោបាយ ក្នុងអំឡុងពេលឈានទៅរកការបោះឆ្នោតក្រុមប្រឹក្សាឃុំនៅខែកុម្ភៈ ឆ្នាំ២០០២ ផងដែរ។ អំពើហិង្សានេះ កើតឡើងស្របគ្នានឹងការកំរើកឡើងនៃអំពើហិង្សានយោបាយរបស់គណបក្សប្រជាជនកម្ពុជានៅទូទាំងប្រទេស ប៉ុន្តែអំពើហិង្សាដ៏អាក្រក់បំផុតរបស់គណបក្សប្រជាជនកម្ពុជា គឺនៅក្នុងយោធភូមិភាគទី ២ នៃខេត្តកំពង់ចាម ដោយយោធាមានការពាក់ព័ន្ធនឹងឃាតកម្មលើសកម្មជននយោបាយប្រឆាំងបួននាក់។ សកម្មជនពីរនាក់ត្រូវបានសម្លាប់ដោយក្រុមទំនើងប្រដាប់អាវុធ ដែលសមាជិកក្រុមនេះភាគច្រើនជាកងកម្លាំងយោធា និងនគរបាល ដែលចល័តនៅតាមតំបន់ខ្លះនៃខេត្តនេះ និងជាក្រុមដែលអ្នកតាមដានស្ថានភាពសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិជឿជាក់ថា ជាក្រុមដែលនៅពេលនោះ កំពុងប្រតិបត្តិការតាមរចនាសម្ព័ន្ធបញ្ជាការភូមិភាគ។[657] កងកម្លាំងយោធភូមិភាគទី២ ក៏ពាក់ព័ន្ធនឹងការប្រើអំពើហិង្សា ក្រៅរឿងនយោបាយផងដែរ រួមមាន អំពើឃាតកម្ម និងបទល្មើសផ្សេងៗ ដែលបានកើតឡើងក្រោយពេលបោះឆ្នោតឃុំ-សង្កាត់។[658]*

*ក្នុងអំឡុងពេលបោះឆ្នោតសភាជាតិឆ្នាំ២០០៣ ខេត្តកំពង់ចាម គឺជាខេត្តមួយ ក្នុងចំណោមខេត្ត ដែលគេសម្គាល់ឃើញមានការបំភិតបំភ័យ ការបំពារបំពាន និងអំពើហិង្សានយោបាយច្រើនបំផុត។*

*នៅក្នុងបញ្ជីឈ្មោះទីប្រឹក្សាផ្ទាល់ខ្លួនរបស់លោក ហ៊ុន សែន ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៨ ក៏មានឈ្មោះលោក ជឿន សុវណ្ណថា ផងដែរ ដោយមានឋានៈក្នុងរដ្ឋាភិបាលខ្ពស់ជាងមុន គឺមានឋានៈស្មើរដ្ឋលេខាធិការ។[659] គាត់បានបន្តធ្វើជាមេបញ្ជាការយោធភូមិភាគទី ២ ចាប់តាំងពីពេលនោះមក ដោយមានអំណាចលើកងពលតូចតំបន់លេខ ២១ និងផ្នែកប្រតិបត្តិការសឹករងខេត្តកំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ក្រចេះ និងស្វាយរៀង ហើយអង្គភាពនីមួយៗទាំងនេះ មានកងយោធាទៅដល់ថ្នាក់ស្រុក ហើយគាត់ក៏មានអំណាចលើកងវរសេនាតូចការពារព្រំដែនផងដែរ។[660]*

---

[657] COHCHR,"របាយការណ៍នៃការិយាល័យប្រចាំខេត្តកំពង់ចាម ៖ ខ្លឹមសាររបាយការណ៍ខែកុម្ភៈ (ឆ្នាំ១៩៩៨)", អង្គការសហប្រជាជាតិ ៖ តំណាងពិសេសនៃអគ្គលេខាធិការ ទទួលបន្ទុកការងារសិទ្ធិមនុស្ស នៅកម្ពុជា ***ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០២*** ទំព័រ ៦-៧, ៩។

[658] ពីប្រភពដដែល Ibid.

[659] រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ នស/រតក/២០០៨/១០៨៣ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៨។

[660] ស្ថានទូតអាមេរិកប្រចាំកម្ពុជា "កងយោធពលខេមរភូមិន្ទ" ឆ្នាំ២០០៣។

ចាប់ពីឆ្នាំ២០០០ មក កងកម្លាំងយោធភូមិភាគទី ២ បានជាប់ពាក់ព័ន្ធនឹងបទល្មើស និងការរំលោភបំពានក្រៅរឿងនយោបាយជាច្រើន ដូចជា ការបូន់ប្រដាប់អាវុធ ឃាតកម្ម ការប៉ុនប៉ងមនុស្សឃាត ការបង្ករបួសស្នាម ការគំរាមសម្លាប់ អំពើជួញដូរមនុស្ស និងការរំលោភសេពសន្ថវៈ ការជំរិតទារប្រាក់ ការឃុំខ្លួនតាមទំនើងចិត្ត និងការបាត់ខ្លួនដោយបង្ខំ បូករួមនឹងការរំលោភដីធ្លី រួមទាំងការបណ្តេញពលរដ្ឋចេញពីលំនៅស្ថានដោយបង្ខំ និងការរំលោភយកដីធ្លីពីក្រុមជនជាតិភាគតិច។[661]

បន្ទាប់ពីមានការបង្ក្រាបរបស់រដ្ឋាភិបាលក្នុងទីក្រុងភ្នំពេញទៅលើគណបក្សសង្គ្រោះជាតិ និងការតវ៉ាដទៃទៀតប្រឆាំងនឹងការលួចបន្លំក្នុងការបោះឆ្នោតខែកក្កដា ឆ្នាំ២០១៣មក កងទ័ពយោធភូមិភាគទី២ បានធ្វើប្រតិបត្តិការទប់ស្កាត់ ឬបំបែកការប្រមូលផ្តុំរបស់គណបក្សសង្គ្រោះជាតិ នៅតំបន់ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់លោក ជឿន សុវណ្ណថា។ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤ អង្គភាពនានានៃយោធភូមិភាគ ២ បានបិទផ្លូវនានា ជាផ្នែកមួយនៃប្រតិបត្តិការរបស់គណបក្សប្រជាជនកម្ពុជា ដោយបានដាក់ពង្រាយសមាជិកគណបក្សប្រជាជនកម្ពុជាយ៉ាងច្រើន ដើម្បីរារាំងលោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ មិនឱ្យចូលរួមកិច្ចប្រជុំមួយជាមួយថ្នាក់ដឹកនាំគណបក្ស និងអ្នកគាំទ្ររបស់គាត់នៅក្នុងខេត្តកំពង់ចាម។ កងទ័ពបានបិទផ្លូវនានាក្នុងបំណងរារាំងសមាជិកគណបក្សសង្គ្រោះជាតិមិនឱ្យធ្វើដំណើរទៅកាន់ទីស្នាក់ការកណ្តាល ខណៈសកម្មជនគណបក្សប្រជាជនកម្ពុជាបានឡោមព័ទ្ធរថយន្តរបស់លោក កឹម សុខា នៅតាមផ្លូវពីសណ្ឋាគារទៅកាន់ទីកន្លែងប្រជុំ។[662] នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៤ កងទ័ពយោធភូមិភាគទី២ រួមទាំងកងយោធាប្រដាប់អាវុធធុនធ្ងន់ពីកងពលតូចលេខ២១ ត្រូវបានដាក់ពង្រាយជាមួយនគរបាល និងកងរាជអាវុធហត្ថ ដើម្បីបិទច្រកចូលទៅកាន់ការិយាល័យតំណាងរាស្ត្រក្នុងខេត្ត ដើម្បីទប់ស្កាត់ក្បួនរបស់គណបក្សសង្គ្រោះជាតិ ដឹកនាំដោយលោក សម រង្ស៊ី និងលោក កឹម សុខា មិនឱ្យចូលទៅដល់ទីនោះ។ អំពើហិង្សាត្រូវបានទប់ស្កាត់ ដោយសារថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ បានសម្រេចចិត្តមិនបន្តទៅមុខ ថ្វីបើមាន

---

661 ពីប្រភពដដែល Ibid.

662 "អ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា រារាំងលោក កឹម សុខា មិនឱ្យគាត់ជួបជាមួយសកម្មជន នៅក្នុងស្រុកកំពង់សៀម" ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤ http://www.dap- news.com/2011-06-14-02-39-55/79846-2014-01-26-04-09-43.html(ចូលមើល នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦), "សកម្មជនគណបក្សប្រជាជនកម្ពុជាប្រឆាំងនឹងវត្តមានរបស់លោក កឹម សុខា នៅក្នុងខេត្តកំពង់ចាម" ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤ http://edition.kpt-news.com/local-news/ 3176-2014-01-26-04-00-51.html (ចូលមើល នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤), "លោកកឹមសុខា ៖ គណបក្សប្រជាជនកម្ពុជា ប្រើប្រាស់នយោបាយគំរាមកំហែងអ្នកគាំទ្រ និងជីវិតរបស់គាត់" ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤ http://vodhotnews.com/18884 (ចូលមើល នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤), "ដុំថ្ម និងកន្លែងរឹង" *Phnom Penh Post*, ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ http://www.phnompenhpost.com/national/rock-and-hard-place (ចូលមើល នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤)។

*ការជំរុញពីអ្នកគាំទ្រ ឱ្យជំនះទៅមុខទៀតក៏ដោយ។*[663]

*នៅខែតុលា ឆ្នាំ២០១៤ កងទ័ពនៃកងពលតូចលេខ ២១ បានទទួលការទូន្មានប្រៀនប្រដៅកម្រិតខ្ពស់ ដើម្បីពង្រឹងស្មារតីប្រឆាំងគណបក្សសង្គ្រោះជាតិ។ ពួកគេបានទទួលការណែនាំថា គណបក្សសង្គ្រោះជាតិ ជាប់ពាក់ព័ន្ធនឹង "កលល្បិច" ដើម្បីផ្តួលរំលំរដ្ឋាភិបាល រួមមានតាមរយៈ "ការរិះគន់" គណបក្សប្រជាជនកម្ពុជា ការរៀបចំបាតុកម្មប្រឆាំងនឹងការលួចបន្លំសន្លឹកឆ្នោតកាលពីពេលបោះឆ្នោតលើកមុន និងការញុះញង់ឱ្យកម្មករធ្វើបាតុកម្ម។ កងទ័ពត្រូវបានប្រាប់ អោយចាត់វិធានការខ្លាំងក្លាក្នុងការអនុវត្តគោលនយោបាយរបស់លោក ហ៊ុន សែន ដើម្បីទប់ស្កាត់មិនឱ្យគណបក្សសង្គ្រោះជាតិទទួលបានជោគជ័យ ហើយថា ពួកគេត្រូវតែគាំទ្រវិធានការទាំងនោះ ដើម្បីរក្សាសន្តិភាព និងធានាការអភិវឌ្ឍសេដ្ឋកិច្ច នៅកម្ពុជា។*[664] *ចាប់ពីឆ្នាំ២០១៤មក បន្ថែមលើការធ្វើសកម្មភាពប្រឆាំងនឹងការប្រមូលផ្តុំគ្នារបស់គណបក្សសង្គ្រោះជាតិ កងទ័ពយោធភូមិភាគទី ២ ក៏ជាប់ពាក់ព័ន្ធផងដែរទៅនឹងការរំលោភសិទ្ធិមនុស្សផ្សេងទៀតនៅតាមមូលដ្ឋាន រួមមាន ការរំលោភដីធ្លី ដែលគាំទ្រដោយកងកម្លាំងប្រដាប់អាវុធ និងការរាំងរារាំងកូដកម្មរបស់កម្មករ។*[665]

*លោក ជឿន សុវណ្ណថា បានចូលរួមបន្ទរការថ្កោលទោសជាសាធារណៈរបស់កងយោធពលខេមរភូមិន្ទ លើថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ ខណៈលើកតម្កើងតួនាទីរបស់លោក ហ៊ុន សែន។ នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ ២០១៧ លោក ជឿន សុវណ្ណថា បានស្វាគមន៍ការចាប់ខ្លួនលោក កឹម សុខា ហើយពីរថ្ងៃក្រោយមក កងកម្លាំងយោធភូមិភាគទី២ ក្រោមបញ្ជាការរបស់គាត់ ក៏បានប្រកាសស្វាគមន៍ផងដែរ។*[666] *នៅថ្ងៃទី១៩ ខែ*

---

663 "លោក សម រង្ស៊ី និងលោក កឹម សុខា ទៅធ្វើយុទ្ធនាការបោះឆ្នោតនៅខេត្តកំពង់ចាម ដែលខណៈនោះ ក៏កំពុងមានការចល័តកងទ័ពជាច្រើន ផងដែរ" ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/85875-2014-05-04-04-38-22.html (ចូលមើល នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៤), សេចក្តីអធិប្បាយរបស់សាក្សី ធ្វើឡើងដោយអ្នកតាមដានការងារខាងសិទ្ធិមនុស្ស ដែលបានសង្កេតមើលព្រឹត្តិការណ៍ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៤។

664 "លោក ហោ ណាំហុង ប្រាប់កងទ័ពថា គណបក្សសង្គ្រោះជាតិប្រើប្រាស់កលល្បិចនានា ជាផ្នែកមួយនៃគោលបំណងរបស់ពួកគេដើម្បីផ្តួលរំលំរាជរដ្ឋាភិបាល" (UI=), ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៥ http://www.dap-news.com/2011-06-14-02-39-55/100748-2015-10-10-06-20-19.html (ចូលមើល នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៥), "លោក ហោ ណាំហុង ចុះសួរសុខទុក្ខនាយទាហាន និងពលទាហាននៃកងពលតូចលេខ ២១ នៅក្នុងខេត្តកំពង់ចាម" ( UI), ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ http://kampucheathmey.com/kpt/?p=87643 (ចូលមើល នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៤)។

665 ពីប្រភពដដែល Ibid.

666 កងទ័ពទាំងអស់នៅយោធភូមិភាគ២ ប្រកាសគាំទ្រដល់ចំណាត់ការសមត្ថកិច្ច ក្នុងការចាប់ខ្លួនលោក កឹម សុខា ដែលក្បត់ជាតិ និងប្រកាសថ្កោលទោសយ៉ាងខ្លាំងៗ៖ កងទ័ពទាំងអស់នៅកងពលពលតូចថ្មើរជើងលេខ២១ ប្រកាសគាំទ្រដល់សមត្ថកិច្ចក្នុងការចាប់ខ្លួនលោក កឹម សុខា ដែលក្បត់ជាតិនិងថ្កោលទោសយ៉ាងធ្ងន់ធ្ងរ។

*តុលា ឆ្នាំ២០១៧ លោក ជឿន សុវណ្ណថា និងមេបញ្ជាការទាំងអស់នៃយោធភូមិភាគទី២ បានប្រកាសថា ពួកគេ និងកងទ័ពបានត្រៀមខ្លួនរួចជាស្រេចក្នុងការតម្រង់អាវុធទៅរកលោក សម រង្ស៊ី លោក កឹម សុខា និងអ្នកផ្សេងទៀតដែលស្ថិតក្នុងចំណោម "ក្រុមអ្នកក្បត់ជាតិ និងអ្នកដែលមានបំណងបង្កើតអសន្តិសុខក្នុងមាតុភូមិនេះ" និងបានបង្ហាញនូវការដឹងគុណជានិរន្តរ៍ ចំពោះលោក ហ៊ុន សែន ដែលបានយកចិត្តទុកដាក់យ៉ាងល្អចំពោះកងកម្លាំងប្រដាប់អាវុធ។[667] នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៧ គាត់បានចេញសេចក្ដីថ្លែងការណ៍មួយជំនួសមុខខ្លួនគាត់ផ្ទាល់ និងកម្លាំងយោធភូមិភាគទី២ទាំងអស់ រំលឹកដល់លោក សម រង្ស៊ី ថា "កងទ័ពទាំងមូលត្រូវបានបង្កើតឡើងដោយសម្ដេចតេជោ ហ៊ុន សែន" ដែលជា "មេបញ្ជាការគ្មានទីបញ្ចប់ នៃកម្ពុជា" ហើយកងទ័ពស៊ូស្លាប់ ដើម្បីការពាររដ្ឋាភិបាលរបស់គាត់ ទោះក្នុងកាលៈទេសៈណាក៏ដោយ។[668]*

## VIII. នាយឧត្តមសេនីយ៍ឯកផ្កាយមាស ៣ ចាប ភក្តី នាយរងសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ និង ជាមេបញ្ជាការកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១

### *លោក ចាប ភក្តី ក្រោយសម័យអ៊ុនតាក់ ឆ្នាំ ១៩៩៣-១៩៩៧*

*លោក ចាប ភក្តី ត្រូវបានគេដឹងថា មានស្រុកកំណើតនៅខេត្តព្រៃវែង និងមានទំនាក់ទំនងជាមួយលោក គន់ គីម ដែលបានជួយធានាឱ្យមានការតំឡើងឋានន្តរសក្តិយោធារបស់គាត់។ ថ្ងៃខែឆ្នាំកំណើតផ្លូវការរបស់គាត់ គឺថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៥៩។[669] គាត់បានលេចមុខមាត់ នៅក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ក្នុងនាមជាមេបញ្ជាការរងនៃកងពលអន្តរាគមន៍លេខ ១ ទើបរៀបចំថ្មីរបស់កងយោធពលខេមរភូមិន្ទ និងមានអតីតជាយុទ្ធជនមកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច បម្រើការងារនៅក្នុងអង្គភាពនោះ។[670]*

---

[667] មេបញ្ជាការ និងកងទ័ពយោធភូមិភាគទី២៖ កងទ័ពគ្មានថ្ងៃបែចុងកាណុងទៅរដ្ឋាភិបាលទេ មានតែបែចុងកាណុងទៅសមរង្ស៊ី និងកឹមសុខា។

[668] មេបញ្ជាការ និងកងទ័ពយោធភូមិភាគទី២ សូមផ្ដាំទៅកូនក្បត់ជាតិសមរង្ស៊ី កងទ័ពបង្កើតឡើងដោយសម្ដេចតេជោ ទោះក្ស័យជីវិតក៏ស្មោះសម្ដេចជានិច្ច។

[669] បញ្ជីឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតបណ្ដោះអាសន្នឆ្នាំ២០១៧ ឯកសារ ០៦-៧១៦-១៨៦។

[670] UNOSGRC, "កងយោធពលខេមរភូមិន្ទ" ឆ្នាំ១៩៩៥, COHCHR, "ការសម្ភាសន៍សម្រិតសម្រាំង នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧" ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៩៧, វិទ្យុភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៦។

*លោក ចាប ភក្តី ត្រូវបានផ្ទេរពីកងពលធំលេខ១១ទៅកាន់កងវរសេនាធំលេខ៩១១ ដែលជាអង្គភាពកងកម្លាំងពិសេសមួយ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩៤ និងត្រូវបានប្រកាសសម្ពោធជាផ្លូវការ នៅថ្ងៃទី៩ វិច្ឆិកា ឆ្នាំ១៩៩៥។*[671] *អង្គភាពនេះបានទទួលការហ្វឹកហ្វឺនពីប្រទេសឥណ្ឌូនេស៊ី ក្នុងសម័យលោកស៊ូហាតូ ហើយក៏បានទទួលការហ្វឹកហ្វឺនពីប្រទេសបារាំងផងដែរ។ ដំបូងឡើយ អង្គភាពនេះស្ថិតក្រោមបញ្ជាការរបស់នាយទាហានគណបក្សហ្វ៊ុនស៊ិនប៉ិច ប៉ុន្តែលោក ចាប ភក្តី បានជំនួសនាយទាហានរូបនោះ។*[672] *នៅចុងឆ្នាំ១៩៩៥ ដល់ដើមឆ្នាំ១៩៩៦ ពលទាហាននៃអង្គភាពនោះត្រូវបានដាក់ពង្រាយដើម្បីប្រឆាំងនឹងការងើបបះបោររបស់ក្រុមខ្មែរក្រហម។*[673]

*នៅដើមឆ្នាំ១៩៩៧ កងវរសេនាធំលេខ ៩១១ ត្រូវបានតំឡើងឋានៈ និងប្តូរឈ្មោះទៅជាកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១។*[674] *មកត្រឹមពេលនោះ ប្រទេសបារាំងបានបញ្ចប់ការហ្វឹកហ្វឺនរបស់ខ្លួនដល់អង្គភាពនេះអស់មួយភាគធំ ប៉ុន្តែអង្គភាពនេះនៅបន្តទទួលការហ្វឹកហ្វឺនពីប្រទេសឥណ្ឌូនេស៊ី ហើយជាបន្តបន្ទាប់ទៀត បានទទួលជំនួយកាន់តែច្រើនពីប្រទេសកូរ៉េខាងត្បូង។*[675] *ការភ្ជាប់ទំនាក់ទំនងនេះ គឺដោយសារកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ បានផ្តល់ការការពារសន្តិសុខសម្រាប់រោងចក្ររបស់កូរ៉េខាងត្បូងនៅក្នុងតំបន់ភ្នំពេញ។*[676]

## *លោក ចាប ភក្តី និងរដ្ឋប្រហាររបស់លោក ហ៊ុន សែន នៅឆ្នាំ ១៩៩៧*

---

[671] "អ្នកនាំពាក្យយោធាបង្ហាញផែនការកំណែទម្រង់" Cambodia Times, ថ្ងៃទី១៤-២០ ខែសីហា ឆ្នាំ១៩៩៤, "ការកាត់បន្ថយជំនួយយោធារបស់បារាំង" Phnom Penh Post, ថ្ងៃទី១៧-៣០ ខែឧសភា ឆ្នាំ១៩៩៦, ស្ថានទូតអាមេរិក នៅកម្ពុជា "កងយោធពលខេមរភូមិន្ទ" ឆ្នាំ២០០៣។

[672] COHCHR, "ការសម្ភាសន៍សម្រិតសម្រាំង នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧" ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៩៧។

[673] "ខ្មែរក្រហមបើកការវាយប្រហារវិញ ក្រោយកាត់ផ្តាច់ទំនាក់ទំនងការងារ" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២០ ខែមិថុនា ដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៥, "សមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការកាន់កាប់ខេត្តប៉ៃលិន នៅមិនទាន់ច្បាស់" ***សារព័ត៌មាន សេរីភាពថ្មី*** ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៦, "រដ្ឋាភិបាលកម្ពុជា វាយប្រហារខ្មែរក្រហម" *បាងកកប៉ុស្តិ៍*, ថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៦។

[674] ស្ថានទូតអាមេរិកប្រចាំកម្ពុជា "កងយោធពលខេមរភូមិន្ទ" ឆ្នាំ២០០៣។

[675] "ឯកអគ្គរដ្ឋទូតឥណ្ឌូនេស៊ី ចូលជម្រាបលាលោក ប៉ុល សារឿន បន្ទាប់ពីបញ្ចប់បេសកកម្មការទូត នៅកម្ពុជា" (t:GfllflsCfl), http://www.kemlu.go.id/phnompenh/Pages/Print.aspx?ListName=EmbassiesNews&IDP=93&CID=en-US; ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៥ http://www.dap-news.com/2011-06-14-02-39-55/76430-2013-11-28-09-29-27.html (ចូលមើល នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣), "ការកាត់បន្ថយជំនួយយោធាបារាំង" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៧-៣០ ខែឧសភា ឆ្នាំ១៩៩៦។

[676] ការសម្ភាសន៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្លាំមើលសិទ្ធិមនុស្ស (ឈ្មោះអ្នកផ្តល់ការសម្ភាសន៍ ត្រូវបានដកចេញ)។

*កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ គឺជាអង្គភាពគួរឱ្យទុកចិត្តបានបំផុតមួយ ក្នុងចំណោមអង្គភាពគួរឱ្យទុកចិត្តបានបំផុតផ្សេងទៀតរបស់កងយោធពលខេមរភូមិន្ទ នៅក្នុងការផ្ដល់ការគាំទ្រដល់រដ្ឋប្រហាររបស់លោក ហ៊ុន សែន នៅឆ្នាំ១៩៩៧។[677] អង្គភាពនេះ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងចលនារបស់លោក ហ៊ុន សែន ក្នុងការដកហូតអាវុធពីគណបក្សហ៊្វុនស៊ិនប៉ិច ដូចជាការវាយប្រហារថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៧ លើទីតាំងរបស់គណបក្សហ៊្វុនស៊ិនប៉ិចដែលស្ថិតនៅភាគខាងជើងទីក្រុងភ្នំពេញ។[678] ដោយអនុវត្តតាមបទបញ្ជារបស់លោក គន់ គីម នៅព្រលឹមព្រឹកថ្ងៃទី៥ ខែកក្កដា លោក ចាប ភក្ដី បានរៀបចំប្រតិបត្តិការវាយប្រហារមូលដ្ឋាននានារបស់គណបក្សហ៊្វុនស៊ិនប៉ិចនៅភាគខាងលិចទីក្រុងភ្នំពេញ ។[679] បន្ទាប់មក កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ បានចូលរួមវាយប្រហារទីតាំងសំខាន់របស់គណបក្សហ៊្វុនស៊ិនប៉ិច នៅបន្ទាយតាំងក្រសាំង ជាទីដែលមេបញ្ជាការសំខាន់បំផុតរបស់គណបក្សហ៊្វុនស៊ិនប៉ិច គឺលោក ញឹក ប៊ុនឆៃ ដែលនៅពេលនោះ គាត់គឺជាអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីជាន់ខ្ពស់របស់គណបក្សហ៊្វុនស៊ិនប៉ិចផ្សេងទៀត កំពុងស្ថិតនៅ។ អង្គភាពនេះ ក៏បានវាយប្រហារទីតាំងផ្សេងៗរបស់គណបក្សហ៊្វុនស៊ិនប៉ិច នៅអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង ក្រៅក្រុងភ្នំពេញផងដែរ។[680]*

*បន្ទាប់ពីការវាយប្រហារបន្ថែមទៀតនៅក្នុង និងជុំវិញទីក្រុងភ្នំពេញ នៅថ្ងៃទី៥-៦ ខែកក្កដាមក កងកុម្ម៉ង់ដូរចល័តនៃកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ បានធ្វើប្រតិបត្តិការ ដោយប្រើប្រាស់ឧទ្ធម្ភាគចក្រមួយចំនួន អស់រយៈពេលជាច្រើនថ្ងៃ ដើម្បីតាមប្រដេញរកកងកម្លាំងហ៊្វុនស៊ិនប៉ិច ដែលកំពុងភៀសខ្លួនទៅភាគខាងជើង ចូលខេត្តកំពង់ស្ពឺ និងឆ្ពោះទៅកាន់ខេត្តកំពង់ឆ្នាំង។ ពួកគេស្ថិតក្រោមការបញ្ជារបស់លោក ហ៊ុន សែន ឱ្យ "បោសសម្អាតកម្លាំងអនាធិបតេយ្យទាំងអស់ និងកម្ទេចពួកគេ គឺពួកគេទាំងអស់" នេះជាការប្រើប្រាស់សំដីដើមរបស់លោក ហ៊ុន សែន ចំពោះគណបក្សហ៊្វុនស៊ិនប៉ិច និងជាភាសាដែលរបបខ្មែរក្រហម*

---

677 UNOSGRC, "របាយការណ៍លេខ ៥៧២"។

678 ការសម្ភាសន៍ជាមួយលោក ហ៊ុន សែន ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧, ការសម្ភាសន៍របស់លោក Brad Adams ជាមួយលោក ថាច់ សាង នាយទាហានហ្វ៊ុនស៊ិនប៉ិច ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០។

679 ការសម្ភាសន៍របស់លោក Brad Adams ជាមួយនាយទាហានជាន់ខ្ពស់ហ្វ៊ុនស៊ិនប៉ិច ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០១,ការ   សម្ភាសន៍របស់លោក Brad Adams ជាមួយលោក ថាច់ សាង ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០, ការសម្ភាសន៍របស់លោក Brad Adams ជាមួយនាយទាហានគណបក្សប្រជាជនកម្ពុជា ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីស្ថានទូតអាមេរិក ខែមេសា ឆ្នាំ២០០០។

680 ការសម្ភាសន៍របស់លោក Brad Adams ជាមួយនាយទាហានគណបក្សប្រជាជនកម្ពុជា ហ្វ៊ុនស៊ិនប៉ិច និងនាយទាហានបរទេស ដែលឈរជើងនៅក្នុងទីក្រុងភ្នំពេញ។

និយមប្រើ ក្នុងការសម្លាប់មនុស្សចោល។[681]

កងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ បានចាប់ខ្លួនមន្ត្រី អង្គរក្ស និងកងទ័ពហ៊្វុនស៊ិនប៉ិចយ៉ាងតិចបំផុត ៤០នាក់។[682] ក្នុងចំណោមនោះ យ៉ាងហោចណាស់មានមន្ត្រីជាន់ខ្ពស់ហ៊្វុនស៊ិនប៉ិចចំនួន៨នាក់ ដែលត្រូវបានសម្លាប់ដោយកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ឬដោយអង្គភាពផ្សេងៗទៀតនៃគណបក្សប្រជាជនកម្ពុជា ដែលបានទទួលមន្ត្រីទាំងនោះពីកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១។[683] មន្ត្រីទាំងប្រាំបីនាក់នេះស្ថិតក្នុងចំណោមមនុស្សយ៉ាងហោចណាស់៤១នាក់ និងអាចច្រើនដល់ទៅ៦០នាក់ ដែលត្រូវបានសម្លាប់នៅក្នុងការប្រហារជីវិតក្រៅប្រព័ន្ធតុលាការដែលទាក់ទងនឹងរដ្ឋប្រហារ នេះបើយោងតាមរបាយការណ៍ថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧ របស់ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា។[684]

កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ បានឃុំខ្លួនមន្ត្រីយោធាហ៊្វុនស៊ិនប៉ិច៣២នាក់ផ្សេងទៀត នៅក្នុងស្នាក់ការកណ្តាលរបស់ខ្លួន នៅកំបូល ធ្វើទារុណកម្មពួកគេមួយចំនួន បង្ខំឱ្យសារភាពក្លែងក្លាយថា ពួកគេគឺជា "ខ្មែរក្រហម" ឬថា រដ្ឋប្រហាររបស់លោក ហ៊ុន សែន គឺជា អំពើត្រឹមត្រូវ ដោយសារលោក ញឹក ប៊ុនឆៃ មានផែនការសម្ងាត់ប៉ុនប៉ងផ្តួលរំលំលោក ហ៊ុន សែន។[685] ដោយប្រឈមមុខជាមួយមន្ត្រីការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ អំពីការឃុំខ្លួននោះ ដំបូងឡើយ លោក ចាប ភក្តី បានបដិសេធទាំងស្រុងចំពោះការឃុំខ្លួនទាំងនោះ បន្ទាប់មកបានព្យាយាមបិទបាំងការពិត។ ទោះបែបនោះក្តី ខណៈប្រឈមមុខជាមួយមន្ត្រីសិទ្ធិមនុស្សអង្គការសហប្រជាជាតិ យ៉ាងហោចណាស់ក៏មានមនុស្សម្នាក់កំពុងត្រូវឃុំខ្លួននៅទីនោះ

681 ការសម្ភាសន៍ជាមួយលោក ហ៊ុន សែន ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧, សូមមើលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យសហចៅក្រមស៊ើបអង្កេត "ដីការដំណោះស្រាយ" (D៤២៧ ភាសាអង់គ្លេស) ទំព័រ ៤៨, ៥១, ៥៨, ១៨៨, ២០២-៥, ២៣៣-៤ និង២៦៦។

682 COHCHR, "តាំងក្រសាំង និងកំបូល" ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៧, COHCHR, "ស៊េរីទីពីរនៃការសម្ភាសន៍ជាមួយទាហានហ៊្វុនស៊ិនប៉ិច ដែលត្រូវឃុំខ្លួននៅក្នុងជំរំ ឬ បន្ទាយតាំងក្រសាំង" ថ្ងៃ២៨ ខែកក្កដា ឆ្នាំ១៩៩៧,COHCHR,"ការប្រហារជីវិតក្រៅប្រព័ន្ធតុលាការ នៅជុំវិញថ្ងៃទី១២ ខែកក្កដា ដោយកងទ័ពឆ័ត្រយោងនៃកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ នៅឃុំត្បែងខ្ពស់ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង" ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧។

683 ការសម្ភាសន៍របស់លោក Brad Adams ជាមួយមន្ត្រីគណបក្សប្រជាជនកម្ពុជា, COHCHR,"ការសម្ភាសន៍សម្រិតសម្រាំងនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៧" ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៩៧, "ការសម្ភាសន៍ជាមួយអង្គរក្សរបស់លោក ញឹក ប៊ុនឆៃ" ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៧ និងថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៧។

684 អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ *"ប្រាប់ពួកគេទៅថា ខ្ញុំចង់សម្លាប់ពួកគេ"* ទំព័រ ៥០។

685 COHCHR,"តាំងក្រសាំង និងកំបូល" ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៧, COHCHR, "ស៊េរីទីពីរនៃការសម្ភាសន៍ជាមួយទាហានហ៊្វុនស៊ិនប៉ិច ដែលត្រូវឃុំខ្លួននៅក្នុងជំរំ ឬ បន្ទាយតាំងក្រសាំង" ថ្ងៃ២៨ ខែកក្កដា ឆ្នាំ១៩៩៧, COHCHR,"ចុះជួប និងសម្ភាសជាមួយទាហាន ដែលត្រូវចាប់ខ្លួនបាន នៅជំរំ ឬបន្ទាយតាំងក្រសាំង ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៧" ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៧។

នៅឡើយ។ យោងតាមរបាយការណ៍របស់អង្គការសហប្រជាជាតិដែលផ្តែកលើការសម្ភាសន៍ជាមួយជនជាប់ឃុំរូបនោះ បន្ទាប់ពីត្រូវបានដោះលែងដោយកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ បានឱ្យដឹងថា "ទារុណកម្មមកលើខ្លួន រួមមាន ការវាយនឹងខ្សែក្រវ៉ាត់ ដើងតុធ្វើពីឈើ ក្តារឈើ ការទាត់ជាក់នឹងស្បែកជើងយោធា និងការប្រើដង្កង់ ការដាល់លើផ្ទៃមុខ និងដងខ្លួនជាដើម។ ទារុណកម្មនេះក៏រួមមានការគំរាមសម្លាប់ដោយភ្ជង់កាំភ្លើងមកលើក្បាល និងគំរាមបាញ់សម្លាប់ផងដែរ។ ក៏មានផងដែរនូវការប្រើអង្គុំដែកកៀបម្រាមដៃ ឬដៃរបស់ជនជាប់ឃុំមួយចំនួនរហូតដល់ពួកគេព្រមផ្តល់ចម្លើយទៅតាមការចង់បានរបស់ក្រុមនោះ។"[686]

## លោក ចាប ភក្តី ចាប់ពីឆ្នាំ១៩៩៧

នៅឆ្នាំ២០០៦ លោក ចាប ភក្តី បានជាប់ពាក់ព័ន្ធនឹងការឃុំខ្លួនតាមទំនើងចិត្ត នូវទាហានមួយរូបនៃកងពលតូចទ័ពពិសេសឆ័ត្រយោងលេខ៩១១ ទាក់ទងនឹងវិវាទដីធ្លីមួយកន្លែងក្នុងទីក្រុងភ្នំពេញ។ ដោយគាត់ឈរនៅខាងភាគីវិវាទម្ខាងទៀត លោក ចាប ភក្តី បានហៅទាហានរូបនោះមកជួបដើម្បីជំរុញឱ្យគាត់យល់ព្រមទទួលយកដំណោះស្រាយ ហើយបន្ទាប់មកក៏ចាប់បុរសនោះឃុំខ្លួននៅពេលគាត់បដិសេធ។ ទាហាននោះបានជាប់ក្នុងគុកងងឹតអស់រយៈពេលបីសប្តាហ៍ ដោយសារត្រូវបានចោទប្រកាន់តាមទំនើងចិត្តថាបាន "រំលោភវិន័យយោធា"។[687]

នៅឆ្នាំ២០១០ កងទ័ពកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ដែលជាប់ពាក់ព័ន្ធនឹងវិវាទដីធ្លីនៅជិតមូលដ្ឋានហ្វឹកហ្វឺននៃកងពលតូចនេះ នៅស្រុកមេមត់ ដែលនៅពេលនោះស្ថិតក្នុងខេត្តកំពង់ចាម បានវាយប្រហារលើគ្រួសារចំនួនបួន នៅក្នុងតំបន់នោះ ដែលបានក្រោកឈរតតាំងនឹងកងពលតូចនេះ ដើម្បីទាមទារយកដីរបស់ពួកគេមកវិញ ដោយបានវាយដំលើរាងកាយរបស់ពួកគេ បំផ្លាញដំណាំ និងដុតផ្ទះរបស់ពួកគេ ដើម្បីបង្ខំឱ្យពួកគេចាកចេញ។[688]

លោក ចាប ភក្តី បានបន្តឡើងតំណែងនៅក្នុងគណបក្សប្រជាជនកម្ពុជា និងកងយោធពលខេមរភូមិន្ទ។ គាត់

---

[686] Brad Adams, "កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ មានប្រវត្តិសាហាវឃោរឃៅ។"

[687] ពីប្រភពដដែល Ibid.

[688] ពីប្រភពដដែល Ibid.

*បានចូលរួមក្នុងគណកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា នៅឆ្នាំ២០០៥។[689] គាត់ក៏ជានាយរងសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ ស្ថិតក្រោមលោក គន់ គីម ដោយផ្ទាល់ និងជាទីប្រឹក្សាផ្ទាល់របស់លោក ហ៊ុន សែន។[690]*

## *លោក ចាប ភក្តី ក្រោយពេលបោះឆ្នោតឆ្នាំ ២០១៣*

*ក្នុងអំឡុងពេលក្រោយការបោះឆ្នោតឆ្នាំ២០១៣ មានបាតុកម្មធំៗតវ៉ាប្រឆាំងនឹងលទ្ធផលផ្លូវការនៃការបោះឆ្នោត និងកូដកម្មរបស់កម្មកររោងចក្រទាមទារតំឡើងប្រាក់ឈ្នួល និងកែលម្អលក្ខខណ្ឌការងារ។ ជាផ្នែកមួយក្នុងការទប់ទល់ជាមួយក្រុមបាតុករ កម្លាំងនៃកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ត្រូវបានបង្កើនតាមរយៈយុទ្ធនាការជ្រើសរើសកងកម្លាំងនៅតាមខេត្ត ហើយកងពលតូចនេះបានចាប់ផ្តើមបើកប្រតិបត្តិការក្រោមការបញ្ជាដោយផ្ទាល់ពីនាយករដ្ឋមន្ត្រី។[691]*

*នៅថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៣ រដ្ឋាភិបាលបានប្រកាសឱសានវាទ ឱ្យកម្មករបញ្ឈប់កូដកម្ម និងបាតុកម្មពាក់ព័ន្ធនានា ត្រឹមថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ ដោយបានព្រមានថា ប្រសិនបើមិនគោរពតាមថ្ងៃឱសានវាទនោះទេរដ្ឋាភិបាលនឹងដាក់ពង្រាយកងកម្លាំងសន្តិសុខ បង្រ្កាបសកម្មភាពរបស់កម្មករដែលរដ្ឋាភិបាលចាត់ទុកថាខុសច្បាប់។[692] ដោយមិនព្រមគោរពតាមការហាមឃាត់នេះ កម្មករបានចាប់ផ្តើមប្រមូលផ្តុំគ្នា និងធ្វើបាតុកម្ម*

---

[689] "សមាជិកថ្មី ១២១នាក់ ពង្រឹកគណៈកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា" *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៥ http://www.phnompenhpost.com/national/121-new-members-boost-cpp-central-committee (ចូលមើល នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៥)។

[690] "កងទ័ពឆ័ត្រយោងពិសេសនៃកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ស្ថិតក្នុងស្ថានភាពត្រៀម ដើម្បីជួយសង្គ្រោះពលរដ្ឋរងគ្រោះដោយទឹកជំនន់" ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/69799-2013-08-07-10-15-20.html (មើលថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣)។

[691] "ពិធីសំណេះសំណាល និងអមដំណើរអ្នកចូលបម្រើទ័ពជាមួយ RCAF" ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៣ http://kpt- news.com/index.php?option=com_content&view=article&id=37770:2013-11-29-09-01-19&catid=1:latest&Itemid=65 (ចូលមើល នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣), "កងទ័ពឆ័ត្រយោងពិសេសនៃកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ស្ថិតក្នុងស្ថានភាពត្រៀម ដើម្បីជួយសង្គ្រោះពលរដ្ឋរងគ្រោះដោយទឹកជំនន់" ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/69799-2013-08-07-10-15-20.html (ចូលមើល នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣)។

[692] "រដ្ឋាភិបាលបញ្ចេញផែនការផ្លូវច្បាប់ ដើម្បីបំបែកកូដកម្មរបស់កម្មកររោងចក្រ" ***ខេមបូឌា ដេលី*** ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ https://www.cambodiadaily.com/archives/govt-unveils-legal-plan-to-break-garment-industry-strike-49763/ (មើល នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤)។

នៅព្រឹកថ្ងៃទី២ ខែមករា នៅមុខរោងចក្រជាច្រើន នៅជាយក្រុងភ្នំពេញ។ អង្គភាពយោធា នគរបាល និងកង រាជអាវុធហត្ថ បានចាប់ផ្តើមដាក់ពង្រាយភ្លាមៗ ដើម្បីបំបែកក្រុមបាតុករ។ នៅកន្លែងខ្លះ ពួកគេចាប់ផ្តើមធ្វើសកម្មភាពនោះភ្លាម ចំណែកនៅកន្លែងខ្លះទៀត ពួកគេបានដកថយ បន្ទាប់ពីប្រមូលបានព័ត៌មានបឋម។

កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ជាអង្គភាពទីមួយ ដែលចាត់វិធានការចម្បង។ អង្គភាពនេះ បានដាក់ពង្រាយកងទ័ពពីទីបញ្ជាការដ្ឋានរបស់ខ្លួន ទៅកាន់រោងចក្រកាត់ដេរយ៉ាក់ជីន (Yakjin) នៅក្បែរនោះ ដែលជារោងចក្ររបស់ជនជាតិកូរ៉េខាងត្បូង ដែលមានកម្មករមួយចំនួនធ្វើកូដកម្ម ហើយរោងចក្រនេះបានស្នើសុំការការពារពីកងកម្លាំងសន្តិសុខ នេះបើយោងតាមអ្នកនាំពាក្យរដ្ឋាភិបាល និងស្ថានទូតកូរ៉េខាងត្បូង។[693] កងយោធានេះស្ថិតក្រោមការបញ្ជារបស់សាច់ញាតិម្នាក់របស់លោក ចាប ភក្តី ឈ្មោះ ចាប សុភ័ណ្ឌ។[694] សកម្មជនសិទ្ធិការងារ និងសកម្មជនសិទ្ធិដីធ្លីកម្ពុជាជាច្រើន ព្រមទាំងអ្នកតាមដានស្ថានការណ៍មួយចំនួន រួមទាំងមន្ត្រីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិផង បានចាប់ផ្តើមមកដល់ទីតាំងកើតហេតុនោះ។ កងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ បានឃុំខ្លួនកម្មករបីនាក់ ក្នុងចំណោមកម្មកររាប់ពាន់នាក់ ដែលមានវត្តមាននៅទីនោះ ហើយប្រព័ន្ធផ្សព្វផ្សាយរបស់គណបក្សប្រជាជនកម្ពុជាបានចោទប្រកាន់ថា កូដករជាអ្នកធ្វើឱ្យរបងរោងចក្រដួលរលំ។[695]

ទោះបីជាយ៉ាងណាក៏ដោយ កូដកម្មនោះត្រូវបានធ្វើឡើងដោយសន្តិវិធី រហូតដល់ពេលដែលកម្លាំងកងពល

---

[693] "មនុស្សប្រហែល ១០នាក់ ត្រូវបានឃាត់ខ្លួន និងមួយចំនួនទៀតរងរបួស នៅក្នុងការប៉ះទង្គិចគ្នា នៅមុខរោងចក្រ Yakjin" ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ http://vodhotnews.com/18301 (ចូលមើល នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤), http://www.yakjin.com/eng/glo/glo_01_002.asp (ចូលមើល នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤), "អ្នកសង្កេតការណ៍មើលបាតុកម្ម ហៅការបង្ក្រាបរបស់យោធានៅតំបន់សេដ្ឋកិច្ចពិសេសថា ជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ" ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ http://vodhotnews.com/18310 (ទទួលបាន ឬ បានអាន នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤), "ប្រទេសកូរ៉េខាងត្បូងបានលួចប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ដើម្បីទាញយកផលប្រយោជន៍ នៅខណៈពេលដែលប្រទេសកម្ពុជាបង្ក្រាបបាតុកម្មរបស់កម្មករ ដោយហិង្សា" *Morning Sun*, ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៤ http://www.themorningsun.com/general-news/20140109/south-korea-pulled-strings-as-cambodia-violently-smashed- labor-protest (ចូលមើល នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤)។

[694] "កងទ័ពឆ័ត្រយោងត្រូវបានដាក់ពង្រាយនៅកន្លែងបាតុកម្ម៖ មនុស្ស ១៥នាក់ ស្លាប់ និងរបួស" ***ខេមបូឌា ដេលី*** ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/paratroopers-deployed-at-garment-protest-15-detained-injured-49960/ (មើលនៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤)

[695] "កងកម្លាំងឆ័ត្រយោងចាប់ឃុំខ្លួនមេក្រុមចំនួនដប់នាក់ ដែលបានបង្កបញ្ហានៅក្នុងរោងចក្រ Yakjin" (lfl OsWlru sBlG) ថ្ងៃទី២ ខែមករា ឆ្នា២០១៤ http://edition.kpt- news.com/local-news/1808-2014-01-02-08-04-54.html (ចូលមើល នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤), មានកំណត់ត្រារបស់អង្គការសិទ្ធិមនុស្សក្នុងស្រុក ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤, "អ្នកសង្កេតការណ៍មើលបាតុកម្ម ហៅការបង្ក្រាបរបស់យោធានៅតំបនសេដ្ឋកិច្ចពិសេសថា ជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ" ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ http://vodhotnews.com/18310 (ចូលមើល នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤), "., *KPT*, ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៤ http://edition.kpt-news.com/local-news/2027-2014-01-06-09-38-26.html (ចូលមើល នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៤)។

តូចទ័ពពិសេសឆ័ត្រយោង ៩១១ ប្រដាប់ដោយកាំភ្លើងវែង និងអាវុធផ្សេងទៀត បានប្រឈមមុខដាក់គ្នាជាមួយក្រុមកម្មករ ព្រះសង្ឃ និងអ្នកផ្សេងទៀត ដោយមិនអើពើចំពោះការព្យាយាមរបស់មន្ត្រីតាមដានសិទ្ធិមនុស្សក្នុងការបន្ធូរស្ថានការណ៍នៅពេលនោះទេ។[696] កងកម្លាំងកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ក៏បានវាយប្រហារលើកម្មករ និងអ្នកសង្កេតការណ៍ ដោយប្រើប្រាស់បំពង់ទីប កាំបិត ចំពាម និងដំបង ដែលបង្កឱ្យមានភាពចលាចលយ៉ាងឆាប់រហ័ស ជាហេតុធ្វើឱ្យសមាជិកនៃក្រុមកម្មករមួយចំនួន ឆ្លើយតបដោយគប់ដប និងដុំថ្ម ត្រលប់ទៅវិញ។[697] កងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ក៏បានចាប់ខ្លួនមនុស្សជាច្រើនថែមទៀត រួមមានមន្ត្រីការពារសិទ្ធិមនុស្សបួននាក់ និងកម្មករបីនាក់បន្ថែមទៀត ហើយពួកគេទាំងអស់គ្នាបានទទួលរងនូវការវាយដំ ឬបំពារបំពាន នៅពេលកំពុងត្រូវបានចាប់ខ្លួន ឬភ្លាមៗ ក្រោយពេលត្រូវបានបញ្ជូនទៅឃុំខ្លួន ប៉ុន្តែពួកគេមិនបានចូលរួមក្នុងអំពើហិង្សាតបតរបស់ហ្វូងបាតុករនោះឡើយ។[698]

ប្រព័ន្ធផ្សព្វផ្សាយរបស់គ្រួសារលោក ហ៊ុន សែន បានរាយការណ៍ថា កងពលតូចនេះ បានចាប់ខ្លួន និងសួរចម្លើយ "មេខ្លោង" ចំនួន១០នាក់មកពីក្រុមមួយចំនួនដែលបានធ្វើសកម្មភាព បណ្តាលឱ្យ"រាំងស្ទះ"ការងាររបស់រោងចក្រ និង"បង្ក"ឱ្យមានកូដកម្ម ដោយបានចាប់ខ្លួនពួកគេក្នុងពេលធ្វើសកម្មភាពនៅរោងចក្រយ៉ាក់ជីន (Yakjin) ស្ថិតនៅកំបូល។ ប្រព័ន្ធផ្សព្វផ្សាយនេះបានរៀបរាប់ថា ការចាប់ខ្លួនរបស់កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ជាផ្នែកមួយនៃប្រតិបត្តិការទូទៅ ធ្វើឡើងដោយកងរាជអាវុធហត្ថ និងកងកម្លាំងសន្តិសុខផ្សេងទៀត ដើម្បីបង្ក្រាបសកម្មភាពបែបនោះ ហើយមន្ត្រីតាមដានសិទ្ធិមនុស្សបានសង្កេតឃើញថា កងរាជអាវុធហត្ថធ្វើប្រតិបត្តិការរួមគ្នាជាមួយកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ក្នុងអំឡុងពេលធ្វើការ

---

[696] "កងទ័ពឆ័ត្រយោង ត្រូវបានដាក់ពង្រាយទៅកាន់កន្លែងបាតុកម្ម ៖ មនុស្ស ១៥នាក់ បានស្លាប់ និងរបួស" ***ខេមបូឌា ដេលី*** ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/paratroopers-deployed-at-garment-protest-15-detained-injured-49960/ (ចូលមើល នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤), "ការព្រួយបារម្ភ និងអនុសាសន៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ដែលត្រូវបានដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅពេលប្រជុំពិនិត្យជាមុនអំពី កម្ពុជា (ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥)", សេចក្តីថ្លែងការណ៍របស់អង្គការសិទ្ធិមនុស្សអន្តជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ http://www.hrw.org/news/2015/03/04/human-rights-watch-concerns-and-recommendations-cambodia-submitted-un-human-rights-c.

[697] "សេចក្តីប្រកាសព័ត៌មាន ៖ អង្គភាពបញ្ជាការពិសេសយោធា ត្រូវបានដាក់ពង្រាយដើម្បីបង្ក្រាបកម្មករដែលកំពុងធ្វើកូដកម្ម" LICADHO et al. សេចក្តីប្រកាសព័ត៌មាន ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ http://www.licadho-cambodia.org/pressrelease.php?perm=333 (មើល នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤)។

[698] "ការព្រួយបារម្ភ និងអនុសាសន៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ដែលត្រូវបានដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅពេលប្រជុំពិនិត្យជាមុនអំពី កម្ពុជា (ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥)" សេចក្តីថ្លែងការណ៍របស់អង្គការ Human Rights Watch ថ្ងៃទី៤ ខែមីនា ឆ្នា២០១៥ http://www.hrw.org/news/2015/03/04/human-rights-watch-concerns-and-recommendations-cambodia-submitted- un-human-rights-c.

ចាប់ខ្លួនមនុស្សនៅ រោងចក្រយ៉ាក់ជីន (Yakjin)។[699] កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ក៏បានឃុំខ្លួនព្រះសង្ឃប្រាំអង្គ ដែលបានចូលរួមជាមួយក្រុមកម្មករតវ៉ាប្រឆាំងនឹងការចាប់ខ្លួនមនុស្សប៉ុន្មាននាក់ដំបូង ដោយបានដោះស្បង់ចីវររបស់ព្រះអង្គនៅមន្ទីរឃុំឃាំង។[700] ក្រោយការសួរចម្លើយបឋមនៅក្នុងមន្ទីរឃុំឃាំងនៃកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញបានចាប់ផ្ដើមធ្វើការចោទប្រកាន់លើសកម្មជន និងកម្មករទាំង១០នាក់ ខណៈដោះលែងអតីតព្រះសង្ឃទាំងប្រាំអង្គ។[701] កងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ បានឃុំខ្លួនពួកគេដោយមិនឱ្យទាក់ទងអ្នកខាងក្រៅអស់ពេញមួយយប់ បន្ទាប់មកពួកគេត្រូវបានបញ្ជូនទៅតុលាការក្រុងភ្នំពេញ និងផ្ទេរឱ្យស្ថិតក្រោមការឃុំខ្លួនរបស់នគរបាលវិញ។[702]

អ្នកទាំង១០នោះស្ថិតក្នុងចំណោមមនុស្ស២៥នាក់ ដែលនៅទីបញ្ចប់ត្រូវបានជំនុំជម្រះដោយតុលាការ ពាក់ព័ន្ធនឹងការតវ៉ា និងបាតុកម្មនៅចុងឆ្នាំ២០១៣ និង២០១៤ ក្រោមបទបង្កហេតុ ញុះញង់ ឬការប្រព្រឹត្តអំពើហិង្សាដោយផ្ទាល់ ដែលបង្ករបួសស្នាមដល់កងកម្លាំងសន្តិសុខ និងខូចខាតទ្រព្យសម្បត្តិ។ ពួកគេត្រូវបានផ្ដន្ទាទោស ទោះបីជាខ្វះភស្ដុតាងភ្ជាប់ពួកគេជាមួយបទល្មើសដែលត្រូវបានចោទប្រកាន់ទាំងនោះក៏ដោយ។ នៅក្នុងករណី រោងចក្រយ៉ាក់ជីន (Yakjin) តុលាការមិនបានសាកសួរឱ្យបានស៊ីជម្រៅអំពីថា តើអ្នកណាម្នាក់ក្នុងចំណោមទាំង១០នាក់ដែលត្រូវបានចោទប្រកាន់នោះ បានចូលរួមប្រើអំពើហិង្សា និងបង្ករបួសស្នាម ឬបង្កការខូចខាតទ្រព្យសម្បត្តិនោះទេ ឬថាតើសកម្មជនទាំងបួននាក់នោះ ពិតជាបានព្យាយាមធ្វើឱ្យស្ថានភាពនៅពេលនោះស្ងប់ស្ងាត់ តាមរយៈការជំរុញឱ្យមានការប្រកាន់ភាពអហិង្សា ឬមួយពួកគេគ្រាន់តែតាម

[699] "កងកម្លាំងឆ័ត្រយោង ៩១១ បានចាប់ឃុំខ្លួនមេក្រុម១០នាក់ ពីបទបង្កការរំខាននៅក្នុងរោងចក្រ Yakjin" ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ http://edition.kpt-news.com/local-news/1808-2014-01-02-08-04-54.html (ចូលមើល នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤), LICADHO LINE Monitoring Group chronology, ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤។

[700] "កងកម្លាំងឆ័ត្រយោង ៩១១ បានចាប់ឃុំខ្លួនមេក្រុម១០នាក់ពីបទបង្កការរំខាននៅក្នុងរោងចក្រ Yakjin" ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ http://edition.kpt-news.com/local-news/1808-2014-01-02-08-04-54.html (ចូលមើល នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤), "មន្ត្រីសិទ្ធិមនុស្ស ៖ ព្រះសង្ឃប្រាំអង្គត្រូវបានចាប់ព្រះកាយ និងផ្សឹកដោយអាជ្ញាធរ ដើម្បីផ្ដន្ទាទោសព្រះអង្គ បន្ទាប់ពីការផ្ទុះអំពើហិង្សានៅមុខរោងចក្រ Yakjin" ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤, http://vodhotnews.com/18309 (ចូលមើល នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤)។

[701] "ព្រះរាជអាជ្ញាអមតុលាការដំបូងសម្រេចចិត្តឃុំខ្លួនមនុស្ស ១៥នាក់ជាបណ្ដោះអាសន្ន" ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤, http://vodhotnews.com/18317 (មើល នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤); "ព្រះរាជអាជ្ញាអមតុលាការដំបូងសម្រេចចិត្តឃុំខ្លួនលោក វ៉ន ពៅ និងសកម្មជនសហជីព៩នាក់ផ្សេងទៀតជាបណ្ដោះអាសន្ន" ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ http://vodhotnews.com/18342 (មើលនៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤)

[702] "សេចក្ដីថ្លែងការព័ត៌មានរួមគ្នា ៖ ជនស៊ីវិលបានស្លាប់ និងរងរបួស បង្កឡើងដោយកងកម្លាំងសន្តិសុខ នៅក្នុងបាតុកម្មក្នុងទីក្រុងភ្នំពេញ" LICADHO, et al. សេចក្ដីថ្លែងការណ៍ព័ត៌មានរួមគ្នា ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ http://www.licadho-cambodia.org/pressrelease.php?perm=334 (ចូលមើល នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤)។

*ដានស្ដានការណ៍នោះ ឬ យ៉ាងណានោះឡើយ។*[703]

*នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ មនុស្សទាំង២៥នាក់ត្រូវបានផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារ និងទទួលបានការព្យួរទោស។ ការជំនុំជម្រះក្ដីរបស់ពួកគេ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជាប្រព័ន្ធរបស់រដ្ឋាភិបាល ដើម្បីបិទបាំងការប្រើប្រាស់កងកម្លាំងហួសប្រមាណរបស់កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ និងកងកម្លាំងសន្តិសុខផ្សេងទៀតក្នុងការបង្រ្កាបបាតុកម្ម និងកូដកម្ម។ គ្មានកងកម្លាំងសន្តិសុខ ឬមេបញ្ជាការរូបណា ធ្លាប់ត្រូវបានផ្ដន្ទាទោសឡើយ ឬទទួលវិន័យចំពោះការសម្លាប់ ឬសកម្មភាពផ្សេងទៀតឡើយ។*[704] *ផ្ទុយទៅវិញ នៅឆ្នាំ២០១៤ កងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ បានទទួលការលើកសរសើរពីកងយោធពលខេមរភូមិន្ទ ថាជា"អង្គភាពគំរូ" ដែលតែងតែ "ចូលរួមគ្រប់ពេលវេលា និងគ្រប់ទីកន្លែងក្នុងការអនុវត្ត" រាល់បទបញ្ជារបស់លោក ហ៊ុន សែន រួមទាំងតាមរយៈ "ការការពារបានយ៉ាងល្អបំផុត ប្រកបដោយគុណតម្លៃ និងភាពអង់អាចនូវសន្តិសុខ និងសុវត្ថិភាព" នៃទីក្រុងភ្នំពេញ។*[705]

*នៅខែកក្កដា ឆ្នាំ២០១៤ នៅឯពិធីមួយ ក្រោមអធិបតីភាពរបស់លោក គន់ គីម កងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ត្រូវបានជំរុញឱ្យ "គាំទ្រទាំងស្រុង" ដល់លោក ហ៊ុន សែន ក្នុងការបន្តធ្វើជានាយករដ្ឋមន្ត្រី។*[706] *ដើម្បីបំពេញកិច្ចការនេះ និងកិច្ចការផ្សេងទៀត នៅចុងខែនោះ កងពលតូចនេះបានចាប់ផ្ដើមវគ្គហ្វឹកហ្វឺនជំនាញ "បង្រ្កាបការបះបោរ" ក្នុងពេលធ្វើសមយុទ្ធបាញ់គ្រាប់ពិត ក្រោមអធិបតីភាពរបស់លោក គន់ គីម។*[707]

---

703 "កម្ពុជា ៖ ការផ្ដន្ទាទោសទុកជាមោឃៈ ចំពោះសកម្មជន និងកម្មករ ២៥នាក់" សេចក្ដីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ាយ វ៉ច្ឆ ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៤ http://www.hrw.org/news/2014/06/01/cambodia-quash-convictions-25-activists-workers.

704 ពីប្រភពដដែល Ibid.

705 "ការបើកវគ្គហ្វឹកហ្វឺនជំនាញលើកទី ១៧ នៅអង្គភាពកងកម្លាំងពិសេសលេខ ៩១១" ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ http://www.nokorwatnews.com/detailnews.php?newsid=47897&mnu=2&cid=4#sthash.rfLaqztG.dpb, (ចូលមើល នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥), នាយឧត្តមសេនីយ៍ គន់ គីម និងនាយឧត្តមសេនីយ៍ ជា តារា ចុះពិនិត្យការត្រៀមខ្លួនបាញ់គ្រាប់ ១០៥ មីលីម៉ែត្រ របស់កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១" ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/90002-2014-07-06-08-04-56.html (ចូលមើល នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៤)។

706 "កងកម្លាំងប្រដាប់អាវុធឈរជើងជួរមុខ បានទទួលអាវភ្លៀងរាប់ពាន់អាវ ពីសម្ដេចតេជោ ហ៊ុន សែន និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត" ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/90823-2014-07-18-11- 36-54.html (ចូលមើល នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤)។

707 "ការហ្វឹកហ្វឺនកងកុម្ម៉ង់ដូរពិសេសលេខ ៩១១ ក្នុងការសាកល្បងបាញ់គ្រាប់ពិតនៅតំបន់ព្រំដែន" ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/91301-2014-07-25- 09-11-23.html, (ចូលមើល នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤), "នាយឧត្តមសេនីយ៍ គន់ គីម ចូលរួមធ្វើជាអធិបតី ក្នុងពិធីបិទវគ្គហ្វឹកហ្វឺនអំពី ការលោតឆ័ត្រយោងលើកទី ៦ និងវគ្គហ្វឹកហ្វឺនកងកុម្ម៉ង់ដូរលើកទី ៨" ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤ http://www.nokorwatnews.com/detailnews.php?newsid=43340&mnu=2&cid=4 (ចូលមើលនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤)។

ដូចគ្នានឹងប្រតិបត្តិការលើកមុនរបស់ខ្លួនដែរ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ កងទ័ពកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ បានរារាំងបាតុកម្មរបស់កម្មកររោងចក្រមួយនៅជិតទីបញ្ជាការដ្ឋានរបស់ខ្លួន នៅកំបូល ដែលតវ៉ាប្រឆាំងនឹងអ្វីដែលពួកគេចាត់ទុកថា ជាការបណ្តេញកម្មករចេញពីការងារ ដោយអយុត្តិធម៌។[708] ក្រោយមកទៀត អង្គភាពនេះបានទទួលការសរសើរពីនាយរងសេនាធិការចម្រុះ និងមេបញ្ជាការរងកងទ័ពជើងគោកលោក ហ៊ុន ម៉ាណែត ដែលជាកូនច្បងរបស់លោក ហ៊ុន សែន ចំពោះការបង្ក្រាបលើអ្វីដែលលោកហៅថា "ការបង្កអសន្តិសុខ" នៅក្នុងសង្គមកម្ពុជា។[709]

នៅខែសីហា ឆ្នាំ២០១៥ កងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ បានចាប់ផ្តើមកម្មវិធីមួយ ប្រហាក់ប្រហែលនឹងនគរបាលប្រយុទ្ធអាបី (A3) ដែលបង្កើតឡើងដោយសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៨៦ ហើយក្រោយមកត្រូវបានរំលាយចោលវិញនៅឆ្នាំ១៩៩១។ កម្មវិធីរបស់កងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ មានដូចជាការហ្វឹកហ្វឺនមន្ត្រីនគរបាលដែលត្រូវបានជ្រើសរើស ដើម្បីឱ្យក្លាយជា "កងកម្លាំងអន្តរាគមន៍ពិសេស" មានសមត្ថភាពប្រើប្រាស់ "អាវុធរបស់ទ័ពថ្មើរជើង" រួមទាំងកាំភ្លើងលបបាញ់ពីចម្ងាយ ដើម្បីចូលរួមគ្នាជាមួយកងទ័ពនៅក្នុង "ការលុបបំបាត់ស្ថានការណ៍អាក្រក់" ដែលបង្កើតឡើងដោយ "ក្រុមអមិត្ត" របស់រដ្ឋាភិបាល និងអ្នកផ្សេងទៀត "ដែលមាននិន្នាការប្រឆាំង" នៅពេលណាដែលនគរបាលសាមញ្ញមិនអាចដោះស្រាយស្ថានការណ៍បែបនោះបាន។[710]

នៅក្នុងពិធីរំលឹកខួបនៃការបង្កើតកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ នៅខែវិច្ឆិកា ឆ្នាំ២០១៥ លោក ចាប ភក្តី បានចាត់ទុក លោក ហ៊ុន សែន ថាជាអ្នកបង្កើតអង្គភាពនេះ និងបានគូសបញ្ជាក់នូវបេសកកម្មដែលកំពុងបន្តរបស់អង្គភាពនេះ ក្នុងការថែរក្សា "សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម" ដើម្បីបន្តការអភិវឌ្ឍកម្ពុ

---

708 "កងទ័ពឆ័ត្រយោង ចុះទៅប្រមូលអ្នកធ្វើឱ្យមានបាតុកម្មរបស់កម្មករនៅក្នុងរោងចក្រ Sin Fang នៅចោមចៅ" ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ http://vodhotnews.com/23911 (ចូលមើលនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤)។

709 "វគ្គហ្វឹកហ្វឺនជំនាញលោតឆ័ត្រយោងពិសេស ត្រូវបានបើក និងបិទ នៅថ្ងៃទីមួយ" ( Ul Ul s s t), ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៥ http://nokorwatnews.com/detailnews.php?newsid=50210&mnu=2&cid=4 (ចូលមើលនៅនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៥)។

710 "អគ្គស្នងការនគរបាលជាតិនឹងបណ្តេញកងកម្លាំងនគរបាលណាម្នាក់ ដែលមិនបានចូលរួមវគ្គហ្វឹកហ្វឺនទៀងទាត់" ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ http://kampucheathmey. com/kpt/?p=88126 (ចូលមើល នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥), "កងកម្លាំងនគរបាលរៀនយុទ្ធវិធីពីកងវរសេនាតូចលេខ ៩១១" ***ខេមបូឌា ដេលី*** ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ https://www.cambodiadaily.com/news/national-police-force-learn-tactics- from-911-brigade-97355/ (ចូលមើល នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៥)។

ជា។[711] នៅចុងខែនោះ លោក ហ៊ុន ម៉ាណែត បានបញ្ជាក់សារជាថ្មីអំពីសារសំខាន់នៃអង្គភាពនេះថា ជាកងកម្លាំងសម្រាប់ "ទប់ស្កាត់គ្រប់សកម្មភាពអសន្តិសុខទាំងអស់" នៅប្រទេសកម្ពុជា។[712] ក្នុងកម្មវិធីបិទវគ្គហ្វឹកហ្វឺននៅកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ក្នុងខែមករា ឆ្នាំ២០១៦ លោក ចាប ភក្តី បានរៀបរាប់អំពីអង្គភាពនេះថា ជាអង្គភាពជាទីពេញចិត្តរបស់លោក ហ៊ុន សែន ដែលមានជំនាញក្នុងប្រតិបត្តិការអន្តរាគមន៍ប្រតិកម្មរហ័ស។[713]

ក្នុងដំណើរឆ្ពោះទៅរកដំណើរការរំលាយគណបក្សសង្គ្រោះជាតិ និងក្នុងអំឡុងពេលនៃដំណើរការរំលាយនោះ ក្រោមលេសថា គណបក្សនេះកំពុងជំរុញឱ្យមានបដិវត្តពណ៌ លោក ចាប ភក្តី បានរក្សាជំហរគាំទ្រចំពោះវិធានការនានាប្រឆាំងគណបក្សនេះ។ នៅក្នុងវគ្គហ្វឹកហ្វឺនអំពីសង្គ្រាមចិត្តសាស្ត្រ សម្រាប់កងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ លោក ចាប ភក្តី បានប្តេជ្ញាចិត្តថា "ប្រឆាំងដាច់ខាតចំពោះអំពើញុះញង់ ដែលធ្វើឡើងដោយមនុស្សអគតិមួយចំនួន ដែលកំពុងប្រមូលផ្តុំគ្នាត្រៀមខ្លួនធ្វើបដិវត្តពណ៌" និងបានបង្ហាញការគាំទ្ររបស់គាត់ចំពោះលោក ហ៊ុន សែន ក្នុងការធ្វើជានាយករដ្ឋមន្ត្រី "ជារៀងរហូត"។[714] នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧ នាយទាហាន និងពលទាហានទាំងអស់នៃកងពលតូចលេខ៩១១ បានថ្កោលទោស "អំពើក្បត់ជាតិ" របស់លោក កឹម សុខា និងបានគាំទ្រការចាប់ខ្លួនគាត់។[715] នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧ លោក ចាប ភក្តី បានបរិហារលោក សម រង្ស៊ី ថា ជា "ជនក្បត់ជាតិសុទ្ធសាធ" ដែលយោធាត្រូវតែគាំទ្រ "ការកំចាត់" រូបគាត់ ដូចលោក កឹម សុខា និងជនក្បត់ជាតិផ្សេងទៀតដែរ។[716] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ នាយទាហាន និងពលទាហានទាំងអស់របស់លោក ចាប ភក្តី នៅក្នុងកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ បានបង្ហាញនូវការគាំទ្រទាំងស្រុងរបស់ពួកគេ ចំពោះសាលដីការបស់

---

[711] "ពិធីរំលឹកខួបការកកើតកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១" ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៥http://beta.nokorwatnews.com/?p=58504 (ចូលមើល នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៥)។

[712] "លោក ហ៊ុន ម៉ាណែត ៖ "ការហ្វឹកហ្វឺនធ្វើឱ្យរាងកាយមាំមួន ដើម្បីមានសមត្ថភាពពេញលេញបម្រើក្នុងជួរកងទ័ព", ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ http://dap-news.com/2011-06-14-02-39-55/102895-2015-11-19-07-00-07.html (ចូលមើល នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥)។

[713] "ពិធីបិទវគ្គហ្វឹកហ្វឺនជំនាញលោតឆ័ត្រយោងលើកទី៣ និងពិធីបើកវគ្គហ្វឹកហ្វឺនដំណាក់កាលទី២០", ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ http://beta.nokorwatnews. com/?p=71575#sthash.n2YYo5mS.dpuf (ចូលមើល នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦)។

[714] ក្រសួងការពារផ្សព្វផ្សាយសភាពការណ៍ថ្មីៗ និងការងារអប់រំចិត្តសាស្ត្រឆ្នាំ២០១៧ ដល់កម្លាំងយោធានៅកងពលពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ឧត្តមសេនីយ៍ចាបភក្តីប្រកាសប្រឆាំងដាច់ខាតចំពោះបដិវត្តពណ៌។

[715] កងពលពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ថ្កោលទោសទង្វើក្បត់ជាតិរបស់លោកកឹមសុខា ហើយប្រកាសគាំទ្រចំពោះការចាប់ខ្លួន។

[716] កងទ័ពទាំងអស់នៃកងពលពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ប្រតិកម្មនឹងសម្តីសមរង្សីដែលអំពាវនាវឲ្យកងកម្លាំងប្រដាប់អាវុធបែរចុងកាណុងផ្តួលរំលំរាជរដ្ឋាភិបាល

*តុលាការកំពូលដែលសម្រេចរំលាយគណបក្សសង្គ្រោះជាតិ ក្រោមបទជាប់ពាក់ព័ន្ធនឹង "អំពើក្បត់ជាតិ" និងការគាំទ្រចំពោះការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យចាត់វិធានការជាមុនបន្ថែមទៀត ប្រឆាំងនឹងផែនការផ្ទើបដិវត្តពណ៌ និងអ្នកនយោបាយ "ដែលបម្រើផលប្រយោជន៍បរទេស"។*[717]

## IX. ឧត្តមសេនីយ៍ឯកផ្កាយមាស ៣ រ័ត្ន ស្រ៊ាង មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និង ជាមេបញ្ជាការកងរាជអាវុធហត្ថ រាជធានីភ្នំពេញ

### *លោក រ័ត្ន ស្រ៊ាង នៅខេត្តកណ្តាល និង ខេត្តបន្ទាយមានជ័យ ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ២០០៣*

*ថ្ងៃខែឆ្នាំកំណើតផ្លូវការរបស់លោក រ័ត្ន ស្រ៊ាង គឺថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៦៦។*[718] *លោកកើតមកមានត្រកូលសៀ ហើយបានទទួលយកឈ្មោះថ្មី នៅពេលដែលគាត់ចូលរួមជាមួយកងរាជអាវុធហត្ថលើផ្ទៃប្រទេស* (GRK) *ក្រោយពេលអង្គភាពនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣។ នៅក្នុងសម័យរដ្ឋកម្ពុជា គាត់គឺជាកម្មាភិបាលយោធាខេត្តកណ្តាល ស្ថិតក្រោមបង្គាប់របស់លោក គន់ គីម នៅពេលដែលលោក គន់ គីម ជាអនុប្រធានគណៈកម្មាធិការប្រជាជនកម្ពុជាខេត្ត ដោយមានការទទួលខុសត្រូវលើកិច្ចការយោធា និងសន្តិសុខ។ គាត់នៅតែបន្តទំនាក់ទំនងផ្ទាល់ខ្លួនយ៉ាងជិតស្និទ្ធិជាមួយលោក គន់ គីម ចាប់តាំងពីសម័យរដ្ឋកម្ពុជាមក។*[719] *បន្ទាប់ពីការបង្កើតកងរាជអាវុធហត្ថលើផ្ទៃប្រទេស* (GRK) *នៅឆ្នាំ១៩៩៣មក គាត់បានក្លាយជាប្រធានការិយាល័យមួយនៃកងរាជអាវុធហត្ថខេត្តកណ្តាល ស្ថិតក្រោមបញ្ជាការរបស់លោក ជួន សុវណ្ណ នៅពេលនោះ។*[720] *បន្ទាប់មកគាត់បានឡើងតំណែងយ៉ាងឆាប់រហ័ស ទៅជាមេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយ*

---

[717] កងពលពលតូចទ័ពពិសេសឆ័ត្រយោង៩១១ ប្រកាសគាំទ្រពេញទំហឹងចំពោះតុលាការកំពូល កាត់រំលាយគណបក្សសង្គ្រោះជាតិ និងគាំទ្រអនុសាសន៍ទាំងស្រុងរបស់សម្តេចតេជោហ៊ុនសែន។

[718] បញ្ជីឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ ឯកសារ ០៥-៨៧៤-៧៦៨។

[719] ការសម្ភាសន៍ជាមួយអតីតមន្ត្រីនគរបាលខេត្តកណ្តាល ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤។

[720] រាជរដ្ឋាភិបាលកម្ពុជា "រចនាសម្ព័ន្ធនៃកងរាជអាវុធហត្ថ" រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ១១ អនក្រ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៩៤, ការសម្ភាសន៍ជាមួយអតីតមន្ត្រីនគរបាលខេត្តកណ្តាល ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤។

មានជ័យ មុនក្លាយជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ នៅថ្ងៃទី២៣ កញ្ញា ឆ្នាំ ២០១៣។[721]

នៅពេលធ្វើជាមេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ លោក រ័ត្ន ស្រ៊ាង បានក្លាយជាមេបញ្ជាការរងកងរាជអាវុធហត្ថ "លើផ្ទៃប្រទេស" ដែលត្រូវបានដាក់ពង្រាយនៅទូទាំងប្រទេស។[722] ដោយឆ្លុះបញ្ចាំងពីឋានៈរបស់គាត់ជាសមាជិកអតីតយុទ្ធជនម្នាក់នៃគណបក្សប្រជាជនកម្ពុជា និងជាកូនចៅដ៏ស្មោះស្ម័គ្ររបស់លោក សៅ សុខា និងលោក ហ៊ុន សែន គាត់ស្ថិតក្នុងចំណោមមនុស្សមានឥទ្ធិពល និងអំណាចបំផុតនៅក្នុងកងរាជអាវុធហត្ថនៅកម្រិតថ្នាក់ជាតិ។ ភាពមានសារៈសំខាន់យ៉ាងខ្លាំងរបស់គាត់ ត្រូវបានទ្រទ្រង់ដោយវត្តមានរបស់បងប្រុសរបស់គាត់ឈ្មោះ សៀ សម្បត្តិ ដែលបានកាន់តំណែងជាច្រើនឆ្នាំជាប្រធានការិយាល័យស្រាវជ្រាវបទល្មើសឧក្រិដ្ឋកម្មនៃនាយកដ្ឋានព្រហ្មទណ្ឌនៃកងរាជអាវុធហត្ថ និងដោយភាពលេចធ្លោរបស់គាត់នៅតាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការរបស់កងរាជអាវុធហត្ថជាតិ (GRK) ដោយបានផ្សព្វផ្សាយយ៉ាងច្រើនអំពីសមិទ្ធផលរបស់លោក រ័ត្ន ស្រ៊ាង ក្នុងនាមជាមេបញ្ជាការខេត្តបន្ទាយមានជ័យ។[723]

ខណៈទទួលបន្ទុកលើកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ លោក រ័ត្ន ស្រ៊ាង បានជាប់ពាក់ព័ន្ធនឹងការរំលោភដីធ្លី ដើម្បីផលប្រយោជន៍ខ្លួនឯង និងជំនួសមុខឱ្យអ្នកផ្សេងទៀត រាប់បញ្ចូលទាំងតាមរយៈការសម្លាប់ ការបង្ករបួសស្នាម ឬការវាយដំអ្នកភូមិ នៅក្នុងអំឡុងពេលបណ្តេញពួកគេចេញដោយបង្ខំ ឃាតកម្ម ការបំពារបំពាន ការបំភិតបំភ័យអ្នកសារព័ត៌មាន ការចាប់ខ្លួន និងឃុំឃាំងតាមទំនើងចិត្ត ការវាយដំជនសង្ស័យ និងជនជាប់ឃុំ និងការគំរាមយកប្រាក់ជាដើម។[724]

កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ក៏បានដឹកនាំដំណើរការមជ្ឈមណ្ឌលឃុំឃាំងអ្នកសេពគ្រឿងញៀនផងដែរ ក្រោមការឃ្លាំមើលរបស់លោក រ័ត្ន ស្រ៊ាង។ ជនដែលត្រូវបានចោទប្រកាន់ថាបានប្រើប្រាស់គ្រឿងញៀន

---

[721] កងរាជអាវុធហត្ថកម្ពុជា "លេខទូរស័ព្ទ" [គ្មានកាលបរិច្ឆេទ], "មេបញ្ជាការកងរាជអាវុធហត្ថ ត្រូវបានផ្លាស់ប្តូរជាផ្លូវការ" *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣, http://www.phnompenhpost.com/national/military-commander-officially-be-replaced (ចូលមើល នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣)។

[722] អនាមិក "ព័ត៌មាន" ផ្សព្វផ្សាយក្នុង "Mengk999," (blog), [គ្មានកាលបរិច្ឆេទ], http://mengk9999.wordpress.com/%E1%9E%96%E1%9E%8F%E1%9F%8C%E1%9E%98%E1%9E%B6%E1%9E%93/.

[723] សម្ភាសន៍ជាមួយមន្ត្រីកងកម្លាំងសន្តិសុខកម្ពុជា ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣, "ទស្សនាវដ្តីកងរាជអាវុធហត្ថលើផ្ទៃប្រទេស" (ទស្សនាវដ្តីកងរាជអាវុធហត្ថលើផ្ទៃប្រទេស), លេខ ៤៨ (២០១១) ទំព័រ ១៧, "ទស្សនាវដ្តីកងរាជអាវុធហត្ថលើផ្ទៃប្រទេស" (ទស្សនាវដ្តីកងរាជអាវុធហត្ថលើផ្ទៃប្រទេស) លេខ ៤៧-៥៤ (២០១១-២០១៣) នៅកន្លែងផ្សេង ក្នុងទស្សនាវដ្តីទាំងនោះ។

[724] កំណត់ត្រារបស់អង្គការសិទ្ធិមនុស្សក្នុងស្រុក។

ត្រូវបានឃុំឃាំងតាមទំនើងចិត្តនៅមជ្ឈមណ្ឌលនេះ ដោយគ្មានការកាត់ក្តី ឬការជំនុំជម្រះ និងបានទទួលរង ការប្រព្រឹត្តអំពើឃោរឃៅ អមនុស្សធម៌ ឬការបន្ទាបបន្ថោក និងទណ្ឌកម្ម ព្រមទាំងពលកម្មដោយបង្ខំផង ដែរ។ នៅពេលនិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយកាលពីខែមករា ឆ្នាំ២០១០ អំពីស្ថានភាពនៅមជ្ឈមណ្ឌល នេះ លោក រ័ត្ន ស្រ៊ាង បានទទួលស្គាល់ថា មនុស្សមួយចំនួននៅទីនោះ ត្រូវបានបង្ខំឱ្យឈរហាលថ្ងៃ ឬ "ដើរ ដូចស្វា" [ដោយដើរជើងបួន] ជាទណ្ឌកម្មសម្រាប់ការប៉ុនប៉ងរត់គេច។"[725]

## លោក រ័ត្ន ស្រ៊ាង និងការបោះឆ្នោតឆ្នាំ២០១៣

ដូចគ្នានឹងមន្ត្រីកងកម្លាំងសន្តិសុខផ្សេងទៀតដែរ លោក រ័ត្ន ស្រ៊ាង បានបង្ហាញការគាំទ្រយ៉ាងចំហ ចំពោះ គណបក្សប្រជាជនកម្ពុជា ក្នុងអំឡុងពេលឈានទៅរកការបោះឆ្នោតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។ គាត់ បានបង្ហាញនូវភក្តីភាពរបស់គាត់ ក្នុងតួនាទីរបស់គាត់ជាសមាជិកនៃគណៈកម្មាធិការគណបក្សប្រជាជន កម្ពុជា ខេត្តបន្ទាយមានជ័យ ទទួលបន្ទុក "ការងារពង្រឹងបក្ស" ក្នុងមូលដ្ឋាននានា នៅស្រុកមង្គលបូរី។[726] នៅ ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត គាត់បានចំណាយពេលវេលារបស់គាត់យ៉ាងច្រើន ក្នុងការ អនុវត្តសកម្មភាពរបស់គណបក្សប្រជាជនកម្ពុជា នៅស្រុកមង្គលបូរី ដូចជា នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ គាត់បានអំពាវនាវឱ្យប្រជាពលរដ្ឋនៅទីនោះ បោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា។[727] គាត់ក៏បានធ្វើ ដំណើរនៅក្នុងខេត្តបន្ទាយមានជ័យម្តងទៀតនៅចុងខែមិថុនា ក្នុងនាមជាគណៈប្រតិភូនៃសមាជិកគណៈកម្មា ធិការកណ្តាលគណបក្សប្រជាជនកម្ពុជានៅថ្នាក់ជាតិ និងបានជំរុញឱ្យប្រជាជនបោះឆ្នោតជូនគណបក្ស ប្រជាជនកម្ពុជា និងគាំទ្រការបន្តធ្វើជានាយករដ្ឋមន្ត្រីរបស់លោក ហ៊ុន សែន។[728]

---

[725] Human Rights Watch, *"គេធ្វើដាក់យើងដូចសត្វធាតុ"៖ ការធ្វើបាបអ្នកប្រើប្រាស់គ្រឿងញៀន និង "អំពើមិនគួរគប្បី" នៅក្នុងមជ្ឈមណ្ឌលឃុំឃាំងអ្នកញៀនគ្រឿងញៀន* (ខែធ្នូ ឆ្នាំ២០១៣) ទំព័រ ៩, ១២, ១៥, ៣៧ http://www.hrw.org/node/120957.

[726] "ឧត្តមសេនីយ៍ទោ រ័ត្ន ស្រ៊ាង ចុះសួរសុខទុក្ខពលរដ្ឋ និងសមាជិកគណបក្សប្រជាជនកម្ពុជា នៅឃុំស្ររៀង ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១២ 53313-2012-11-25-07-11-20.html, ចូលមើល នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១២។

[727] "លោក រ័ត្ន ស្រ៊ាង ចុះជួយឃុំស្ររៀង និងដឹកនាំក្រុមការងារចែកអំណោយជូនប្រជាជន ៥ គ្រួសារ រងគ្រោះដោយសារខ្យល់ព្យុះរលំផ្ទះ" ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14- 02-39-55/63346-2013-05-03-07-41-55.html, ទទួលបាន ឬ បានអាន នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៣។

[728] "ការប្រកាសទទួលស្គាល់សមាជិកគណបក្សប្រជាជនកម្ពុជា ៣១១ នាក់ នៅឃុំស្ររៀង និងឃុំតាឡាំ"(GssrusruCflCfls), ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៣ http://dap-news.com/2011-06-14-02-39-55/66831-2013-06-24-09-26-23.html.

## *លោក រ័ត្ន ស្រ៊ាង ជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានី ពីខែកញ្ញា ឆ្នាំ២០១៣ -មករា ២០១៤*

*ក្រោយពេលទទួលបន្ទុកលើកងរាជអាវុធហត្ថរាជធានីភ្នំពេញ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ លោក រ័ត្ន ស្រ៊ាង បានក្លាយជាមន្ត្រីជាន់ខ្ពស់បំផុតម្នាក់ ក្នុងចំណោមមន្ត្រីកងកម្លាំងសន្តិសុខជាន់ខ្ពស់ពីរនាក់ ដែលម្នាក់ទៀតគឺ លោក ជួន សុវណ្ណ ស្នងការនគរបាលរាជធានីភ្នំពេញ ទទួលបន្ទុកលើ "ការគ្រប់គ្រងបាតុកម្ម" នៅក្នុងរាជធានី។[729] ក្នុងកិច្ចសហការជាមួយលោក ជួន សុវណ្ណ គាត់បានប្រឹងប្រែង "គាំទ្រការប្រឆាំង" ការប្រមូលផ្តុំនានា ដែលត្រូវបានចាត់ទុកថា ជា "ការបង្កហេតុដោយក្រុមប្រឆាំង ឬអ្នកញុះញង់"។ វិធានការដែលមន្ត្រីសន្តិសុខជាន់ខ្ពស់ទាំងនេះយល់ថា ល្អបំផុតនោះ គឺ "ការទប់ស្កាត់ជាមុន" នូវសកម្មភាពនានា ប៉ុន្តែបើសិនវិធានការនេះបរាជ័យ គឺត្រូវប្រើកម្លាំងបង្ក្រាប។[730]*

*បន្ទាប់ពីលោក ជួន សុវណ្ណ បានបញ្ជាឱ្យបង្ក្រាបកូដកម្មនៃកម្មករនៅតំបន់ស្ទឹងមានជ័យក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលនគរបាលក្រោមបញ្ជាការរបស់គាត់បានប្រើប្រាស់កងកម្លាំងដ៏គ្រោះថ្នាក់ច្រើនហួសប្រមាណ ដែលបានសម្លាប់មនុស្សម្នាក់ និងបង្ករបួសស្នាមដល់មនុស្សបីនាក់ទៀត ដោយការប្រើកាំភ្លើងខ្លីបាញ់ប្រហារនោះមក លោក រ័ត្ន ស្រ៊ាង បានដាក់ពង្រាយកងរាជអាវុធហត្ថរាជធានីដើម្បីអនុវត្តការបោសសម្អាត ដែលពួកគេ និងកងកម្លាំងសន្តិសុខផ្សេងទៀត បានវាយដំយ៉ាងធ្ងន់ធ្ងរលើបុរសវ័យក្មេងម្នាក់ និងបានចាប់ខ្លួនមនុស្ស ឬដេញចេញពីតំបន់នោះ ដោយបង្ករបួសស្នាមដល់មនុស្ស ២៣នាក់។[731]*

*នៅខណៈដែលលោក ជួន សុវណ្ណ បានចាកចេញពីប្រទេសនៅថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៣ លោក រ័ត្ន ស្រ៊ាង នៅបន្តបញ្ជាកងរាជអាវុធហត្ថរាជធានីភ្នំពេញ ដោយបំពេញការងារក្រោមការបញ្ជារបស់លោក ម៉ក់ ជីតូ*

---

[729] "មេបញ្ជាការកងរាជអាវុធហត្ថ ត្រូវបានផ្លាស់ប្តូរជាផ្លូវការ" *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣, http://www.phnompenhpost.com/national/military-commander-officially-be-replaced (ចូលមើល នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣), "សាលារាជធានីភ្នំពេញ ពិភាក្សាអំពី ការគ្រប់គ្រងបាតុកម្ម ជាមួយគណបក្សសង្គ្រោះជាតិ" ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/77868---cnrp--.html (ចូលមើល នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣)។

[730] "ក្នុងអំឡុងពេលមួយខែមុន ករណីបទល្មើសឧក្រិដ្ឋនៅក្នុងរាជធានីភ្នំពេញកើនឡើងដល់ ២០ករណី!" ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ http://edition.bayontv.com.kh/bayontv-national-news/23381-2014-03-14-04-33-45.html (ចូលមើល នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤)។

[731] ផ្អែកលើវីដេអូភស្តុតាង កងរាជអាវុធហត្ថនៅក្នុងវីដេអូ ត្រូវបានមន្ត្រីកងកម្លាំងសន្តិសុខម្នាក់ ដែលបានមើលវិដីអូនេះ កំណត់ថា ជាកងកម្លាំងរាជធានី ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៤ (វីដេអូរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ), "កម្ពុជា ៖ ការជំនុំជម្រះករណីស្ទឹងមានជ័យ មានកំហុសយ៉ាងខ្លាំង" ***សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ*** ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៤ http://www.hrw.org/news/2014/05/11/cambodia-steung- meanchey-trial-deeply-flawed.

ដែលអ្នកទាំងពីរបានជំនួសលោក ជួន សុវណ្ណ ហើយក្រោយមក ពួកគេបានទទួលតួនាទីកាន់តែមានឥទ្ធិពល ជាប្រធានគណៈបញ្ជាការឯកភាព សម្រាប់ទីក្រុងភ្នំពេញ ដោយដាក់លោក ម៉ក់ ជីតូ ឱ្យទទួលបន្ទុករួមលើបញ្ហាសន្តិសុខ នៅទូទាំងរាជធានី។[732] លោក រ័ត្ន ស្រ៊ាង ទទួលបន្ទុកគ្រប់គ្រងយុទ្ធវិធីរបស់កងរាជអាវុធហត្ថ ដោយបញ្ជាពួកគេតាមវិទ្យុទាក់ទង ឬដោយផ្ទាល់ នៅទីតាំងធ្វើប្រតិបត្តិការ។[733]

នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ កងរាជអាវុធហត្ថក្រុង និងខណ្ឌក្រោមបង្គាប់ បានដើរតួនាទីសំខាន់ ក្នុងការអនុវត្តន៍ឱសានវាទរបស់រដ្ឋាភិបាល ដើម្បីឱ្យកម្មកររោងចក្រកាត់ដេរបញ្ឈប់កូដកម្ម និងបាតុកម្មទាមទារដំឡើងប្រាក់ឈ្នួលសួល នៅកម្ពុជា។ នៅព្រឹកថ្ងៃទី២ ខែមករា ដោយសារកម្មករនៅបន្តប្រមូលផ្តុំ ដើម្បីធ្វើបាតុកម្មនៅមុខរោងចក្រកាត់ដេរជាច្រើន នៅជាយក្រុងភ្នំពេញ អង្គភាពកងទ័ព នគរបាល និងកងរាជអាវុធហត្ថ បានចាប់ផ្តើមដាក់ពង្រាយទៅទីនោះ។ ប្រតិបត្តិការបំបែកដំបូង ត្រូវធ្វើឡើងដោយកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១ ដែលបានបំបែកបាតុកម្មនោះយ៉ាងហិង្សា និងបានចាប់ខ្លួនមនុស្ស ១៥នាក់ និងបញ្ជូនពួកគេឱ្យទៅនៅក្រោមការឃុំឃាំងរបស់កងកម្លាំងបោសសម្អាតរបស់លោក រ័ត្ន ស្រ៊ាង។ តាមបទបញ្ជារបស់លោក រ័ត្ន ស្រ៊ាង មនុស្ស១០នាក់ ក្នុងចំណោម១៥នាក់ ត្រូវបានបញ្ជូនទៅតុលាការ ដើម្បីធ្វើការឃុំខ្លួនបណ្តោះអាសន្ន ស្របពេលដែល៥នាក់ទៀត ជាព្រះសង្ឃ ត្រូវបានដោះលែង។[734]

នៅយប់ថ្ងៃទី២ ឈានចូលថ្ងៃទី៣ ខែមករា តាមបញ្ជារបស់លោក ម៉ក់ ជីតូ កងកម្លាំងសន្តិសុខរាប់រយនាក់

[732] "សាលារាជធានី ពិភាក្សាអំពី ការគ្រប់គ្រងបាតុកម្ម ជាមួយគណបក្សសង្គ្រោះជាតិ" ( lfl s bl Cfl CNRPbl .), ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/77868---cnrp--.html (នៅថ្ងៃទី២៣ ធ្នូ ឆ្នាំ២០១៣), ការសង្កេតមើលការជំនុំជម្រះដោយតុលាការក្រុងភ្នំពេញចំពោះលោក វ៉ន ពៅ et al, ថ្ងៃទី២១ ឧសភា ឆ្នាំ២០១៤ រួមទាំងសក្ខីកម្មរបស់លោកគុយ គីនី មេបញ្ជាការរងកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

[733] ការសម្ភាសន៍ជាមួយមន្ត្រីកងកម្លាំងសន្តិសុខកម្ពុជាម្នាក់ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៤ និងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៦។

[734] ការសម្ភាសន៍ជាមួយមន្ត្រីកងកម្លាំងសន្តិសុខ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៤, អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្លាំមើលសិទ្ធិមនុស្ស ហ៊ូមែនរ៉ៃត៍វ៉ច្ឆ "ការដាក់ស្នើរបស់អង្គការ Human Rights Watch ដើម្បីឱ្យគណៈកម្មាធិការសិទ្ធិមនុស្ស ពិនិត្យស្ថានភាពនៅកម្ពុជា" ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៤, "អ្នកស្រី យ៉ោម បុប្ផា ដឹកនាំអ្នករួមគំនិតជាមួយគាត់ បិទផ្លូវជាតិលេខ ៤" ( ., ) ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/78576-2014-01-02-10-03-23.html (ចូលមើល នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤), "មនុស្សប្រហែល១០នាក់ ត្រូវបានឃុំខ្លួន និងមួយចំនួនផ្សេងទៀត បានរងរបួស នៅក្នុងការប៉ះទង្គិចគ្នានៅមុខរោងចក្រ Yakjin" ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ http://vodhotnews.com/18301 (ចូលមើល នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤), "ការឃុំខ្លួនក្រុមលោក វ៉ន ពៅ ទាំង១០នាក់ ពីបទបានប្រើប្រាស់អំពើហិង្សា និងបំផ្លិចបំផ្លាញ ដោយមានចេតនា" ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤, http://edition.kpt-news.com/local-news/1886-2014-01-03-11-59-40.html (ចូលមើល នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤), "កងរាជអាវុធហត្ថបញ្ជូនជនបង្កបញ្ហាទាំង១០នាក់ ដែលបង្កភាពចលាចលសង្គម ទៅតុលាការ" ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ http://edition.kpt-news.com/local-news/1898-2014-01-04-02-42-16.html (ចូលមើល នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤)។

ត្រូវបានដាក់ពង្រាយ ដើម្បីបោសសម្អាតកម្មករ ដែលបានបិទផ្លូវនៅតំបន់ឧស្សាហកម្មវេងស្រេង។[735] កងរាជអាវុធហត្ថក្រុង និងខណ្ឌ ក្រោមបង្គាប់ របស់លោក រ័ត្ន ស្រ៊ាង ភាគច្រើន គឺមកពី "កងកម្លាំងចម្រុះ" ទាំងនេះ។[736] ការប៉ះទង្គិចគ្នាយ៉ាងហិង្សាបានផ្ទុះឡើង ដោយកម្មករមួយចំនួនបានគប់ដុំថ្ម កំណាត់ឈើ និងដបសាំង និងវាយប្រហារលើទ្រព្យសម្បត្តិ ស្របពេលដែលកងកម្លាំងសន្តិសុខ ក្នុងនោះមានមួយចំនួនបានរងរបួស បានបាញ់ឧស្ម័នបង្ហូរទឹកភ្នែក គ្រាប់បែកផ្សែង និងបាញ់គ្រាប់ពិត ម្ដងម្កាល។ ពួកគេក៏បានវាយដំមនុស្សជាច្រើននាក់ រួមទាំងបុរសវ័យក្មេងបីនាក់ ដែលត្រូវបានចាប់ខ្លួននៅយប់នោះ ហើយការចាប់ខ្លួននេះគឺច្បាស់ណាស់ ធ្វើឡើងដោយមិនរើសមុខ ប៉ុន្តែនៅទីបំផុតបុរសទាំងបីនាក់ត្រូវជំនុំជម្រះ និងផ្ដន្ទាទោសពីបទបង្កអំពើហិង្សា ទោះបីជាគ្មានភស្តុតាងគួរឱ្យទុកចិត្តបាន ដែលបញ្ជាក់ថា ពួកគេបានជាប់ពាក់ព័ន្ធនឹងសកម្មភាពហិង្សានោះក៏ដោយ។[737]

កងរាជអាវុធហត្ថក្រុង និងខណ្ឌក្រោមបញ្ជានៅនឹងកន្លែងរបស់លោក រ័ត្ន ស្រ៊ាង ដែលបានគ្រវីកាំភ្លើងខ្លីស្វ័យប្រវត្តិនោះ គឺមានចំនួនយ៉ាងច្រើន នៅក្នុងចំណោមកងកម្លាំងចម្រុះ ដែលគណៈបញ្ជាការឯកភាពបានបញ្ជូនទៅកាន់តំបន់ផ្លូវវេងស្រេង នៅព្រឹកថ្ងៃទី៣ ខែមករា ជាមួយនឹងបទបញ្ជា ឱ្យទៅដណ្ដើមយកការគ្រប់គ្រងពីកម្មករ ដែលបន្តស្ថិតនៅតំបន់នោះ។ នៅក្នុងប្រតិបត្តិការប្រឆាំងនឹងកម្មករ ដែលពួកគេមួយចំនួនបានធ្វើសកម្មភាពហិង្សា ដោយគប់ដុំថ្ម និងដបពីចម្ងាយ ដែលដុំថ្មតិតតួចអាចទៅដល់ ឬមិនអាចទៅដល់កន្លែងកងរាជអាវុធហត្ថឈរជើង ប៉ុន្តែកងរាជអាវុធហត្ថបានប្រើកាំភ្លើងវែងបាញ់រះបណ្ដាលអោយសម្លាប់មនុស្សប្រាំនាក់។[738] ហើយបានចាប់ខ្លួនមនុស្ស១០នាក់ដោយមិនរើសមុខ រួចវាយដំ និងធ្វើហិង្សាបែបនេះទៅលើមនុស្សជាច្រើននាក់ផ្សេងទៀត។ ជនរងគ្រោះម្នាក់ ក្នុងចំណោមជនរងគ្រោះដែលកងរាជអាវុធហត្ថ

---

735 "ការដាក់ស្នើរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ" ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៤។

736 "ពលរដ្ឋរាប់រយនាក់លើកគ្នាមកតវ៉ានៅមុខតុលាការដំបូងរាជធានីភ្នំពេញ និងស្រែកទាមទារឱ្យដោះលែងលោក វ៉ន ពៅ" ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39- 55/78586-2014-01-03-01-29-09.html (ចូលមើល នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤), ការសង្កេតមើលការជំនុំជម្រះលោក វ៉ន ពៅ និងអ្នកផ្សេងទៀត នៅថ្ងៃទី១៩-២២ ខែឧសភា ឆ្នាំ២០១៤ រួមទាំងសក្ខីកម្មរបស់មន្ត្រីកងរាជអាវុធហត្ថ និងមន្ត្រីនគរបាល, ការសម្ភាសន៍ជាមួយមន្ត្រីកងកម្លាំងសន្តិសុខកម្ពុជាម្នាក់ ថ្ងៃ១ ខែកុម្ភៈ ឆ្នាំ២០១៤។

737 ពីប្រភពដដែល Ibid.

738 ការសម្ភាសន៍ជាមួយមន្ត្រីកងកម្លាំងសន្តិសុខកម្ពុជាម្នាក់ ថ្ងៃ១ ខែកុម្ភៈ ឆ្នាំ២០១៤, វីដេអូ និងរូបថតជាភស្តុតាង ពីហេតុការណ៍នោះ:, "សមត្ថកិច្ចបន្តបំបែកបាតុករ ដែលបានបិទផ្លូវវេងស្រេង ឈានដល់ការបាញ់កាំភ្លើង"។ (GsttruUls"), ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ http://www.dap- news.com/2011-06-14-02-39-55/78603-2014-01-03-03-52-39.html (ចូលមើល នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤), ការសម្ភាសន៍ជាមួយអ្នកតាមដានសិទ្ធិមនុស្សកម្ពុជាដែលមានវត្តមាននៅទីនោះ ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៦។

បានវាយដំនោះ បានស្លាប់ដោយសាររបួស។ កម្មករទាំង១០នាក់ ដែលត្រូវបានចាប់ខ្លួននៅព្រឹកថ្ងៃទី៣ ខែមករា នៅទីបំផុត ត្រូវបានជំនុំជម្រះ និងផ្តន្ទាទោសពីបទប្រព្រឹត្តអំពើហិង្សា បើទោះបីជាគ្មានភស្តុតាងគួរឱ្យជឿបានថា ពួកគេបានធ្វើបែបនោះក៏ដោយចុះ។[739]
នៅពេលកងរាជអាវុធហត្ថបាញ់កាំភ្លើងរបស់ពួកគេ ជាទូទៅ កងរាជអាវុធហត្ថទាំងនោះ ឈរនៅទីតាំងក្នុងចម្ងាយមួយដែលមានសុវត្ថិភាពពីកម្មករ និងកុបករ។ យោងតាមរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ និងភស្តុតាងបង្ហាញក្នុងឃ្លីបវីដេអូអំពីហេតុការណ៍នោះ ដែលអង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ (Human Rights Watch) ពិនិត្យមើល បង្ហាញថា នៅពេលកងកម្លាំងសន្តិសុខបាញ់ទៅកាន់ហ្វូងមនុស្សដែលកំពុងខ្ទោលឡើង កងកម្លាំងទាំងនោះមិនស្ថិតក្នុងស្ថានភាពអាចមានគ្រោះថ្នាក់ជាក់ស្តែងដល់ពួកគេឡើយ។ ថ្វីបើបានបង្កឱ្យមានការស្លាប់ និងរបួសយ៉ាងច្រើនក៏ដោយ ក៏ការបាញ់កាំភ្លើងវែងរបស់កងរាជអាវុធហត្ថបានត្រឹមតែបង្កឱ្យមានកុបកម្មដ៏វិនាសកម្មបន្ថែមទៀត និងកាន់តែច្រើនឡើងប៉ុណ្ណោះ។[740]

នៅពេលថ្លែងទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ លោក រ័ត្ន ស្រ៊ាង បាននិយាយការពារការបាញ់ ដែលបណ្តាលឱ្យស្លាប់មនុស្សនោះថា មិនមែនជាការចាំបាច់សម្រាប់ការពារកងរាជអាវុធហត្ថ និងអ្នកផ្សេងទៀតពីគ្រោះថ្នាក់នោះឡើយ ប៉ុន្តែវាជាការចាំបាច់សម្រាប់បោសសម្អាតការតវ៉ា ដោយគាត់បញ្ជាក់ថា "យើងមិនអាចអនុញ្ញាតឱ្យពួកគេបិទផ្លូវទេ យើងត្រូវបង្ក្រាបពួកគេ" និងបានពោលអះអាងថា "យើងគ្មានជម្រើសទេ"។[741]

កងរាជអាវុធហត្ថក្រុង និងកងរាជអាវុធហត្ថខណ្ឌ ក្រោមបង្គាប់ មានវត្តមានម្តងទៀត នៅពេលកងកម្លាំងសន្តិសុខបំបែកការតវ៉ានៅមុខតុលាការរាជធានីភ្នំពេញ នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ ដែលទាមទារឱ្យដោះលែងអ្នកដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២-៣។[742] នៅថ្ងៃជាមួយគ្នានោះ អាជ្ញាធរបានធ្វើការហាមឃាត់

---

739 ពីប្រភពដដែល Ibid.

740 "នគរបាលបានសម្លាប់មនុស្ស៥នាក់ ក្នុងអំឡុងពេលប៉ះទង្គិចគ្នាជាមួយបាតុករ" ***ខេមបូឌា ដេលី*** ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/military-police-kill-5-during-clash-with-demonstrators-50081/ (ចូលមើល នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១៤), "អ្នករងរបួសរៀបរាប់អំពី ភាពកម្រោលចូលរបស់កងរាជអាវុធហត្ថ" ***ខេមបូឌា ដេលី*** ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/wounded-recount-rampage-by-military-police-50297/ (ចូលមើល នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤), វីដេអូដែលថតដោយអ្នកតាមដានសិទ្ធិមនុស្សក្នុងស្រុក (នៅក្នុងកម្រងឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ)។

741 "មន្ត្រីសិទ្ធិមនុស្សអះអាងថា មនុស្ស៥នាក់បានស្លាប់នៅក្នុងការប៉ះទង្គិចគ្នានោះ" ***ខេមបូឌា ដេលី*** ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/three-killed-as-police-open-fire-on-protesters-50022/ (ចូលមើល នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤)។

742 "តុលាការចោទប្រកាន់អ្នកតវ៉ាថា ជាអ្នកគាំទ្រ, នគរបាលប៉ះទង្គិចគ្នានៅខាងក្រៅ" ***ខេមបូឌា ដេលី*** ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤

*តាមទំនើងចិត្តនូវរាល់បាតុកម្ម និងកូដកម្មទាំងអស់ រហូតទាល់តែមានការជូនដំណឹងជាថ្មី រួមទាំងនៅទីលានប្រជាធិបតេយ្យ ក្នុងរាជធានីភ្នំពេញ ជាទីតាំងដែលច្បាប់កំណត់ឱ្យធ្វើការប្រមូលផ្តុំនយោបាយ និងការប្រមូលផ្តុំគ្នាផ្សេងទៀត ដោយសន្តិវិធី នោះផងដែរ។ នៅពេលនោះ គណបក្សសង្គ្រោះជាតិ បានប្រើប្រាស់ទីលាននេះ ក្នុងគោលបំណងជួបជុំគ្នាតវ៉ាដោយសន្តិវិធី។*[743]

*កងរាជអាវុធហត្ថក្រុង និងកងរាជអាវុធហត្ថខណ្ឌ ក្រោមបង្គាប់ បានផ្តល់ការគាំទ្រចំពោះការបោសសម្អាតនៅទីលានប្រជាធិបតេយ្យ នៅថ្ងៃទី៤ ខែមករា តាមរយៈការចូលកាន់កាប់ទីតាំងនៅជុំវិញនោះ ដែលពួកគេអាចធ្វើជាកងកម្លាំងបម្រុង ក្នុងករណីកងកម្លាំងនៅទីលាននោះ ត្រូវការកម្លាំងបន្ថែម។*[744] *បន្ទាប់ពីថ្ងៃទី៤ ខែមករា កងកម្លាំងកងរាជអាវុធហត្ថទាំងនោះ បានបន្តល្បាតនៅទីលាន និងតំបន់ជិតៗនោះ រួមគ្នាជាមួយនឹងនគរបាល ដោយពួកគេរារាំងជនណា ដែលប៉ុនប៉ងចូលទៅប្រមូលផ្តុំនៅលើបរិវេណនោះ ដូចជា ក្រុមយុវជនសកម្មជនគណបក្សសង្គ្រោះជាតិ ដែលមានបំណងច្រៀងចម្រៀងអំពីភាពអហិង្សានៅជាយជ្រុងម្ខាងនៃទីលាននោះ ប៉ុន្តែពួកគេបានគៀសខ្លួនចេញក្រោយពេលច្រៀងចម្រៀងបានមួយបទ ដើម្បីគេចចេញពីការវាយបំបែករបស់កងកម្លាំងសន្តិសុខ។ ពេលនិយាយបន្ថែមជាមួយក្រុមអ្នកសារព័ត៌មាន លោក រ័ត្ន ស្រ៊ាង បានទទួលស្គាល់ថា មានការប្រើប្រាស់កងរាជអាវុធហត្ថនោះមែន។*[745]

*លោក រ័ត្ន ស្រ៊ាង ក៏បានដឹកនាំប្រតិបត្តិការរួមគ្នា រវាងកងរាជអាវុធហត្ថ និងនគរបាលដោយផ្ទាល់ផងដែរ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ដែលបានធ្វើប្រតិបត្តិការយ៉ាងរហ័ស នៅក្នុងការបណ្តេញអ្នកតវ៉ាអហិង្សា ដែលគាំទ្រការទាមទាររបស់ម្ចាស់ស្ថានីយ៍វិទ្យុឯករាជ្យរបស់លោក ម៉ម សូណង់ដូ ក្នុងការពង្រីកសមត្ថភាព*

---

http://www.cambodiadaily.com/news/court-charges-protesters-as-supporters-police-scuffle-outside-50079/ (ចូលមើល នៅថ្ងៃទី៤ ខែមករា ឆ្នាំ ២០១៤), ការសម្ភាសន៍ជាមួយកងកម្លាំងសន្តិសុខម្នាក់ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៤។

[743] ពីប្រភពដដែល Ibid.

[744] "បន្ទាប់ពីបោសសម្អាតទីលានប្រជាធិបតេយ្យហើយ អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ ត្រូវបានគេកោះហៅទៅតុលាការ" ***ខេមបូឌា ដេលី*** ថ្ងៃទី៥ ខែមករា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/security-guards-police-clear-freedom-park-50086/ (ចូលមើល នៅថ្ងៃទី៦ ខែមករា ឆ្នាំ ២០១៤), "រដ្ឋាភិបាលទទួលបានការជំទាស់យ៉ាងខ្លាំងចំពោះការបណ្តេញមនុស្សចេញពីសួនសេរីភាព" ***ខេមបូឌា ដេលី*** ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/government-blasted-for-eviction-of-freedom-park-50132/ (ចូលមើល នៅថ្ងៃទី៧ ខែមករា ឆ្នាំ២០១៤), ការសម្ភាសន៍ជាមួយកងកម្លាំងសន្តិសុខម្នាក់ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៤។

[745] "យុវជនប្រឆាំងច្រៀងចម្រៀងប្រឆាំងនឹងការហាមឃាត់ នៅពេលនគរបាលប្រដាប់អាវុធល្បាត" ***ខេមបូឌា ដេលី*** ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/opposition-youth-sing-against-the-ban-as-armed-police-patrol-50401/ (មើល នៅថ្ងៃទី១២ មករា ឆ្នាំ២០១៤)។

*ផ្សព្វផ្សាយវិទ្យុ និងអាជ្ញាប័ណ្ណទូរទស្សន៍ ចេញពីតំបន់នៅជិតៗក្រសួងព័ត៌មាន។ កងរាជអាវុធហត្ថ និងកងកម្លាំងសន្តិសុខផ្សេងទៀត បានបាញ់គ្រាប់បែកផ្សែង និងកាន់ដំបងប្រឆាំងនឹងក្រុមអ្នកតវ៉ា ដែលមិនមានបំណងតតាំងជាមួយ។ កម្លាំងសន្តិសុខបានប្រើប្រាស់ទីតាំងនៅជិតសាលារាជធានីភ្នំពេញ ជាមូលដ្ឋានសម្រាប់បង្ក្រាបអ្នកតវ៉ា និងបានបង្ករបួសស្នាមដល់មនុស្សចំនួន១០នាក់ ហើយភាគច្រើនរបួសធ្ងន់ធ្ងរ។*[746]

## *លោក រ័ត្ន ស្រ៊ាង ជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ បន្ទាប់ពីខែមករា ឆ្នាំ២០១៤*

*នៅក្នុងពិធីមួយ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ លោក រ័ត្ន ស្រ៊ាង បានសរសើរកងរាជអាវុធហត្ថ ក្រោមបញ្ជារបស់គាត់ ចំពោះវិន័យល្អនៅក្នុងការប្រតិបត្តិបេសកកម្មរបស់ពួកគេ រួមទាំងតាមរយៈការបំពេញការងារ "បានល្អបំផុត" នៅក្នុងការ "ទប់ស្កាត់កូដកម្ម និងបាតុកម្មជាច្រើនដង" ជាហេតុធ្វើឱ្យរក្សាបាននូវសណ្ដាប់ធ្នាប់ និងសន្តិសុខនៅក្នុងរាជធានី។*[747] *គាត់បាននិយាយឡើងវិញនូវការការពាររបស់គាត់ ចំពោះការប្រើប្រាស់កាំភ្លើងវែង ដោយនិយាយថា "ហេតុអ្វីបានជាយើងប្រើប្រាស់កាំភ្លើងអាកា (AKs) បែបនេះ? យើងស្ពាយកាំភ្លើងបែបនេះ ដើម្បីប្រឆាំងនឹងឧក្រិដ្ឋជន"។*[748] *នៅខែកញ្ញា ឆ្នាំ២០១៤ ប្រព័ន្ធផ្សព្វផ្សាយរបស់លោក ហ៊ុន សែន បានសរសើរលោក រ័ត្ន ស្រ៊ាង ចំពោះ "ភាពដឹកនាំដ៏ម៉ឺងម៉ាត់" លើកងរាជអាវុធហត្ថរាជធានីភ្នំពេញរបស់គាត់ ថាការដឹកនាំបែបនេះ ធានាបាននូវសុវត្ថិភាព និងសន្តិសុខនៅក្នុងរាជធានី។*[749]

*នៅចមាសចុងក្រោយនៃឆ្នាំ២០១៤ កងរាជអាវុធហត្ថក្នុងទីក្រុងភ្នំពេញ បន្តអនុវត្តប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបកូដកម្ម និងបាតុកម្ម នានា។ នៅថ្ងៃទី២ ខែតុលា កងរាជអាវុធហត្ថរាជធានី បានអន្តរាគមន៍រារាំង*

---

[746] "ការប្រមូលផ្ដុំ ត្រូវបានបំបែកយ៉ាងហិង្សា" "Rally violently dispersed," ***ភ្នំពេញប៉ុស្តិ៍***, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ http://www.phnompenhpost.com/national/rally- violently-dispersed (ចូលមើល នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤), "ដំបងរបស់កងរាជអាវុធហត្ថសម្រុកវាយលើអ្នកតវ៉ាអហិង្សា" ***ខេមបូឌា ដេលី***, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/military-police-baton-charge-peaceful-protesters-51068/ (ចូលមើលនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤)។

[747] "អភិបាលរាជធានីភ្នំពេញជួប និងជជែកជាមួយមន្ត្រីកងរាជអាវុធហត្ថ" ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/93889-2014-08-28-05-23-17.html (ចូលមើល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤)។

[748] "កងរាជអាវុធហត្ថ ដែលធ្វើការបានល្អ បានទទួលកិត្តិយសជាមួយនឹងការផ្ដល់ប្រាក់" ***ខេមបូឌា ដេលី***, ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/perfect-military-police-honored-with-cash-67263/ (ចូលមើល នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៤)។

[749] "ក្នុងអំឡុងពេលមួយខែមុន បទល្មើសឧក្រិដ្ឋនៅក្នុងទីក្រុងភ្នំពេញបានកើនឡើងដល់ ៥៩ករណី" ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៤ http://edition.bayontv.com.kh/bayontv- national-news/31652-2014-09-12-07-33-36.html (ចូលមើល នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៤)។ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ http://edition.bayontv.com.kh/bayontv-national-news/23381-2014-03-14-04-33-45.html (ចូលមើលនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤)។

កូដកម្មរបស់កម្មករនៅក្នុងខណ្ឌពោធិ៍សែនជ័យនៃរាជធានីភ្នំពេញ ដោយចាប់ដកហូតយកឧបករណ៍បំពងសម្លេង និងបានប្រវ៉ាយប្រតប់គ្នាជាមួយកម្មករ។[750] នៅថ្ងៃទី៥ ខែតុលា ពួកគេបានឈរជើង ដើម្បីទប់ស្កាត់គ្រូបង្រៀន មិនឱ្យចូលទៅជិតផ្ទះរបស់លោក ហ៊ុន សែន នៅក្នុងរាជធានីភ្នំពេញដែលគាត់កម្រស្នាក់នៅ ដោយពួកគេគាំទ្រដល់នគរបាលដែលបញ្ជប់ពួកគេនៅឆ្ងាយពីផ្ទះនោះ។[751] ពួកគេបានអនុវត្តមុខងារដូចគ្នា ដោយធ្វើជាកងកម្លាំងបម្រុង នៅពេលកងសន្តិសុខក្នុងមូលដ្ឋាន ប្រើប្រាស់អំពើហិង្សាបញ្ឈប់សកម្មជនសិទ្ធិដីធ្លី មកពីខេត្តព្រះវិហារ មិនឱ្យធ្វើដំណើរទៅកាន់ផ្ទះរបស់នាយករដ្ឋមន្ត្រី នៅថ្ងៃទី២១ ខែតុលា ដែលជាលទ្ធផលគឺមានមនុស្ស ១៨ នាក់ រងរបួស។[752]

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤ កងរាជអាវុធហត្ថបានចូលរួមជាមួយនគរបាលមូលដ្ឋាន ឡោមព័ទ្ធវត្តមួយនៅក្នុងទីក្រុងភ្នំពេញ ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីរារាំងអ្នកនៅក្នុងវត្តនោះមិនឱ្យចូលរួមក្នុងបាតុកម្មប្រឆាំងនឹងការរំលោភដីធ្លី ជាប្រតិបត្តិការមួយដែលនគរបាលបានចាប់ខ្លួនព្រះសង្ឃពីរអង្គផងដែរ។[753] ព្រះសង្ឃទាំងពីរអង្គត្រូវឃុំខ្លួន ដើម្បីជំនុំជម្រះពីបទចោទ "ចូលរួមក្នុងក្រុមមួយ ឬការរួមគំនិត" ដើម្បី "ប្រព្រឹត្តបទឧក្រិដ្ឋមួយ ឬច្រើន" ដោយផ្អែកលើអំណះអំណាងរបស់កងសន្តិសុខថា ព្រះសង្ឃបានយកដំបងឫស្សី និងដងទង់ជាតិផ្សេងទៀត ទៅធ្វើបាតុកម្ម ក្នុងគោលបំណងប្រើប្រាស់ជាអាវុធប្រឆាំងនឹងកងកម្លាំងសន្តិសុខ"។[754] ពួកគេត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន នៅខែមេសា ឆ្នាំ២០១៥ ហើយរឿងក្តីនោះមិនទាន់ត្រូវបានទម្លាក់ចោលនៅឡើយទេ។[755]

---

750 "កម្មករ កងរាជអាវុធហត្ថ ប្រវ៉ាយប្រតប់គ្នាដណ្តើមឧបករណ៍បំពងសម្លេង" ***ខេមបូឌា ដេលី***, ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/workers-military-police-scuffle-over-speakers-69018/ (ចូលមើលនៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៤)។

751 "គ្រូបង្រៀនហែរក្បួនរាប់រយនាក់ នៅថ្ងៃទិវាគ្រូបង្រៀនពិភពលោក" ***ខេមបូឌា ដេលី***, ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/hundreds-march-for-world-teachers-day-69117/ (ចូលមើល នៅថ្ងៃទី ៧ ខែតុលា ឆ្នាំ ២០១៤)។

752 "អ្នកតវ៉ាប៉ះទង្គិចគ្នាជាមួយកងកម្លាំងសន្តិសុខនៅក្នុងរាជធានី" ***ខេមបូឌា ដេលី***, ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/protesters-clash-with-security-guards-in-phnom-penh-70393/ (ចូលមើល នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤)។

753 "ព្រះសង្ឃពីរអង្គត្រូវបានចាប់ព្រះកាយ ដោយសារការដឹកទង់ជាតិចូលវត្ត" ***ខេមបូឌា ដេលី***, ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/two-monks-arrested-for-transporting-flags-to-pagoda-72156/ (ចូលមើល នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤)។

754 "កម្ពុជា ៖ ការបង្ក្រាបជាថ្មីលើបាតុករ" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ២០១៤ http://www.hrw.org/news/2014/11/13/cambodia-new-crackdown-protesters.

755 "សកម្មជនគណបក្សសង្គ្រោះជាតិប្រាំនាក់ និងព្រះសង្ឃបីអង្គ ត្រូវបានដោះលែង" ***ខេមបូឌា ដេលី*** ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥ https://www.hrw.org/news/2014/11/13/cambodia-new-crackdown-protesters (ចូលមើល នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៥)។

*នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៥ លោក រ័ត្ន ស្រ៊ាង ត្រូវបានដំឡើងទៅជាសមាជិកគណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា នៅក្នុងមហាសន្និបាតវិសាមញ្ញរបស់គណបក្ស។[756] នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥ បងប្រុសរបស់គាត់គឺ លោក សៀ សម្បត្តិ ដែលនៅពេលនោះ ជាឧត្តមសេនីយ៍ត្រី ត្រូវបានដំឡើងតំណែងទៅជាស្នងការផ្នែកយុត្តិធម៌នៃស្នងការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ហើយបងប្រុសទីពីរម្នាក់ទៀតគឺ លោកឧត្តមសេនីយ៍ត្រី សៀ តូនី ត្រូវបានដំឡើងតំណែងទៅជាជំនួយការរបស់លោក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។[757] និងមានកូនប្រុសម្នាក់គឺ វរសេនីយ៍ សៀ ទីន ជាមេបញ្ជាការកងកម្លាំងអន្តរាគមន៍នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ។[758]*

*នៅឆ្នាំ២០១៦ លោក រ័ត្ន ស្រ៊ាង បន្តគូសបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់គាត់ ក្នុងការទប់ស្កាត់ "រាល់ និងគ្រប់សកម្មភាពទាំងអស់" ដែលរដ្ឋាភិបាលចាត់ទុកថា រួមចំណែកក្នុង "ការប៉ុនប៉ង" ដើម្បី "បំផ្លាញស្ថិរភាពនយោបាយ ឬភាពស្ងប់ស្ងាត់ និងសន្តិសុខ នៅក្នុងសង្គមជាតិ" ហើយគាត់ត្រូវបានដំឡើងតំណែងពីឧត្តមសេនីយ៍ទោ ទៅជាឧត្តមសេនីយ៍ឯកផ្កាយមាស៣។[759] នៅខណៈនោះដែរ កងរាជអាវុធហត្ថរាជធានីបន្តចូលរួមក្នុងប្រតិបត្តិការបង្ក្រាបការប្រមូលផ្តុំអហិង្សា ដូចជា ការរាំងខ្ទប់មិនឱ្យប្រមូលផ្តុំគ្នារំលឹកខួបនៃការសម្លាប់កម្មករនៅខែមករា ឆ្នាំ២០១៤ ក្នុងអំឡុងពេលបាតុកម្មនៅលើផ្លូវវ៉េងស្រេង ដូចបានរៀបរាប់ខាងលើ។[760]*

*នៅចុងឆ្នាំ២០១៦ កងរាជអាវុធហត្ថរបស់លោក រ័ត្ន ស្រ៊ាង នៅរាជធានីភ្នំពេញ បានចូលរួមក្នុងការហ្វឹកហ្វឺនកងរាជអាវុធហត្ថរាជជាតិ (GRK) ជុំថ្មី អំពីរបៀបចាត់វិធានការដោះស្រាយជាមួយក្រុមនានា ដែលត្រូវបាន*

---

[756] "កម្ពុជា ៖ គណបក្សពង្រីកការត្រួតត្រារបស់កងកម្លាំងសន្តិសុខ" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ 2015, https://www.hrw.org/news/2015/02/04/cambodia-party-extends-control-security-forces.

[757] "សេចក្តីប្រកាសអំពី ការតែងតាំង និងផ្ទេរមន្ត្រីកងរាជអាវុធហត្ថលើផ្ទៃប្រទេស" , ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ http://www.dap-news.com/2011-06-14-02-39-55/89556-2015-04-10-04-46-01.html (ចូលមើលនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥)។

[758] "នៅថ្ងៃប្រារព្ធទិវានៃក្តីស្រឡាញ់ លោកវរសេនីយ៍ត្រី សៀ ទីន បានយកអំណោយចែកជូនគ្រួសារក្រីក្រ ដែលជួបប្រទះការលំបាក"  ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៦ http://www.dap-news.com/2011-06-14-02-39-55/108938-2016-02-14-09-30-25.html (ចូលមើល នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៦)។

[759] "លោក រ័ត្ន ស្រ៊ាង ៖ មន្ត្រីកងរាជអាវុធហត្ថ នៅទូទាំងរាជធានី ត្រូវបន្តអនុវត្តក្រមសីលធម៌ នៅក្នុងបេសកកម្មរបស់ខ្លួន" ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ http://kampucheathmey.com/kpt/?p=156469 (ចូលមើល នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦); "នគរបាលដែលបានដឹកនាំការបង្ក្រាបនៅផ្លូវវ៉េងស្រេងបានទទួលការតម្លើងតំណែង" ***ភ្នំពេញប៉ុស្តិ៍*** ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ http://www.phnompenhpost.com/national/cop-who-led-veng-sreng-crackdown- promoted (ចូលមើល នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦)។

[760] ពីប្រភពដដែល Ibid.

ចាត់ទុកថា គំរាមកំហែងដល់ "សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ"។[761] ក្នុងនាមជាអនុប្រធានសមាគមអតីតយុទ្ធជនរាជធានីភ្នំពេញ គាត់ក៏បានចូលរួមក្នុងកិច្ចប្រជុំមួយនៃកងកម្លាំងជំនួយរបស់គណបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់លោក គន់ គីម ដែលជាអ្នកគាំទ្រផ្នែកនយោបាយរបស់គាត់ ហើយគាត់បានលើកសរសើរលោក ហ៊ុន សែន និងបានសង្កត់ធ្ងន់លើតួនាទីរបស់អតីតយុទ្ធជននៅក្នុងការទំនាក់ទំនងជាមួយមន្ត្រីសន្តិសុខសកម្មក្នុងមូលដ្ឋាន។[762] នៅខែមេសា ឆ្នាំ២០១៧ គាត់បានចូលរួមនិយាយបន្ទរជាមួយមេបញ្ជាការកងកម្លាំងសន្តិសុខទាំងឡាយ ដោយណែនាំពលទាហានក្រោមបញ្ជារបស់ពួកខ្លួនឱ្យ "ស្មោះស្ម័គ្រ ឥតងាករេ" ចំពោះរដ្ឋាភិបាលរបស់លោក ហ៊ុន សែន តាមរយៈ "ការមិនអនុញ្ញាតដាច់ខាតឱ្យមានការកើតឡើងនូវបដិវត្តពណ៌ណាមួយឡើយ"។[763]

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ លោក រ័ត្ន ស្រ៊ាង បានប្រកាសនូវការគាំទ្រទាំងស្រុងរបស់គាត់ និងរបស់កងរាជអាវុធហត្ថរាជធានីភ្នំពេញទាំងអស់ ចំពោះសាលដីកានៃតុលាការកំពូល ដែលរំលាយគណបក្សសង្គ្រោះជាតិ ក្រោមមូលហេតុថា បានចូលរួមនៅក្នុង "អំពើក្បត់ជាតិ" ដោយមិនអាចអត់ឱនឱ្យបាន និងគាំទ្រចំពោះការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យចាត់វិធានការជាមុនបន្ថែមទៀត ដើម្បីប្រឆាំងនឹងផែនការបដិវត្តពណ៌ និងអ្នកនយោបាយ "ដែលបម្រើផលប្រយោជន៍បរទេស"។[764]

---

[761] "រូបថត នៅក្នុងការហ្វឹកហ្វឺន បង្កការភ្ញាក់ផ្អើល" ***ភ្នំពេញប៉ុស្តិ៍*** ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ http://www.phnompenhpost.com/national/training-photos-raising-eyebrows (ចូលមើល នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦)។

[762] "លោក កែប ជុតិមា ម៉ម ប៊ុនហេង និង ប៉ា សុជាតិវង្ស ផ្តល់ថវិកា ៧៣ លានរៀល សម្រាប់ដោះស្រាយបញ្ហាអតីតយុទ្ធជន" ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ http://www.freshnewsasia.com/index.php/en/localnews/42370-2016-12-22-00-31-18.html (ចូលមើល នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦)។

[763] "ឧត្តមសេនីយ៍ទោ រ័ត្ន ស្រ៊ាង សំណេះសំណាល និងសាកសួរសុខទុក្ខកងកម្លាំងកងរាជអាវុធហត្ថ នៅទូទាំងរាជធានីភ្នំពេញ និងចែកអំណោយស្វាគមន៍ បុណ្យចូលឆ្នាំថ្មី" ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៧http://www.freshnewsasia.com/index.php/en/localnews/51329-2017-04-02-08-35-05.html (ទទួលបាន ឬបានអាន នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១៧)។

[764] ឧត្តមសេនីយឯករ័ត្នស្រ៊ាង ប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះតុលាការកំពូល កាត់រំលាយគណបក្សសង្គ្រោះជាតិ និងគាំទ្រអនុសាសន៍ទាំងស្រុងរបស់សម្តេចតេជោហ៊ុនសែន។

## X. នាយឧត្តមសេនីយ៍ផ្កាយមាស ៤ សុខ ផល អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍

### *លោក សុខ ផល នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៩១*

*នៅឆ្នាំ១៩៧៩ លោក អ៊ឹង សុខ ផល (ហៅខ្លួនគាត់ថាជា សុខ ផល) បានចូលរួមក្នុងជួរនគរបាលប្រជាជនសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបន្ទាប់មកស្ថិតក្រោមបង្គាប់របស់ក្រសួងមហាផ្ទៃ ដែលក្រសួងនេះ មានសិទ្ធិអំណាចក្នុងការ "រៀបចំ បញ្ជា និងណែនាំ" ពលនគរបាលទាំងអស់ និងមាននាយកដ្ឋានចំនួនប្រាំពីរ រួមទាំងនាយកដ្ឋានសន្តិសុខប្រជាជន និងនាយកដ្ឋាននគរបាលប្រជាជនផង។*[765]

*លោក សុខ ផល បានឡើងតំណែងក្នុងជួរកងកម្លាំងសន្តិសុខ ក្លាយជាកម្មាភិបាលយ៉ាងសំខាន់នៃនាយកដ្ឋានសន្តិសុខប្រជាជន ដែលប្រតិបត្តិមុខងារ "ការពារសន្តិសុខនយោបាយ" ពោលគឺបង្ក្រាបរាល់ជនទាំងឡាយណា ដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ហៅថាជា សត្រូវនយោបាយ។*[766] *ហេតុនេះ គាត់គឺជាអ្នកដើរតួនាទីយ៉ាងសំខាន់ នៅក្នុងប្រព័ន្ធរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងការធ្វើទារុណកម្ម និងការឃុំខ្លួនអ្នកទោសនយោបាយ ដោយគ្មានការចោទប្រកាន់ ឬការជំនុំជម្រះ ឬក្រោយពេលជំនុំជម្រះដ៏អយុត្តិធម៌ ដែលមនុស្សរាប់ពាន់នាក់ បានជាប់ឃុំឃាំង។ អ្នកជាប់ឃុំទាំងនេះ រួមមាន មិនត្រឹមតែប្រជាជនដែលត្រូវបានចោទប្រកាន់ថា ជាប់ពាក់ព័ន្ធជាមួយខ្មែរក្រហម និងការបះបោរផ្សេងទៀតនោះទេ ប៉ុន្តែថែមទាំងអ្នកប្រើប្រាស់វិធីអហិង្សា ប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ឬប្រឆាំងវត្តមាននៃកងទ័ពវៀតណាមនៅកម្ពុជាផងដែរ។ ក្នុងចំណោមអ្នកប្រឆាំងទាំងនោះ ក៏មានអ្នកធ្វើការនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងអ្នកមានតួនាទីក្នុងជួរគណបក្សកាន់អំណាចផងដែរ។*[767]

---

[765] Amnesty International, មានកំណត់ត្រាស្តីពី ការសម្ភាសន៍ជាមួយមន្ត្រីការពារសន្តិសុខនយោបាយរបស់ក្រសួងមហាផ្ទៃ ភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩១, "នាយឧត្តមសេនីយ៍ផ្កាយមាសបួនចំនួនប្រាំមួយនាក់ទៀត" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤ http://www.phnompenhpost.com/national/six-more-four-star-generals (ចូលមើល នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨), សាធារណរដ្ឋប្រជាមានិតកម្ពុជា អនុក្រឹត្យលេខ ០៩ អនក្រ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៨៣។

[766] Amnesty International, មានកំណត់ត្រា សម្ភាសន៍ជាមួយមន្ត្រីការពារសន្តិសុខនយោបាយរបស់ក្រសួងមហាផ្ទៃ ភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩១។

[767] Amnesty International, *ការដាក់គុកនយោបាយ*; LCIHR, *បន្ទាប់ពីសម័យមានស្ថានការណ៍អាក្រក់បំផុត*។

ទោះបីជាក្រសួងមហាផ្ទៃនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា មានអំណាចលើកងនគរបាលនៅទូទាំងប្រទេសក៏ដោយ ក៏អំណាចនេះត្រូវបានបែងចែកដល់មេដឹកនាំគណបក្សប្រជាជនកម្ពុជា នៅថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ និងកម្រិតក្រោមបង្គាប់ផ្សេងទៀតផងដែរ។[768] អ្នកដឹកនាំគណបក្សប្រជាជនកម្ពុជាទាំងនោះ ក៏ត្រូវសហការជាមួយកងកម្លាំងកម្រិតក្រសួងមហាផ្ទៃផងដែរ ជាពិសេស ក្នុងកិច្ចការងារទាក់ទងនឹងអ្វីដែលត្រូវបានចាត់ទុកថាជា "គោលដៅ" នយោបាយ ដែលមានតម្លៃខ្ពស់ និងជាពិសេសនៅក្នុងក្រុងភ្នំពេញ ជាទីដែលទំនាក់ទំនងរវាងក្រសួង និងបុគ្គលិកសន្តិសុខនយោបាយថ្នាក់ក្រុង មានភាពជិតស្និទ្ធគ្នាមិនធម្មតា។[769]

នៅក្នុងកិច្ចសម្ភាសន៍ឆ្នាំ១៩៨៦ អតីតមន្ត្រីនគរបាលម្នាក់នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានរៀបរាប់យ៉ាងលម្អិតអំពីនីតិវិធីជាប្រក្រតី នៅក្នុងករណីនយោបាយនានាថា៖ នៅពេលនគរបាលបានចាប់ខ្លួនជនសង្ស័យណាម្នាក់ ពួកគេនឹងរៀបចំសំណុំឯកសារអំពីជននោះ ហើយបញ្ជូនជនសង្ស័យ រួមជាមួយសំណុំឯកសារនោះ ទៅមន្ត្រីអង្គភាពនគរបាលពាក់ព័ន្ធ ឬមន្ត្រី "ការពារសន្តិសុខនយោបាយ" នៃក្រសួងមហាផ្ទៃ ដើម្បីសួរចម្លើយបន្ថែម។ កម្មាភិបាលទាំងនេះ ទទួលខុសត្រូវលើការ "ស៊ើបអង្កេតទាំងមូល ដើម្បីកំណត់ឱ្យច្បាស់ថា តើនេះគឺជាករណីអ្វី និងតើត្រូវធ្វើអ្វីខ្លះចំពោះករណីនេះ"។ ដោយផ្អែកជាបឋមលើ "ចម្លើយសារភាព" ដែលបង្ខំសួរយកពីជនជាប់ឃុំដោយ "ការិយាល័យជំនាញសួរចម្លើយ" កម្មាភិបាលទាំងនេះក៏កំណត់រយៈពេល ដែលត្រូវជាប់ពន្ធនាគារ ទៅតាមការវិនិច្ឆ័យលើភាពធ្ងន់ធ្ងរនៃ "អំពើក្បត់ជាតិ" ដែលពួកគេបានចោទប្រកាន់។ រយៈពេលកំណត់អោយជាប់ពន្ធនាគារ ក៏អាស្រ័យទៅលើការរួមផ្សំនឹងកម្រិតនៃកិច្ចសហការរបស់ជនជាប់ឃុំក្នុងដំណើរការស៊ើបអង្កេត និងសញ្ញានានាដែលបង្ហាញអំពីការទទួលស្គាល់កំហុសនយោបាយរបស់ខ្លួន។ ក្នុងករណីកម្រមួយចំនួន ដែលកម្មាភិបាលនៃអគ្គនាយកដ្ឋានការពារសន្តិសុខនយោបាយសន្និដ្ឋានថា គួរប្រើជនជាប់ឃុំធ្វើជាឧទាហរណ៍មួយ តាមរយៈការជំនុំជម្រះជាសាធារណៈនោះ ក៏ពួកគេនៅតែមិនប្រើតុលាការក្នុងលក្ខណៈប្រកបដោយអត្ថន័យដដែល ពោលគឺ៖ ពួកគេជាអ្នកសម្រេច

---

768 សាធារណរដ្ឋប្រជាមានិតកម្ពុជា "យោបល់ណែនាំ និងបទបញ្ជាអំពី ការតស៊ូប្រឆាំងនឹងជនក្បត់បដិវត្តន៍ និងការរក្សាសន្តិសុខ និងបទបញ្ជាល្អ នៅក្នុងស្ថានភាពថ្មី" ឆ្នាំ១៩៧៩ សាធារណរដ្ឋប្រជាមានិតកម្ពុជា សេចក្តីសម្រេចលេខ ១៥៣ SRoCh ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨១, សាធារណរដ្ឋប្រជាមានិតកម្ពុជា អនុក្រឹត្យលេខ ០៤ អនក្រ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៨៣។

769 Amnesty International, មានកំណត់ត្រាដាក់ចំណងជើងថា "ឯកសារចងក្រង ស្តីពីមន្ត្រីពន្ធនាគារ/មណ្ឌលកែប្រែ និងអង្គភាពនានា ដែលមានអំណាចចាប់ខ្លួន និងសួរចម្លើយ" មិថុនា ឆ្នាំ១៩៨៦, Amnesty International, មានកំណត់ត្រា មានចំណងជើងថា "ពន្ធនាគារ នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា" ថ្ងៃទី៤ សីហា ឆ្នាំ១៩៨៦, ឯកសារទាំងពីរត្រូវបានចងក្រងសម្រាប់អង្គការ Amnesty International, *ការដាក់ពន្ធនាគារនយោបាយ។*

*លើការចោទប្រកាន់ និងការដាក់ទោសទណ្ឌ ហើយក្រសួងមហាផ្ទៃបញ្ជូនសំណុំឯកសារនោះ ទៅកាន់ក្រសួងយុត្តិធម៌ ដែលបន្ទាប់មករៀបចំឱ្យមានដំណើរជំនុំជម្រះក្តីក្លែងក្លាយ។*[770]

*មនុស្សដែលត្រូវក្រសួងមហាផ្ទៃចាប់ខ្លួន ត្រូវបានដាក់នៅក្នុងផ្នែកមួយនៃគុកធំជាងគេនៅទីក្រុងភ្នំពេញ ឈ្មោះថា គុកតេបី* (T3) *ដែលគ្រប់គ្រងដោយក្រសួងនេះ។*[771] *មនុស្សជាច្រើន ដែលត្រូវឃុំខ្លួននៅទីនោះ ត្រូវបានដាក់ឱ្យស្ថិតនៅក្នុងស្ថានភាពដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ហើយមនុស្សជាច្រើនបានស្លាប់នៅក្នុងមន្ទីរឃុំឃាំង ដោយសារស្ថានភាពបែបនោះ។ ក្រសួងមហាផ្ទៃ ក៏ដំណើរការមន្ទីរឃុំឃាំងនយោបាយពិសេស និងសម្ងាត់ផងដែរ ដែលជនជាប់ឃុំមួយចំនួននៅទីនោះបាន "បាត់ខ្លួន" តែម្តង ដោយសារត្រូវបានគេប្រហារជីវិត ឬបានស្លាប់ដោយសារការធ្វើបាប។*[772]

## *លោក សុខ ផល និង អ៊ុនតាក់ ចាប់ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៣*

*កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស កំណត់ឱ្យអ៊ុនតាក់* (UNTAC) *គ្រប់គ្រងដោយផ្ទាល់ លើវិស័យសន្តិសុខសាធារណៈនៃរបបរដ្ឋកម្ពុជា* (SOC-- *អតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា*)*។ រដ្ឋកម្ពុជាបានបង្កើតក្រសួងសន្តិសុខជាតិថ្មីមួយ ដែលបំបែកចេញពីក្រសួងមហាផ្ទៃ ដោយសង្ឃឹមថា ក្រសួងនេះ នឹងគេចផុតពីការគ្រប់គ្រងរបស់អ៊ុនតាក់។ លោក សុខ ផល បានទទួលការតែងតាំងឱ្យធ្វើជាប្រធាននាយកដ្ឋានចារកម្មនៃក្រសួងថ្មីនេះ ដែលពីមុនជានាយកដ្ឋានការពារសន្តិសុខនយោបាយ ២។*[773] *នាយកដ្ឋាននេះ អនុវត្តមុខងារដែលត្រូវបានបង្កើតឡើងតាំងពីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺប្រមូលព័ត៌មាន សម្រាប់កំណត់អត្តសញ្ញាណសត្រូវនយោបាយ រួមជាមួយនឹងនាយកដ្ឋានប្រឆាំងភេរវកម្ម (អតីតនាយកដ្ឋានការពារសន្តិ*

---

770 ពីប្រភពដដែល Ibid.

771 Amnesty International, មានកំណត់ត្រា ដាក់ចំណងជើងថា "ការជំនុំជម្រះជនសង្ស័យនយោបាយ នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា"" [គ្មានកាលបរិច្ឆេទ], ត្រូវបានរៀបចំចងក្រង សម្រាប់អង្គការ Amnesty International, *ការដាក់ពន្ធនាគារ នយោបាយ។*

772 Amnesty International, *ការដាក់ពន្ធនាគារនយោបាយ,* LCIHR, *ក្រោយពីមានស្ថានភាពអាក្រក់បំផុត*។

773 វិទ្យុភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩២, Amnesty International, មានកំណត់ត្រាស្តីពី ការសម្ភាសន៍ជាមួយមន្ត្រីការពារសន្តិសុខនយោបាយនៃក្រសួងមហាផ្ទៃ ភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩១, អ៊ុនតាក់ "បញ្ជីឋាននន្តរសក្តិ", ម៉ាក់ ជីតូ លិខិតទៅកាន់អ្នកកែសម្រួលអត្ថបទ "ការអះអាងមិនប្រុងប្រយ័ត្ន ធ្វើឱ្យអង្គការសិទ្ធិមនុស្សទទួលបានកិត្តិយសតិចតួច" ភ្នំពេញប៉ុស្ត៍, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ http://www.phnompenhpost.com/index.php/2012111659766/National-news/reckless-claims-do-rights-organisation-little- credit.html (ចូលមើលនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២)។

សុខនយោបាយ ១) នៃក្រសួងថ្មីនោះ។[774] ច្បាប់មួយនៅក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលត្រូវបាន អនុម័តដោយរដ្ឋកម្ពុជា បានបញ្ជាក់ថា ប្រធាន និងអនុប្រធាននាយកដ្ឋានទាំងនោះ មានអំណាចថ្នាក់ជាតិ ជាមន្ត្រីនគរបាលយុត្តិធម៌ ដែលរាប់បញ្ចូលទាំងអំណាចក្នុងការចាប់ខ្លួនផង។[775]

គណបក្សប្រជាជនកម្ពុជា បានប្រើប្រាស់មធ្យោបាយជាច្រើន ដើម្បីគេចពីការគ្រប់គ្រងរបស់អ៊ុនតាក់ លើសន្តិសុខសាធារណៈ និងវិស័យផ្សេងទៀត និងបានព្យាយាមបំភិតបំភ័យគណបក្សប្រឆាំង និងអ្នកគាំទ្រគណបក្សប្រឆាំង ដោយបើកយុទ្ធនាការប្រើប្រាស់ហិង្សានយោបាយ ដែលត្រូវរៀបចំឡើងជាសម្ងាត់។ ដោយសារមានវត្តមានរបស់អ៊ុនតាក់ ការចាប់ខ្លួន ការឃុំខ្លួន ឬការដាក់ពន្ធនាគារក្រុមប្រឆាំង ដោយបើកចំហ លែងអាចធ្វើតទៅទៀតបាន។ ប៉ុន្តែ ក្រសួងសន្តិសុខជាតិ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់បង្កើតអង្គភាពបំភិតបំភ័យ យាយី និងធ្វើឃាតដោយសម្ងាត់ លើគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រឆាំងផ្សេងទៀត។ ប្រតិបត្តិការរបស់ក្រសួងនេះ គឺជាផ្នែកមួយនៃការបង្ក្រាបរបស់គណបក្សប្រជាជនកម្ពុជា នៅមុនមានការបោះឆ្នោត ។[776]

ជាពិសេស រដ្ឋមន្ត្រី និងអនុរដ្ឋមន្ត្រីទទួលបន្ទុកសន្តិសុខជាតិក្នុងសម័យរដ្ឋកម្ពុជា បានធ្វើការងារជាមួយមន្ត្រីការពារសន្តិសុខនយោបាយ និងនគរបាលផ្សេងទៀត ព្រមទាំងកងកម្លាំងសន្តិសុខ ក្នុងការប្រព្រឹត្តអំពើហិង្សានយោបាយ ដែលដឹកនាំដោយចារកម្ម នៅក្នុងទីក្រុងភ្នំពេញ និងតំបន់ផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។ តួនាទីសំខាន់មួយនៃប្រតិបត្តិការបែបនោះ គឺត្រូវបានអនុវត្តដោយអង្គភាពសម្ងាត់នានា ដែលត្រូវបានគេស្គាល់ថាជា "ក្រុមអា" (A-Teams) ដែលគណបក្សប្រជាជនកម្ពុជាបានបង្កើតឡើង ដើម្បីរារាំងសកម្មភាពផ្សេងៗរបស់គណបក្សប្រឆាំងនានា តាមរយៈការប្រើអំពើហិង្សា និងមធ្យោបាយផ្សេងទៀត និងដើម្បីជ្រៀតចូលក្នុងអ៊ុនតាក់។[777] ភ្នាក់ងារជាន់ខ្ពស់របស់របបរដ្ឋកម្ពុជា ដែលបានសារភាពថា ខ្លួនបានចូល

[774] បេសកកម្មអង្កេតការណ៍ របស់អង្គការសហប្រជាជាតិ ទៅកាន់ប្រទេសកម្ពុជា "សន្តិសុខសាធារណៈ និងនគរបាលស៊ីវិលនៅសម័យរដ្ឋកម្ពុជា" ខែធ្នូ ឆ្នាំ១៩៩១ ទំព័រ ១-៤០។

[775] រដ្ឋកម្ពុជា "ច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ" ថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣។

[776] ការសម្ភាសន៍របស់លោក Brad Adams ជាមួយអតីតមន្ត្រីនគរបាលរដ្ឋកម្ពុជា ភ្នំពេញ ខែមីនា ឆ្នាំ២០០០។

[777] អ៊ុនតាក់ ក្រុមត្រួតពិនិត្យ "របកគំហើញរបស់ក្រុមត្រួតពិនិត្យ" ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៩៣, អ៊ុនតាក់ ផ្នែកអប់រំ "ឯកសារបកប្រែដែលក្រុមត្រួតពិនិត្យទទួលបាន" ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៩៣, អ៊ុនតាក់ ផ្នែកព័ត៌មាន/ការអប់រំ "ឯកសាររដ្ឋកម្ពុជា/គណបក្សប្រជាជនកម្ពុជា ដែលក្រុមត្រួតពិនិត្យទទួលបាននៅខេត្តព្រះសីហនុ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៣", អ៊ុនតាក់ ផ្នែកព័ត៌មាន/ការអប់រំ "អបគមន៍និយមរបស់គណបក្សប្រជាជនកម្ពុជា ការលាលែងពីរដ្ឋសភា និងការបំភិតបំភ័យ  អ៊ុនតាក់ ៖ សារតា និងទ្រឹស្តី ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៩៣" អ៊ុនតាក់ ផ្នែកព័ត៌មាន/ការអប់រំ "បន្ទាប់ពីតំបន់ស្វ័យយ័ត ខេត្តព្រៃ

រួមនៅក្នុងការរៀបចំផែនការធ្វើឃាតសកម្មជនគណបក្សប្រឆាំង និងចូលរួមនៅក្នុងការប្រជុំនានារបស់មន្ត្រីជាន់ខ្ពស់ នៅពេលក្រោយមកបានរំលឹកថា ៖ "គណបក្សប្រជាជនកម្ពុជា ភ័យខ្លាចថា ពួកគេនឹងចាញ់នៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ ហេតុនេះលោក ស៊ិន សុង និងលោក ស៊ិន សេន ដែលទទួលខុសត្រូវលើសន្តិសុខផ្ទៃក្នុង បានធ្វើការងារជាមួយនាយឧត្តមសេនីយ៍មកពីនគរបាល និងយោធាមួយចំនួន ដើម្បីបង្កើតរចនាសម្ព័ន្ធថ្មីៗ..។ ក្រុមអា (A-Teams) ទាំងអស់ ត្រូវរាយការណ៍ទៅលោក សុខ ផល ហើយលោក សុខ ផល ត្រូវរាយការណ៍ទៅលោក ស៊ិន សេន។[778] ប្រភពពីកងកម្លាំងសន្តិសុខម្នាក់ផ្សេងទៀតនិយាយថា ទោះ ជាលោក សុខ ផល "ធ្វើការឱ្យលោក ស៊ិន សេន ក៏ដោយក៏គាត់រាយការណ៍ផ្ទាល់ទៅលោក ហ៊ុន សែន ដែរនៅក្នុងសម័យអ៊ុនតាក់ ដែលខ្សែសង្វាក់បញ្ជាក្នុងសម័យនោះ គឺពីលោក ហ៊ុន សែន ទៅលោក សុខ ផល"។[779]

លោក សុខ ផល ក៏ត្រូវបានគេលើកឡើងថា ជាអ្នកទទួលខុសត្រូវ ជានាទូវការអនុវត្តបទបញ្ជារបស់គណបក្សប្រជាជនកម្ពុជាផងដែរ។ បទបញ្ជាទាំងនោះកំណត់ថា នគរបាលមិនត្រូវស៊ើបអង្កេតឧក្រិដ្ឋកម្មហិង្សានយោបាយរបស់គណបក្សប្រជាជនកម្ពុជាឡើយ ទោះបីជាក្នុងករណីដែលពួកគេត្រូវធ្វើពុតជា ស៊ើបអង្កេតក៏ដោយ។[780] ការធ្វើបែបនេះគឺ ស្របតាមគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ដែលតែងតែចាត់ទុកអំពើហិង្សានយោបាយថា ត្រូវបានប្រព្រឹត្តដោយសមាសភាពហួសពីការគ្រប់គ្រងរបស់ខ្លួន និងស្របតាមការអនុវត្តរបស់គណបក្សប្រជាជនកម្ពុជា ដែលរៀបឬកឱ្យមើលទៅហាក់ដូចជាសហការជាមួយអ៊ុនតាក់ក្នុងការ "ស៊ើបអង្កេត" ឧប្បត្តិហេតុនានា ដែលតាមការពិតគឺគ្រាន់តែដើម្បីបិទបាំងបទបញ្ជា និងការគ្រប់គ្រងរបស់គណបក្សនេះប៉ុណ្ណោះ។[781]

របាយការណ៍របស់អ៊ុនតាក់ ដែលត្រូវបានសរសេរឡើងនៅខែមេសា ឆ្នាំ១៩៩៣ ផ្អែកលើឯកសារផ្ទៃក្នុងរបស់គណបក្សប្រជាជនកម្ពុជា ដែលអ៊ុនតាក់ទទួលបានក្នុងអំឡុងពេលអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស រៀបរាប់ថា បណ្តាក្រុមអា (A-Teams) បាន "ជាប់ពាក់ព័ន្ធក្នុងសកម្មភាពនានាដែលធ្វើឱ្យខូចប្រយោជន៍ទាំងមូលដល់ការបង្កើតបរិយាកាសនយោបាយប្រកបដោយអព្យាក្រឹតភាព"។ ឯកសារដដែលនេះ បាន

វែង ថ្ងៃទី១៧-១៨ ខែមិថុនា ឆ្នាំ១៩៩៣"។

[778] ការសម្ភាសន៍របស់លោក Brad Adams ជាមួយអតីតមន្ត្រីនគរបាលរដ្ឋកម្ពុជា ភ្នំពេញ ខែមីនា ឆ្នាំ២០០០។

[779] ការសម្ភាសន៍របស់លោក Brad Adams ជាមួយអតីតសមាជិកក្រុម ក ភ្នំពេញ ខែធ្នូ ឆ្នាំ២០០១។

[780] COHCHR, ការសម្ភាសន៍ជាមួយលោក ស៊ិន សេន ភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៥។

[781] UNTAC, "អបគមន៍និយមរបស់គណបក្សប្រជាជនកម្ពុជា", "ហ៊ុន សែន ៖ ជនល្មើសកំពុងត្រូវបានស្វែងរក" *AFP*, ភ្នំពេញ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៩៣។

បង្ហាញថា រដ្ឋកម្ពុជា (SOC) បានដឹងនូវអំពើដែលខ្លួនបានប្រព្រឹត្ត គឺជាការរំលោភបំពានលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដូច្នេះទើបបាន "ចាត់វិធានការគ្រប់ដំហាន ដើម្បីបិទបាំងសកម្មភាពទាំងនោះ ពីអ៊ុនតាក់ និងប្រជារាស្ត្រ"។[782] ឯកសារមួយរបស់ក្រសួងសន្តិសុខជាតិ មានចំណងជើងថា "ការបង្កើតកងកម្លាំងអា-៩២ (A-92 Forces) " ដែលអ៊ុនតាក់ទទួលបាន និងមាននៅអង្គការសិទ្ធិមនុស្ស យូមែន រ៉ៃត៍ វ៉ច្ឆ (Human Rights Watch) បានបរិយាយពីតួនាទីរបស់ក្រុមអា និងកម្លាំងអា-៩២ (A-Teams, A-92 Forces) យ៉ាងលំអិត។ រចនាសម្ព័ន្ធបញ្ជាការសម្ងាត់ចាប់ពីស្នងការ ឬស្នងការរងសន្តិសុខ នៅខេត្តនីមួយៗ ត្រូវបានបង្កើតឡើង និងបានជ្រើសរើសមនុស្សដែលមានតួនាទីខ្ពស់ ដូចជា សាស្ត្រាចារ្យ គ្រូបង្រៀន គ្រូពេទ្យ ព្រះសង្ឃ និង "អ្នកផ្សេងទៀត ដែលមានឥទ្ធិពលក្នុងចំណោមហ្វូងមហាជន"។ ភ្នាក់ងាររបស់ក្រុម អា-៩២ (A-92 Forces) ត្រូវបានបញ្ជាឱ្យជ្រៀតខ្លួនចូល និងធ្វើវិទ្ធង្សនាក្នុង "អង្គការចាត់តាំងនយោបាយទាំងអស់ ដែលមានគោលនយោបាយប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជា"។ គោលបំណង គឺដើម្បីរកព័ត៌មានអំពីយុទ្ធសាស្ត្រ និងអ្នកគាំទ្ររបស់ពួកគេ និងដើម្បីរារាំងពួកគេ តាមរយៈការដណ្តើមយកការគ្រប់គ្រងលើមុខងារចាំបាច់ផ្សេងៗ រួមមាន ធនធានសេដ្ឋកិច្ច ជាដើម។ មុខងាររបស់ក្រុមនេះ រួមមាន "បង្កើតអោយមានការយល់ច្រឡំក្នុងចំណោមមហាជន អំពីគណបក្សប្រឆាំង បង្កើតសកម្មភាពផ្សេងៗដែលបង្ខូចកេរ្តិ៍ឈ្មោះ និងផលប្រយោជន៍របស់ក្រុមប្រឆាំង បង្កើតភាពមិនចុះសម្រុងគ្នា និងបែកបាក់គ្នាក្នុងចំណោមកម្លាំងរបស់ពួកគេ និងប្រើប្រាស់វិធីសាស្ត្របង្ការជាមុន ដើម្បីទប់ស្កាត់គណបក្សប្រឆាំង មិនឱ្យទទួលបានប្រយោជន៍ពីការបោះឆ្នោត"។[783]

ឯកសារនោះ សរសេរថា ភ្នាក់ងារក្រុមអា-៩២ (A-92 Forces) នឹង៖

> អនុវត្តដោយខ្លួនឯងផ្ទាល់ ឬតាមរយៈអន្តរការី នូវការបំផ្លាញចោល និងការទប់ស្កាត់យុទ្ធសាស្ត្រ ផែនការ វិធីសាស្ត្រ ល្បិច ព្រមទាំងសកម្មភាពរបស់គណបក្សប្រឆាំង ដែលមានបំណងពង្រីកឥទ្ធិពល និងសមាជិករបស់ពួកគេ ដើម្បីបំផ្លាញយើង។ មន្ត្រី ឬភ្នាក់ងារក្រុមអា-៩២ (A-92 Forces) ក៏ត្រូវសម្រេចឱ្យបាននូវគោលដៅណាមួយ ក្នុងចំណោមគោលដៅជាច្រើន សំខាន់គឺគោលដៅចម្បងៗ ដូចជា លុបបំបាត់ឥទ្ធិពល ការឃោសនា និងសង្គ្រាមចិត្ត

782 អ៊ុនតាក់ ផ្នែកព័ត៌មាន/ការអប់រំ "កងកម្លាំងប្រតិកម្ម និង ក្រុមអា (A-Team Member) " ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៣។

783 ក្រសួងសន្តិសុខជាតិ "ការបង្កើតកងកម្លាំង A-៩២" (ឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ)។

សាស្ត្រ របស់គណបក្សប្រឆាំង និងជាពិសេស លុបបំបាត់ឥទ្ធិពលរបស់ពួកគេក្នុងចំណោមមហាជន។

ឯកសារនោះបន្តទៀតថា ៖ "ការបង្កើតក្រុមជំនួយនានា ទាំងនៅក្នុងក្រសួងទាំងឡាយ និងនៅតាមខេត្តក្រុងគឺជាការចាំបាច់។ ក្រុមទាំងនេះ ត្រូវជ្រើសរើសចេញពីក្នុងចំណោមកងកម្លាំងសន្តិសុខ។ .... ក្រសួងសន្តិសុខជាតិបញ្ជាក់ថា ឯកសារនេះ ត្រូវទុកជាឯកសារសម្ងាត់ខ្ពស់បំផុត"។[784]

កំណត់ត្រារបស់អ៊ុនតាក់ បង្ហាញថា បណ្តាក្រុមអា (Teams-A) បានលើកទឹកចិត្ត និងណែនាំសមាជិករបស់ខ្លួន ឱ្យធ្វើការវាយប្រហារ និងបិទបាំងភស្តុតាងនៃការសមគំនិតជាផ្លូវការ។[785] ដោយសារកងកម្លាំងប្រតិកម្មមិនមានទំនាក់ទំនងផ្លូវការជាមួយកងកម្លាំងសន្តិសុខនៃរបបរដ្ឋកម្ពុជា នគរបាលអាចបដិសេធការជាប់ពាក់ព័ន្ធបាន។ ឯកសារដែលត្រូវបានរកឃើញនៅខេត្តតាកែវ ព្រៃវែង និងកំពង់ចាម បង្ហាញថា សមាជិកកងកម្លាំងសន្តិសុខ បានទទួលការលើកទឹកចិត្ត ឱ្យបង្កើតហេតុការណ៍តាមចំនួនកំណត់ និងបិទបាំងការរួមគំនិតជាមួយគណបក្សប្រជាជនកម្ពុជា តាមរយៈការធ្វើជាជួយដល់អ្នកស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិ។ ហេតុនេះ មនុស្សដដែលៗនៅពីក្រោយអំពើឧក្រិដ្ឋកម្ម អាចមានឥទ្ធិពលលើការស៊ើបអង្កេត។[786]

អង្គភាពទាំងនេះ មិនត្រឹមតែបង្កការភ័យខ្លាចខ្លាំង នៅក្នុងចំណោមក្រុមប្រឆាំងជាចំហប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងបង្កភាពភ័យខ្លាចដល់អ្នកនៅក្នុងរបបរដ្ឋកម្ពុជា និងគណបក្សប្រជាជនកម្ពុជាផងដែរ ។ ដោយបុគ្គលបម្រុងដែលនឹងក្លាយជាអ្នកកែទម្រង់នៅក្នុងរបបនោះជាច្រើន បានរៀបរាប់ថា រចនាសម្ព័ន្ធសន្តិសុខ និងការអនុវត្តន៍វិទ្ធង្សនាបែបនេះ គឺជាការប្រឆាំងយ៉ាងខ្លាំងទៅនឹងការផ្លាស់ប្តូរនយោបាយ និងជាការបំផ្លាញដំណើរការប្រជាធិបតេយ្យ ដែលរបបរដ្ឋកម្ពុជា បានប្តេជ្ញាចិត្តថា ខ្លួននឹងទទួលយកតាមរយៈកិច្ចព្រមព្រៀងទីក្រុងសន្តិភាពប៉ារីស។[787]

---

784 ពីប្រភពដដែល Ibid.

785 Judy Ledgerwood, "ទម្រង់នៃការបង្ក្រាបរបស់នយោបាយគណបក្សប្រជាជនកម្ពុជា និងអំពើហិង្សាក្នុងសម័យអ៊ុនតាក់" នៅក្នុង Steve Heder និង Judy Ledgerwood, eds., *ការឃោសនា នយោបាយ និងអំពើហិង្សានៅក្នុងប្រទេសកម្ពុជា ៖ អន្តរកាលប្រជាធិបតេយ្យ នៅក្រោមការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ* (ទីក្រុងឡុងដ៍៖ M.E Sharpe, ឆ្នាំ១៩៩៦), ទំព័រ ១២៩។

786 អ៊ុនតាក់ ផ្នែកព័ត៌មាន/ការអប់រំ "ក្រុមប្រតិកម្ម និងក្រុមអា (A-Team Member) " ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៣។

787 Amnesty International, កំណត់ត្រារក្សាទុកជាឯកសារ មានចំណងជើងថា "កាលបរិច្ឆេទ ៖ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩២, ស្តីពី៖ របាយការណ៍

## លោក សុខ ផល នៅក្រោមនាយកដ្ឋានកណ្ដាលសន្តិសុខនៃរាជរដ្ឋាភិបាល ពីឆ្នាំ១៩៩៣-២០០៣

លោក សុខ ផល បន្តនៅធ្វើជាប្រធាននាយកដ្ឋានចារកម្ម បន្ទាប់ពីគណបក្សហ៊្វុនស៊ិនប៉ិចបានឈ្នះការបោះឆ្នោតនៅខែឧសភា ឆ្នាំ១៩៩៣ និងក្រោយការបង្កើតរដ្ឋាភិបាលចម្រុះរវាងគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា ដោយមានសហនាយករដ្ឋមន្ត្រី។ ក្នុងក្រសួងមហាផ្ទៃដែលត្រូវបានបង្រួបបង្រួមគ្នាឡើងវិញក្រោមរដ្ឋាភិបាលចម្រុះ លោក សុខ ផល នៅតែមានតួនាទីដដែល ដោយរាយការណ៍ជូនរដ្ឋលេខាធិការម្នាក់របស់គណបក្សប្រជាជនកម្ពុជា។[788] អនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា នៅខែធ្នូ ឆ្នាំ ១៩៩៣ បានរៀបចំរចនាសម្ព័ន្ធកងកម្លាំងសន្តិសុខឡើងវិញ ដោយបង្កើតអគ្គស្នងការនគរបាលជាតិ ដែលមានអំណាចគួរឱ្យកត់សម្គាល់ លើអគ្គនាយកដ្ឋានថ្នាក់កណ្ដាលជាច្រើន ដែលត្រូវបានបំបែកបន្តទៀតទៅជានាយកដ្ឋាន។ នាយកដ្ឋានមួយ ក្នុងចំណោមនាយកដ្ឋានទាំងនេះ គឺនាយកដ្ឋានព័ត៌មានទូទៅ ជាឈ្មោះថ្មីរបស់អង្គភាពដែលលោក សុខ ផល បន្តនៅធ្វើជាប្រធាន និង ត្រូវបានដាក់ឱ្យស្ថិតក្រោមនាយកដ្ឋានកណ្ដាលសន្តិសុខ។[789] មន្ត្រីនៃអង្គភាពទាំងនេះ មានដែនសមត្ថកិច្ចកម្រិតថ្នាក់ជាតិ ប៉ុន្តែគ្មានអំណាចច្រើនក្នុងការបញ្ជាប្រតិបត្តិការលើនគរបាលមូលដ្ឋានឡើយ។[790] មួយរយៈពេលក្រោយមក នាយកដ្ឋានព័ត៌មានទូទៅ បានប្ដូរឈ្មោះត្រលប់ទៅជានាយកដ្ឋានចារកម្មវិញដោយមានលោក សុខ ផល ជាអ្នកទទួលបន្ទុកដូចពេលមុន។[791] ក្នុងដំណើរការផ្លាស់ប្ដូរឈ្មោះចុះឡើងនេះ នាយកដ្ឋានរបស់លោក សុខ ផល ជាអង្គភាពមួយក្នុងចំណោម

---

បេសកកម្ម ទៅកាន់ប្រទេសកម្ពុជា, កាលបរិច្ឆេទនៃបេសកកម្ម ៖ ថ្ងៃទី៨-២៨ ខែធ្នូ ឆ្នាំ១៩៩១"។

[788] ការសម្ភាសន៍ជាមួយលោក ខាន់ សារឿន ខេត្តសុរិន្ទ ប្រទេសថៃ ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧។

[789] រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣, COHCHR, "ក្រសួងមហាផ្ទៃ" ឆ្នាំ១៩៩៥, រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ៩៩ អនក្រ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៤។

[790] រាជរដ្ឋាភិបាលកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៧) មាត្រា ៦០, ៦៧, http://www.wipo.int/wipolex/en/text.jsp?file_id=24088, ចូលមើល នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥, រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ២៧ អនក្រ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩, "អាជ្ញាធរថៃ ប្រគល់ឃាតកខ្មែរម្នាក់ ដែលបាញ់សម្លាប់ប្អូនជនជាតិជប៉ុន មកឱ្យសមត្ថកិច្ចកម្ពុជា" ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៣ http://www.khmerload.com/news/13106 (ចូលមើល នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣); "ដៃទាំងពីរលើជនល្មើស និងអ្នករួមគំនិតបីនាក់ ដែលត្រូវឃុំខ្លួនពីបទប្លន់ម៉ូតូ និងឃាតកម្ម) ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១២ http://www.yolprom.com/news/20121030-349 (ចូលមើល នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១២); *ខេមបូឌា ដេលី* ថ្ងៃទី៧-៩ ខែតុលា ឆ្នាំ១៩៩៤, រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃ៩ ខែឧសភា ឆ្នាំ១៩៩៤, រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ១៥៦ អនក្រ ចុះថ្ងៃ៣១ ខែមីនា ឆ្នាំ២០១៤។

[791] រាជរដ្ឋាភិបាលកម្ពុជា "ក្រសួងមហាផ្ទៃ" ថ្ងៃ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨, រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យលេខ នស/០៦១០/៥៦៧ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, ការសម្ភាសន៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ ជាមួយមន្ត្រីនគរបាលជាន់ខ្ពស់ (ឈ្មោះត្រូវបានដកចេញ)។

អង្គភាពកងកម្លាំងសន្តិសុខដែលមានអំណាចបំផុតនៅថ្នាក់កណ្តាល។[792] លោក ហ៊ុន សែន បានប្រើប្រាស់នាយកដ្ឋាននេះ ដើម្បីបង្ហាញអំណាចមិនត្រឹមតែលើគណបក្សហ៊្វុនស៊ិនប៉ិចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើលោក ស ខេង រដ្ឋមន្ត្រីមកពីគណបក្សប្រជាជនកម្ពុជា ដែលលោក ហ៊ុន សែន មិនទុកចិត្តនោះផងដែរ។[793]

ដោយមានមន្ត្រីចំនួន២៥០-៣០០នាក់ និងបុគ្គលិកចំនួនជាង ២,០០០ (ពីរពាន់) នាក់ ដោយអ្នកខ្លះក្លែងធ្វើជាអ្នកសារព័ត៌មាន ធ្វើការងារអោយគាត់ផ្ទាល់។ លោក សុខ ផល បានរក្សាទុក និងពង្រីកសំណុំឯកសារចារកម្មរបស់គាត់អំពីអ្នកនយោបាយទាំងអស់ ដោយពង្រឹងបន្ថែមលើការងារដែលគាត់បានធ្វើតាំងពីទសវត្សរ៍ឆ្នាំ១៩៨០មក។[794] គាត់បានទទួលខុសត្រូវចំពោះការពង្រីកការត្រួតពិនិត្យតាមដានលើប្រព័ន្ធទូរគមនាគមន៍ តាមរយៈការពង្រាយបុគ្គលិកនៅតាមក្រុមហ៊ុនទូរគមនាគមន៍នានា ដោយផ្តោតលើអ្នកប្រឆាំងរួមទាំងមន្ត្រីជាន់ខ្ពស់របស់គណបក្សហ៊្វុនស៊ិនប៉ិចជាច្រើនរូប ដូចជា ករណីដែលត្រូវបានលើកឡើងខាងលើរបស់រដ្ឋមន្ត្រីការបរទេស គឺសម្តេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ ដែលទ្រង់ត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារក្រោមបទចោទប្រកាន់ផ្អែកលើព័ត៌មានមិនពិត ដោយសារតែការលួចស្តាប់យកការណ៍ដោយខុសច្បាប់របស់លោក សុខ ផល។[795] គ្រឿងបរិក្ខារចារកម្មក៏ត្រូវបានប្រើប្រាស់ ដើម្បីឃ្លាំមើលអង្គការមិនមែនរដ្ឋាភិបាល អ្នកជំនួញ និងសមាជិកគណបក្សប្រជាជនកម្ពុជា រួមទាំងលោក ស ខេង ផងដែរ។[796]

ក្នុងអំឡុងពេល និងក្រោយពេលរដ្ឋប្រហារ នៅខែកក្កដា ឆ្នាំ១៩៩៧ របស់លោក ហ៊ុន សែន និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ១៩៩៨ និង២០០៣ ការងារចម្បងរបស់នាយកដ្ឋានលោក សុខ ផល គឺនៅតែជាប្រតិបត្តិការឃ្លាំមើល ដោយផ្តោតលើគោលដៅស៊ីវិល និងសំខាន់បំផុត គឺគណបក្សនយោបាយប្រឆាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។[797] គាត់ក៏នៅបន្តទទួលខុសត្រូវក្នុងការទប់ស្កាត់ មិនឱ្យនគរបាលធ្វើការស៊ើបអង្កេតលើឃាតកម្មនយោបាយ និងប្រតិបត្តិការផ្សេងទៀតរបស់គណបក្សប្រជាជនកម្ពុជាទប់ទល់នឹង

---

792 COHCHR, ការសម្ភាសន៍ជាមួយលោក ស៊ិន សេន ភ្នំពេញ ថ្ងៃ២០ ខែមករា ឆ្នាំ២០០៤។

793 ការសម្ភាសន៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្លាំមើលសិទ្ធិមនុស្ស ជាមួយមន្ត្រីនគរបាលជាន់ខ្ពស់ ដែលឈ្មោះរបស់ពួកគេត្រូវបានដកចេញ។

794 ពីប្រភពដដែល Ibid.

795 ការសម្ភាសន៍របស់លោក Brad Adams ជាមួយអតីតមន្ត្រីនគរបាល ប៉ារីស ឆ្នាំ២០០៤។

796 ការសម្ភាសន៍ជាមួយអតីតមន្ត្រីនគរបាល ស្តុកខុម ឆ្នាំ២០០៤, ការសម្ភាសន៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្លាំមើលសិទ្ធិមនុស្ស ជាមួយមន្ត្រីនគរបាលជាន់ខ្ពស់ ដែលឈ្មោះរបស់ពួកគេត្រូវបានដកចេញ។

797 ការសម្ភាសន៍ជាមួយឧត្តមសេនីយ៍ ចៅ ផល្លី ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៣។

*ក្រុមប្រឆាំង ហើយមនុស្សផ្ទៃក្នុងម្នាក់បាននិយាយពីអង្គភាពរបស់គាត់ថា ជាអង្គភាព "មានសារៈសំខាន់បំផុត ចំពោះគណបក្សប្រជាជនកម្ពុជា" នៅក្នុងការរក្សាអំណាច និងជាពិសេស សម្រាប់ផែនការនយោបាយទុច្ចរិតរបស់លោក ហ៊ុន សែន។*[798]

## *លោក សុខ ផល ក្នុងតួនាទីជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០១៤*

*នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៣ លោក ហ៊ុន សែន បានដំឡើងតំណែងរបស់លោក សុខ ផល ទៅជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ដោយដាក់គាត់ឱ្យទទួលបន្ទុករាល់មុខងារចាស់ក្នុងការការពារសន្តិសុខនយោបាយនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងមុខងារថ្មីៗរបស់នាយកដ្ឋានដែលត្រូវបានបន្ថែមចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ មក។*[799] *អំណាចរបស់នាយកដ្ឋាននេះ រួមមាន អំណាចលើនាយកដ្ឋានព័ត៌មានទូទៅ ឬចារកម្ម នាយកដ្ឋានសន្តិសុខផ្ទៃក្នុង នាយកដ្ឋានប្រឆាំងភេរវកម្ម នាយកដ្ឋានអន្តោប្រវេសន៍ នាយកដ្ឋាននគរបាលអន្តរជាតិ* (Interpol) *ព្រមទាំងនាយកដ្ឋានកងអង្គរក្ស និងមន្ត្រីនគរបាលយុត្តិធម៌របស់នាយកដ្ឋានទាំងនេះ ដែលមានដែនសមត្ថកិច្ចនៅទូទាំងប្រទេស។*[800]

*គិតត្រឹមឆ្នាំ២០០៥ លោក សុខ ផល ក៏មានតួនាទីជាអគ្គស្នងការរងនគរបាលជាតិដែរ ដែលបានដើរតួនាទីជា "សេនាធិការ" របស់អគ្គស្នងការ (ដំបូងឡើយ គឺលោក ហុក ឡង់ឌី ក្រោយមកទៀតលោក នេត សាវឿន)។*[801] *នៅចុងឆ្នាំ២០០៥ គាត់ក៏បានចូលរួមជាសមាជិកគណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា ក្នុងពេលជាមួយគ្នានឹងកងកម្លាំងសន្តិសុខកំពូលៗ ដែលលោក ហ៊ុន សែន ពេញចិត្ត ដូចជា លោក គន់ គីម និង*

---

798 ការសម្ភាសន៍ជាមួយលោក ស៊ិន សេន ភ្នំពេញ ថ្ងៃ២០ ខែមករា ឆ្នាំ២០០៤, ការសម្ភាសន៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ជាមួយមន្ត្រីនគរបាលជាន់ខ្ពស់ ដែលឈ្មោះរបស់ពួកគេត្រូវបានដកចេញ។

799 រាជរដ្ឋភិបាលកម្ពុជា អនុក្រឹត្យលេខ ៦៦ អនក្រ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៣ ស្តីពីការតែងតាំងតួនាទីមន្ត្រីនគរបាលជាតិជាន់ខ្ពស់, ការសម្ភាសន៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ជាមួយមន្ត្រីនគរបាលជាន់ខ្ពស់ ដែលឈ្មោះរបស់ពួកគេត្រូវបានដកចេញ, រាជរដ្ឋាភិបាល អនុក្រឹត្យលេខ ៦៦ អនក្រ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៣ ស្តីពីការតែងតាំងតួនាទីមន្ត្រីនគរបាលជាតិជាន់ខ្ពស់។

800 រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រមលេខ នស/០៦១០/៤៦៧ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, រាជរដ្ឋាភិបាលកម្ពុជា អង្គការលេខ "អគ្គស្នងការនគរបាលជាតិ" [គ្មានកាលបរិច្ឆេទ] (ប៉ុន្តែត្រូវបានចុះកាលបរិច្ឆេទតាមកាលបរិច្ឆេទ ឆ្នាំ២០១៤)។

801 "នាយករដ្ឋមន្ត្រី អំពាវនាវឱ្យមន្ត្រីរដ្ឋាភិបាល ដោះស្រាយបញ្ហាភេរវកម្ម" *កម្ពុជាស្ថិតក្នុងការចាប់អារម្មណ៍* (ណូវ៉ែលហ្សេឡង់), ខែ កក្កដា ឆ្នាំ២០០៥, សម្រាប់ការពន្យល់មុខងារនៃអគ្គស្នងការរង, រាជរដ្ឋាភិបាលកម្ពុជា "អគ្គស្នងការនគរបាលជាតិ ចេញសេចក្តីប្រកាសអំពី តួនាទី និងភារកិច្ចនៃអគ្គស្នងការរងទាំង ១៤ រូប" ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៤ (ឯកសារនៅក្នុងចំណោមឯកសារកម្មសិទ្ធិរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ)។

លោក នេត សាវឿន ដែរ។[802]

## សុខ ផល និងការបង្ក្រាបអ្នកសកម្មនិយមខ្មែរក្រោម និងអ្នកចែកខិតប័ណ្ណប្រឆាំងលោក ហ៊ុន សែន

ចាប់ពីឆ្នាំ២០០៩ មក នាយកដ្ឋានកណ្តាលសន្តិសុខ បានដើរតួនាទីសំខាន់ ដោយរួមគ្នាជាមួយនឹងនគរបាលថ្នាក់កណ្តាលផ្សេងទៀត និងពេលខ្លះក៏រួមជាមួយនឹងនគរបាលថ្នាក់ក្រោមជាតិផងដែរ នៅក្នុងការបង្ក្រាបភាពសកម្មក្នុងរឿងនយោបាយដោយអហិង្សារបស់សកម្មជនខ្មែរក្រោម និងសកម្មភាពចែក ឬ បាចខិតប័ណ្ណប្រឆាំងលោក ហ៊ុន សែន ដែលធ្វើឡើងដោយខ្មែរក្រោម និងខ្មែរនៅក្នុងប្រទេសកម្ពុជា (ខ្មែរក្រោម គឺជាពាក្យ ដែលប្រើសំដៅដល់មនុស្ស ដែលកំណត់ថា ជាជនជាតិដើមខ្មែរកើតនៅក្នុងទឹកដីរបស់ខ្លួន ដែលបច្ចុប្បន្នស្ថិតក្នុងប្រទេសវៀតណាមភាគខាងត្បូង ឬមានដូនតាកើតនៅទីនោះ។ សហគមន៍ខ្មែរក្រោមយ៉ាងច្រើនសម្បើមនៅតែបន្តរស់នៅក្នុងផ្នែកខ្លះនៃតំបន់ដីសណ្តទន្លេមេគង្គក្រោម ក្នុងប្រទេសវៀតណាម ប៉ុន្តែអ្នកផ្សេងទៀត តិច ឬ ច្រើន បានធ្វើចំណាកស្រុក ទៅកាន់តំបន់នានា ក្នុងដែនដីកម្ពុជា)។[803]

សកម្មភាពនានារបស់នាយកដ្ឋានកណ្តាលសន្តិសុខ ត្រូវបានធ្វើឡើង ក្រោយពេលមានការបង្ក្រាបជាហូរហែរបស់អាជ្ញាធរវៀតណាមចាប់តាំងពីឆ្នាំ២០០៧មក  ទៅលើបាតុកម្មនានា ជាពិសេស បាតុកម្មដោយព្រះសង្ឃខ្មែរក្រោម និកាយថេរវាទ ដែលបានធ្វើបាតុកម្មអហិង្សា ប្រឆាំងការរឹតត្បិតរបស់រដ្ឋាភិបាលវៀតណាមមកលើសេរីភាពសាសនា និងអ្វីដែលពួកគេហៅថា ជាការបង្រៀនភាសាខ្មែរមិនបានគ្រប់គ្រាន់ ក្នុងប្រទេសវៀតណាម។[804] សកម្មភាពទាំងនោះ រាប់បញ្ចូលទាំងប្រតិបត្តិការកាលពីខែមេសា ឆ្នាំ២០០៩ ដែលធ្វើឡើងក្នុងគោលបំណងចាប់ខ្លួនអតីតព្រះសង្ឃខ្មែរក្រោមប្រាំនាក់ ដែលបានភៀសខ្លួនទៅជ្រកកោនក្នុងប្រទេសកម្ពុជា បន្ទាប់ពីជាប់ពន្ធនាគារពីរឆ្នាំនៅក្នុងប្រទេសវៀតណាមពីបទចូលរួមក្នុងចលនាតវ៉ារបស់ខ្មែរក្រោម និងព្រឹត្តិការណ៍នៅខែមករា-ឧសភា ឆ្នាំ២០១០ ពាក់ព័ន្ធនឹងបុគ្គលដែលត្រូវបានចោទថា ជាខ្មែរក្រោម និងជាអ្នកបាចខិតប័ណ្ណដទៃទៀត។[805] ប្រតិបត្តិការក្រោយនេះ បានបង្កឱ្យមានកាត់ទោសមនុស្សប្រាំនាក់ដាក់

---

[802] "សមាជិកថ្មី១២១រូបនៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៥ http://www.phnompenhpost.com/national/121-new-members-boost-cpp-central-committee (ចូលមើល នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣)។

[803] Philip Taylor *ដែនដីខ្មែរនៃប្រទេសវៀតណាម ៖ បរិយាកាស លោកធាតុវិទ្យា និងអធិបតេយ្យភាព* (សិង្ហបូរី NUS Press ២០១៤)។

[804] អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ,*នៅលើផ្នែកដែលគេមើលរំលង ៖ការរំលោភបំពានសិទ្ធិមនុស្សលើជនជាតិខ្មែរ នៅតំបន់ដីសន្ទទន្លេមេគង្គប្រទេសវៀតណាម* (ញូវយ៉ក ៖ ឆ្នាំ២០០៩) ទំព័រ ២៧-៤៣ ៩, ៥៧-៧០ http://www.hrw.org/sites/default/files/reports/vietnam0109web_0.pdf.

[805] ពីប្រភពដដែល Ibid.

ពន្ធនាគារ ពីបទចូលរួមក្នុងសកម្មភាពបាចខិតប័ណ្ណដោយចេតនា រួមទាំងបុគ្គលិកម្នាក់របស់អង្គការសិទ្ធិមនុស្សផងដែរ។[806] នាយកដ្ឋានកណ្តាលសន្តិសុខបានដើរតួនាទីនៅក្នុងប្រតិបត្តិការបន្តបន្ទាប់ទៀត ក្នុងការចាប់ខ្លួន និង ក្នុងការជំនុំជម្រះខ្មែរក្រោម និងបុគ្គលដទៃទៀតដែលត្រូវបានចោទប្រកាន់ថា បានបាចខិតប័ណ្ណ នៅឆ្នាំ២០១១ ដោយមនុស្ស១០នាក់ទៀត ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ។[807]

នៅខែមីនា ឆ្នាំ២០១៣ ដោយមានការជួយពីអាជ្ញាធរថៃ នាយកដ្ឋានកណ្តាលសន្តិសុខ បានចាប់ខ្លួនខ្មែរក្រោម និងជនជាតិកម្ពុជាផ្សេងទៀត ចំនួនប្រាំពីរនាក់ នៅក្នុងប្រទេសថៃ រួមទាំង អ្នកដែលត្រូវបានចោទប្រកាន់ថា បានជាប់ពាក់ព័ន្ធនឹងការបាចខិតប័ណ្ណប្រឆាំងលោក ហ៊ុន សែន ដូចបានរៀបរាប់ខាងលើ។ ពួកគេត្រូវបានបញ្ជូនទៅកាន់ប្រទេសកម្ពុជា និងត្រូវបានឃុំខ្លួននៅក្នុងទីក្រុងភ្នំពេញ។[808] ពួកគេ និងមនុស្សប្រាំមួយនាក់ផ្សេងទៀត ដែលមិនត្រូវបានចាប់ខ្លួន ត្រូវបានចោទប្រកាន់ពីបទចូលរួមជាមួយរណសិរ្សរំដោះជាតិកម្ពុជា បង្កើតឡើងដោយបុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងប្រាំមួយនាក់នោះ ដែលរស់នៅក្នុងប្រទេសដាណឺម៉ាក (Denmark) និងដែលបានប្រកាសថា អង្គការរបស់គាត់មានបំណង "សង្គ្រោះ" កម្ពុជាចេញពីការ

---

806 ពីប្រភពដដែល Ibid.; "កម្ពុជា ៖ ដោះលែងបុគ្គលិកសិទ្ធិមនុស្ស" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ https://www.hrw.org/news/2011/07/14/cambodia-free-human-rights-worker.

807 ពីប្រភពដដែល Ibid.; តុលាការសាលាដំបូងខេត្តតាកែវ "ដីការសម្រេចឱ្យនៅក្រៅឃុំបណ្តោះអាសន្ន" (លេខ ១៧២/២០១១) ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ (ឯកសារក្នុងចំណោមឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ); "អ្នករត់ម៉ូតូឌុប មានទោសដោយសារការជួយបាចខិតប័ណ្ណ" *ខេមបូឌា ដេលី* ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១, ពីប្រភពដដែល Ibid.; "សមាគមព្រះសង្ឃពុទ្ធសាសនាខ្មែរក្រោមនៅទ្វីបអឺរ៉ុប" បង្ហោះផ្សាយដោយ Uoong Sok នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ http://www.khmerbuddhism.ca/forum/topics/association-moine-bouddhisme- khmer-du-kampuchea-krom-en-europe (ចូលមើល នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥); តុលាការសាលាដំបូងខេត្តតាកែវ "ដីការសម្រេចឱ្យនៅក្រៅឃុំបណ្តោះអាសន្ន" (លេខ ១៧២/២០១១) ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ (ឯកសារក្នុងចំណោមឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ), ឧត្តមក្រុមប្រឹក្សាជាតិខ្មែរក្រោម "សេចក្តីថ្លែងការណ៍នៃឧត្តមក្រុមប្រឹក្សាជាតិខ្មែរក្រោម" ខែមេសា ឆ្នាំ២០១០ (ឯកសារក្នុងចំណោមឯកសារអង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ), ពីប្រភពដដែលIbid.; "តុលាការខេត្តតាកែវ ផ្តន្ទាទោសមនុស្ស៥នាក់ ពីបទបានចែកចាយខិតប័ណ្ណ" *ខេមបូឌា ដេលី*, ថ្ងៃទី១ ខែកក្កដា ២០១១។

808 សាលាដំបូងរាជធានីភ្នំពេញ "សាលក្រម" (លេខ ២១ KB3Ngo), ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤ (ឯកសារក្នុងចំណោមឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ), *មានកំណត់ត្រារបស់អង្គការលីកាដូ PP033IAD13, ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៣* "ខ្មែរក្រោមពីរនាក់ត្រូវបានចោទប្រកាន់ពីបទកំពុងធ្វើការងារដើម្បីផ្តួលរំលំរដ្ឋាភិបាលកម្ពុជា" *Prey Nokor News*, ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៣, "ថៃផ្ទេរ "ភេរវករ"" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៨ មីនា ឆ្នាំ២០១៣ http://www.phnompenhpost.com/national/thais-hand-over-%E2%80%98terrorists%E2%80%99; "ភស្តុតាងមិនគ្រប់គ្រាន់ប្រឆាំងនឹងក្រុមដែលត្រូវចោទប្រកាន់ថា ជាភេរវករ (ម្នាក់ទៀត)" *ខេមបូឌា ដេលី*, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ http://sithi.org/temp.php?url=news_detail.php&mid=7108 (ចូលមើល នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១៣), រណសិរ្សរំដោះជាតិកម្ពុជា "ការប្តឹងឧទ្ធរណ៍ឲ្យដោះលែងព្រះសង្ឃ និងខ្មែរក្រោមបីអង្គ និង នាក់" ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣, រណសិរ្សរំដោះជាតិកម្ពុជា "សេចក្តីប្រកាសបន្ទាន់" ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៣ (ឯកសារក្នុងចំណោមឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ)។

*ដឹកនាំដោយ "ជនផ្តាច់ការ ហ៊ុន សែន"។*[809] *បន្ទាប់ពីលោក ហ៊ុន សែន បានចោទប្រកាន់ថា ជនសង្ស័យគឺជា "ជនឧទ្ទាមប្រដាប់អាវុធ" និង "គេរវករ" មក តុលាការក្រុងភ្នំពេញបានផ្តន្ទាទោសពួកគេ ក្រោយពីសវនាការអស់រយៈពេលមួយថ្ងៃ នៅខែមីនា ឆ្នាំ២០១៤ ពីបទរៀបចំ "ផែនការក្បត់" ប្រឆាំងនឹងរដ្ឋាភិបាល ទោះបីគ្មានភស្តុតាងរឹងមាំ សម្រាប់ធ្វើការចោទប្រកាន់ក៏ដោយ។ ផ្ទុយទៅវិញ មូលដ្ឋាននៃការចោទប្រកាន់ក្នុងករណីនេះ គឺការចែកចាយខិតប័ណ្ណ ដែលត្រូវបានចាត់ទុកថាជា "ការប្រឆាំងនឹងរដ្ឋាភិបាល"។*[810] *មនុស្ស ១៣ នាក់ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីប្រាំទៅប្រាំបួនឆ្នាំ។*[811]

## *លោក សុខ ផល និងការបញ្ជូនជនជាតិអ៊ុយហ្គ័រ* (Uighur)*ដែលស្វែងរកសិទ្ធិជ្រកកោន ត្រលប់ទៅប្រទេសចិនវិញដោយបង្ខំ*

*ចន្លោះខែឧសភា និងខែតុលា ឆ្នាំ២០០៩ ជនជាតិអ៊ុយហ្គ័រ* (Uighur) *ជាក្រុមតូចៗកាន់សាសនាឥស្លាមមកពីប្រទេសចិន បានមកដល់ប្រទេសកម្ពុជា ដើម្បីស្វែងរកសិទ្ធិជ្រកកោន និងឋានៈជាជនភៀសខ្លួន។*[812] *ពួកគេបានភៀសខ្លួនចេញពីការបង្ក្រាបយ៉ាងឃោរឃៅរបស់អាជ្ញាធរចិន លើភាពសកម្មរបស់ជនជាតិអ៊ុយហ្គ័រ នៅខេត្តស៊ីនជាំង* (Xinjiang) *ដែលជាខេត្តកំណើតរបស់ពួកគេ និងបានអះអាងថា ពួកគេនឹងរងនូវការធ្វើទុក្ខបុកម្នេញផ្នែកសាសនា និងនយោបាយយ៉ាងធ្ងន់ធ្ងរ ប្រសិនពួកគេវិលត្រលប់ទៅប្រទេសចិនវិញ។ ទោះជាយ៉ាងណា រដ្ឋាភិបាលកម្ពុជាបានទទួលរងសម្ពាធកាន់តែខ្លាំងឡើងៗពីសំណាក់រដ្ឋាភិបាលចិន ឱ្យបញ្ជូនពួកទាំងនោះត្រលប់ទៅវិញ។ នៅក្នុងបរិបទនេះ នៅថ្ងៃទី១៧ ធ្នូ ឆ្នាំ២០០៩ លោក ហ៊ុន សែន បានចុះហត្ថលេខាលើអនុក្រឹត្យមួយរបស់រដ្ឋាភិបាល ដើម្បីត្រួសត្រាយផ្លូវច្បាប់សម្រាប់ការបញ្ជូនជនភៀសខ្លួនត្រឡប់ទៅវិញ ដែលការធ្វើដូចនេះ គឺជាការបំពារបំពានលើកាតព្វកិច្ចជាអន្តរជាតិរបស់កម្ពុជា ក្នុងនាមជាភាគីនៃអនុសញ្ញាជនភៀសខ្លួនឆ្នាំ១៩៥១ ហើយអនុក្រឹត្យនេះ បានផ្តល់សិទ្ធិអំណាចឱ្យនាយកដ្ឋានអន្តោប្រវេសន៍នៃនាយកដ្ឋាន*

---

809 រណសិរ្សរំដោះជាតិកម្ពុជា "សេចក្តីថ្លែងការណ៍" និង "សេចក្តីប្រកាស ស្តីពី ការបង្កើតរណសិរ្សរំដោះជាតិកម្ពុជា" ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ (ឯកសារក្នុងចំណោមឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ)។

810 "កម្ពុជា ៖ លើកលែងករណី "រៀបចំផែនការក្បត់" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤ http://www.hrw.org/news/2014/04/09/cambodia-drop-treacherous-plotting-case.

811 សាលាដំបូងរាជធានីភ្នំពេញ "សាលក្រម" (លេខ ២១ KB3Ngo), ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤ (ឯកសារក្នុងចំណោមឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ)។

812 "កម្ពុជា ៖ តើមានអ្វីដែលនឹងកើតឡើងចំពោះអ្នកស្វែងរកសិទ្ធិជ្រកកោនអ៊ុយហ្គ័រ?" *Jesuit Refugee Service*, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ http://jrsusa.org/news_detail. cfm?TN =NEWS-20101217085047 (ចូលមើល នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១១)។

កណ្តាលសន្តិសុខ ដើរតួនាទីសំខាន់ក្នុងការប្រព្រឹត្តរំលងច្បាប់អន្តរជាតិស្តីពីការពារជនភៀសខ្លួនមួយនេះ។ នៅថ្ងៃដែលលោក ហ៊ុន សែន ចុះហត្ថលេខាលើអនុក្រឹត្យនោះ ជនស្វែងរកសិទ្ធិជ្រកកោនអ៊ុយហ្គ័រ ២០ នាក់ ត្រូវបានដាក់ឱ្យនៅក្នុងផ្ទះសុវត្ថិភាពមួយ ដែលគ្រប់គ្រងរួមគ្នាដោយអាជ្ញាធរកម្ពុជា និងឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន (UNHCR) ដែលអង្គការនេះ បានចេញលិខិតបញ្ជាក់ថា ពួកគេគឺជា "បុគ្គលដែលស្ថិតក្រោមកិច្ចការពាររបស់អង្គការ UNHCR និងរង់ចាំការកំណត់ឋានៈជាជនសុំសិទ្ធិជ្រកកោន"។ ប៉ុន្តែ នៅល្ងាចថ្ងៃទី១៨ ខែធ្នូ នគរបាលអន្តោប្រវេសន៍ប្រដាប់ដោយអាវុធ បានចូលចាប់ខ្លួនជនជាតិអ៊ុយហ្គ័រទាំង ២០ នាក់នោះ។ ពួកគេត្រូវបានបញ្ជូនតាមយន្តហោះចិនមួយចេញពីប្រទេសកម្ពុជាទាំងបង្ខំ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩។[813] សកម្មភាពនេះ គឺជាការរំលោភយ៉ាងជាក់ស្តែង លើសិទ្ធិរបស់ពួកគេ ក្រោមអនុសញ្ញាជនភៀសខ្លួន ប្រឆាំងនឹងការបញ្ជូនត្រលប់ដោយបង្ខំ ដែលមានន័យថា គេមិនអាចបញ្ជូនបុគ្គលណាម្នាក់ទៅកន្លែងណាមួយដែលជីវិត ឬសេរីភាពរបស់បុគ្គលនោះ ប្រឈមឬស្ថិតក្នុងគ្រោះថ្នាក់នោះទេ។[814]

## លោក សុខ ផល ពេលបោះឆ្នោតជាតិឆ្នាំ ២០១៣ និង ចាប់តាំងពីធ្វើជាអគ្គនាយកអន្តោប្រវេសន៍

ដូចគ្នានឹងមន្ត្រីនគរបាល យោធា និងកងរាជអាវុធហត្ថជាន់ខ្ពស់ផ្សេងទៀតដែរ លោក សុខ ផល បានធ្វើយុទ្ធនាការឱ្យគណបក្សប្រជាជនកម្ពុជា ក្នុងអំឡុងពេលឆ្ពោះទៅរកការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រខែកក្កដា ឆ្នាំ២០១៣ ក្នុងនាមគាត់ជាប្រធានក្រុម "ពង្រឹងមូលដ្ឋាន" របស់គណបក្សប្រជាជនកម្ពុជា នៅក្នុងស្រុកមួយ នៅខេត្តបាត់ដំបង។ ក្នុងចំណោមកិច្ចការផ្សេងៗទៀត គាត់ក៏បានធ្វើជាអធិបតីលើការចុះឈ្មោះសមាជិកថ្មីរបស់គណបក្សប្រជាជនកម្ពុជាផងដែរ។[815]

នៅខែមករា ឆ្នាំ២០១៤ លោក ហ៊ុន សែន បានរៀបចំដំឡើងឋានៈរបស់លោក សុខ ផល ឱ្យទៅជានាយ

---

[813] "បទវិភាគ ៖ នៅក្នុងទស្សនវិស័យស្តីពី ជនជាតិអ៊ុយហ្គ័រ" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ាយ វ៉ច្ឆ Human Rights Watch ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ http://www.hrw.org/news/2010/12/20/analysis-inside-perspective-uighurs.

[814] "លិខិតទៅកាន់លោកស្រី គ្លីនតុន ស្តីពី ការនិទេសជនសុំសិទ្ធិជ្រកកោនអ៊ុយហ្គ័រ របស់កម្ពុជា ត្រលប់ទៅកាន់ប្រទេសចិនវិញ" ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១០, លិខិតរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ http://www.hrw.org/news/2010/04/09/letter-secretary-clinton-cambodia-s-deportation-uighur-asylum-seekers-china.

[815] "គណបក្សប្រជាជន នៅស្រុកបាកាន បានទទួលសមាជិកថ្មី ៨៨៧ នាក់" ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/64070-2013-05-14-10-52-59.html (ចូលមើល នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៣)។

*ឧត្តមសេនីយ៍ផ្កាយមាស៤ពេញលេញ។*[816] *ការដំឡើងឋានៈនេះ គឺជាការផ្តើមតែងតាំងលោក សុខ ផល ឱ្យធ្វើជាអគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដែលត្រូវបានបង្កើតឡើងនៅខែមេសា ឆ្នាំ២០១៤ ដោយរួមបញ្ចូលគ្នានូវនាយកដ្ឋានអន្តោប្រវេសន៍ដែលមានស្រាប់ និងអង្គភាពនគរបាល ឬ អង្គភាពនៃក្រសួងមហាផ្ទៃមួយចំនួនទៀត ដើម្បីបង្កើតជាអង្គភាពទទួលបន្ទុកលើជនបរទេសអន្តោប្រវេសន៍ ជនបរទេសមិនមែនអន្តោប្រវេសន៍ និងជនភៀសខ្លួន ប៉ុន្តែមិនមែនទទួលបន្ទុកលើលិខិតឆ្លងដែន និងឯកសារអត្តសញ្ញាណផ្សេងទៀតឡើយ។ អគ្គនាយកដ្ឋាននេះ ត្រូវបានកំណត់ឱ្យនៅដាច់ដោយឡែកពីនគរបាលជាតិ ប៉ុន្តែស្ថិតក្រោមក្រសួងមហាផ្ទៃ។*[817] *ក្រោយពីទទួលតួនាទីថ្មី លោក សុខ ផល បានបោះបង់ចោលតួនាទីចាស់ ជាអគ្គស្នងការរងនគរបាលជាតិ និងប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ។*[818]

*ចាប់ពីចុងឆ្នាំ២០១៤ មក ជនស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាពីប្រទេសវៀតណាមបានមកដល់ប្រទេសកម្ពុជា ដោយឆ្លងកាត់តាមព្រំដែនចូលខេត្តរតនគិរី។ ពួកគេគឺជាក្រុមជនជាតិចារ៉ាយ និង ក្រុមជនជាតិភាគតិចតំបន់ភ្នំ ដែលភាគច្រើនគោរពគ្រីស្តសាសនា ក្នុងទម្រង់មួយចំនួន ដែលអាជ្ញាធរវៀតណាមចោទថា ជា*

---

[816] "នាយនគរបាលជាតិ ៦ រូប បានក្លាយជានាយឧត្តមសេនីយ៍ផ្កាយមាស ៤" ( s., s Cflrn Cff., ), ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/80347-2014-02-05-14-21-04.html (ចូលមើល នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤); "នាយឧត្តមសេនីយ៍ផ្កាយមាសបួនចំនួនប្រាំមួយនាក់បន្ថែមទៀត" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៦ កុម្ភៈ ឆ្នាំ២០១៤, http://www.phnompenhpost.com/national/six-more-four-star- generals (មើលនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៤)។

[817] "សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លើការបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម" ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤ http://www.dap- news.com/2011-06-14-02-39-55/84120-2014-04-02-07-49-59.html (ចូលមើល នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៤), "ពិធីបង្កើតអគ្គនាយកដ្ឋានពីរ និងតែងតាំងអគ្គនាយក និងប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា" ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/85236-2014-04-23-10-24-47.html (ទទួលបាន ឬបានអាន នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៤), "អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ស្បថចូលកាន់តំណែង" *ខេមបូឌា ដេលី*, ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/heads-of-new-departments-of-immigration-identification-sworn-in-57344/ (ចូលមើល នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤), "ឯកឧត្តម ឧត្តមសេនីយ៍ឯក ឌី វិជ្ជា ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ" ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ http://edition.bayontv.com.kh/bayontv-national-news/30108-2014-08-08-11-30-04.html (ចូលមើល នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤)។

[818] "សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លើការបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម" ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤ http://www.dap- news.com/2011-06-14-02-39-55/84120-2014-04-02-07-49-59.html (មើល នៅថ្ងៃទី៥ មេសា ឆ្នាំ២០១៤), "ពិធីបង្កើតអគ្គនាយកដ្ឋានពីរ និងតែងតាំងអគ្គនាយក និងប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា" (bl ns s t Cfl s s .,, s Cflt ), ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤, http://www.dap-news.com/2011-06-14-02-39-55/85236-2014-04-23-10-24-47.html (ចូលមើល នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៤), "អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ស្បថចូលកាន់តំណែង" *ខេមបូឌា ដេលី*, ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/heads-of-new-departments-of-immigration-identification-sworn-in-57344/ (ចូលមើល នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤), ), "ឯកឧត្តម ឧត្តមសេនីយ៍ឯក ឌី វិជ្ជា ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ" (t: 8 8 st: Cflst Cflsss.,), ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ http://edition.bayontv.com.kh/bayontv-national-news/30108-2014-08-08-11-30-04.html (ចូលមើល នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤)។

ទម្រង់នៃសាសនា "តាមផ្លូវអាក្រក់"។ នៅខែធ្នូ ឆ្នាំ២០១៤ នាយកដ្ឋានជនភៀសខ្លួននៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានអនុញ្ញាតឱ្យជនស្វែងរកសិទ្ធិជ្រកកោនជនជាតិចារ៉ាយចំនួន ១៣ នាក់ បានចុះឈ្មោះជាជនភៀសខ្លួន នៅក្នុងទីក្រុងភ្នំពេញ ហើយក្រោយមក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានចេញសេចក្តីប្រកាសទទួលស្គាល់ពួកគេថា ជាជនភៀសខ្លួន។ ប៉ុន្តែដំបូងឡើយ នាយកដ្ឋានជនភៀសខ្លួនបានបដិសេធមិនអនុញ្ញាតឱ្យជនស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាណាម្នាក់ ក្នុងចំណោមអ្នកទាំងជាង ៣០០ នាក់ ដែលបានមកដល់កម្ពុជា គិតចាប់ពីចុងឆ្នាំ២០១៤មក សូម្បីតែចុះឈ្មោះ ដើម្បីសុំការកំណត់ថា តើពួកគេមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាជនភៀសខ្លួនឬទេ។ ក្នុងអំឡុងឆ្នាំ ២០១៤-២០១៥ មានជនស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាយ៉ាងហោចណាស់ ៥៤ នាក់ ត្រូវបានបញ្ជូនដោយបង្ខំភ្លាមៗ ចេញពីខេត្តរតនគិរី ទៅប្រទេសវៀតណាមវិញ។ អ្នកដែលបន្តស្ថិតនៅក្នុងប្រទេសកម្ពុជា រស់នៅដោយភាពភ័យខ្លាច ចំពោះការបញ្ជូនត្រលប់ទៅវិញស្រដៀងគ្នានេះ ដូចដែលលោក សុខ ផល បានគំរាមនៅក្នុងសេចក្តីថ្លែងការណ៍មួយ ដែលចាត់ទុកជនម៉ុងតាញ៉ាទាំងអស់នោះថា ជា"ជនអន្តោប្រវេសន៍វៀតណាមខុសច្បាប់" ធម្មតាដែលត្រូវតែចាប់ខ្លួន អនុលោមតាមគោលនយោបាយនិរទេសជនបែបនោះ លើកលែងតែជន១៣ នាក់ប៉ុណ្ណោះ ដែលត្រូវបានទទួលស្គាល់ជាជនភៀសខ្លួន។[819]

វិធីសាស្ត្រដោះស្រាយរបស់លោក សុខ ផល ចំពោះបញ្ហាជនជាតិម៉ុងតាញ៉ា ទំនងជាមានគោលបំណងបំពេញតាមគោលនយោបាយផ្ទៃក្នុងរបស់គណបក្សប្រជាជនកម្ពុជា ដែលចាត់ទុកកិច្ចខិតខំប្រឹងប្រែងរបស់ជនជាតិម៉ុងតាញ៉ា ក្នុងការស្វែងរកឋានៈជាជនភៀសខ្លួន និងសិទ្ធិជ្រកកោននៅកម្ពុជា ថាជា "កលល្បិចរបស់ក្រុមអមិត្ត រាប់បញ្ចូលទាំងឧត្តមស្នងការនៃអង្គការសហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន" ផងដែរ ដែលសំដៅបង្កភាពល្អក់កករចំពោះទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ យោងតាមគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា "កលល្បិច" នេះ គឺជាអ្វីដែលប្រទេសកម្ពុជា និងប្រទេសវៀតណាម ត្រូវតែធ្វើសហប្រតិបត្តិការជាមួយគ្នា ដើម្បី "ទប់ស្កាត់ និងកម្ទេច" ជាពិសេស នៅពេលដែលការ

---

[819] អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ច *ការធ្វើទុក្ខបុកម្នេញសាសនា "អាក្រក់"៖ ការរំលោភបំពានលើជនម៉ុងតាញ៉ានៅក្នុងប្រទេសវៀតណាម* ថ្ងៃទី២៦ មិថុនា ឆ្នាំ២០១៥ https://www.hrw.org/report/2015/06/26/persecuting-evil-way-religion/abuses-against-montagnards-vietnam; "អគ្គនាយកអន្តោប្រវេសន៍ ចោទប្រកាន់អង្គការសហប្រជាជាតិថា កំពុងរត់ពន្ធអ្នកស្វែងរកសិទ្ធិជ្រកកោន" *ខេមបូឌា ដេលី* ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ https://www.cambodiadaily.com/news/immigration-chief-accuses-un-of-smuggling-asylum-seekers-82947/ (ចូលមើល នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៥), "សមត្ថកិច្ចត្រៀមបញ្ជូនជនអន្តោប្រវេសន៍ជាច្រើន ត្រលប់ទៅប្រទេសរបស់ពួកគេវិញ" ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ http://kampucheathmey.com/kpt/?cat=3 (ចូលមើល នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥)។

បង្កបញ្ហាដោយចេតនានេះ រួមមាន ផែនការសម្ងាត់ ដើម្បី "បំផ្លាញបដិវត្តន៍វៀតណាម"។ ក្នុងការអនុវត្តជាក់ស្តែង នេះមានន័យថា គោលនយោបាយនេះតម្រូវឱ្យកងកម្លាំងសន្តិសុខនៃរដ្ឋាភិបាលទាំងពីរ ត្រូវធ្វើការងារជាមួយគ្នា ដើម្បីបញ្ឈប់ជនជាតិម៉ុងតាញ៉ា មិនឱ្យឆ្លងកាត់ព្រំដែនចូលក្នុងប្រទេសកម្ពុជា ហើយចំពោះជនជាតិម៉ុងតាញ៉ាដែលអាចឆ្លងកាត់ព្រំដែនរួច កងកម្លាំងសន្តិសុខខាងកម្ពុជាត្រូវធានាថា ជនទាំងនោះនឹងត្រូវបានបញ្ជូនទៅកាន់ប្រទេសទីបី ឬ ត្រូវបានចាប់ខ្លួន និងបញ្ជូនត្រលប់ទៅប្រទេសវៀតណាមវិញ។[820]

របាយការណ៍បានបង្ហាញថា ជនស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ា ដែលកំពុងស្ថិតនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងឆមាសទីពីរ ឆ្នាំ២០១៥ មានចំនួនជាង ២០០ នាក់។[821] ចាប់ពីខែតុលា ឆ្នាំ២០១៥មក ពួកគេមួយចំនួនបានចាប់ផ្តើមវិលត្រលប់ទៅប្រទេសវៀតណាមវិញ ដោយមានការអមដំណើរពីមន្ត្រីរដ្ឋាភិបាលកម្ពុជា និងមន្ត្រីនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) រីឯអ្នកសេសសល់ដែលបន្តរស់នៅកម្ពុជា បានត្អូញត្អែរអំពីស្ថានភាពរស់នៅដ៏លំបាក។[822]

នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ រដ្ឋាភិបាលកម្ពុជាបានប្រកាសថា ជនជាតិម៉ុងតាញ៉ាទាំង ១៣ នាក់ដែលត្រូវបានទទួលស្គាល់ជាជនភៀសខ្លួន  នឹងត្រូវបញ្ជូនទៅតាំងទីលំនៅថ្មី នៅប្រទេសទីបីណាមួយ ហើយបានសន្យាថា ខ្លួននឹងធ្វើការងារ "ប៉ាន់ប្រមាណ វាយតម្លៃ និងសម្ភាស" ជនជាតិម៉ុងតាញ៉ា ១៧១ នាក់ ផ្សេងទៀត។[823] អ្នកនាំពាក្យរបស់អង្គការ UNHCR ដែលមានអាណត្តិជួយដល់រដ្ឋាភិបាលកម្ពុជាលើកិច្ចការនេះបានចាត់ទុកសេចក្តីប្រកាសនោះថាជា កិច្ចព្រមព្រៀងរបស់រដ្ឋាភិបាល "ក្នុងការបន្តការងារចុះឈ្មោះ និងបន្តដំណើរការ សម្រាប់ក្រុមជនស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាដែលមានស្រាប់ ខណៈអង្គការ UNHCR បានយល់ព្រមបន្តស្វែងរកដំណោះស្រាយសមស្រប សម្រាប់បុគ្គលទាំងនេះ" ដោយបាននិយាយថា " ដំណោះស្រាយទាំងនេះ អាចជាការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត ឬ ការតាំងទីលំនៅជាថ្មីនៅក្នុង

---

820 គណបក្សប្រជាជនកម្ពុជា *ប្រវត្តិនៃការតស៊ូ* ទំព័រ ២៦០, ២៦៧-២៦៨, ២៧៥-២៧៦។

821 "អង្គការសហប្រជាជាតិ ប្រកាសអាសន្នលើការគំរាមបញ្ជូនត្រលប់ជនភៀសខ្លួន ១៣ នាក់" *ខេមបូឌា ដេលី* ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ https://www.cambodiadaily.com/news/un-raises-alarm-over-threat-to-return-13-refugees-98247/ (ចូលមើល នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥)។

822 "ជីវិតវេទនាណាស់ ជួយពួកយើងផង ៖ ជនភៀសខ្លួនម៉ុងតាញ៉ា" *Khmer Times*, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ http://www.khmertimeskh.com/news/19259/life-miserable--help-us--montagnard-refugees/ (ទទួលបាន ឬ បានអាន នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥)។

823 "ជនជាតិម៉ុងតាញ៉ា ១៣ នាក់ ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា នឹងត្រូវបញ្ជូនទៅប្រទេសទីបី" (sCflt bl Cfl s s s) ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ http://www.dap-news.com/2011-06- 14-02-39-55/107293-2016-01-20-12-55-53.html (ចូលមើល នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦)។

*ប្រទេសទីបី" ដែលនេះគឺជាការរៀបចំមួយ ប្រឆាំងនឹងការបញ្ជូនត្រលប់ដោយបង្ខំ ប៉ុន្តែក៏មិនបាននិយាយអំពីលទ្ធភាពតាំងទីលំនៅជាថ្មីនៅក្នុងប្រទេសកម្ពុជាផងដែរ។*[824] *ទោះបីជាយ៉ាងណា នៅដើមខែកុម្ភៈ ឆ្នាំ ២០១៦ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានប្រកាសថា ភាគច្រើននៃអ្នកសុំសិទ្ធិជ្រកកោនទាំងនោះ នឹងត្រូវនិរទេសចេញពីកម្ពុជា រីឯលោក សុខ ផល នៅពេលនោះបាននិយាយថា កិច្ចដំណើរការលើពាក្យអះអាងសុំសិទ្ធិជ្រកកោន មិនទាន់បានចាប់ផ្តើមនៅឡើយទេ។*[825]

*ជនទាំង១៣នាក់ ដែលត្រូវបានទទួលស្គាល់ជាជនភៀសខ្លួន បានចាកចេញពីកម្ពុជា នៅថ្ងៃទី២៧ ខែឧសភា ដែលពេលនោះ អង្គការ* UNHCR *បាននិយាយថា នៅទីបំផុតជនម៉ុងតាញ៉ា ១៧១នាក់ បានឆ្លងកាត់ដំណើរការ "ចុះឈ្មោះ និងកំណត់ឋានៈជាជនភៀសខ្លួន ដោយនាយកដ្ឋានជនភៀសខ្លួនរបស់រដ្ឋាភិបាល"។*[826] *ទោះបីជាយ៉ាងណា នៅដើមខែមិថុនា ឆ្នាំ២០១៦ មានសេចក្តីរាយការណ៍ថា ជនជាតិម៉ុងតាញ៉ា៣០នាក់ បានវិលត្រលប់ទៅប្រទេសវៀតណាមវិញ "ដោយស្ម័គ្រចិត្ត"។ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ រដ្ឋាភិបាលកម្ពុជាបានរៀបចំឱ្យនគរបាលវៀតណាមមួយក្រុម និងមន្ត្រីផ្សេងទៀត អមដំណើរមន្ត្រីរបស់ខ្លួន ចុះជួបជនស្វែងរកសិទ្ធិជ្រកកោនមួយចំនួន នៅក្នុងទីក្រុងភ្នំពេញ ដើម្បីបញ្ចុះបញ្ចូលពួកគេឱ្យវិលត្រលប់ទៅប្រទេសវៀតណាមវិញ ដែលការធ្វើបែបនេះ ផ្ទុយនឹងបទដ្ឋានអន្តរជាតិ ដែលចែងថា អ្នកស្វែងរកសិទ្ធិជ្រកកោនមិនគួរតម្រូវឱ្យជួបជាមួយអាជ្ញាធរនៃប្រទេស ដែលពួកគេបានភៀសខ្លួនចេញមកនោះឡើយ។*[827] *នៅពាក់កណ្តាលខែកក្កដា ឆ្នាំ២០១៦ ជនជាតិម៉ុងតាញ៉ា ១៦នាក់ទៀត បានវិលត្រលប់ទៅប្រទេសវៀតណាមវិញក្រោមការត្រួតពិនិត្យរបស់អង្គការ* UNHCR*។ លោក សុខ ផល បានសាទរចំពោះការចាកចេញរបស់ពួកគេ ប៉ុន្តែមិនបានបង្ហាញអំពីស្ថានភាពនៃកិច្ចដំណើរការរបស់រដ្ឋាភិបាល ចំពោះករណីជនជាតិម៉ុងតាញ៉ាផ្សេងទៀត ដែលនៅតែស្ថិតក្នុងហានិភ័យនៃការបញ្ជូនត្រលប់ទៅវិញដោយបង្ខំនោះឡើយ។*[828]

---

[824] "រដ្ឋាភិបាល អង្គការ UNHCR ត្រូវទទួលខុសត្រូវជាមួយគ្នា ចំពោះកិច្ចការជនភៀសខ្លួន" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ http://www.phnompenhpost.com/ national/govt-unhcr-share-refugee-responsibilities (ចូលមើល នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៦)។

[825] "ជនជាតិម៉ុងតាញ៉ា "ដែលត្រូវដំណើរការ"" ***Phnom Penh Post***, ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ http://www.phnompenhpost.com/national/montagnards-be-processed (ចូលមើល នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៦)។

[826] "ជនភៀសខ្លួនម៉ុងតាញ៉ា រៀបចំចេញដំណើរទៅប្រទេសហ្វីលីពីន" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ http://www.phnompenhpost.com/national/montagnard-refugees-set-their-course-philippines (ចូលមើល នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៦)។

[827] "នគរបាលវៀតណាម ចុះជួបជាមួយក្រុមជនម៉ុងតាញ៉ា" *ខេមបូឌា ដេលី* ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ https://www.cambodiadaily.com/news/vietnamese-police-pay-a-visit-to-montagnards-113833/ (ចូលមើល នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦)។

[828] "ដោយគ្មានសង្ឃឹមថានឹងទទួលបានសិទ្ធិជ្រកកោន ជនម៉ុងតាញ៉ា ១៦ នាក់ ក៏បានវិលត្រលប់ទៅប្រទេសវៀតណាមវិញ" *ខេមបូឌា ដេលី* ថ្ងៃទី១៤ ខែ

*នៅចុងខែមីនា ឆ្នាំ២០១៧ ជនស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាចំនួនជិត ៩០ នាក់ បានភៀសខ្លួនពីកម្ពុជាទៅ ប្រទេសថៃ បន្ទាប់ពីទទួលបានដំណឹងថា ពាក្យសុំឋានៈជាជនភៀសខ្លួនរបស់ពួកគេ ត្រូវបានបដិសេធ។ បើតាមមន្ត្រីម្នាក់នៃអង្គការក្រៅរដ្ឋាភិបាលមួយដែលអាចទុកចិត្តបាន ក្នុងចំណោមជនទាំងនោះ មានករណីជនជាតិម៉ុងតាញ៉ាជាច្រើននាក់ ហើយនិងករណីជនស្វែងរកសិទ្ធិជ្រកកោនផ្សេងទៀតដែលអាជ្ញាធរអន្តោប្រវេសន៍របស់លោក សុខ ផល បន្តបដិសេធមិនផ្តល់ឋានៈជាជនភៀសខ្លួន គឺជា"ករណីដែលមានមូលដ្ឋានរឹងមាំ" ក្នុងការទទួលបានឋានៈជាជនភៀសខ្លួន។ មន្ត្រីអន្តោប្រវេសន៍ម្នាក់បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា ចាប់តាំងពីពេលដែលរដ្ឋាភិបាលបានផ្តល់ឋានៈដល់ជនជាតិចារ៉ាយមកពីប្រទេសវៀតណាមចំនួន ១២៣ នាក់ក្នុងឆ្នាំ២០១៥មក មានជនស្វែងរកសិទ្ធិជ្រកកោនតែ៣នាក់បន្ថែមទៀតប៉ុណ្ណោះ ដែលទទួលបានការទទួលស្គាល់ថា ជាជនភៀសខ្លួន។ ត្រឹមដើមខែមេសា ឆ្នាំ២០១៧ មានជនជាតិម៉ុងតាញ៉ា៩៦នាក់ បន្តរស់នៅក្នុងទីក្រុងភ្នំពេញ ក្នុងរបៀបដូចត្រូវឃុំខ្លួនក្នុងផ្ទះយ៉ាងតឹងរឹង។ ពួកគេប្រឈមការដែលអាចនឹងត្រូវបានបញ្ជូនខ្លួនត្រលប់ទៅប្រទេសវៀតណាមវិញដោយបង្ខំ ក្នុងនាមជា "បុគ្គលដែលគ្មានសិទ្ធិរស់នៅក្នុងប្រទេសកម្ពុជា" ទោះបីជាពួកគេខ្លះ នៅមានលទ្ធភាពប្តឹងឧទ្ធរណ៍ ជំទាស់នឹងសេចក្តីសម្រេចដំបូងរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្តី។*[829] *ស្របពេលគ្នានោះ លោក សុខ ផល បានបញ្ជាមន្ត្រីអន្តោប្រវេសន៍ ឱ្យពង្រឹងការត្រួតពិនិត្យព្រំដែនបន្ថែមទៀត តាមរយៈការបញ្ជូនអ្នកដែលចូលក្នុងប្រទេសកម្ពុជាដោយខុសច្បាប់ត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេវិញ ពោលគឺអ្នកដែលគ្មានឯកសារត្រឹមត្រូវតែត្រូវបានបណ្តោយឱ្យចូលមកក្នុងប្រទេសកម្ពុជា ដែលនេះគឺជាជំហរមួយ ហាក់ហាមឃាត់ជនស្វែងរកសិទ្ធិជ្រកកោនទាំងឡាយមិនឱ្យចូលទឹកដីកម្ពុជា និងជាការសន្យាថា នឹងបញ្ជូនពួកគេ ឱ្យត្រលប់ទៅប្រទេសកំណើតវិញភ្លាមៗដោយបង្ខំ។*[830]

---

កក្កដា ឆ្នាំ២០១៦ https://www.cambodiadaily.com/news/with-asylum-hope-over-16-montagnards-return-to-vietnam-115421/ (មើល នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦)។

[829] "ជនម៉ុងតាញ៉ាភៀសខ្លួនទៅកាន់ប្រទេសថៃ ដោយសារភ័យខ្លាចចំពោះការវិលត្រលប់ទៅរកការធ្វើទុក្ខបុកម្នេញវិញនៅក្នុងប្រទេសវៀតណាម" *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៧http://www.phnompenhpost.com/national/montagnards-flee-thailand-fearing-return-persecution vietnam (ចូលមើល នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧), "ជនភៀសខ្លួនម៉ុងតាញ៉ាស្វែងរកកន្លែងជ្រកកោនមានសុវត្ថិភាព នៅប្រទេសថៃ" *ខេមបូឌា ដេលី* ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧ https://www.cambodiadaily.com/news/montagnard-refugees-seek-thai-safe-haven-127477/ (ចូមើលនៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៧), "គ្រួសារអ្នកស្វែងរកសិទ្ធិជ្រកកោន កំពុងរង់ចាំការនិរទេសចេញ" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៦ ខែមេសា ឆ្នា២០១៧ http://www.phnompenhpost.com/national/asylum-seeker-family-awaiting-deportation (ចូលមើល នៅថ្ងៃទី៧ ខែ មេសា ឆ្នាំ២០១៧)។

[830] "នាយឧត្តមសេនីយ៍ សុខ ផល ប្រាប់នគរបាលអន្តោប្រវេសន៍ តាមព្រំដែន ឲ្យចាប់បញ្ជូនជនបរទេស ដែលមកខុសច្បាប់ ត្រឡប់ទៅវិញ យ៉ាងដាច់ខាត" ថ្ងៃទី៣ មេសា ឆ្នាំ២០១៧ http://www.freshnewsasia.com/index.php/en/localnews/51391-2017-04-03-07-22-31.html (ចូលមើល នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៧)។

គិតត្រឹមដើមខែតុលា ឆ្នាំ២០១៧ មានជនជាតិម៉ុងតាញ៉ាដែលបានមកប្រទេសកម្ពុជាដើម្បីស្វែងរកសិទ្ធិជ្រកកោន ចាប់ពីចុងឆ្នាំ២០១៤មក តែ ២០ នាក់ប៉ុណ្ណោះ ដែលទទួលបានឋានៈជាជនភៀសខ្លួន ទោះបីពួកគេជាច្រើននាក់ទៀត ត្រូវបានអង្គការ UNHCR និងអ្នកជំនាញផ្នែកជនភៀសខ្លួននៃអង្គការមិនមែនរដ្ឋាភិបាល ចាត់ទុកថា មានលក្ខណសម្បត្តិដើម្បីទទួលបានឋានៈនេះក៏ដោយ។ ពួកគេទាំងនេះ រាប់បញ្ចូលទាំងជនជាតិម៉ុងតាញ៉ា ២៣នាក់ ដែលបន្តនៅក្នុងកម្ពុជា និងដែលត្រូវបានលោក សុខ ផល ប្រកាសថា នឹងត្រូវបានបញ្ជូនត្រលប់ទៅប្រទេសវៀតណាមវិញផងនោះ ដោយគាត់បាននិយាយថា នៅទីនោះ ពួកគេនឹង "មិនប្រឈមមុខនឹងបញ្ហា" ឡើយ ប៉ុន្តែគាត់បានទទួលស្គាល់ថា ពួកគេប្រហែលជាអាចជាប់ពន្ធនាគារ។[831]

លើវិស័យនយោបាយក្នុងប្រទេសនៅពេលនោះវិញ លោក សុខ ផល បានក្លាយជាផ្នែកមួយនៃការបង្ក្រាបរបស់រដ្ឋាភិបាលកាន់តែខ្លាំងលើក្រុមប្រឆាំង ក្នុងអំឡុងឆមាសទីពីរ ឆ្នាំ២០១៥ ដែលឈានដល់ការចេញដីកាចាប់ខ្លួនលោក សម រង្ស៊ី នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ខណៈលោក សម រង្ស៊ី កំពុងនៅក្រៅប្រទេសរួចទៅហើយនោះ។ ដីកានេះ បានផ្តល់អំណាចដល់ការអនុវត្តការផ្តន្ទាទោសដាក់ពន្ធនាគារលោក សម រង្ស៊ី ដែលត្រូវបានសម្រេចកាលពីមុនមក គឺនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ ដែលកាលណោះ គាត់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ក្រោមបទញុះញង់ឱ្យមានការរើសអើង ដែលជាបទចោទមានចរិតនយោបាយ។[832] នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៥ លោក សុខ ផល មានឈ្មោះនៅក្នុងគណៈកម្មាធិការរបស់ក្រសួងមហាផ្ទៃ ដែលមានភារកិច្ចចាប់ខ្លួនលោក សម រង្ស៊ី នៅពេលដែលអាចធ្វើទៅបាន។[833]

លោក សុខ ផល បានផ្តល់ការគាំទ្រយ៉ាងពេញទំហឹង ពីក្រោយការកម្ទេចគណបក្សសង្គ្រោះជាតិ ពីឆាកនយោបាយកម្ពុជា។ ក្រោយពេលចាប់ខ្លួនលោក កឹម សុខា នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧ លោក សុខ ផល និងនគរបាលអន្តោប្រវេសន៍ទាំងអស់បានថ្កោលទោស "អំពើក្បត់ជាតិ" របស់មេដឹកនាំគណបក្សសង្គ្រោះ

[831] រដ្ឋាភិបាលមានបំណងនិរទេសជនសុំសិទ្ធិជ្រកកោន ចេញ ទោះបីជាមានការព្រមានក៏ដោយ ថ្ងៃព្រហស្បតិ៍ ទី៥ ខែតុលា ឆ្នាំ ២០១៧។

[832] សាលាដំបូងរាជធានីភ្នំពេញ "សាលក្រមលេខ ៣២ 'Ch'," ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១, "កម្ពុជា ៖ លើកលែងករណីប្រឆាំងនឹងប្រធានគណបក្សប្រឆាំង" ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែន រ៉ាយ វ៉ច្ឆ https://www.hrw.org/news/2015/11/13/cambodia-drop-case-against-opposition-leader.

[833] "រាជរដ្ឋាភិបាលសម្រេចបង្កើតគណៈកម្មាធិការមួយ ដើម្បីអនុវត្តដីការចាប់ខ្លួនលោក សម រង្ស៊ី" ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ http://www.dap-news.com/2011-06-14-02-39-55/102630-2015-11-16-02-29-44.html (ចូលមើល នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥)។

ជាតិ និងបានសាទរចំពោះការឃុំខ្លួនគាត់ដើម្បីផ្តន្ទាទោស។[834] នៅថ្ងៃទី១៩ ខែតុលា លោក សុខ ផល បាន កោះប្រជុំមួយជាមួយមន្ត្រីអន្តោប្រវេសន៍ជាន់ខ្ពស់ និងមន្ត្រីអន្តោប្រវេសន៍ផ្សេងទៀត ដែលក្នុងនោះ គាត់ បានថ្កោលទោស "គម្រោងការបដិវត្តពណ៌...បង្កើតឡើងដោយក្រុមគណបក្សប្រឆាំង" តាម "ការណែនាំ និង ការបញ្ជារបស់មហាអំណាចអាមេរិក"។ លោក សុខ ផល បានណែនាំមន្ត្រីក្រោមបង្គាប់របស់គាត់ ឱ្យរាយ ការណ៍អំពីសកម្មភាពបែបនេះ ដែលពួកគេសង្កេតឃើញនៅពេលបំពេញការងារ។[835] ពីរថ្ងៃក្រោយមក គាត់បានចេញសេចក្តីថ្លែងការណ៍មួយដោយ "តាំងនាមឱ្យកងកម្លាំងនគរបាលអន្តោប្រវេសន៍" ថ្កោលទោស លោក សម រង្ស៊ី ថា ជាជនក្បត់ជាតិ ជាមួយលោក កឹម សុខា និងជាមួយជនផ្សេងទៀតថាក្បត់ "ឆ្កួតនឹង អំណាច" ដែល "មិនខ្វល់អំពីផលប្រយោជន៍របស់ប្រទេសជាតិទាល់តែសោះ"។ គាត់បានប្រកាសបញ្ជាក់គាំ ទ្រចំពោះវិធានការទាំងឡាយដែលបានអនុវត្តរួចហើយប្រឆាំងនឹងពួកគេ និងបានបញ្ជាក់ថា នគរបាល អន្តោប្រវេសន៍ត្រៀមខ្លួនរួចហើយ ក្នុងការ "បំផ្លាញ និងកម្ទេច" ពួកគេ។[836] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ លោក សុខ ផល ក្នុងនាមជាមេដឹកនាំនគរបាលអន្តោប្រវេសន៍ និងតាំងនាមឱ្យមន្ត្រីទាំងអស់នៃអគ្គនាយក ដ្ឋានអន្តោប្រវេសន៍ បានថ្លែងគាំទ្រទាំងស្រុងចំពោះសាលដីរបស់តុលាការកំពូល ដែលសម្រេចរំលាយគណ បក្សសង្គ្រោះជាតិ ក្រោមមូលហេតុថា បានចូលរួមក្នុង "អំពើក្បត់ជាតិ" ដែលមិនអាចអត់ឱនឱ្យបាន និងគាំ ទ្រចំពោះការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យចាត់វិធានការជាមុនបន្ថែមទៀត ប្រឆាំងផែនការធ្វើ បដិវត្តពណ៌ និងប្រឆាំងអ្នកនយោបាយដែលលោកចោទថា "បម្រើផលប្រយោជន៍បរទេស"។[837]

## XI. នាយឧត្តមសេនីយ៍ផ្កាយមាស៤ ម៉ក់ ជីតូ អគ្គស្នងការរងនគរបាលជាតិ

លោក ម៉ក់ ជីតូ ដែលមានថ្ងៃខែឆ្នាំកំណើតផ្លូវការនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៦២ ត្រូវបានគេរាយការណ៍ថា ជា ប្រធានផ្នែកម្នាក់នៃនាយកដ្ឋានការពារសន្តិសុខនយោបាយមួយរបស់ក្រសួងមហាផ្ទៃ នៅក្នុងរបបសាធារណ រដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា។[838] ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស លោក ម៉ក់ ជីតូ ត្រូវបាន

---

[834] នាយឧត្តមសេនីយ៍សុខ ផល និងនគរបាលអន្តោប្រវេសន៍ទាំងអស់ថ្កោលទោសទង្វើក្បត់ជាតិរបស់លោកកឹម សុខា ហើយគាំទ្រចំពោះការចាប់ខ្លួន។

[835] នាយឧត្តមសេនីយ៍សុខផល ដឹកនាំប្រជុំផ្សព្វផ្សាយពីឧបាយកល និងផែនការបដិវត្តពណ៌របស់ក្រុមក្បត់ជាតិ។

[836] កងកម្លាំងនគរបាលអន្តោប្រវេសន្ត៍ ប្រកាសថ្កោលទោសសម្តីជនក្បត់ជាតិសមរង្ស៊ី ដែលញុះញង់ឲ្យកងកម្លាំងប្រដាប់អាវុធប្រឆាំងរដ្ឋាភិបាល។

[837] នាយឧត្តមសេនីយ៍ សុខ ផល ប្រកាសគាំទ្រពេញទំហឹងចំពោះការរំលាយគណបក្សសង្គ្រោះជាតិ និងគាំទ្រអនុសាសន៍សម្តេចតេជោហ៊ុនសែន។

[838] បញ្ជីឈ្មោះអ្នកចុះបោះឆ្នោតបណ្តោះអាសន្នឆ្នាំ២០១៧ ឯកសារ ០៦-៧៩០-៥៥៨, អង្គការ Amnesty International, មានកំណត់ត្រា ដាក់ចំណងជើង

*គេរាយការណ៍ថា បានបម្រើការក្នុងនាយកដ្ឋានប្រឆាំងភេរវកម្មនៃក្រសួងបង្កើតថ្មី ដែលអតីតជានាយកដ្ឋានការពារសន្តិសុខនយោបាយ ១ នៃក្រសួងមហាផ្ទៃ។*[839] *គាត់បានដើរតួនាទីសំខាន់នៅក្នុងក្រុមអា* (A-Teams) *ដោយជួយដឹកនាំក្រុមទាំងនេះ ជាពិសេសនៅក្នុងតំបន់ទីក្រុងភ្នំពេញ។*[840] *អតីតមន្ត្រីនគរបាលជាច្រើននាក់បានចោទប្រកាន់ លោក ម៉ក់ ជីតូ ថា បានជាប់ពាក់ព័ន្ធនៅក្នុងអំពើឃាតកម្មនានា ក្នុងនោះមានឃាតកម្មនយោបាយ អំពើចាប់ជម្រិត ការធ្វើទារុណកម្ម និងការរំលោភបំពានផ្សេងៗទៀត។*[841]

## *លោក ម៉ក់ ជីតូ ក្រោយសម័យអ៊ុនតាក់ ចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០១២*

*បន្ទាប់ពីការបោះឆ្នោតខែឧសភា ឆ្នាំ១៩៩៣ និងការបង្កើតរដ្ឋាភិបាលចម្រុះ រវាងគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជាមក លោក ម៉ក់ ជីតូ បានក្លាយជាប្រធានការិយាល័យនគរបាលព្រហ្មទណ្ឌនៃស្នងការដ្ឋាននគរបាលក្រុងភ្នំពេញ។ នៅក្នុងតួនាទីនេះ គាត់បានសច្ចាចាត់ "វិធានការខ្លាំងក្លា" ប្រឆាំង "សកម្មភាពវិទ្ធង្សនា" នានានៅក្នុងរាជធានី ដោយពឹងផ្អែកលើមន្ត្រីនគរបាលដែលមានឯកសណ្ឋាន និងមន្ត្រីនគរបាលសម្ងាត់ នៅក្នុងការធ្វើប្រតិបត្តិការទាំងនោះ។*[842] *នោះ គឺជារយៈពេលនៃឃាតកម្មនយោបាយជាបន្តបន្ទាប់ ជាពិសេស លើអ្នកសារព័ត៌មានរិះគន់រដ្ឋាភិបាល ដែលលោក ម៉ក់ ជីតូ ត្រូវបានចោទប្រកាន់ថា បានជួយក្នុងការដឹកនាំ និងបិទបាំងសកម្មភាពទាំងនេះ តាមរយៈការធ្វើឱ្យរាំងស្ទះដល់ការស៊ើបអង្កេត ឬតាមរយៈការរៀបចំសម្លាប់ឃាតកបំបិទមាត់ ដើម្បីបង្ការកុំឱ្យឃាតកទាំងនោះអាចទាញគាត់ និងអ្នកដទៃទៀតឱ្យជាប់ពាក់ព័ន្ធ។*[843] *នោះក៏ជារយៈពេលពោរពេញទៅដោយការចាប់ជម្រិតទារប្រាក់ពីសមាជិកក្រុម*

---

ថា "ការចងក្រងទិន្នន័យស្តីពី មន្ត្រីពន្ធនាគារ/មណ្ឌលកែប្រែ និងអង្គភាព ឬអង្គការចាត់តាំង ដែលមានសិទ្ធិអំណាចចាប់ខ្លួន និងសួរចម្លើយ " ខែមិថុនា ឆ្នាំ១៩៨៦, អង្គការ Amnesty International, មានកំណត់ត្រា ដាក់ចំណងជើងថា "ពន្ធនាគារនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា" ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៨៦ ៖ ឯកសារទាំងនេះ ត្រូវបានរៀបចំចងក្រង សម្រាប់ អង្គការ, *ការដាក់ពន្ធនាគារនយោបាយ*; COHCHR, ការសម្ភាសន៍ជាមួយអតីតសមាជិកក្រុមអា (A-Team Member) ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣។

[839] វិទ្យុភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩២, អ៊ុនតាក់ "បញ្ជីឋានន្តរស័ក្តិ", ម៉ក់ ជីតូ លិខិតទៅកាន់អ្នកកែសម្រួលអត្ថបទ "ការទាមទារដោយខ្វះការប្រុងប្រយ័ត្ន ធ្វើឱ្យអង្គការសិទ្ធិមនុស្សទទួលបានកិត្តិយសតិចតួច", *Phnom Penh Post*, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ http://www.phnompenhpost.com/index.php/2012111659766/National-news/reckless-claims-do-rights-organisation-little- credit.html (ចូលមើលនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២)។

[840] ការសម្ភាន៍របស់លោក Brad Adams ជាមួយអតីតសមាជិកក្រុមអា (A-Team Member) ។

[841] ការសម្ភាន៍របស់លោក Brad Adams ជាមួយមន្ត្រីនគរបាល បច្ចុប្បន្ន អតីតមន្ត្រីនគរបាល និងមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា។

[842] "វិធានការប្រឆាំងនឹង "សកម្មភាពវិទ្ធង្សនា"" *Cambodian Times*, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៩៦។

[843] ឧទាហរណ៍ សូមមើល អង្គការ Amnesty International, "ចាន់ ដារា, អ្នកសារព័ត៌មានកាសែតកោះសន្តិភាព, អ៊ុច សៅសារិទ្ធ អ្នកកែសម្រួលអត្ថបទ

*អភិជនជំនួញ ដែលទើបលេចមុខ ជាពិសេស ជនជាតិភាគតិចចិននៅកម្ពុជា។*[844] *មន្ត្រីនគរបាលបច្ចុប្បន្ន និងអតីតមន្ត្រីនគរបាលជាច្រើន បានចោទលោក ម៉ក់ ជីតូ ថាមិនបានបង្ក្រាបបទល្មើសទាំងនោះទេ តែបែរជាបានរៀបចំ និងទទួលផលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ ពីបទល្មើសមួយចំនួន ក្នុងចំណោមបទល្មើសទាំងនោះទៅវិញ។*[845]

*នៅដើមឆ្នាំ១៩៩៧ លោក ម៉ក់ ជីតូ បានរារាំងការខិតខំប្រឹងប្រែងរបស់គណបក្សជាតិខ្មែរ ដែលជាគណបក្សប្រឆាំងដឹកនាំដោយលោក សម រង្ស៊ី អតីតរដ្ឋមន្ត្រីនៃគណបក្សហ៊្វុនស៊ិនប៉ិច ក្នុងការគាំទ្រជាសាធារណៈដល់បាតុកម្មរបស់ក្រុមកម្មកររោងចក្រកាត់ដេរនៅកម្ពុជា ដើម្បីទាមទារប្រាក់ឈ្នួល និងលក្ខខណ្ឌការងារប្រសើរជាងមុន។*[846] *លោក ម៉ក់ ជីតូ មានវត្តមាននៅទីតាំងដែលទទួលរងការវាយប្រហារដោយគ្រាប់បែកដៃ*

---

កាសែតព្រាបនាំសារ និងអ្នកយកសារព័ត៌មានផ្សេងទៀតនៃកាសែតព្រាបនាំសារ" (AI Index ASA 23/11/94) ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៤, អង្គការ Amnesty International, "ទូ ឈំ មង្គល និពន្ធនាយក អ្នកកែសម្រួលអត្ថបទពីរនាក់ (អត់ស្គាល់ឈ្មោះ) និងបុគ្គលិកផ្សេងទៀតនៃកាសែតអន្តរាគមន៍" (AI Index ASA 23/11/94), ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៤, "អ្នកកែសម្រួលអត្ថបទកាសែតប្រឆាំងរដ្ឋាភិបាល ត្រូវបានធ្វើឃាតនៅក្នុងរាជធានី" *AFP* ភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៤, អង្គការ Amnesty International, ស្នងការអង្គការសហប្រជាជាតិស្តីពី សិទ្ធិមនុស្ស ឆ្នាំ១៩៩៦ – អនុសាសន៍ស្តីពី ប្រទេសនានា នៅលើរបៀបវារៈ (AI Index IOR 41/03/96), ខែមីនា ឆ្នាំ១៩៩៦, អង្គការ Amnesty International, "ឃាតកម្មលើកលោក ធុន ប៊ុនលី" (AI Index ASA 23/05/96), ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៦, អង្គការ Amnesty International, "ព្រះរាជាណាចក្រកម្ពុជា ៖ ចាន់ រតនា-អ្នកទោសមនសិការ" (AI Index ASA 23/09/96), ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៦, អង្គការ Amnesty International, "ព្រឹត្តិការណ៍ដែលត្រូវបានជ្រើសរើសនៅអាស៊ី/ប៉ាស៊ីហ្វិក ចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ១៩៩៧" (AI Index Pol 10/03/97), ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៧, បណ្តឹងផ្លូវការ សំណុំឯកសារនគរបាល តុលាការ និងឯកសារផ្លូវការផ្សេងទៀត ចុះថ្ងៃទី១៧, ២១ និង២៨ ខែធ្នូ ឆ្នាំ១៩៩៣ ថ្ងៃទី១, ២, ៤, ៥ និង១០ ខែកក្កដា ឆ្នាំ១៩៩៥ ថ្ងៃទី១៧, ១៨, ១៩, ២១, ២៣, ២៥ ខែកក្កដា ឆ្នាំ១៩៩៧, ថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៩៨ ថ្ងៃទី៨, ១៦ ខែកញ្ញា ឆ្នាំ១៩៩៨, ថ្ងៃទី៤, ៥, ៦, ៧, ៩ ខែតុលា ឆ្នាំ១៩៩៨ ថ្ងៃទី១០, ១២ ខែធ្នូ ឆ្នាំ១៩៩៨ (ឯកសារទាំងអស់នេះ ស្ថិតក្នុងចំណោមឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ ឈ្មោះដើមបណ្តឹង អ្នកស៊ើបអង្កេត និងមន្ត្រីតុលាការ ត្រូវបានដកចេញ)។ ការចោទប្រកាន់ទាំងនេះ ចំពោះលោក ម៉ក់ ជីតូ គឺដោយឡែកពី និងបន្ថែមលើបណ្តាការចោទប្រកាន់ផ្សេងទៀត ដែលត្រូវធ្វើឡើងដោយអតីតស្នងការនគរបាលក្រុងភ្នំពេញ គឺលោក ហេង ពៅ នៅមុន និងក្រោយការចាប់ខ្លួនគាត់ នៅក្នុងឆ្នាំ ២០០៦ និងការជំនុំជម្រះ និងការផ្តន្ទាទោសជាបន្តបន្ទាប់ ចំពោះការប្រព្រឹត្តបទល្មើសស្រដៀងគ្នានេះ។ ការសម្ភាសន៍ជាមួយ "Les basses oeuvres de Hun Sen," *L'Express*, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៦ http://www.lexpress.fr/informations/les-basses-oeuvres-de-hun-sen_674887.htm (ចូលមើល នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២), ស្ថានទូតអាមេរិក នៅកម្ពុជា "មេដឹកនាំនគរបាលកម្ពុជាដែលបានប្តូរចិត្ត" ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦
http://www.wikileaks.org/plusd/cables/06PHNOMPENH1509_a.html (ចូលមើល នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៤), "តុលាការប្រកាន់ខ្ជាប់នូវការវិនិច្ឆ័យលើលោក ហេង ពៅ" *ខេមបូឌា ដេលី* ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/supreme-court-upholds- verdict-against-heng-pov-70977 (ចូលមើល នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៤)។ ការប្រកួតប្រជែង និងការស្អប់ខ្ពើមគ្នាយ៉ាងខ្លាំងក្លា រវាងលោក ហេង ពៅ និងលោក ម៉ក់ ជីតូ បង្កការលំបាកដល់ការវាយតម្លៃលើភាពជឿជាក់បាន ចំពោះការចោទប្រកាន់របស់លោក ហេង ពៅ លើលោក ម៉ក់ ជីតូ។

844 UNOSGRC, "របាយការណ៍ប្រចាំសប្តាហ៍ លេខ ៩០ សម្រាប់រយៈពេល ចាប់ពីថ្ងៃទី៦ ដល់ ១២ ខែមីនា ឆ្នាំ១៩៩៦"។

845 ការសម្ភាន៍របស់លោក Brad Adams មន្ត្រីនគរបាលបច្ចុប្បន្ន អតីតមន្ត្រីនគរបាល និងមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា។

846 UNOSGRC, "របាយការណ៍ប្រចាំសប្តាហ៍ លេខ១១៦ ចាប់ពីថ្ងៃទី៦ ដល់ទី១២ ខែមករា ឆ្នាំ១៩៩៧", អង្គការ Amnesty International, ព្រឹត្តិការណ៍ដែលត្រូវបានជ្រើសរើសនៅអាស៊ី/ប៉ាស៊ីហ្វិក ចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ១៩៩៧" (AI Index Pol 10/03/97), ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៧។

*លើលោក សម រង្ស៊ី នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧។ គាត់បានបដិសេធមិនព្រមសហការក្នុងការស៊ើបអង្កេតរបស់ការិយាល័យស៊ើបអង្កេតសហព័ន្ធ* (FBI) *របស់សហរដ្ឋអាមេរិកលើឧប្បត្តិហេតុនេះ។*[847]

*ដោយសារបណ្តឹងផ្លូវការពីសាធារណជន និងពីក្នុងជួរនគរបាល ចំពោះអាកប្បកិរិយារបស់លោក ម៉ក់ ជីតូ កើនឡើងកាន់តែច្រើនទៅៗ គាត់បានចាប់ផ្តើមមានឈ្មោះស្អុយអាសោច ជាហេតុធ្វើឱ្យគាត់ត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅការិយាល័យនគរបាលក្រុងភ្នំពេញ ទទួលបន្ទុករដ្ឋបាលជនបរទេស ហើយបន្ទាប់មកត្រូវបានព្យួរពីតួនាទីនេះ នៅខែធ្នូ ឆ្នាំ១៩៩៨។*[848] *ទោះបីជាយ៉ាងណា គាត់បានទទួលការតែងតាំងជាថ្មីឱ្យធ្វើជាប្រធាននគរបាលព្រហ្មទណ្ឌក្រុងភ្នំពេញវិញយ៉ាងឆាប់រហ័ស។*[849] *ជាលទ្ធផល មានការចោទប្រកាន់ថ្មីៗទៀតប្រឆាំងនឹងលោក ម៉ក់ ជីតូ រាប់បញ្ចូលទាំងការផ្តល់ភស្តុតាងផ្លូវច្បាប់បន្ថែមទៀត ស្តីពីការចូលរួមដោយសម្ងាត់របស់គាត់នៅក្នុងការប្រព្រឹត្ត ឬ ជួយបិទបាំងអំពើឃាតកម្មនយោបាយ និងការចាប់ជម្រិត ដើម្បីទទួលបានលាភសក្ការៈ។*[850] *ទោះជាយ៉ាងណា គាត់នៅតែទទួលបានការដំឡើងតំណែងឱ្យក្លាយជាប្រធាននាយកដ្ឋានកណ្តាលយុត្តិធម៌* (*នគរបាលយុត្តិធម៌*) *ថ្នាក់ជាតិ ដែលស្ថិតក្រោមអគ្គស្នងការនគរបាលជាតិ នៅក្រសួងមហាផ្ទៃ។ នៅក្នុងតួនាទីនេះ លោក ម៉ក់ ជីតូ មានអំណាចគ្រប់គ្រងដោយផ្ទាល់លើក្រុមនគរបាលយុត្តិធម៌ថ្នាក់ជាតិដ៏មានឥទ្ធិពលមួយចំនួនតូច ដោយមានដែនសមត្ថកិច្ចនៅទូទាំងប្រទេសកម្ពុជា រាប់បញ្ចូលទាំងនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ដ៏គួរឱ្យកត់សម្គាល់បំផុតផងដែរ។*[851]

---

[847] ព្រឹទ្ធសភាសហរដ្ឋអាមេរិក គណៈកម្មាធិការ ស្តីពីទំនាក់ទំនងបរទេស របាយការណ៍បុគ្គលិក "ការវាយប្រហារដោយគ្រាប់បែកដៃ នៅកម្ពុជា នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧" ខែតុលា ឆ្នាំ១៩៩៩ http://www.gpo.gov/fdsys/pkg/CPRT-106SPRT59737/html/CPRT-106SPRT59737.htm (ចូលមើល នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០០០)។

[848] ពាក្យបណ្តឹងរបស់ជនរងគ្រោះ ដែលបានដាក់ទៅនគរបាលយុត្តិធម៌ក្រុងភ្នំពេញ និងក្រសួងមហាផ្ទៃ សំណុំឯកសារផ្សេងទៀតរបស់នគរបាលតុលាការក្រុងភ្នំពេញ និងសំណុំឯកសារយុត្តិធម៌ផ្លូវការផ្សេងទៀត ចុះថ្ងៃទី១៧, ២១ និង២៨ ខែធ្នូ ឆ្នាំ១៩៩៣ ថ្ងៃទី១, ២, ៤, ៥ និង១០ ខែតុលាការ ឆ្នាំ១៩៩៥ ថ្ងៃទី១៧, ១៨, ១៩, ២១, ២៣, ២៥ ខែកក្កដា ឆ្នាំ១៩៩៧ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៩៨ ថ្ងៃទី៨, ១៦ ខែកញ្ញា ឆ្នាំ១៩៩៨ ថ្ងៃទី៤, ៥, ៦, ៧, ៩ ខែតុលា ឆ្នាំ១៩៩៨ ថ្ងៃទី១០, ១២ ខែធ្នូ ឆ្នាំ១៩៩៨ ១៩៩៨ (ឯកសារទាំងអស់នេះ ស្ថិតក្នុងចំណោមឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្លាំមើលសិទ្ធិមនុស្ស ឈ្មោះដើមបណ្តឹង អ្នកស៊ើបអង្កេត និងមន្ត្រីតុលាការ ត្រូវបានដកចេញ), COHCHR, "លោក ម៉ក់ ជីតូ ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌនៃក្រសួងមហាផ្ទៃ" [គ្មានកាលបរិច្ឆេទ], "លោក ម៉ក់ ជីតូ ត្រូវបានបញ្ជាឱ្យព្យួរការងារចំពេលមានជម្លោះ" *ខេមបូឌា ដេលី* ថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៩៨ https://www.cambodiadaily.com/archives/mok-chito-ordered-suspended-amid-feud-12171/ (ចូលមើល នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០០០)។

[849] COHCHR, , "លោក ម៉ក់ ជីតី ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌនៃក្រសួងមហាផ្ទៃ" [គ្មានកាលបរិច្ឆេទ]។

[850] ការសម្ភាសន៍របស់ COHCHR ឈ្មោះអ្នកត្រូវសម្ភាសន៍ ត្រូវបានដកចេញ, អង្គភាពទទួលបន្ទុកការងារបោះឆ្នោតនៃ COHCHR, "ឃាតកម្មនយោបាយ ៖ រចនាសម្ព័ន្ធ និងអង្គការចាត់តាំង" ខែមិថុនា ឆ្នាំ២០០៣។

[851] សម្រាប់ជាឯកសារយោង ចំពោះភាពខុសគ្នា រវាងនគរបាលយុត្តិធម៌ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សូមមើល "រាជរដ្ឋាភិ បាល មានវិធានការសម្រាប់គ្រប់គ្រងមន្ត្រីរាជការស៊ីវិល នគរបាលជាតិ មន្ត្រីយោធា មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីអណ្តែតនៅឆ្នាំ២០១៥ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥

*ក្នុងនាមជាប្រធាននាយកដ្ឋានកណ្តាលយុត្តិធម៌ (នគរបាលយុត្តិធម៌) លោក ម៉ក់ ជីតូ បានដឹកនាំជាសាធារណៈ ក្នុងការចាប់ខ្លួនក្រោមហេតុផលនយោបាយ ចំពោះសកម្មភាពសិទ្ធិមនុស្សដ៏ល្បីល្បាញមួយចំនួន ដូចជា ការចាប់ខ្លួនលោក កឹម សុខា ដែលនៅពេលនោះជាប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងលោក យ៉េង វីរៈ ប្រធានមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ នៅក្នុងឆ្នាំ២០០៦។[852] នេះគឺជាផ្នែកមួយនៃរូបភាពបំពារបំពាន និងបំភិតបំភ័យកាន់តែខ្លាំងឡើងៗមកលើសកម្មជនទាំងនោះ ដែលជាធម្មតាតែងតែទទួលរងនូវការគំរាមកំហែងផ្តន្ទាទោសចំពោះបទល្មើសផ្សេងៗដោយផ្អែកលើព័ត៌មានមិនពិត នៅមុនពេលត្រូវបានដោះលែងវិញ។ លោក ម៉ក់ ជីតូ ក៏បានចូលរួមក្នុងរូបភាពនៃការធ្វើទុក្ខបុកម្នេញស្រដៀងគ្នានេះដែរ លើសកម្មភាពសិទ្ធិដីធ្លី និងផ្ទះសម្បែង ដែលកំពុងមានចំនួនកើនឡើង។[853] ស្របពេលជាមួយគ្នានោះ ក៏មានការចោទប្រកាន់ផ្សេងៗជាថ្មីទៀត ទាក់ទងនឹងការជាប់ពាក់ព័ន្ធរបស់គាត់ក្នុងអំពើចាប់ជម្រិត និងឃាតកម្មនានា តាំងពីទសវត្សរ៍ឆ្នាំ១៩៩០មក។[854]*

*នៅខែមេសា ឆ្នាំ២០១២ លោក ហ៊ុន សែន បានតែងតាំងលោក ម៉ក់ ជីតូ ធ្វើជាប្រធានគណៈកម្មការពិសេស ទទួលបន្ទុកត្រួតពិនិត្យការស៊ើបអង្កេតករណីបាញ់សម្លាប់សកម្មជនបរិស្ថានដ៏ល្បីល្បាញគឺ លោក ឈុត វុទ្ធី ក្នុងខេត្តកោះកុង ដែលត្រូវបានបាញ់សម្លាប់ក្នុងពេលលោកកំពុងស៊ើបអង្កេតអាជីវកម្មខុសច្បាប់មួយ ដែលពាក់ព័ន្ធ នឹងកងរាជអាវុធហត្ថ។ នៅខែឧសភា គណៈកម្មការនេះបានចុះទៅដល់ខេត្តកោះកុង និងបានចង*

http://www.kampucheathmey.com/local-news/general-news/26705-2015-03-10-07-26-54.html (ចូលមើល នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥), សម្រាប់ជាឯកសារយោង ទៅកាន់នាយកដ្ឋាននេះ សូមមើល "នគរបាលព្រហ្មទណ្ឌកម្រិតស្រាល ក្រសួងមហាផ្ទៃ បញ្ជូនជនសង្ស័យ ឆក់កាបូប ២នាក់ទៅកាន់តុលាការ" ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ http://beta.nokorwatnews.com/%E1%9E%93%E1%9E%82%E1%9E%9A%E1%9E%94%E1%9E%B6%E1%9E%9B%E2%80%8B%E1%9E%96%E1%9F%92%E1%9E%9A%E1%9E%A0%E1%9F%92%E1%9E%98%E1%9E%91%E1%9E%8E%E1%9F%92% E1%9E%8C%E2%80%8B%E1%9E%80%E1%9E%98%E1%9F%92%E1%9E%9A/ (ចូលមើល នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥)។ ក្នុងរយៈពេលពីរសប្តាហ៍ នាយកដ្ឋានកណ្តាលយុត្តិធមិ ប្រមូលផ្តុំព័ត៌មានអំពី បទល្មើស ដែលបានកើតឡើងនៅទូទាំងប្រទេសកម្ពុជា ដោយផ្អែកលើរបាយការណ៍នានា ពីអគ្គស្នងការនគរបាលជាតិ និងស្នងការនគរបាលខេត្តក្រុង។ ឧទាហរណ៍ សូមមើល "នាយកដ្ឋានកណ្តាលនគរបាលយុត្តិធមិ អគ្គស្នងការនគរបានជាតិ ក្រសួងមហាផ្ទៃ របាយការណ៍នានា" ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ (ឯកសារ ក្នុងចំណោមឯកសារនានារបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ)។

[852] ពីប្រភពដដែល Ibid.

[853] ពីប្រភពដដែល Ibid.

[854] ពាក្យបណ្តឹងរបស់ជនរងគ្រោះ ដែលបានដាក់ទៅនគរបាលយុត្តិធមិក្រុងភ្នំពេញ និងក្រសួងមហាផ្ទៃ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩ (ឯកសារទាំងអស់នេះ ស្ថិតក្នុងចំណោមឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ។ ឈ្មោះដើមបណ្តឹងត្រូវបានដកចេញ)។

ក្រង់របាយការណ៍ដែលមិនគួរឱ្យជឿទុកចិត្តបានមួយ អំពីរបៀបដែលលោក ឈុត វុទ្ធី ត្រូវបានធ្វើឃាត។ ការស៊ើបអង្កេតនោះ បាននាំទៅដល់ការផ្តន្ទាទោសជនម្នាក់ ដែលទំនងគ្រាន់តែជាអ្នកទទួលរងកំហុសជំនួសគេ ពីបទមនុស្សឃាត ដែលក្រោយមកត្រូវបានដោះលែងវិញ ក្រោយពីបានអនុវត្តទោសរយៈពេលយ៉ាងខ្លី។ ការស៊ើបអង្កេត និងការជំនុំជម្រះ ដែលលោក ម៉ក់ ជីតូ បានចូលរួមនៅពេលនោះ គឺហាក់បីដូចជាត្រូវបានរៀបចំឡើង ដើម្បីការពារជនដែលត្រូវទទួលខុសត្រូវពិតប្រាកដ ចំពោះការស្លាប់របស់លោក ឈុត វុទ្ធី ឱ្យរួចផុតពីការផ្តន្ទាទោស។[855]

## ម៉ក់ ជីតូ ការបោះឆ្នោត ការបង្ក្រាបក្រោយការបោះឆ្នោត ខែកក្កដា ឆ្នាំ ២០១៣ និងពីពេលនោះមក

ដូចមន្ត្រីយោធា កងរាជអាវុធហត្ថ និងនគរបាលជាន់ខ្ពស់ផ្សេងទៀតដែរ លោក ម៉ក់ ជីតូ បានគាំទ្រយ៉ាងបើកចំហចំពោះគណបក្សកាន់អំណាចរបស់លោក ហ៊ុន សែន គឺគណបក្សប្រជាជនកម្ពុជា នៅក្នុងយុទ្ធនាការរបស់គណបក្សនេះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។ លោក ម៉ក់ ជីតូ គឺជាប្រធានក្រុមការងារបក្សប្រជាជនកម្ពុជា ដែលត្រូវបានចាត់តាំងឱ្យធ្វើយុទ្ធនាការសម្រាប់គណបក្ស នៅស្រុកកៀនស្វាយ ខេត្តកណ្តាល និងបានបញ្ចេញមន្ត្រីនគរបាលក្រោមបង្គាប់របស់គាត់ ឱ្យធ្វើសកម្មភាពយុទ្ធនាការឃោសនាសម្រាប់គណបក្សប្រជាជនកម្ពុជានៅទីនោះ។[856]

ប្រទេសកម្ពុជាត្រូវបានហ៊ុំព័ទ្ធដោយវិបត្តិសិទ្ធិមនុស្សយ៉ាងខ្លាំងក្លា បន្ទាប់ពីការបោះឆ្នោតឆ្នាំ២០១៣។ ការប៉ុនប៉ងនានានៃកងកម្លាំងសន្តិសុខរបស់រដ្ឋាភិបាល ក្នុងការទប់ស្កាត់ ឬបង្ក្រាបការប្រមូលផ្តុំដោយសន្តិវិធី បានបង្កទៅជាអំពើហិង្សាភ្លាមៗជាច្រើនដង ក្នុងអំឡុងខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៣។ ជាច្រើនលើកច្រើនគ្រា អង្គភាពនគរបាល និងអង្គភាពសន្តិសុខដទៃទៀត បានប្រើប្រាស់កងកម្លាំងដ៏គ្រោះថ្នាក់យ៉ាងច្រើនហួសប្រមាណ និងដោយមិនចាំបាច់ បណ្តាលឱ្យមានមនុស្សពីរនាក់ស្លាប់ និងរបួសជាច្រើននាក់ផ្សេងទៀត។ កងកម្លាំងនគរបាល និងកងកម្លាំងសន្តិសុខ ក៏បានចាប់ខ្លួនមនុស្សមួយចំនួនតាមទំនើងចិត្ត ដែលក្រោយមក

---

[855] អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្លាំមើលសិទ្ធិមនុស្ស "*ប្រាប់ពួកគេទៅ ខ្ញុំចង់សម្លាប់ពួកគេ*" ទំព័រ ៥៨-៦៣។

[856] "ក្រុមការងារនៃគណៈកម្មាធិការពង្រឹងមូលដ្ឋាន ក្នុងឃុំគគីរ ចុះសំណេះសំណាលជាមួយប្រជាជនដល់ផ្ទះរបស់ពួកគេ" (: bl s ru G Cfl Cflbl ), ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/65163-2013-06-01-07-02-14.html (ចូលមើល នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៣), អគ្គស្នងការនគរបាលជាតិ http://www.police.gov.kh/?p=12964 (ចូលមើល នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៣)។

ពួកគេត្រូវបានចោទប្រកាន់ពីបទល្មើសប្រឆាំងនឹងកងកម្លាំង និងបំផ្លាញទ្រព្យសម្បត្តិរបស់កងកម្លាំងសន្តិសុខ ថ្វីបើមិនមានភស្តុតាងដែលគួរឱ្យជឿទុកចិត្តបាន គ្រប់គ្រាន់ក្នុងការចោទប្រកាន់ពួកគេក្តី។ ទោះបីជាយ៉ាងណា ទំហំបាតុកម្មនៃគណបក្សសង្គ្រោះជាតិ និងកូដកម្មរបស់កម្មករបានបន្តកើនឡើង។[857] ទោះបីជាកាលណោះ លោក កឹម សុខា ដែលជាអនុប្រធានគណបក្សសង្គ្រោះជាតិ រងការគំរាមសម្លាប់យ៉ាងណាក្តី ក៏លោក ម៉ក់ ជីតូ បានប្រកាសថា បញ្ហានេះមិនមែនជាកង្វល់របស់នគរបាលឡើយ។[858]

នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ លោក ម៉ក់ ជីតូ បានក្លាយជាស្នងការស្តីទីនៃនគរបាលរាជធានីភ្នំពេញ រយៈពេល ១២ថ្ងៃ នៅពេលលោក ជួន សុវណ្ណ ដែលជាស្នងការនគរបាលរាជធានីភ្នំពេញមិននៅក្នុងប្រទេស។[859] នៅពេលជាមួយគ្នានោះដែរ គាត់បានចូលរួមជាមួយគណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ ដែលជាអង្គភាពមួយទទួលខុសត្រូវចំពោះប្រតិបត្តិការកងកម្លាំងសន្តិសុខ នៅក្នុងរាជធានី រួមទាំងប្រតិបត្តិការរបស់នគរបាល និងកងរាជអាវុធហត្ថផងដែរ។[860] នៅថ្ងៃទី២៦ ខែធ្នូ គាត់បានស្តីបន្ទោសគណបក្សសង្គ្រោះជាតិថា បានញុះញង់ឱ្យមានកូដកម្ម និងបានអះអាងថា នេះគឺជាផ្នែកមួយនៃការប៉ុនប៉ងដោយខុសច្បាប់ "ដើម្បីផ្តួលរំលំរដ្ឋាភិបាល" ដែលជាការចោទប្រកាន់ដោយគ្មានភស្តុតាង។[861] នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ គាត់បានព្រមានថា នគរបាលនឹងចាត់វិធានការ ប្រសិនបើកម្មករបង្ក "ភាពច្របូកច្របល់នៅក្នុងទីក្រុង"។"[862] ក្រោយមក គាត់បានបន្តការគ្រប់គ្រងលើប្រតិបត្តិការទាំងមូលរបស់គណៈបញ្ជាការឯកភាពរាជធានីភ្នំពេញក្នុងនាមជាប្រធានស្តីទី។

---

857 "ក្តីបារម្ភ និងអនុសាសន៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ដែលត្រូវបានដាក់ជូនគណៈកម្មាធិការអង្គការសហប្រជាជាតិ ដើម្បីពិនិត្យអំពី ស្ថានភាពនៅក្នុងប្រទេសកម្ពុជា ជាមុន នៅមុនពេលមានប្រជុំពិនិត្យរបស់គណៈកម្មាធិការនេះ" អនុស្សារណៈរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ http://www.hrw.org/news/2015/03/04/human-rights-watch-concerns-and-recommendations-cambodia-submitted-un-human-rights-c.

858 "គណបក្សសង្គ្រោះជាតិ គិតអំពី ការដាក់ពាក្យបណ្តឹងលើការគំរាមសម្លាប់" *ខេមបូឌា ដេលី* ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣ http://www.cambodiadaily.com/news/cnrp-mulls-filing-complaint-over-death-threat-48729/ (ចូលមើល នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣)។

859 លោក ម៉ក់ ជីតូ ឡើងជាស្នងការស្តីទីនគរបាលរាជធានីភ្នំពេញជំនួសលោក ជួន សុវណ្ណ ១២ថ្ងៃ, ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ http://kohsantepheapdaily.com.kh/article/86707.html (ចូលមើល នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣)។

860 "កម្ពុជា ៖ គណបក្ស ពង្រីកការគ្រប់គ្រងរបស់កងកម្លាំងសន្តិសុខ" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ http://www.hrw.org/news/2015/02/04/cambodia-party-extends-control-security-forces.

861 "រោងចក្រនានាបានទទួលការណែនាំឱ្យបិទទ្វារ នៅពេលកូដកម្មទាមទារប្រាក់ឈ្នួល កើនឡើង" *ខេមបូឌា ដេលី* ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ https://www.cambodiadaily.com/archives/factories-advised-to-close-as-wage-strikes-swell-49703/ (ចូលមើល នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣)។

862 "នៅចំពេលពាក់កណ្តាលនៃកូដកម្មនោះ រដ្ឋមន្ត្រីបានបង្កើនប្រាក់ឈ្នួលអប្បបរមា ទៅដល់ ១០០ ដុល្លារ" *ខេមបូឌា ដេលី* ថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ https://www.cambodiadaily.com/archives/amid-strikes-minister-raises-minimum-wage-to-100-49798/(ចូលមើល នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤)។

នៅព្រឹកថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ នៅពេលកម្មករបានប្រមូលផ្តុំគ្នាធ្វើបាតុកម្មនៅមុខរោងចក្រកាត់ដេរជាច្រើននៅជាយក្រុងភ្នំពេញ លោក ម៉ក់ ជីតូ បានដាក់ពង្រាយអង្គភាពកងកម្លាំងសន្តិសុខ ដើម្បីបំបែកការប្រមូលផ្តុំរបស់ក្រុមកម្មករ។ នៅយប់ថ្ងៃទី២ ឆ្លងចូលថ្ងៃទី៣ ខែមករា គណៈបញ្ជាការនេះបានបញ្ជូនកងកម្លាំងនគរបាល និងកងរាជអាវុធហត្ថរាជធានី និងខណ្ឌ រាប់រយនាក់ ដើម្បីបោសសម្អាតកម្មករ ដែលកំពុងតវ៉ាបិទផ្លូវនានានៅតំបន់ឧស្សាហកម្ម ផ្លូវវ៉េងស្រេង ជាយរាជធានីភ្នំពេញ។[863] ការប៉ះទង្គិចគ្នាយ៉ាងហិង្សាបានផ្ទុះឡើង ដោយកម្មករមួយចំនួនបានគប់ដុំថ្ម កំណាត់ឈើ និងដបសាំង និងបានបំផ្លិចបំផ្លាញរបស់របរផ្សេងៗ ខណៈកងកម្លាំងសន្តិសុខ ដែលមួយចំនួនបានរង់របួសដែរនោះ បានបាញ់ឧស្ម័នបង្ហូរទឹកភ្នែក គ្រាប់បែកផ្សែង និង បាញ់គ្រាប់ពិត ម្តងម្កាល។ ពួកគេក៏បានវាយដំមនុស្សជាច្រើននាក់ រួមទាំងបុរសវ័យក្មេងបីនាក់ ដែលត្រូវបានចាប់ខ្លួន និងក្រោយមកត្រូវបានជំនុំជម្រះ។ នៅព្រឹកថ្ងៃទី៣ ខែមករា កងកម្លាំងកងរាជអាវុធហត្ថមួយក្រុមធំបានបើកប្រតិបត្តិការចូលកាន់កាប់តំបន់វ៉េងស្រេង ហើយពួកគេមួយចំនួនបានបាញ់កាំភ្លើងវ៉ែងរបស់ខ្លួនដោយមិនសំចៃ បណ្តាលឱ្យមនុស្ស៥នាក់ស្លាប់ និង១០នាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន។ បន្ទាប់មក តំបន់នោះ ត្រូវបានកាន់កាប់ដោយកងកម្លាំងយោធា។ ជនរងគ្រោះម្នាក់ ក្នុងចំណោមជនរងគ្រោះផ្សេងទៀត ដែលត្រូវបានកងរាជអាវុធហត្ថវាយដំ ក្រោយមកបានស្លាប់ដោយសាររបួស។ មនុស្ស១៣នាក់ ដែលត្រូវបានចាប់ខ្លួន ក្រោយមកត្រូវបានជំនុំជម្រះ និងផ្តន្ទាទោសឱ្យទទួលខុសត្រូវចំពោះអំពើហិង្សាដែលបានកើតឡើង ទោះបីជាគ្មានភស្តុតាងគួរឱ្យជឿបានសម្រាប់ចោទប្រកាន់ពួកគេក៏ដោយចុះ។[864] ចាប់ពីពេលនោះមក លោក ម៉ក់ ជីតូ បានឡើងតំណែង ទាំងនៅក្នុងជួរនគរបាល ទាំងនៅក្នុងជួរគណបក្សប្រជាជនកម្ពុជា។ នៅខែធ្នូ ឆ្នាំ២០១៤ លោក នាយករដ្ឋមន្ត្រីហ៊ុន សែន បានចាត់តាំងគាត់ឱ្យធ្វើជាអគ្គស្នងការរងនគរបាលជាតិ ដែលនៅពេលនោះ គាត់បានបោះបង់តំណែងពីមុនរបស់គាត់ ជាប្រធាននាយកដ្ឋានកណ្តាលយុត្តិធម៌ (នគរបាលយុត្តិធម៌)។[865] នៅខែកុម្ភៈ ឆ្នាំ២០១៥ គាត់បានចូលរួមក្នុងគណៈកម្មាធិការ

---

863 យោងតាមសក្ខីកម្មរបស់នមន្ត្រីនគរបាល និងកងរាជអាវុធហត្ថ ដែលបានបង្ហាញខ្លួនក្នុងសវនាការ ចាប់ពីថ្ងៃទី២៥ ខែមេសា ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ដើម្បីជំនុំជម្រះលើករណីមនុស្សដែលត្រូវបានចាប់ខ្លួននៅក្នុងព្រឹត្តិការណ៍ផ្លូវវ៉េងស្រេង។

864 "ក្តីបារម្ភ និងអនុសាសន៍របស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ដែលត្រូវបានដាក់ជូនគណៈកម្មាធិការអង្គការសហប្រជាជាតិ ដើម្បីពិនិត្យអំពី ស្ថានភាពនៅក្នុងប្រទេសកម្ពុជា ជាមុន នៅមុនពេលមានការប្រជុំពិនិត្យរបស់គណកម្មាធិការនេះ" អនុស្សរណៈរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ http://www.hrw.org/news/2015/03/04/human-rights-watch-concerns-and-recommendations-cambodia-submitted-un- human-rights-c.។

865 "រាជរដ្ឋាភិបាល តម្លើងមុខតំណែងរបស់លោក ម៉ក់ ជីតូ និងលោក ហឹម យ៉ាន និងផ្តល់តួនាទីបន្ថែមដល់លោក ទូច ណារុថ" ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/101748-2014-12-26-03-23-03.html (ចូលមើល នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤)។

កណ្តាលរបស់គណបក្សប្រជាជនកម្ពុជា ហើយនៅខែវិច្ឆិកា ឆ្នាំ២០១៥ លោកហ៊ុន សែន បានតែងតាំងគាត់ជាអគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បន្ថែមពីលើតួនាទីជាអគ្គស្នងការរងនគរបាលជាតិ។[866] ដូចលោក សុខ ផល ដែរ លោក ម៉ក់ ជីតូ មានឈ្មោះនៅក្នុងគណៈកម្មាធិការរបស់ក្រសួងមហាផ្ទៃដែលមានភារកិច្ចចាប់ខ្លួនលោក សម រង្ស៊ី នៅពេលណាដែលអាចធ្វើបាន។[867] នៅខែតុលា ឆ្នាំ២០១៧ គាត់ត្រូវបានដំឡើងឋានន្តរសក្តិ ឱ្យទៅជានាយឧត្តមសេនីយ៍ផ្កាយមាស៤ យ៉ាងពេញលេញ។[868]

ស្របពេលជាមួយគ្នានោះ លោក ម៉ក់ ជីតូ បន្តធ្វើការងារពង្រឹងមូលដ្ឋានឱ្យគណបក្សប្រជាជនកម្ពុជា និងគាំទ្រដល់ការបន្តធ្វើជានាយករដ្ឋមន្ត្រីរបស់លោក ហ៊ុន សែន។[869] នៅចុងឆ្នាំ២០១៦ លោក ម៉ក់ ជីតូ និងមន្ត្រីក្រោមបង្គាប់ម្នាក់ បានធ្វើទស្សនកិច្ចទៅកាន់ខេត្តតាកែវ ដែលនៅទីនោះ មន្ត្រីក្រោមបង្គាប់រូបនោះ ជំនួសមុខលោក ម៉ក់ ជីតូ បានថ្លែងកោតសរសើរចំពោះការងារជានាយករដ្ឋមន្ត្រីរបស់លោក ហ៊ុន សែន។[870] នៅថ្ងៃចាប់ខ្លួនលោក កឹម សុខា នៅខែកញ្ញា ឆ្នាំ២០១៧ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់លោក ម៉ក់ ជីតូ បានបង្ហាញការគាំទ្រទាំងស្រុងចំពោះការចាប់ខ្លួនលោក កឹម សុខា ដោយចោទប្រកាន់លោកថា បានឃុបឃិតជាមួយបរទេសប្រព្រឹត្តអំពើក្បត់បដិវត្តពណ៌ និងធ្វើចារកម្មឱ្យបរទេស ជាហេតុនាំឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សន្តិសុខជាតិក្នុងលក្ខខណ្ឌមួយដែលមិនអាចអត់ឱនឱ្យបាន។[871]

---

866 "កម្ពុជា ៖ គណបក្ស ពង្រីកការគ្រប់គ្រងរបស់កងកម្លាំងសន្តិសុខ" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ http://www.hrw.org/news/2015/02/04/cambodia-party-extends-control-security-forces; "ការតែងតាំងលោក ម៉ក់ ជីតូ ជាអគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន", ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥http://kampucheathmey.com/kpt/?p=105531 (ចូលមើល នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥)

867 "រាជរដ្ឋាភិបាលកម្ពុជា សម្រេចបង្កើតគណៈកម្មាធិការមួយ ដើម្បីអនុវត្តដីការចាប់ខ្លួនលោក សម រង្ស៊ី" (Gns.,ru s lfl), ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ http://www.dap- news.com/2011-06-14-02-39-55/102630-2015-11-16-02-29-44.html (ចូលមើល នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥)។

868 ឃី សុវុទ្ធី "មន្ត្រីពាក់ឯកសណ្ឋាន ទទួលបានឋានៈកាន់តែខ្ពស់" *Khmer Times*, ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៧។

869 "លោក ម៉ក់ ជីតូ សំណេះសំណាលជាមួយមន្ត្រីរាជការស៊ីវិល និងនិវត្តជន នៅស្រុកកៀនស្វាយ" (6u'), ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥ http://beta.nokorwatnews.com/%e1%9e%9b%e1%9f%84%e1%9e%80%e2%80%8b-%e1%9e%98% e1%9f%89%e1%9e%80%e1%9f%8b%e2%80%8b-%e1%9e%87%e1%9e%b8%e2%80%8b%e1%9e%8f% e1%9e%bc%e2%80%8b-%e1%9e%9f%e1%9f%86%e1%9e%8e%e1%9f%81%e1%9f%87%e1%9e%9f/# sthash.cX7yQNAf.dpuf (ចូលមើល នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥)។

870 "អង្គកឋិនទាន លោក ម៉ក់ ជីតូ និងលោក យឹង សារ៉ាត់ ដង្ហែចូលវត្តអង្គកំណាប់ ខេត្តតាកែវ ប្រមូលបច្ច័យបានជាង១ម៉ឺនដុល្លារ កសាងសមិទ្ធផលក្នុងវត្ត", ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៦ http://www.freshnewsasia.com/index.php/en/localnews/39342-2016-11-14-04-19-06.html (ចូលមើលនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៦)។

871 អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រកាសគាំទ្រទាំងស្រុងចំពោះការចាប់ខ្លួនកឹមសុខារឿងក្បត់ជាតិ។

# XII. នាយឧត្តមសេនីយ៍ផ្កាយមាស ៤ ជួន សុវណ្ណ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ

## *លោក ជួន សុវណ្ណ នៅខេត្តកណ្តាល ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ២០១០*

*ថ្ងៃខែឆ្នាំកំណើតផ្លូវការរបស់លោក ជួន សុវណ្ណ គឺថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៥៨។[872] នៅសម័យរដ្ឋកម្ពុជា គាត់គឺជាកម្មាភិបាលយោធា ក្នុងខេត្តកណ្តាល ដោយធ្វើការក្រោមបង្គាប់លោក គន់ គីម។ គាត់ក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយលោក គន់ គីម តាំងពីពេលនោះមក។[873] ក្រោយការបង្កើតកងរាជអាវុធហត្ថលើផ្ទៃប្រទេស (GRK) នៅឆ្នាំ១៩៩៣ លោក ជួន សុវណ្ណ បានក្លាយជាមេបញ្ជាការកងរាជអាវុធហត្ថខេត្តកណ្តាលជាតួនាទី ដែលគាត់កាន់រហូតដល់ខ្នង់ឆ្នាំ២០១០។[874] ក្នុងនាមជាសមាជិកសកម្មម្នាក់នៃគណបក្សប្រជាជនកម្ពុជា លោកក៏បានក្លាយជាបុគ្គល ដែលលោក ហ៊ុន សែន ពេញចិត្ត ហើយពួកគេទាំងពីរតែងតែជួបគ្នាជជែកលេងជាញឹកញាប់នៅភូមិគ្រឹះ និងបញ្ជាការដ្ឋានរបស់នាយករដ្ឋមន្ត្រី នៅទួលក្រសាំង ស្ថិតនៅក្រៅក្រុងតាខ្មៅ។[875] ត្រឹមដើមឆ្នាំ១៩៩៧ លោក ជួន សុវណ្ណ ក៏មានតួនាទីបន្ថែមមួយទៀត គឺជាអង្គរក្សផ្ទាល់ខ្លួនរបស់លោក ហ៊ុន សែន មានឋានៈជាមន្ត្រី ដែលជាឋានៈលោក ហ៊ុន សែន ផ្តល់ឱ្យសម្រាប់កិច្ចបំរើរបស់គាត់ជូនលោក ហ៊ុន សែន។[876]*

*មួយខែក្រោយរដ្ឋប្រហាររបស់លោក ហ៊ុន សែន នៅខែកក្កដា ឆ្នាំ១៩៩៧ ប្រឆាំងនឹងគណបក្សហ៊្វុនស៊ិនប៉ិចដែលជាអតីតដៃគូរដ្ឋាភិបាលចម្រុះរបស់គាត់ លោក ជួន សុវណ្ណ ត្រូវបានតែងតាំងជាផ្លូវការជាទីប្រឹក្សារបស់លោក គន់ គីម ដែលជាមេបញ្ជាការផ្នែកយុទ្ធសាស្ត្រដ៏សំខាន់ម្នាក់របស់លោក ហ៊ុន សែន ក្នុងអំឡុង*

---

[872] បញ្ជីឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតជាបណ្តោះអាសន្ន ក្នុងឆ្នាំ២០១៧ ឯកសារ ០៥-១៩៤-៣៨៦។

[873] ការសម្ភាសន៍ជាមួយអតីតមន្ត្រីនគរបាលខេត្តកណ្តាល ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤។

[874] រដ្ឋាភិបាលកម្ពុជា "រចនាសម្ព័ន្ធកងរាជអាវុធហត្ថ", រដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ១១ អនក្រ ចុះថ្ងៃទី៨ មីនា ឆ្នាំ១៩៩៤, សម្ភាសន៍អតីតមន្ត្រីនគរបាលខេត្តកណ្តាល ថ្ងៃទី៧ កក្កដា២០១៤, កងរាជអាវុធហត្ថ "លេខទូរស័ព្ទ",សម្ភាសបុគ្គលិកអង្គការសិទ្ធិមនុស្សកម្ពុជាថ្ងៃទី៣០-៣១តុលា ២០១៤។

[875] ការសម្ភាសន៍ជាមួយអតីតមន្ត្រីនគរបាលខេត្តកណ្តាល ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤។

[876] រាជរដ្ឋាភិបាលកម្ពុជា សេចក្តីសម្រេចលេខ ០៩ សសរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧។

*ពេលធ្វើរដ្ឋប្រហារនោះ។*[877]

*នៅពេលលោក ជួន សុវណ្ណ ធ្វើជាមេបញ្ជាការកងរាជអាវុធហត្ថ ខេត្តកណ្ដាល ពួកគេបានជាប់ពាក់ព័ន្ធនៅក្នុងការរំលោភសិទ្ធិមនុស្សយ៉ាងច្រើន រាប់បញ្ចូលទាំងការបំពារបំពាន និងការគំរាមសម្លាប់ ការបំភិតបំភ័យសកម្មជនគណបក្សប្រឆាំង និងការរំលោភដីធ្លីដ៏ហិង្សា ដែលក្នុងអំឡុងពេលនោះ ពួកគេត្រូវបានចោទប្រកាន់ថា បានបាញ់ដោយខុសច្បាប់ទៅលើក្រុមអ្នកភូមិ ដែលមានទំនាស់ជាមួយអាជីវកម្មមួយ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយលោក គន់ គីម។*[878]

## *លោក ជួន សុវណ្ណ ជាអគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ*

*ត្រឹមឆ្នាំ២០១១ លោក ជួន សុវណ្ណ បានទទួលការដំឡើងតំណែង និងត្រូវបានផ្ទេរទៅកាន់តួនាទីនៅរាជធានីភ្នំពេញ ជាអគ្គស្នងការរងនគរបាលជាតិ ដោយមានការទទួលខុសត្រូវខ្ពះលើមន្ត្រីនគរបាលរាជធានី។*[879] *នេះគឺជាផ្នែកមួយនៃដំណើរការពង្រឹងការក្ដោបក្ដាប់របស់លោក ហ៊ុន សែន និង គណបក្សរបស់លោកលើកងកម្លាំងសន្តិសុខនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ដែលក្នុងនោះរួមមានការលើកបន្ទុបលោក នេត សាវឿន ជាអគ្គស្នងការនគរបាលជាតិ នៅឆ្នាំ២០០៨ និងការលើកបន្ទុបលោក គន់ គីម ជាប្រធានសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ (កងយោធពលខេមរភូមិន្ទ) នៅឆ្នាំ២០០៩ ផងដែរ។*[880]

*នៅថ្ងៃទី ៣ ខែតុលា ឆ្នាំ២០១២ លោក ជួន សុវណ្ណ បានចូលកាន់តំណែងបន្ថែមមួយទៀតជាស្នងការនគរ*

---

[877] រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ១៥៤ អនក្រ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧។

[878] អនាមិក "កូនប្រុសរបស់នាយឧត្តមសេនីយ៍ផ្កាយមាស ៤ ម្នាក់ បាននិយាយថា បច្ចុប្បន្ននេះ អំពើពុករលួយ កំពុងកើតឡើងតាំងពីលើដល់ក្រោម" បង្ហោះផ្សាយនៅលើ "កញ្ចក់" http://cambodiamirror.wordpress.com/2010/01/05/the-son-of-a-four-star-general-said-corruption-occurs-at-present-from-top-to-bottom-monday-4-1-2010/.

[879] យឹម សុជាតិត្រូវបានទៅកាន់តំណែងជាប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះក្រុង, CamNews, ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ https://icamnews.wordpress.com/2011/03/24/%e1%9e%99%e1%9e%b9%e1%9e%98-%e1%9e%9f%e1%9e%bb%e1%9e%87%e1%9e%b6%e1%9e%8f%e1%9e%b7%e1%9e%8f%e1%9f%92%e1%9e%9a%e1%9e%bc%e1%9e%9c%e1%9e%94% e1%9e%b6%e1%9e%93%e1%9e%91%e1%9f%85-%e1%9e%80%e1%9e%b6/.

[880] ការសម្ភាសន៍ជាមួយអតីតមន្ត្រីនគរបាលខេត្តកណ្ដាល ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៨ "នាយឧត្តមសេនីយ៍ នេត សាវឿន ក្មួយប្រសារលោក ហ៊ុន សែន ត្រូវបានតម្លើងតំណែងជាមេនគរបាល" *VOA* ជាភាសាខ្មែរ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ http://khmerization.blogspot.com/2008/11/gen-neth-savoeun- hun-sens-nephew-in-law.html (ចូលមើល នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨), រាជរដ្ឋាភិបាលកម្ពុជា ព្រះរាជក្រឹត្យ NS/RPhT/0109/069, ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩។

បាលរាជធានីភ្នំពេញ ជំនួសលោក ទូច ណារុថ។[881] ភ្លាមៗក្រោយពេលនោះ អ្វីដែលត្រូវបានបង្ហាញឱ្យឃើញកាន់តែច្បាស់នោះ គឺថា លោក ជួន សុវណ្ណ មានឆន្ទៈខ្ពស់ជាងលោក ទូច ណារុថ ក្នុងការប្រើប្រាស់កងកម្លាំង រួមទាំងកងកម្លាំងដ៏គ្រោះថ្នាក់ ក្នុងការបង្ក្រាបមនុស្សដែលពួកគេហៅថា ក្រុមប្រឆាំងផ្នែកនយោបាយ និងសង្គម ដែលក្នុងនោះ រួមមាន ការបង្ក្រាបតាមរយៈការអនុវត្តច្បាប់ឆ្នាំ២០០៩ ស្តីពីបាតុកម្មដោយសន្តិវិធី ដែលមានបទប្បញ្ញត្តិរឹតត្បិតការប្រមូលផ្តុំគ្នានៅតាមទីសាធារណៈ។ បន្ទាប់ពីទទួលបានការតែងតាំងមក លោក ជួន សុវណ្ណ បានអនុវត្តការរឹតត្បិតបែបនេះ តាមរយៈការប្រើប្រាស់នគរបាល ដើម្បីទប់ស្កាត់ ឬបំបែកការប្រមូលផ្តុំគ្នា ដែលអាជ្ញាធរចាត់ទុកតាមទំនើងចិត្តថា បង្កការគំរាមកំហែងដល់ "សន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ" ជាពិសេស ក្នុងករណីបាតុកម្ម ដែលត្រូវបានគ្រោងនឹងធ្វើឡើងនៅក្រៅ "ទីលានប្រជាធិបតេយ្យ" ឬ "សួនសេរីភាព" ដែលកំណត់ដោយច្បាប់ឆ្នាំ២០០៩។[882] ក្រោមហេតុផលផ្លូវច្បាប់នេះ លោកជួន សុវណ្ណ បានវែកញែកថា ការទប់ស្កាត់បទល្មើសជាមុន គឺវាល្អជាងការបង្ក្រាបនៅក្រោយពេលវាកើតឡើងហើយ ហេតុនេះ យកល្អត្រូវទប់ស្កាត់រាល់ការប្រមូលផ្តុំគ្នាទាំងអស់ ដែលទំនងជាបង្កការរំខានដល់សណ្តាប់ធ្នាប់សង្គម ដូចជា កូដកម្ម ជាដើម។[883] ក្នុងការធ្វើដូចនេះ គាត់បានប្រើប្រាស់អំណាចជាស្នងការនគរបាលរាជធានីភ្នំពេញ ដាក់ពង្រាយអង្គភាពនគរបាលខណ្ឌ និងអង្គភាពនគរបាលផ្សេងទៀត រួមទាំងនគរបាលរដ្ឋបាលសង្កាត់ ដែលនគរបាលទាំងពីរអង្គភាពនេះ តែងតែទទួលបានជំនួយជាប្រចាំ ពីសំណាក់ក្រុមសន្តិសុខសណ្តាប់ធ្នាប់សាធារណៈមូលដ្ឋាន នៅក្នុងប្រតិបត្តិការរបស់ពួកគេ។[884]

---

881 "នៅពេលនេះ លោក ទូច ណារុថ បានចាកចេញពីតំណែងស្នងការនគរបាលរាជធានីភ្នំពេញជាផ្លូវការ" ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១២ http://www.cen.com.kh/localnews/details_more/19?token=MDQxY2U4OWMwMTI4ZTM2YzM0MGQ2YjIwZjdlYmMx (ចូលមើល នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១២)។

882 ការសម្ភាសន៍ជាមួយមន្ត្រីកងកម្លាំងសន្តិសុខ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥, អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្លាំមើលសិទ្ធិមនុស្ស (យូមែនរ៉ៃត៍វ៉ច្ឆ) "ការដាក់ស្នើរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ដើម្បីឱ្យគណៈកម្មាធិការសិទ្ធិមនុស្ស ពិនិត្យស្ថានភាពក្នុងប្រទេស កម្ពុជា" ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៤។

883 "គណបក្សប្រជាជនកម្ពុជា សម្តោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវអគារគណបក្ស នៅឃុំរការ ស្រុកភ្នំក្រវ៉ាញ" ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/63395-2013-05-04-07-27-55.html (ចូលមើល នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៣)។

884 "ក្រុមចលនាយុវជនសម រង្ស៊ី ប៉ុនប៉ងធ្វើបាតុកម្មនៅមុខស្ថានទូតអាមេរិក" ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២http://www.cen.com.kh/localnews/details_more/19?token=MWEzOTU3NjhlZTJmNzYxZjlmYWJiMzRhN2EwMjEy (ចូលមើល នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២), "លោកស្នងការនគរបាលរាជធានីភ្នំពេញ ចុះពិនិត្យ និងពង្រឹងភារកិច្ចនគរបាល នៅខណ្ឌដង្កោ" ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ http://kpt-news.com/index.php?option=com_content&view=article&id=32655:2013-08-23-07-34- 02&catid=1:latest&Itemid=65 (ចូលមើល នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣), "កងកម្លាំងនគរបាលខណ្ឌដូនពេញ ប្រមូលផ្តុំគ្នា ដើម្បីហ្វឹកហ្វឺនបង្កើនសមត្ថភាពការពារសន្តិសុខជូនប្រជាជន" ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/70801-2013-08-24-08- 09-24.html (ចូលមើល នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣), Amnesty International, "កម្ពុជា ចេញទៅតាមផ្លូវ ៖ សេរីភាពក្នុងការប្រមូលផ្តុំអហិង្សានៅកម្ពុជា" (ASA 23/1506/2015), ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៥ ទំព័រ ៨-៩, ១៧, ៣៨-៣៩, ៤៨, ៥១-៦២, ៦៥, ៨៣-៨៥, ៩៥, ១០១-១០៦, ១១០, ១១៤-១១៥។

ស្របនឹងគោលគំនិតនៃពាក្យថា "កងកម្លាំងចម្រុះ" ដែលមានតាំងពីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាមក លោក ជួន សុវណ្ណ បានសម្របសម្រួលប្រតិបត្តិការរបស់នគរបាលក្រុង ជាមួយនឹងប្រតិបត្តិការរបស់កងរាជអាវុធហត្ថ។ តាំងពីដំបូងទីមក គាត់បានភ្ជាប់ទំនាក់ទំនងរបស់គាត់យ៉ាងជិតស្និទ្ធជាមួយអតីតប្រធានរបស់គាត់ គឺលោក សៅ សុខា ដែលជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។[885] ក្រោយមកគាត់ក៏បានធ្វើដូចគ្នានេះដែរ ចំពោះអតីតមិត្តរួមអាវុធរបស់គាត់មកពីខេត្តកណ្តាល នោះគឺលោក រ័ត្ន ស្រ៊ាង ដែលធ្លាប់ជាកូនចៅរបស់លោក ជួន សុវណ្ណ នៅក្នុងកងរាជអាវុធហត្ថខេត្តកណ្តាល បន្ទាប់មកបានក្លាយជាមេបញ្ជាការកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ មុនពេលក្លាយជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣។[886] ជាច្រើនលើកច្រើនគ្រា គាត់ក៏បានសម្របសម្រួលសកម្មភាពរបស់នគរបាលជាមួយសកម្មភាពរបស់កងកម្លាំងនៃអង្គភាពកងអង្គរក្សរបស់លោក ហ៊ុន សែន ក្នុងការអនុវត្តភារកិច្ច (ដែលពួកគេហៅថា) ដើម្បីរក្សា "សន្តិសុខ និង សណ្តាប់ធ្នាប់"។[887]

ការចាត់តាំងលោក ជួន សុវណ្ណ ជាស្នងការនគរបាលរាជធានីភ្នំពេញកើតឡើង ចំពេលដែលរដ្ឋាភិបាលកម្ពុជា កំពុងត្រៀមធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន ASEAN) និងកិច្ចប្រជុំពាក់ព័ន្ធនានា រាប់បញ្ចូលទាំងកិច្ចប្រជុំជាមួយមេដឹកនាំនៃមហាអំណាច ដែលមិនមែនជាសមាជិកអាស៊ាន ក្នុងនោះក៏មានលោក **បារ៉ាក់ អូបាម៉ា** (Barak Obama) ប្រធានាធិបតីសហរដ្ឋអាមេរិក ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១២។[888] រដ្ឋាភិបាលបានពង្រឹងវិធានការសន្តិសុខ នៅមុននិងក្នុងអំឡុងពេលមានព្រឹត្តិការណ៍ទាំងនោះ រួមមាន ការបង្កើនការរឹតត្បិតលើសេរីភាពក្នុងការប្រមូលផ្តុំគ្នា ដែលមានលោក ជួន សុវណ្ណ ដើរតួនាទីសំខាន់។ នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២ គាត់បានដាក់ពង្រាយ

---

https://www.amnesty.org/en/documents/asa23/1506/2015/en/ (ចូលមើល នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៥)។

885 "កងរាជអាវុធហត្ថលើផ្ទៃប្រទេស បានបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១២ និងដាក់ចេញទិសដៅឆ្នាំ២០១៣" ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ http://www.dap-news.com/2011-06-14-02-39-55/55049-2012-12-27-08-42-59.html (ចូលមើល នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២)។

886 "សាលារាជធានីភ្នំពេញ ពិភាក្សាលើការគ្រប់គ្រងបាតុកម្ម ជាមួយគណបក្សសង្គ្រោះជាតិ" ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/77868---cnrp--.html (ចូលមើល នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣), ការសម្ភាសន៍ជាមួយអតីតមន្ត្រីនគរបាលខេត្តកណ្តាល ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤, កងរាជអាវុធហត្ថខ្មែរ "លេខទូរស័ព្ទ" [គ្មានកាលបរិច្ឆេទ], "មេបញ្ជាការយោធា ត្រូវបានផ្លាស់ប្តូរជាផ្លូវការ" *ភ្នំពេញប៉ុស្តិ៍*, ខែកញ្ញា ឆ្នាំ២០១៣,http://www.phnompenhpost.com/national/military-commander-officially-be-replaced (មើល នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣)។

887 "ស្នងការនគរបាលរាជធានីភ្នំពេញ ប្រជុំគ្នា ដើម្បីត្រៀមកងកម្លាំងការពារកិច្ចប្រជុំកំពូលអាស៊ាន" ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ http://www.dap-news.com/2011-06-14-02-39-55/52501-2012-11-12-04-06-06.html (ចូលមើល នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២)។

888 "ក្រុមចលនាយុវជន សម រង្ស៊ី ប៉ុនប៉ងធ្វើបាតុកម្មនៅមុខស្ថានទូតអាមេរិក" ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ http://www.cen.com.kh/localnews/details_more/19?token=MWEzOTU3NjhlZTJmNzYxZjlmYWJiMzRhN2EwMjEy (មើលថ្ងៃទី១៨ វិច្ឆិកា ២០១២)។

*នគរបាល ដោយមានឯកសណ្ឋាន និងឧបករណ៍បង្ក្រាបកុបកម្ម ដើម្បីបញ្ចៀសក្រុមអ្នកតវ៉ាសិទ្ធិដីធ្លីក្នុងទីក្រុង ឱ្យចេញឆ្ងាយពីទីតាំងប្រមូលផ្តុំគ្នាដែលពួកគេបានគ្រោងទុកនៅខាងមុខស្ថានទូតសហរដ្ឋអាមេរិក។*[889] *នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ លោក ជួន សុវណ្ណ បានកោះប្រជុំមួយជាមួយអង្គភាពនគរបាលខណ្ឌ និងអង្គភាពនគរបាលផ្សេងទៀត ដើម្បីធ្វើការរៀបចំជាចុងក្រោយសម្រាប់កិច្ចប្រជុំកំពូលនោះ។*[890] *គាត់បានប្រកាសពីបំណងរបស់គាត់ក្នុងការបន្តបង្ក្រាបរាល់បាតុកម្ម និងការប្រមូលផ្តុំទាំងអស់ ដែលមិនទទួលបានការអនុញ្ញាតជាមុនពីសាលារាជធានី និងក្រសួងមហាផ្ទៃ។*[891] *នៅថ្ងៃទី១៣ ខែវិច្ឆិកា នៅក្នុងប្រតិបត្តិការរួមគ្នាមួយជាមួយកងរាជអាវុធហត្ថ កងកម្លាំងនគរបាលរបស់លោក ជួន សុវណ្ណ បានអន្តរាគមន៍ ទប់ស្កាត់ការប្រមូលផ្តុំគ្នាមួយ របស់សកម្មជនរាប់រយនាក់មកពីប្រទេសកម្ពុជា និងមកពីបណ្តាប្រទេសនានាក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីទាមទារអោយអង្គប្រជុំកំពូលអាស៊ាននោះ គិតគូរលើកកម្ពស់សិទ្ធិមនុស្ស។*[892]

*ការបង្ក្រាបរបស់នគរបាលរាជធានីភ្នំពេញលើបាតុកម្មអហិង្សា និងការប្រមូលផ្តុំគ្នាដោយសន្តិវិធី នៅតែបន្តកើតមាននៅក្រោយកិច្ចប្រជុំកំពូលអាស៊ាន។ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ប្រតិបត្តិការរួមគ្នាមួយរវាងកងអន្តរាគមន៍ នគរបាលខណ្ឌ និងកងរាជអាវុធហត្ថ បានប្រើប្រាស់កងកម្លាំងច្រើនលើសលប់ ដើម្បីបំបែកបាតុកម្មមួយរបស់ក្រុមកម្មករ បន្ទាប់ពីរោងចក្ររបស់ពួកគេបានបណ្តេញសមាជិកសហជីពពីរនាក់ចេញពីការងារ។*[893] *នៅក្នុងការពន្យល់អំពីវិធានការទាំងនោះ លោក ជួន សុវណ្ណ បានថ្លែងថា ទោះបីជាតាមគោលការណ៍ កម្មករមានសិទ្ធិធ្វើបាតុកម្មក៏ដោយ ក៏នៅក្នុងការអនុវត្តជាក់ស្តែង គាត់បានណែនាំនគរបាលឱ្យ*

---

[889] "អ្នកតវ៉ាបោះជំរំ នៅស្ថានទូតអាមេរិក នៅថ្ងៃទី២" *ខេមបូឌា ដេលី* ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១២http://www.cambodiadaily.com/news/protesters-camp-at-us-embassy-for-second-day-5358/ (ចូលមើល នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១២), "បាតុករប្រឆាំងនឹងការបណ្តេញចេញពីលំនៅដ្ឋាន ធ្វើការតវ៉ា បង្ហាញលោក **អូបាម៉ា**" *ខេមបូឌា ដេលី* ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២ http://www.cambodiadaily.com/news/anti-eviction-protesters-appeal-to-obama-5315/ (ចូលមើល នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១២)។

[890] "ស្នងការនគរបាលរាជធានីភ្នំពេញ ប្រជុំគ្នា ដើម្បីត្រៀមកងកម្លាំងការពារកិច្ចប្រជុំកំពូលអាស៊ាន" ថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ២០១២ http://www.dap-news.com/2011-06-14-02-39-55/52501-2012-11-12-04-06-06.html (ចូលមើល នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២)។

[891] "ក្រុមចលនាយុវជន សម រង្ស៊ី ប៉ុនប៉ងធ្វើបាតុកម្ម នៅមុខស្ថានទូតអាមេរិក" ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ http://www.cen.com.kh/localnews/details_more/19?token=MWEzOTU3NjhlZTJmNzYxZjlmYWJiMzRhN2EwMjEy (ចូលមើល នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២)។

[892] "បញ្ឈប់ការរំខានដល់ព្រឹត្តិការណ៍នានារបស់អង្គការសង្គមស៊ីវិល និងការរឹតត្បិតសេរីភាព ក្នុងការបញ្ចេញមតិ និងការជួបជុំ នៅមុនកិច្ចប្រជុំកំពូលអាស៊ាន" *អង្គការលីកាដូ*, et al., សេចក្តីថ្លែងការណ៍ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២ http://www.licadho-cambodia.org/pressrelease.php?perm=294 (ចូលមើល នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២) "ឆ្នាំ២០១២ នៅក្នុងការពិនិត្យឡើងវិញ៖ ការបង្ក្រាបលើសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពក្នុងការជួបប្រជុំគ្នា" *អង្គការលីកាដូ* អត្ថបទ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ http://www.licadho-cambodia.org/articles/20130215/136/index.html (ចូលមើល នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៣), ពីប្រភពដដែល (Ibid.)

[893] ពីប្រភពដដែល (Ibid.)

*បង្ក្រាបការប្រមូលផ្តុំណាមួយ ដែលត្រូវបានចាត់ទុកថា មិនស្របនឹង "នីតិរដ្ឋ"។ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ក្រុមនគរបាលបានប៉ះទង្គិចជាមួយកម្មកររាប់រយនាក់ ដែលកំពុងធ្វើកូដកម្មទាមទារឱ្យមេដឹកនាំសហជីពពីរនាក់ ដែលត្រូវបានបណ្តេញចេញពីការងារបានចូលធ្វើការងារវិញ។[894] នៅថ្ងៃទិវាសិទ្ធិមនុស្សអន្តរជាតិ (១០ ធ្នូ) នគរបាលបានរារាំងការដើរដង្ហែក្បួន ដើម្បីប្រារព្ធពិធីនេះ ហើយបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលម្នាក់ត្រូវបានឃុំខ្លួនមួយរយៈពេលខ្លី ដោយសារមូលហេតុដ៏សាមញ្ញមួយ គឺបានថតរូបលោក ជួន សុវណ្ណ។[895]*

*នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ ក្នុងប្រតិបត្តិការរួមគ្នាជាមួយកងរាជអាវុធហត្ថ នគរបាលខណ្ឌដូនពេញបានចូលរួមក្នុងការបំបែកដ៏ហិង្សាលើបាតុកម្មរបស់សកម្មជនសិទ្ធិលំនៅឋាន និងដីធ្លី ដែលទាមទារឱ្យដោះលែងអ្នកការពារសិទ្ធិមនុស្សដ៏ល្បីល្បាញម្នាក់ គឺអ្នកស្រី យ៉ោម បុប្ផា។ បាតុករប្រាំនាក់បានរងរបួសធ្ងន់ ដោយសាររងការវាយដំដោយដំបង ឬខែលប្រឆាំងកូដកម្ម។[896] នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ក្នុងប្រតិបត្តិការរួមគ្នាជាមួយកងរាជអាវុធហត្ថ នគរបាលខណ្ឌដូនពេញ បានទប់ស្កាត់ដោយបង្ខំចំពោះសកម្មជនសិទ្ធិដីធ្លី និងលំនៅឋាន ដែលប៉ុនប៉ងធ្វើដំណើរទៅកាន់ទីស្នាក់ការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា នៅភ្នំពេញ ដើម្បីដាក់ញត្តិ។[897] នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ នគរបាលរាជធានីភ្នំពេញ បានវាយទាត់ធាក់ស្ត្រីសកម្មជនសិទ្ធិដីធ្លី និងលំនៅឋានមួយចំនួន ក្នុងពេលបាតុកម្មតវ៉ាប្រឆាំងនឹងការបន្តឃុំខ្លួនអ្នកស្រី យ៉ោម បុប្ផា ដែលជាអ្នកការពារសិទ្ធិមនុស្ស ដោយបង្កឱ្យជនរងគ្រោះយ៉ាងតិចបួននាក់ក្នុងចំណោមជនរងគ្រោះផ្សេងទៀតសន្លប់។[898] នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៣ ពួកគេបានចូលរួមក្នុងប្រតិបត្តិការ "កងកម្លាំងចម្រុះ" ក្នុងការបំបែកការប្រមូលផ្តុំគ្នាដោយអហិង្សារបស់កម្មករ ដែលកំពុងធ្វើកូដកម្មនៅកណ្តាលទី*

---

[894] "បាតុកររោងចក្រកាត់ដេរ ប៉ះទង្គិចគ្នាជាមួយនគរបាល" ***ខេមបូឌា ដេលី*** ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ http://www.cambodiadaily.com/news/garment-factory-protesters-clash-with-police-6449/ (ទទួលបានឬ បានអាន នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២)។

[895] "កម្ពុជាបង្ក្រាបការដើរដង្ហែក្បួន នៅថ្ងៃ ទិវាសិទ្ធិមនុស្ស" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ http://www.phnompenhpost.com/index.php/2012121160214/National-news/cambodia-cracks-down-on-rights-day- march.html (ចូលមើល នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២)។

[896] "នគរបាល និងសន្តិសុខ ប្រើកម្លាំងហួសប្រមាណ បង្ក្រាបអ្នកតវ៉ា ដោយអហិង្សា មកពីបឹងកក់" អង្គការលីកាដូ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ http://www.licadho-cambodia.org/video.php?perm=37 (ចូលមើល នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣), "នគរបាលវាយដំអ្នកតវ៉ាបឹងកក់ បានបង្កឱ្យមនុស្សប្រាំនាក់រងរបួស" អង្គការលីកាដូ et al., សេចក្តីថ្លែងការ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ http://www.licadho-cambodia.org/pressrelease.php?perm=304 (ចូលមើល នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣), ពីប្រភពដដែល (Ibid.)

[897] "APWLD - វេទិកាអាស៊ីប៉ាស៊ីហ្វិកស្តីពី ស្ត្រី ច្បាប់ និងការអភិវឌ្ឍន៍ បានចែកផ្សព្វផ្សាយកម្រងរូបថតរបស់អង្គការលីកាដូ" ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ https://www.facebook.com/apwld.ngo/posts/517840108272525, ចូលមើល នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៣, ពីប្រភពដដែល (Ibid.)

[898] "តម្កល់ទុកការកាត់ទោសដាក់ពន្ធនាគារសកម្មជនប្រឆាំងនឹងការបណ្តេញចេញពីដីធ្លី" ***ខេមបូឌា ដេលី*** ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ http://www.cambodiadaily.com/news/jail-sentence-for-anti-eviction-activist-upheld-31073/ (មើលថ្ងៃទី១៦ មិថុនា ២០១៣), ពីប្រភពដដែល (Ibid.)

*ក្រុងភ្នំពេញ។ ជាថ្មីម្តងទៀត លោក ជួន សុវណ្ណ បានពន្យល់ពីមូលហេតុនៃការចាត់វិធានការបែបនោះថា ដោយសារការប្រមូលផ្តុំគ្នានោះពុំមានការអនុញ្ញាតពីអាជ្ញាធរ។[899] នៅថ្ងៃបន្ទាប់ គាត់បាននិយាយការពារស្រដៀងគ្នានឹងលើកមុនដែរថា ប្រតិបត្តិការរបស់នគរបាល គឺមានភាពចាំបាច់ ដើម្បីទប់ស្កាត់បាតុករតវ៉ាប្រឆាំងនឹងការបណ្តេញចេញពីដីធ្លី មិនឱ្យដាក់ញត្តិនៅព្រះបរមរាជវាំង ដោយបានបង្កឱ្យមានការប្រវាយប្រតប់គ្នា ដែលក្នុងនោះ មានអ្នកដាក់ញត្តិម្នាក់បានរងរបួស។[900]*

## *លោក ជួន សុវណ្ណ និង ការបោះឆ្នោតឆ្នាំ ២០១៣*

*ប្រតិបត្តិការប្រឆាំងនឹងអង្គការសង្គមស៊ីវិល និងសកម្មជននានា ត្រូវបានអនុវត្ត ខណៈការបោះឆ្នោតសកាជាតិ ដែលគ្រោងនឹងធ្វើឡើងនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ជាការប្រកួតប្រជែងគ្នារវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កំពុងខិតចូលមកដល់។ ក្នុងអំឡុងពេលធ្វើយុទ្ធនាការ លោក ជួន សុវណ្ណ បានគាំទ្រដោយចំហ ចំពោះគណបក្សប្រជាជនកម្ពុជា និងលោក ហ៊ុន សែន។ គាត់គឺជាអនុប្រធាននៃក្រុមការងារគណបក្សប្រជាជនកម្ពុជា ប្រចាំស្រុកពារាំង ខេត្តព្រៃវែង និង ជាប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជា ប្រចាំសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។[901] គាត់បានបញ្ជូនកងកម្លាំងនគរបាល ក្រោមបង្គាប់របស់គាត់ ទៅធ្វើការឃោសនាជំនួសមុខគាត់ ឱ្យគណបក្សប្រជាជនកម្ពុជា និង លោក ហ៊ុន សែន។[902] លើសពីនេះ នៅដើមខែមិថុនា ឆ្នាំ២០១៣ លោក ជួន សុវណ្ណ និងនគរបាលក្រោម*

---

[899] "កូដកម្មនៅណាហ្គាវើល បញ្ចប់ដោយកងកម្លាំង" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ http://www.phnompenhpost.com/2013061966368/National/nagaworld-strike-ends-with-force.html (ចូលមើល នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣)។

[900] "សកម្មជន និងនគរបាល បានប៉ះទង្គិចគ្នា នៅព្រះបរមរាជវាំង" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ http://www.phnompenhpost.com/2013061966366/National/activists-cops-clash-at-palace.html (ចូលមើល នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣)។

[901] "លោក ជួន សុវណ្ណ ចូលរួមក្នុងពិធីចម្រើនព្រះជន្ម និងស្រោច ឬស្រង់ទឹកជនចាស់ជរា នៅក្នុងស្រុកពារាំង" ថ្ងៃទី៩ មេសា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/61905-2013-04-09-07-35-33.html (មើល នៅថ្ងៃទី១០ មេសា ២០១៣), "សង្កាត់បឹងទំពុន បើកវេទិកាសាធារណៈ ដើម្បីស្តាប់អំពី ការលំបាក និងសំណើរបស់ពលរដ្ឋ" ថ្ងៃទី២៩ មេសា ឆ្នាំ២០១៣ http://www.dap-news. com/2011-06-14-02-39-55/63060-2013-04-29-09-15-47.html (មើលនៅថ្ងៃទី៣០ មេសា ២០១៣)។

[902] "កងកម្លាំងនគរបាលខណ្ឌពោធិ៍សែនជ័យ ទទួលការហ្វឹកហ្វឺន សម្រាប់បង្កើនសន្តិសុខ និងសណ្តាប់ធ្នាប់ (មានខ្សែវីដេអូ)", ថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០១៣ http://www.dap-news.com/2011-06-14-02- 39-55/70246-2013-08-15-04-44-32.html (ចូលមើល នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣), "លោក ប៊ិន សំអាត យកអំណោយ និងថវិកា ចែកជូនប្រជាពលរដ្ឋនៅភូមិព្រៃខ្លា", ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/64305-2013-05-18-04-57-21.html (ចូលមើល នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៣), "លោក នេត វុត្ថា ចុះសួរសុខទុក្ខប្រជាជនក្រីក្រនៅភូមិត្នោត ៤ និងចែកអំណោយដល់ពួកគេ", ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/64283-2013-05-18-02-21-49.html (ចូលមើល នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៣)។

បង្គាប់របស់លោក បានសម្របសម្រួលអោយមានបាតុកម្មមួយ នៅក្នុងទីក្រុងភ្នំពេញប្រឆាំងនឹងលោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ។[903]

ក្នុងអំឡុងពេលធ្វើយុទ្ធនាការបោះឆ្នោត អ្នកចូលរួមយុទ្ធនាការឃោសនារបស់លោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា បានព្រមានម្តងហើយម្តងទៀតថា ប្រសិនបើបក្សប្រឆាំងឈ្នះការបោះឆ្នោត នោះ "សង្គ្រាម" អាចនឹងកើតមានឡើង ដែលផ្តើមចេញពីគណបក្សប្រជាជនកម្ពុជា ដើម្បីការពារផលប្រយោជន៍ជាតិ។[904] ការណ៍នេះនឹងរាប់បញ្ចូលទាំងការបន្តធ្វើជានាយករដ្ឋមន្ត្រីរបស់លោក ហ៊ុនសែន ដើម្បីបញ្ចៀសស្ថានភាព "ក្រឡាប់ចាក់" នៅក្នុងប្រទេសកម្ពុជា។[905] ក្នុងបរិបទនេះ លោក ជួន សុវណ្ណ បាននិយាយនៅពីរបីថ្ងៃមុនថ្ងៃបោះឆ្នោតថា នគរបាលមានគម្រោងដាក់ពង្រាយកងកម្លាំង ៥,៥០០ (ប្រាំពាន់ប្រាំរយ) នាក់ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ និងក្រោយថ្ងៃនោះ ដើម្បីទប់ស្កាត់អំពើហិង្សានានា ដែលអាចកើតចេញពីការបដិសេធរបស់គណបក្សប្រឆាំង ចំពោះការប្រកាសជ័យជំនះរបស់គណបក្សប្រជាជនកម្ពុជា។[906]

## ជួន សុវណ្ណ ការបង្ក្រាបចលាចលក្រោយការបោះឆ្នោតពីឆ្នាំ ២០១៣-២០១៤ និងពីពេលនោះមក

---

[903] "មនុស្សរាប់ពាន់នាក់ ចេញមកប្រឆាំងនឹងអនុប្រធានគណបក្សសង្គ្រោះជាតិ" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ http://www.phnompenhpost.com/2013061066176/National/thousands-turn-out-against-cnrp-deputy.html (ចូលមើល នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣), "ពលរដ្ឋទូទាំងប្រទេស បានរៀបចំបាតុកម្មនៅព្រឹកនេះប្រឆាំងនឹងលោក កឹម សុខា" ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/65670-2013-06-09-01-36-24.html (ចូលមើល នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣)។

[904] "គ្រាន់តែដោយសារបំណងប្រាថ្នាចង់ផ្លាស់ប្តូររបបដឹកនាំ ប្រទេសកម្ពុជាបានក្លាយជាទេសរងគ្រោះនៃសង្គ្រាម និងការវិនាសដល់ឫសគល់", ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ http://dap-news.com/2011-06-14-02-39-55/66861-2013-06-25-02-44-12.html (ចូលមើល នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣), "លោក ហ៊ុន សែន និយាយថា សង្គ្រាមស៊ីវិល គឺជាកំហុសរបស់គណបក្សប្រឆាំង" ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ http://www.cambodiadaily.com/elections/hun-sen-says-civil-war-would-be-oppositions-fault-30249/ (ទទួលបាន ឬ ពានអាន នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣), "តើការគំរាមកំហែងរបស់លោក ហ៊ុន សែន ថាមានសង្គ្រាម បានប្រែក្លាយទៅជាសន្លឹកឆ្នោតឬ ?" *ខេមបូឌា ដេលី* ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៣ http://www.cambodiadaily.com/news/will-hun-sens-threat-of-war-translate-into-votes-32182/ (ចូលមើលនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣)

[905] "សម្តេចតេជោ ប្រកាសអំពីការផ្លាស់ប្តូរអាណត្តិនាយករដ្ឋមន្ត្រីពី ទីបួន ទៅជាទីប្រាំ" ( = ), ថ្ងៃទី៨ខែមិថុនាឆ្នាំ២០១៣)http:/www.dap-news.com/2011-06-14-02-39-55/65620-2013-06-08-04-47- 52.html (ចូលមើល នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៣), "ការវិភាគអំពី សេចក្តីប្រកាសរបស់សម្តេចតេជោអំពីការផ្លាស់ប្តូរអាណត្តិនាយករដ្ឋមន្ត្រីពី ទីបួន ទៅជាទីប្រាំ" (==), ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/65717-2013-06-10-03-44-31.html(ចូលមើល នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣)។

[906] "សមត្ថកិច្ចសម្រេចចិត្តដោះលែងជនសង្ស័យ ៨នាក់ ដែលបានបើកការបាញ់ប្រហារនៅផ្ទះរបស់លោកឧកញ៉ា ឃី គីមលុន" (!: ), ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៣ http://kpt-news.com/index.php?option=com_content&view=article&id=30465:2013-07-06-10-01-56&catid=1:latest&Itemid=65 (ចូលមើល នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៣), "ស្ថានីយ៍បោះឆ្នោត៖ ការណែនាំរបស់នគរបាល ត្រូវបានដាក់ចេញ" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ http://www.phnompenhpost.com/national/polling-station-police-directives-handed-down (ចូលមើល នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣)។

*បញ្ហានានា ដែលបានកើតពីការបន្លំរបស់គណបក្សប្រជាជនកម្ពុជា និងភាពមិនប្រក្រតីនៅក្នុងការបោះឆ្នោតនោះ បានធ្វើឱ្យប្រទេសកម្ពុជា ធ្លាក់ក្នុងវិបត្តិសិទ្ធិមនុស្ស។[907] នៅថ្ងៃបោះឆ្នោត លោក ជួន សុវណ្ណ បានដឹកនាំកងកម្លាំងនគរបាល១០០នាក់ ដាក់ពង្រាយដើម្បីបង្រ្កាបកុបកម្ម នៅមណ្ឌលបោះឆ្នោតមួយ ក្នុងរាជធានីភ្នំពេញ ដែលបង្កឡើងដោយក្រុមមនុស្សតវ៉ាចំពោះអ្វីដែលពួកគេហៅថា ជាការបន្លំក្នុងការបោះឆ្នោតនៅទីតាំងបោះឆ្នោតនោះ ហើយនៅអំឡុងពេលនោះ រថយន្តពីរគ្រឿងរបស់កងរាជអាវុធហត្ថត្រូវបានដុតបំផ្លាញ។[908] ចាប់ពីខែសីហា ឆ្នាំ២០១៣ មក បាតុកម្មនានាបានចាប់ផ្តើមកើតមានប្រឆាំងនឹងលទ្ធផលបោះឆ្នោតផ្លូវការ ដោយបានអំពាវនាវឱ្យមានការស៊ើបអង្កេតលទ្ធផលបោះឆ្នោត កំណែទម្រង់ការបោះឆ្នោត ទាមទារការបោះឆ្នោតឡើងវិញ និងទាមទារឱ្យលោក ហ៊ុន សែន ចុះពីតំណែង។ គណបក្សសង្គ្រោះជាតិបានរៀបចំបាតុកម្ម ចាប់ពីខែកញ្ញា ហើយគណបក្សនេះ ក៏បានធ្វើពហិការមិនចូលរួមក្នុងសភាជាតិផងដែរ។[909]*

*នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ លោក ជួន សុវណ្ណ បានចាប់ផ្តើមអនុវត្តបទបញ្ជាពី "ថ្នាក់លើ" ដើម្បីធ្វើការហ្វឹកហ្វឺននគរបាលរាជធានីភ្នំពេញ និងនគរបាលមកពីគ្រប់ខណ្ឌទាំងអស់នៃរាជធានីភ្នំពេញ អំពីរបៀប "ការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ"។[910] នៅថ្ងៃជាមួយគ្នានោះដែរ គាត់បានបញ្ជាដោយខុសច្បាប់ ឱ្យឃុំខ្លួនម្ចាស់ហាងបោះពុម្ពម្នាក់ និងបុគ្គលិករបស់គាត់ ព្រមទាំងនិស្សិតពីរនាក់ ជាបណ្តោះអាសន្ន ពាក់ព័ន្ធនឹងការចោទប្រកាន់ថា បានបោះពុម្ព និងមានផែនការចែកចាយខិតប័ណ្ណដែលអំពាវនាវឱ្យមានការផ្លាស់ប្តូរនយោបាយដោយសន្តិវិធី។[911] គិតត្រឹមថ្ងៃទី២៣ ខែសីហា ការហ្វឹកហ្វឺននេះត្រូវបានពង្រីកទៅដល់*

---

907 អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ "ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ៖ ការអនុម័តលើលទ្ធផល UPR របស់កម្ពុជា" សេចក្តីថ្លែងការណ៍ផ្ទាល់មាត់ នៅថ្ងៃទី២៦ខែមិថុនាឆ្នា២០១៤ http://www.hrw.org/news/2014/06/26/un-human-rights-council-adoption-upr-outcome-cambodia.

908 "វីដេអូ ៖ អ្នកបោះឆ្នោត ដែលមានកំហឹង ធ្វើកូដកម្មនៅស្ទឹងមានជ័យ" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៣ http://www.phnompenhpost.com/video/video-angry-voters-riot-stung-meanchey (ចូលមើល នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣)។

909 អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ "ការដាក់ស្នើរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ទៅគណៈ  កម្មាធិការសិទ្ធិមនុស្ស ឱ្យពិនិត្យស្ថានភាពនៅកម្ពុជា" ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៤។

910 "កងកម្លាំងនគរបាលខណ្ឌពោធិ៍សែនជ័យ បានទទួលការហ្វឹកហ្វឺន ដើម្បីបង្កើនសន្តិសុខ និងសណ្តាប់ធ្នាប់ (មានវីដេអូ" ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02- 39-55/70246-2013-08-15-04-44-32.html (ចូលមើល នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣), "លោកស្នងការនគរបាលរាជធានីភ្នំពេញ ចុះពិនិត្យ និងពង្រឹងភារកិច្ចរបស់នគរបាល នៅខណ្ឌដង្កោ"  ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ http://kpt-news.com/index.php?option=com_content&view=article&id=32655:2013-08-23-07-34-02&catid=1:latest&Itemid=65 (ចូលមើល នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣), "នគរបាលខណ្ឌដូនពេញ ប្រមូលផ្តុំគ្នា ដើម្បីហ្វឹកហ្វឺនបង្កើនសមត្ថភាពការពារសន្តិសុខ ជូនប្រជាពលរដ្ឋ"  ថ្ងៃទី២៤ សីហា ២០១៣ http://www.dap-news.com/2011-06-14-02-39-55/70801-2013-08-24-08-09-24.html (ចូលមើល នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣)។

911 "សញ្ញានៃសន្តិភាព បានត្រលប់បញ្ច្រាស ៖ និស្សិតពីរនាក់ ត្រូវបានធ្លាក់ក្នុងអន្ទាក់" អង្គការលីកាដូ et al., សេចក្តីថ្លែងការណ៍ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ http://www.licadho-cambodia.org/pressrelease.php?perm=320 (ចូលមើល នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣), ពីប្រភពដដែល (Ibid.)

នគរបាលរដ្ឋបាលសង្កាត់ ដែលត្រូវបានបំពាក់គ្រឿងបរិក្ខារប្រឆាំងនឹងកុបកម្ម ដូចនគរបាលខណ្ឌទាំងអស់ដែរ ដោយសារមានការបង្កើនថវិកាពីក្រសួងមហាផ្ទៃក្រោយការបោះឆ្នោត។[912] ថវិកានេះក៏ត្រូវបានចំណាយលើការទិញកាំភ្លើងខ្លីដែលលោក ជួន សុវណ្ណ យកទៅចែកឱ្យមន្ត្រីនគរបាលផងដែរ។[913] តាំងនាមឱ្យលោក ជួន សុវណ្ណ លោក ជួន ណារិន ដែលជាស្នងការរងនគរបាលរាជធានីភ្នំពេញ បានប្រកាសថា នគរបាល "ត្រូវការពារដាច់ខាតចំពោះរដ្ឋាភិបាលស្របច្បាប់ និងនាយករដ្ឋមន្ត្រីស្របច្បាប់ ដែលកើតចេញពីលទ្ធផលនៃការបោះឆ្នោត" នោះគឺ គណបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់លោក ហ៊ុន សែន។[914]

នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៣ លោក ជួន សុវណ្ណ បានបញ្ជាដោយផ្ទាល់នៅក្នុងវគ្គបណ្តុះបណ្តាល និងលំហាត់សមយុទ្ធដ៏ធំមួយសម្រាប់នគរបាលរាជធានី និងខណ្ឌចំនួនជាង ២,០០០ (ពីរពាន់) នាក់ ដោយមានបំពាក់គ្រឿងបរិក្ខារប្រឆាំងកុបកម្មយ៉ាងពេញលេញផង ដែលក្នុងវគ្គហ្វឹកហ្វឺននោះ នគរបាលទាំងនោះបានអនុវត្តការដាក់ពង្រាយរនាំងការពារ ការប្រើប្រាស់គ្រាប់បែកផ្សែង និងការប្រើកាណុងបាញ់ទឹកនៃរថយន្តពន្លត់អគ្គីភ័យ។ គាត់បាននិយាយអំពី "ការបង្ក្រាបជាទ្រង់ទ្រាយធំ" ដើម្បី "ការពារប្រទេសជាតិ ដែលស្ថិតក្រោមការដឹកនាំស្របច្បាប់របស់គណបក្សប្រជាជនកម្ពុជា"។[915] ចាប់ពីព្រឹកព្រលឹមថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ នគរបាលថ្នាក់ជាតិ រាជធានី និងស្រុក ខណ្ឌ បានចូលរួមជាមួយកងរាជអាវុធហត្ថថ្នាក់ជាតិ ខេត្ត រាជធានី និងស្រុក ខណ្ឌ ក្នុងបំណងរាំងដល់ការប្រមូលផ្តុំគ្នាដ៏ធំមួយរបស់គណបក្សសង្គ្រោះជាតិ នៅទីលានប្រជាធិបតេយ្យ នៅថ្ងៃនោះ និងធ្វើឱ្យការប្រមូលផ្តុំគ្នាសំខាន់ៗនៅកន្លែងផ្សេងទៀតក្នុងរាជធានី មិន

---

[912] "លោកស្នងការនគរបាលរាជធានីភ្នំពេញ ចុះពិនិត្យ និងពង្រឹងភារកិច្ចរបស់នគរបាល នៅខណ្ឌដង្កោ" ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ http://kpt-news.com/index.php?option=com_content&view=article&id=32655:2013-08-23-07-34-02&catid=1:latest&Itemid=65 (ចូលមើល នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣), "នគរបាលខណ្ឌដូនពេញ ប្រមូលផ្តុំគ្នា ដើម្បីហ្វឹកហ្វឺនបង្កើនសមត្ថភាពការពារសន្តិសុខ ជូនប្រជាពលរដ្ឋ" ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/70801-2013-08-24-08-09-24.html (ចូលមើល នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣)។

[913] "កាំភ្លើងខ្លីចំនួន ២៧០ ដើម ត្រូវបានប្រគល់ដល់នគរបាលចរាចរ និងនគរបាលមកពីខណ្ឌទាំង ៩ ដើម្បីបង្កើនសន្តិសុខ" ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/69791-2013-08-07-08-25-56.html (ចូលមើល នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៣)។

[914] "នគរបាលខណ្ឌដូនពេញ ប្រមូលផ្តុំគ្នា ដើម្បីហ្វឹកហ្វឺនបង្កើនសមត្ថភាពការពារសន្តិសុខ ជូនប្រជាពលរដ្ឋ" ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ http://www.dap-news.com/2011-06-14-02-39-55/70801-2013-08-24-08-09-24.html (ចូលមើល នៅថ្ងៃទី២៤ ខែសីហា)។

[915] "លោក ជួន សុវណ្ណ ដឹកនាំនគរបាលជាង ២០០នាក់ ចូលរួមក្នុងការហ្វឹកហ្វឺន ដើម្បីពង្រឹងសុវត្ថិភាព ជូនប្រជាពលរដ្ឋ" ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១ http://kpt-news.com/index.php?option=com_content&view=article&id=33142:2013-09-02-04-35-41&catid=1:latest&Itemid=65 (ចូលមើល នៅថ្ងៃទី២ កញ្ញា ឆ្នាំ២០១៣), "ក្នុងស្ថានភាពផ្ទុយគ្នាគឺ នគរបាល និង គណបក្សប្រឆាំង បានត្រៀមសម្រាប់បាតុកម្ម" *ខេមបូឌា ដេលី* ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១ http://www.cambodiadaily.com/elections/in-contrasting-styles-police-opposition-prepare-for-protests-41545/ (ចូលមើល នៅថ្ងៃទី៣ ខែកញ្ញាឆ្នាំ២០១៣), "នគរបាលជាង ២.០០០នាក់ ហ្វឹកហ្វឺនបង្កើនសមត្ថភាព រក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ (មានវីដេអូ)" ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៣ http://www.dap-news.com/ 2011-06-14-02-39-55/71251-2013-09-01-00-30-17.html (ចូលមើលនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៣)។

អាចប្រព្រឹត្តទៅបាន។ នៅរសៀលនោះ លោក ជួន សុវណ្ណ បានបញ្ជាដោយផ្ទាល់លើក្រុមនគរបាល ដែលត្រូវបានដាក់ពង្រាយឱ្យទប់ស្កាត់បាតុករ មិនឱ្យបំបែក ឬទម្លាយរនាំងការពារ ដែលបានដាក់មិនឱ្យមានការប្រមូលផ្តុំគ្នានៅកន្លែងផ្សេងទៀត ក្រៅពីទីលានប្រជាធិបតេយ្យ។ នគរបាលទាំងនេះបានប្រើប្រាស់កាណុងបាញ់ទឹក និងគ្រាប់បែកផ្សែង ឬឧស្ម័នបង្ហូរទឹកភ្នែក ដើម្បីគ្រប់គ្រងអ្នកមានបំណងធ្វើបាតុកម្មទាំងនោះ។[916]

នៅទីនោះ លោក ជួន សុវណ្ណ បានពន្យល់ថា គាត់កំពុងអនុវត្តការដាក់កំហិត ដែលចេញដោយសាលារាជធានី និងទម្លាក់ការទទួលខុសត្រូវលើគណបក្សសង្គ្រោះជាតិចំពោះអំពើហិង្សា ដោយចោទថា គណបក្សនេះបានបរាជ័យក្នុងការធានាឱ្យបាននូវការគោរពចំពោះការដាក់កំហិតទាំងនេះ ដែលជាហេតុបង្កឱ្យមានសកម្មភាពខុសច្បាប់នេះ។[917] នៅល្ងាចថ្ងៃទី១៥ ខែកញ្ញា បន្ទាប់ពីការប្រមូលផ្តុំគ្នារបស់គណបក្សសង្គ្រោះជាតិនៅទីលានប្រជាធិបតេយ្យបានបញ្ចប់ទៅដោយគ្មានឧប្បត្តិហេតុអ្វីកើតឡើងនោះមក ការប៉ុនប៉ងជាបន្តបន្ទាប់របស់នគរបាល និងកងកម្លាំងសន្តិសុខដទៃទៀត ក្នុងការបិទសេរីភាពនៃការផ្លាស់ទីនៅក្នុង និងជុំវិញទីក្រុងភ្នំពេញស្ទើរតែទាំងស្រុង បានបង្កឱ្យមានភាពចលាចលសង្គម ដែលកងកម្លាំងសន្តិសុខបានធ្វើការបង្ក្រាបយ៉ាងហិង្សា រួមទាំងតាមរយៈការប្រើប្រាស់កងម្លាំងច្រើនហួសប្រមាណ និងប្រកបដោយគ្រោះថ្នាក់ដែលបានបង្កឱ្យមនុស្សម្នាក់ស្លាប់ និងរបួសធ្ងន់ធ្ងរយ៉ាងហោចណាស់១២នាក់ ផ្សេងទៀត។ គ្រាប់កាំភ្លើងដែលសម្លាប់ជីវិតមនុស្សនោះ គឺបាញ់ចេញពីកាំភ្លើងខ្លីមួយដែលត្រូវបានចែកឱ្យនគរបាលប្រើប្រាស់។[918]

នៅខណៈលោក ជួន សុវណ្ណ ធ្វើជាអធិបតីក្នុងការធ្វើសមយុទ្ធនគរបាលដ៏ធំថ្មីមួយ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ស្របគ្នានឹងកម្មករមកពីរោងចក្រកាត់ដេរមួយបានដើរដង្ហែក្បួន សំដៅឆ្ពោះទៅកាន់គូមិគ្រឹះរបស់លោក ហ៊ុន សែន នៅកណ្តាលរាជធានីភ្នំពេញ ដើម្បីតវ៉ាសុំអន្តរាគមន៍ស្វែងរកដំណោះស្រាយពីរដ្ឋាភិបាល

---

916 "គ្រាប់បែកផ្សែងត្រូវបានបាញ់ទៅលើអ្នកតវ៉ា" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ http://www.phnompenhpost.com/national/smoke-grenades-fired-protesters (ចូលមើល នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣)។

917 "បាតុកម្មប្រែក្លាយជារឿងក្រៀមក្រំចិត្ត" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ http://www.phnompenhpost.com/national/protest- takes-dark-turn (ចូលមើល នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣), "ទូរទស្សន៍កម្ពុជា មិនផ្សព្វផ្សាយអំពី បាតុកម្មនានា" *ខេមបូឌា ដេលី* ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ http://www.cambodiadaily.com/elections/cambodian-tv-fails-to-cover-cnrp-protests-42377/ (ចូលមើលនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣) ឡើយ, "គ្រាប់បែកផ្សែងត្រូវបានបាញ់ទៅលើអ្នកតវ៉ា" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ http://www.phnompenhpost.com/national/smoke-grenades-fired-protesters (ចូលមើលនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៣)។

918 "កម្ពុជា៖ ដោះលែងមនុស្សទាំង ៦នាក់ ដែលត្រូវបានចាប់ខ្លួនដោយចៃដន្យនៅក្នុងភាពចលាចល" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤ http://www.hrw.org/news/2014/02/19/cambodia-free-6-randomly-arrested-during-unrest; ពីប្រភពដដែល (Ibid.)

*នៅក្នុងវិវាទមួយចំនួនជាមួយអ្នកគ្រប់គ្រងរោងចក្ររបស់ពួកគេ។ នៅពេលដឹងពីបញ្ហានេះ លោក ជួន សុវណ្ណ បានបញ្ជាឱ្យដាក់ពង្រាយនគរបាលដើម្បី "ចាប់ខ្លួនមេក្មេងនោះ"។ នគរបាលដែលត្រូវបានដឹកតាមរថយន្តទៅកាន់ទីតាំងនោះ បានប៉ុនប៉ងបង្ក្រាបកម្មករ ដែលធ្វើបាតុកម្មទាំងនោះ ដោយបានវាយដំលើទាំងអ្នកដែលរឹងទទឹង ទាំងអ្នកដែលបានព្យាយាមគេចខ្លួន។*[919]

*នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ លោក ជួន សុវណ្ណ បានដឹកនាំដោយផ្ទាល់ នៅក្នុងការបង្ក្រាបបាតុកម្មជាថ្មីរបស់កម្មករមកពីរោងចក្រនោះ ដោយបានដាក់បទបញ្ជាឱ្យវាយប្រហារ ក្នុងប្រតិបត្តិការដែលប្រើប្រាស់កម្លាំងនគរបាលរាជធានី និងនគរបាលខណ្ឌ ក្នុងការបំបែកក្បួនដង្ហែដោយអហិង្សារបស់ក្រុមកម្មករ និងបន្ទាប់មក បានបង្ក្រាបភាពចលាចលសង្គម ដែលផ្ទុះឡើងចេញពីការបង្ក្រាបនោះ នៅខណ្ឌមានជ័យ រាជធានីភ្នំពេញ។*[920] *ក្នុងអំឡុងពេលនៃប្រតិបត្តិការនោះ ការបាញ់ដោយមិនរើសមុខរបស់នគរបាល បានសម្លាប់អ្នកឈរមើលហេតុការណ៍ម្នាក់ ហើយមនុស្សប្រាំបួននាក់ផ្សេងទៀតរបួស ដោយសារការប្រើប្រាស់អាវុធដោយមិនចាំបាច់របស់នគរបាល។ ការផ្ទុះអាវុធរបស់នគរបាលបានកើតឡើង បន្ទាប់ពីលោក ជួន សុវណ្ណ បានច្រានចោលការប៉ុនប៉ងរបស់មន្ត្រីសិទ្ធិមនុស្សក្នុងការបន្ធូរបន្ថយស្ថានការណ៍នោះ។*[921]

*បន្ទាប់ពីរដ្ឋាភិបាលបានកំណត់យកថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ ជាឱសានវាទឱ្យបញ្ឈប់នូវអ្វី ដែលខ្លួនចាត់ទុកតាមទំនើងចិត្តថា ជាសកម្មភាពកូដកម្មខុសច្បាប់នោះ  នគរបាលរាជធានី និងនគរបាលខណ្ឌស្ថិតក្នុងចំណោមកងកម្លាំង ដែលត្រូវបានដាក់ពង្រាយ ដើម្បីអនុវត្តការហាមឃាត់នោះ។ ទោះជាយ៉ាងណា លោក ជួន សុវណ្ណ មិនបាននៅក្នុងប្រទេសឡើយ នៅពេលកងកម្លាំងសន្តិសុខប្រើអំពើហិង្សាបង្ក្រាប ដែលបណ្តាលឱ្យមនុស្សប្រាំមួយនាក់ស្លាប់នោះ។*[922]

---

[919] "នគរបាល ហ្វឹកហ្វឺននៅទីលានប្រជាធិបតេយ្យ នៅពេលអ្នកតវ៉ាផ្តោតលើគេហដ្ឋានលោក ហ៊ុន សែន" *ខេមបូឌា ដេលី* ថ្ងៃទី២២ តុលា ឆ្នាំ២០១៣ http://www.cambodiadaily.com/news/police-train-at-freedom-park-as-protesters-target-hun-sens-house-2-45638/ (ថ្ងៃទី២៣ តុលា ឆ្នាំ២០១៣)។

[920] "ជួន សុវណ្ណ វាយប្រហារកម្មករ នៅថ្ងៃទី១២ វិច្ឆិកា២០១៣" https://www.youtube.com/watch?v=f-gSJm5UNZc (មើលនៅថ្ងៃទី២៩ វិច្ឆិកា ២០១៣)

[921] "កម្ពុជា ៖ ការជំនុំជម្រះករណីស្ទឹងមានជ័យ មានកំហុសខ្លាំង" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៤ http://www.hrw.org/news/2014/05/11/cambodia-steung-meanchey-trial-deeply-flawed; "មានមនុស្សម្នាក់ស្លាប់ ប្រាំពីរនាក់ទៀតរងរបួស នៅពេលប៉ះទង្គិចគ្នាដោយហិង្សា ក្នុងពេលមានបាតុកម្មរបស់កម្មកររោងចក្រ SL" អង្គការលីកាដូ et al., សេចក្តីថ្លែងការណ៍ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ http://www.licadho- cambodia.org/pressrelease.php?perm=327 (ចូលមើលនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣), ពីប្រភពដដែល (Ibid.)

[922] "លោក ម៉ក់ ជីតូ ឡើងជាស្នងការស្តីទី នគរបាលរាជធានី ជំនួសលោក ជួន សុវណ្ណ ១២ថ្ងៃ"  ( lfl Cfl ., s s s lfl s ) ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ http://kohsantepheapdaily.com.kh/article/86707.html (ចូលមើល នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣), អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែនរ៉ៃត៍វ៉ច្ឆ "ការដាក់ស្នើរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ យូមែន  រ៉ាយ វ៉ច្ឆ ឱ្យគណៈកម្មាធិការសិទ្ធិមនុស្ស ពិនិត្យស្ថានភាពនៅកម្ពុជា" ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៤, "កម្មករ

*លោក ជួន សុវណ្ណ បានវិលត្រឡប់មកកម្ពុជាវិញនៅចំ ឬ ម្ដុំថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ ជាថ្ងៃ ដែលរដ្ឋាភិបាលរបស់លោក ហ៊ុន សែន បានហាមឃាត់តាមទំនើងចិត្តចំពោះបាតុកម្មទាំងអស់។*[923] *ចាប់ពីពេលនោះរហូតដល់ចុងខែកក្កដា ឆ្នាំ២០១៤ អាជ្ញាធរបានអនុវត្តការហាមឃាត់នេះដោយដាក់ពង្រាយកងកម្លាំងសន្តិសុខ រួមមាននគរបាលរាជធានី ខណ្ឌ និងសង្កាត់ ដើម្បីបំបែកការប្រមូលផ្ដុំ ដែលពេលខ្លះសូម្បីតែការប្រមូលផ្ដុំគ្នាតូចតាចបំផុត និង អហិង្សាទាំងស្រុងក៏បំបែកដែរ ដោយប្រើប្រាស់កម្លាំងដែលមិនចាំបាច់ទាំងមិនមានបញ្ហាសន្តិសុខជាក់ស្ដែង។ ក្នុងអំឡុងពេលនោះ នគរបាល និងកងកម្លាំងសន្តិសុខផ្សេងទៀត ក៏បានកាន់កាប់ទីលានប្រជាធិបតេយ្យ ដោយប្រែក្លាយទីនោះ ទៅជាជំរំកងកម្លាំងប្រដាប់អាវុធ។*[924] *លោក ជួន សុវណ្ណ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រតិបត្តិការទាំងនោះ។*[925]

*នៅថ្ងៃទី១៩ និង ទី២០ ខែមករា ឆ្នាំ២០១៤ នគរបាលរាជធានីភ្នំពេញ បានឃុំខ្លួនមេដឹកនាំសហជីពគឺ លោក សុខ ឈុនអ៊ីង អស់រយៈពេលមួយយប់ តាមទំនើងចិត្ត បន្ទាប់ពីចាប់ខ្លួនគាត់ ក្នុងពេលនគរបាលប៉ុនប៉ងបំបែកការប្រមូលផ្ដុំអហិង្សាមួយរបស់ក្រុមសង្គមស៊ីវិល ដែលអំពាវនាវឱ្យមានការដោះលែងមនុស្ស២៣នាក់ ដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ថ្ងៃទី២-៣ ខែមករា។*[926] *នៅថ្ងៃទី២៦ ខែមករា លោក ជួន សុវណ្ណ បានបញ្ជាកងកម្លាំងចម្រុះ រួមទាំងកងរាជអាវុធហត្ថផង អោយបំបែកយ៉ាងហិង្សាលើក្រុមមនុស្ស ដែលកំពុងប្រមូលផ្ដុំគ្នានៅជិតទីលានប្រជាធិបតេយ្យ ដើម្បីទាមទារឱ្យបង្កើនប្រាក់ឈ្នួលដល់កម្មករ និងទាមទារឱ្យដោះលែងមនុស្សទាំង២៣នាក់។*[927] *ការបង្ក្រាបយ៉ាងហិង្សានោះបានបណ្ដាលឱ្យ*

---

រោងចក្រម្នាក់ដែលរងរបួសក្នុងព្រឹត្តិការណ៍នៃការបង្ក្រាបនាថ្ងៃទី៣ ខែមករា បានទទួលមរណភាព នៅព្រឹកមិញនេះ ដោយមូលហេតុមិនទាន់បានកំណត់ច្បាស់" អង្គការលីកាដូ ព័ត៌មានរហ័ស ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៤ http://www.licadho-cambodia. org/flashnews.php?perm=62 (ចូលមើលនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤), ពីប្រភពដដែល (Ibid.)

923 "លោក ម៉ក់ ជីតូ ឡើងជាស្នងការស្ដីទី នគរបាលរាជធានី ជំនួសលោក ជួន សុវណ្ណ ១២ថ្ងៃ" ( Ifl Cfl ., s s s Ifl s ) ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ http://kohsantepheapdaily.com.kh/article/86707.html (ចូលមើល នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣) http://kohsantepheapdaily.com.kh/article/86707.html (accessed December 30, 2013).

924 ពីប្រភពដដែល (Ibid.)

925 "សកម្មជន១១នាក់ត្រូវបានចាប់ខ្លួន ដោយសារការយល់ឃើញថា "បានជះឥទ្ធិពលលើសណ្ដាប់ធ្នាប់សាធារណៈ"" *ខេមបូឌា ដេលី* ថ្ងៃទី២២ មករា ២០១៤ http://www.cambodiadaily.com/news/eleven-activists-arrested-for-views-that-impact-public-order-50934/ (មើលថ្ងៃទី២៣មករា ឆ្នាំ២០១៤)

926 "មេដឹកនាំសមាគមម្នាក់ទៀត ត្រូវបានចាប់ខ្លួន ក្នុងពេលមានការជួបជុំគ្នា ដើម្បីអំពាវនាវឲ្យមានការដោះលែងមេដឹកនាំសមាគម និងកម្មកររោងចក្រទាំង ២៣នាក់" ព័ត៌មានរហ័សរបស់អង្គការលីកាដូ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៤ http://www.licadho-cambodia.org/flashnews.php?perm=26 (ចូលមើល នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៤), ពីប្រភពដដែល (Ibid.)

927 "ការប្រមូលផ្ដុំរបស់សហជីព និងសមាគម ប្រែក្លាយទៅការប៉ះទង្គិចគ្នាយ៉ាងហិង្សា" ព័ត៌មានរហ័សរបស់អង្គការលីកាដូ ថ្ងៃទី២៦ ខែ មករា ឆ្នាំ២០១៤

*មនុស្សយ៉ាងហោចណាស់ប្រាំបីនាក់រងរបួស។ នៅថ្ងៃបន្ទាប់ គឺថ្ងៃទី២៧ ខែមករា នគរបាលក្នុងប្រតិបត្តិការជាមួយកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានវាយប្រហារលើការដើរដង្ហែក្បួនរបស់លោក ម៉ម សូណង់ដូ ដែលជាម្ចាស់ប្រព័ន្ធផ្សព្វផ្សាយមួយ និងអ្នកគាំទ្រប្រមាណជា ១,០០០ (មួយពាន់) នាក់ ដែលទាមទារឱ្យរដ្ឋាភិបាលអនុញ្ញាតដល់ការពង្រីកសមត្ថភាពផ្សព្វផ្សាយវិទ្យុរបស់គាត់ និងផ្តល់អាជ្ញាប័ណ្ណបើកស្ថានីយ៍ទូរទស្សន៍ បណ្តាលឱ្យបាតុករយ៉ាងហោចណាស់ប្រាំបីនាក់រងរបួស។*[928]

*នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤ នគរបាលក្រោមបង្គាប់លោក ជួន សុវណ្ណ បានបណ្តេញអ្នកតវ៉ាចេញពីអគារមួយ ដែលពួកគេកាន់កាប់នៅក្នុងតំបន់បូរីកីឡា ក្រុងភ្នំពេញ បណ្តាលឱ្យមនុស្សយ៉ាងហោចណាស់ប្រាំនាក់របួស។*[929] *នៅថ្ងៃទី២០ ខែកុម្ភៈ គាត់បានបំបែកការប្រមូលផ្តុំតូចមួយរបស់សកម្មជនជាយុវជន ដែលប៉ុនប៉ងរំលឹកទិវាយុត្តិធម៌សង្គមពិភពលោកនៅជិតទីលានប្រជាធិបតេយ្យ បណ្តាលឱ្យមនុស្សម្នាក់របួស ហើយអ្នករបួសនោះ ក៏ត្រូវបានឃុំខ្លួនបណ្តោះអាសន្នផងដែរ។*[930] *នៅថ្ងៃទី២៧ កុម្ភៈ ពួកគេបានរាំងខ្ទប់ការចែកចាយខិតប័ណ្ណផ្សព្វផ្សាយកូដកម្មរបស់សកម្មជនសហជីព ដោយបានឃុំខ្លួនសកម្មជនពីរនាក់បណ្តោះអាសន្ន តាមទំនើងចិត្ត។*[931] *នៅថ្ងៃទី៣ ខែមីនា ពួកគេបានបំបែកការប្រមូលផ្តុំរបស់សកម្មជនសិទ្ធិដីធ្លី និងលំនៅឋាន ដែលទាមទារឱ្យដោះលែងមនុស្ស២១នាក់ ដែលបន្តជាប់ឃុំបណ្តោះអាសន្ន ពាក់ព័ន្ធនឹងហេតុការណ៍នៅថ្ងៃទី២-ទី៣ ខែមករា ហើយការបំបែកនោះបានធ្វើឱ្យអ្នកចូលរួមប្រមូលផ្តុំនោះពីរនាក់របួស។*[932]

---

http://www.licadho- cambodia.org/flashnews.php?perm=31 (ចូលមើល នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤), ពីប្រភពដដែល (Ibid.)

928 "សាលក្រមសម្រាប់អ្នកស្រី យ៉ោម បុប្ផា ត្រូវបានតម្កល់" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃសទី១៥ ខែមិថុនា ឆ្នាំ២០១៣ http://www.phnompenh post. com/2013061566292/National/yorm-bopha-verdict-upheld.html (ចូលមើល នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៣), ពីប្រភពដដែល (Ibid.)

929 "កម្ពុជា ៖ កងកម្លាំងសន្តិសុខ វាយដំអ្នកតវ៉ាសិទ្ធិលំនៅឋាន" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤ http://www.hrw.org/news/2014/02/14/cambodia-security-forces-beat-housing-rights-protesters; "យុវជនទទួលរងការវាយដំ ក្នុងពេលចាត់វិធានការចូលកាន់កាប់តំបន់បូរីកីឡា" វីដេអូរបស់អង្គការលីកាដូ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤http://www.licadho- cambodia.org/video.php?perm=45 (ចូលមើល នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤), "ការចូល ស្នាក់នៅរយៈពេលខ្លីរបស់ប្រជាពលរដ្ឋបុរីកីឡា ត្រូវបានបញ្ចប់ដោយហិង្សា" ព័ត៌មានរហ័សរបស់អង្គការលីកាដូ ថ្ងៃទី១៤ កុម្ភៈ ឆ្នាំ២០១៤ http://www.licadho-cambodia.org/flashnews.php?perm=41 (មើលនៅថ្ងៃទី១៤ កុម្ភៈ ឆ្នាំ២០១៤); ពីប្រភពដដែល (Ibid.)

930 "បុរសម្នាក់រងការវាយដំ និងការចាប់ខ្លួន នៅពេលយុវជនប៉ុនប៉ងរំលឹកទិវាយុត្តិធម៌សង្គម" *ខេមបូឌា ដេលី* ថ្ងៃទី ២១កុម្ភៈ ២០១៤ http://www.cambodiadaily.com/news/man-beaten-arrested-as-youth-group-marks-social-justice-day-52880/ (accessced ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០១៤); ពីប្រភពដដែល (Ibid.)

931 "តំណាងសហជីព ត្រូវបានឃុំខ្លួន ដោយសារចែកចាយខិតប័ណ្ណកូដកម្ម" *ដឺខេមបូឌា ដេលី* ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ http://www. cambodiadaily.com/news/union-representatives-detained-for-distributing-strike-leaflets-53330/ (ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៤), "ការឃាត់ខ្លួនដោយសារខិតប័ណ្ណដើម្បីសួរនាំ" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៨ កុម្ភៈ ២០១៤ http://www.phnompenhpost.com/national/leaflet-arrests-questioned (ទី២ ខែមីនា ២០១៤); ពីប្រភពដដែល (Ibid.)

932 "ការប្រមូលផ្តុំបន្តដើម្បីទាមទារយុត្តិធម៌ និងការដោះលែង" អង្គការលីកាដូ ព័ត៌មានរហ័ស ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៤ http://www.licadho-

នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៤ លោក ជួន សុវណ្ណ បានដឹកនាំការហ្វឹកហ្វឺនដ៏ធំមួយទៀតសម្រាប់នគរបាលរាជធានី និង ខណ្ឌនៅក្នុងការធ្វើសមយុទ្ធ ដើម្បីដោះស្រាយបាតុកម្មណាមួយទៀតរបស់គណបក្សសង្គ្រោះជាតិ ដែល "គ្មានការអនុញ្ញាត"។[933] នៅចុងខែមីនា លោក ជួន សុវណ្ណ ក៏បានគ្រប់គ្រងលើការហ្វឹកហ្វឺននគរបាលអន្តរាគមន៍ពិសេសនៃរាជធានី និងខណ្ឌ ផងដែរ។[934] នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ នគរបាលរាជធានីភ្នំពេញ និងនគរបាលផ្សេងទៀត បានចាប់ខ្លួនសមាជិកគណបក្សសង្គ្រោះជាតិបួននាក់ ដែលជាតំណាងរាស្ត្រ និងមេដឹកនាំយុវជនគណបក្សសង្គ្រោះជាតិម្នាក់ ដែលត្រូវបានចោទប្រកាន់ដោយមិនត្រឹមត្រូវថា ជាអ្នកទទួលខុសត្រូវចំពោះការប៉ះទង្គិចគ្នាយ៉ាងហិង្សារវាងអ្នកតវ៉ាដែលទាមទារឱ្យបើកទីលានប្រជាធិបតេយ្យឡើងវិញ និងក្រុមសន្តិសុខដែលព្យាយាមបណ្តេញពួកគេឱ្យចេញឆ្ងាយពីបរិវេណទីលាននោះ។[935] នេះជាការចាប់ផ្តើមរលកនៃការចាប់ខ្លួនសមាជិកសភា និងសកម្មជនពីគណបក្សសង្គ្រោះជាតិ ដែលសុទ្ធតែត្រូវបានចោទប្រកាន់ដោយមិនត្រឹមត្រូវពីបទ "បះបោរ" ដែលជាការចោទប្រកាន់គ្មានភស្តុតាងគួរឱ្យជឿបាន ប៉ុន្តែត្រូវបានលោក ជួន សុវណ្ណ សន្និដ្ឋានយ៉ាងដូច្នោះ នៅក្នុងពិធីជួបជុំត្រួតពិនិត្យការងាររបស់នគរបាលរាជធានីភ្នំពេញ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤។[936] គាត់បានចាត់ទុកគ្រប់អំពើហិង្សាទាំងអស់ ដែលបាន

---

cambodia.org/flashnews.php?perm=44 (អាននៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៤); ពីប្រភពដដែល (Ibid.)

[933] "ឯកឧត្តម ជួន សុវណ្ណ ដឹកនាំនគរបាលជាច្រើនពាន់នាក់ ដើម្បីហ្វឹកហ្វឺនពង្រឹងសុវត្ថិភាព សម្រាប់ប្រជាពលរដ្ឋ" (!:UI =), ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៤ http://edition.bayontv.com.kh/bayontv-national-news/22957-2014-03-06-09-47-23.html (ចូលមើល នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៤)។

[934] "សមត្ថកិច្ចនគរបាលអន្តរាគមន៍ខណ្ឌ ៧ មករា ៣៦ នាក់ ទទួលការហ្វឹកហ្វឺនកាយសម្បទា និងផ្លូវចិត្ត" ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/83740-2014-03-27-04-14-01.html (ចូលមើល នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤)។

[935] "សមាជិកសភាជាតិ មកពីគណបក្សសង្គ្រោះជាតិ ទាំងបីនាក់ ត្រូវបានបញ្ជូនទៅស្នងការដ្ឋាន ស្របពេលដែលកងសន្តិសុខខណ្ឌ ២១ នាក់ បានរងរបួសធ្ងន់ និងស្រាល" ( s ru s ., CNRP s s., .,, s s ), ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/90514-2014-07-15-03-45-12.html (ទទួលបាន ឬ ពានអាននៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤), "អំពើហិង្សានៅជិតទីលានប្រជាធិបតេយ្យ ៖ សាលារាជធានីភ្នំពេញប្រកាសចាប់ខ្លួនជនល្មើសផ្ទាល់ដៃ និងអ្នកទទួលខុសត្រូវ ១២ នាក់ ដែលត្រូវតែទទួលទោស" (UIJ 6u'Cii'i), ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ http://www.dap- news.com/2011-06-14-02-39-55/90553-2014-07-15-10-51-26.html (ចូលមើល នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤), "អង្គការលីកាដូថ្កោលទោសអំពើហិង្សានៅពេលព្រឹកនេះ នៅសួនសេរីភាពក្នុងរាជធានីភ្នំពេញ" អង្គការលីកាដូ សេចក្តីថ្លែងការណ៍ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ http://www.licadho- cambodia.org/pressrelease.php?perm=348 (ចូលមើល នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤), "មួយថ្ងៃបន្ទាប់ពីអំពើហិង្សានៅសួនសេរីភាព ៖ សមាជិកសភា ប្រាំនាក់នៅតុលាការ" អង្គការលីកាដូ ផ្សាយផ្ទាល់ ថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០១៤ http://stream.licadho-cambodia.org/five_elect_cnrp_court/ (ចូលមើល នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤), "កម្ពុជា ៖ លើកលែងករណីប្រឆាំងនឹងអ្នកនយោបាយគណបក្សប្រឆាំង" សេចក្តីប្រកាសព័ត៌មានរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ឃ្យូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ http://www.hrw.org/news/2014/07/17/cambodia-drop-cases-against-opposition-politicians; "ក្រុមសង្គមស៊ីវិល ថ្កោលទោសការចោទប្រកាន់ ដោយគ្មានមូលដ្ឋានច្បាស់លាស់ និងអំពាវនាវឱ្យបញ្ចប់អំពើហិង្សា និងការបង្ក្រាប" អង្គការលីកាដូ et al., សេចក្តីថ្លែងការណ៍ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ http://www.licadho-cambodia.org/pressrelease.php?perm=349 (ចូលមើល នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤), ពីប្រភពដដែល (Ibid.)

[936] "សមាជិកក្រុមប្រឹក្សាខណ្ឌ គណបក្សសង្គ្រោះជាតិទី១២ ដែលត្រូវបានចាប់ខ្លួន លើករណីហិង្សានៅស្ពាននាគ" អង្គការលីកាដូ ព័ត៌មានរហ័ស ថ្ងៃទី

កើតឡើងនៅក្នុងឆ្នាំមុន ថាកើតចេញពីការញុះញង់របស់ "គណបក្សសង្គ្រោះជាតិ សង្គមស៊ីវិល និងសហជីពមួយចំនួន" ដែលនោះបង្កប់ន័យថា អ្នកទាំងនោះត្រូវទទួលខុសត្រូវចំពោះការស្លាប់ និងការរងរបួសទាំងអស់ដែលបានកើតឡើង មិនថា ការស្លាប់ ឬរបួសរបស់បាតុករ កម្មករ អ្នកតវ៉ា ឬ កងកម្លាំងសន្តិសុខនោះឡើយ។ គាត់បានពណ៌នាអំពីអាកប្បកិរិយារបស់នគរបាលទាំងអស់នៅពេលនោះថា មានភាព "ល្អឥតខ្ចោះ" និងបានចែកអំណោយរបស់លោក ហ៊ុន សែន ដល់នគរបាលម្នាក់ៗ ដែលស្ថិតក្រោមបញ្ជាការរបស់គាត់ ដោយក្នុងម្នាក់ទទួលបានអំណោយដែលមានតម្លៃស្មើនឹង ២៥ ដុល្លារអាមេរិក។[937]

សមាជិកសភាមកពីគណបក្សសង្គ្រោះជាតិ ដែលត្រូវបានចាប់ខ្លួន ពាក់ព័ន្ធនឹងហេតុការណ៍ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ក្រោយមកត្រូវបានដោះលែងជាបណ្តោះអាសន្ន ប៉ុន្តែនៅតែបន្តស្ថិតក្នុងហានិភ័យនៃការ  ផ្តន្ទាទោសដដែល។[938] នៅថ្ងៃទី២១ កក្កដា ឆ្នាំ២០១៥ សកម្មជនគណបក្សសង្គ្រោះជាតិ ១១នាក់ត្រូវបានចាប់ខ្លួន និងផ្តន្ទាទោសយ៉ាងអយុត្តិធម៌ពីបទ "បះបោរ" ពាក់ព័ន្ធនឹងហេតុការណ៍ថ្ងៃទី១៥ ខែកក្កដានោះ និងត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារពី៧ឆ្នាំដល់២០ឆ្នាំ។[939] លោក ជួន សុវណ្ណ ក៏មានឈ្មោះក្នុងគណៈកម្មាធិការក្រសួងមហាផ្ទៃ ដែលមានភារកិច្ចចាប់ខ្លួនលោក សម រង្ស៊ី នៅពេលណាធ្វើទៅបាន ផងដែរ។[940] នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ លោក ជួន សុវណ្ណ បានឡើងតំណែងជានាយឧត្តមសេនីយ៍ផ្កាយមាស៤យ៉ាងពេញលេញ ជាការដំឡើងតំណែងដែលអ្នកតាមដានស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាយល់ថាជារង្វាន់ចំពោះការបម្រើការងាររបស់គាត់ ឱ្យគណបក្សប្រជាជនកម្ពុជា។[941] នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ

---

២៩ ខែកញ្ញា ឆ្នាំ២០១៤ http://www.licadho-cambodia.org/flashnews.php?perm=82 (ចូលមើល នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៤)។

937 "ស្ថានភាពក្រោយប្រតិបត្តិការពេញមួយឆ្នាំរបស់នគរបាលរាជធានីភ្នំពេញ ត្រូវបានបង្ហាញ" ( bl s bl s bl ., bl ), ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ http://edition.bayontv.com.kh/bayontv-national-news/29616-2014-07-30-03-35-24.html (ចូលមើល នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤), "កងកម្លាំងនគរបាលរាជធានីភ្នំពេញ បានរៀបចំការប្រជុំដើម្បីបូកសរុបប្រតិបត្តិការរក្សាសន្តិសុខនយោបាយ ក្រោយពេលបញ្ចប់វិបត្តិនយោបាយ" (Cii ), ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ http://www.dap-news.com/2011-06-14-02-39-55/91587-2014-07-30-03-27-02.html (ចូលមើល នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤), "នគរបាលបានទទួលថវិកាចំនួន៥ម៉ឺនដុល្លារ សម្រាប់រក្សាសណ្តាប់ធ្នាប់នៅក្រោយការបោះឆ្នោត" *ខេមបូឌា ដេលី* ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ http://www.cambodiadaily.com/news/police-given- 50k-for-keeping-order-post-election-65403 (ចូលមើលនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១៤)។

938 "សមាជិកក្រុមប្រឹក្សាខណ្ឌគណបក្សសង្គ្រោះជាតិទី១២ ដែលត្រូវបានចាប់ខ្លួន លើករណីហិង្សា នៅស្ពាននាគ" អង្គការលីកាដូ ព័ត៌មានរហ័ស ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ http://www.licadho-cambodia.org/flashnews.php?perm=82 (ចូលមើល នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៤)។

939 "កម្ពុជា ៖ ការប្រកាសលើកលែងការចោទប្រកាន់ ចំពោះសកម្មជន ១១ ដែលត្រូវបានផ្តន្ទាទោស ទាំងអយុត្តិធម៌" សេចក្តីប្រកាសព័ត៌មានរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សយូមែនរ៉ៃត៍វ៉ច្ឆ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥  https://www.hrw.org/news/2015/07/21/cambodia-exonerate-11-wrongly-convicted-activists.

940 "រាជរដ្ឋាភិបាល សម្រេចបង្កើតគណៈកម្មាធិការមួយ ដើម្បីអនុវត្តដីការចាប់ខ្លួនលោក សម រង្ស៊ី ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ http://www.dap-news.com/2011-06-14-02-39-55/102630-2015-11-16-02-29-44.html (ទទួលបាន ឬ បានអាន នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥)។

941 "គណបក្សប្រជាជនកម្ពុជា នគរបាល បានឡើងតំណែង" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦ http://www.phnompenhpost.com/national/cpp-

*ដែលចេញផ្សាយជាសាធារណៈ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ នគរបាលរាជធានីភ្នំពេញរបស់លោក ជួន សុវណ្ណ បានអបអរសាទរចំពោះខ្លួនឯងថា ក្នុងឆ្នាំ២០១៥ ពួកគេបាន "ទប់ស្កាត់អស្ថិរភាពនយោបាយ ការបែកបាក់សាមគ្គីផ្ទៃក្នុង កាត់បន្ថយអំពើហិង្សា ទប់ស្កាត់គ្រោះមហន្តរាយសង្គមដ៏ធំសម្បើម និងរក្សាសុវត្ថិភាព"។ របាយការណ៍នេះ បានពន្យល់ថាៈ*

> *ភាគច្រើននៃ [បាតុកម្ម និងកូដកម្ម] ត្រូវបានបង្កឡើងដោយអ្នកនយោបាយ ក្រុមសង្គមស៊ីវិល សហព័ន្ធ និងសហជីព មួយចំនួន ដែលប្រឆាំងនឹងរដ្ឋាភិបាល។ [ពួកគេ] បង្កើតការញុះញង់ និងទាក់ទាញសកម្មជន និងអ្នកតវ៉ា ឱ្យធ្វើការអំពាវនាវដល់រដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ ឱ្យដោះស្រាយទៅតាមការទាមទាររបស់ពួកគេ។ យើងបានយកចិត្តទុកដាក់ចំពោះកូដកម្ម និងបាតុកម្មទាំងនេះ ហើយបានដោះស្រាយបញ្ហាទាំងនោះ តាមរយៈកិច្ចសហប្រតិបត្តិការគ្នា ដើម្បីការពារសន្តិសុខ សុវត្ថិភាព និងរក្សាសណ្តាប់ធ្នាប់។*[942]

*នៅក្នុងសុន្ទរកថាមួយ ថ្លែងទៅកាន់នគរបាលរាជធានីភ្នំពេញនៅថ្ងៃបន្ទាប់ លោក ប៉ា សុជាតិវង្ស អភិបាលរាជធានីភ្នំពេញ បានដាស់តឿនពួកគេថា ខណៈការបោះឆ្នោតខិតជិតមកដល់ ពួកគេត្រូវតែត្រៀមខ្លួនឱ្យរួចរាល់ ដើម្បីបន្តប្រតិបត្តិការបង្ក្រាបរបស់ពួកគេលើអ្នកទាំងឡាយណា ដែលបង្ក "អស្ថិរភាពនយោបាយ"។*[943]

*នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ លោក ជួន សុវណ្ណ បានប្រកាសអំពីភាពចាំបាច់នៃប្រតិបត្តិការទាំងនោះ នៅពេលពន្យល់អំពីការឃុំខ្លួនបណ្តោះអាសន្នអ្នកការពារសិទ្ធិមនុស្ស និង សកម្មជនសង្គមប្រាំមួយនាក់ នៅថ្ងៃដដែលនោះ ដើម្បីសាកសួរ។ អ្នកការពារសិទ្ធិមនុស្ស និងសកម្មជននានា បានប្រមូលផ្តុំគ្នាដោយសន្តិវិធី ដើម្បីអំពាវនាវឱ្យដោះលែងមន្ត្រីការពារសិទ្ធិមនុស្ស ដែលត្រូវបានឃុំខ្លួន តាំងពីចុងខែមេសា និងត្រូវបានឃុំខ្លួន ក្រោមបទចោទដែលមានចរិតនយោបាយ ពាក់ព័ន្ធនឹងសកម្មភាពរបស់ពួកគេ  ដែលប្រឆាំងនឹងការ*

---

police-brass-promoted (ចូលមើល នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦)។

942 "នគរបាលក្រុង លើកសរសើរអំពី ការបង្ក្រាបការតវ៉ា" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ http://www.phnompenhpost.com/national/city-cops-sing-praises-protest-crackdowns (ចូលមើល នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦)

943 "ការព្រមាន ដោយកងកម្លាំង នៅក្នុងការប្រជុំរបស់នគរបាល" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ http://www.phnompenhpost.com/national/sabres- rattled-police-meet (ចូលមើល នៅថ្ងៃទី ២ ខែមេសា ឆ្នាំ២០១៦)។

*រំលោភសិទ្ធិមនុស្ស។[944] លោក ជួន សុវណ្ណ បានថ្លែងថា "ការតវ៉ា ការដង្ហែក្បួន ឬការប្រមូលផ្ដុំមនុស្ស" ណាមួយ ដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋាភិបាល ដែលនគរបាលគិតថាអាច "ជះផលអាក្រក់ដល់សន្តិសុខសណ្ដាប់ធ្នាប់ ឬស្ថិរភាពនយោបាយ" នឹងត្រូវបាន "បំបែក ធ្វើឱ្យខ្ចាត់ខ្ចាយ និងហាមឃាត់មិនឱ្យធ្វើបន្ត" ហើយ "អ្នកតំណាង" នៃការប្រមូលផ្ដុំគ្នាបែបនោះ នឹងត្រូវនគរបាលបញ្ជូនទៅឃុំខ្លួន ដើម្បីសាកសួរ រហូតដល់ពួកគេយល់ព្រមបញ្ឈប់ការប្រមូលផ្ដុំគ្នា និងឈប់រៀបចំការប្រមូលផ្ដុំគ្នា។[945] ចំណាត់ការជាបន្តបន្ទាប់ដែលមានលក្ខណៈបែបនេះក្នុងអំឡុងប៉ុន្មានខែក្រោយពេលនោះមក ធ្វើឱ្យពួកគេទទួលបានលទ្ធផលដែលខ្លួនប៉ងប្រាថ្នា នោះគឺការរារាំង មិនឱ្យមានការអនុវត្តសិទ្ធិប្រមូលផ្ដុំគ្នាដោយសន្តិវិធី។[946]*

*ចំពោះផ្នែកនយោបាយវិញ លោក ជួន សុវណ្ណ ក្នុងនាមជាប្រធានសមាគមអតីតយុទ្ធជននៃរាជធានីភ្នំពេញ បានចូលរួមក្នុងកិច្ចប្រជុំមួយនៅចុងឆ្នាំ២០១៦ នៃកងកម្លាំងជំនួយមួយនេះរបស់គណបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់លោក គន់ គីម ដែលជាបក្សពួកនយោបាយរបស់គាត់ ហើយនៅក្នុងកិច្ចប្រជុំនោះ លោក គន់ គីម បានកោតសរសើរលោក ហ៊ុន សែន និងបានសង្កត់ធ្ងន់លើតួនាទីរបស់អតីតយុទ្ធជន ក្នុងកិច្ចសហការជាមួយមន្ត្រីសន្តិសុខប្រចាំការដែលសកម្មនៅថ្នាក់មូលដ្ឋាន។[947]*

*ក្នុងដំណើរឆ្ពោះទៅរក និងក្នុងអំឡុងពេលនៃដំណើរការរំលាយគណបក្សសង្គ្រោះជាតិ ក្រោមលេសមិនត្រឹមត្រូវថា គណបក្សនេះកំពុងជំរុញឱ្យមានបដិវត្តពណ៌ លោក ជួន សុវណ្ណ បានផ្ដល់ការគាំទ្រយ៉ាងពេញទំហឹង។ នៅថ្ងៃទី៧-៨ ខែសីហា ឆ្នាំ២០១៧ គាត់បានធ្វើជាអធិបតីនៅក្នុងសមយុទ្ធបាញ់គ្រាប់ពិតស្វ័យប្រវត្តិ*

---

[944] "កម្ពុជា ៖ បញ្ឈប់យុទ្ធនាការ ដើម្បីបន្ថយការតាមដានសិទ្ធិមនុស្ស ការផ្ដន្ទាទោសមានលក្ខណៈនយោបាយ ដើម្បីគំរាមការងារសិទ្ធិមនុស្ស ទាំងអស់" សេចក្ដីប្រកាសព័ត៌មានរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦https://www.hrw.org/news/2016/05/03/cambodia-cease- campaign-curtail-rights-monitoring.

[945] "នាយឧត្តមសេនីយ៍ ជួន សុវណ្ណ ៖ សកម្មជនដីធ្លី និងមន្ត្រីសង្គមស៊ីវិលទាំង៦នាក់ ក្រោមការសាកសួរ, បើសួរទៅគ្មានទោស នឹងឲ្យធ្វើកិច្ចសន្យាត្រឡប់ទៅវិញ" ថ្ងៃទី៩ ឧសភា ២០១៦http://www.freshnewsasia.com/index.php/en/23779-2016-05-09-04-50-11.html (មើល ថ្ងៃទី៩ ឧសភា ២០១៦) ។

[946] "នាយឧត្តមសេនីយ៍ ជួន សុវណ្ណ ៖ កម្លាំងនគរបាលជាច្រើននាក់ កំពុងបង្កើនការហ្វឹកហាត់ ដើម្បីថែរក្សាសន្តិសុខ និង សណ្ដាប់ធ្នាប់សង្គម" ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៦ http://www.freshnewsasia.com/index.php/en/26453-2016-06-14-03-31-38.html (ចូលមើល នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦), "'លុយកខ្វក់' សកម្មជនផ្អាកយុទ្ធនាការ" *ខេមបូឌា ដេលី* ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៦ https://www.cambodiadaily. com/news/ black-monday-activists-suspend-campaign-116155/ (ចូលមើល នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៦)។

[947] "លោក កែប ជុតិមា, លោក ម៉ម ប៊ុនហេង និងលោក ប៉ា សុជាតិវង្ស ផ្ដល់ថវិកា ៧៣ លានរៀល ដោះស្រាយបញ្ហាអតីតយុទ្ធជន" ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ http://www.freshnewsasia.com/index.php/en/localnews/42370-2016-12-22-00-31-18.html (ចូលមើល នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦)។

*របស់នគរបាលអន្តរាគមន៍បែបយោធា កាលពីខែសីហា ឆ្នាំ២០១៥ សម្រាប់ប្រតិបត្តិការពិសេសប្រឆាំងនឹងអ្នកទាំងឡាយណាដែលមាន "និន្នាការប្រឆាំង"។[948] វគ្គហ្វឹកហ្វឺននោះ គឺច្បាស់ណាស់ ដើម្បីឆ្លើយតបនឹងបាតុកម្ម។[949] នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៧ លោក ជួន សុវណ្ណ បានចេញសេចក្តីថ្លែងការណ៍មួយក្នុងនាមខ្លួនគាត់ផ្ទាល់ និងក្នុងនាមនគរបាលរាជធានីភ្នំពេញទាំងអស់ ថ្កោលទោសលោក សម រង្ស៊ី លោក កឹម សុខា និងជនក្បត់ "ឆ្កួតនឹងអំណាច" ផ្សេងទៀត ដែលរិះផែនការប្រឆាំងពួកគេត្រូវបានត្រៀមរួចរាល់។ គាត់បានបន្ថែមថា "ខ្ញុំចង់បញ្ជាក់ឱ្យច្បាស់ថា កងកម្លាំងនគរបាលទាំងអស់" នៅថ្នាក់រាជធានី និងខណ្ឌនៃរាជធានីភ្នំពេញ "បានត្រៀមខ្លួនរួចជាស្រេច ក្នុងការកម្ចាត់ក្រុមទាំងឡាយណា ដែលមានបំណងបង្កើតភាពឥតសណ្តាប់ធ្នាប់ ដើម្បីឱ្យសង្គមចលាចល" ដោយបានពន្យល់ថា នគរបាល "គ្រាន់តែត្រៀមខ្លួនរង់ចាំទទួលបទបញ្ជាពីថ្នាក់លើរបស់ខ្លួនប៉ុណ្ណោះ នៅពេលណាមានបញ្ជាពីថ្នាក់លើភ្លាម នគរបាលនឹងចេញធ្វើប្រតិបត្តិការភ្លាម ដើម្បីការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ"។[950]*

*ថ្លែងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្នុងនាមជាស្នងការរាជធានីភ្នំពេញ និងតាំងនាមឱ្យមន្ត្រីទាំងអស់របស់រាជធានី លោក ជួន សុវណ្ណ បានបញ្ជាក់នូវការគាំទ្រទាំងស្រុង ចំពោះសាលដីការបស់តុលាការកំពូលដែលសម្រេចរំលាយគណបក្សសង្គ្រោះជាតិ ក្រោមបទចូលរួមក្នុង "អំពើក្បត់ជាតិ" ដែលមិនអាចអត់ឱនឱ្យបាន និងគាំទ្រទាំងស្រុងចំពោះការអំពាវនាវរបស់លោក ហ៊ុន សែន ឱ្យចាត់វិធានការជាមុនបន្ថែមទៀត ប្រឆាំងនឹងផែនការធ្វើបដិវត្តពណ៌ និងអ្នកនយោបាយ "ដែលបម្រើផលប្រយោជន៍បរទេស"។[951]*

---

[948] កងកម្លាំងនគរបាលរាជធានីភ្នំពេញ ហ្វឹកហ្វឺនបាញ់គ្រាប់ពិត ពង្រឹងការពារសន្តិសុខ និងសណ្តាប់ធ្នាប់ជូនរាជរដ្ឋាភិបាលស្របច្បាប់ និងពលរដ្ឋ, លទ្ធផលទទួលបានល្អ បង្គួរ៩៩%; "អគ្គស្នងការនគរបាលជាតិនឹងបណ្តេញកងកម្លាំងនគរបាលណា ដែលមិនចូលរួមហ្វឹកហ្វឺនជំនាញទៀងទាត់" (អគ្គស្នងការនគរបាលជាតិ និងបណ្តាញកងកម្លាំងនគរបាលណាដែលមិនចូលរួមហ្វឹកហ្វឺនទៀងទាត់), ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ http://kampucheathmey.com/kpt/?p=88126 (អាននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥), "កងកម្លាំងនគរបាលជាតិរៀនអំពី កលយុទ្ធពីកងពលតូចទ័ពពិសេសឆ័ត្រយោង ៩១១" *ខេមបូឌា ដេលី* ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ https://www.cambodiadaily.com/news/national-police-force-learn-tactics-from-911-brigade-97355/ (អាននៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៥)។

[949] អង្គភាពគ្រប់គ្រងហ្វូងមនុស្សបញ្ចេញខ្សែវីដេអូអំពី សមយុទ្ធបាញ់គ្រាប់ពិត ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧។

[950] ជួន សុវណ្ណ៖ កម្លាំងនគរបាលទូទាំងរាជធានី ប្រកាសថ្កោលទោសសម្តីជនក្បត់ជាតិ សមរង្ស៊ី និងត្រៀមគ្រប់ពេលកំចាត់ក្រុមបង្ករចលាចលសង្គម។

[951] នាយឧត្តមសេនីយ៍ជួន សុវណ្ណ ប្រកាសគាំទ្រពេញទំហឹង ចំពោះសាលដីកាតុលាការកំពូលរំលាយគណបក្សសង្គ្រោះជាតិ និងគាំទ្រអនុសាសន៍ទាំងស្រុងរបស់សម្តេចតេជោ ហ៊ុន សែន។

# XIII. ការទទួលស្គាល់របស់អង្គការសហប្រជាជាតិ ចំពោះសារសំខាន់នៃកំណែទម្រង់វិស័យសន្តិសុខ

## *មិនធ្វើតាមការសន្យា*

*បញ្ហាជារចនាសម្ព័ន្ធក្នុងវិស័យសន្តិសុខរបស់ប្រទេសកម្ពុជា មានចាប់តាំងពីអំឡុងពេលក្រោយទទួលបានឯករាជ្យពីប្រទេសបារាំង នៅឆ្នាំ១៩៥៣ មកម្ល៉េះ រាប់បញ្ចូលទាំងការរៀបចំកម្លាំងសន្តិសុខក្រោមរបបខ្មែរក្រហម និងរដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយនិងរបបរដ្ឋកម្ពុជាផងដែរ។ បញ្ហាទាំងនេះ គួរតែត្រូវបានដោះស្រាយ និងកាត់បន្ថយបានយ៉ាងច្រើន តាមរយៈវិធានការនានា ដែលមាននៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងតាមរយៈការដាក់ពង្រាយកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ អ៊ុនតាក់ (UNTAC) លើប្រទេសនេះ ចាប់ពីខែមីនា ឆ្នាំ១៩៩២ ដល់ខែកញ្ញា ឆ្នាំ១៩៩៣។*

*ការណ៍ដែលកងកម្លាំងសន្តិសុខរបស់ប្រទេសកម្ពុជា បន្តស្ថិតក្រោមឥទ្ធិពលរបស់មន្ត្រីឃោរឃៅ ដែលត្រូវបានកត់ត្រាក្នុងរបាយការណ៍នេះ គឺជាមត៌កសំខាន់មួយដែលបន្សល់ទុកពីភាពបរាជ័យរបស់សហគមន៍អន្តរជាតិ ក្នុងការឆ្លើយតបឱ្យបានពេញលេញ និងដោយមិនញញើតទៅនឹងការដែលរដ្ឋាភិបាលលោក ហ៊ុន សែន ប្រើប្រាស់កងកម្លាំងសន្តិសុខរបស់បក្ស និង ប្រើកងកម្លាំងសន្តិសុខរដ្ឋធ្វើជារបស់ផ្ទាល់ខ្លួន ដើម្បីកំណត់គន្លងនយោបាយរបស់ប្រទេសនេះ។ អង្គការសហប្រជាជាតិ និងរដ្ឋចំនួន ១៨ ទៀត ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ជាមួយប្រទេសកម្ពុជា បានផ្តល់អាណត្តិដល់អ៊ុនតាក់ ដើម្បីត្រួតពិនិត្យមើលការបញ្ចប់សង្គ្រាមស៊ីវិល នៅក្នុងប្រទេសកម្ពុជា និងធ្វើសកម្មភាពជានានាឱ្យមានបរិយាកាសនយោបាយអព្យាក្រឹត សម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដើម្បីឱ្យប្រទេសកម្ពុជាស្ថិតលើមាគ៌ាឆ្ពោះទៅរកអនាគតមួយដែលប្រកាន់លទ្ធិប្រជាធិបតេយ្យ។ កិច្ចព្រមព្រៀងនេះ រួមមានបទប្បញ្ញត្តិស្តីពីការរៀបចំកងកម្លាំងយោធាកម្ពុជា ដែលកំពុងប្រកួតប្រជែងគ្នានោះ ជាក្រុមឡើងវិញ និងការរៀបចំមូលដ្ឋានយោធា ក្រោមការត្រួតពិនិត្យរបស់អ៊ុនតាក់ រួចហើយរំសាយកម្លាំង*

យោធាឱ្យបាន៧០ភាគរយ ដោយអាចមានការរំសាយកងកម្លាំងបម្រុង ឬ ទុកឱ្យរដ្ឋាភិបាលដែលជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យជាអ្នកគ្រប់គ្រងពួកគេនៅក្រោយការបោះឆ្នោត។ កិច្ចព្រមព្រៀងនេះ ក៏មានបទប្បញ្ញត្តិតម្រូវឱ្យអ៊ុនតាក់ (UNTAC) "គ្រប់គ្រងដោយផ្ទាល់" លើមុខងារការពារជាតិ និងមុខងារសន្តិសុខសាធារណៈ នៃរដ្ឋបាលនយោបាយកម្ពុជា ដែលកំពុងប្រកួតប្រជែងគ្នានោះផងដែរ ក្នុងគោលបំណងសំដៅធានាឱ្យបាននូវ "បរិយាកាសនយោបាយអព្យាក្រឹត"។[952]

ទោះបីជាយ៉ាងណា បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះរួច អ៊ុនតាក់ (UNTAC) អគ្គលេខាធិការអង្គការសហប្រជាជាតិ ភាគីហត្ថលេខីទាំង ១៨ និងរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ មិនបានទប់ស្កាត់ខ្មែរក្រហមរបស់ប៉ុល ពត ពីការក្បត់ការប្តេជ្ញាចិត្តលើផ្នែកយោធារបស់ពួកគេ ឬ ធ្វើការឆ្លើយតបប្រកបដោយប្រសិទ្ធភាពឡើយ ខណៈរបបរដ្ឋកម្ពុជារបស់លោក ហ៊ុន សែន ក៏បានបោះបង់ចោលការប្តេជ្ញាចិត្តរបស់ខ្លួនដែរ។ ពួកគេបានបរាជ័យ មិនអាចយកឈ្នះលើភាពរឹងរូសរបស់គណបក្សប្រជាជនកម្ពុជាដែលជម្ទះមិនព្រមឱ្យមានការគ្រប់គ្រងដោយផ្ទាល់របស់ អ៊ុនតាក់ (UNTAC) លើកិច្ចការទាក់ទងនឹងការការពារជាតិ និងសន្តិសុខសាធារណៈ។ នៅពេលគណបក្សប្រជាជនកម្ពុជាចាញ់ការបោះឆ្នោត ឆ្នាំ១៩៩៣ លោក ហ៊ុន សែន និងគណបក្សលោក បានគំរាមធ្វើអបគមន៍ខេត្តចំនួនប្រាំពីរ នៅជាប់ព្រំដែនវៀតណាម ព្រមទាំងបានគំរាមវាយប្រហារលើកងកម្លាំងរបស់អ៊ុនតាក់ (UNTAC) ។ អ៊ុនតាក់ (UNTAC) និងសហគមន៍អន្តរជាតិបានដកថយបន្តិច បណ្តាលឱ្យលទ្ធផលនៃការបោះឆ្នោតលែងបានការ ហើយលោក ហ៊ុន សែន អាចរក្សាតួនាទីជាសហនាយករដ្ឋមន្ត្រី។ លោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា បានបន្តរក្សាការគ្រប់គ្រងរបស់ខ្លួនលើកងកម្លាំងសន្តិសុខរបស់ប្រទេសនេះ ដែលនេះជាការត្រួសត្រាយផ្លូវសម្រាប់ការធ្វើរដ្ឋប្រហារក្នុងឆ្នាំ១៩៩៧ ដែលជាការបិទបញ្ចប់រដ្ឋាភិបាលដែលដឹកនាំដោយគណបក្សនយោបាយពីររួមគ្នា ហើយវាក៏ជាការត្រួសត្រាយផ្លូវសម្រាប់ការបោះឆ្នោត ដែលគ្មានភាពអព្យាក្រឹតនៅឆ្នាំ១៩៩៨ ដែលបានទុកឱ្យលោក ហ៊ុន សែន អាចគ្រប់គ្រងលើរដ្ឋាភិបាលបានយ៉ាងណែនដៃ។

អ្វីដែលសំខាន់ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស មិនមានបទប្បញ្ញត្តិសម្រាប់កំណែទម្រង់វិស័យសន្តិសុខបន្ថែមទៀត ក្រោយពេលអាណត្តិរបស់អ៊ុនតាក់ (UNTAC) ត្រូវបានបញ្ចប់ ដែលនោះគឺជាកំហុសដ៏ធំមួយ។

[952] "ក្របខណ្ឌការងារ សម្រាប់ការដោះស្រាយផ្នែកនយោបាយដ៏ទូលំទូលាយ ចំពោះវិវាទនៅកម្ពុជា" ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ http://www.cambodia.org/facts/?page=1991+Paris+Peace+Agreements#annex_2 (ចូលមើល នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨)។

ទោះបីជាយ៉ាងនោះក្តី កិច្ចព្រមព្រៀងនេះបានកំណត់ឱ្យកម្ពុជា មានការប្តេជ្ញាចិត្ត ក្នុងអំឡុងសម័យអ៊ុនតាក់ (UNTAC) និងនៅពេលអនាគត ក្នុងការៈ

- ជានានូវការគោរព និងអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន នៅក្នុងប្រទេសកម្ពុជា។
- គាំទ្រសិទ្ធិរបស់ពលរដ្ឋកម្ពុជាទាំងអស់ក្នុងការធ្វើសកម្មភាពនានា ដែលលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។

កិច្ចព្រមព្រៀងនេះ ក៏បានកំណត់ស្រដៀងគ្នានេះដែរ នូវការប្តេជ្ញាចិត្តរបស់ភាគីហត្ថលេខីផ្សេងទៀត ក្នុងការ "លើកកម្ពស់ និងលើកទឹកចិត្តនូវការគោរព និងការប្រតិបត្តិតាមគោលការណ៍សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា ដូចមានចែងនៅក្នុងលិខិតូបករណ៍អន្តរជាតិដែលពាក់ព័ន្ធ ជាពិសេសដើម្បីទប់ស្កាត់ការកើតឡើងវិញនូវការរំលោភសិទ្ធិមនុស្ស"។[953]

នៅពេលថ្មីៗនេះ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ និងអគ្គលេខាធិការ បានទទួលស្គាល់នូវសារសំខាន់នៃកំណែទម្រង់វិស័យសន្តិសុខ ដើម្បីឱ្យមានការប្រើប្រាស់យ៉ាងត្រឹមត្រូវនូវអំណាចរដ្ឋឱ្យបានទូទៅជាងមុន និងបទដ្ឋានដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងស្ថានភាពនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដែលត្រូវបានប្រកាន់យក និង ដើម្បីឱ្យមានដំណោះស្រាយចំពោះការរំលោភបំពាននានា ដែលកំពុងរីកដុះដាលនៅក្នុងវិស័យសន្តិសុខ ដូចមានចែងលម្អិត នៅក្នុងរបាយការណ៍នេះ។

## បទដ្ឋានកំណែទម្រង់វិស័យសន្តិសុខរបស់អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ បានទទួលស្គាល់ថា ការដោះស្រាយបញ្ហាក្នុងវិស័យសន្តិសុខ ដូចបញ្ហាដែលមាននៅក្នុងប្រទេសកម្ពុជា មានភាពសំខាន់ចាំបាច់ ដើម្បីកាត់បន្ថយ និងទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស។ នៅខែកុម្ភៈ ឆ្នាំ២០០៧ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ដែលកាលនោះ ស្ថិតក្រោមការដឹកនាំរបស់សាធារណរដ្ឋស្លូវ៉ាគី (Slovak Republic) បានរៀបចំការប្រជុំពិភាក្សាលើកដំបូងបំផុតស្តីពី កំណែទម្រង់វិស័យ

---

[953] ពីប្រភពដដែល (Ibid.)

សន្តិសុខ។ ឯកសារទស្សនទានរបស់សាធារណរដ្ឋស្លូវ៉ាគី សម្រាប់ការពិភាក្សានោះ បានប្រកាសថា "គោលបំណងធំបំផុត" នៃកំណែទម្រង់វិស័យសន្តិសុខ គឺត្រូវតែដើម្បី "ធានាថា ស្ថាប័នសន្តិសុខ" ដែលស្ថាប័នស្នូលមានជាអាទិ៍ "កងកម្លាំងប្រដាប់អាវុធ ដូចជា នគរបាល រាជអាវុធហត្ថ យោធា កងការពារប្រធានាធិបតី កងកម្លាំងចារកម្ម និងសន្តិសុខ ឆ្មាំសមុទ្រ ឆ្មាំការពារព្រំដែន អាជ្ញាធរគយ និងអង្គភាពសន្តិសុខបម្រុង និងក្នុងមូលដ្ឋាន" ត្រូវអនុវត្តមុខងារកំណត់ដោយច្បាប់របស់ខ្លួន ប្រកបដោយម៉ឺងម៉ាត់មិនផ្លាស់ប្តូរ ដោយមាន "និយាមប្រជាធិបតេយ្យ និងគោលការណ៍នៃអភិបាលកិច្ចល្អ និងនីតិរដ្ឋ"។ ឯកសារនោះបានសង្កត់ធ្ងន់ថា កំណែទម្រង់វិស័យសន្តិសុខ គឺ "មានទំនាក់ទំនងជាមួយនឹងការជួយធ្វើឱ្យមានស្ថិរភាព និងការជួយកសាងឡើងវិញនូវអាទិភាពផ្សេងៗទៀត ដូចជា យុត្តិធម៌អន្តរកាល នីតិរដ្ឋ និងសិទ្ធិមនុស្ស"។ ឯកសារនោះ ក៏បានសង្កត់ធ្ងន់ថា កំណែទម្រង់ក្នុងវិស័យសន្តិសុខ គឺមិនអាចសម្រេចទៅបានដោយប្រើ "ដំណោះស្រាយឆាប់រហ័ស" ណាមួយឡើយ ដោយសារបទពិសោធន៍បានបង្ហាញថា "គោលដៅរយៈពេលខ្លី នាំទៅរកលទ្ធផលដែលមិនដំណើរការ និងគ្មាននិរន្តរភាព"។ ជំនួសមកវិញ កំណែទម្រង់ត្រូវតែជា "ការប្រឹងប្រែងព្យាយាមក្នុងរយៈពេលវែង"។ ឯកសារនោះ អំពាវនាវឱ្យអង្គការសហប្រជាជាតិ ទាញប្រយោជន៍ពីធម្មនុញ្ញភាព និងបទពិសោធន៍របស់ខ្លួន ដើម្បីលើកកម្ពស់ "ការគាំទ្រជាអន្តរជាតិ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានភាពប្រទាក់ក្រឡាគ្នា និងមានការសម្របសម្រួល" ចំពោះកំណែទម្រង់។ បើមិនដូច្នោះទេ វិស័យសន្តិសុខ ដែលគ្មានការកែទម្រង់នឹងបន្តស្ថិតនៅជា "ឧបសគ្គដាច់ខាត គ្របសង្កត់លើសន្តិភាព ស្ថិរភាព ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយចីរភាព នីតិរដ្ឋ អភិបាលកិច្ចល្អ និងការគោរពសិទ្ធិមនុស្ស"។[954]

កិច្ចប្រជុំវែកញែករបស់ក្រុមប្រឹក្សាសន្តិសុខនេះ បានបន្សល់ទុកនូវរបាយការណ៍មួយរបស់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិស្តីពី តួនាទីរបស់អង្គការសហប្រជាជាតិក្នុងការគាំទ្រកំណែទម្រង់វិស័យសន្តិសុខ ដែលរបាយការណ៍នេះ ត្រូវបានចែកចាយនៅខែមករា ឆ្នាំ២០០៨។ របាយការណ៍នេះបានកំណត់និយមន័យនៃកំណែទម្រង់វិស័យសន្តិសុខ ថាជាដំណើរការមួយដែលមានគោលបំណង "លើកកម្ពស់សន្តិសុខសម្រាប់រដ្ឋ និងប្រជាជនរបស់ពួកគេ ប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព ដោយគ្មានការរើសអើង និងមានការគោរពយ៉ាងពេញលេញដល់សិទ្ធិមនុស្ស និង នីតិរដ្ឋ"។ របាយការណ៍នោះបានបង្ហាញពីការ

[954] ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ "លិខិត ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០៧ ពីតំណាងអចិន្ត្រៃយ៍នៃប្រទេសស្លូវ៉ាគី នៅអង្គការសហប្រជាជាតិ ទៅកាន់អគ្គលេខាធិការ" S/2007/72 (2007), ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៧ https://unssr.unlb.org/Resources/UNDocuments/tabid/255/SMID/498/ItemId/80/Default.aspx (ចូលមើល នៅថ្ងៃទី២០ ខែ មិថុនា ឆ្នាំ២០១៥)។

សោកស្តាយ ដោយសរសេរថា ភាពខ្វះចន្លោះរបស់អង្គការសហប្រជាជាតិក្នុងកិច្ចខិតខំប្រឹងប្រែងដោះស្រាយជម្លោះកាលពីអតីតកាល នៅក្នុងការដោះស្រាយបញ្ហាកំណែទម្រង់វិស័យសន្តិសុខប្រកបដោយប្រសិទ្ធភាពតាំងពីដើមទីនៃបញ្ហា បានបណ្តុះគ្រាប់ពូជនៃជម្លោះនៅពេលអនាគត ដោយបានថ្លែងថា បញ្ហានេះកើតចេញពីការមិនអើពើចំពោះការពិតដែលថា "ប្រសិទ្ធភាព គណនេយ្យភាព និងអភិបាលកិច្ចបែបប្រជាធិបតេយ្យ គឺជាធាតុផ្សំដែលពង្រឹងគ្នាទៅវិញទៅមក នៅក្នុងវិស័យសន្តិសុខ" ដែលទាមទារនូវ "ភាពមិនលម្អៀង និងការគោរពសិទ្ធិមនុស្ស ក្នុងចំណោមតួអង្គសន្តិសុខនានា"។

ក្នុងពេលជាមួយគ្នានោះដែរ របាយការណ៍នោះបានលើកជាយោបល់ថា ស្ថានភាពបែបនេះ អាចកែតម្រូវបាន សូម្បីតែនៅក្រោយពេលដែលប្រតិបត្តិការចម្បងរបស់អង្គការសហប្រជាជាតិបានបញ្ចប់ទៅហើយក៏ដោយ ដោយត្រូវបន្តកំណែទម្រង់វិស័យសន្តិសុខរយៈពេលវែង តាមរយៈ "ដំណើរការមានលក្ខណៈបរិយាប័ន្ន (រួមបញ្ចូលគ្នា ឬមិនផាត់ចោលភាគីពាក់ព័ន្ធ) ដែលក្នុងនោះអាជ្ញាធរជាតិ និងមូលដ្ឋាន រដ្ឋសភា និងសង្គមស៊ីវិល... ចូលរួមយ៉ាងសកម្ម" ដើម្បីបង្កើត "សន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ដោយឈរលើមូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស"។ នៅក្នុងរបាយការណ៍នោះ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិបានសង្កត់ធ្ងន់ថា ដើម្បីឱ្យដំណើរការកំណែទម្រង់ទទួលបានជោគជ័យ "ការចូលរួមរបស់តួអង្គមិនមែនរដ្ឋ ដូចជា អង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ គឺមានសារសំខាន់"។ គាត់ក៏បានគូសបញ្ជាក់ផងដែរនូវសារសំខាន់នៃជំនួយរបស់អង្គការសហប្រជាជាតិ នៅក្នុង "ការបង្កើតការព្រមព្រៀងគ្នាជាសកលមួយលើគោលការណ៍ និងការអនុវត្តកំណែទម្រង់សន្តិសុខ" ដោយផ្អែកលើច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និង អាចជាអ្វីដែលអនុញ្ញាតដោយសេចក្តីសម្រេចនៃក្រុមប្រឹក្សាសន្តិសុខ ឬ មហាសន្និបាតអង្គការសហប្រជាជាតិ។ គាត់បានកត់សម្គាល់ថា ជំនួយបែបនេះអាចរួមបញ្ចូលនូវ "ការសម្របសម្រួលនៃកិច្ចសន្ទនាថ្នាក់ជាតិ៖ ការគាំទ្រដល់អាជ្ញាធរជាតិ និងមូលដ្ឋាន តួអង្គក្នុងវិស័យសន្តិសុខ សង្គមស៊ីវិល និងតួអង្គមិនមែនរដ្ឋផ្សេងទៀត ក្នុងគោលដៅសម្របសម្រួលឱ្យមានកំណែទម្រង់ប្រកបដោយតម្លាភាព និងបរិយាប័ន្ន" ដែលការត្រួតពិនិត្យវិនិច្ឆ័យលើបុគ្គលិកកងកម្លាំងសន្តិសុខ អាចជាទិដ្ឋភាពមួយនៅក្នុងនោះ។[955]
របាយការណ៍ទីពីរ របស់អគ្គលេខាធិការស្តីពី កំណែទម្រង់វិស័យសន្តិសុខ ត្រូវបានផ្សព្វផ្សាយនៅខែសីហា

[955] មហាសន្និបាតអង្គការសហប្រជាជាតិ/ក្រុមប្រឹក្សាសន្តិសុខ "សន្តិភាព និងការអភិវឌ្ឍន៍សន្តិសុខ ៖ តួនាទីរបស់អង្គការសហប្រជាជាតិ ក្នុងការគាំទ្រកំណែទម្រង់វិស័យសន្តិសុខ របាយការណ៍នៃអគ្គលេខាធិការ" A/62/659-S/2008/39, ថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ https://unssr.unlb.org/Resources/UNDocuments/tabid/255/SMID/498/ItemId/120/Default.aspx (ចូលមើល នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៥)។

ឆ្នាំ២០១៣។ របាយការណ៍នេះ បានអត្ថាធិប្បាយថា ព្រឹត្តិការណ៍នានា ដែលបានកើតឡើងនាពេលថ្មីៗនេះ នៅក្នុងបរិបទផ្សេងៗគ្នា បានបង្ហាញឱ្យកាន់តែច្បាស់ថែមទៀតពី តម្រូវការនៃការធ្វើកំណែទម្រង់ ដើម្បីបន្ធូរបន្ថយ "ការធ្វើឱ្យកងកម្លាំងសន្តិសុខពាក់ព័ន្ធនឹងនយោបាយ" ដែលជាផ្នែកមួយនៃ "អន្តរកាលនយោបាយ" នៅក្នុងស្ថានភាពប្រទេសក្រោយមានជម្លោះ ដើម្បីឱ្យសង្គមទាំងឡាយ អាចងើបចេញពី "ការគ្រប់គ្រងបែបគាបសង្កត់" និងដើម្បីទប់ស្កាត់ការវិលទៅរកជម្លោះវិញ រួមទាំងតាមរយៈ "ការដោះស្រាយឱនភាពទាំងឡាយដែលមានក្នុងវិស័យសន្តិសុខ" ដែលអាចនាំទៅរកជម្លោះ ឬធ្វើឱ្យជម្លោះកាន់តែធ្ងន់ធ្ងរឡើង។ ក្នុងពេលជាមួយគ្នានោះដែរ របាយការណ៍នោះបានសរសេរថា "ការតាមដានត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើវិស័យសន្តិសុខ តាមរយៈយន្តការគ្រប់គ្រងបែបប្រជាធិបតេយ្យ ក៏មានសារសំខាន់ផងដែរ ក្នុងការទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស និង ក្នុងការកសាងទំនុកចិត្តចំពោះស្ថាប័នសន្តិសុខ"។ អាស្រ័យហេតុនេះ លោកអគ្គលេខាធិការបានណែនាំថា ការគាំទ្ររបស់អង្គការសហប្រជាជាតិ ចំពោះកំណែទម្រង់វិស័យសន្តិសុខ ត្រូវតែលើកកម្ពស់ដំណើរការ និងលទ្ធផលនានាដែល "មានលក្ខណៈបរិយាប័ន្ន និងគណនេយ្យភាព អនុវត្តតាមបទដ្ឋានសិទ្ធិមនុស្ស និងមានគោលដៅពង្រឹងកិច្ចសន្យារវាងរដ្ឋ និងសង្គម និងនៅទីបំផុត រវាងប្រជាជន និងស្ថាប័នសន្តិសុខ ដែលទទួលបានសិទ្ធិអំណាច ក្នុងការការពារប្រជាជន"។ គាត់បានសរសើរកិច្ចខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ ក្នុងការពង្រឹងបណ្តាញសង្គមស៊ីវិល ដើម្បីតាមដានត្រួតពិនិត្យសកម្មភាពរបស់កងកម្លាំងសន្តិសុខ។

នៅទីបំផុត របាយការណ៍នេះ បានសរសេរថា "ជោគជ័យ ឬបរាជ័យនៃការប្រឹងប្រែងធ្វើកំណែទម្រង់សន្តិសុខ គឺអាស្រ័យលើបរិយាកាសនយោបាយ" គឺបរិយាកាសមួយ ដែលអាចកែលម្អបាន ដោយអង្គការសហប្រជាជាតិ និងរដ្ឋជាសមាជិក ទាក់ទងនឹងស្ថានភាពប្រទេសនោះ "ដោយប្រឹងឱ្យហួសពីភាពជាដៃគូលក្ខណៈចង្អៀតជាមួយនឹងអាជ្ញាធរផ្លូវការ ឆ្ពោះទៅរកអតិក្រមសង្គមទាំងមូល ដែលផ្តោតជាពិសេសលើការបង្កការចូលរួមរបស់សង្គមស៊ីវិល" និង "ផ្អែកលើការចង់បាន និងតម្រូវការរបស់ប្រជាពលរដ្ឋនៃប្រទេសនោះ"។ លោកបានបញ្ជាក់យ៉ាងច្បាស់ថា ការតាមដានត្រួតពិនិត្យសិទ្ធិមនុស្ស "មានសារសំខាន់" ក្នុងការ "ធានាថា យុទ្ធសាស្ត្រកែទម្រង់វិស័យសន្តិសុខ ធានាបាននូវការគោរពសិទ្ធិមនុស្សយ៉ាងពេញលេញ ពីសំណាក់ស្ថាប័នវិស័យសន្តិសុខ ដែលកំពុងធ្វើកំណែទម្រង់នោះ"។ ក្នុងន័យនេះ លោកបានលើកសរសើរ (លើកទឹកចិត្ត) ពីការប្រើប្រាស់ "ក្របខណ្ឌការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដែលរួមមានសូចនាករស្តង់ដារគំរូ គោលដៅ និងគោលបំណង" ដើម្បី "វាយតម្លៃឱ្យច្បាស់អំពី ផលប៉ះពាល់នៃកំណែទម្រង់វិស័យ

សន្តិសុខ"។ ចំពោះការធ្វើឱ្យមានលទ្ធផលវិជ្ជមាន លោកក៏បានលើកសរសើរដែរដល់ការប្រើប្រាស់ការពិនិត្យ វិនិច្ឆ័យលើមន្ត្រីកម្លាំងសន្តិសុខ" ដើម្បីធានាថាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនឹងមិនកើតឡើងជាថ្មីទៀត" ។[956]

ដោយឆ្លុះបញ្ចាំងរបាយការណ៍របស់អគ្គលេខាធិការ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ នៅថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៤ បានអនុម័តជាឯកច្ឆន្ទលើសេចក្តីសម្រេចលេខ ២១៥១ ដែលចែងថា "ការកែទម្រង់វិស័យសន្តិសុខ នៅក្នុងបរិយាកាសក្រោយជម្លោះ គឺមានសារសំខាន់ក្នុងការពង្រឹងសន្តិភាព និងស្ថិរភាព កាត់បន្ថយភាពក្រីក្រ លើកកម្ពស់នីតិរដ្ឋ និងអភិបាលកិច្ចល្អ ពង្រីកអំណាចរដ្ឋ ដែលស្របច្បាប់ និងទប់ស្កាត់មិនឱ្យប្រទេសទាំងនោះធ្លាក់ចូលទៅក្នុងជម្លោះវិញ" និងចែងថា "វិស័យសន្តិសុខប្រកបដោយគណនេយ្យភាព (ការទទួលខុសត្រូវ) និងការអនុវត្តច្បាប់ និងវិស័យយុត្តិធម៌ ដែលមិនលំអៀង និងបើកចំហ គឺមានសារសំខាន់ដូចគ្នាទៅនឹងការចាក់គ្រឹះសម្រាប់សន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព"។ របាយការណ៍នោះ ក៏ទទួលស្គាល់ដែរថា ឆន្ទៈនយោបាយរបស់អាជ្ញាធរជាតិ គឺ "មានសារសំខាន់សម្រាប់វឌ្ឍនភាពនៃកំណែទម្រង់វិស័យសន្តិសុខ" ដែលមានន័យថា "កំណែទម្រង់វិស័យសន្តិសុខត្រូវតែបានការគាំទ្រ និងផ្អែកលើព័ត៌មានអំពីដំណើរការនយោបាយថ្នាក់ជាតិ ដោយបញ្ចូលគ្រប់ផ្នែកទាំងអស់នៃសង្គម រួមទាំងការចូលរួមរបស់សង្គមស៊ីវិលផងដែរ" ។ ប៉ុន្តែខណៈស្ថិតក្នុងដំណើរឆ្ពោះទៅគោលដៅនោះ ក៏ចាំបាច់ត្រូវ "ដោះស្រាយបញ្ហានិទណ្ឌភាព (ការអនុញ្ញាតអោយជនល្មើសរួចខ្លួន) ពីការរំលោភបំពានសិទ្ធិមនុស្ស" ដែលប្រព្រឹត្តដោយបុគ្គលិកកងកម្លាំងសន្តិសុខផងដែរ។ របាយការណ៍នោះបានកត់សម្គាល់ថា អង្គការសហប្រជាជាតិ "ស្ថិតក្នុងតួនាទីដ៏ល្អ ជាពិសេសក្នុងការគាំទ្រ និងសម្របសម្រួលកំណែទម្រង់ក្នុងវិស័យនេះទាំងមូល" ដោយផ្អែកលើគោលការណ៍ទាំងនេះ និងលើកទឹកចិត្តរដ្ឋជាសមាជិក ឱ្យគាំទ្រកំណែទម្រង់បែបនេះ។[957] នៅក្នុងការឆ្លុះបញ្ចាំងយ៉ាងម៉ត់ចត់មួយទៀត អំពីកំហុសនានាពីអតីតកាល ក្រុមពិនិត្យផ្ទៃក្នុងរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ បានធ្វើការសន្និដ្ឋាននៅឆ្នាំ២០១២ថា ពីមុនមក ធ្លាប់មាន "បរាជ័យជាប្រព័ន្ធ" នៅក្នុងការបំពេញការទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិ ក្នុងការរារាំងទប់ស្កាត់ និងឆ្លើយតបទៅនឹងការរំលោភសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌ធ្ងន់ធ្ងរ និងក្នុងការងារការពារប្រជាជន ដែល

---

[956] មហាសន្និបាត អង្គការសហប្រជាជាតិ/ក្រុមប្រឹក្សាសន្តិសុខ "ការរក្សាសន្តិសុខ ចំពោះរដ្ឋ និងសង្គម ៖ ការពង្រឹងការគាំទ្រគ្រប់ជ្រុងជ្រោយរបស់អង្គការសហប្រជាជាតិ ចំពោះកំណែទម្រង់វិស័យសន្តិសុខ" (A/67/970-S/2013/480), ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ https://unssr.unlb.org/Resources/UNDocuments/tabid/255/SMID/498/ItemId/119/Default.aspx (ចូលមើល នៅថ្ងៃទី២០ ខែ មិថុនា ឆ្នាំ២០១៥)។

[957] ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ, សេចក្តីសម្រេចលេខ ២១៥១ (ឆ្នាំ២០១៤) (S/RES2151 (2014)), ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ http://www.un.org/en/ga/search/view_doc.asp?symbol=S/RES/2151(2014) (ចូលមើល នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៥)។

ស្ថិតក្នុងហានិភ័យ។ ហេតុនេះ លោកអគ្គលេខាធិការ បានជំរុញឱ្យមានចំណាត់ការនេះ ដើម្បីធានាថា អង្គការសហប្រជាជាតិ សម្រេចបាននូវការទទួលខុសត្រូវរបស់ខ្លួន លើការងារទប់ស្កាត់ នៅគ្រប់ប្រទេសទាំងអស់ ដែលការណ៍នេះបាននាំឱ្យមានការបង្កើតផែនការសកម្មភាព និង គំនិតផ្តួចផ្តើមរបស់អង្គការសហប្រជាជាតិដោយផ្តោតលើ "សិទ្ធិមនុស្សជាចម្បង" ។ ឯកសារទាំងនោះអំពាវនាវឱ្យប្រព័ន្ធអង្គការសហប្រជាជាតិ តាមដានជានិច្ចនូវការរំលោភសិទ្ធិមនុស្សនានា ដែលជាសញ្ញាអាចវិវឌ្ឍទៅរកស្ថានភាពកាន់តែអាក្រក់ ដើម្បីបង្កើតកម្មវិធីយុទ្ធសាស្ត្ររបស់អង្គការសហប្រជាជាតិ ក្នុងបំណងបញ្ចៀសហានិភ័យនៃវិបត្តិ និង ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ នេះគឺជាយុទ្ធសាស្ត្រចូលរួមបែបត្រៀមចាំទប់ទល់ជាមុនទៅក្នុងស្ថានភាពក្នុងប្រទេសនានា ដើម្បីបង្កើតការគាំទ្រផ្នែកនយោបាយ ចំពោះវិធានការបង្ការទប់ស្កាត់ជាមុន និងទាន់ពេលវេលា ដែលរួមមានតាមរយៈការលើកឡើងនូវក្តីបារម្ភអំពីហានិភ័យនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ជាមួយអាជ្ញាធរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត។[958] ក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងទៀតទាំងនោះ គឺរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ដែលអង្គការសហប្រជាជាតិគួរតែធ្វើការជាមួយ ដើម្បីឱ្យពួកគេបំពេញការទទួលខុសត្រូវផ្នែកសិទ្ធិមនុស្សរបស់ពួកគេផ្ទាល់ ហើយដែលការគាំទ្ររបស់រដ្ឋភាគីទាំងនោះ ជាអ្វីដែលអង្គការសហប្រជាជាតិគិតថា មានភាពចាំបាច់ចំពោះវិធានការការពារ និងទប់ស្កាត់ប្រកបដោយជោគជ័យ។[959] ស្របជាមួយនឹងគោលនយោបាយ និងនីតិវិធីរបស់អង្គការសហប្រជាជាតិ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ លោក **បាន គីមូន** (Ban-Ki moon) ដែលនៅពេលនោះ ជាអគ្គលេខាធិការអង្គការសហប្រជាជាតិ បានទូរស័ព្ទទៅលោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិកម្ពុជា។ លោកបានបង្ហាញក្តីបារម្ភអំពីស្ថានភាពសិទ្ធិមនុស្ស ដែលកាន់តែដុនដាបទៅៗ នៅកម្ពុជា ពាក់ព័ន្ធនឹងរបាយការណ៍ដែលបានទៅដល់លោក ស្តីអំពី "ការបំភិតបំភ័យយ៉ាងរីករាលដាល ការធ្វើទុក្ខបុកម្នេញ និង ការចាប់ខ្លួនតួអង្គសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ បុគ្គលិក និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង

---

[958] ស្ថាប័នអង្គការសហប្រជាជាតិផ្នែកអភិវឌ្ឍន៍ "សិទ្ធិមនុស្សជាមុន ៖ ទិដ្ឋភាពទូទៅ" [គ្មានកាលបរិច្ឆេទ], https://undg.org/wp-content/uploads/2015/09/Overview-of-Human-Rights-up-Front-2015-07-24.pdf (ចូលមើល នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៥); ស្ថាប័នអង្គការសហប្រជាជាតិផ្នែកអភិវឌ្ឍន៍ "គំនិតផ្តួចផ្តើមសិទ្ធិមនុស្សជាមុន" [គ្មានកាលបរិច្ឆេទ], https://undg.org/home/guidance-policies/country-programming-principles/human-rights/rights-up-front-initiative/ (ចូលមើល នៅថ្ងៃទី២០ ខែ មិថុនា ឆ្នាំ២០១៥)។

[959] អង្គការសហប្រជាជាតិ "អគ្គលេខាធិការ ៖ ការបន្តឡើងវិញនូវការប្តេជ្ញាចិត្តចំពោះប្រជាជន និងគោលបំណងនៃអង្គការសហប្រជាជាតិ" ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ https://undg.org/wp-content/uploads/2014/09/SGs-commitment-statement-Final-English.pdf (ចូលមើល នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៥); អង្គការសហប្រជាជាតិ "អគ្គលេខាធិការរង ៖ ចំណាប់អារម្មណ៍ក្រៅផ្លូវការក្នុងការពន្យល់សង្ខេបអំពី មហាសន្និបាតស្តីពី សិទ្ធិមនុស្សជាមុន ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣" https://undg.org/wp-content/uploads/2014/09/DSG-informal-remarks-at- briefing-of-the-GA-on-Rights-up-Front.docx (ចូលមើល នៅថ្ងៃទី២០ ខែ មិថុនា ឆ្នាំ២០១៥)។

សមាជិកនៃគណបក្សប្រឆាំង” និង បានអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជា “ធានានូវការគោរពសិទ្ធិមនុស្សឱ្យបានពេញលេញ” នៅក្នុងប្រទេស។[960] ទន្ទឹមគ្នានឹងការកើនឡើងនូវការព្រួយបារម្ភរបស់អន្តរជាតិ អំពីស្ថានភាពសិទ្ធិមនុស្សកាន់តែអាក្រក់នៅប្រទេសកម្ពុជា វិធានការ (ការយកចិត្តទុកដាក់) កម្រិតខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិ ដែលប្រព័ន្ធផ្សព្វផ្សាយពណ៌នាថា ជាករណីដ៏ “កម្រ”នេះ ត្រូវបានក្រុមសង្គមស៊ីវិលនៅកម្ពុជាស្វាគមន៍ភ្លាមៗ ក៏ប៉ុន្តែត្រូវបានបដិសេធដោយរដ្ឋាភិបាល។[961]

[960] អង្គការសហប្រជាជាតិ “ព័ត៌មានស្តីពីការនិយាយគ្នាតាមទូរស័ព្ទរបស់អគ្គលេខាធិការ ជាមួយឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា” ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ https://www.un.org/sg/en/content/sg/readout/2016-06-08/readout-secretary-general%E2%80%99s-phone-call-he-mr- prak-sokhonn-minister (ចូលមើល នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦)។

[961] ការដាក់សម្ពាធជាសកល លើគណបក្សប្រជាជនកម្ពុជា បានកើនឡើង *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ http://www.phnompenhpost.com/national/global-pressure-cpp-builds(ចូលមើល នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦);“លោក **បាន គី មូន** ទូរស័ព្ទទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេស ជាមួយនឹងក្តីបារម្ភ” *ខេមបូឌា ដេលី* ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ https://www.cambodiadaily.com/news/ban-ki-moon-calls-foreign-minister-with-concerns-113920/ (ចូលមើល នៅថ្ងៃទី១១ មិថុនា ឆ្នាំ២០១៦, “រដ្ឋមន្ត្រីការបរទេសឆ្លើយតបចំពោះលោក **បាន គីមូន**” *ខេមបូឌា ដេលី* ថ្ងៃទី១៣ មិថុនា ឆ្នាំ២០១៦ https://www.cambodiadaily.com/news/foreign-minister-responds-to-ban-ki-moon-114015/ (ចូលមើល នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦)។

## XIV. អនុសាសន៍

*ក្នុងរយៈពេល ២៥ឆ្នាំកន្លងទៅនេះ មានសេចក្ដីសម្រេច និង របាយការណ៍ជាច្រើនរាប់មិនអស់របស់មហាសន្និបាតអង្គការសហប្រជាជាតិ គណៈកម្មការសិទ្ធិមនុស្ស ក្រុមប្រឹក្សាសិទ្ធិមនុស្ស តំណាងពិសេសអង្គការសហប្រជាជាតិ អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិ និងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលបានអំពាវនាវឱ្យមានចំណាត់ការមុតមាំក្នុងការដោះស្រាយបញ្ហានិទ្ទណ្ឌភាពរៀបចំយោធា កងរាជអាវុធហត្ថ និង នគរបាលរបស់កម្ពុជាឱ្យមានវិជ្ជាជីវៈ និង មិនឱ្យពាក់ព័ន្ធនឹងនយោបាយ។ ម្ចាស់ជំនួយ និង អង្គការសង្គមស៊ីវិល ក៏បានអំពាវនាវស្រដៀងគ្នានេះ ម្ដងហើយម្ដងទៀតដែរ។*

*មានអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនអង្គការសង្គមស៊ីវិលជាច្រើននាក់នៅកម្ពុជា បានប្រថុយប្រថានជីវិត ដើម្បីប្រែក្លាយកម្ពុជាឱ្យក្លាយជាប្រទេសប្រជាធិបតេយ្យ គោរពសិទ្ធិមនុស្ស ដូចដែលបានចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ពួកគេមិនត្រឹមតែមិនទទួលបានជោគជ័យទេ ថែមទាំងត្រូវរដ្ឋាភិបាលឆ្លើយតបវិញជាញឹកញាប់ ដោយការវាយប្រហារលើរូបរាងកាយ ការចាប់ខ្លួន និងការដាក់ទោសទណ្ឌឱ្យជាប់ពន្ធនាគាររយៈពេលយូរទៀតផង។ ថ្វីបើក្រុមសង្គមស៊ីវិលទាំងនោះបានបំពេញការងាររបស់ខ្លួនជាគំរូក៏ដោយ ក៏សហគមន៍អន្តរជាតិមិនបានផ្ដល់ការគាំទ្រដល់ពួកគេពីក្រោយឡើយ ពីព្រោះសហគមន៍អន្តរជាតិ ហាក់ក្ដោបមិនបានជុំនូវការពិតនៃបញ្ហានិទ្ទណ្ឌភាព និងមិនបានយល់ពេញលេញនូវតម្រូវការក្នុងការផ្លាស់ប្ដូរអ្នកដឹកនាំក្នុងកងកម្លាំងសន្តិសុខរបស់ប្រទេសកម្ពុជាទេ។*

*រដ្ឋាភិបាលបរទេស និងម្ចាស់ជំនួយនានា ជាពិសេស មើលទៅហាក់ដូចជាមិនពេញចិត្តនឹងឥទ្ធិពលរបស់ថ្នាក់ដឹកនាំនៃកងកម្លាំងសន្តិសុខ ដែលបម្រើនយោបាយ និង អំពើនិទ្ទណ្ឌភាព ដែលញាំញីលើគ្រប់ទិដ្ឋភាពទាំងអស់នៃអភិបាលកិច្ច ធ្វើឱ្យប៉ះពាល់ដល់ការប្រឹងប្រែងបង្កើតនីតិរដ្ឋ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយដល់ធ្ងន់។ ហេតុផលមួយផ្នែកនៃបញ្ហានេះ គឺដោយសារកិច្ចប្រឹងប្រែងកសាងស្ថាប័ន ដែលពួកគេបានទាមទារ និងគាំទ្រឱ្យមានអស់រយៈពេល ២៥ឆ្នាំ តាំងពីសម័យ អ៊ុនតាក់ (UNTAC) មក បានបរាជ័យយ៉ាងធំធេង ដោយបន្សល់ទុកនូវស្លាកស្នាមដ៏អាក្រក់ នៅក្នុងរយៈពេលក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។*

*វប្បធម៌និទ្ទណ្ឌភាព ឬ ទម្លាប់ឱ្យជនល្មើសច្បាប់រួចទោសនេះ ចាំបាច់ត្រូវមានដំណោះស្រាយឱ្យបានមោះ*

មុត មិនមែនទុកបណ្ដោយឱ្យកើតមានដោយមិនអើពើ ឬមើលស្រាល ដូចដែលរដ្ឋាភិបាលបរទេស និងម្ចាស់ជំនួយ បានធ្វើក្នុងរយៈពេល ២៥ឆ្នាំកន្លងទៅនេះទេ។ រដ្ឋាភិបាលនានា និងប្រទេសម្ចាស់ជំនួយទាំង ឡាយ គួរតែបញ្ឈប់វប្បធម៌និយាយបែបទូទៅ (មិនច្បាស់លាស់) និងបញ្ចប់វប្បធម៌គេចវេះ មិនហ៊ានប្រឈមមុខជាមួយមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ជាមួយមន្ត្រីគណបក្សប្រជាជនកម្ពុជា និងជាមួយមន្ត្រីកងកម្លាំងសន្តិសុខ។

មានឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលកត់ត្រាទុកអំពីបុគ្គលកាន់តួនាទីជាមន្ត្រីមានឋានន្តរសក្តិខ្ពង់ខ្ពស់នៅកម្ពុជា។ ទាល់តែរដ្ឋាភិបាលនៃប្រទេសនានា អង្គទូត និងម្ចាស់ជំនួយនានា មានការយល់ដឹងបានគ្រប់គ្រាន់អំពីកំណត់ត្រានៃមេដឹកនាំកម្ពុជា ដែលពួកគេធ្វើការជាមួយនោះ ព្រមទាំងស្ថានភាពជុំវិញការងាររបស់ពួកគេ ទើបពួកគេអាចចាប់ផ្ដើមដាក់សម្ពាធលើរដ្ឋាភិបាលកម្ពុជា ឱ្យយកចិត្តទុកដាក់ដោះស្រាយបញ្ហានិទណ្ឌភាពនេះបាន។ ប្រសិនបើ មិនមានការចងចាំទេ យុត្តិធម៌ក៏មិនមានដែរ។

ចំណុចល្អដែលត្រូវចាប់ផ្ដើម គឺត្រូវពិនិត្យមើលកំណត់ត្រាអំពីបុគ្គលម្នាក់ៗ ដែលមានឈ្មោះនៅក្នុងរបាយការណ៍នេះ និង មន្ត្រីដែលមានឈ្មោះអសោចដទៃទៀត។ បុគ្គលដែលប្រឈមនឹងការចោទប្រកាន់មានលក្ខណៈសមហេតុសមផល ត្រូវតែត្រូវបានស៊ើបអង្កេត ហើយក្នុងពេលណាមួយសមរម្យ ពួកគេត្រូវតែទទួលបានការផ្ដន្ទាទោស ការដកចេញពីតំណែង ហើយដាក់ជំនួសមកវិញនូវអ្នកទាំងឡាយណា ដែលមានវិជ្ជាជីវៈ មិនពាក់ព័ន្ធនឹងនយោបាយ មានភាពស្មោះស្ម័គ្រចំពោះរដ្ឋ និង សាធារណជន – គឺមិនមែនស្មោះស្ម័គ្រនឹងលោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជានោះឡើយ។

ជំហានទាំងនេះគួរតែជាផ្នែកមួយនៃកិច្ចប្រឹងប្រែងធ្វើកំណែទម្រង់វិស័យសន្តិសុខទាំងមូល ពីព្រោះវាមានសារសំខាន់បំផុត ក្នុងការបញ្ចប់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលមានលក្ខណៈជាប្រព័ន្ធ និងការបង្កើតបានស្ថាប័នប្រជាធិបតេយ្យពិតប្រាកដ។ បើគ្មានកំណែទម្រង់បែបនេះទេ អនាគតកម្ពុជានឹងងងឹតអាប់អួរ។

ថ្វីបើការទទួលខុសត្រូវជាចម្បងសម្រាប់ការកែទម្រង់ទាំងនេះស្ថិតនៅលើរដ្ឋសភា និងរដ្ឋាភិបាលកម្ពុជាក្ដី ក៏សហគមន៍ម្ចាស់ជំនួយនៅតែមានឥទ្ធិពលដ៏សំខាន់ក្នុងការទាមទារឱ្យមានកំណែទម្រង់នេះ និងក្នុងការទាមទារឱ្យមានការគោរពសិទ្ធិមនុស្ស និងក្នុងការប្រែក្លាយគោលការណ៍សិទ្ធិមនុស្ស ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងក្នុងគោលការណ៍អង្គការសហប្រជា

ជាតិ ឱ្យទៅជាច្បាប់ជាតិ ដើម្បីប្រើប្រាស់ក្នុងការគ្រប់គ្រងរដ្ឋ នៅក្នុងប្រទេសកម្ពុជា។

**រដ្ឋាភិបាលពាក់ព័ន្ធ ម្ចាស់ជំនួយកម្ពុជា អង្គការសហប្រជាជាតិ និងតួអង្គមានឥទ្ធិពលផ្សេងទៀត គួរតែ ៖**

- គាំទ្រដល់ការស៊ើបអង្កេតឯករាជ្យលើបុគ្គលដែលមានឈ្មោះនៅក្នុងរបាយការណ៍នេះ ដើម្បីឱ្យមានលទ្ធភាពជំនុំជម្រះក្រោមច្បាប់ជាតិ និងក្រោមយុត្តាធិការ (អំណាចកាត់ក្ដី) នានា។ យុត្តាធិការទាំងឡាយណា ដែលអនុញ្ញាតឱ្យមានការផ្តន្ទាទោស ចំពោះបទរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឬអំពើទារុណកម្ម ដែលស្ថិតក្រោមច្បាប់ "យុត្តាធិការសកល" គួរតែពិចារណាអំពីឱ្យមានការស៊ើបអង្កេត ហើយក្នុងករណីសមស្រប បើការជំនុំជម្រះ។

- ដាក់ទណ្ឌកម្មផ្តោតលើបុគ្គលដែលរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ រួមទាំងមន្ត្រីទាំងឡាយ ដែលជាប្រធានបទនៅក្នុងរបាយការណ៍នេះផងដែរ ដូចជាការហាមប្រាមលើការធ្វើដំណើរ ឬ ការបង្កកទ្រព្យសម្បត្តិ (ឧទាហរណ៍៖ តាមរយៈច្បាប់ ក្លូបល ម៉េកនីតស្គី (Global Magnitsky Act) របស់សហរដ្ឋអាមេរិក ឬ ច្បាប់ដទៃទៀត ដែលស្រដៀងគ្នានេះ)។

- បន្តគាំទ្រពេញទំហឹងដល់ការងាររបស់អង្គការសិទ្ធិមនុស្ស និងអ្នកការពារសិទ្ធិមនុស្ស នៅកម្ពុជា។

- បន្តគាំទ្រពេញទំហឹងដល់ការងាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា (UN-OHCHR) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្ស នៅកម្ពុជា នីតិវិធីពិសេសនានារបស់អង្គការសហប្រជាជាតិ និងស្ថាប័នសន្ធិសញ្ញានានារបស់អង្គការសហប្រជាជាតិ។

- ដាក់សម្ពាធលើរដ្ឋាភិបាលកម្ពុជាឱ្យសហការឱ្យបានពេញលេញ និងអនុញ្ញាតមានការប្រើប្រាស់យន្តការអង្គការសហប្រជាជាតិគ្រប់បែបយ៉ាង ដោយមិនមានការរារាំង។ គាំទ្រដល់ក្រុមការងារអង្គការសហប្រជាជាតិប្រចាំប្រទេស ដើម្បីឱ្យពួកគេអាចបំពេញការងារបានសកម្ម ទៅតាមការទទួល

*ខុសត្រូវរបស់ពួកគេ ស្របតាមអាណត្តិ «**សិទ្ធិមនុស្សជាចម្បង** **(Human Rights Up Front)**» របស់អង្គការសហប្រជាជាតិ ដែលមានបំណងពង្រឹងសកម្មភាពរបស់អង្គការសហប្រជាជាតិក្នុងការងារលើកស្ទួយ និងការពារសិទ្ធិមនុស្ស ព្រមទាំងឆ្លើយតបចំពោះការរំលោភសិទ្ធិមនុស្ស ដែលរួមទាំងតាមរយៈការរិះគន់លើគោលនយោបាយ និងការអនុវត្តទាំងឡាយណាដែលមិនស្របច្បាប់ និងការផ្តល់អនុសាសន៍រឹងមាំ ដើម្បីដោះស្រាយបញ្ហាទាំងនោះ។*

- *គាំទ្រដល់ក្រុមសង្គមស៊ីវិល ដែលជួយជនរងគ្រោះពីការរំលោភបំពានដោយកងកម្លាំងសន្តិសុខ។*

**_ចំពោះការចូលរួមប្រឡូកប៉ូកប៉ាក់ក្នុងឆាកនយោបាយរបស់កងកម្លាំងសន្តិសុខកម្ពុជាវិញ រដ្ឋាភិបាលពាក់ព័ន្ធនានា ម្ចាស់ជំនួយរបស់កម្ពុជា អង្គការសហប្រជាជាតិ និងតួអង្គ ដែលមានឥទ្ធិពលដទៃទៀត គួរតែ៖_**

- *ទាមទារឱ្យមានការបង្កើតកងយោធា អាវុធហត្ថ និងនគរបាល ដែលមានវិជ្ជាជីវៈ អព្យាក្រឹត្យមិនជាប់ជំពាក់នឹងនយោបាយ ដែលឯករាជ្យពីការត្រួតត្រារបស់គណបក្សកាន់អំណាច និងមានថ្នាក់ដឹកនាំ ដែលត្រូវបានតែងតាំងដោយគណៈកម្មការឯករាជ្យមួយ ដែលមានអំណាចធ្វើសវនកម្មលើកងកម្លាំងនីមួយៗ ស៊ើបអង្កេតបណ្តឹង និងមានអំណាចបណ្តេញមន្ត្រីទាំងឡាយណា ដែលរំលោភបំពានក្រមប្រតិបត្តិវិជ្ជាជីវៈ។*

- *ដាក់សម្ពាធឱ្យមានការហាមប្រាមដល់មន្ត្រីជាន់ខ្ពស់ក្នុងយោធា កងរាជអាវុធហត្ថ និង នគរបាល មិនឱ្យកាន់តួនាទីដឹកនាំផ្លូវការ ឬក្រៅផ្លូវការណាមួយ នៅក្នុងគណបក្សនយោបាយ។*

- *ទទូចឱ្យមានការអនុវត្តមាត្រា ៩ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរៈភូមិន្ទ (ឆ្នាំ១៩៩៧) ដែលចែងថា "យោធិនត្រូវមានអព្យាក្រឹតភាពក្នុងមុខនាទី ក្នុងសកម្មភាពការងារ និងហាមឃាត់ការប្រើមុខងារ និងសម្ភារៈរបស់រដ្ឋ ដើម្បីសកម្មភាពនយោបាយណាមួយ។"*

- *គាំទ្រការបង្កើតគណៈកម្មការឯករាជ្យ ដើម្បីឃ្លាំមើលកំណត់ត្រាសិទ្ធិមនុស្ស និង ការបំពេញមុខងាររបស់យោធា កងរាជអាវុធហត្ថ និងនគរបាល តាមវិជ្ជាជីវៈ និងអព្យាក្រឹត្យក្នុងរឿងនយោបាយ ព្រម*

ទាំងអនុវត្តដំណើរការវាយតម្លៃគុណវុឌ្ឍន៍របស់មន្ត្រីជាន់ខ្ពស់ផ្នែកកម្លាំងសន្តិសុខទាំងឡាយ និងជនដទៃទៀតដែលមានអំណាចចេញបទបញ្ជា ដើម្បីបញ្ជាក់ឱ្យប្រាកដថាតើ បុគ្គលណាបានរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរៗ សមាសភាពគណៈកម្មការឯករាជ្យនេះ គួរតែ៖

- មានសមាជិកជាបុគ្គលដែលមានគេគោរពច្រើន ចេញពីចំណោមអតីតសមាជិកនៃអង្គភាពអនុវត្តច្បាប់ ជាចៅក្រមចូលនិវត្តន៍ និងជាសមាជិកនៃសហគមន៍សិទ្ធិមនុស្សកម្ពុជា គាំទ្រដោយអង្គការសហប្រជាជាតិ និងដែលមិនមានឥទ្ធិពលពីគណបក្សនយោបាយណាមួយ រួមទាំងត្រូវឯករាជ ដាច់ស្រឡះពីស្ថាប័នបញ្ជាកងកម្លាំងសន្តិសុខ និងស្ថាប័នរដ្ឋទាំងអស់។

- មានសិទ្ធិពេញលេញ ក្នុងការទទួលបានឯកសារផ្លូវការពាក់ព័ន្ធទាំងអស់ មានអំណាចចេញដីកាកោះ និងបង្គាប់ឱ្យសាក្សីចូលមកបង្ហាញខ្លួន និងផ្តល់សក្ខីកម្ម មានមធ្យោបាយប្រកបដោយប្រសិទ្ធភាពក្នុងការផ្តល់ការការពារដល់សាក្សីតាមការចាំបាច់ និងមានអំណាច ព្រមទាំងឆន្ទានុសិទ្ធិពេញលេញ ក្នុងការចេញសេចក្តីថ្លែងការណ៍ជាសាធារណៈក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់ខ្លួន ហើយ
- មានអំណាចព្យួរការងាររបស់បុគ្គលទាំងឡាយណា ដែលឋិតនៅក្រោមការស៊ើបអង្កេតពីការកិច្ច ដែលកំពុងមាន និងមានអំណាចក្នុងការផ្តល់អនុសាសន៍ដល់ប្រព័ន្ធតុលាការ ដើម្បីឱ្យមានការស៊ើបអង្កេត និងការជំនុំជម្រះក្តីសមស្រប។

- កំណត់ឱ្យច្បាស់ថា ទំនាក់ទំនងអនាគតជាមួយយោធា កងរាជអាវុធហត្ថ និងនគរបាល រាប់ទាំងការចូលរួមក្នុងលំហាត់សមយុទ្ធយោធារួមគ្នាផង ព្រមទាំងការផ្តល់ការហ្វឹកហ្វឺន និងជំនួយគាំទ្រផ្សេងៗផង នឹងត្រូវសម្រេចដោយផ្អែកលើការរកឃើញរបស់គណៈកម្មការឃ្លាំមើល ហើយក្នុងករណីដែលរកឃើញថា មិនមានការកែទម្រង់វិស័យសន្តិសុខប្រកបដោយអត្ថន័យទេនោះ ជំនួយដល់វិស័យសន្តិសុខទៅកម្ពុជានឹងត្រូវព្យួរ។

- បង្ហាញការគាំទ្រជាសាធារណៈ និងផ្តល់ជំនួយដល់ដំណើរការកែទម្រង់វិស័យសន្តិសុខណាមួយដែលធ្វើឡើងដោយម៉ត់ចត់ និងពេញលេញ ដែលអនុវត្តតាមគោលការណ៍ និងគោលបំណង តាម

*ការដាក់ចេញនៅក្នុងរបាយការណ៍របស់មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ ២០០៨ និងឆ្នាំ ២០១៣ និងសេចក្តីសម្រេច លេខ ២១៥១ (ឆ្នាំ ២០១៤) របស់ក្រុមប្រឹក្សាសន្តិសុខ។ ដំណើរការណាមួយដែលមានលក្ខណៈបែបនេះ ត្រូវដាក់បញ្ចូលយន្តការឃ្លាំមើល និងវាយតម្លៃ ដែលក្នុងនោះមានសូចនករណ៍* (Indicators) *ស្តង់ដារគោល* (Benchmarks) *គោលដៅ* (Targets) *និងគោលបំណង* (Objectives) *ដើម្បីវាយតម្លៃឱ្យបានច្បាស់អំពីប្រសិទ្ធភាព* (Impact) *នៃកំណែទម្រង់ផ្នែកសន្តិសុខ ហើយត្រូវផ្សព្វផ្សាយជាសាធារណៈ អំពីអនុសាសន៍របស់អង្គការសហប្រជាជាតិ ស្តីពីកំណែទម្រង់វិស័យសន្តិសុខ តាមរយៈសន្និសីទនានា នៅក្នុងប្រទេសកម្ពុជា ឬនៅកន្លែងផ្សេងទៀត។*

- *ត្រូវបញ្ជាក់ឱ្យច្បាស់ទៅកាន់រដ្ឋាភិបាលកម្ពុជាថា ការបន្តបរាជ័យក្នុងការធ្វើឱ្យកងកម្លាំងសន្តិសុខមានវិជ្ជាជីវៈ និង ឯករាជ្យពីការត្រួតត្រារបស់គណបក្សកាន់អំណាច នឹងនាំមកនូវការកាត់បន្ថយជំនួយដល់រដ្ឋាភិបាល ហើយថា រដ្ឋនានាទាំងនោះនឹងប្រើសំឡេង និង អំណាចនៃសំឡេងឆ្នោតរបស់ពួកគេនៅតាមស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា ធនាគារពិភពលោក* (World Bank) *ជាដើម ដើម្បីឱ្យស្ថាប័នទាំងនោះ ដាក់បញ្ចូលលក្ខខណ្ឌនានាទៅក្នុងជំនួយ ឬ ក្នុងកម្ចីដល់រដ្ឋាភិបាលកម្ពុជា ដោយតម្រូវឱ្យមានការរីកចម្រើនពិតប្រាកដក្នុងការដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្សទាំងឡាយនៅកម្ពុជា ដូចជា ការបង្រ្កាបលើសិទ្ធិមូលដ្ឋាននានា និងគោលការណ៍ប្រជាធិបតេយ្យ ជាដើម។*

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ ត្រូវបានស្រាវជ្រាវ និងសរសេរឡើងដោយ ប្រ៊ែដ អាដាមស៍ (Brad Adams) នាយកប្រតិបត្តិប្រចាំតំបន់អាស៊ីនៃអង្គការសិទ្ធិមនុស្សអន្តរជាតិ ហ្យូមែនរ៉ៃត៍វ៉ច្ (Human Rights Watch)។ ការស្រាវជ្រាវបន្ថែមបានធ្វើឡើងដោយអ្នកស្រាវជ្រាវ ទីប្រឹក្សា សហការី និងអ្នកស្ម័គ្រចិត្តនៃអង្គការសិទ្ធិមនុស្ស ហ្យូមែនរ៉ៃត៍វ៉ច្។ របាយការណ៍នេះត្រូវបានត្រួតពិនិត្យដោយ ជេមស៍ រ៉ស (James Ross) នាយកផ្នែកច្បាប់ និងគោលនយោបាយ និងលោក ចូសេហ្វ សនដឺរស៍ (Joseph Saunders) នាយករងកម្មវិធី។ ចំណែកស៊ីហ្សៀ វ៉ាង (Seashia Vang)សហការីប្រចាំតំបន់អាស៊ី និងហូសេ ម៉ារទីនណេស (Jose Martinez) អ្នកសម្របសម្រួលជាន់ខ្ពស់ និងហ្វិជស្រយ ហិបឃីនស៍ (Fitzroy Hepkins) ជាអ្នកគ្រប់គ្រងផ្នែករដ្ឋបាល បានផ្តល់ជំនួយផ្នែកផលិត៕

*ក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រទេសកម្ពុជាស្ថិតក្នុងដំណើរធ្លាក់ស្រុតចុះមិនអាចទប់បានផ្នែកសិទ្ធិមនុស្ស។ ថ្វីបើមានបទប្បញ្ញត្តិនានាយ៉ាងរឹងមាំស្តីពីសិទ្ធិមនុស្ស ចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ព្រមទាំងជំនួយអភិវឌ្ឍន៍រាប់ពាន់លានដុល្លារ រួមទាំងជំនួយផ្នែកបច្ចេកទេសសម្រាប់លើកកម្ពស់នីតិរដ្ឋ កំណែទម្រង់ប្រព័ន្ធតុលាការ និងសិទ្ធិមនុស្សយ៉ាងណាក្តី ក៏ប្រទេសកម្ពុជាកំពុងតែវិលទៅរកការដឹកនាំរដ្ឋបែបឯកបក្សយ៉ាងឆាប់រហ័ស។*




នគរបាលប្រឆាំងកុបកម្ម និងកងកម្លាំងសន្តិសុខ បង្ក្រាបបាតុករទាមទារសិទ្ធិដីធ្លីមកពីសហគមន៍បូរីកីឡាក្នុងទីក្រុងភ្នំពេញ ក្នុងអំឡុងពេលតវ៉ាប្រឆាំងនឹងរដ្ឋាភិបាល និងក្រុមហ៊ុនសាងសង់មួយ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៤។

*© 2014 Satoshi Takahashi/LightRocket via Getty Images*

***«ឧត្តមសេនីយ៍បាតដៃកខ្វក់ទាំង១២នាក់របស់កម្ពុជា»*** *ផ្តោតលើមន្ត្រីកងកម្លាំងសន្តិសុខជាន់ខ្ពស់ចំនួន១២រូប ដែលជាឆ្អឹងខ្នងនៃរបបនយោបាយផ្តាច់ការ និងរំលោភបំពាន។ អ្នកទាំងនោះរួមគ្នាបង្កើតបានជាកងការពារជាន់ខ្ពស់សម្រាប់លោក ហ៊ុន សែន ដែលតំណែងជាន់ខ្ពស់រកកម្រៃបានច្រើនរបស់ពួកគេ កើតចេញពីទំនាក់ទំនងផ្ទាល់ខ្លួនដែលមានរយៈកាលពីរទសវត្សរ៍ ឬ យូរជាងនេះ និងការហ៊ានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សដោយមិនរារែក។ ជាជាងបម្រើដល់សាធារណជន ពួកគេម្នាក់ៗបែរជានាំគ្នាធានាថា យោធា កងរាជអាវុធហត្ថ និងនគរបាល ប្តេជ្ញាការពារការបន្តកាន់អំណាចរបស់លោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា ទៅវិញ។*

*របាយការណ៍នេះ ចងក្រងតួនាទីរបស់មន្ត្រីទាំងនេះ នៅក្នុងការបង្ក្រាបជាបន្តបន្ទាប់លើអ្នកដែលមាននិន្នាការនយោបាយប្រឆាំងខ្លួន និងអ្នកតវ៉ាអហិង្សា ដែលប្រឆាំងការរឹបអូសយកដីធ្លី និងការរំលោភបំពានកម្លាំងពលកម្ម។ ពួកគេជាច្រើននាក់ ក៏បានជាប់ពាក់ព័ន្ធនឹងអំពើឃាតកម្ម ទារុណកម្ម និងការឃុំខ្លួនមនុស្សតាមទំនើងចិត្ត។ ពួកគេមួយចំនួនក៏បានចូលរួមក្នុងរបបខ្មែរក្រហម ដែលពោរពេញដោយការកាប់សម្លាប់មនុស្ស ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ផងដែរ។*

*របាយការណ៍នេះ អំពាវនាវឱ្យមានការស៊ើបអង្កេតដោយឯករាជ្យ និងចោទប្រកាន់ផ្តន្ទាទោសឱ្យបានសមស្រប ទៅលើមន្ត្រីទាំង១២នាក់នេះ និងបុគ្គលិកសន្តិសុខដែលរំលោភបំពានដទៃទៀត។ មន្ត្រីទាំងនេះ គួរតែត្រូវបានជំនួសដោយមន្ត្រីមានវិជ្ជាជីវៈ មិនពាក់ព័ន្ធនឹងនយោបាយ ដែលមានភក្តីភាពចំពោះរដ្ឋ និងសាធារណជន មិនមែនមានភក្តីភាពចំពោះលោក ហ៊ុន សែន ឬ គណបក្សកាន់អំណាចឡើយ។ ជំហានទាំងនេះ គួរតែជាផ្នែកមួយនៃកំណែទម្រង់វិស័យសន្តិសុខទាំងមូល ដែលមានសារសំខាន់ក្នុងការបញ្ចប់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងជាប្រព័ន្ធ ហើយជំហានទាំងនេះ ក៏ជាគន្លឹះសំខាន់ក្នុងការបង្កើតស្ថាប័នប្រជាធិបតេយ្យពិតប្រាកដទាំងឡាយ នៅក្នុងប្រទេសកម្ពុជា៕*



ឧត្តមសេនីយ៍ គន់ គីម អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ



ឧត្តមសេនីយ៍ ម៉ក់ ជីតូ នាយរងអគ្គស្នងការនគរបាលជាតិ



ឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ



ឧត្តមសេនីយ៍ ប៉ុល សារឿន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ



ឧត្តមសេនីយ៍ សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថ



ឧត្តមសេនីយ៍ សុខ ផល អគ្គនាយកនៃនាយកដ្ឋានអន្តោប្រវេសន៍



ឧត្តមសេនីយ៍ឯក ប៊ុន សេង មេបញ្ជាការរង និងជាមេបញ្ជាការយោធភូមិភាគ ៥



ឧត្តមសេនីយ៍ឯក ចាប ភក្តី មេបញ្ជាការរង និងជាមេបញ្ជាការកងពលតូច ៩១១



ឧត្តមសេនីយ៍ ជា ម៉ុន មេបញ្ជាការរង និងជាមេបញ្ជាការយោធភូមិភាគ ៤



ឧត្តមសេនីយ៍ឯក រ័ត្ន ស្រៀង អគ្គមេបញ្ជាការរងនៃកងរាជអាវុធហត្ថ និងជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ



ឧត្តមសេនីយ៍ ជួន សុវណ្ណ នាយអគ្គស្នងការរងនគរបាលជាតិ



ឧត្តមសេនីយ៍ឯក ជឿន សុវណ្ណថា អគ្គមេបញ្ជាការរង និងជាមេបញ្ជាការយោធភូមិភាគ ២

hrw.org

*Photos © Human rights monitors' collection from social media*